# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
# ព្រះអដ្ឋកថា

## ភាគ៧២

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# អភិធម្មបិដក

និង

## បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## កថាវត្ថុ

## ទុតិយភាគ ~ តតិយភាគ

## ៧២

## បាលីប្រែ ៨៥-៨៦

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៧២

# អភិធម្មបិដក

# កថាវត្ថុ ទុតិយភាគ

*សូមនមស្ការចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## សង្គហិតកថា

[ ៦៨២ ] ពួកធម៌និមួយ សង្គ្រោះដោយពួកធម៌និមួយ មិនមានទេឬ ។ អើ ។ ក្រែងពួកធម៌និមួយ ដល់នូវការរាប់ ដល់នូវឧទ្ទេស រាប់បញ្ចូលដោយពួកធម៌និមួយមានឬ ។ អើ ។ បើពួកធម៌និមួយ ដល់នូវការរាប់ ដល់នូវឧទ្ទេស រាប់បញ្ចូល ដោយពួកធម៌និមួយមានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌និមួយ សង្គ្រោះដោយពួកធម៌និមួយ មិនមានទេ ។

[ ៦៨៣ ] អាយតនៈ គឺភ្នែក ដល់នូវការរាប់ ដោយខន្ធណា ។ ដល់នូវការរាប់ ដោយរូបក្ខន្ធ ។ បើអាយតនៈ គឺភ្នែក ដល់នូវការរាប់ ដោយរូបក្ខន្ធ យ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈ គឺភ្នែក សង្គ្រោះដោយរូបក្ខន្ធ ។ អាយតនៈ គឺត្រចៀក ។បេ។ អាយតនៈ គឺច្រមុះ ។បេ។ អាយតនៈ គឺអណ្តាត ។បេ។ អាយតនៈ គឺកាយ ដល់នូវការរាប់ ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈ គឺកាយ ដល់នូវការរាប់ដោយរូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈ គឺកាយ សង្គ្រោះដោយរូបក្ខន្ធ ។

[ ៦៨៤ ] អាយតនៈ គឺរូប ។បេ។ អាយតនៈ គឺសំឡេង ។បេ។ អាយតនៈ គឺក្លិន ។បេ។ អាយតនៈ គឺរស ។បេ។ អាយតនៈ គឺសម្ផស្ស ដល់នូវការរាប់ ដោយខន្ធណា ។ ដល់នូវការរាប់ ដោយរូបក្ខន្ធ ។ បើអាយតនៈ គឺសម្ផស្ស ដល់នូវការរាប់ ដោយរូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈ គឺសម្ផស្ស សង្គ្រោះដោយរូបក្ខន្ធ ។

[ ៦៨៥ ] សុខវេទនា ដល់នូវការរាប់ ដោយខន្ធណា ។ ដល់នូវការរាប់ដោយវេទនាខន្ធ ។ បើសុខវេទនា ដល់នូវការរាប់ដោយវេទនាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សុខវេទនា សង្គ្រោះដោយវេទនាខន្ធ ។ ទុក្ខវេទនា ។បេ។ អទុក្ខមសុខវេទនា ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយវេទនាខន្ធ ។ បើអទុក្ខមសុខ-វេទនា ដល់នូវការរាប់ដោយវេទនាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អទុក្ខមសុខវេទនា សង្គ្រោះដោយវេទនាខន្ធ ។

[ ៦៨៦ ] សញ្ញាកើតអំពីចក្ខុសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការាប់ដោយសញ្ញាខន្ធ ។ បើសញ្ញាកើតអំពីចក្ខុសម្ផស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញាកើតអំពីចក្ខុសម្ផស្ស សង្គ្រោះដោយសញ្ញាខន្ធ ។ សញ្ញាកើតអំពីសោតសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសញ្ញាខន្ធ ។ បើសញ្ញាកើតអំពីមនោ-សម្ផស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន

ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញាកើតអំពីមនោសម្ផស្ស សង្គ្រោះដោយសញ្ញាខន្ធ ។

[ ៦៨៧ ] ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសង្ខារក្ខន្ធ ។ បើចេតនាកើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយសង្ខារក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកគួរពោលថា ចេតនាកើតអំពីមនោសម្ផស្ស សង្គ្រោះដោយសង្ខារក្ខន្ធ ។

[ ៦៨៨ ] ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ ។ បើមនោវិញ្ញាណដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា មនោវិញ្ញាណ សង្គ្រោះដោយវិញ្ញាណក្ខន្ធ ។ គោបម្រើ ២ សង្គ្រោះដោយខ្សែទាម ឬដោយពួរ បិណ្ឌបាត សង្គ្រោះ ( ដាក់បញ្ចូល ) ក្នុងសម្រែក ឯសម្រែកនោះ សង្គ្រោះដោយឈើពុន យ៉ាងណា ធម៌ទាំងនោះ សង្គ្រោះដោយធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។ បើគោបម្រើ ២ សង្គ្រោះដោយខ្សែទាម ឬដោយពួរ បិណ្ឌបាត សង្គ្រោះ ( ដាក់បញ្ចូល ) ក្នុងសម្រែក ឯសម្រែកនោះ សង្គ្រោះដោយឈើពុន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទីមួយ សង្គ្រោះដោយពួកធម៌ទីមួយ មានដែរ ។

សង្គហិតកថា ចប់

# អដ្ឋកថា

## សង្គហិតកថា

[ ៦៨២ ] ឥឡូវនេះ នឹងពណ៌នាអំពីធម៌ដែលសង្គ្រោះគ្នាបានដូចតទៅ ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា ព្រោះធម៌ពួកខ្លះ ដែលឈ្មោះថា សង្គ្រោះចូលគ្នាបាន ដោយធម៌ពួកខ្លះ ដូចគោបម្រើជាដើម ដែលគេចងដោយខ្សែទាមជាដើម រមែងមិនមាន ព្រោះហេតុនោះ ធម៌ពួកណា ដែលសង្គ្រោះដោយធម៌ពួកខ្លះ មិនមាន កាលបើភាពយ៉ាងនេះមាន ពាក្យថា ការសង្គ្រោះរូបដោយភាពជាមួយគ្នាបាន ក៏មិនមានប្រយោជន៍ ដូច្នេះជាដើម ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ដើម្បីនឹងសម្ដែងភាពដែលធម៌សង្គ្រោះចូលគ្នាបាន ដោយអត្ថដទៃ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ឥឡូវនេះ ការសង្គ្រោះធម៌ ដែលបណ្ឌិតរកបានដោយអត្ថឯណា ដើម្បីសម្ដែងអត្ថនោះ ទើបសកវាទីផ្ដើមពាក្យថា **ននុ អត្ថិ កេចិ ធម្មា** ជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចលោកពោលហើយ ខាងដើមនោះឯង ។

[ ៦៨៨ ] ពាក្យឧបមាថា **យថា ឆាមេន វា** ជាដើមនេះ ដែលបរវាទី នាំមកដើម្បីតាំងលទ្ធិរបស់ខ្លួន បណ្ឌិតគប្បីជ្រាបថា លទ្ធិរបស់បរវាទីនោះ ត្រូវសកវាទីដែលមិនត្រេកអរ មិនជំទាស់ពាក្យឧបមានោះ ទម្លាយហើយ ដោយពាក្យថា បើគោបម្រើសង្គ្រោះដោយខ្សែទាម ឬដោយពួរ ដូច្នេះ ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថថា បើឈ្មោះថា គោបម្រើជាដើម ដែលគេសង្គ្រោះ គឺចងមួយគូ សម្រាប់ទឹមទូវនឹមដោយខ្សែជាដើម តាមលទ្ធិរបស់អ្នក មានសោត ធម៌ទាំងឡាយពួកខ្លះ ដែលអ្នកសង្គ្រោះគ្នាបានដោយធម៌ពួកខ្លះ ក៏មិនមាន ដូច្នេះ ។l។

## អដ្ឋកថាសង្គហិតកថា ចប់

# អភិធម្មបិដក

## សម្បយុត្តកថា

[ ៦៨៩ ] ពួកធម៌នីមួយ ប្រកបដោយពួកធម៌នីមួយ មានឬ ។ អើ ។ ក្រែងពួកធម៌នីមួយ ប្រព្រឹត្តទៅមួយអន្លើ កើតមួយអន្លើ ប្រទល់ព្រម កើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌នីមួយឬ ។ អើ ។ បើពួកធម៌នីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រទល់ព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌នីមួយ មាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌នីមួយ ប្រកបដោយពួកធម៌នីមួយ មិនមានទេ ។

[ ៦៩០ ] វេទនាខន្ធ កើតជាមួយនឹងសញ្ញាខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយនឹងសញ្ញាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយសញ្ញាខន្ធ ( មាន ) ។ វេទនាខន្ធ កើតជាមួយនឹងសង្ខារក្ខន្ធ នឹងវិញ្ញាណក្ខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយនឹងវិញ្ញាណក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយវិញ្ញាណក្ខន្ធ ( មាន ) ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ កើតជាមួយនឹងវេទនាខន្ធ នឹងសញ្ញាខន្ធ នឹងសង្ខារក្ខន្ធឬ ។ អើ ។ បើវិញ្ញាណក្ខន្ធ កើតជាមួយនឹងសង្ខារក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិញ្ញាណក្ខន្ធ

ប្រកបដោយសង្ខារក្ខន្ធ ( មាន ) ។ ប្រេងល្ង ស្ថិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងគ្រាប់ល្ង រសអំពៅ ស្ថិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងដើមអំពៅ យ៉ាងណា ធម៌ទាំងនោះ ស្ថិតនៅស៊ប់ ចូលទៅស៊ប់ ដោយធម៌ទាំងនោះ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## សម្បយុត្តកថា ចប់

# អដ្ឋកថា

## សម្បយុត្តកថា

[ ៦៨៩-៦៩០ ] ឥឡូវនេះ នឹងពណ៌នាអំពីសម្បយុត្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា ព្រោះធម៌ទាំងឡាយ មានវេទនាជាដើម តាមចូលទៅក្នុងសញ្ញាជាដើម ដូចប្រេងដែលជ្រាបក្នុងគ្រាប់ល្ង ក៏មិនមែន ព្រោះហេតុនោះ ទើបធម៌ណាមួយ មិនសម្បយុត្តជាមួយធម៌ណាមួយ កាលបើដូច្នេះ ពាក្យថា សម្បយុត្តដោយញាណជាដើម ក៏មិនមានប្រយោជន៍ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ដើម្បីសម្តែងសម្បយុត្តធម៌ ដោយអត្ថដទៃនោះឯង ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចគ្នា តាមដែលបានពោលហើយខាងដើមនោះឯង ។

ម្យ៉ាងទៀត ឧបមាបញ្ហាណាថា ប្រេងដែលជ្រួតជ្រាបក្នុងគ្រាប់ល្ងជាដើម ដែលបរវាទីនាំមកហើយ ព្រោះឧបមាបញ្ហានោះ មិនមានការកំណត់ភាពផ្សេងគ្នា ដោយលក្ខណៈរបស់គ្រាប់ល្ង និងប្រេង ដូចរបស់

*វេទនា និងសញ្ញា ។ ពិតហើយ ពាក្យថា លូ ក្នុងគ្រាប់របស់លូ ឬសម្បក លូទាំងពួង ត្រឹមតែជាវោហារ បុគ្គលធ្វើឲ្យលូកើតហើយ ក៏កាន់យកដោយ វោហារនោះឯង ។ ឈ្មោះថា លូ រមែងមិនប្រាកដ ដោយសណ្ឋានដើម ព្រោះហេតុនោះ ឧបមាបញ្ហានេះ ក៏ដូចគ្នានឹងមិនបាននាំមកនោះឯង ដូច្នេះ ។ល។*

## អដ្ឋកថាសម្បយុត្តកថា ចប់

# អភិធម្មបិដក

## ចេតសិកកថា

[ ៦៩១ ] ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មិនមានឬ ។ អើ ។ ក្រែងពួកធម៌នីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តមានដែរឬ ។ អើ ។ បើពួកធម៌នីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តមាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេ ។

[ ៦៩២ ] ផស្សៈ កើតជាមួយនឹងចិត្តឬ ។ អើ ។ បើផស្សៈ កើតជាមួយនឹងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ផស្សៈ ជាចេតសិក ។ វេទនា ។បេ។ សញ្ញា ចេតនា ។បេ។ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា រាគៈ ទោសៈ មោហៈ ។បេ។ អនោត្តប្បៈ កើតជាមួយនឹងចិត្តឬ ។ អើ ។ បើអនោត្តប្បៈ កើតជាមួយនឹងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនោត្តប្បៈ ជាចេតសិក ។ ពួកធម៌ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ប្រព្រឹត្តទៅក្នុងផស្សៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងផស្សៈឬ ។ អើ ។ ពួកធម៌ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តកើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ និងវេទនា ។បេ។ និងសញ្ញា

និងចេតនា និងសទ្ធា និងវីរិយៈ និងសតិ និងសមាធិ និងបញ្ញា និងរាគៈ និងទោសៈ និងមោហៈ ។បេ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងអនោត្តប្បៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងអនោត្តប្បៈឬ ។ អើ ។ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

> ចិត្តនេះក្តី ចេតសិកធម៌ទាំងឡាយក្តី របស់បុគ្គលដែលដឹងច្បាស់ ដោយអនត្តលក្ខណៈ កើតប្រាកដ បុគ្គលឃើញដោយប្រពៃ នូវធម៌ដ៏ថោកទាប និងប្រសើរ ក៏ព្រោះដឹងច្បាស់ នូវធម៌ទាំង ២ នេះ ទើបទទួលលោកធម៌ ( ធម៌ដែលបាក់បែក ទ្រុឌទ្រោមទៅ ) ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

[ ៦៩៣ ] ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ ភិក្ខុក្នុងធម្មវិន័យនេះ តែងចង្អុលបង្ហាញចិត្តផង ចង្អុលបង្ហាញធម៌ដែលប្រព្រឹត្តទៅក្នុងចិត្តផង ចង្អុលបង្ហាញធម៌ដែលខ្ទួនត្រិះរិះហើយផង ចង្អុលបង្ហាញធម៌ដែលខ្ទួនពិចារណាហើយផង ដល់ពួកសត្វដទៃ ដល់ពួកបុគ្គលដទៃថា ចិត្តរបស់អ្នក យ៉ាងនេះខ្លះ ចិត្តរបស់អ្នក មានប្រការយ៉ាងនេះខ្លះ ចិត្តរបស់អ្នក ដូច្នេះខ្លះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅចិត្ត មាន ។

**ចេតសិកកថា ចប់**

# អដ្ឋកថា

## ចេតសិកកថា

[ ៦៩១ ] ឥឡូវនេះ នឹងពណ៌នាអំពីចេតសិកដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា ព្រោះឈ្មោះថា ធម៌ទាំងឡាយមានផស្សកៈ ( ធម៌ដែលប្រកបជាមួយផស្សៈ ) ជាដើម មិនមាន ព្រោះហេតុនោះ សូម្បីចេតសិក ក៏មិនគប្បីមាន ចេតសិកធម៌ ក៏មិនមាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ៦៩២ ] បទថា **សហជាតោ** ដែលសកវាទីពោលហើយ សំដៅយកការកើតព្រមគ្នារបស់សម្បយុត្តធម៌ ។ ពាក្យសួរថា **ផស្សិកា** ជាពាក្យរបស់បរវាទី ដែលមិនឃើញនូវវោហារបែបនោះ ។ នឹងមានប្រយោជន៍ណា ដោយវោហារ ឈ្មោះថា **ចេតសិក** ព្រោះអត្ថថា អាស្រ័យចិត្ត មានយ៉ាងណា កាលពោលថា ចេតសិកនោះ ឈ្មោះថា **ផស្សិក** ព្រោះអាស្រ័យផស្សៈ ក៏មិនខុស ក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបសកវាទីឆ្លើយទទួល ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាចេតសិកកថា ចប់**

# អភិធម្មបិដក

## ធាតុកថា

[ ៦៩៤ ] ធម៌ប្រព្រឹត្តទៅក្នុងចិត្តជាទានឬ ។ អើ ។ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អើ ។ ផស្សៈ ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ចេតនា សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញា ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៩៥ ] បុគ្គលមិនគួរនិយាយថា ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ជាទានទេឬ ។ អើ ។ ទានមានផល មិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផល មិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ ចម្រើនដោយទុក្ខ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងទានមានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អើ ។ បើទានមានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ធម៌ប្រព្រឹត្តទៅក្នុងចិត្តចាត់ជាទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទានមានផលជាទីប្រាថ្នា ចុះចីវរ

ជាទានឬ ។ អើ ។ ចីវរមានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទានមានផលជាទីប្រាថ្នា ចុះបិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ចាត់ជាទានឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៩៦ ] បុគ្គលមិនគួរនិយាយថា ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សទ្ធា ហិរិ និងកុសល ហៅថា ទាន ធម៌ទាំងនុ៎ះ ជាទីប្រព្រឹត្តទៅរឿយៗ នៃសប្បុរស ព្រោះថា អ្នកប្រាជ្ញទាំងឡាយ រមែងពោលនូវធម៌នុ៎ះ ថាជាផ្លូវគួរប្រាថ្នា ព្រោះបុគ្គលទៅកាន់ទេវលោក ដោយផ្លូវនុ៎ះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។

[ ៦៩៧ ] បុគ្គល មិនគួរនិយាយថា ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះ ជាមហាទាន ដែលបណ្ឌិតដឹងថា ជាទានប្រសើរ

ដឹងថា មានមកអស់កាលយូរហើយ ដឹងថា ជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល នឹងមិនលះចោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញមិនបោះបង់ចោលឡើយ ។ ទានទាំង ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវក វៀរស្រឡះចាកបាណាតិបាតហើយ ឈ្មោះថា ឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក ដោយសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ១ ជាមហាទាន ដែលបណ្ឌិតដឹងថា ជាទានដ៏ប្រសើរ ដឹងថា មានមកអស់កាលយូរហើយ ដឹងថា ជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល និងមិនលះចោល ដែលសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក លះបង់នូវអទិន្នាទាន ។បេ។ លះបង់នូវការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។បេ។ លះបង់នូវមុសាវាទ ។បេ។ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ជាអ្នកវៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្តី

ប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យហើយ ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្ដីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្ដីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក ដោយការមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ៥ ជាមហាទាន ដែលបណ្ឌិតដឹងថា ជាទានប្រសើរ ដឹងថា មានមកអស់កាលយូរហើយ ដឹងថា ជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល នឹងមិនលះចោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះឯង ជាមហាទាន ដែលបណ្ឌិតដឹងថា ជាទានប្រសើរ ដឹងថា មានមកអស់កាលយូរហើយ ដឹងថា ជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល នឹងមិនលះចោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។

[ ៦៩៨ ] បុគ្គល មិនត្រូវនិយាយថា ទេយ្យធម៌ជាទានទេឬ ។ អើ ។

ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយាន ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសម្នាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទេយ្យធម៌ ចាត់ជាទាន ។

[ ៦៩៩ ] ទេយ្យធម៌ ឈ្មោះថា ជាទានឬ ។ អើ ។ ទេយ្យធម៌ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ( យ៉ាងនេះ ) ចុះចីវរ ជាទានឬ ។ អើ ។ ចីវរមានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ( យ៉ាងនេះ ) ចុះបិណ្ឌបាតជាទាន សេនាសនៈជាទាន គិលានប្បច្ចយភេសជ្ជបរិក្ខារជាទានដែរឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទេយ្យធម៌ជាទានទេ ។

ទានកថា ចប់

# អដ្ឋកថា

## ទានកថា

[ ៦៩៤ ] ឥឡូវនេះ នឹងពណ៌នាអំពីទានដូចតទៅ

ក្នុងរឿងនោះ ឈ្មោះថា ទាន មាន ៣ យ៉ាង គឺចាគចេតនា វិរតិ ទេយ្យធម៌ ។ ចាគចេតនា ឈ្មោះថា ទាន មានទីមកក្នុងពាក្យថា សទ្ធាទាន ហិរិទាន កុសលទាន ដូច្នេះ ។ ទាន ឈ្មោះថា វិរតិ មានទីមកក្នុងពាក្យថា អរិយសាវក ជាអ្នកវៀរចាកបាណាតិបាត ឈ្មោះថា ឲ្យនូវអភ័យ ... ដល់សត្វទាំងឡាយ មានប្រមាណមិនបាន ដូច្នេះ ។ ទេយ្យធម៌ ឈ្មោះថា ទាន មានទីមកក្នុងពាក្យថា បុគ្គលរមែងឲ្យទាន គឺបាយ ទឹកជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងទានទាំងនេះដូចតទៅនេះ ចាគចេតនា ឈ្មោះថា ទាន ព្រោះអត្ថថា រមែងឲ្យវត្ថុដែលគួរឲ្យ ជាហេតុឲ្យវត្ថុដែលគប្បីឲ្យ ។ វិរតិ ឈ្មោះថា ទាន ដោយអត្ថថា ជាការកាត់ ឬដោយអត្ថថា ជាការទម្លាយ ។ ពិតហើយ វិរតិនោះ កាលកើតឡើង រមែងកាត់ ឬទម្លាយចេតនាដែលជាហេតុទ្រុស្តសីល ពោល គឺភ័យ និងសភាពគួរខ្លាចជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា ទាន ។ ទេយ្យធម៌ឯណា ដែលគេរមែងឲ្យ ព្រោះហេតុនោះ ទើបទេយ្យធម៌នោះ ឈ្មោះថា ទាន ។ ទានទាំង ៣ យ៉ាង មានប្រការដូចពោលមកនេះ កាលពោលដោយអត្ថ ក៏មានត្រឹម ២ យ៉ាង គឺចេតសិកធម៌ និងទេយ្យធម៌ ។ ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា ចេតសិកធម៌ប៉ុណ្ណោះ ជាទាន ទេយ្យធម៌

មិនមែនទាន ដូច្នេះ ពាក្យសួររបស់សកវាទីថា **ចេតសិកោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ពាក្យសួររបស់សកវាទីថា **លព្ភា** ដើម្បីចោទសួរបរវាទីនោះដោយអំណាចនៃទេយ្យធម៌ ។ ពាក្យឆ្លើយបដិសេធ ជាពាក្យរបស់បរវាទី ព្រោះបុគ្គលនោះ មិនអាចឲ្យចេតសិកធម៌ ដូចការឲ្យបាយទឹកជាដើមបានឡើយ ។ កាលសកវាទីសួរបញ្ហានោះ ធ្វើឲ្យមាំទាំទៀត បរវាទីនោះឯង ក៏ឆ្លើយទទួលដោយអំណាចនៃព្រះសូត្រថា ព្រះអរិយសាវក វៀរស្រឡះចាកបាណាតិបាតហើយ ឈ្មោះថា ឲ្យអភ័យ ... ដល់សត្វទាំងឡាយ ប្រមាណមិនបានដូច្នេះ ។ តែក្នុងបញ្ហាទាំងឡាយ មានបញ្ហាពោលដោយផស្សៈជាដើម បរវាទីកាលមិនឃើញវោហារថា បុគ្គលនឹងឲ្យផស្សៈបានជាដើម ទើបឆ្លើយបដិសេធ ។

[ ៦៩៥ ] បទថា **អនិដ្ឋផលំ** ជាដើម លោកពោលហើយ ដើម្បីសម្តែងនូវភាពដែលធម៌ មិនមែនចេតសិកជាទាន ។ ពិតហើយ ធម៌ មានបាយជាដើម ដែលមិនមែនចេតសិក រមែងមិនឲ្យវិបាកដែលគួរប្រាថ្នាក្នុងខាងមុខ តែពាក្យនេះ បណ្ឌិតគប្បីជ្រាបថា លោកពោលហើយ ដើម្បីកំណត់ភាពជាផលដែលគួរប្រាថ្នា ។

ក្នុងពាក្យនេះ មានអធិប្បាយថា បើធម៌ មានបាយជាដើម ដែលមិនមែនចេតសិក គប្បីជាទានបានសោត កាលបុគ្គលឲ្យភេសជ្ជៈដែលមិនគួរប្រាថ្នា មិនគួរពេញចិត្ត ដោយចិត្តអនុគ្រោះ ផលដែលមិនគួរប្រាថ្នានោះ

ឯង គប្បីកើតឡើង ដូចឈើស្ដៅជាដើម កើតអំពីពូជនៃស្ដៅ ដូច្នោះ តែក្នុងទីនេះ ព្រោះការឲ្យដោយចាគចេតនា រមែងឲ្យនូវផល ដែលជាប្រយោជន៍ ព្រោះហេតុនោះ ទាន រមែងមានផល គួរជាទីគាប់ចិត្តទាំងអស់ សូម្បីក្នុងទេយ្យធម៌ ដែលមិនគួរប្រាថ្នា ដូច្នេះ ។

កាលបរវាទីតាំងចេតសិកធម៌ ជាទានយ៉ាងនេះហើយ ទើបសកវាទីពោលពាក្យជាដើមថា **ទានំ ឥដ្ឋផលំវុត្តំ ភគវតា** ដូច្នេះជាដើម ដើម្បីញ៉ាំងទេយ្យធម៌ដោយបរិយាយក្រៅអំពីនេះថា ជាទានឲ្យសម្រេច តែបរវាទីកាលមិនឃើញភាពដែលចីវរជាដើម មានវិបាកដែលគួរប្រាថ្នា ទើបបដិសេធ ។ ការអាងព្រះសូត្រ រមែងត្រឹមត្រូវ ទាំងក្នុងវាទៈរបស់បរវាទី និងក្នុងវាទៈរបស់សកវាទី តែរមែងមិនត្រឹមត្រូវដោយអត្ថដូចគ្នា ។

[ ៦៩៩ ] ក្នុងបទថា **ទេយ្យធម្មោ ឥដ្ឋផលោ** នេះ សកវាទីឆ្លើយបដិសេធ ត្រឹមតែការមានផលជាទីប្រាថ្នាប៉ុណ្ណោះ ព្រោះហេតុនោះ ក្នុងបទថា **តេន ហិ ន វត្តព្វំ** ក៏ជាការពោលដែលមិនត្រឹមត្រូវ ព្រោះភាពដែលទានមានផលគួរប្រាថ្នានោះឯង ។ ម្យ៉ាងទៀត ទេយ្យធម៌ ឈ្មោះថា ទាននោះឯង ដោយអត្ថថា ដែលបុគ្គលគប្បីឲ្យ ។ ពិតហើយ រឿងទាននេះលោកពោលដើម្បីដោះនូវការលាយឡំគ្នានៃទានទាំង ២ ប៉ុណ្ណោះឯង ។

**អដ្ឋកថាទានកថា ចប់**

# អភិធម្មបិដក

## បរិភោគមយបុញ្ញកថា

[ ៧០០ ] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ផស្សៈ សម្រេចដោយការបរិភោគ តែងចម្រើន វេទនាតែងចម្រើន សញ្ញាតែងចម្រើន ចេតនាតែងចម្រើន ចិត្តតែងចម្រើន សទ្ធាតែងចម្រើន វិរិយៈតែងចម្រើន សតិតែងចម្រើន សមាធិតែងចម្រើន បញ្ញាតែងចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧០១ ] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ បុណ្យតែងចម្រើន ដូចជាវល្លិ៍ ( ឡើងដើមឈើ ) ចម្រើនដូចជាពួរជ្រៃ ចម្រើនដូចជាដើមឈើ ចម្រើនដូចជាស្មៅ ចម្រើនដូចជាបាច់នៃស្មៅយាប្លង ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧០២ ] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយកឲ្យទាន មិនពិចារណាទេ បុណ្យមានដែរឬ ។ អើ ។ បុណ្យរបស់បុគ្គលកាលមិននឹកនា មិនអើពើ មិនពិចារណា មិនធ្វើទុកក្នុងចិត្ត មិនគិត មិនប្រាថ្នា មិនតម្កល់ចិត្តមាំ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងបុណ្យរបស់បុគ្គល កាលនឹកនា អើពើ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តម្កល់ចិត្តមាំ មានឬ ។ អើ ។ បើបុណ្យរបស់បុគ្គល កាលនឹកនា អើពើ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តម្កល់ចិត្តមាំ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុណ្យ សម្រេចដោយការបរិភោគ តែង

ចម្រើនទេ ។

[ ៧០៣ ] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយកឲ្យទាន ហើយត្រិះរិះនូវកាមវិតក្ក ត្រិះរិះនូវព្យាបាទវិតក្ក ត្រិះរិះនូវវិហឹសាវិតក្ក បុណ្យមានដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំចុះនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំងពីរ មានឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងចំណែក-ស មកកាន់ភាវៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងចំណែក-ស មកកាន់ភាវៈចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងណាស់នេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងណាស់ ទាំង ៤ នោះ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងប្រឹថពីនេះជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយខាងអាយ និងត្រើយខាងនាយនៃសមុទ្ទ នេះជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យរះឡើងអំពីទីណា នឹងអស្តង្គតទៅ ក្នុងទីណា នេះជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៣ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយរបស់ពួកសប្បុរស និងធម៌ទាំងឡាយរបស់ពួកអសប្បុរស នេះជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៤ ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងណាស់

មាន ៤ យ៉ាងនេះឯង ។

ពពក ( ស្ថិតនៅក្នុងទីឆ្ងាយ ) ប្រឹថពី ( ក៏ស្ថិតនៅ ) ក្នុងទីឆ្ងាយពីគ្នា ( អ្នកប្រាជ្ញពោល ) នូវត្រើយសមុទ្រនោះ ថាឆ្ងាយ ព្រះអាទិត្យរះឡើងអំពីទីណា ព្រះអាទិត្យអស្តង្គតទៅក្នុងទីណា អ្នកប្រាជ្ញពោលនូវទីនោះ ថាជាទីឆ្ងាយក្រៃលែងអំពីទីនោះពិត បុគ្គលអ្នកសម្តែងនូវធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស រមែងមាន សមាគមរបស់សប្បុរសទាំងឡាយ ស្ថិតនៅជរាបណា ( បុគ្គលអ្នកសម្តែង ) ក៏រមែងមានជរាបនោះ សមាគមរបស់អសប្បុរសទាំងឡាយរមែងសាបសូន្យទៅឆាប់រហ័ស ព្រោះហេតុនោះ ធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរនិយាយថា ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោសថោកទាប និងឧត្តម មានចំណែកខ្មៅ និងចំណែក-ស មកកាន់ការៈចំពោះមុខទេ ។

[ ៧០៤ ] បុគ្គល មិនគួរនិយាយថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ជនទាំងឡាយណា ជាអ្នកដាំសួនច្បារ អ្នកដាំដើមឈើ អ្នកធ្វើស្ពាន ជនទាំងឡាយណា ឲ្យទាន ដាក់ទានទឹកផង អណ្តូង

ទឹកផង ទីសម្នាក់អាស្រ័យផង បុណ្យ តែងចម្រើន ដល់
ជនទាំងនោះ ទាំងថ្ងៃ ទាំងយប់ សព្វកាល ជនទាំងនោះ ជា
អ្នកតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល តែងទៅកាន់ស្ថាន
សួគ៌ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុណ្យសម្រេច ដោយការបរិភោគ តែងចម្រើន ។

[ ៧០៥ ] បុគ្គលមិនគួរនិយាយថា បុណ្យសម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ៤ យ៉ាងនេះ នាំមកនូវសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអវយវៈដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ អានិសង្សនៃបុណ្យ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិភោគ ( ប្រើប្រាស់ ) ចីវររបស់ទាយកណា ហើយចូលកាន់ចេតោ-សមាធិ មានប្រមាណមិនបាន អានិសង្សនៃបុណ្យ អានិសង្សនៃកុសល នាំមកនូវសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអវយវៈដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ មានប្រមាណមិនបាន រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទាយកនោះ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុបរិភោគបិណ្ឌបាត ។បេ។ បរិភោគសេនាសនៈ ។បេ។ បរិភោគគិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ទាយកណា ហើយចូលកាន់ចេតោសមាធិ មានប្រមាណមិនបាន អានិសង្សនៃបុណ្យ អានិសង្សនៃកុសល នាំមកនូវសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអារម្មណ៍ដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ មានប្រមាណមិនបាន រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទាយកនោះ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ៤ យ៉ាងនេះឯង នាំមកនូវសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអារម្មណ៍ដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុណ្យសម្រេចដោយការបរិភោគ តែងចម្រើន ។

[ ៧០៦ ] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយកឲ្យទាន បដិគ្គាហកទទួលហើយ មិនបរិភោគ លះបង់ចោល បុណ្យរមែងមានឬ ។ អើ ។ បើទាយកឲ្យទាន បដិគ្គាហកទទួលហើយ មិនបរិភោគ លះបង់ចោល បុណ្យរមែងមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុណ្យសម្រេចដោយការបរិភោគ តែងចម្រើនទេ ។

[ ៧០៧ ] បុណ្យសម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។

ទាយកឲ្យទាន កាលបើបដិគ្គាហកទទួលហើយ ពួកស្តេចយកទៅក្តី ពួកចោរលួចយកទៅក្តី ភ្លើងឆេះក្តី ទឹកបន្សាត់ទៅក្តី ពួកទាយាទមិនជាទីស្រឡាញ់យកទៅក្តី បុណ្យរមែងមានឬ ។ អើ ។ បើទាយកឲ្យទាន កាលបើបដិគ្គាហកទទួលហើយ ពួកស្តេចយកទៅក្តី ពួកចោរលួចយកទៅក្តី ភ្លើងឆេះក្តី ទឹកបន្សាត់ទៅក្តី ពួកទាយាទមិនជាទីស្រឡាញ់យកទៅក្តី បុណ្យរមែងមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរនិយាយថា បុណ្យសម្រេចដោយការបរិភោគ តែងចម្រើនទេ ។

**បរិភោគមយបុញ្ញកថា ចប់**

# អដ្ឋកថា

## បរិភោគមយបុញ្ញកថា

[ ៧០០ ] ឥឡូវនេះ នឹងពណ៌នាអំពីបុណ្យសម្រេចអំពីការបរិភោគ ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និកាយសិទ្ធត្ថិកៈ និងនិកាយសមិតិយៈទាំងឡាយថា បុណ្យឈ្មោះថា សម្រេចអំពីការបរិភោគមាន ព្រោះកាន់យកដោយមិនពិចារណានូវព្រះសូត្រទាំងឡាយ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) យ៉ាងនេះថា បុណ្យរមែងចម្រើនមិនដាច់ ទាំងថ្ងៃ ទាំងយប់ គ្រប់វេលា ដូច្នេះជាដើម និងព្រះសូត្រ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលប្រើប្រាស់ចីវររបស់ទាយកណា ដូច្នេះ ពាក្យសួររបស់សកវាទីថា **បរិភោគមយំ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ផ្ដើមពាក្យថា **បរិភោគមយោ ផស្សោ** ជាដើម ដើម្បីនឹងចោទសួរបរវាទីនោះថា កុសលធម៌ទាំងឡាយមានផស្សៈជាដើម ឈ្មោះថា បុណ្យ ក្រៅអំពីនេះ មិនមែនជាបុណ្យ ព្រោះហេតុនោះ អ្នកគប្បីញុំាងកុសលធម៌ទាំងឡាយ មានផស្សៈជាដើម ឲ្យចម្រើនបានឬ ដូច្នេះ ។ ពាក្យទាំងអស់ បរវាទីឆ្លើយបដិសេធ ព្រោះមិនមានការចម្រើនឡើងនៃផស្សៈជាដើមនោះ ។

[ ៧០១ ] បទទាំងឡាយ មានបទថា **លតាវិយ** ជាដើម សកវាទី

ពោលដើម្បីចោទសួរថា វល្លិ៍ជាដើម សូម្បីវៀរចាកការបម្រើ ឬការធ្វើឲ្យ ចម្រើន រមែងចម្រើនឯងបាននោះឯង យ៉ាងណា តាមលទ្ធិរបស់អ្នក បុណ្យ ទាំងឡាយ រមែងចម្រើនយ៉ាងនោះឬ តែបរវាទីឆ្លើយបដិសេធថា **ន ហេវំ** ព្រោះបុណ្យនឹងចម្រើនបែបនោះ មិនមាន ។

[ ៧០២ ] ក្នុងបញ្ហាថា **ន សមន្នាហរតិ** បរវាទីឆ្លើយទទួល ដោយ អំណាចនៃលទ្ធិថា បុរិមចេតនារបស់ទាយកនោះ រមែងចម្រើនបាន ដោយ ការបរិភោគរបស់បដិគ្គាហកទាំងឡាយ វត្ថុនោះ រមែងជាបុណ្យយ៉ាងនេះ ។ លំដាប់នោះ បរវាទី ត្រូវសកវាទីសួរដោយពាក្យថា **អនាវជ្ជេន្តស្ស** ក៏ឆ្លើយ បដិសេធ ព្រោះសំដៅយកចាគចេតនារបស់ទាយក ។ ក្នុងបទទាំងនោះ បទ ថា **អនាវជ្ជេន្តស្ស** បានដល់ ដល់ទាយកដែលមិននឹកដល់ មិនផ្លាស់ប្តូរទៅ មកនៅកវជ្ជចិត្ត ដោយការពិចារណាដែលជាបុរេចារិកក្នុងទានចេតនា ។ បទ ថា **អនាភោគស្ស** បានដល់ ដល់បុគ្គលដែលមិននឹកដល់ទានចេតនា ។ បទ ថា **អសមន្នាហរន្តស្ស** បានដល់ ដល់បុគ្គលដែលមិនមានការដាក់ចិត្ត ។ ពិត ហើយ អាវជ្ជនចិត្ត កាលកាត់ស្រែខ្សែភវង្គដាច់ហើយ ក៏កើតក្នុងវិថីរបស់ ខ្លួន ទើបឈ្មោះថា ដាក់ចិត្តក្នុងទានចេតនា ។ សកវាទីរមែងសួរថា បុណ្យ របស់ទាយកដែលមិនមានការដាក់ចិត្ត រមែងមានដោយចិត្តនេះ ដោយកិច្ច យ៉ាងនេះឬ ។ បទថា **អមនសិករោន្តស្ស** បានដល់ ដល់បុគ្គលដែលមិនធ្វើ ទុកចិត្ត ពិតហើយ បុគ្គលឈ្មោះថា ធ្វើទុកចិត្តដែលកំពុងកើតឡើងឲ្យជាប់ តគ្នាដោយអាវជ្ជនចិត្ត អធិប្បាយថា ដល់បុគ្គលមិនធ្វើយ៉ាងនេះ ។ ម្យ៉ាង

ទៀត បទថា **មនសិ** ជាសត្តមីវិភត្តិ ចុះក្នុងទុតិយាវិភត្តិ ។ បទថា **អចេត-យន្តស្ស** បានដល់ ដល់ទាយកដែលមិនឲ្យចេតនាក្នុងទានកើតឡើង ។ បទថា **អបរក្កន្តស្ស** បានដល់ ដល់ទាយកដែលមិនធ្វើធុរៈក្នុងកុសល ពោលគឺសេចក្តីត្រូវការ ។ បទថា **អប្បណិធហន្តស្ស** អធិប្បាយថា ដល់បុគ្គលមិនឲ្យចិត្តតាំងនៅដោយអំណាចនៃទានចេតនា ។ ក្នុងវាទៈថា **ននុ អាវជ្ជន្តស្ស** បទថា **អាភោគស្ស** បានដល់ ដល់បុគ្គលដែលមានការចងចិត្ត ។ម្យ៉ាងទៀត អធិប្បាយថា បុណ្យ រមែងកើតជាប់តគ្នាដល់បុគ្គលនោះអំពីការចងចិត្ត ឬដល់បុគ្គលដែលចងចិត្ត ( ធ្វើនូវអាភោគចិត្ត ) ។

[ ៧០៣ ] ក្នុងបញ្ហាទាំងឡាយ មានបទថា **ទ្វិន្នំ ផស្សានំ** ជាដើម បរវាទីរមែងឆ្លើយបដិសេធ ព្រោះទាយកមិនមានផស្សៈទាំង ២ ជាដើមក្នុងខណៈតែមួយ ។ រមែងឆ្លើយទទួល សំដៅយកផស្សៈជាដើមរបស់បុគ្គល ២ នាក់ គឺរបស់ទាយក និងរបស់អ្នកបរិភោគ ។ ម្យ៉ាងទៀត លទ្ធិនៃបរវាទីនោះថា ការប្រជុំព្រមគ្នានៃបញ្ចវិញ្ញាណមាន ដូច្នេះ ទើបឆ្លើយទទួលដោយអំណាចលទ្ធិនោះ ។ លំដាប់នោះ ទើបសកវាទីសួរបញ្ហា មានពាក្យថា **កុសលា** ជាដើម ជាមួយបរវាទីនោះ ដើម្បីបិទទ្វារនៃការបរិយាយ ហើយក៏ចោទសួរដោយធម៌ដែលជាសត្រូវ ដល់គ្នានិងគ្នាដោយត្រង់ ។ ក្នុងបញ្ហាថា **កុសលា** ជាដើមនេះ បរវាទីឆ្លើយបដិសេធ សំដៅយកការមិនមានការប្រកបនូវគ្នានិងគ្នានៃកុសល និងអកុសល ក្នុងខណៈជាមួយគ្នា តែឆ្លើយទទួល ព្រោះលទ្ធិថា ចិត្តដែលសម្រេចដោយការបរិភោគ ជាចិត្តដែលមិន

ប្រកបជាមួយគ្នា រមែងកើតឡើងបាន ។ ពេលនោះ ទើបសកវាទីតិះដៀល បរវាទីនោះដោយព្រះសូត្រ ។

[ ៧០៤ ] ក្នុងការនាំព្រះសូត្រមកអាងនោះ បរវាទីពោលថា **សទា បុញ្ញំ បវឌ្ឍតិ** សំដៅយកបុណ្យដែលកើតជាប់តគ្នាទៅ ដោយអំណាចនៃការតាមរឭក និងការជួសជុលជាដើមដល់បុគ្គលដែលដាំសួនច្បារជាដើម ។

[ ៧០៥ ] បទថា **អប្បមាណោ តស្ស បុញ្ញាភិសន្ទោ** នេះ បរវាទីពោលព្រោះភាពដែលបច្ច័យ ដែលខ្លួនប្រគេនដល់ភិក្ខុដែលចូលសមាធិដែលប្រមាណមិនបាន និងព្រោះអំណាចនៃការអនុមោទនាថា ភិក្ខុបែបនេះប្រើប្រាស់ចីវរអញ ដូច្នេះ ។ បរវាទីនោះ រមែងកំណត់បុណ្យនោះថាសម្រេចអំពីការបរិភោគ ដូច្នេះ ។ សេចក្ដីពិត ព្រោះក្នុងទេយ្យធម៌ ដែលបដិគ្គាហកទទួលហើយ មិនទាន់បរិភោគក្ដី បុណ្យនោះ រមែងកើតដល់ទាយកនោះឯង ព្រោះហេតុនោះ ទើបវាទៈរបស់សកវាទីរាប់ថា មានកម្លាំងច្រើន ។

[ ៧០៧ ] ក្នុងបញ្ហានោះ បណ្ឌិតគប្បីជ្រាបអត្ថថា កាលទេយ្យធម៌ដែលបដិគ្គាហកទទួលហើយរបស់បទថា **បដិគ្គាហកេន បដិគ្គហិតេ** ដូច្នេះ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាបរិភោគមយបុញ្ញកថា ចប់

# អភិធម្មបិដក

## ឥតោនិន្នកថា

[ ៧០៨ ] ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបានដែរឬ ។ អើ ។ ញាតិទាំងឡាយ ឲ្យចីវរ អំពីមនុស្សលោកនេះ ពួកប្រេត បរិភោគចីវរនោះ ក្នុងបេតវិស័យនោះបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកញាតិឲ្យបិណ្ឌបាត អំពីមនុស្សលោកនេះ ឲ្យសេនាសនៈ អំពីមនុស្សលោកនេះ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ អំពីមនុស្សលោកនេះ ឲ្យវត្ថុគួរទំពាស៊ី អំពីមនុស្សលោកនេះ ឲ្យវត្ថុគួរបរិភោគ អំពីមនុស្សលោកនេះ ឲ្យទឹកគួរផឹក អំពីមនុស្សលោកនេះ ពួកប្រេតបរិភោគទឹកគួរផឹកនោះ ក្នុងបេតវិស័យនោះបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧០៩ ] ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបានឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើនូវបុគ្គលដទៃ សុខទុក្ខដែលបុគ្គលដទៃធ្វើ បុគ្គលដទៃធ្វើ បុគ្គលដទៃទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១០] បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះទេឬ ។ អើ ។ ក្រែងពួកប្រេត អនុមោទនា នូវទានដែលញាតិកាលឲ្យដើម្បីប្រយោជន៍ខ្លួន ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបីតិឲ្យកើតឡើង បាន

ចំពោះនូវសោមនស្សឬ ។ អើ ។ បើពួកប្រេត អនុមោទនានូវទាន ដែលញាតិកាលឲ្យដើម្បីប្រយោជន៍ខ្លួន ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបីតិឲ្យកើតឡើង បានចំពោះនូវសោមនស្ស ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន ។

[ ៧១១ ] បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ទឹកភ្លៀង ដែលមហាមេឃបង្អុរចុះហើយ ក្នុងទីទួល រមែង
ហូរទៅកាន់ទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ
អំពីលោកនេះ ក៏រមែងសម្រេចផល ដល់ប្រេតទាំងឡាយ
ដូច្នោះឯង ផ្លូវទឹកដ៏ពេញ រមែងញុំាងសាគរ គឺសមុទ្ទ ឲ្យ
ពេញត្រៀប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពី
មនុស្សលោកនេះ ក៏រមែងសម្រេចផល ដល់ប្រេតទាំងឡាយ
ដូច្នោះឯង ការភ្ជួរស្រែ ក៏មិនមានក្នុងបេតវិស័យនោះ ការ
រក្សាគោ ក៏មិនមាន ក្នុងបេតវិស័យនោះ ការជួញប្រែជា
ហេតុបាននូវសម្បត្តិ ប្រាកដដូច្នោះ ក៏មិនមាន ការលក់ទិញ
ផ្លាស់ប្តូរដោយប្រាក់ ក៏មិនមាន ពួកប្រេត កាលធ្វើកាល-
កិរិយា ទៅកើតក្នុងបេតវិស័យនោះ រមែងញុំាងអត្តភាពឲ្យ

ប្រព្រឹត្តទៅ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្ស-
លោកនេះបាន ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកប្រេតញ៉ាំង អត្តភាពឲ្យប្រព្រឹត្តទៅក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន ។

[ ៧១២ ] បុគ្គល មិនគួរនិយាយថា ពួកប្រេត ញ៉ាំងអត្តភាពឲ្យ ប្រព្រឹត្តទៅ ក្នុងបេតវិស័យ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្ស-លោកនេះទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មាតា និងបិតា កាលឃើញច្បាស់នូវស្ថាន ៥ យ៉ាងនេះ ទើបប្រាថ្នាបុត្ត ដែលកើតក្នុងត្រកូល ។ ស្ថានទាំង ៥ យ៉ាង តើដូចម្តេច ។ គឺ បុត្តដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងធ្វើកិច្ចរបស់យើង ១ វង្សត្រកូល នឹងស្ថិតនៅអស់កាលយូរ ១ បុត្តនឹងទទួលគ្រប់គ្រងមត៌ក ១ មួយទៀត បុត្តនឹងឧទ្ទិសបញ្ជូនទក្ខិណាទានដល់យើង ដែលធ្វើកាលកិរិយាទៅកើតក្នុងបរលោកនាយ ១ ម្នាលភិក្ខុទាំងឡាយ មាតា និងបិតា កាលឃើញច្បាស់នូវស្ថានទាំង ៥ យ៉ាងនេះឯង ទើបប្រាថ្នាបុត្តដែលកើតក្នុងត្រកូល ។

បណ្ឌិតទាំងឡាយ កាលបើឃើញច្បាស់ នូវស្ថានទាំង ៥
យ៉ាងហើយ ទើបប្រាថ្នាបុត្ត ( ដោយគិតថា ) បុត្តដែល
យើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងធ្វើកិច្ចរបស់

យើង ១ វង្សត្រកូល គប្បីស្ថិតនៅអស់កាលយូរ ១ បុត្ត
នឹងទទួលគ្រប់គ្រងមត៌ក ១ មួយទៀត បុត្តនឹងឧទ្ទិសបញ្ជូន
ទក្ខិណាទានដល់យើង ដែលធ្វើកាលកិរិយាទៅកើតក្នុងបរ-
លោក ១ បណ្ឌិតទាំងឡាយ កាលបើឃើញច្បាស់នូវស្ថាន
ទាំង ៥ យ៉ាងនេះឯង ទើបប្រាថ្នាបុត្ត ព្រោះហេតុនោះ
សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ហើយ អ្នកដឹងនូវឧប-
ការគុណ ដែលធ្វើហើយ ប្រាកដ ការរឭកឃើញនូវឧប-
ការគុណ ដែលមាតាបិតាធ្វើហើយ ក្នុងកាលមុន រមែង
ចិញ្ចឹមមាតាបិតា ធ្វើកិច្ចទាំងឡាយ ដល់មាតា និងបិតាទាំង
នោះ ដែលជាបុព្វការីដោយពិត បុត្តជាអ្នកធ្វើតាមឱវាទ អ្នក
ចិញ្ចឹមមាតាបិតា ដែលចិញ្ចឹមខ្លួន ញុំាងវង្សត្រកូលមិនឲ្យ
វិនាស ជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល អ្នកប្រាជ្ញ
រមែងសរសើរ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកប្រេត
ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យ
ហើយ អំពីមនុស្សលោកនេះ ។

**ឥតោទិន្នកថា ចប់**

# អដ្ឋកថា

## ឥតោទិន្នកថា

[ ៧០៨ ] ឥឡូវនេះ នឹងពណ៌នាអំពីទានដែលបុគ្គលឲ្យហើយ អំពីលោកនេះដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា វត្ថុឯណា មានចីវរទានជាដើម ដែលបុគ្គលឲ្យហើយអំពីលោកនេះ ប្រេតទាំងឡាយ រមែងញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ បានដោយវត្ថុនោះឯង ដូច្នេះ ព្រោះអាស្រ័យព្រះបាលីថា បុគ្គលទាំងឡាយ ធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយសារតែផលទាន ដែលញាតិឲ្យហើយអំពីលោកនេះ ដូច្នេះ ពាក្យសួររបស់សកវាទីថា **ឥតោ ទិន្នេន** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បរវាទី ត្រូវសកវាទីសួរបញ្ហា ដោយការឲ្យចីវរជាដើមទៀត ក៏ឆ្លើយបដិសេធ ។

[ ៧០៩ ] បទថា **អញ្ញោ អញ្ញស្ស ការកោ** លោកអធិប្បាយថា បុគ្គលដទៃជាអ្នកធ្វើកម្មទាំងឡាយ ដើម្បីឲ្យវិបាកកើតឡើង ដល់បុគ្គលដទៃ មិនមែនខ្លួនឯងធ្វើកម្មឲ្យដល់ខ្លួនឡើយ ។ បរវាទីនោះ ត្រូវសួរបញ្ហាយ៉ាងនេះ ក៏ឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ ។

[ ៧១០ ] បទថា **ធានំ ធេន្តំ** អធិប្បាយថា ឃើញហើយ នូវបុគ្គល

ដែលឲ្យនូវទាន ។ ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបអត្ថថា ព្រោះហេតុដែលភោគៈទាំងឡាយ រមែងកើតឡើងដល់ប្រេតទាំងឡាយនោះ ក្នុងទីនោះ ព្រោះការអនុមោទនារបស់ខ្លួន ព្រោះហេតុនោះ លទ្ធិរបស់បរវាទីនោះ សូម្បីតាំងនៅដោយហេតុនេះ ក៏រាប់ថា មិនជាការតាំងនៅបាន ព្រោះថា ប្រេតទាំងឡាយនោះ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយវត្ថុដែលបុគ្គលឲ្យហើយ អំពីលោកនេះ ក៏មិនមែន ។ ក្នុងការនាំព្រះសូត្រដ៏សេសមកអាង ក៏មានន័យនេះឯង ៗ។

## អដ្ឋកថាឥតោធិដ្ឋកថា ចប់

# អភិធម្មបិដក

## បឋវីកម្មវិបាកោតិកថា

[ ៧១៣ ] ប្រឹថពី ជាវិបាក ( ផល ) នៃកម្មឬ ។ អើ ។ ប្រឹថពី គួរដល់ការវេទសុខ គួរដល់ការវេទទុក្ខ គួរដល់ការវេទអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ( នូវសេចក្ដីប្រាថ្នា ) នៃប្រឹថពីនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងប្រឹថពី មិនគួរដល់ការវេទសុខ មិនគួរដល់ការវេទទុក្ខ មិនគួរដល់ការវេទអារម្មណ៍ មិនជាទុក្ខ មិនជាសុខ មិនប្រកបដោយសុខវេទនា មិនប្រកបដោយទុក្ខវេទនា មិនប្រកបដោយអទុក្ខមសុខវេទនា មិនប្រកបដោយផស្សៈ មិនប្រកបដោយវេទនា មិនប្រកបដោយសញ្ញា មិនប្រកបដោយចេតនា មិនប្រកបដោយចិត្ត ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ( នូវសេចក្ដីប្រាថ្នា ) នៃប្រឹថពីនោះ មិនមានទេឬ ។ អើ ។ បើប្រឹថពី មិនគួរដល់ការវេទសុខ មិនគួរដល់ការវេទទុក្ខ ។បេ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹក ។បេ។ ការតាំងទុក ( នូវសេចក្ដីប្រាថ្នា ) នៃប្រឹថពីនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ប្រឹថពីជាវិបាកនៃកម្មទេ ។

[ ៧១៤ ] ផស្សៈ ជាវិបាកនៃកម្ម ផស្សៈ គួរដល់ការវេទនាសុខ គួរដល់ការវេទនាទុក្ខ គួរដល់ការវេទនាអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ដោយទុក្ខវេទនា ។បេ។ ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាសភាវៈប្រកបដោយអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃផស្សៈនោះមានដែរឬ ។ អើ ។ ប្រឹថពី ជាវិបាកនៃកម្ម ប្រឹថពី គួរដល់ការវេទនាសុខ គួរដល់ការវេទនាទុក្ខ គួរដល់ការវេទនាអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខ-វេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃប្រឹថពីនោះមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១៥ ] ប្រឹថពី ជាវិបាកនៃកម្ម ប្រឹថពី មិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃប្រឹថពីនោះ មិនមានទេឬ ។ អើ ។ ផស្សៈជាវិបាកនៃកម្ម ផស្សៈ មិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ ជាសភាវៈមិនមានអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១៦ ] ប្រឹថពី ជាវិបាកនៃកម្មឬ ។ អើ ។ ប្រឹថពី គួរដល់នូវការលើកឡើង និងការដាក់ចុះ គួរដល់ការដាច់បង់ និងការបែកធ្លាយដែរឬ ។ អើ ។ វិបាកនៃកម្ម គួរដល់ការលើកឡើង និងការដាក់ចុះ គួរដល់ការដាច់បង់ និងការបែកធ្លាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១៧ ] ប្រឹថពី បុគ្គលគប្បីបាន ដើម្បីទិញ ដើម្បីលក់ ដើម្បីតម្កល់ទុក ដើម្បីសន្សំទុក ដើម្បីជ្រើសរើសដែរឬ ។ អើ ។ វិបាកនៃកម្ម បុគ្គលគប្បីបាន ដើម្បីទិញ ដើម្បីលក់ ដើម្បីតម្កល់ទុក ដើម្បីសន្សំទុក ដើម្បីជ្រើសរើសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១៨ ] ប្រឹថពី ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អើ ។ វិបាកនៃកម្មជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១៩ ] វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កំណប់ទ្រព្យ គឺបុណ្យ មិនជាសាធារណៈ ដល់ពួកសត្វដទៃ
ទេ ចោរលួចយកមិនបានទេ សត្វនោះ គប្បីធ្វើបុណ្យទាំង
ឡាយ គប្បីប្រព្រឹត្តធម៌នោះ ឲ្យសុចរិតដោយពិត ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃទេ ។

[ ៧២០ ] ប្រឹថពី ជាវិបាកនៃកម្មឬ ។ អើ ។ ប្រឹថពី តាំងនៅមុន

ហើយ ទើបសត្វទាំងឡាយ កើតឡើងជាខាងក្រោយឬ ។ អើ ។ វិបាកកើតឡើងមុន ទើបសត្វទាំងឡាយ ធ្វើកម្មដើម្បីបាននូវវិបាក ក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២១ ] ប្រឹថពី ជាវិបាកនៃកម្មរបស់សត្វទាំងអស់ឬ ។ អើ ។ សត្វទាំងអស់ បរិភោគប្រឹថពីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្វទាំងអស់ បរិភោគប្រឹថពីឬ ។ អើ ។ សត្វពួកខ្លះ បរិភោគប្រឹថពី ហើយរលត់ទៅ មានដែរឬ ។ អើ ។សត្វពួកខ្លះ ញុំាងវិបាកនៃកម្មមិនឲ្យអស់ទៅ ហើយ រលត់ទៅ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២២ ] ប្រឹថពី ជាវិបាកនៃកម្ម របស់សត្វជាចក្កពត្តិឬ ។ អើ ។ ពួកសត្វដទៃ បរិភោគប្រឹថពីឬ ។ អើ ។ ពួកសត្វដទៃ បរិភោគវិបាកនៃកម្មរបស់សត្វជាចក្កពត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វដទៃបរិភោគវិបាកនៃកម្មរបស់សត្វជាចក្កពត្តិឬ ។ អើ ។ ពួកសត្វដទៃ បរិភោគផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា របស់សត្វជាចក្កពត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២៣ ] បុគ្គល មិនគួរនិយាយថា ប្រឹថពី ជាវិបាកនៃកម្មទេឬ ។ អើ ។ ក្រែងកម្មដែលគួរដល់ការប្រព្រឹត្ត ដើម្បីភាវៈនៃខ្លួនជាឥស្សរៈ កម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាអធិបតី មានដែរឬ ។ អើ ។ បើកម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាឥស្សរៈ កម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាអធិបតី រមែងមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ប្រឹថពី ជាវិបាកនៃកម្ម ។

## បឋវីកម្មវិបាកោតិកថា ចប់

# អដ្ឋកថា

## បឋវីកម្មវិបាកោតិកថា

[ ៧១៣ ] ឥឡូវនេះ នឹងពណ៌នាអំពីផែនដី ជាកម្មវិបាកដូចតទៅ ក្នុងរឿងនោះ ព្រោះហេតុដែលពាក្យថា ភាពនៃជនទាំងឡាយដែលជាធំ ឈ្មោះថា ឥស្សរិយៈ ភាពជាអធិបតីនៃជនទាំងឡាយ ឈ្មោះថា អាធិបច្ចៈ កម្មដែលមានការទាក់ទងដោយភាពជាឥស្សរិយៈ និងភាពជាអធិបច្ចៈក្នុងផែនដី មាន ដូច្នេះ លោកពោលក្នុងពាក្យថា កម្មដែលញ៉ាំងសត្វ ឲ្យប្រព្រឹត្តទៅព្រម ដើម្បីភាពជាធំ កម្មដែលញ៉ាំងសត្វឲ្យប្រព្រឹត្តទៅព្រម ដើម្បីភាពជាម្ចាស់ ជាធំ មាន ដូច្នេះ ព្រោះហេតុនោះ ជនពួកណាមានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ផែនដីជាកម្មវិបាក ដូច្នេះ ពាក្យសួររបស់សកវាទីថា **បឋវី** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **សុខវេទនីយា** ជាដើម សកវាទីពោលដោយអំណាចនៃការសម្ដែងសភាពនៃកម្មវិបាក ។ ផស្សៈមាន ផស្សៈដែលប្រកបដោយសុខវេទនាជាដើមមាន ក្នុងវិបាកទាំងឡាយ ដែលលោកសម្ដែងដោយន័យថា ផស្សៈក៏កើតមានជាដើម ផស្សៈនោះផង ធម៌ទាំងឡាយ មានសញ្ញាជាដើមផង សម្បយុត្តជាមួយធម៌ទាំងឡាយ មានសុខ-វេទនាជាដើម ធម៌ទាំងឡាយ មានសុខវេទនាជាដើម ក៏សម្បយុត្តជាមួយធម៌ទាំងឡាយ មានសញ្ញាជាដើម ធម៌ទាំងអស់នេះ ប្រព្រឹត្តទៅដោយអា-រម្មណ៍ អាវជ្ជនចិត្ត ពោល គឺការទទួលអារម្មណ៍ដែលជាបុរេចារិកជាដើម

នៃធម៌ទាំងនោះ និងចេតនាដែលជាកម្មប្បច្ច័យនៃធម៌ទាំងនោះក៏មាន ក្នុងធម៌ទាំងនោះ ធម៌ណា មានវិបាកដែលគួរប្រាថ្នា ការប្រាថ្នាធម៌នោះ មានតណ្ហាជាមូល ប្រព្រឹត្តទូទៅហើយ ដោយអំណាចនៃការតាំងចិត្ត ដូច្នោះ ទើបសកវាទីសួរថា តាមលទ្ធិរបស់អ្នកផែនដីយ៉ាងនេះៗ ឬ ។ បរវាទីឆ្លើយបដិសេធ ។ បដិលោមបុច្ឆាជាដើម មានអត្ថងាយយល់ហើយ ។

[ ៧១៨ ] ក្នុងបញ្ហាថា **កម្មវិបាកោ បរេសំ សាធារណោ** បរវាទីឆ្លើយបដិសេធ សំដៅយកធម៌ទាំងឡាយ មានផស្សៈជាដើម ។ រមែងឆ្លើយទទួល សំដៅយករូបដែលមានកម្មជាសមុដ្ឋាន និងសំដៅយកភាពដែលផែនដីជាដើម ជារបស់ទូទៅ ។

[ ៧១៩ ] ព្រះសូត្រថា **អសាធារណមញ្ញេសំ** ជាព្រះសូត្រដែលសកវាទីនាំមកសម្តែងអំពីលទ្ធិរបស់បរវាទី ។

[ ៧២១ ] ក្នុងបញ្ហាថា **សព្វេ សត្តា បឋវី បរិភុញ្ជន្តិ** បរវាទីឆ្លើយបដិសេធ សំដៅយកសត្វដែលមិនអាស្រ័យផែនដី តែឆ្លើយទទួល សំដៅយកសត្វដែលអាស្រ័យផែនដី ។ ក្នុងបញ្ហាថា **បឋវី អបរិភុញ្ជិត្វា បរិនិព្វាយន្តិ** បរវាទីឆ្លើយទទួល ដោយអំណាចសត្វទាំងឡាយ ដែលបរិនិព្វានក្នុងអរូបភព ។ បទថា **កម្មវិបាកំ អនាបេត្វា** នេះ សកវាទីពោលដោយអំណាចនៃលទ្ធិរបស់បរវាទី ។ ព្រោះលទ្ធិរបស់បរវាទីនោះថា សត្វទាំងឡាយញ៉ាំងកម្មវិបាកឲ្យអស់ទៅហើយ ទើបបរិនិព្វានបាន តែក្នុងលទ្ធិរបស់សកវាទី ការមិនញ៉ាំងវិបាកដែលកើតឡើងហើយ នៃកម្មដែលបានឱកាសឲ្យ

ផលហើយ ឲ្យអស់ទៅមុន ក៏និព្វានបាន រមែងមិនមាន ។ មួយវិញទៀត ពោលដោយលទ្ធិនៃលោកទាំងនោះ បឋវី ឈ្មោះថា ជាវិបាកដែលកើតឡើងហើយ ព្រោះជាសាធារណវិបាក ទើបគួរសួរថា ការមិនឲ្យបឋវីដែលតាំងនៅ ដោយភាពជាវិបាកនោះឲ្យអស់ទៅហើយ បរិនិព្វាន រមែងមិនត្រឹមត្រូវ ។ បរវាទីឆ្លើយបដិសេធ ដោយអំណាចនៃលទ្ធិ ។

[ ៧២២ ] ក្នុងបញ្ហាថា **ចក្ខាវត្តិសត្តស្ស កម្មវិបាកំ** បរវាទីឆ្លើយបដិសេធ សំដៅយកធម៌ មានផស្សៈជាដើម ដែលមិនទូទៅ ។ រមែងឆ្លើយទទួល សំដៅយកធម៌ដែលជាសាធារណៈ ។ ពិតហើយ លោកទាំងនោះ មានលទ្ធិថា ផែនដី សមុទ្ទ ព្រះចន្ទ និងព្រះអាទិត្យជាដើម ជាកម្មវិបាក ដែលទូទៅដល់សត្វទាំងពួង ។

[ ៧២៣ ] ក្នុងបទថា **ឥស្សរិយសំវត្តនិយំ** នេះ សេចក្ដីថា ភាពជាអ្នកមានទ្រព្យច្រើន ឈ្មោះថា ឥស្សរៈ ព្រោះញុំាងជនដ៏សេស ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ភាពជាធំ ដោយអត្ថថា ជនទាំងនោះ គប្បីធ្វើការសរសើរ ទើបឈ្មោះថា ជាអធិបតី ។ ក្នុងបញ្ហានោះ កម្ម ឈ្មោះថា ញុំាងសត្វឲ្យប្រព្រឹត្តទៅព្រម ដើម្បីភាពជាធំ និងភាពជាអធិបតី ដោយអំណាចនៃការបានចំពោះ មិនមែនដោយអំណាចនៃការឲ្យកើត ព្រោះហេតុនោះ ទើបពាក្យថា **បឋវី** នោះ មិនសម្រេចក្នុងភាពជាកម្មវិបាក ដោយប្រការដូច្នេះ ។៚

**អដ្ឋកថាបឋវីកម្មវិបាកោតិកថា ចប់**

# អភិធម្មបិដក

## ជាមរណាវិចាកោតិកថា

[ ៧២៤ ] ជរា និងមរណៈ ជាវិបាកឬ ។ អើ ។ ជរា និងមរណៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃជរា និងមរណៈនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងជរា និងមរណៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។បេ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃជរា និងមរណៈនោះមិនមានទេឬ ។ អើ ។ បើជរា និងមរណៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។បេ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក( នូវសេចក្តីប្រាថ្នា ) នៃជរា និងមរណៈនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ជរា និងមរណៈ ជាវិបាកទេ ។

[ ៧២៥ ] ផស្សៈ ជាវិបាក ផស្សៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។បេ។ ជាសភាវៈប្រកបដោយអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃផស្សៈនោះមានដែរឬ ។ អើ ។ ជរា និងមរណៈ

ជាវិបាក ជរា និងមរណៈ គួរដល់ការវេទនាសុខ គួរដល់ការវេទនាទុក្ខ ។បេ។ ជាធម្មជាតប្រកបដោយអារម្មណ៍ ការទឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) ជរា និងមរណៈនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៦ ] ជរា និងមរណៈជាវិបាក ជរា និងមរណៈ មិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ ជាធម្មជាតមិនមានអារម្មណ៍ ការទឹកនា ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃជរា និងមរណៈនោះ មិនមានទេឬ ។ អើ ។ ផស្សៈជាវិបាក ផស្សៈមិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ ជាសភាវៈមិនមានអារម្មណ៍ ការទឹក ។បេ។ ការតាំងទុក ( នូវសេចក្តីប្រាថ្នា ) នៃផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២៧ ] ជរា និងមរណៈ នៃពួកកុសលធម៌ ជាវិបាកនៃអកុសលឬ ។ អើ ។ ជរា និងមរណៈ នៃពួកកុសលធម៌ ជាវិបាកនៃពួកកុសលធម៌ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២៨ ] ជរា និងមរណៈ នៃពួកកុសលធម៌ មិនគួរនិយាយថា ជាវិបាកនៃពួកកុសលធម៌ទេឬ ។ អើ ។ ជរា និងមរណៈ នៃពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាកនៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២៩ ] ជរា និងមរណៈ នៃពួកកុសលធម៌ ជាវិបាកនៃពួកអកុសល-

ធម៌ឬ ។ អើ ។ជវ៉ា និងមរណៈ នៃពួកអកុសលធម៌ជាវិបាក នៃពួកកុសល-ធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣០ ] ជរា និងមរណៈ នៃពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាកនៃពួកកុសលធម៌ទេឬ ។ អើ ។ ជរា និងមរណៈ នៃពួកកុសលធម៌ មិនគួរនិយាយថា ជាវិបាកនៃពួកអកុសលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣១ ] ជរា និងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ ជាវិបាកនៃពួកអកុសលធម៌ឬ ។ អើ ។ ជរា និងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ ជាវិបាកនៃពួកកុសលធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣២ ] ជរា និងមរណៈនៃពួកកុសលធម៌ និងពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាកនៃពួកកុសលធម៌ទេឬ ។ អើ ។ ជរា និងមរណៈនៃពួកកុសលធម៌ និងពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាកនៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣៣ ] បុគ្គលមិនគួរនិយាយថា ជរា និងមរណៈ ជាវិបាកទេឬ ។ អើ ។ ក្រែងកម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីពណ៌អាក្រក់ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីអាយុខ្លី មានដែរឬ ។ អើ ។ បើកម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីពណ៌អាក្រក់ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីអាយុខ្លី មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ជរា និងមរណៈ ជាវិបាក ។

# អដ្ឋកថា

## ជរាមរណំ វិបាកោតិកថា

[ ៧២៤ ] ឥឡូវនេះ នឹងពណ៌នាអំពីជរា និងមរណៈជាវិបាកដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ក្នុងពាក្យថា កម្មដែលញុំាងសត្វឲ្យប្រព្រឹត្តទៅព្រម ដើម្បីភាពជាបុគ្គលមានពណ៌សម្បុរអាក្រក់ និងឲ្យមានអាយុតិចនោះមានភាពជាអ្នកមានសម្បុរអាក្រក់ ឈ្មោះថា ជរា ភាពជាអ្នកមានអាយុតិច ឈ្មោះថា មរណៈ កម្មដែលញុំាងសត្វឲ្យប្រព្រឹត្តទៅព្រម ដើម្បីភាពជាអ្នកមានពណ៌សម្បុរអាក្រក់ និងឲ្យមានអាយុតិចមាន ព្រោះហេតុនោះ ទើបជរាមរណៈជាវិបាក ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាបដិលោម បទថា **អនារម្មណំ** អធិប្បាយថា ជរាមរណៈនៃរូបធម៌ទាំងឡាយ មិនមានអារម្មណ៍ឡើយ ឯជរាមរណៈនៃអរូបទាំងឡាយ ឈ្មោះថា មិនមានអារម្មណ៍ ព្រោះការមិនមានលក្ខណៈនៃសម្បយោគ ។

[ ៧២៧ ] ក្នុងបញ្ហាថា **អកុសលានំ ធម្មានំ ជរាមរណំ អកុសលានំ ធម្មានំ វិបាកោ** បរវាទីឆ្លើយទទួលតាមលទ្ធិថា ឈ្មោះថា ជរា និងមរណៈ គប្បីជាវិបាកដែលមិនគួរប្រាថ្នា ។ ដោយហេតុនោះឯង រមែងឆ្លើយបដិសេធ នូវភាពដែលជរាមរណៈនៃកុសលធម៌ ជាកុសលវិបាក និងរមែងឆ្លើយទទួលនូវភាពដែលជរា និងមរណៈនៃកុសលធម៌នោះ ជាអកុសលវិបាកនោះឯងខាងមុខ ។

[ ៧៣១ ] ម្យ៉ាងទៀត សកវាទីរមែងបញ្ហាឲ្យតែមួយ ដោយអំណាចនៃពាក្យសួរថា **កុសលាធម្មា អកុសលាធម្មា** តែជវនមរណៈនៃកុសលធម៌ និងអកុសលធម៌នោះ រមែងមិនមានក្នុងខណៈតែមួយ ។ ការសម្ដែងដោយពាក្យដែលបុគ្គលគប្បីពោលថា ជវនមរណៈនៃអព្យាកត ដែលមិនមានវិបាកទាំងឡាយ ជាវិបាក ដូច្នេះ រមែងមិនមាន ព្រោះហេតុនោះ ទើបសកវាទី មិនបានធ្វើពាក្យសួរដោយអំណាចអព្យាកត ។

[ ៧៣៣ ] ក្នុងបទថា **ទុព្វណ្ណសំវត្តនិយំ** អធិប្បាយថា ការមានពណ៌សម្បុរមិនបរិសុទ្ធ ឈ្មោះថា ភាពជាអ្នកមានពណ៌សម្បុរអាក្រក់ ភាពជាអ្នកមិនអាចឲ្យអាយុប្រព្រឹត្តទៅបានយឺនយូរ ឈ្មោះថា ភាពជាអ្នកមានអាយុតិច ។ ក្នុងបញ្ហានោះ អកុសលកម្ម ជាកម្មប្បច្ច័យនៃរូប ដែលមានពណ៌សម្បុរមិនល្អ ដែលមានកម្មជាសមុដ្ឋាន តែវិបាកនៃអកុសលកម្មនោះ រមែងមិនមានដល់រូបនោះ ព្រោះជាសភាវធម៌មិនដូចគ្នា ។ ម្យ៉ាងទៀត វិបាកនៃអកុសលកម្មនោះ រមែងជាបច្ច័យនៃសមុដ្ឋានទាំងឡាយ មានឧតុសមុដ្ឋានជាដើម ដោយអំណាចនៃការឲ្យបានរូបដែលមានពណ៌សម្បុរអាក្រក់នោះ និង

ដោយអំណាចនៃការចូលទៅកាត់នូវអាយុ ។ អកុសលកម្មនោះ ឈ្មោះថា ប្រព្រឹត្តទៅ ដើម្បីភាពជាអ្នកមានពណ៌សម្បុរអាក្រក់ និងជាអ្នកមានអាយុតិចនោះដោយបរិយាយ ដោយប្រការដូច្នេះ ។ អកុសលកម្មនោះ រមែងមិនឲ្យប្រព្រឹត្តទៅដោយអំណាចនៃការឲ្យកើត ដូចឲ្យផស្សៈដែលជាវិបាកជាដើមកើតឡើង ព្រោះហេតុនោះ ទើបជរាមរណៈនោះ មិនសម្រេចក្នុងភាពជាវិបាក ។ ពាក្យដ៏សេស ក្នុងទីនេះ ដូចគ្នានឹងពាក្យដែលខ្ញុំពោលហើយខាងដើមនោះឯង ។ល។

## អដ្ឋកថាជរាមរណំវិចាកោតិកថា ចប់

# អភិធម្មបិដក

## អរិយធម្មវិបាកកថា

[ ៧៣៤ ] វិបាកនៃអរិយធម៌ ( មគ្គ ) មិនមានទេឬ ។ អើ ។ ក្រែង សាមញ្ញ ( មគ្គ ) ជាផលដ៏ប្រសើរ ព្រហ្មញ្ញ ជាផលដ៏ប្រសើរឬ ។ អើ ។ បើសាមញ្ញ ជាផលដ៏ប្រសើរ ព្រហ្មញ្ញ ជាផលដ៏ប្រសើរ ( រមែងមាន ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។

[ ៧៣៥ ] វិបាកនៃអរិយធម៌ មិនមានទេឬ ។បេ។ ក្រែងសោតាបត្តិ-ផលមានឬ ។ អើ ។ បើសោតាបត្តិផល មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។ ក្រែងសកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល មានឬ ។ អើ ។ បើអរហត្តផល មាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ជាវិបាកនៃអរិយធម៌ មិនមានទេ ។

[ ៧៣៦ ] សោតាបត្តិផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃទាន មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃសីល ។បេ។ ផលនៃភាវនាមិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃទាន មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរហត្ត-ផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃសីល ។បេ។ ផលនៃភាវនា

មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣៧ ] ផលនៃទានជាវិបាកឬ ។ អើ ។ សោតាបត្តិផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផលនៃទានជាវិបាកឬ ។ អើ ។ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផលនៃសីល ។បេ។ ផលនៃភាវនា ជាវិបាកឬ ។ អើ ។ សោតាបត្តិផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផលនៃភាវនា ជាវិបាកឬ ។ អើ ។ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣៨ ] កាមាវចរកុសល ប្រកបដោយវិបាកឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបាវចរកុសល ។បេ។ អរូបាវចរកុសល ប្រកបដោយវិបាកឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣៩ ] លោកុត្តរកុសល មិនមានវិបាកទេឬ ។ អើ ។ កាមាវចរកុសល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ លោកុត្តរកុសល មិនមានវិបាកទេឬ ។ អើ ។ រូបាវចរ ។បេ។ អរូបាវចរកុសល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤០ ] កាមាវចរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំ

កពូនឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបាវចរ ។បេ។ អរូបាវចរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤១ ] លោកុត្តរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អើ ។ កាមាវចរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ លោកុត្តរ-កុសល ប្រកបដោយវិបាក មិនដល់ការសន្សំការកពូនឡើងទេឬ ។ អើ ។ រូបាវចរ ។បេ។ អរូបាវចរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## អរិយធម្មវិបាកកថា ចប់

# អដ្ឋកថា

## អរិយធម្មវិបាកកថា

[ ៧៣៥ ] ឥឡូវនេះ នឹងពណ៌នាអំពីវិបាកនៃអរិយធម៌ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា សាមញ្ញផល ត្រឹមតែការលះកិលេសប៉ុណ្ណោះ មិនមែនចិត្ត និងចេតសិកធម៌ឡើយ ដូច្នេះ ពាក្យសួររបស់សកវាទីថា **នត្ថិ អរិយធម្មវិបាកោ** សំដៅដល់ជនទាំងនោះ ។ បណ្តាបទទាំងនោះ បទថា **អរិយធម្មវិបាកោ** បានដល់ ផលរបស់អរិយធម៌ គឺផលរបស់មគ្គ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយលទ្ធិថា អរិយផល ត្រឹមតែជាការអស់ទៅនៃកិលេស ។ បទថា **សាមញ្ញំ** បានដល់ គុណនៃភាពជាសមណៈ ពាក្យនេះ ជាឈ្មោះរបស់អរិយមគ្គ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងភាពជាសមណៈ និងផលនៃភាពជាសមណៈដល់អ្នកទាំងឡាយ ដូច្នេះ សូម្បីក្នុងព្រហ្មញ្ញគុណ ក៏ន័យនេះដូចគ្នា ។

[ ៧៣៦ ] ក្នុងបញ្ហាទាំងឡាយ មានពាក្យថា **សោតាបត្តិផលំ ន វិបាកោ** ជាដើម បរវាទីឆ្លើយទទួលនូវភាពដែលអរិយផលទាំងឡាយមិនជាវិបាក ព្រោះសំដៅយកភាពដែលសោតាបត្តិមគ្គជាដើម មិនមានការសន្សំវដ្តៈ រមែងឆ្លើយបដិសេធនូវភាពដែលផលនៃទានជាដើម មិនជាវិបាក ។ ពិតហើយ លោកហាមអត្ថនៃអាចយគាមីតិកៈ ដោយពាក្យយ៉ាងនេះថា ធម៌

ពួកណា រមែងទៅកាន់ការសន្សំ ពោល គឺវិបាក ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **អាចយគាមី ។**ម្យ៉ាងទៀត ធម៌ទាំងឡាយណា កាលសន្សំ រមែងទៅកាន់ទីដែលមានការសន្សំ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **អាចយគាមី** ធម៌ទាំងឡាយណា កាលមិនមានការសន្សំ វិបាករមែងទៅ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **អបចយគាមី** ព្រោះហេតុនោះ ទើបបរវាទីឆ្លើយទទួលផង បដិសេធផងយ៉ាងនេះ ។

[ ៧៤០ ] ពាក្យសួរថា **កាមាវចរំ កុសលំ សវិបាកំ អាចយគាមី** ជាដើម ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល និងបដិសេធ ជាពាក្យរបស់សកវាទី ។ ពិតហើយ ក្នុងលោកិយកុសលវិបាក ឈ្មោះថា **អាចយគាមី** ព្រោះអត្ថថា សន្សំចុតិ បដិសន្ធិ និងវដ្ដៈប្រព្រឹត្តទៅ ។ លោកុត្តរកុសលនេះ ឈ្មោះថា **អបចយគាមី** ព្រោះអត្ថថា មានប្រក្រតី មិនសន្សំចុតិ បដិសន្ធិ និងវដ្ដៈប្រព្រឹត្តទៅ ។ លោកុត្តរកុសលនេះ ជាធម៌មានវិបាកនោះឯង មិនមែនមិនមានវិបាក ដោយហេតុត្រឹមតែពាក្យថា ជាអបចយគាមី ។ គប្បីជ្រាបពាក្យឆ្លើយទទួល និងពាក្យបដិសេធ របស់សកវាទីក្នុងទីនេះ ព្រោះសំដៅយកសេចក្ដីនេះ ដោយប្រការដូច្នេះ ។

## អដ្ឋកថាអរិយធម្មវិបាកកថា ចប់

# អភិធម្មបិដក

## វិបាកវិបាកធម្មធម្មោតិកកថា

[ ៧៤២ ] វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ វិបាកនៃធម៌ដែលវិបាកជាប្រក្រតីនោះ ជាធម៌មានវិបាកជាប្រក្រតីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាកនៃធម៌ដែលមានវិបាកជាប្រក្រតីនោះ ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្តៈមិនមាន ការរម្ងត់នូវអនុបាទា មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤៣ ] វិបាកជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ ធម៌ គឺវិបាកក្តី ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មានវិបាកជាប្រក្រតីក្តី វិបាកក្តី ទុំះជាធម៌តាំងនៅជាមួយគ្នា ស្មើគ្នា មានចំណែកស្មើ កើតជាមួយនឹងធម៌នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤៤ ] វិបាក ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ វិបាកក្តី ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មានវិបាកជាប្រក្រតីក្តី វិបាកក្តី ជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា ប្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤៥ ] វិបាក ជាធម៌មានវិបាកប្រក្រតីឬ ។ អើ ។ អកុសលនោះឯង ជាវិបាកនៃអកុសលនោះ កុសលនោះឯង ជាវិបាកនៃកុសលនោះឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤៦ ] វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ បុគ្គលសម្លាប់សត្វដោយចិត្តណា រមែងឆេះនៅក្នុងនរកដោយចិត្តនោះឯង ឲ្យទានដោយចិត្តណា រមែងរីករាយក្នុងស្ថានសួគ៌ ដោយចិត្តនោះឯងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤៧ ] បុគ្គលមិនគួរនិយាយថា វិបាក ជាធម៌ដែលមានវិបាក ជាប្រក្រតីទេឬ ។ អើ ។ ក្រែងវិបាកទាំងឡាយ ជាខន្ធ ៤ ដែលមិនមានរូបជាបច្ច័យដល់គ្នានិងគ្នាឬ ។ អើ ។ បើវិបាកទាំងឡាយជាខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដល់គ្នានិងគ្នា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិបាក ជាធម៌មានវិបាកប្រក្រតី ។

**វិបាកវិបាកធម្មធម្មោតិកថា ចប់**

**សត្តមវគ្គ ចប់**

## ឧទ្ទាននៃសត្តមវគ្គនោះ គឺ

និយាយអំពីការសង្គ្រោះ ១ ការប្រកបព្រម ១ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ១ ទានប្រព្រឹត្តទៅក្នុងចិត្ត ១ បុណ្យសម្រេចដោយការបរិភោគតែងចម្រើន ១ ពួកប្រេតញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបិត្តិវិស័យនោះដោយទានដែលញាតិឲ្យហើយ អំពីលោកនេះ ១ ប្រឹថពី ជាវិបាកនៃកម្ម ១ ជរា និងមរណៈជាវិបាក ១ វិបាកនៃអរិយធម៌ មិនមាន ១ វិបាក ជាធម៌មានវិបាកជាប្រក្រតី ១ ។

# អដ្ឋកថា

## វិបាកវិបាកធម្មធម្មោតិកថា

[ ៧៤២ ] ឥឡូវនេះ នឹងពណ៌នាអំពីវិបាកជាវិបាកធម្មធម្មៈដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រោះវិបាកជាបច្ច័យដល់វិបាក ដោយអំណាចនៃបច្ច័យ មានអញ្ញមញ្ញប្បច្ច័យជាដើម ព្រោះហេតុនោះ សូម្បីវិបាក ក៏ជាវិបាកធម្មធម្មៈ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បទថា **តស្ស វិបាកោ** សេចក្តីថា សកវាទី រមែងសួរថា វិបាកណា មានដល់វិបាកដែលជាវិបាកធម្មធម្មៈនោះ វិបាកនោះតាមលទ្ធិរបស់អ្នកក៏ជាវិបាកធម្មធម្មៈឬ បរវាទីឆ្លើយបដិសេធ សំដៅយកភាវៈនៃការឲ្យផលតទៅ ។ ត្រូវសួរលើកទី ២ រមែងឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីលទ្ធិ ។ រមែងឆ្លើយទទួល សំដៅយកការកើតឡើងនៃវិបាកដទៃ ព្រោះវិបាកនោះជាបច្ច័យ ។ កាលបើភាពយ៉ាងនោះមាន វិបាកនៃវិបាកនោះក៏មានវិបាកនៃវិបាកនោះតទៅ ដូចវិបាកនៃកុសល និងអកុសល ព្រោះហេតុនោះ ទើបមិនមានការចូលទៅកាត់ផ្តាច់វដ្តៈឬ បរវាទីត្រូវសួរបញ្ហានេះ ក៏ឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីលទ្ធិ ។

[ ៧៤៣ ] ក្នុងការអេះអាងបទថា **វិបាកោតិ វា** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះការគិតថា បើគប្បីមានភាពដែលវិបាកជាអត្ថតែមួយ ជាមួយគ្នានឹងធម៌ដែលជាហេតុនៃវិបាកសោត កុសល អកុសល និងអព្យាកត ក៏គប្បីមានអត្ថដូចគ្នា ។

[ ៧៤៤ ] ក្នុងបទថា **វិបាកោ ច វិបាកធម្មធម្មោ ច** នេះ មានអធិប្បាយថា កាលបរវាទីកំណត់នូវភាពជាវិបាកធម្មធម្មៈនីមួយៗ ក្នុងវិបាកក្ខន្ធទាំង ៤ ដោយអត្ថថា ជាបច្ច័យក្នុងបច្ច័យទាំងឡាយ មានអញ្ញមញ្ញប្បច្ច័យជាដើម និងកំណត់នូវវិបាក ដោយអត្ថថា កើតឡើងអំពីបច្ច័យ ត្រូវសកវាទីសួរថា វិបាកជាធម៌មានវិបាកជាប្រក្រតីឬ ទើបឆ្លើយទទួលថា អើ ។ គ្រានោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា ព្រោះវិបាកក្នុងនាមក្ខន្ធ ៤ ក្តី ធម៌ដែលជាហេតុនៃវិបាកក្នុងនាមក្ខន្ធ ៤ ក្តី ជាធម៌ដែលអ្នកទទួលហើយ ក្នុងខណៈតែមួយ ព្រោះហេតុនោះ វិបាក និងធម៌ដែលជាហេតុនៃវិបាកទាំងនោះរមែងប្រាកដថា ជាធម៌សហគតៈគ្នាជាដើម ទើបពោលយ៉ាងនេះ ។ បរវាទីឆ្លើយបដិសេធ សំដៅយកធម៌ដែលជាហេតុនៃវិបាក គឺកុសល និងអកុសល ។

[ ៧៤៥ ] បទថា **តញ្ញេវ អកុសលំ** សេចក្តីថា បើវិបាកជាធម៌ ដែលជាហេតុនៃវិបាកតាមលទ្ធិរបស់អ្នកសោត វិបាកណា ជាអកុសលវិបាក វិបាកនោះ ក៏ដល់នូវភាពជាអកុសល ។ ព្រោះហេតុអ្វី ព្រោះវិបាកដូចគ្នាតែមួយ ជាមួយនឹងធម៌ដែលជាហេតុនៃវិបាក ។ ក្នុងបទថា **តញ្ញេវ កុសលំ** ជាដើម ក៏ន័យនេះឯង ។

[ ៧៤៧ ] បទថា **អញ្ញមញ្ញប្បច្ចយា** នេះ បរវាទីពោលហើយដោយអំណាចត្រឹមតែជាបច្ច័យនៃសហជាតធម៌ទាំងឡាយ ព្រោះហេតុនោះទើបបទថា **អញ្ញមញ្ញប្បច្ចយ** នេះ មិនសម្រេចប្រយោជន៍ ។ម្យ៉ាងទៀតជាការពោលដល់ភាពដែលមហាភូតរូបទាំងឡាយ ជាបច្ច័យដល់គ្នានិងគ្នា មិនមែនពោលដល់វិបាកទាំងនោះ និងមិនមែនពោលដល់ធម៌ដែលជាហេតុនៃវិបាកផងដែរ ដោយប្រការដូច្នេះ ។

**អដ្ឋកថាវិបាកោវិបាកធម្មធម្មោតិកថា ចប់**

**វគ្គទី ៧ ចប់**

# អភិធម្មបិដក

## ជគតិកថា

[ ៧៤៨ ] គតិ មាន ៦ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គតិ មាន ៥ គឺនរក ១ កំណើតសត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គតិមាន ៥ គឺនរក ១ កំណើតសត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិមាន ៦ ទេ ។

[ ៧៤៩ ] គតិមាន ៦ ឬ ។ អើ ។ ក្រែងពួកកាលកញ្ជិកាសុរមានវណ្ណៈស្មើគ្នា មានភោគៈ គឺមេថុនស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នា និងពួកប្រេត ទៅកាន់អាវាហៈ និងវិវាហៈជាមួយនឹងពួកប្រេតដែរឬ ។ អើ ។ ប្រសិនបើ ពួកកាលកញ្ជិកាសុរ មានវណ្ណៈស្មើគ្នា មានភោគៈ គឺមេថុនស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នា និងពួកប្រេត ទៅកាន់អាវាហៈ និងវិវាហៈជាមួយនឹងពួកប្រេត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិមាន ៦ ទេ ។

[ ៧៥០ ] គតិ មាន ៦ ឬ ។ អើ ។ ក្រែងពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ មានវណ្ណៈស្មើគ្នា មានភោគៈ គឺបញ្ចកាមគុណស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកទេវតា ទៅកាន់អាវាហៈ និងវិវាហៈ ជាមួយនឹងពួកទេវតាដែរឬ ។ អើ ។ ប្រសិនបើ ពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ មានវណ្ណៈស្មើគ្នា មានភោគៈ គឺបញ្ចកាមគុណស្មើគ្នា មានអាហារស្មើគ្នា មាន

អាយុស្មើគ្នានឹងពួកទេវតា ទៅកាន់អាវាហៈ និងវិវាហៈជាមួយនឹងពួកទេវតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ មាន ៦ ទេ ។

[ ៧៥១ ] គតិ មាន ៦ ឬ ។ អើ ។ ក្រែងពួកបរិស័ទរបស់ព្រះបាទវេបចិត្តិជាទេវតាដើមឬ ។ អើ ។ ប្រសិនបើ ពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ ជាទេវតាដើម ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ មាន ៦ ទេ ។

[ ៧៥២ ] បុគ្គល មិនគួរនិយាយថា គតិ មាន ២ ទេឬ ។ អើ ។ ក្រែងអសុរកាយមានដែរឬ ។ អើ ។ ប្រសិនបើ អសុរកាយ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គតិ មាន ៦ យ៉ាង ។

ឆគតិកថា ចប់

# អដ្ឋកថា

## ឆគតិកថា

[ ៧៤៨ ] ឥឡូវនេះ នឹងពណ៌នាអំពីគតិ ៦ ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយឧត្តរាបថកៈទាំងឡាយថា គតិមាន ៦ រួមទាំងអសុរកាយ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរដោយអំណាចនៃគតិទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់កំណត់ក្នុងរឿងលោមហំសនសូត្រថា

ម្នាលសារីបុត្ត គតិនេះមាន ៥ ប្រការ ដូច្នេះ ទើបពោលថា **ឆន្នុ បញ្ច គតិយោ** ជាដើម ។ បរវាទីឆ្លើយទទួល ព្រោះខ្លាចខុសចំពោះព្រះសូត្រ ។ សួរថា ព្រោះហេតុអ្វី ទើបសកវាទីមិនទទួលគតិ ៦ សូម្បីអសុរកាយ លោកក៏សង្គ្រោះចូលក្នុងអបាយភូមិ ដូចពាក្យនេះថា ព្រះអរិយៈផុតហើយចាកអបាយទាំង ៤ ដូច្នេះ មិនមែនឬ ឆ្លើយថា លោកសង្គ្រោះអសុរកាយ ក្នុងសេចក្ដីនោះក៏ពិត តែមិនបាត់ជាគតិ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានគតិចំណែកមួយដោយឡែក ។ ពិតហើយ ពួកអសុរ ឈ្មោះថា កាលកញ្ជិកា ក្នុងពួកអសុរកាយ លោកសង្គ្រោះចូលក្នុងគតិនៃប្រេត ។ បរិស័ទរបស់ព្រះបាទវេបចិត្តិ ( ស្ដេចអសុរ ) លោកសង្គ្រោះចូលក្នុងទេវគតិ ។ ពាក្យថា **អសុរកាយ** នេះ ឈ្មោះថា ជាគតិមួយដោយឡែក

រមែងមិនមាន ។

[ ៧៤៩ ] ឥឡូវនេះ សកវាទីផ្ដើមពាក្យថា **ឆន្ទ កាលកញ្ជិកា** ជាដើម ដើម្បីសម្ដែងអត្ថតែមួយនោះឯង ។ ក្នុងបទទាំងនោះ បទថា **សមានវណ្ណា** បានដល់ មានរូបសណ្ឋានដូចគ្នា ។ បទថា **ពីភច្ឆា** បានដល់ មានរូបពិការមិនគួរមើល ។ បទថា **សមានភោគា** បានដល់ មានការប្រព្រឹត្តក្នុងមេថុនធម្មដូចគ្នា ។ បទថា **សមានាហារា** បានដល់ មានអាហារ គឺទឹកមាត់ ទឹកសម្បោរ ទឹកខ្ទុះ និងឈាមជាដើមដូចគ្នា ។ បទថា **សមានាយុកា** បានដល់ មានការកំណត់អាយុដូចគ្នា ។ បទថា **អាវាហ-វិវាហំ** បានដល់ ការទទួលកូនក្រមុំ និងការឲ្យកូនក្រមុំ ។

[ ៧៥០ ] ក្នុងសុក្កបក្ខ បទថា **សមានវណ្ណា** បានដល់ មានរូបរាងសណ្ឋានស្អាតដូចគ្នា ដល់ព្រមដោយរស្មី ដែលនាំមកនូវសេចក្ដីជ្រះថ្លា គួរមើល ។ បទថា **សមានភោគា** បានដល់ មានការបរិភោគកាមគុណ ៥ ដូចគ្នា ។ បទថា **សមានាហារា** បានដល់ អាហារ មានសុធាភោជនជាដើមដូចគ្នា ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

[ ៧៥២ ] បទថា **ឆន្ទ អត្ថិ អសុរកាយោ** នេះ ជាការសម្រេចប្រយោជន៍ត្រឹមតែអសុរកាយមានប៉ុណ្ណោះ តែមិនសម្រេចជាគតិ ព្រោះមិនមានការកំណត់គតិនៃអសុរកាយដោយចំណែកមួយ ដូច្នេះ ។៚

**អដ្ឋកថាឆគតិកថា ចប់**

# អភិធម្មបិដក

## អន្តរាភវកថា

[ ៧៥៣ ] អន្តរាភព ( ភពដែលមានក្នុងចន្លោះ ឬក្នុងរវាង ) មានឬ ។ អើ ។ គឺកាមភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព មានឬ ។ អើ ។ គឺរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព មានឬ ។ អើ ។ គឺអរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៥៤ ] អន្តរាភព មានឬ ។ អើ ។ អន្តរាភព មានក្នុងចន្លោះនៃកាមភព និងរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភពមានឬ ។ អើ ។ អន្តរាភព មានក្នុងចន្លោះនៃរូបភព និងអរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៥៥ ] អន្តរាភព មិនមាន ក្នុងចន្លោះនៃកាមភព និងរូបភពទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព មិនមានក្នុងចន្លោះនៃកាមភព និងរូបភពទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភពមានទេ ។ អន្តរាភព មិនមានក្នុងចន្លោះនៃរូបភព និងអរូបភពទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព មិនមានក្នុងចន្លោះនៃរូបភព និងអរូបភពទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភពមានទេ ។

[ ៧៥៦ ] អន្តរាភព មានឬ ។ អើ ។ គឺកំណើតជាគម្រប់ ៥ នោះ គតិជាគម្រប់ ៦ នោះ វិញ្ញាណដ្ឋិតិជាគម្រប់ ៨ នោះ សត្តាវាស ជាគម្រប់ ១០ នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព មានឬ ។ អើ ។

អន្តរាភព គឺភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងអន្តរាភព មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វចូលទៅកើតក្នុងអន្តរាភព មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វតែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអន្តរាភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៥៧ ] កាមភព រមែងមាន ចុះកាមភព ភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព ( មាន ) ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព ( មាន ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងកាមភព មានដែរឬ ។ អើ ។ កម្មនាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វចូលទៅកើតក្នុងកាមភព មានដែរឬ ។ អើ ។ ពួកសត្វចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ

មានក្នុងកាមភពដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអនាគតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមភព គឺបញ្ចវោការភពឬ ។ អើ ។ អនាគត គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៥៨ ] រូបភព រមែងមាន ចុះរូបភព ភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបាទចំពោះនូវអត្តភាព ( មាន ) ដែរឬ ។ អើ ។ អនាគត រមែងមាន ចុះអនាគត ភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបាទចំពោះនូវអត្តភាព ( មាន ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងរូបភព មានដែរឬ ។ អើ ។ កម្មនាំចូលទៅកើតក្នុងអនាគត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងរូបភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអនាគត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងរូបភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអនាគតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងរូបភពដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអនាគតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបភព គឺបញ្ចវោការភពឬ ។ អើ ។ អនាគត គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៥៩ ] អរូបកព រមែងមាន ចុះអរូបកព ភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព ( មាន ) ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព ( មាន ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អើ ។ កម្មនាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអរូបភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអរូបភពដែរឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរូបភព គឺចតុវោការភពឬ ។ អើ ។ អន្តរាភព គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៦០ ] អន្តរាភព មានដែរឬ ។ អើ ។ អន្តរាភពរបស់ពួកសត្វទាំងអស់ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភពរបស់ពួកសត្វទាំងអស់ មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរាភពរបស់ពួកសត្វទាំងអស់ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

[ ៧៦១ ] អន្តរាភគព មានដែរឬ ។ អើ ។ អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភគព មានទេ ។

[ ៧៦២ ] អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ អន្តរាភគព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមែនជាមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភគព របស់បុគ្គលអ្នកចូលទៅកើតក្នុងនរក ( មាន ) ។បេ។ របស់បុគ្គលអ្នកចូលទៅកើតក្នុងអសញ្ញសត្វ ( មាន ) ។បេ។ របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភគព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភគព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភគព មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរាភគព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភគព មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភគព មានទេ ។

[ ៧៦៣ ] អន្តរាភគព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភគព មិនមានទេឬ ។ អើ ។ អន្តរាភគព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភគព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភគព របស់បុគ្គលអ្នកចូល

ទៅកើតក្នុងអរូភព មិនមានទេឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមែនជាមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៦៤ ] បុគ្គលមិនគួរនិយាយថា អន្តរាភព មានទេឬ ។ អើ ។ ក្រែងបុគ្គលជាអន្តរាបរិនិព្វាយី មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលជាអន្តរាបរិនិព្វាយី មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។ អន្តរាភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គលជាអន្តរា-បរិនិព្វាយី មានឬ ។ អើ ។ ឧបហច្ចភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គលជាឧបហច្ចបរិនិព្វាយី មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គលជាអន្តរាបរិនិព្វាយី មានឬ ។ អើ ។ បុគ្គលជាអន្តរាបរិនិព្វាយី ។បេ។ សសង្ខារភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គលជាសសង្ខារបរិនិព្វាយី មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## អន្តរាភវកថា ចប់

# អដ្ឋកថា

## អន្តរាភវកថា

[ ៧៥៣ ] ឥឡូវនេះ នឹងពណ៌នាអំពីអន្តរាភពដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយសមិតិយៈទាំងឡាយថា សត្វដែលមិនមានទិព្វចក្ខុ រមែងជាបុគ្គលហាក់បីដូចមានទិព្វចក្ខុ ដែលមិនមានឫទ្ធិ រមែងជាបុគ្គលហាក់បីដូចមានឫទ្ធិ សម្លឹងមើលនូវការនៅរួមរបស់មាតាបិតា និងកាលមានរដូវ បុគ្គលនោះ តាំងនៅប្រមាណ ៧ ថ្ងៃ ឬលើសជាងនោះ ក្នុងទីណា ទីនោះ ឈ្មោះថា អន្តរាភព ព្រោះកាន់យកបទព្រះសូត្រដោយមិនពិចារណាថា បុគ្គលឈ្មោះថា អន្តរាបរិនិព្វាយី ដូច្នេះ ពាក្យសួររបស់សកវាទីថា **អត្ថិ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ លំដាប់នោះ សកវាទីដើម្បីនឹងចោទសួរបរវាទីនោះ ដោយអំណាចនៃភពទាំង ៣ ដែលព្រះមានព្រះភាគត្រាស់ហើយ ទើបពោលពាក្យថា **កាមភវោ** ជាដើម ។

ក្នុងបញ្ហានោះ មានអធិប្បាយថា បើភពណាមួយ ឈ្មោះថា អន្តរាភព មានតាមលទ្ធិរបស់អ្នកសោត ភពនោះ គប្បីជាភពណាមួយ នៃកាមភពជាដើមនោះឯង ដូចបញ្ចវោការភពជាដើម ព្រោះហេតុនោះ ទើបខ្ញុំសួរអ្នកថា ឈ្មោះថា អន្តរាភព តាមលទ្ធិរបស់អ្នក ជាកាមភព ឬរូបភព ឬជាអរូបភព ។ បរវាទីកាលមិនកាន់យកបែបនោះ ទើបបដិសេធទាំងអស់ ។

[ ៧៥៤-៧៥៥ ] បទថា **កាមភវស្ស ច** ជាដើម សកវាទីពោល ដើម្បីចោទសួរថា បើឈ្មោះថា អន្តរាភពមានសោត អន្តរាភពទាំងនេះ ក៏គប្បីមានដូចជាព្រំដែនរវាងសីមាទាំង ២ ។ បរវាទី កាលមិនកាន់យកបែបនោះ ទើបបដិសេធបញ្ហាទាំងពួងទៅតាមលទ្ធិតែម្យ៉ាង មិនមែនតាមសេចក្តីពិត ។ ដោយពាក្យនោះឯង ទើបសកវាទីពោលបដិសេធនឹងបរវាទីថា **នោ វត រេ** ដូច្នេះ ។

[ ៧៥៦ ] បទថា **បញ្ចមី សា យោនិ** ជាដើម សកវាទីសួរដើម្បីចោទសួរថា អន្តរាភពនោះ មិនសង្គ្រោះក្នុងកំណើតជាដើម តាមដែលព្រះមានព្រះភាគទ្រង់បានកំណត់ហើយ កាលបើដូច្នេះ អន្តរាភពនោះ ក៏គប្បីជាភពដែលលើសអំពីកំណើត អំពីគតិជាដើមនោះៗ ។ បទថា **អន្តរាភវូបគំ កម្មំ** សកវាទីសួរដើម្បីចោទសួរថា បើអន្តរាភពនោះ គប្បីជាភពមួយដោយឡែកសោត កម្មដែលញុំាងសត្វឲ្យចូលដល់អន្តរាភពនោះ ក៏គប្បីមានដូចកម្មជាដើមដែលញុំាងសត្វឲ្យចូលដល់កាមភពជាដើម ដែលព្រះសាស្តាទ្រង់ចែកសម្តែងហើយថា ជាកម្មមាន ។ ម្យ៉ាងទៀត ព្រោះលទ្ធិរបស់ជនទាំងនោះ ក្នុងលទ្ធិរបស់បរវាទីថា កម្មដោយចំពោះ ឈ្មោះថា ញុំាងសត្វឲ្យចូលដល់អន្តរាភពមិនមាន សត្វនឹងចូលដល់ភពណាមួយ រមែងកើតក្នុងអន្តរាភពបាន ដោយកម្មដែលញុំាងសត្វឲ្យចូលដល់ភពនោះឯង ព្រោះហេតុនោះ ទើបបរវាទីឆ្លើយបដិសេធថា **ន ហេវំ** ដូច្នេះ ។ ត្រូវសកវាទីសួរថា **អត្ថិ អន្តរាភវូបគា សត្តា** បរវាទីឆ្លើយបដិសេធតាមលទ្ធិថា សត្វទាំងនោះ

ឈ្មោះថា កើតក្នុងកាមភពនោះឯង ។ សូម្បីត្រូវសួរថា **ជាយន្តិ** ជាដើម បរវាទី កាលមិនកាន់យកនូវការកើត ការចាស់ ការស្លាប់ និងចុតិ បដិសន្ធិ តទៅ ក្នុងអន្តរាភពនោះ ទើបឆ្លើយបដិសេធ ។ សូម្បីត្រូវសួរដោយអំណាចនៃរូបជាដើម រមែងឆ្លើយបដិសេធ ព្រោះលទ្ធិនៃជនទាំងនោះថា រូបរបស់សត្វក្នុងអន្តរាភព ឃើញមិនបាន សូម្បីធម៌ទាំងឡាយ មានវេទនាជាដើម ក៏មិនគ្រោតគ្រាតដូចសត្វពួកដទៃ ដោយហេតុនោះឯង គប្បីជ្រាបការបដិសេធ សូម្បីក្នុងភាពជាបញ្ចវោការភព ។

[ ៧៥៧ ] ឥឡូវនេះ បទថា **កាមភវោ ភវោ គតិ** ជាដើម ឈ្មោះថា ជាការប្រៀបធៀបភព ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា បើភពណាមួយ ឈ្មោះថា អន្តរាភពគប្បីមាន តាមលទ្ធិរបស់អ្នកសោត ភព និងគតិជាដើម បណ្តាភពទាំងឡាយ មានកាមភពជាដើម គប្បីឃើញបានយ៉ាងណា ក្នុងអន្តរាភពនោះ ក៏គប្បីឃើញបានយ៉ាងនោះ ។ ក្នុងអន្តរាភពមិនទាន់ឃើញបានយ៉ាងណា សូម្បីក្នុងកាមភពជាដើមនោះ ក៏ឃើញមិនបានយ៉ាងនោះ ព្រោះថា កាលភាពជាភពមាន ការបែកនៃភពនោះឯង រមែងមាន មិនមែនក្នុងភពក្រៅអំពីនេះ ព្រោះហេតុនោះ តើអ្វីជាហេតុប្លែកគ្នារវាងកាមភពជាដើមនោះ និងអន្តរាភពក្នុងទីនេះ ។ បរវាទីរមែងឆ្លើយទទួល និងឆ្លើយបដិសេធនូវបញ្ហានោះ ដោយអំណាចត្រឹមតែលទ្ធិ ។

[ ៧៦០ ] បរវាទី ត្រូវសកវាទីសួរថា **សព្វេសញ្ញោវ សត្តានំ អត្ថិ អន្តរាភវោ** ព្រោះមិនកាន់យកថា អន្តរាភព មានដល់សត្វ ដែលកើតក្នុង

ក្នុងនរក អសញ្ញីសត្វ និងអរូបព្រហ្ម ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ។ ដោយហេតុនោះឯង រមែងឆ្លើយទទួល ដោយបដិលោម ។

[ ៧៦១ ] បទថា **អានន្តរិយស្ស** ជាដើម សកវាទីពោល ដើម្បីចែកសម្ដែងសត្វទាំងឡាយដែលបរវាទីនោះ មិនកាន់យកថា មានអន្តរាកព ។ ពាក្យទាំងអស់នោះ បណ្ឌិតគប្បីជ្រាបដោយទំនងនៃព្រះបាលី ព្រមទាំងការអានព្រះសូត្រនោះឯង ។៚

**អដ្ឋកថាអន្តរាភវកថា ចប់**

# អភិធម្មបិដក

## កាមគុណកថា

[ ៧៦៥ ] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ ក្រែងឆន្ទៈ ប្រកប ដោយកាមគុណនោះ មានដែរឬ ។ អើ ។ ប្រសិនបើ ឆន្ទៈប្រកបដោយ កាមគុណនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេ ក្រែងរាគៈ ប្រកបដោយកាមគុណនោះ ឆន្ទរាគៈ ប្រកប ដោយកាមគុណនោះ សង្កប្បប្រកបដោយកាមគុណនោះ រាគៈ ប្រកបដោយ កាមគុណនោះ សង្កប្បរាគៈ ប្រកបដោយកាមគុណនោះ បីតិប្រកបដោយ កាមគុណនោះ សោមនស្ស ប្រកបដោយកាមគុណនោះ បីតិសោមនស្ស ប្រកបដោយកាមគុណនោះ មានដែរឬ ។ អើ ។ ប្រសិនបើ បីតិសោមនស្ស ប្រកបដោយកាមគុណនោះមានមែន អ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេ ។

[ ៧៦៦ ] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ ចក្ខុរបស់ពួក មនុស្ស មិនមែនជាកាមធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀករបស់ពួកមនុស្ស ។បេ។ ច្រមុះ របស់ពួកមនុស្ស ។បេ។ អណ្តាត របស់ពួកមនុស្ស ។បេ។ កាយរបស់ពួកមនុស្ស ។បេ។ ចិត្តរបស់ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចិត្តរបស់ ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អើ ។ ក្រែងព្រះមានព្រះ ភាគទ្រង់ ត្រាស់ថា

កាមគុណ ៥ មានចិត្តជាគម្រប់ ៦ តថាគតសំដែងទុកក្នុង
លោក បុគ្គលកម្ចាត់បង់ឆន្ទៈ ក្នុងកាមគុណនុ៎ះ រមែងរួចចាក
ទុក្ខ ដោយហេតុយ៉ាងនេះឯង ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ចិត្តរបស់ពួកមនុស្ស មិនមែនជាកាមធាតុទេ ។

[ ៧៦៧ ] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ កាមគុណ គឺភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមគុណ គឺបញ្ច-វោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើង ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើតឡើង គូនៃសាវក កើតឡើង ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមធាតុ គឺភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការចំពោះនូវអត្តភាពឬ ។ អើ ។ កាមគុណ គឺភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោល

យ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងកាមធាតុមានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងកាមធាតុ មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅ កើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួក សត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមធាតុដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមគុណដែរឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងកាមធាតុឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមធាតុជាបញ្ចវោការភពឬ ។ អើ ។ កាមគុណ គឺបញ្ចវោការភពឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើង ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើត ឡើង គូនៃសាវកកើតឡើងក្នុងកាមធាតុ ដែរឬ ។ អើ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើង ព្រះបច្ចេកសម្ពុទ្ធ ទាំងឡាយ កើតឡើង គូនៃសាវកកើតឡើង ក្នុងកាមគុណដែរឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៦៨ ] បុគ្គលមិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាមគុណ នេះ មាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្ដេច ។ គឺរូបទាំងឡាយ ដែលគប្បីដឹងដោយភ្នែកជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាព

ជាទីស្រឡាញ់ ប្រកបដោយកាមគួរីកករាយ ១ សំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ។បេ។ ក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ ។បេ។ រសទាំងឡាយ ដែលគប្បីដឹងដោយអណ្តាត ។បេ។ ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរីកករាយ ១ ម្នាលភិក្ខុទាំងឡាយ កាមគុណ មាន ៥ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ កាមគុណ ៥ យ៉ាង ជាកាមធាតុ ( ដោយពិត ) ។

កាមគុណកថា ចប់

# អដ្ឋកថា

## កាមគុណកថា

[ ៧៦៥ ] ឥឡូវនេះ នឹងពណ៌នាអំពីកាមគុណដូចតទៅ

ក្នុងរឿងនោះ ក្នុងលទ្ធិរបស់សកវាទី វត្ថុកាមក្តី កិលេសកាមក្តី កាមភពក្តី លោកហៅថា **កាមធាតុ** ។ ពិតហើយ ក្នុងកាមទាំងនោះ វត្ថុកាម ឈ្មោះថា **កាម** ព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នា ឈ្មោះថា **កាមធាតុ** ព្រោះអត្ថថា ជាធាតុ ដោយអត្ថថា ជាសភាវៈ ដែលមិនមែនសត្វ និង សោះសូន្យទទេ ។ កិលេសកាម ឈ្មោះថា **កាម** ព្រោះអត្ថថា ជាវត្ថុដែល គួរប្រាថ្នា និងដោយអត្ថថា ជាការពេញចិត្ត ឈ្មោះថា **កាមធាតុ** ព្រោះ អត្ថថា ជាធាតុ តាមដែលពោលហើយនោះឯង ។ ក្នុងកាមភព ឈ្មោះថា **កាម** ព្រោះហេតុ ៣ គឺព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នា ១ ព្រោះអត្ថថា ជាការពេញចិត្ត ១ ព្រោះអត្ថថា ជាទីប្រព្រឹត្តទៅនៃវត្ថុកាម ១ ។ ឈ្មោះថា កាមធាតុ ព្រោះអត្ថថា ជាធាតុ ដោយអត្ថតាមដែលពោលហើយនោះឯង ។ ក្នុងលទ្ធិរបស់បរវាទីកាន់យកថា កាមគុណ ៥ ប៉ុណ្ណោះ ជាកាមធាតុ ព្រោះ អាស្រ័យត្រឹមតែបាលីថា ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាង ដូច្នេះ ព្រោះហេតុនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយ បុព្វសេលិយៈទាំងឡាយ ក្នុងឥឡូវនេះ សកវាទី សំដៅដល់ជនទាំងនោះ ទើបសួរថា **បញ្ចេវ** ជាដើម ដើម្បីចោទសួរនូវភាពដែលកាមធាតុផ្សេងអំពី កាមគុណ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយអំណាចនៃលទ្ធិ ។

បទថា **ឆន្ទុ អត្ថិ** ជាដើម សកវាទីពោលហើយ ដើម្បីសម្តែងដល់កិលេសកាម ។

ក្នុងបទទាំងនោះ បទថា **តប្បដិសំយុត្តោ** បានដល់ ប្រកបហើយដោយកាមគុណ គឺមានកាមគុណជាអារម្មណ៍ ។ ក្នុងបទទាំងឡាយថា **ឆោ ច វត វេ វត្តព្វេ បញ្ចេវ** សេចក្តីថា កាលធម៌ទាំងឡាយ មានការពេញចិត្តទាក់ទងដោយកាមគុណ ៥ នោះជាដើមមាន ក៏មិនគួរពោលថា កាមគុណ ៥ ប៉ុណ្ណោះជាកាមធាតុ ។ អធិប្បាយថា ធម៌ទាំងឡាយ មានការពេញចិត្តជាដើមទាំងនេះ ឈ្មោះថា កាមធាតុ ព្រោះអត្ថថា ជាកាមផង ព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នាផង ជាធាតុផង ឈ្មោះថា កាមធាតុ ព្រោះអត្ថថា ជាធាតុ ពោល គឺកាម ព្រោះអត្ថថា ជាការពេញចិត្ត ។

[ ៧៦៦ ] បទថា **មនុស្សានំ ចក្ខុំ** ជាដើម សកវាទីពោលដើម្បីសម្តែងដល់វត្ថុកាម ។ ក្នុងបញ្ហាទាំងនោះ បរវាទីបដិសេធហើយ នូវភាពដែលអាយតនៈទាំង ៦ ព្រោះជាវត្ថុកាម ទើបមិនជាកាមធាតុ ត្រូវសួរទៀតថា **មនោ** ក៏ឆ្លើយទទួលនូវភាពដែលចិត្តនោះមិនជាកាមធាតុ ព្រោះសំដៅយកមហគ្គតចិត្ត និងលោកុត្តរចិត្ត ។ ព្រោះមនោដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ក៏ឈ្មោះថា កាមធាតុ ព្រោះហេតុនោះ ទើបសកវាទីសន្កត់សង្កិនបរវាទីនោះ ដោយព្រះសូត្រ ។

[ ៧៦៧ ] បទថា **កាមគុណា ភវោ** ជាដើម សកវាទីពោលដើម្បី

*សម្តែងនូវភាពដែលភពជាកាមធាតុ តែព្រោះវោហារថា ភព ក្នុងពាក្យត្រឹមតែជាកាមគុណ រមែងមិនមាន ព្រោះហេតុនោះ ទើបបរវាទីបដិសេធថា* **ឆ ហេវំ** *។ បទទាំងពួង មានបទថា* **កាមគុណូបគំ កម្មំ** *ជាដើម សកវាទី ពោលហើយ ដើម្បីសម្តែងនូវភាពដែលត្រឹមតែកាមគុណ មិនជាកាមធាតុ ។ ពិតហើយ កម្មដែលញ៉ាំងសត្វឲ្យចូលដល់កាមភព ពោល គឺកាមធាតុមានសត្វទាំងឡាយដែលកើតក្នុងកាមភពនោះឯងក៏មាន បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីទាំងពួង ដោយឧបាយនេះថា សត្វទាំងឡាយ រមែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមភពនោះ មិនមែនក្នុងកាមគុណទាំងឡាយ ដូច្នេះឯង ៕៚*

## អដ្ឋកថាកាមគុណកថា ចប់

# អភិធម្មបិដក

## កាមកថា

[ ៧៦៩ ] អាយតនៈ ៥ ជាកាមឬ ។ អើ ។ ក្រែងឆន្ទៈដែលប្រកប ដោយអាយតនៈនោះ មានដែរឬ ។ អើ ។ ប្រសិនបើ ឆន្ទៈដែលប្រកប ដោយអាយតនៈនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អាយតនៈ ៥ ជាកាមទេ ។ ក្រែងរាគៈ ដែលប្រកបដោយអាយតនៈនោះ ឆន្ទរាគៈ ដែលប្រកបដោយអាយតនៈនោះ សង្កប្ប ដែលប្រកបដោយ អាយតនៈនោះ រាគៈ ដែលប្រកបដោយអាយតនៈនោះ សង្កប្បរាគៈ ដែល ប្រកបដោយអាយតនៈនោះ បីតិ ដែលប្រកបដោយអាយតនៈនោះ សោម-នស្ស ដែលប្រកបដោយអាយតនៈនោះ បីតិសោមនស្ស ដែលប្រកបដោយ អាយតនៈនោះ មានដែរឬ ។ អើ ។ ប្រសិនបើ បីតិសោមនស្ស ដែល ប្រកបដោយអាយតនៈនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោល ថា អាយតនៈ ៥ ជាកាមទេ ។

[ ៧៧០ ] បុគ្គលមិនគួរនិយាយថា អាយតនៈ ៥ ជាកាមទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ ។ កាមគុណ ៥ តើដូចម្តេច ។ គឺរូបទាំងឡាយ ដែលគប្បីដឹង ដោយភ្នែក ។បេ។ ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ពាក្យ ដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អាយតនៈ ៥ ជាកាម ។

[ ៧៧១ ] អាយតនៈ ៥ ជាកាមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ ។ កាមគុណ ៥ តើដូចម្ដេច ។ គឺរូបទាំងឡាយ ដែលគប្បីដឹងដោយភ្នែក ។បេ។ ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ មួយទៀតកាមទាំងនុ៎ះ មិនឈ្មោះថា ជាកាមគុណប៉ុណ្ណោះទេ កាមទាំងនុ៎ះ លោកហៅក្នុងវិន័យរបស់ព្រះអរិយៈថា

សង្កប្បរាគៈ ជាកាមរបស់បុរស ភិក្ខុទាំងឡាយណា ក្នុង
លោក ចិត្តទាំងនោះ មិនមែនជាកាមទេ សង្កប្បរាគៈ ជា
កាមរបស់បុរស ចិត្តទាំងឡាយ តែងស្ថិតនៅក្នុងលោក
ដោយប្រការដូច្នោះឯង កាលបើយ៉ាងនេះ អ្នកប្រាជ្ញទាំង
ឡាយ តែងកម្ចាត់បង់នូវឆន្ទៈ ក្នុងកាមនុ៎ះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា អាយតនៈ ៥ ជាកាមទេ ។

**កាមកថា ចប់**

# អដ្ឋកថា

## កាមកថា

[ ៧៦៩ ] ឥឡូវនេះ នឹងពណ៌នាអំពីកាមដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា អាយតនៈទាំង ៥ មានរូបាយតនៈជាដើម ប៉ុណ្ណោះជាកាម ព្រោះអាស្រ័យត្រឹមតែព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ ដូច្នេះ ពាក្យសួររបស់សកវាទីថា **បញ្ច** ដើម្បីសម្តែងនូវភាពដែលកិលេសកាមនោះឯង ជាកាមដោយពិត សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាកាមកថា ចប់**

# អភិធម្មបិដក

## រូបធាតុកថា

[ ៧៧២ ] ពួកធម៌ មានរូប ជារូបធាតុឬ ។ អើ ។ រូប គឺភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងរូប មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងរូប មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិក្នុងរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៧៣ ] រូបធាតុ គឺភព គតិ ។បេ។ និងការចំពោះនូវអត្តភាពឬ ។ អើ ។ រូប គឺភព គតិ ។បេ។ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងរូបធាតុ មានដែរឬ ។ អើ ។ កម្មនាំចូលទៅកើតក្នុងរូប មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងរូបធាតុ មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងរូប មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងរូបធាតុឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងរូបដែរឬ ។ អ្នកមិនគួរពោល

យ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងរូបធាតុដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបធាតុ ជាបញ្ចវោការភពឬ ។ អើ ។ រូបជាបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ មានរូប ជារូបធាតុ ចុះរូប មានក្នុងកាមធាតុដែរឬ ។ អើ ។ កាមធាតុនោះឯង គឺរូបធាតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមធាតុនោះឯង គឺរូបធាតុនោះឬ ។ អើ ។ បុគ្គលប្រកបដោយកាមភព ឈ្មោះថា ប្រកបដោយភព ២ គឺកាមភព និងរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

រូបធាតុកថា ចប់

# អដ្ឋកថា

## រូបធាតុកថា

[ ៧៧២ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបធាតុដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា រូបធម៌ប៉ុណ្ណោះ ឈ្មោះថា រូបធាតុ ដូច្នេះ ពាក្យសួររបស់សកវាទីថា **រូបិនោ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពេលនោះ ព្រោះរូបភពក៏ឈ្មោះថា រូបធាតុ មិនមែនត្រឹមតែរូបតែម្យ៉ាងប៉ុណ្ណោះទេ ព្រោះហេតុនោះ សកវាទី ដើម្បីចោទសួរបរវាទីនោះ ដោយអត្ថនោះ ទើបពោលពាក្យថា **រូបធាតុ** ជាដើម ។ ពាក្យទាំងអស់នោះ បណ្ឌិតគប្បីជ្រាបអត្ថដោយន័យដែលខ្ញុំពោលហើយ ក្នុងរឿងកាមគុណានោះឯង ។

[ ៧៧៣ ] បរវាទី ត្រូវសកវាទីសួរថា **សាវ កាមធាតុ** កាលឃើញនូវការខុសអំពីការកំណត់ភូមិ ទើបឆ្លើយបដិសេធ ។ ត្រូវសួរដដែលឲ្យមាំទៀត ក៏ឆ្លើយទទួលដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ កាលបើយ៉ាងនោះ រូបនោះ ក៏រមែងប្រាកដ ព្រោះការប្រជុំគ្នាដោយភពទាំង ២ ។ ព្រោះហេតុនោះ ទើបសកវាទីពោលនឹងបរវាទីនោះថា **កាមភវេន ច** ជាដើម ។ បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានរូបត្រឹមតែមួយ ប្រកបដោយភពទាំង ២ ដូច្នេះ ។ល។

**អដ្ឋកថារូបធាតុកថា ចប់**

# អភិធម្មបិដក

## អរូបធាតុកថា

[ ៧៧៤ ] ពួកធម៌ មិនមានរូប ជាអរូបធាតុឬ ។ អើ ។ វេទនា គឺភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងវេទនា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងវេទនា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងវេទនាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ ក្នុងវេទនា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ជាចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៧៥ ] អរូបធាតុ គឺភព គតិ ។បេ។ និងការបានចំពោះនូវអត្តភាព ឬ ។ អើ ។ វេទនា គឺភព គតិ ។បេ។ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មនាំចូលទៅកើតក្នុងអរូបធាតុ មានដែរឬ ។ អើ ។ កម្មនាំចូលទៅកើតក្នុងវេទនា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ ចូលទៅកើតក្នុងអរូបធាតុ មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងវេទនា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអរូបធាតុដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងវេទនា

ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអរូបធាតុដែរឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងវេទនាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរូប-ធាតុ ជាចតុវោការភពឬ ។ អើ ។ វេទនា ជាចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ មិនមានរូប ជាអរូបធាតុ ចុះវេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងកាមធាតុដែរឬ ។ អើ ។ កាមធាតុនោះឯង គឺអរូបធាតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមធាតុនោះឯង គឺអរូបធាតុនោះឬ ។ អើ ។ បុគ្គលប្រកបដោយកាមភព ឈ្មោះថា ប្រកបដោយភព ២ គឺកាមភព និងអរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ មានរូប ជារូបធាតុ ពួកធម៌មិនមានរូប ជាអរូបធាតុ ចុះរូបវេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងកាមធាតុដែរឬ ។ អើ ។ កាមធាតុនោះឯង គឺរូបធាតុនោះ គឺអរូបធាតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមធាតុនោះឯង គឺរូបធាតុនោះ គឺអរូបធាតុនោះឬ ។ អើ ។ បុគ្គលប្រកបដោយកាមភព ឈ្មោះថា ប្រកបដោយភព ៣ គឺកាមភព ១ រូបភព ១ អរូបភព ១ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**អរូបធាតុកថា ចប់**

# អដ្ឋកថា

## អរូបធាតុកថា

[ ៧៧៤ ] ឥឡូវនេះ ក្នុងរឿងអរូបធាតុ បណ្ឌិតគប្បីជ្រាបអត្ថដោយឧបាយនេះឯង គឺតាមន័យដែលពោលហើយ ។ តែលោកកំណត់សម្តែងក្នុងទីនេះ ដោយន័យថា **វេទនា ភវោ** ជាដើម ព្រោះកាន់យកវេទនាខន្ធនោះឯងក្នុងអរូបធម៌ទាំងឡាយ ។ ក្នុងបញ្ហានោះ បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា សកវាទីសួរថា វេទនាដែលដល់នូវការរាប់ថា ជាអរូបធម៌ទាំងឡាយណាមួយ ក្នុងវេទនាជាដើម តាមលទ្ធិរបស់អ្នកឬ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលហើយខាងដើមនោះឯង ៕ល៕

**អដ្ឋកថាអរូបធាតុកថា ចប់**

# អភិធម្មបិដក

## រូបធាតុអាយតនកថា

[ ៧៧៦ ] អត្តភាព ប្រកបដោយអាយតនៈ ៦ ក្នុងរូបធាតុ មានដែរឬ ។ អើ ។ ឃានាយតនៈ ក្នុងរូបធាតុនោះ មានដែរឬ ។ អើ ។ គន្ធាយតនៈ ក្នុងរូបធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជិវ្ហាយតនៈ ក្នុងរូបធាតុនោះ មានដែរឬ ។ អើ ។ រសាយតនៈ ក្នុងរូបធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយាយតនៈ ក្នុងរូបធាតុនោះ មានដែរឬ ។ អើ ។ ផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៧៧ ] គន្ធាយតនៈ ក្នុងរូបធាតុនោះ មិនមានទេឬ ។ អើ ។ ឃានាយតនៈ ក្នុងរូបធាតុនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រសាយតនៈ ក្នុងរូបធាតុនោះ មិនមានទេឬ ។ អើ ។ ជិវ្ហាយតនៈ ក្នុងរូបធាតុនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មិនមានទេឬ ។ អើ ។ កាយាយតនៈ ក្នុងរូបធាតុនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៧៨ ] ចក្ខាយតនៈ ក្នុងរូបធាតុនោះ មាន ចុះរូបាយតនៈ មានដែរឬ ។ អើ ។ ឃានាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគន្ធាយតនៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខាយតនៈ ក្នុងរូបធាតុនោះ មាន ចុះរូបាយតនៈ មានដែរឬ ។ អើ ។ ជិវ្ហាយតនៈ ក្នុងរូបធាតុនោះ មាន ចុះ

រសាយតនៈ មានដែរឬ ។បេ។ កាយាយតនៈ ក្នុងរូបធាតុនោះ មាន ចុះផោដ្ឋព្វាយតនៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៧៩ ] សោតាយតនៈ ក្នុងរូបធាតុនោះ មាន ចុះសទ្ទាយតនៈ មានដែរឬ ។បេ។ មនាយាតនៈ ក្នុងរូបធាតុនោះ មាន ចុះធម្មាយតនៈ មានដែរឬ ។ អើ ។ ឃានាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគន្ធាយតនៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនាយតនៈ ក្នុងរូបធាតុនោះ មាន ចុះធម្មាយតនៈ មានដែរឬ ។ អើ ។ ជិវ្ហាយតនៈ ក្នុងរូបធាតុនោះ មាន ចុះរសាយតនៈ មានដែរឬ ។បេ។ កាយាយតនៈ ក្នុងរូបធាតុនោះ មាន ចុះផោដ្ឋព្វាយតនៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨០ ] ឃានាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគន្ធាយតនៈ មិនមានទេឬ ។ អើ ។ ចក្ខាយតនៈ ក្នុងរូបធាតុនោះ មាន ចុះរូបាយតនៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ឃានាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគន្ធាយតនៈ មិនមានទេឬ ។ អើ ។ សោតាយតនៈ ក្នុងរូបធាតុនោះ មាន ចុះសទ្ទាយតនៈ មិនមានទេឬ ។បេ។ មនាយតនៈ ក្នុងរូបធាតុនោះ មាន ចុះធម្មាយតនៈមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨១ ] ជិវ្ហាយតនៈ ក្នុងរូបធាតុនោះ មាន ចុះរសាយតនៈ មិនមានទេឬ ។បេ។ កាយាយតនៈ ក្នុងរូបធាតុនោះ មាន ចុះផោដ្ឋព្វាយតនៈ មិនមានទេឬ ។ អើ ។ ចក្ខាយតនៈ ក្នុងរូបធាតុនោះ មាន ចុះរូបាយតនៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយាយតនៈ ក្នុងរូបធាតុ

នោះ មាន ចុះផោដ្ឋព្វាយតនៈ មិនមានទេឬ ។ អើ ។ សោតាយតនៈ ក្នុងរូបធាតុនោះ មាន ចុះសទ្ទាយតនៈ មិនមានទេឬ ។បេ។ មនាយតនៈ ក្នុងរូបធាតុនោះ មាន ចុះធម្មាយតនៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨២ ] ចក្ខាយតនៈ និងរូបាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេឃើញរូបនោះ ដោយភ្នែកនោះដែរឬ ។ អើ ។ ឃានាយតនៈ និងគន្ធាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេធុំក្លិននោះ ដោយច្រមុះនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខាយតនៈ និងរូបាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេឃើញរូបនោះ ដោយភ្នែកនោះដែរឬ ។ អើ ។ ជិវ្ហាយតនៈ និងរសាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេលិទ្ធភក្សរសនោះ ដោយអណ្ដាតនោះដែរឬ ។បេ។ កាយាយតនៈ និងផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេពាល់ត្រូវផោដ្ឋព្វាយតនៈនោះ ដោយកាយនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៣ ] សោតាយតនៈ និងសទ្ទាយតនៈ ក្នុងរូបធាតុនោះ មាន ។បេ។ មនាយតនៈ និងធម្មាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេដឹងច្បាស់នូវធម៌នោះ ដោយចិត្តនោះដែរឬ ។ អើ ។ ឃានាយតនៈ និងគន្ធាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេធុំក្លិននោះ ដោយច្រមុះនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនាយតនៈ និងធម្មាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេដឹងច្បាស់នូវធម៌នោះ ដោយចិត្តនោះដែរឬ ។ អើ ។ ជិវ្ហាយតនៈ និង

រសាយតនៈ ក្នុងរូបធាតុនោះ មាន ។បេ។ កាយាយតនៈនិងផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេពាល់ត្រូវនូវផោដ្ឋព្វៈនោះ ដោយកាយនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៤ ] ឃានាយតនៈ និងគន្ធាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនធុំក្លិននោះ ដោយច្រមុះនោះទេឬ ។ អើ ។ ចក្ខាយតនៈ និងរូបាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនឃើញនូវរូបនោះ ដោយភ្នែកនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ឃានាយតនៈ និងគន្ធាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនធុំក្លិននោះ ដោយច្រមុះនោះទេឬ ។ អើ ។ សោតាយនៈ និងសទ្ទាតយនៈ ក្នុងរូបធាតុនោះ មានមែន ។បេ។ មនាយតនៈ និងធម្មាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនដឹងច្បាស់ នូវធម៌នោះ ដោយចិត្តនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៥ ] ជិវ្ហាយតនៈ និងរសាយតនៈ ក្នុងរូបធាតុនោះ មានមែន ។បេ។ កាយាយតនៈ និងផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនពាល់ត្រូវនូវផោដ្ឋព្វៈនោះ ដោយកាយនោះទេឬ ។ អើ ។ ចក្ខាយតនៈ និងរូបាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនឃើញ នូវរូបនោះដោយភ្នែកនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយាយតនៈ និងផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មានមែន តែគេមិនពាល់ត្រូវនូវផោដ្ឋព្វៈនោះ ដោយកាយនោះទេឬ ។ អើ ។ សោតាយតនៈ និងសទ្ទាយតនៈ ក្នុងរូបធាតុនោះ មានមែន ។បេ។ មនាយតនៈ និងធម្មាយតនៈ ក្នុងរូបធាតុនោះ

មានមែន តែគេមិនដឹងច្បាស់នូវធម៌នោះ ដោយចិត្តនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៦ ] ឃានាយតនៈ និងគន្ធាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេធុំក្លិននោះ ដោយច្រមុះនោះដែរឬ ។ អើ ។ ក្លិនឫស ក្លិនខ្លឹម ក្លិនសម្បក ក្លិនស្លឹក ក្លិនផ្កា ក្លិនផ្លែ ក្លិនស្រស់ ក្លិនជាពិស ក្លិនក្រអូប ក្លិនស្អុយ ក្នុងរូបធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៧ ] ជិវ្ហាយតនៈ និងរសាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេលិទ្ធភ្លក្សរសនោះ ដោយអណ្តាតនោះដែរឬ ។ អើ ។ រសឫស រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ ជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ ជូរអែម ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ក្នុងរូបធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៨ ] កាយាយតនៈ និងផោដ្ឋព្វាយតនៈ ក្នុងរូបធាតុនោះ មាន ចុះគេពាល់ត្រូវនូវផោដ្ឋព្វៈនោះ ដោយកាយនោះដែរឬ ។ អើ ។ រឹង ទន់ ល្អិត គ្រោតគ្រាត សម្ផស្សជាសុខ សម្ផស្សជាទុក្ខ ធ្ងន់ ស្រាល ក្នុងរូបធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨៩ ] បុគ្គលមិនគួរនិយាយថា អត្តភាព ប្រកបដោយអាយតនៈ ៦ ក្នុងរូបធាតុ មានទេឬ ។ អើ ។ ក្រែងឃានទិមិត្ត ជិវ្ហានិមិត្ត កាយនិមិត្ត ក្នុងរូបធាតុនោះ មានដែរឬ ។ អើ ។ ប្រសិនបើ ឃាននិមិត្ត ជិវ្ហានិមិត្ត កាយនិមិត្ត ក្នុងរូបធាតុនោះ មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អត្តភាព ប្រកបដោយអាយតនៈ ៦ ក្នុងរូបធាតុ មាន ។

## រូបធាតុអាយតនកថា ចប់

# អដ្ឋកថា

## រូបធាតុយាអាយតនកថា

[ ៧៧៦ ] ឥឡូវនេះ នឹងពណ៌នាអំពីអាយតនៈក្នុងរូបធាតុដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយសមិតិយៈទាំងឡាយថា អត្តភាពរបស់ពួកព្រហ្មទាំងនោះមានអាយតនៈគ្រប់ទាំង ៦ ព្រោះកំណត់យកថា សូម្បីឃានទិមិត្តជាដើមរបស់ពួកព្រហ្មទាំងនោះ ជាអាយតនៈនោះឯង ព្រោះអាស្រ័យព្រះសូត្រ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា មានរូបជាទិព្វ សម្រេចដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកទាប គឺមានឥន្ទ្រិយពេញលេញ ដូច្នេះ ពាក្យសួររបស់សកវាទីថា **សឡាយតនិកោ** សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយអំណាចនៃលទ្ធិ ។ ពេលនោះ សកវាទីដើម្បីចោទសួរបរវាទីនោះ ដោយអំណាចនៃអាយតនៈដែលមិនមានក្នុងពួកព្រហ្មនោះ ទើបផ្ដើមពាក្យថា **អត្ថិ តត្ថ ឃានាយតនំ** ជាដើម ។ លំដាប់នោះ បរវាទីក៏ឆ្លើយទទួលដោយលទ្ធិថា សណ្ឋានទិមិត្តរបស់អាយតនៈទាំង ៣ គឺឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ ដែលជាខាងក្នុង មានឃានាយតនៈជាដើមឯណា មានក្នុងរូបធាតុនោះ សណ្ឋានទិមិត្តនោះឯង ជាអាយតនៈ ដូច្នេះ ។ បរវាទី ត្រូវសួរដោយអំណាចនៃគន្ធាយតនៈជាដើម ដែលជារបស់ខាងក្រៅ រមែងមិនកាន់យកឃានបសាទជាដើម ក្នុងរូបធាតុនោះ ព្រោះហេតុនោះ កាលជំទាស់នូវអារម្មណ៍នៃឃានា-

យតនៈជាដើមនោះ ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាបដិលោម និងបញ្ហាពោលដោយការប្រៀបធៀបទាំងឡាយ បណ្ឌិតគប្បីជ្រាបអត្ថដោយឧបាយនេះឯង ។

[ ៧៨២ ] បទថា **អត្ថិ តត្ថ ឃានាយតនំ អត្ថិ គន្ធាយតនំ តេន ឃានេន តំ គន្ធំ ឃាយតិ** សកវាទីពោលសំដៅដល់អាចារ្យពួកខ្លះ ក្នុងលទ្ធិរបស់បរវាទីប៉ុណ្ណោះ ។ បានឮថា អាចារ្យពួកខ្លះនោះ មានការសម្គាល់ថា ក្នុងរូបធាតុនោះ មានអាយតនៈខាងក្នុងគ្រប់បរិបូណ៌ទាំង ៦ និងឈ្មោះថា អាយតនៈ ក៏គប្បីធ្វើកិច្ចរបស់ខ្លួន ព្រោះហេតុនោះ ទើបរូបព្រហ្មទាំងនោះ ហិតក្លិន លិទ្ធរស ពាល់ត្រូវនូវផោដ្ឋព្វៈទាំងនោះ បានដោយឃានៈជាដើមទាំងនោះ ដូច្នេះ ។ បរវាទីអាស្រ័យលទ្ធិនោះ ទើបឆ្លើយទទួលថា **អាមន្តា** ។

[ ៧៨៦ ] បរវាទីត្រូវសួរថា **អត្ថិ តត្ថ មូលគន្ធោ** ដូច្នេះជាដើម កាលមិនអាចញុំាងភាពដែលមានឲ្យប្រាកដបាន ទើបឆ្លើយបដិសេធ ។

[ ៧៨៩ ] បទថា **ននុ អត្ថិ តត្ថ ឃាននិមិត្តំ** ជាដើម សម្រេចត្រឹមតែជារូបរាងសណ្ឋានប៉ុណ្ណោះ មិនសម្រេចជាអាយតនៈឡើយ ព្រោះហេតុនោះ ពាក្យនោះ សូម្បីបរវាទីលើកឡើងមកហើយ ក៏ដូចជាមិនបានលើកឡើងដូច្នេះ ។ល។

**អដ្ឋកថារូបធាតុយាអាយតនកថា ចប់**

# អភិធម្មបិដក

## អរូបរូបកថា

[ ៧៩០ ] រូបក្នុងពួកអរូប មានដែរឬ ។ អើ ។ ភពនៃរូប គតិនៃរូប សត្តាវាសនៃរូប សំសារនៃរូប កំណើតនៃរូប និងការបាទចំពោះនូវអត្តភាពនៃរូប ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងភពនៃអរូប គតិនៃអរូប សត្តាវាសនៃអរូប សំសារនៃអរូប កំណើតនៃអរូប និងការចំពោះនូវអត្តភាពនៃអរូប ( មាន ) ឬ ។ អើ ។ ប្រសិនបើ ភពនៃអរូប ។បេ។ និងការបាទចំពោះអត្តភាពនៃអរូប ( មាន ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបក្នុងពួកអរូប មានទេ ។

[ ៧៩១ ] រូបក្នុងពួកអរូប មានឬ ។ អើ ។ បញ្ចវោការភព គតិ សត្តាវាស សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបាទចំពោះនូវអត្តភាព ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងចតុវោការភព ។បេ។ និងការបាទចំពោះនូវអត្តភាព ( មាន ) ឬ ។ អើ ។ ប្រសិនបើ ចតុវោការភព គតិ ។បេ។ និងការបាទចំពោះនូវអត្តភាព ( មាន ) ម្នាល អ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបក្នុងអរូប មានទេ ។

[ ៧៩២ ] រូបក្នុងរូបធាតុ មាន ចុះរូបភពនោះ គតិនៃរូប សត្តាវាសនៃរូប សំសារនៃរូប កំណើតនៃរូប និងការបាទចំពោះនូវអត្តភាពនៃរូប ( មាន ) ឬ ។ អើ ។ រូបក្នុងពួកអរូប មាន ចុះរូបភពនោះ គតិនៃរូប ។បេ។ និងការបាទចំពោះនូវអត្តភាពនៃរូប ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។ រូបក្នុងរូបធាតុ មាន ចុះបញ្ចវោការភពនោះ គតិ ។បេ។ និង ការបានចំពោះនូវអត្តភាព ( មាន ) ឬ ។ អើ ។ រូបក្នុងពួកអរូប មាន ចុះបញ្ចវោការភពនោះ គតិ ។បេ។ និងការបានចំពោះនូវអត្តភាព ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៩៣ ] រូប ក្នុងពួកអរូប មាន ចុះអរូបភពនោះ គតិនៃអរូប សត្តាវាសនៃអរូប សំសារនៃអរូប កំណើតនៃអរូប និងការបានចំពោះនូវ អត្តភាពនៃអរូប ( មាន ) ឬ ។ អើ ។ រូប ក្នុងអរូបធាតុ មាន ចុះអរូប-ភពនោះ គតិនៃអរូប ។បេ។ និងការបានចំពោះនូវអត្តភាពនៃអរូប ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៩៤ ] រូប ក្នុងពួកអរូប មាន ចុះចតុវោការភពនោះ គតិ ។បេ។ និងការបានចំពោះនូវអត្តភាព ( មាន ) ឬ ។ អើ ។ រូប ក្នុងអរូបធាតុ មាន ចុះចតុវោការភពនោះ គតិ ។បេ។ និងការបានចំពោះនូវអត្តភាព ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៩៥ ] រូប ក្នុងពួកអរូប គ្មានឬ ។ អើ ។ ក្រែងការរលាស់ចេញ នូវពួករូប ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អរូបឬ ។ អើ ។ ប្រសិន

បើ ការរលាស់ចេញនូវពួករូប ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាអរូប ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ក្នុងពួកអរូប មានទេ ។

[ ៧៩៦ ] ការរលាស់ចេញនូវពួករូប ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាអរូប ចុះរូប ក្នុងពួកអរូប មានឬ ។ អើ ។ ការរលាស់ចេញនូវពួកកាម ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជានេក្ខម្មៈ ចុះពួកកាម ក្នុងពួកនេក្ខម្មៈ មាន ពួកអាសវៈ ក្នុងពួកអាសវៈ មាន ពួកបរិយាបន្ន ក្នុងពួកអបរិយាបន្ន មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អរូបរូបកថា ចប់

# អដ្ឋកថា

## អរូបេរូបកថា

[ ៧៩០ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបក្នុងអរូបសត្វដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា សុខុមរូប អាស្រ័យឱឡារិករូប មានក្នុងអរូបភព ព្រោះព្រះបាលីថា **វិញ្ញាណប្បច្ចយា នាមរូបំ** ដូច្នេះ ពាក្យសួររបស់សកវាទីថា **អត្ថិ រូបំ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាអរូបេរូបកថា ចប់**

# អភិធម្មបិដក

## រូបំ កម្មន្តិកថា

[ ៧៩៧ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អើ ។ រូបប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូបមិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលទេ ។

[ ៧៩៨ ] ផស្សៈ តាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មានឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ចេតនា សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញា តាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះបញ្ញានោះ មានឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល

ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៩៩ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ តាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ វេទនា ។បេ។ សញ្ញា ចេតនា សទ្ធា វីរិយៈ សតិ សមាធិ ។បេ។ បញ្ញា តាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះបញ្ញានោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០០ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អើ ។ រូបណាមួយ តាំងឡើងដោយកុសលចិត្ត រូបទាំងអស់នោះ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០១ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វ-

យតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនោះទេ ។បេ។

[ ៨០២ ] រូបាយតនៈ តាំងឡើងដោយកុសលចិត្ត ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនោះទេ ។បេ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ ការតាំងឡើងដោយកុសលចិត្ត ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៣ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៤ ] រូបាយតនៈ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទា-

យតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៥ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ប្រាសចាកផស្សៈ ជាកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយកុសលចិត្ត ប្រាសចាកផស្សៈ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ប្រាសចាកផស្សៈ ជាកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសល-ចិត្ត ប្រាសចាកផស្សៈ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៦ ] រូបាយតនៈ តាំងឡើងដោយកុសលចិត្ត ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទា-យតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសលចិត្ត ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសល-ចិត្ត ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៧ ] រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៨ ] រូបាយតនៈ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០៩ ] រូបជាវចីកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អើ ។ រូបប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមាន

អារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូបមិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាវិចីកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលទេ ។

[ ៨១០ ] ផស្សៈ តាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មានឬ ។ អើ ។ រូបជាវិចីកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ចេតនា សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញាតាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះបញ្ញានោះ មានឬ ។ អើ ។ រូបជាវិចីកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១១ ] រូបជាវិចីកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ តាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុកចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាវិចីកម្ម តាំងឡើងដោយកុសលចិត្ត

ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ វេទនា ។បេ។ សញ្ញា ចេតនា សទ្ធា វីរិយៈ សតិ សមាធិ ។បេ។ បញ្ញាតាំងឡើងដោយកុសលចិត្ត ជាកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះបញ្ញានោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១២ ] រូបជាវចីកម្ម តាំងឡើងដោយកុសលចិត្ត ជាកុសលឬ ។ អើ ។ រូបណាមួយ តាំងឡើងដោយកុសលចិត្ត រូបទាំងអស់នោះ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយកម្ម យ៉ាងណា វចីកម្ម ក៏យ៉ាងនោះ ។

[ ៨១៣ ] រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អើ ។ រូបប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូបមិនមានអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលទេ ។

[ ៨១៤ ] ផស្សៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មានឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ចេតនា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។បេ។ អនោត្តប្បៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះអនោត្តប្បៈនោះ មានឬ ។ អើ ។ រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១៥ ] រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ វេទនា ។បេ។ សញ្ញា ចេតនា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។បេ។ អនោត្តប្បៈ

តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះអនោត្តប្បៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៨១៦ ] រូបជាកាយកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល ឬ ។ អើ ។ រូបណាមួយ តាំងឡើងដោយអកុសលចិត្ត រូបទាំងអស់នោះ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១៧ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អើ ។ រូបប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេ ឬ ។ អើ ។ ប្រសិនបើ រូបមិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលទេ ។

[ ៨១៨ ] ផស្សៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មានឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ចេតនា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។បេ។ អនោត្តប្បៈ តាំង

ឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះអនោត្តប្បៈនោះ មានឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១៩ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ វេទនា ។បេ។ សញ្ញា ចេតនា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងទុកចំពោះអនោត្តប្បៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២០ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អើ ។ រូបណាមួយ តាំងឡើងដោយអកុសលចិត្ត រូបទាំងអស់នោះ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២១ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ( សុក្កៈ ) ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២២ ] រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើសតាំងឡើងដោយអកុសលចិត្ត ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៣ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។

បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៤ ] រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៥ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ប្រាសចាកផស្សៈ ជាអកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត ប្រាសចាកផស្សៈ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត ប្រាសចាកផស្សៈ ជាអកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ បឋវីធាតុ អាបោធាតុ តេជោធាតុ ។បេ។ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត ប្រាសចាកផស្សៈ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៦ ] រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៧ ] រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអកុសលឬ ។ អើ ។ រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអកុសលឬ ។ អើ ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៨ ] រូបាយតនៈ តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍

ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទាយតនៈ ។បេ។ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើស តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបជាវចីកម្ម តាំងឡើងដោយអកុសលចិត្ត មិនមានអារម្មណ៍ ប្រាសចាកផស្សៈ ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២៩ ] បុគ្គលមិនគួរនិយាយថា រូបជាកុសលក៏មាន ជាអកុសលក៏មានទេឬ ។ អើ ។ ក្រែងកាយកម្ម វចីកម្ម ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ប្រសិនបើ កាយកម្ម វចីកម្ម ជាកុសលក៏មាន ជាអកុសលក៏មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបជាកុសលក៏មាន ជាអកុសលក៏មាន ។

[ ៨៣០ ] រូបជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ចក្ខាយតនៈ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ សោតាយតនៈ ។បេ។ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ របស់មិនស្អាត ទឹកភ្នែក ឈាម ។បេ។ ញើសជាកុសលក៏មាន ជាអកុសល

ក៏មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣១ ] កាយជារូប កាយកម្ម ជារូបឬ ។ អើ ។ ចិត្ត ជារូប មនោកម្ម ជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣២ ] ចិត្ត ជាអរូប មនោកម្ម ជាអរូបឬ ។បេ។ កាយ ជាអរូប កាយកម្ម ជាអរូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣៣ ] កាយ ជារូប កាយកម្ម ជាអរូបឬ ។ អើ ។ ចិត្ត ជារូប មនោកម្ម ជាអរូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣៤ ] ចិត្ត ជាអរូប មនោកម្ម ជាអរូបឬ ។ អើ ។ កាយ ជាអរូប កាយកម្ម ជាអរូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣៥ ] កាយ ជារូបឬ ។ កាយកម្ម ជារូបឬ ។ អើ ។ ចក្ខាយតនៈ ជារូបឬ ។ ចក្ខុវិញ្ញាណ ជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយ ជារូបឬ ។ កាយកម្ម ជារូបឬ ។ អើ ។ សោតាយតនៈ ជារូបឬ ។ សោតវិញ្ញាណ ជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយ ជារូបឬ ។ កាយកម្ម ជារូបឬ ។ អើ ។ ឃានាយតនៈ ជារូបឬ ។ ឃានវិញ្ញាណ ជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយ ជារូបឬ ។ កាយកម្ម ជារូបឬ ។ អើ ។ ជិវ្ហាយតនៈ ជារូបឬ ។ ជិវ្ហាវិញ្ញាណ ជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយ ជារូបឬ ។ កាយកម្ម ជារូបឬ ។ អើ ។ កាយាយតនៈ ជារូបឬ ។ កាយវិញ្ញាណ ជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣៦ ] រូប ជាកម្មឬ ។ អើ ។ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនា ជាកម្ម បុគ្គលគិតហើយទើបធ្វើនូវកម្ម ដោយកាយ ដោយវាចា ដោយចិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា រូបជាកម្មទេ ។

[ ៨៣៧ ] រូប ជាកម្មឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ កាលបើកាយមាន សុខ និងទុក្ខខាងក្នុង ក៏កើតឡើងដោយហេតុកាយសញ្ចេតនា ម្នាលអានន្ទ កាលបើវាចាមាន សុខ និងទុក្ខខាងក្នុង ក៏កើតឡើងដោយហេតុវចីសញ្ចេតនា ម្នាលអានន្ទ កាលបើចិត្តមាន សុខ និងទុក្ខខាងក្នុង ក៏កើតឡើងដោយហេតុមនោសញ្ចេតនា ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា រូប ជាកម្មទេ ។

[ ៨៣៨ ] រូប ជាកម្មឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ ប្រការ ជាអកុសលកាយកម្ម មានទុក្ខជាកម្រៃ មានទុក្ខជាវិបាក ម្នាលភិក្ខុទាំងឡាយ វចីសញ្ចេតនា ៤ ប្រការ ជាអកុសលវចីកម្ម មានទុក្ខជាកម្រៃ មានទុក្ខជាវិបាក ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនា ៣ ប្រការ ជាអកុសលមនោកម្ម មានទុក្ខជាកម្រៃ មានទុក្ខជាវិបាក ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ ប្រការ ជាកុសលកាយកម្ម មានសុខជាកម្រៃ មានសុខជាវិបាក ម្នាលភិក្ខុទាំងឡាយ វចីសញ្ចេតនា ៤ ប្រការ ជាកុសលវចីកម្ម មានសុខជាកម្រៃ មានសុខជាវិបាក ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនា ៣ ប្រការ ជាកុសលមនោកម្ម

មានសុខជាកម្រៃ មានសុខជាវិបាក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា រូបជាកម្មទេ ។

[ ៨៣៩ ] រូប ជាកម្មឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ បើសមិទ្ធិមោឃបុរស ( មោឃបុរសឈ្មោះសមិទ្ធិ ) នេះ ត្រូវបាតលិបុត្តបរិព្វាជកសួរយ៉ាងនេះហើយ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោបាតលិបុត្ត បុគ្គលណា ធ្វើកម្មប្រកបដោយចេតនា ដោយកាយ វាចា ចិត្ត ជាកម្មគួរដល់ការទទួលសេចក្ដីសុខ បុគ្គលនោះ រមែងទទួលសេចក្ដីសុខ ម្នាលអាវុសោបាតលិបុត្ត បុគ្គលណា ធ្វើកម្មប្រកបដោយចេតនា ដោយកាយ វាចា ចិត្ត ជាកម្មគួរដល់ការទទួលសេចក្ដីទុក្ខ បុគ្គលនោះ រមែងទទួលសេចក្ដីទុក្ខ ម្នាលអាវុសោបាតលិបុត្ត បុគ្គលណា ធ្វើកម្មប្រកបដោយចេតនា ដោយកាយ វាចា ចិត្ត ជាកម្មគួរដល់ការទទួលអទុក្ខមសុខ បុគ្គលនោះ រមែងទទួលអទុក្ខមសុខ ម្នាលអានន្ទ សមិទ្ធិមោឃបុរស កាលដោះស្រាយយ៉ាងនេះហើយ ឈ្មោះថា ដោះស្រាយដោយប្រពៃ គប្បីដោះស្រាយចំពោះបាតលិបុត្ត-បរិព្វាជក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា រូប ជាកម្មទេ ។

**រូបំ កម្មន្តិកថា ចប់**

# អដ្ឋកថា

## រូបំ កម្មន្តិកថា

[ ៧៩៧ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបជាកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហិសាសកៈ និងនិកាយសមិតិយៈទាំងឡាយថា កាយវិញ្ញត្តិរូប និងវចី-វិញ្ញត្តិរូបនោះឯង ឈ្មោះថា កាយកម្ម និងវចីកម្ម ក៏រូបនោះ មានកុសលជាសមុដ្ឋាន រមែងជាកុសល មានអកុសលជាសមុដ្ឋាន ក៏រមែងជាអកុសល ដូច្នេះ ពាក្យសួររបស់សកវាទីថា **កុសលេន ចិត្តេន សមុដ្ឋិតំ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើរូបនោះជាកុសលសោត ប្រភេទនៃធម៌ មានធម៌ដែលមានអារម្មណ៍ជាដើម រមែងមានដល់កុសលប្រភេទនោះ មានដល់រូបនោះ តាមលទ្ធិរបស់អ្នកឬ ដូច្នេះ ទើបផ្តើមពាក្យថា **សារម្មណំ** ជាដើម ។

ក្នុងបញ្ហានោះ បទថា **បត្ថនា បណិធិ** ជាវេវចនៈរបស់ចេតនានោះឯង ។ ពិតហើយ ចេតនាដែលជាកុសលដែលនឹកដល់ លោក ហៅថា **បត្ថនា** និងហៅថា **បណិធិ** ព្រោះតាំងទុកដោយអំណាចនៃការនឹកដល់ ។

[ ៧៩៨ ] ម្យ៉ាងទៀត ក្នុងបទថា **កុសលេន ចិត្តេន សមុដ្ឋិតា វេទនា សញ្ញា ចេតនា សទ្ធា** ជាដើមខាងមុខ បទថា **ចេតនា បត្ថនា បណិធិ** រមែងមានដល់វេទនាជាដើម រមែងមិនមានដល់ចេតនា ។ សួរថា ព្រោះ

ហេតុអ្វី ឆ្លើយថា ព្រោះការមិនមានចេតនាទាំង ២ ដួង រួមជាដួងតែ ១ ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបបែបផែនយ៉ាងនេះថា មានហើយ ព្រោះភាពដែលចេតនានោះ ជាធម្មជាតធ្លាក់ទៅកាន់ក្រសែ ។

[ ៨០១ ] បទថា **រូបាយតនំ** ជាដើម សកវាទីពោលដើម្បីសម្តែងប្រភេទនៃធម៌ដែលសង្ខេប ក្នុងវារៈដំបូងថា **សព្វន្តំ កុសលំ** ។ ន័យប្រៀបធៀបដ៏សេស ជាពាក្យពោលដោយវចីកម្ម និងការកំណត់ជាដើមថា ពាក្យថា **អកុសលេន ចិត្តេន សមុដ្ឋិតំ** បណ្ឌិតគប្បីជ្រាបពាក្យទាំងពួងដោយទំនងនៃបាលីនោះឯង ។

[ ៨២១ ] ក្នុងបទថា **អសុចិ** លោកបំណងយកទឹកសុក្កៈ ។ ការអះអាងដោយព្រះសូត្រ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថារូបំកម្មន្តិកថា ចប់**

# អភិធម្មបិដក

## ជីវិតិន្ទ្រិយកថា

[ ៨៤០ ] រូបជីវិតិន្ទ្រិយ មិនមានទេឬ ។ អើ ។ អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួកធម៌មានរូប មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួកធម៌មានរូប មានឬ ។ អើ ។ ប្រសិនបើ អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួកធម៌មានរូប មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជីវិតិន្ទ្រិយ មិនមានទេ ។

[ ៨៤១ ] អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួកធម៌មិនមានរូប មាន ចុះអរូបជីវិតិន្ទ្រិយ មានឬ ។ អើ ។ អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួកធម៌មានរូប មាន ចុះរូបជីវិតិន្ទ្រិយ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤២ ] អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួកធម៌មានរូប មាន ចុះរូបជីវិតិន្ទ្រិយ មិនមានទេឬ ។ អើ ។ អាយុ ការតាំងនៅ ការរស់នៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សាទុកនូវពួក

ធម៌មិនមានរូប មាន ចុះអរូបជីវិតិន្ទ្រិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៣ ] អាយុនៃពួកធម៌មិនមានរូប ជាអរូបជីវិតិន្ទ្រិយឬ ។ អើ ។ អាយុនៃពួកធម៌មានរូប ជារូបជីវិតិន្ទ្រិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៤ ] អាយុនៃពួកធម៌មានរូប មិនគួរនិយាយថា ជារូបជីវិតិន្ទ្រិយទេឬ ។ អើ ។ អាយុនៃពួកធម៌មិនមានរូប មិនគួរនិយាយថា ជាអរូប-ជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៥ ] អាយុនៃពួកធម៌មានរូប ជាអរូបជីវិតិន្ទ្រិយឬ ។ អើ ។ អាយុនៃពួកធម៌មិនមានរូប ជារូបជីវិតិន្ទ្រិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៦ ] អាយុនៃពួកធម៌មិនមានរូប មិនគួរនិយាយថា ជារូបជីវិ-តិន្ទ្រិយទេឬ ។ អើ ។ អាយុនៃពួកធម៌មានរូប មិនគួរនិយាយថា ជាអរូប-ជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៧ ] អាយុនៃពួកធម៌មានរូប និងពួកធម៌មិនមានរូប ជាអរូប-ជីវិតិន្ទ្រិយឬ ។ អើ ។ អាយុនៃពួកធម៌មានរូប និងពួកធម៌មិនមានរូប ជារូបជីវិតិន្ទ្រិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៨ ] អាយុនៃពួកធម៌មានរូប និងពួកធម៌មិនមានរូប មិនគួរនិយាយថា ជារូបជីវិតិន្ទ្រិយទេឬ ។ អើ ។ អាយុនៃពួកធម៌មានរូប និងពួកធម៌មិនមានរូប មិនគួរនិយាយថា ជាអរូបជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤៩ ] រូបជីវិតិន្ទ្រិយ មិនមានទេឬ ។ អើ ។ ជីវិតិន្ទ្រិយរបស់បុគ្គលចូលកាន់និរោធ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥០ ] ជីវិតិន្ទ្រិយ របស់បុគ្គលចូលកាន់និរោធ មានឬ ។ អើ ។ ប្រសិនបើ ជីវិតិន្ទ្រិយរបស់បុគ្គលចូលកាន់និរោធ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជីវិតិន្ទ្រិយ មិនមានទេ ។

[ ៨៥១ ] ជីវិតិន្ទ្រិយ របស់បុគ្គលចូលកាន់និរោធមានឬ ។ អើ ។ ជីវិតិន្ទ្រិយរាប់បញ្ចូលក្នុងខន្ធដូចម្តេច ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធរបស់បុគ្គលចូលកាន់និរោធ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធរបស់បុគ្គលចូលកាន់និរោធ មានឬ ។ អើ ។ វេទនាខន្ធ ។បេ។ សញ្ញាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ របស់បុគ្គលចូលកាន់និរោធ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥២ ] វេទនាខន្ធ ។បេ។ សញ្ញាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ របស់បុគ្គលចូលកាន់និរោធ មានឬ ។ អើ ។ បុគ្គលចូលកាន់និរោធ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥៣ ] រូបជីវិតិន្ទ្រិយ មិនមានទេឬ ។ អើ ។ ជីវិតិន្ទ្រិយរបស់ពួកអសញ្ញសត្វ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជីវិតិន្ទ្រិយរបស់ពួកអសញ្ញសត្វ មានឬ ។ អើ ។ ប្រសិនបើ ជីវិតិន្ទ្រិយរបស់ពួកអសញ្ញសត្វ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជីវិតិន្ទ្រិយ មិនមានទេ ។

[ ៨៥៤ ] ជីវិតិន្ទ្រិយ របស់ពួកអសញ្ញសត្វ មានឬ ។ អើ ។ ជីវិ-តិន្ទ្រិយរាប់បញ្ចូលក្នុងខន្ធដូចម្ដេច ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធរបស់ពួកអសញ្ញសត្វ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខា-រក្ខន្ធរបស់ពួកអសញ្ញសត្វ មានឬ ។ អើ ។ វេទនាខន្ធ ។បេ។ សញ្ញាខន្ធ ។បេ។ វិញ្ញាណក្ខន្ធរបស់ពួកអសញ្ញសត្វ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនាខន្ធ ។បេ។ សញ្ញាខន្ធ ។បេ។ វិញ្ញាណក្ខន្ធរបស់ពួកអសញ្ញសត្វ មានឬ ។ អើ ។ គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥៥ ] ជីវិតិន្ទ្រិយ តាំងឡើងដោយចិត្តដែលកំពុងស្វែងរកកំណើត កាលចិត្តដែលកំពុងស្វែងរកកំណើត បែកធ្លាយទៅ ជីវិតិន្ទ្រិយ ជាចំណែកបែកធ្លាយទៅឬ ។ អើ ។ ផស្សៈ តាំងឡើងដោយចិត្តដែលកំពុងស្វែងរកកំណើត កាលចិត្តដែលកំពុងស្វែងរកកំណើតបែកធ្លាយទៅ ផស្សៈ ជាចំណែកបែកធ្លាយទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥៦ ] ផស្សៈ តាំងឡើងដោយចិត្តដែលកំពុងស្វែងរកកំណើត កាលចិត្តដែលកំពុងស្វែងរកកំណើតបែកធ្លាយទៅ ផស្សៈ ឥតសេសសល់ បែកធ្លាយទៅឬ ។ អើ ។ ជីវិតិន្ទ្រិយតាំងឡើងដោយចិត្តដែលកំពុងស្វែងរកកំណើត កាលចិត្តដែលកំពុងស្វែងរកកំណើតបែកធ្លាយទៅ ជីវិតិន្ទ្រិយឥតសេសសល់ បែកធ្លាយទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥៧ ] ជីវិតិន្ទ្រិយ មាន ២ ឬ ។ អើ ។ សត្វរស់នៅដោយជីវិត ២ ស្លាប់ទៅដោយមរណៈ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ជីវិតិន្ទ្រិយកថា ចប់

# អដ្ឋកថា

## ជីវិតិន្ទ្រិយកថា

[ ៨៤០ ] ឥឡូវនេះ នឹងពណ៌នាអំពីជីវិតិន្ទ្រិយដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយសមិតិយៈទាំងឡាយថា ឈ្មោះថា ជីវិតិន្ទ្រិយ ជាធម៌មិនមានរូប មិនប្រកបជាមួយចិត្ត ព្រោះហេតុនោះ ទើបរូបជីវិតិន្ទ្រិយមិនមាន ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

ក្នុងបញ្ហាថា **នត្ថិ រូបីនំ ធម្មានំ អាយុ** អធិប្បាយថា បរវាទីនោះរមែងកាន់យកថា អាយុ ការតាំងនៅ ការរស់នៅ ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សា គឺប្រព្រឹត្តទៅដោយអំណាចនៃការបន្តនៃឧបាទិន្នរូបខ្លះ នៃអនុបាទិន្នរូប មានស្មៅ និងដើមឈើជាដើមខ្លះ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាថា **អត្ថិ** ក៏ឆ្លើយទទួលដោយហេតុនេះ ។

[ ៨៤១ ] ក្នុងបញ្ហាថា **អត្ថិ អរូបជីវិតិន្ទ្រិយំ** បរវាទីកាន់យកថា ឈ្មោះថា ការបន្តនៃជីវិតិន្ទ្រិយ ដែលមិនប្រកបជាមួយចិត្តនៃអរូបធម៌ទាំងឡាយ មាន ព្រោះហេតុនោះ ទើបឆ្លើយទទួល ។

[ ៨៤៥ ] ក្នុងបញ្ហាថា **រូបីនំ ធម្មានំ អាយុ អរូបជីវិតិន្ទ្រិយំ** អធិប្បាយថា ជីវិតិន្ទ្រិយដែលជារូបធម៌ក្តី ដែលជាអរូបធម៌ក្តី មានក្នុង

សន្តាននៃសត្វ បរវាទីរមែងកាន់យកចំពោះអរូបជីវិតិន្ទ្រិយ ដែលមិនប្រកប ជាមួយចិត្ត នៃសត្វទាំងពួង ព្រោះហេតុនោះ ទើបឆ្លើយទទួល ។

[ ៨៤៩-៨៥០ ] ក្នុងបញ្ហា ពោលដោយបុគ្គលចូលនិរោធសមាបត្តិ បរវាទីសំដៅយកអរូបជីវិតិន្ទ្រិយ ដែលមិនប្រកបជាមួយចិត្តនោះឯង ទើបឆ្លើយបដិសេធខ្លះ ឆ្លើយទទួលខ្លះ ។ ឯសកវាទី កាលមិនព្រមទទួលពាក្យឆ្លើយនោះ ទើបពោលថា **ហញ្ចិ** ជាដើម ដើម្បីចោទសួរថា កាលអរូបមិនប្រព្រឹត្តទៅ វត្ថុណាមាន វត្ថុនោះ គប្បីជារូប ។

[ ៨៥១-៨៥២ ] ក្នុងបញ្ហាពោលដោយសង្ខារក្ខន្ធ បរវាទីសំដៅយកសង្ខារក្ខន្ធ មានផស្សៈជាដើម ទើបឆ្លើយបដិសេធ តែសំដៅយកសង្ខារក្ខន្ធមានកាយកម្មជាដើម ទើបឆ្លើយទទួល ។ លទ្ធិរបស់បរវាទីថា ធម៌ទាំងឡាយមានកាយវិញ្ញត្តិ វចីវិញ្ញត្តិ សម្មាវាចា សម្មាកម្មន្ត: និងជីវិតិន្ទ្រិយជាដើម ជាធម៌ទាក់ទងដោយសង្ខារក្ខន្ធ ដូច្នេះ ។ តែសកវាទី កាលមិនព្រមទទួលពាក្យឆ្លើយនោះ ក៏ពោលថា **អត្ថិ វេទនាក្ខន្ធោ** ជាដើម ដើម្បីចោទសួរថា បើការប្រព្រឹត្តទៅនៃអរូប សូម្បីលត់ទៅហើយ សង្ខារក្ខន្ធនៅមានសោតនាមក្ខន្ធទាំង ៤ ក៏ត្រូវមាន ដូច្នេះ ។ បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកខាងក្នុងសមាបត្តិ រមែងឆ្លើយទទួល ព្រោះសំដៅយកខាងដើមរបស់បុគ្គលដែលចូលសមាបត្តិ និងចំណែកខាងចុង របស់បុគ្គលដែលចេញអំពីសមាបត្តិ ។

[ ៨៥៣-៨៥៤ ] ក្នុងវារៈពោលដោយអសញ្ញសត្វ ក៏មានន័យដូច្នេះ

ឯង ៗ ពិតហើយ តាមលទ្ធិនោះថា ក្នុងបដិសន្ធិកាលនៃអសញ្ញសត្វទាំងឡាយ ចិត្តកើតឡើងហើយ ក៏រលត់ទៅ អរូបជីវិតិន្ទ្រិយដែលមិនប្រកបជាមួយចិត្ត កើតឡើងហើយជាមួយចិត្តនោះ ក៏ប្រព្រឹត្តទៅ ដរាបដល់អស់អាយុ ព្រោះហេតុនោះ កាលត្រូវសកវាទីសួរថា អសញ្ញសត្វទាំងឡាយ មិនមានជីវិតិន្ទ្រិយឬ ក៏ឆ្លើយបដិសេធ ៗ ត្រូវសួរថា មានជីវិតិន្ទ្រិយឬ ក៏ឆ្លើយទទួល ៗ រមែងបដិសេធនូវវេទនាខន្ធជាដើម ដោយអំណាចនៃបវត្តិកាលរបស់អសញ្ញសត្វទាំងនោះ រមែងឆ្លើយទទួលដោយអំណាចនៃបដិសន្ធិកាលរបស់អសញ្ញសត្វទាំងនោះ ៗ សកវាទី កាលមិនកាន់យកពាក្យដែលឆ្លើយនោះ ទើបពោលថា **បញ្ចវោការភវោ** ជាដើម ដើម្បីចោទសួរថា បើក្នុងអសញ្ញសត្វទាំងនោះ មានវេទនាជាដើម ត្រឹមតែខណៈមួយសោតអសញ្ញសត្វនោះ ក៏នឹងដល់នូវភាពជាបញ្ចវោការភព ៗ បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ ៗ

[ ៨៥៥ ] ក្នុងបញ្ហាថា **ឯកាភេសំ ភិជ្ជតិ** អធិប្បាយថា លទ្ធិរបស់បរវាទីនោះថា ធម៌ដែលសម្បយុត្ត រមែងបែកធ្លាយទៅ តែធម៌ដែលវិប្បយុត្ត

រមែងតាំងនៅ ព្រោះហេតុនោះ ទើបឆ្លើយទទួល ។

[ ៨៥៧ ] ពាក្យសួររបស់បរវាទីថា **ទ្វេ ជីវិតិន្ទ្រិយានិ** ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ។ ពិតហើយ ជីវិតិន្ទ្រិយមាន ២ យ៉ាង គឺ រូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយ ទើបលោកពោលថា សត្វរមែងប្រព្រឹត្តទៅដោយជីវិត ២ យ៉ាងនោះឯង រមែងស្លាប់ព្រោះការបែកធ្លាយនៃជីវិត ២ យ៉ាងនោះ ។ ក្នុងចុតិក្ខណៈ ជីវិតទាំង ២ រមែងបែកធ្លាយព្រមគ្នានោះឯង ដូច្នេះ ។l៙

## អដ្ឋកថាជីវិតិន្ទ្រិយកថា ចប់

# អភិធម្មបិដក

## កម្មហេតុកថា

[ ៨៥៨ ] ព្រះអរហន្ត សាបសូន្យចាកព្រះអរហត្ត ព្រោះហេតុនៃកម្មឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ព្រោះហេតុនៃកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកព្រះអរហត្ត ព្រោះហេតុនៃកម្មឬ ។ អើ ។ សកទាគាមិបុគ្គល ។បេ។ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផល ព្រោះហេតុនៃកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥៩ ] សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផល ព្រោះហេតុនៃកម្មទេឬ ។ អើ ។ ព្រះអរហន្ត មិនសាបសូន្យចាកព្រះអរហត្ត ព្រោះហេតុនៃកម្មទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល ។បេ។ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផល ព្រោះហេតុនៃកម្មទេឬ ។ អើ ។ ព្រះអរហន្ត មិនសាបសូន្យចាកព្រះអរហត្ត ព្រោះហេតុនៃកម្មទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៦០ ] ព្រះអរហន្ត សាបសូន្យចាកព្រះអរហត្ត ព្រោះហេតុនៃកម្មឬ ។ អើ ។ ( សាបសូន្យ ) ព្រោះហេតុនៃបាណាតិបាតកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( សាបសូន្យ ) ព្រោះហេតុនៃអទិន្នាទានកម្ម ។បេ។ ព្រោះហេតុនៃកាមេសុមិច្ឆាចារកម្ម ព្រោះហេតុនៃមុសាវាទកម្ម ព្រោះហេតុនៃបិសុណាវាចាកម្ម ព្រោះហេតុនៃផរុសវាចាកម្ម ព្រោះហេតុនៃសម្ផប្បលាប-

កម្ម ព្រោះហេតុនៃមាតុឃាតកកម្ម ព្រោះនៃបិតុឃាតកកម្ម ព្រោះហេតុនៃអរហន្តឃាតកកម្ម ព្រោះហេតុនៃរុហិរុប្បាទកម្ម ព្រោះហេតុនៃសង្ឃភេទកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( សាបសូន្យ ) ព្រោះហេតុនៃកម្ម ដូចម្ដេច ។ បើដូច្នោះ មានតែបុគ្គលពោលបង្កាច់ព្រះអរហន្ត ។ ព្រះអរហន្តសាបសូន្យចាកព្រះអរហត្ត ព្រោះហេតុនៃកម្ម គឺការពោលបង្កាច់នូវព្រះអរហន្តឬ ។ អើ ។ បុគ្គលណាមួយ ពោលបង្កាច់ព្រះអរហន្ត បុគ្គលទាំងអស់នោះ ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

កម្មហេតុកថា ចប់

អដ្ឋមវគ្គ ចប់

## ឧទ្ទាននៃអដ្ឋមវគ្គនោះ គឺ

និយាយអំពីគតិ ៦ យ៉ាង ១ អន្តរាភព ១ កាមគុណ ៥ ជាកាមធាតុ ១ អាយតនៈ ៥ ជាកាម ១ ពួកធម៌មានរូប ជារូបធាតុ ១ ពួកធម៌មិនមានរូប ជាអរូបធាតុ ១ អត្តភាព ប្រកបដោយអាយតនៈ ៦ ក្នុងពួករូបធាតុ ១ រូបក្នុងអរូប ១ រូបជាកម្ម ១ រូបជីវិតិន្ទ្រិយ ១ ( ព្រះអរហន្ត ) សាបសូន្យ ( ចាកព្រះអរហត្ត ) ព្រោះហេតុនៃកម្ម ។

# អដ្ឋកថា

## កម្មហេតុកថា

[ ៨៥៨ ] *ឥឡូវនេះ នឹងពណ៌នាអំពីហេតុនៃកម្មដូចតទៅ*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយសមិតិយៈទាំងឡាយថា ព្រះអរហន្តអង្គណាធ្លាប់ពោលបង្កាច់ព្រះអរហន្ត ក្នុងភពមុន ព្រះអរហន្តអង្គនោះ រមែងសាបសូន្យចាកភាពជាព្រះអរហន្ត ព្រោះកម្មនោះជាហេតុ ដូច្នេះ ពាក្យសួររបស់សកវាទីថា* **កម្មហេតុ** *សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស មានន័យដូចពាក្យដែលពោលក្នុងបរិហានិកថានោះឯង ។*

[ ៨៦០ ] *បទថា* **ហន្ទ ហិ អរហន្តានំ អព្ភាចិក្ខតិ** *សេចក្តីថា ភាពជាព្រះអរហន្ត រមែងសាបសូន្យព្រោះហេតុនៃកម្មណា បរវាទីពោលពាក្យនេះ ដើម្បីឲ្យសកវាទីព្រមទទួលនូវកម្មនោះ ។ ពេលនោះ សកវាទី ញុំាងបរវាទីនោះ ឲ្យទទួលនូវចំណែកនោះហើយ ទើបពោលថា* **យេ កេចិ** *ជាដើម ដើម្បីចោទសួរថា បើជនទាំងឡាយណា គប្បីជាបុគ្គលពោលបង្កាច់ព្រះអរហន្តយ៉ាងនេះសោត ជនទាំងឡាយនោះ គប្បីសម្រេចជាព្រះអរហន្តបាន ឬ ។ បរវាទី កាលមិនឃើញនិយាម ក្នុងការសម្រេចភាពជាព្រះអរហន្ត ដោយកម្មនោះ ទើបឆ្លើយបដិសេធ ។*

**អដ្ឋកថាកម្មហេតុកថា ចប់**

**វគ្គទី ៨ ចប់**

# អភិធម្មបិដក

## អានិសំសកថា

[ ៨៦១ ] ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្សប្រុ ។ អើ ។ ព្រោះបុគ្គលកាលធ្វើទុកក្នុងចិត្ត នូវសង្ខារទាំងឡាយថាជារបស់មិនទៀង ទើបលះបង់ពួកសញ្ញោជនៈឬ ។ អើ ។ ប្រសិនបើ បុគ្គលធ្វើទុកក្នុងចិត្ត នូវសង្ខារទាំងឡាយ ថាជារបស់មិនទៀង ទើបលះបង់ពួកសញ្ញោជនៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្សទេ ។បេ។ ព្រោះបុគ្គលកាលធ្វើទុកក្នុងចិត្ត នូវសង្ខារទាំងឡាយ ថាជាទុក្ខ ។បេ។ ថាជារោគ ថាជាពក ថាជាកូនសរ ថាជាអន្តរាយ ថាជាអាពាធ ថាជារបស់ដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់ចង្រៃ ថាជារបស់ឧបទ្រព ថាជាភ័យ ថាជាឧបសគ្គ ថាជារបស់ញាប់ញ័រ ថាជារបស់ពុកផុយ ថាជារបស់មិនទៀង ថាជារបស់មិនមានទីពឹង ថាជារបស់មិនមានទីជ្រកកោន ថាជារបស់មិនមានទីរឭក ថាជាសភាពមិនមានទីរឭក ថាជារបស់តិចតួច ថាជារបស់ទទេ ថាជារបស់សូន្យ ថាមិនមែនជារបស់ខ្លួន ថាជាទោស ។បេ។ ថាជារបស់ប្រែប្រួលជាធម្មតា ទើបលះបង់ពួកសញ្ញោជនៈឬ ។ អើ ។ ប្រសិនបើ បុគ្គលកាលធ្វើទុកក្នុងចិត្តនូវសង្ខារទាំងឡាយ ថាជារបស់ប្រែប្រួលជាធម្មតា ទើបលះបង់ពួកសញ្ញោជនៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្សទេ ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវសង្ខារទាំងឡាយ ថាជា

របស់មិនទៀង ឃើញអានិសង្ស ក្នុងព្រះនិព្វានផងឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវសង្ខារទាំងឡាយ ថាជារបស់មិនទៀង ឃើញអានិសង្ស ក្នុងព្រះនិព្វានផងឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវសង្ខារទាំងឡាយ ថាជាទុក្ខ ។បេ។ ថាជារោគ ។បេ។ ថាជារបស់ប្រែប្រួលជាធម្មតាផង ឃើញអានិសង្ស ក្នុងព្រះនិព្វានផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្តនូវសង្ខារទាំងឡាយ ថាជារបស់ប្រែប្រួលជាធម្មតាផង ឃើញអានិសង្ស ក្នុងព្រះនិព្វានផងឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៦២ ] បុគ្គលមិនគួរនិយាយថា ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្សទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរឿយៗ នូវសេចក្ដីសុខក្នុងព្រះនិព្វាន មានសេចក្ដីសម្គាល់ថាជាសុខ ទទួលសេចក្ដីសុខ ជឿស៊ប់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ ញឹកញាប់ មិនដាច់ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្ស ។

## អានិសំសកថា ចប់

# អដ្ឋកថា

## អានិសំសទស្សាវីកថា

[ ៨៦១ ] ឥឡូវនេះ នឹងពណ៌នាអំពីអានិសង្សដូចតទៅ

ក្នុងរឿងនោះ ការដាក់ចិត្ត ក្នុងលទ្ធិរបស់សកវាទីថា ការលះសញ្ញោជនៈ រមែងមានដល់បុគ្គលឃើញសង្ខារទាំងឡាយ ដោយភាពជាទោស និងឃើញព្រះនិព្វានដោយភាពជាអានិសង្ស ដូច្នេះ ជនទាំងឡាយណាមានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ការលះសញ្ញោជនៈ រមែងមានដល់បុគ្គលអ្នកឃើញអានិសង្ស ( ក្នុងព្រះនិព្វាន ) ប៉ុណ្ណោះ ព្រោះកាន់យកវាទៈត្រឹមតែម្ខាង ក្នុងវាទៈ ២ នោះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គ្រានោះ ទើបសកវាទីពោលពាក្យថា **សង្ខារេ** ជាដើម ដល់បរវាទីនោះ ដើម្បីសម្តែងការបែកថា វាទៈតែម្ខាងនោះ ដែលអ្នកកាន់យកហើយ សូម្បីភាពជាទោសក្នុងសង្ខារទាំងឡាយ អ្នកក៏គប្បីឃើញផងដែរ ។

ក្នុងបញ្ហាថា **សង្ខារេ ច អនិច្ចតោ មនសិករោតិ និព្វានេ ច អានិសំសទស្សាវី ហោតិ** គប្បីជ្រាបអធិប្បាយដូចតទៅនេះ លទ្ធិរបស់បរវាទីទាំងនោះថា ការលះសញ្ញោជនៈ រមែងមានដល់បុគ្គលដែលឃើញអានិសង្សក្នុងព្រះនិព្វាន ដូច្នេះ ត្រូវសកវាទីសួរថា បុគ្គលមនសិការនូវសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀង លះសញ្ញោជនៈបាន មិនមែនឬ បរវាទីឆ្លើយទទួលថា **អាមន្តា** ។ ដោយហេតុនោះ ពាក្យនេះ របស់អ្នកថា បុគ្គល

មនសិការនូវសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងផង ជាអ្នកឃើញអានិសង្សក្នុងព្រះនិព្វានផង ដូច្នេះ រមែងត្រឹមត្រូវ ពាក្យនេះ អ្នកទទួលឬ លំដាប់នោះ ទើបបរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកត្រឹមខណៈចិត្ត ១ ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួលដោយអំណាចនៃចិត្តផ្សេងៗ ។ សកវាទីរួបរួមពាក្យអធិប្បាយរបស់បរវាទីនោះហើយ ទើបសួរថា **ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតិ** ព្រោះភាពនៃបុគ្គលដែលមនសិការសង្ខារដោយភាពជារបស់មិនទៀង និងភាពជាអ្នកឃើញអានិសង្សព្រះនិព្វាន ដែលបរវាទីឆ្លើយបញ្ញត្តិដូចគ្នាតែមួយ ។ បរវាទីកាលមិនឃើញការប្រជុំគ្នានៃផស្សៈ ២ យ៉ាងជាដើម ទើបឆ្លើយបដិសេធ ។ សូម្បីក្នុងបញ្ហា មានពាក្យថា **ទុក្ខតោ** ក៏ន័យនោះឯង ។

ក្នុងសេចក្តីនេះ មានការសន្និដ្ឋានដូចម្តេច គឺបុគ្គលដែលមនសិការសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម រមែងលះសំយោជនៈទាំងឡាយបានឬ ឬបុគ្គលអ្នកឃើញអានិសង្សក្នុងព្រះនិព្វាន ឬបុគ្គលអ្នកធ្វើ សូម្បីទាំង ២ យ៉ាងរួមគ្នា រមែងលះសំយោជនៈបាន ។ បើការលះសំយោជនៈ គប្បីមានដល់បុគ្គលដែលមនសិការសង្ខារ ដោយភាពជារបស់មិនទៀងជាដើមមុនសោត ការលះនេះ ក៏គប្បីមានដោយវិបស្សនាចិត្តប៉ុណ្ណោះ បើការលះសំយោជនៈ គប្បីមានដល់បុគ្គលដែលមានប្រក្រតីឃើញអានិសង្សសោត ការលះនោះ ក៏គប្បីមានដោយវិបស្សនាចិត្ត របស់អ្នកឃើញនូវអានិសង្សក្នុងព្រះនិព្វាន ដោយអំណាចការស្តាប់ពាក្យប្រៀនប្រដៅនោះឯង

បើការលះសំយោជនៈ គប្បីមានដល់បុគ្គលដែលធ្វើទាំង ២ យ៉ាង រួមគ្នា សោត ការប្រជុំនៃផស្សៈ ២ យ៉ាងជាដើម ក៏គប្បីមាន ។ ទោះបីជាយ៉ាងនេះក្តី ព្រោះកិច្ចរបស់បុគ្គលដែលមនសិការសង្ខារ ដោយភាពជារបស់មិនទៀងជាដើម ការឃើញអានិសង្សក្នុងព្រះនិព្វានរមែងសម្រេច សកវាទីរមែងត្រូវការឃើញអានិសង្សក្នុងព្រះនិព្វាន ដោយភាពដែលការប្រកាន់សង្ខារទាំងឡាយ ដោយភាពជារបស់ទៀងជាដើម ជាធម៌ដែលមិនកើតឡើងទៀត និងដោយប្រចក្សក្នុងព្រះនិព្វាននោះឯង ហេតុនោះ បណ្ឌិតគប្បីជ្រាបថា ការលះសំយោជនៈទាំងឡាយ រមែងមានដល់បុគ្គលដែលឃើញអានិសង្សក្នុងព្រះនិព្វាន ដោយអំណាចនៃការឲ្យសម្រេចកិច្ច ក្នុងខណៈនៃអរិយមគ្គផង ដោយអំណាចនៃការប្រព្រឹត្តទៅ ព្រោះធ្វើឲ្យជាអារម្មណ៍របស់បុគ្គលមនសិការសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើមផង ។

[ ៨៦២ ] ព្រះសូត្រថា **និព្វានេ សុខានុបស្សី** ជាដើម រមែងឲ្យសម្រេចនូវភាវៈ ពិចារណាឃើញថា ជាសុខក្នុងព្រះនិព្វានជាដើម មិនមែនឲ្យសម្រេចការលះសំយោជនៈទាំងឡាយ ដោយត្រឹមតែការឃើញអានិសង្សក្នុងព្រះនិព្វានប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះសូត្រ សូម្បីបរវាទីនាំមកអាងហើយ ក៏ដូចជាមិនបាននាំមកអាងនោះឯង ដូច្នេះ ។

**អដ្ឋកថាអានិសំសទស្សាវីកថា ចប់**

# អភិធម្មបិដក

## អមតារម្មណកថា

[ ៨៦៣ ] សញ្ញោជនៈ មានអមតជាអារម្មណ៍ឬ ។ អើ ។ ( បើដូច្នោះ ) អមតៈ ( និព្វាន ) ជាទីតាំងនៃសញ្ញោជនៈ ជាទីតាំងនៃគន្ថៈ ជាទីតាំងនៃឱឃៈ ជាទីតាំងនៃយោគៈ ជាទីតាំងនៃនីវរណៈ ដែលតណ្ហាស្ទាបអង្អែល ជាទីតាំងនៃឧបាទាន គួរដល់សេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអមតៈ មិនជាទីតាំងនៃសញ្ញោជនៈ មិនជាទីតាំងនៃគន្ថៈ ។បេ។ មិនគួរដល់សេចក្តីសៅហ្មងទេឬ ។ អើ ។ ប្រសិនបើ អមតៈ មិនជាទីតាំងនៃសញ្ញោជនៈ ។បេ។ មិនគួរដល់សេចក្តីសៅហ្មងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈ មានអមតៈ ជាអារម្មណ៍ទេ ។

[ ៨៦៤ ] រាគៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងឬ ។ អើ ។ ( បើដូច្នោះ ) អមតៈ ជាទីតាំងនៃរាគៈ ជាទីតាំងនៃតម្រេក ជាទីតាំងនៃសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីស្រវឹង ជាទីតាំងនៃចំណង ជាទីតាំងនៃសេចក្តីវង្វេងជ្រប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអមតៈ មិនជាទីតាំងនៃរាគៈ មិនជាទីតាំងនៃតម្រេក មិនជាទីតាំងនៃសេចក្តីប្រាថ្នា មិនជាទីតាំងនៃសេចក្តីស្រវឹង មិនជាទីតាំងនៃចំណង មិនជាទីតាំងនៃសេចក្តីវង្វេងជ្រប់ទេឬ ។ អើ ។ ប្រសិនបើ អមតៈ មិនជាទីតាំងនៃរាគៈ មិនជាទីតាំងនៃតម្រេក មិនជាទីតាំងនៃសេចក្តីប្រាថ្នា មិនជាទីតាំងនៃសេចក្តីស្រវឹង មិនជាទីតាំងនៃចំណង មិនជាទីតាំងនៃសេចក្តីវង្វេងជ្រប់ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា

រាគៈ ប្រារព្ធអមតៈ ទើបកើតឡើងទេ ។

[ ៨៦៥ ] ទោសៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងឬ ។ អើ ។ ( បើដូច្នោះ ) អមតៈ ជាទីតាំងនៃទោសៈ ជាទីតាំងនៃសេចក្តីក្រោធ ជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអមតៈ មិនជាទីតាំងនៃទោសៈ មិនជាទីតាំងនៃសេចក្តីក្រោធ មិនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេឬ ។ អើ ។ ប្រសិនបើ អមតៈ មិនជាទីតាំងនៃទោសៈ មិនជាទីតាំងនៃសេចក្តីក្រោធ មិនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទោសៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងទេ ។

[ ៨៦៦ ] មោហៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងឬ ។ អើ ។ ( បើដូច្នោះ ) អមតៈ ជាទីតាំងនៃមោហៈ ជាទីធ្វើមិនឲ្យមានញាណ ជាទីធ្វើមិនឲ្យមានចក្ខុ ជាទីតាំងនៃការរលត់បញ្ញា ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីនិព្វានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអមតៈ មិនជាទីតាំងនៃមោហៈ មិនជាទីធ្វើមិនឲ្យមានញាណ មិនជាទីធ្វើមិនឲ្យមានចក្ខុ ជាទីតាំងនៃសេចក្តីចម្រើនបញ្ញា មិនជាចំណែកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីនិព្វានឬ ។ អើ ។ ប្រសិនបើ អមតៈ មិនជាទីតាំងនៃមោហៈ មិនជាទីធ្វើឲ្យមានញាណ ។បេ។ ប្រព្រឹត្តទៅ ដើម្បីនិព្វានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មោហៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងទេ ។

[ ៨៦៧ ] សញ្ញោជនៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប ជាទីតាំងនៃ

សញ្ញោជនៈ ជាទីតាំងនៃគន្ថៈ ។បេ។ គួរដល់សេចក្ដីសៅហ្មងឬ ។ អើ ។ សញ្ញោជនៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ ជាទីតាំងនៃសញ្ញោជនៈ ជាទីតាំងនៃគន្ថៈ ។បេ។ គួរដល់សេចក្ដីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៦៨ ] រាគៈ ប្រារព្ធនូវរូប ទើបកើតឡើង រូបជាទីតាំងនៃរាគៈ ជាទីតាំងនៃតម្រេក ជាទីតាំងនៃសេចក្ដីប្រាថ្នា ជាទីតាំងនៃសេចក្ដីស្រវឹង ជាទីតាំងនៃចំណង ជាទីតាំងនៃសេចក្ដីវង្វេងជ្រប់ឬ ។ អើ ។ រាគៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ ជាទីតាំងនៃរាគៈ ។បេ។ ជាទីតាំងនៃសេចក្ដីវង្វេងជ្រប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៦៩ ] ទោសៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប ជាទីតាំងនៃទោសៈ ជាទីតាំងនៃសេចក្ដីក្រោធ ជាទីតាំងនៃសេចក្ដីថ្នាំងថ្នាក់ឬ ។ អើ ។ ទោសៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ ជាទីតាំងនៃទោសៈ ជាទីតាំងនៃសេចក្ដីក្រោធ ជាទីតាំងនៃសេចក្ដីថ្នាំងថ្នាក់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧០ ] មោហៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប ជាទីតាំងនៃមោហៈ ជាទីធ្វើមិនឲ្យមានញាណ ។បេ។ មិនប្រព្រឹត្តទៅ ដើម្បីនិព្វានទេឬ ។ អើ ។ មោហៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ ជាទីតាំងនៃមោហៈ ជាទីធ្វើមិនឲ្យមានញាណ ។បេ។ មិនប្រព្រឹត្តទៅ ដើម្បីនិព្វានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧១ ] ពួកសញ្ញោជនៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ

មិនជាទីតាំងនៃសញ្ញោជនៈ មិនទីតាំងនៃគន្ថៈ មិនជាទីតាំងនៃឱឃៈ មិនជាទីតាំងនៃយោគៈ មិនជាទីតាំងនៃនីវរណៈ ដែលតណ្ហាមិនស្ទាបអង្អែល មិនជាទីតាំងនៃឧបាទាន មិនគួរដល់សេចក្តីសៅហ្មងទេឬ ។ អើ ។ ពួកសញ្ញោជនៈប្រារព្ធនូវរូប ទើបកើតឡើង រូប មិនជាទីតាំងនៃសញ្ញោជនៈ មិនជាទីតាំងនៃគន្ថៈ ។បេ។ មិនគួរដល់សេចក្តីសៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧២ ] រាគៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ មិនជាទីតាំងនៃរាគៈ មិនជាទីតាំងនៃតម្រេក មិនជាទីតាំងនៃសេចក្តីប្រាថ្នា មិនជាទីតាំងនៃសេចក្តីស្រើង មិនជាទីតាំងនៃចំណង មិនជាទីតាំងនៃសេចក្តីវង្វេងជ្រប់ទេឬ ។ អើ ។ រាគៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប មិនជាទីតាំងនៃរាគៈ ។បេ។ មិនជាទីតាំងនៃសេចក្តីវង្វេងជ្រប់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧៣ ] ទោសៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ មិនជាទីតាំងនៃទោសៈ មិនជាទីតាំងនៃសេចក្តីក្រោធ មិនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេឬ ។ អើ ។ ទោសៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប មិនជាទីតាំងនៃទោសៈ មិនជាទីតាំងនៃសេចក្តីក្រោធ មិនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧៤ ] មោហៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ មិនជាទីតាំងនៃមោហៈ មិនជាទីធ្វើមិនឲ្យមានញាណ ។បេ។ ជាធម្មជាតប្រព្រឹត្តទៅដើម្បីព្រះនិព្វានឬ ។ អើ ។ មោហៈ ប្រារព្ធនូវរូប ទើបកើតឡើង រូបមិនជាទី

តាំងនៃមោហៈ មិនជាទីធ្វើមិនឲ្យមានញាណ ។បេ។ ជាធម្មជាតប្រព្រឹត្តទៅដើម្បីព្រះនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧៥ ] បុគ្គលមិនគួរនិយាយថា សញ្ញោជនៈ មានអមតៈជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដឹងច្បាស់នូវនិព្វាន ថាជានិព្វាន លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានហើយ តែងសម្គាល់នូវនិព្វាន សម្គាល់ក្នុងនិព្វាន សម្គាល់ថាជានិព្វាន សម្គាល់ថានិព្វានជារបស់អញ ត្រេកអរនឹងព្រះនិព្វាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សញ្ញោជនៈ មានអមតៈជាអារម្មណ៍ ។

អមតារម្មណកថា ចប់

# អដ្ឋកថា

## អមតារម្មណកថា

[ ៨៦៣ ] ឥឡូវនេះ នឹងពណ៌នាអំពីសំយោជនៈ មានអមតៈជាអារម្មណ៍ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា សំយោជនៈ មានអមតៈជាអារម្មណ៍បាន ព្រោះកាន់យកដោយមិនពិចារណានូវអត្ថនៃបទទាំងឡាយថា បុថុជ្ជន សម្គាល់ព្រះនិព្វានជាដើម ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទី ពោលនឹងបរវាទីថា **អមតំ សំយោជនិយំ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា ប្រសិនបើសំយោជនៈ មានអមតៈជាអារម្មណ៍បានសោត អមតៈ ក៏ត្រូវប្រាកដថា ជាអារម្មណ៍របស់សំយោជនៈជាដើមបាន ។ បរវាទី ឆ្លើយបដិសេធពាក្យទាំងពួង ព្រោះខ្លាចខុសអំពីព្រះសូត្រ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងវារៈទាំងពួងដោយឧបាយនេះ ។

[ ៨៧៥ ] ព្រះសូត្រដែលបរវាទីលើកមកថា **និព្វានំ និព្វានតោ** នេះបរវាទីពោលសំដៅយកនិព្វានក្នុងទិដ្ឋធម៌ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនសម្រេចប្រយោជន៍ ដូច្នេះឯង ។ល។

**អដ្ឋកថាអមតារម្មណកថា ចប់**

# អភិធម្មបិដក

## រូបសារម្មណាទិកថា

[ ៨៧៦ ] រូប ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ការសង្ស៊ឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងចិត្តទុក មានចំពោះរូបនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងការពិចារណា ការសង្ស៊ឹម ។បេ។ ការតាំងចិត្តទុក មិនមានចំពោះរូបនោះទេឬ ។ អើ ។ ប្រសិនបើ ការពិចារណា ការសង្ស៊ឹម ។បេ។ ការតាំងចិត្តទុក មិនមានចំពោះរូបនោះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ប្រកបដោយអារម្មណ៍ទេ ។

[ ៨៧៧ ] ផស្សៈ ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស៊ឹម ។បេ។ ការតាំងចិត្តទុក មានចំពោះផស្សៈនោះឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស៊ឹម ។បេ។ ការតាំងចិត្តទុក មានចំពោះរូបនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧៨ ] វេទនា ។បេ។ សញ្ញា ចេតនា ចិត្ត សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។បេ។ អនោត្តប្បៈ ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស៊ឹម ។បេ។ ការតាំងចិត្តទុក មានចំពោះអនោត្តប្បៈនោះឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស៊ឹម ។បេ។ ការតាំងចិត្តទុក មានចំពោះរូបនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧៩ ] រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស័យ ។បេ។ ការតាំងចិត្តទុក មិនមានចំពោះរូបនោះទេឬ ។ អើ ។ ផស្សៈ ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស័យ ។បេ។ ការតាំងចិត្តទុក មិនមានចំពោះផស្សៈនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨០ ] រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស័យ ។បេ។ ការតាំងចិត្តទុក មិនមានចំពោះរូបនោះទេឬ ។ អើ ។ វេទនា សញ្ញា ។បេ។ អនោត្តប្បៈ ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ស័យ ។បេ។ ការតាំងចិត្តទុក មិនមានចំពោះអនោត្តប្បៈនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨១ ] បុគ្គល មិនគួរនិយាយថា រូប ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ក្រែងរូបប្រកបដោយបច្ច័យឬ ។ អើ ។ ប្រសិនបើ រូបប្រកបដោយបច្ច័យមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបប្រកបដោយអារម្មណ៍ដែរ ។

## រូបសារម្មណាន្តិកថា ចប់

# អដ្ឋកថា

## រូបសារម្មណាទិកថា

[ ៨៧៦ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបជាធម៌មានអារម្មណ៍ដូចតទៅ ក្នុងរឿងនោះ ពោលដោយអំណាចអារម្មណប្បច្ច័យថា រូប ឈ្មោះថា ជាធម៌មានអារម្មណ៍ ដោយអត្ថថា មានបច្ច័យ តែរូបនោះ ធ្វើធម៌ដទៃឲ្យជាអារម្មណ៍មិនបាន ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា រូប ជាធម៌មានអារម្មណ៍បាន ដោយមិនប្លែកគ្នាដូច្នេះ ។ ពាក្យសួររបស់សកវាទី ដើម្បីសម្តែងវិភាគារម្មណ៍ ២ យ៉ាង ( គឺ **ឱលុព្ភារម្មណំ** បានដល់ អារម្មណ៍ដែលជាគ្រឿងតោង និង **បច្ចយារម្មណំ** បានដល់ អារម្មណ៍ដែលជាបច្ច័យ ) សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយទំនងនៃព្រះបាលីនោះឯង ។

[ ៨៨១ ] ក្នុងបញ្ហាថា **ន វត្តព្វំ** ជាដើម ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី សំដៅយកឱលុព្ភារម្មណ៍ ។ ក្នុងបញ្ហាទី ២ សកវាទីនោះឆ្លើយទទួល សំដៅយកអារម្មណ៍ដែលជាបច្ច័យ ។ ព្រោះហេតុនោះ ក្នុងទីនេះ ភាពដែលរូបនោះ ជាធម្មជាតមានអារម្មណ៍សម្រេចហើយ ដោយអត្ថថា មានបច្ច័យប៉ុណ្ណោះ ដោយប្រការដូច្នេះ ។៙

**អដ្ឋកថារូបំសារម្មណាទិកថា ចប់**

# អភិធម្មបិដក

## អនុសយអនារម្មណាតិកថា

[ ៨៨២ ] អនុស័យ មិនមានអារម្មណ៍ទេឬ ។ អើ ។ ចុះ រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( មិនមានអារម្មណ៍ទេ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨៣ ] កាមរាគានុស័យ មិនមានអារម្មណ៍ទេឬ ។ អើ ។ ចុះកាម-រាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះកាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ កាមរាគានុស័យ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨៤ ] កាមរាគានុស័យ មិនមានអារម្មណ៍ទេឬ ។ អើ ។ ( កាម-រាគានុស័យ ) រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨៥ ] ចុះកាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អើ ។ កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ ដែលរាប់

បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៨៨៦ ] កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេ ចុះកាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨៧ ] បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ មិនមានអារម្មណ៍ទេឬ ។ អើ ។ អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជា មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា ។បេ។ នីវរណៈ គឺអវិជ្ជា ប្រកបដោយអារម្មណ៍ឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨៨ ] អវិជ្ជានុស័យ មិនមានអារម្មណ៍ទេឬ ។ អើ ។ ( អវិជ្ជានុស័យ ) រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ

មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨៩ ] អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អើ ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩០ ] អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេ ចុះអវិជ្ជាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ទេឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩១ ] បុគ្គលមិនគួរនិយាយថា អនុស័យ មិនមានអារម្មណ៍ទេឬ ។ អើ ។ បុគ្គលជាបុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ គួរនិយាយថា ប្រកបដោយអនុស័យឬ ។ អើ ។ អារម្មណ៍របស់

អនុស័យទាំងនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះ ហេតុនោះ អនុស័យ មិនមានអារម្មណ៍ទេ ។

[ ៨៩២ ] បុគ្គល ជាបុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ គួរនិយាយថា ប្រកបដោយរាគៈឬ ។ អើ ។ អារម្មណ៍នៃរាគៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ រាគៈ មិនមានអារម្មណ៍ទេ ។

អនុសយអនារម្មណាតិកថា ចប់

# អដ្ឋកថា

## អនុសយអនារម្មណាតិកថា

[ ៨៨២ ] ឥឡូវនេះ នឹងពណ៌នាអំពីអនុស័យ ជាធម៌មិនមានអារម្មណ៍ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និកាយឯកច្ចៈ និងនិកាយឧត្តរាបថកៈទាំងឡាយថា ឈ្មោះថាអនុស័យទាំងឡាយ មិនប្រកបជាមួយចិត្តជាអហេតុកៈ ជាអព្យាកត និងដោយហេតុនោះឯង គឺដោយហេតុដែលមិនប្រកបជាមួយចិត្តជាដើម ទើបជាធម៌មិនមានអារម្មណ៍ ដូច្នេះ ពាក្យសួររបស់សកវាទីថា **អនុសយា** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលថា **រូបំ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា ឈ្មោះថា អនុស័យ ដែលមិនមានអារម្មណ៍ គប្បីជាយ៉ាងនេះឬ ។

[ ៨៨៣ ] បទថា **កាមរាគោ** ជាដើម លោកសម្ដែង ព្រោះមិនមែនយ៉ាងដទៃអំពីកាមរាគានុស័យ ។

[ ៨៨៤ ] ក្នុងបញ្ហាថា **សង្ខារក្ខន្ធោ អនារម្មណោ** បរវាទីពោលសំដៅយកសង្ខារក្ខន្ធ ដែលសម្បយុត្តដោយចិត្ត ទើបឆ្លើយបដិសេធ សំដៅយកអនុស័យ ជីវិតិន្ទ្រិយ និងរូបមានកាយកម្មជាដើមថា ជាធម៌ដែលទាក់ទងដោយសង្ខារក្ខន្ធ ទើបឆ្លើយទទួល ។ បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងវារៈទាំងពួង ដោយឧបាយនេះឯង ។

[ ៨៩១ ] ម្យ៉ាងទៀត ក្នុងបញ្ហាថា **សានុសយោ** លោកឆ្លើយទទួលភាពដែលបុគ្គលមានអនុស័យ ព្រោះមិនទាន់លះអនុស័យបាន មិនមែនព្រោះសភាពប្រព្រឹត្តទៅនៃអនុស័យទាំងឡាយ ។ ពិតហើយ អនុស័យណាដែលបុគ្គលមិនទាន់លះបាន អនុស័យនោះ មិនរាប់ថា ជាអតីត អនាគតនិងបច្ចុប្បន្នឡើយ តែអនុស័យនោះ ឈ្មោះថា ជាកិលេស ដែលគប្បីលះដោយមគ្គ លោកពោលថា ជារបស់មាន ដូច្នេះ ព្រោះមិនទាន់លះបាននោះឯង ។ ម្យ៉ាងទៀត បុគ្គលណាមួយ មិនគប្បីពោលថា អារម្មណ៍ឈ្មោះនេះមានដល់អនុស័យបែបនេះ ព្រោះហេតុនោះ ទើបអារម្មណ៍របស់អនុស័យនោះ សកវាទីបដិសេធហើយ ។ ដែលពិត អារម្មណ៍នោះៗ រមែងមិនមានដល់អនុស័យតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន អារម្មណ៍ដូចគ្នានោះឯង រមែងមិនមានដល់កិលេសទាំងឡាយ មានរាគៈជាដើម ព្រោះហេតុនោះ ទើបសេចក្ដីនេះ មិនសម្រេចនូវភាពដែលអនុស័យទាំងឡាយ ជាសភាពមានអារម្មណ៍ ដូច្នេះ ។៙

## អដ្ឋកថាអនុសយអនារម្មណាតិកថា ចប់

# អភិធម្មបិដក

## ញាណអនារម្មណត្តិកថា

[ ៨៩៣ ] ញាណ មិនមានអារម្មណ៍ទេឬ ។ អើ ។ ចុះ រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( មិនមានអារម្មណ៍ ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ មិនមានអារម្មណ៍ទេឬ ។ អើ ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ញាណ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩៤ ] ញាណ មិនមានអារម្មណ៍ទេឬ ។ អើ ។ ( ញាណ ) រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។អើ ។ វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩៥ ] ញាណ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។អើ ។ បញ្ញា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ញាណ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩៦ ] ញាណ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេ ចុះបញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះមិនមានអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩៧ ] បុគ្គលមិនគួរនិយាយថា ញាណ មិនមានអារម្មណ៍ទេឬ ។ អើ ។ ព្រះអរហន្ត ព្រមព្រៀងដោយចក្ខុវិញ្ញាណ គួរនិយាយថា មានញាណឬ ។ អើ ។ អារម្មណ៍របស់ញាណនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បើដូច្នោះ ញាណ មិនមានអារម្មណ៍ទេ ។ ព្រះអរហន្ត ព្រមព្រៀងដោយចក្ខុវិញ្ញាណ គួរនិយាយថា មានបញ្ញាឬ ។ អើ ។ អារម្មណ៍របស់បញ្ញានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បើដូច្នោះ បញ្ញាមិនមានអារម្មណ៍ទេ ។

ញាណអនារម្មណាន្តិកថា ចប់

# អដ្ឋកថា

## ញាណអនារម្មណាទិកថា

[ ៨៩៣ ] ឥឡូវនេះ នឹងពណ៌នាអំពីញាណ ជាធម៌មិនមានអារម្មណ៍ ដូចតទៅ

ក្នុងរឿងនោះ ព្រោះព្រះអរហន្ត ដែលដល់ព្រមដោយចក្ខុវិញ្ញាណ គេហៅថា មានញាណ តែអារម្មណ៍របស់ញាណ ក្នុងខណៈដែលចក្ខុវិញ្ញាណកំពុងកើតនោះ មិនមាន ព្រោះហេតុនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ញាណជាធម៌ មិនមានអារម្មណ៍ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងរឿងអនុស័យនោះឯង ដូច្នេះ ៕

**អដ្ឋកថាញាណអនារម្មណាទិកថា ចប់**

# អភិធម្មបិដក

## អតីតារម្មណកថា

[ ៨៩៨ ] ចិត្ត ជាអតីតារម្មណ៍ ( មានអារម្មណ៍ជាអតីត ) មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែងមានអារម្មណ៍ជាអតីតឬ ។ អើ ។ ប្រសិនបើចិត្តមានអារម្មណ៍ជាអតីត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេ ( ព្រោះពាក្យថា ) ចិត្ត មានអតីតារម្មណ៍ មិនមានអារម្មណ៍ ដូច្នេះ ជាពាក្យខុសទេ មួយទៀត ប្រសិនបើ ចិត្តមិនមានអារម្មណ៍ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត មានអារម្មណ៍ជាអតីតទេ ( ព្រោះពាក្យថា ) ចិត្ត មិនមានអារម្មណ៍ និងមានអារម្មណ៍ជាអតីត ដូច្នេះ ជាពាក្យខុស ។

[ ៨៩៩ ] ចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែងការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីតឬ ។ អើ ។ ប្រសិនបើការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេ ។

**អតីតារម្មណកថា ចប់**

# អភិធម្មបិដក

## អនាគតារម្មណកថា

[ ៩០០ ] ចិត្ត ជាអនាគតារម្មណ៍ ( មានអារម្មណ៍ជាអនាគត ) មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែងមានអារម្មណ៍ជាអនាគតឬ ។ អើ ។ ប្រសិនបើ ( ចិត្ត ) មានអារម្មណ៍ជាអនាគត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ( ព្រោះពាក្យថា ) ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ ដូច្នេះ ជាពាក្យខុស មួយទៀត ប្រសិនបើ ចិត្ត មិនមានអារម្មណ៍ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត មានអារម្មណ៍ជាអនាគតទេ ( ព្រោះពាក្យថា ) មិនមានអារម្មណ៍ និងមានអារម្មណ៍ជាអនាគត ដូច្នេះ ជាពាក្យខុស ។

[ ៩០១ ] ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគតឬ ។ អើ ។ ប្រសិនបើការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ។

[ ៩០២ ] ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្តជាបច្ចុប្បន្នារម្មណ៍ ( មានអារម្មណ៍ជាបច្ចុប្បន្ន ) ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ចុះចិត្តជាអតីតារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អ្នក

មិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩០៣ ] ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្តជាបច្ចុប្បន្នារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ចុះចិត្តជាអនាគតារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩០៤ ] ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ចុះចិត្តជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្តជាបច្ចុប្បន្នារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩០៥ ] ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ចុះចិត្តជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្តជាបច្ចុប្បន្នារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩០៦ ] បុគ្គល មិនគួរនិយាយថា ចិត្តជាអតីតារម្មណ៍ និងជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែងអតីត និងអនាគត មិនមានទេឬ ។ អើ ។ ប្រសិនបើ អតីត និងអនាគត មិនមានទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ចិត្ត ជាអតីតារម្មណ៍ និងជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ។បេ។

**អនាគតារម្មណកថា ចប់**

# អដ្ឋកថា

## អតីតានាគតារម្មណកថា

[ ៨៩៨-៩០៦ ] ឥឡូវនេះ នឹងពណ៌នាចិត្ត ដែលមានអតីត និង អនាគត ជាអារម្មណ៍ដូចតទៅ

ក្នុងរឿងនោះ ព្រោះចិត្តដែលមានអតីត និងអនាគត ជាអារម្មណ៍ មិនមាន ព្រោះហេតុនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា តទារម្មណចិត្តនោះ គប្បីជាចិត្ត ដែលមិនមានអារម្មណ៍ ព្រោះកាលដែលអារម្មណ៍មិនមាន ព្រោះហេតុនោះ ទើបចិត្តដែលមានអតីតជាអារម្មណ៍ ជាចិត្តដែលមិនមានអារម្មណ៍ ដូច្នេះ ពាក្យសួររបស់សកវាទីថា **អតីតារម្មណំ** ជាដើម សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីកាន់យកតាមព្រះបាលីនោះឯង ។៙

**អដ្ឋកថាអតីតានាគតារម្មណកថា ចប់**

# អភិធម្មបិដក

## វិតក្កានុបតិតកថា

[ ៩០៧ ] ចិត្តទាំងអស់ ដែលវិតក្កជាប់តាមឬ ។ អើ ។ ចិត្តទាំងអស់ ដែលវិចារជាប់តាម ដែលបីតិជាប់តាម ដែលសុខជាប់តាម ដែលទុក្ខជាប់តាម ដែលសោមនស្សជាប់តាម ដែលទោមនស្សជាប់តាម ដែលឧបេក្ខាជាប់តាម ដែលសទ្ធាជាប់តាម ដែលវីរិយៈជាប់តាម ដែលសតិជាប់តាម ដែលសមាធិជាប់តាម ដែលបញ្ញាជាប់តាម ដែលរាគៈជាប់តាម ដែលទោសៈជាប់តាម ។បេ។ ដែលអនោត្តប្បៈជាប់តាមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩០៨ ] ចិត្តទាំងអស់ ដែលវិតក្កជាប់តាមឬ ។ អើ ។ ក្រែងសមាធិមិនមានវិតក្ក មានត្រឹមតែវិចារ មានដែរឬ ។ អើ ។ ប្រសិនបើ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កជាប់តាមទេ ។

[ ៩០៩ ] ចិត្តទាំងអស់ ដែលវិតក្កជាប់តាមឬ ។ អើ ។ ក្រែងសមាធិមិនមានវិតក្ក មិនមានវិចារ មានដែរឬ ។ អើ ។ ប្រសិនបើសមាធិ មិនមានវិតក្ក មិនមានវិចារ មានដែរ ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កជាប់តាមទេ ។

[ ៩១០ ] ចិត្តទាំងអស់ ដែលវិតក្កជាប់តាមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សមាធិ មាន ៣ គឺសមាធិមានវិតក្ក មានទាំងវិចារ ១ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ ១ សមាធិ មិនមានវិតក្ក មិនមានទាំងវិចារ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សមាធិ មាន ៣ គឺសមាធិមានវិតក្ក មានទាំងវិចារ ១ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ ១ សមាធិមិនមានវិតក្ក មិនមានទាំងវិចារ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កជាប់តាមទេ ។

វិតក្កានុបតិតកថា ចប់

# អដ្ឋកថា

## វិតក្កានុបតិតកថា

[ ៩០៧ ] ឥឡូវនេះ នឹងពណ៌នាអំពីចិត្ត ទាក់ទងដោយវិតក្កដូចតទៅ ក្នុងរឿងនោះ ឈ្មោះថា ចិត្តដែលទាក់ទងដោយវិតក្ក មាន ២ យ៉ាង គឺដោយអារម្មណ៍ ១ ដោយសម្បយោគ ១ ។ ក្នុង ២ យ៉ាងនោះ ចិត្តទាំងអស់ ឈ្មោះថា ជាចិត្តទាក់ទងដោយវិតក្កគប្បីមាន ព្រោះការមិនមានការកំណត់ពិតប្រាកដថា ឈ្មោះថា ចិត្តដួងនោះ មិនមានអារម្មណ៍ ប្រព្រឹត្តទៅជាមួយវិតក្ក ដូច្នេះ តែចិត្តទាំងអស់នោះ ឈ្មោះថា មិនទាក់ទងដោយវិតក្ក ព្រោះសភាពនៃចិត្តដែលវិប្បយុត្តចាកវិតក្ក ។ ជនទាំងឡាយណា មានលទ្ធិដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា ចិត្តគ្រប់ដួង ទាក់ទងដោយវិតក្ក ដោយមិនប្លែកគ្នាឡើយ ព្រោះមិនធ្វើការបែកអត្ថនេះ ដោយប្រការយ៉ាងនេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីកាន់យកដោយអំណាចព្រះបាលីនោះឯង ដូច្នេះ ៕

**អដ្ឋកថាវិតក្កានុបតិតកថា ចប់**

# អភិធម្មបិដក

## វិតក្កវិប្ផារសទ្ទកថា

[ ៩១១ ] សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្ក របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ឬ ។ អើ ។ សំឡេង ជាគ្រឿងផ្សាយចេញនៃផស្សៈ របស់បុគ្គលកាលពាល់ត្រូវដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃវេទនា របស់បុគ្គលកាលទទួលអារម្មណ៍ ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃសញ្ញា របស់បុគ្គលកាលចំណាំបាន ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃចេតនា របស់បុគ្គលកាលនឹកដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃចិត្ត របស់បុគ្គលកាលគិតដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃសតិ របស់បុគ្គលកាលរឭកដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃបញ្ញា របស់បុគ្គលកាលដឹងដោយសព្វគ្រប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩១២ ] សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្ក របស់បុគ្គលកាលត្រិះរិះ កាលពិចារណាដោយសព្វគ្រប់ឬ ។ អើ ។សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្ក ជាសំឡេងដែលគួរដឹងបានដោយត្រចៀក ប៉ះទង្គិចក្នុងត្រចៀក មក

កាន់គន្លងនៃត្រចៀកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសំឡេងជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេងមិនគួរដឹងដោយត្រចៀក មិនប៉ះទង្គិចក្នុងត្រចៀក មិនមកកាន់គន្លងនៃត្រចៀកទេឬ ។ អើ ។ ប្រសិនបើ សំឡេងជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេងដែលមិនគួរដឹងដោយត្រចៀក មិនប៉ះទង្គិចក្នុងត្រចៀក មិនមកកាន់គន្លងនៃត្រចៀកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះកាលពិចារណា ដោយសព្វគ្រប់ទេ ។

## វិតក្កវិប្ផារសទ្ទកថា ចប់

# អដ្ឋកថា

## វិតក្កវិប្ផារសទ្ទកថា

[ ៩១១ ] ឥឡូវនេះ នឹងពណ៌នាអំពីការផ្សាយទៅនៃវិតក្ក ជាសំឡេងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា ព្រោះព្រះមានព្រះភាគត្រាស់ថា វិតក្កវិចារ ជាវចីសង្ខារ ហេតុនោះ គ្រប់គ្រា កាលបុគ្គលត្រិះរិះ ពិចារណា ដោយហោចសូម្បីក្នុងវេលាប្រព្រឹត្តទៅនៃមនោធាតុ ការផ្សាយចេញទៅនៃវិតក្កនោះឯងជាសំឡេង ពាក្យសួររបស់សកវាទីថា **សព្វសោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គ្រានោះ សកវាទីក៏ពោលថា **សព្វសោ ផុសយតោ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើហេតុត្រឹមតែការផ្សាយចេញទៅនៃវិតក្ក ជាសំឡេងសោត ការផ្សាយចេញទៅនៃផស្សៈជាដើម ក៏គប្បីជាសំឡេង ដូច្នេះ បរវាទី កាលមិនឃើញលេសន័យរបស់ព្រះសូត្របែបនោះ ទើបឆ្លើយបដិសេធ ។

[ ៩១២ ] បទថា **វិតក្កវិប្ផារោ សទ្ទោ សោតវិញ្ញេយ្យោ** សេចក្តីថា សកវាទីធ្វើបញ្ហាសួរថា ហេតុត្រឹមតែការផ្សាយទៅនៃវិតក្កប៉ុណ្ណោះ ជាសំឡេងឬ មិនធ្វើបញ្ហាសួរដល់សំឡេងដែលកើតឡើង ព្រោះការផ្សាយចេញទៅនៃវិតក្ក របស់បុគ្គលដែលដេកលក់ ឬដែលមិនមានស្មារតី ។ បរវាទីឆ្លើយបដិសេធ ។ សកវាទីសម្តែងពាក្យនេះ តាមលទ្ធិរបស់បរវាទី

នោះឯងថា **ឆន្ទុ វិតក្កវិប្ផារោ សទ្ទោ ន សោតវិញ្ញេយ្យោ** ដូច្នេះ ។ ពិតហើយ សកវាទីពោលនូវហេតុត្រឹមតែការផ្សាយទៅ នៃវិតក្កប៉ុណ្ណោះថាជាសំឡេង តែសំឡេងនោះ បុគ្គលមិនគប្បីដឹងបានដោយសោតវិញ្ញាណ តែបរវាទីពោលថា សំឡេងនោះ គប្បីដឹងបានដោយសោតវិញ្ញាណនោះឯង ព្រោះព្រះបាលី ( ក្នុងទីឃនិកាយ បាដិក្កវគ្គ ) ថា បុគ្គលស្តាប់សំឡេងដែលផ្សាយចេញទៅនៃវិតក្ក ហើយបានស្តាប់សំឡេងដែលផ្សាយចេញអំពីសេចក្តីត្រិះរិះ របស់អ្នកដែលកំពុងទឹក កំពុងគិតហើយទាយ ក៏ទេដែរ ដូច្នេះ ។ល។

## អដ្ឋកថាវិតក្កវិប្ផារសទ្ទកថា ចប់

# អភិធម្មបិដក

## នយជាចិត្តសម្បយុត្តវាចាតិកថា

[ ៩១៣ ] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ វាចា របស់បុគ្គលមិនមានផស្សៈ វាចា របស់បុគ្គលមិនមានវេទនា វាចា របស់បុគ្គលមិនមានសញ្ញា វាចា របស់បុគ្គលមិនមានចេតនា វាចា របស់បុគ្គលមិនមានចិត្តឬ ។ មិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងវាចារបស់បុគ្គលប្រកបដោយផស្សៈ វាចារបស់បុគ្គលប្រកបដោយវេទនា វាចារបស់បុគ្គលប្រកបដោយសញ្ញា វាចារបស់បុគ្គលប្រកបដោយចេតនា វាចារបស់បុគ្គលប្រកបដោយចិត្តឬ ។ អើ ។ ប្រសិនបើ វាចារបស់បុគ្គលប្រកបដោយផស្សៈ ។បេ។ វាចារបស់បុគ្គលប្រកបដោយចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចារបស់បុគ្គលមិនពោលតាមចិត្តទេ ។

[ ៩១៤ ] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ វាចា របស់បុគ្គលកាលមិនពិចារណា វាចា របស់បុគ្គលកាលមិនសង្ស៊ើម ។បេ។ វាចា របស់បុគ្គលកាលមិនតាំងចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងវាចារបស់បុគ្គលកាលពិចារណា វាចារបស់បុគ្គលកាលសង្ស៊ើម ។បេ។ វាចារបស់បុគ្គលកាលតាំងចិត្តឬ ។ អើ ។ ប្រសិនបើ វាចារបស់បុគ្គលកាលពិចារណា វាចារបស់បុគ្គលកាលសង្ស៊ើម ។បេ។ វាចារបស់បុគ្គលកាលតាំងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចារបស់បុគ្គលមិនពោលតាមចិត្តទេ ។

[ ៩១៥ ] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ ក្រែង វាចាតាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតឡើងព្រមគ្នានឹងចិត្តឬ ។ អើ ។ ប្រសិនបើ វាចាតាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតឡើងព្រមគ្នានឹងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចារបស់បុគ្គលមិនពោលតាមចិត្តទេ ។

[ ៩១៦ ] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ បុគ្គលចង់និយាយ តែមិននិយាយ ចង់ពោល តែមិនពោល ចង់ហៅ តែមិនហៅ ចង់ចរចា តែមិនចរចាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងបុគ្គលចង់និយាយ តែងនិយាយបាន ចង់ពោល តែងពោលបាន ចង់ហៅ តែងហៅបាន ចង់ចរចា តែងចរចាបានឬ ។ អើ ។ ប្រសិនបើ បុគ្គលចង់និយាយ តែងនិយាយបាន ចង់ពោល តែងពោលបាន ចង់ហៅ តែងហៅបាន ចង់ចរចា តែងចរចាបាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចារបស់បុគ្គលមិនពោលតាមចិត្តទេ ។

[ ៩១៧ ] បុគ្គលមិនគួរនិយាយថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ ក្រែងបុគ្គលនីមួយគិតថា អាត្មាអញ នឹងនិយាយពាក្យដទៃ រមែងនិយាយពាក្យដទៃវិញ គិតថា អាត្មាអញនឹងពោលពាក្យដទៃ រមែងពោលពាក្យដទៃវិញ គិតថា អាត្មាអញនឹងហៅពាក្យដទៃ រមែងហៅពាក្យដទៃវិញ គិតថា អាត្មាអញ នឹងចរចាពាក្យដទៃ រមែងចរចាពាក្យដទៃវិញមានឬ ។ អើ ។ ប្រសិនបើ បុគ្គលនីមួយ គិតថា អាត្មាអញ នឹងនិយាយពាក្យដទៃ រមែងនិយាយពាក្យដទៃវិញ ។បេ។ គិតថា អាត្មាអញនឹងចរចាពាក្យដទៃ រមែងចរចាពាក្យដទៃវិញ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាចារបស់បុគ្គលមិនពោលតាមចិត្ត ។

នយថាចិត្តស្សវាចាតិកថា ចប់

# អដ្ឋកថា

## នយជាចិត្តស្ស វាចាតិកថា

[ ៩១៣ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនមានការគិតណាមួយ ក៏មានវាចាបានដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយ បុព្វសេលិយៈទាំងឡាយថា ព្រោះបុគ្គលខ្លះ គិតថា អញនឹងពោលយ៉ាង នេះ តែរមែងពោលដទៃ ហេតុនោះ វាចារបស់បុគ្គលមិនមានការគិតយ៉ាង ណា ទើបឈ្មោះថា មិនសមគួរដល់ចិត្ត មិនអនុលោមទៅតាមចិត្ត វៀរចិត្ត ហើយ វាចារមែងប្រព្រឹត្តទៅបាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅ ដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គ្រានោះ សកវាទីក៏ពោលពាក្យថា **អជស្សកស្ស** ជាដើម ដើម្បីចោទសួរបរវាទីនោះ ថា បើចិត្តដែលជាហេតុឲ្យវាចាកើតឡើង មិនគប្បីមានសោត ធម៌ទាំង ឡាយ មានផស្សៈជាដើម ក៏មិនគប្បីមានក្នុងខណៈនោះ ដូច្នេះ ។

[ ៩១៦ ] ក្នុងបទទាំងឡាយ មានបទថា **ន ភណិតុកាមោ** ជាដើម អធិប្បាយថា ព្រោះបុគ្គលគិតថា អញនឹងពោលពាក្យណាមួយ សូម្បីពោល នូវពាក្យណាមួយដទៃទៀត បុគ្គលនោះ រមែងឈ្មោះថា ជាអ្នកប្រាថ្នានឹង ពោលនោះឯង ហេតុនោះ ទើបបរវាទីឆ្លើយបដិសេធថា **ន ហេវំ** ។

[ ៩១៧ ] ក្នុងបទទាំងឡាយ មានបទថា **ននុ អត្ថិ កោចិ អញ្ញំ ភណិស្សាមិ** ជាដើម អធិប្បាយថា បុគ្គលណា ប្រាថ្នានឹងពោលថា **ចីវរំ**

( ចីវរ ) តែបែរជាពោលថា **ចិរំ** ( សម្បកឈើ ) ។ ក្នុងទីនេះ ចិត្តដែលប្រាថ្នាដើម្បីពោលម្យ៉ាង ចិត្តដែលពោលក៏ម្យ៉ាងទៀត ព្រោះហេតុនោះ ទើបឈ្មោះថា មិនប្រព្រឹត្តទៅតាមចិត្ត ព្រោះមិនដូចចិត្តដែលជាចំណែកខាងដើម ព្រោះហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា មិនត្រូវអាបត្តិ ( មុសា ) ដោយចំណែកមួយ តែចិត្តដែលញុំាងវាចាឲ្យកើតឡើងថា **ចិរំ** មិនមាន ក៏មិនមែន ព្រោះហេតុនោះ ទើបបរវាទីសំដៅយកសេចក្តីថា វាចានោះ មិនមានចិត្ត ទើបឆ្លើយបដិសេធ ។ ដោយឧទាហរណ៍នេះ លទ្ធិដែលបរវាទីតាំងហើយថា បុគ្គលមិនមានការគិតណាមួយ ក៏មានវាចាបាន ដូច្នេះ រមែងជាលទ្ធិតាំងនៅមិនបានឡើយ ដូច្នេះឯង ។ល។

## អដ្ឋកថានយថាចិត្តស្សវាចាតិកថា ចប់

# អភិធម្មបិដក

## នយជាចិត្តសម្បយុត្តកាយកម្មត្តិកថា

[ ៩១៨ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេឬ ។ អើ ។ កាយកម្ម របស់បុគ្គលមិនមានផស្សៈ ។បេ។ កាយកម្មរបស់បុគ្គលមិនមានចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងកាយកម្មរបស់បុគ្គលប្រកបដោយផស្សៈ ។បេ។ កាយកម្មរបស់បុគ្គលប្រកបដោយចិត្តឬ ។ អើ ។ ប្រសិនបើកាយកម្មរបស់បុគ្គលប្រកបដោយផស្សៈ ។បេ។ កាយកម្មរបស់បុគ្គលប្រកបដោយចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្មរបស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[ ៩១៩ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ កាយកម្មរបស់បុគ្គលកាលមិនពិចារណា ។បេ។ កាយកម្ម របស់បុគ្គលកាលមិនបានតាំងចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងកាយកម្មរបស់បុគ្គលកាលពិចារណា ។បេ។ កាយកម្មរបស់បុគ្គលកាលតាំងចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម របស់បុគ្គលកាលពិចារណា ។បេ។ កាយកម្ម របស់បុគ្គលកាលតាំងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[ ៩២០ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ ក្រែងកាយកម្មតាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតព្រមជាមួយនឹងចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត

កើតព្រមជាមួយនឹងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[ ៩២១ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ បុគ្គលចង់ឈានទៅមុខ តែឈានទៅមុខមិនកើត ចង់ឈានថយក្រោយ តែឈានថយក្រោយមិនកើត ចង់ក្រឡេកទៅមុខ តែក្រឡេកទៅមុខមិនកើត ចង់ក្រឡេកទៅទិសផ្សេងៗ តែក្រឡេកទៅទិសផ្សេងៗ មិនកើត ចង់បត់អវយវៈចូល តែបត់អវយវៈចូលមិនកើត ចង់លាអវយវៈចេញ តែលាអវយវៈចេញមិនកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងបុគ្គល ចង់ឈានទៅមុខ តែងឈានទៅមុខបាន ចង់ឈានថយក្រោយ តែងឈានថយក្រោយបាន ចង់ក្រឡេកទៅមុខ តែងក្រឡេកទៅមុខបាន ចង់ក្រឡេកទៅទិសផ្សេងៗ តែងក្រឡេកទៅទិសផ្សេងៗ បាន ចង់បត់អវយវៈចូល តែងបត់អវយវៈចូលបាន ចង់លាអវយវៈចេញ តែងលាអវយវៈចេញបានដែរឬ ។ អើ ។ ប្រសិនបើបុគ្គលចង់ឈានទៅមុខ តែងឈានទៅមុខបាន ។បេ។ ចង់លាអវយវៈចេញ តែងលាអវយវៈចេញបាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[ ៩២២ ] បុគ្គលមិនគួរនិយាយថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេឬ ។ អើ ។ ក្រែងបុគ្គលទីមួយ គិតថា អាត្មាអញ នឹងទៅក្នុងទិសដទៃ តែត្រឡប់ជាទៅក្នុងទិសដទៃវិញ ។បេ។ គិតថា អាត្មាអញ នឹងលាន្ទូវអវយវៈដទៃ តែត្រឡប់ជាលាន្ទូវអវយវៈដទៃវិញ មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទីមួយ គិតថា អាត្មាអញ នឹងទៅក្នុងទិសដទៃ តែត្រឡប់ជាទៅក្នុងទិសដទៃវិញ ។បេ។ គិតថា អាត្មាអញ នឹងលាន្ទូវអវយវៈដទៃ តែត្រឡប់ជាលាន្ទូវអវយវៈដទៃវិញ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្ត ។

នយថាចិត្តស្ស កាយកម្មន្តិកថា ចប់

# អដ្ឋកថា

## នយជាចិត្តស្ស កាយកម្មន្តិកថា

[ ៩១៨ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនមានការគិតណាមួយ ក៏មានកាយកម្មបានដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា ព្រោះបុគ្គលពួកខ្លះ ដែលគិតថា អញនឹងទៅក្នុងទីមួយ តែក៏ទៅទីមួយដទៃទៀត ព្រោះហេតុនោះ ទើបកាយកម្ម របស់បុគ្គលដែលមិនមានការគិតណាមួយ មិនសមគួរដល់ចិត្ត មិនអនុលោមទៅតាមចិត្ត សូម្បីវៀរចិត្តក៏ប្រព្រឹត្តទៅបាន ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ខាងដើមនោះឯង ។\ ។

**អដ្ឋកថានយជាចិត្តស្សកាយកម្មន្តិកថា ចប់**

# អភិធម្មបិដក

## អតីតានាគតប្បច្ចុប្បន្នកថា

[ ៩២៣ ] បុគ្គល ប្រកបដោយអតីតឬ ។ អើ ។ ក្រែងអតីតរលត់ហើយ ទៅប្រាសហើយ ប្រែប្រួលហើយ អស់ហើយ បាត់ហើយឬ ។ អើ ។ ប្រសិនបើ អតីតរលត់ហើយ ទៅប្រាសហើយ ប្រែប្រួលហើយ អស់ហើយ បាត់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រកបដោយអតីតទេ ។

[ ៩២៤ ] បុគ្គល ប្រកបដោយអនាគតឬ ។ អើ ។ ក្រែងអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់លូតលាស់ មិនទាន់ដុះ មិនទាន់ដុះដាល មិនទាន់កើតប្រាកដទេឬ ។ អើ ។ ប្រសិនបើ អនាគត មិនទាន់កើត មិនទាន់មាន មិនទាន់លូតលាស់ មិនទាន់ដុះ មិនទាន់ដុះដាល មិនទាន់កើតប្រាកដទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រកបដោយអនាគតទេ ។

[ ៩២៥ ] បុគ្គល ប្រកបដោយរូបក្ខន្ធជាអតីត ប្រកបដោយរូបក្ខន្ធជាអនាគត ប្រកបដោយរូបក្ខន្ធជាបច្ចុប្បន្នដែរឬ ។ អើ ។ មានតែបុគ្គលប្រកបដោយរូបក្ខន្ធ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រកបដោយខន្ធ ៥ ជាអតីត ប្រកបដោយខន្ធ ៥ ជាអនាគត ប្រកបដោយខន្ធ ៥ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយខន្ធ ១៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩២៦ ] បុគ្គល ប្រកបដោយចក្ខាយតនៈជាអតីត ប្រកបដោយ

ចក្ខាយតនៈជាអនាគត ប្រកបដោយចក្ខាយតនៈ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយចក្ខាយតនៈ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រកបដោយអាយតនៈ ១២ ជាអតីត ប្រកបដោយអាយតនៈ ១២ ជាអនាគត ប្រកបដោយអាយតនៈ ១២ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយអាយតនៈ ៣៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩២៧ ] បុគ្គលប្រកបដោយចក្ខុធាតុ ជាអតីត ប្រកបដោយចក្ខុធាតុ ជាអនាគត ប្រកបដោយចក្ខុធាតុ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយចក្ខុធាតុ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រកបដោយធាតុ ១៨ ជាអតីត ប្រកបដោយធាតុ ១៨ ជាអនាគត ប្រកបដោយធាតុ ១៨ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយធាតុ ៥៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩២៨ ] បុគ្គល ប្រកបដោយចក្ខុន្ទ្រិយជាអតីត ប្រកបដោយចក្ខុន្ទ្រិយ ជាអនាគត ប្រកបដោយចក្ខុន្ទ្រិយជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយចក្ខុន្ទ្រិយ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រកបដោយឥន្ទ្រិយ ២២ ជាអតីត ប្រកបដោយឥន្ទ្រិយ ២២ ជាអនាគត ប្រកប

ដោយឥន្ទ្រិយ ២២ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយឥន្ទ្រិយ ៦៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩២៩ ] បុគ្គល មិនគួរនិយាយថា បុគ្គលប្រកបដោយអតីត និងអនាគតទេឬ ។ អើ ។ ក្រែងបុគ្គលជាអ្នកចម្រើននូវវិមោក្ខ ៨ ជាអ្នកបានដោយមិនបាច់ប្រាថ្នានូវឈានទាំង ៤ បាននូវអនុបុព្វវិហារសមាបត្តិទាំង ៩ មានឬ ។ អើ ។ ប្រសិនបើ បុគ្គលជាអ្នកចម្រើននូវវិមោក្ខ ៨ ជាអ្នកបានដោយមិនបាច់ប្រាថ្នា នូវឈានទាំង ៤ បាននូវអនុបុព្វវិហារសមាបត្តិទាំង ៩ មាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលប្រកបដោយអតីត និងអនាគត ។

**អតីតានាគតប្បច្ចុប្បន្នកថា ចប់**

**នវមវគ្គ ចប់**

## ឧទ្ទាននៃនវមវគ្គនោះ គឺ

និយាយអំពីការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្ស ១ សញ្ញោជនៈ មានអមតៈជាអារម្មណ៍ ១ រូបប្រកបដោយអារម្មណ៍ ១ ពួកអនុស័យមិនមានអារម្មណ៍ ១ ញាណមិនមានអារម្មណ៍យ៉ាងនោះដែរ ១ ចិត្តជាអតីតារម្មណ៍ និងអនាគតារម្មណ៍ ១ ចិត្តទាំងអស់ មានវិតក្កជាប់តាម ១ សំឡេងជាគ្រឿងផ្សាយចេញ នៃវិតក្ករបស់បុគ្គលកាលត្រិះរិះ កាលពិចារណាដោយសព្វគ្រប់ ១ វាចារបស់បុគ្គលមិនពោលតាមចិត្ត ១ កាយកម្មរបស់បុគ្គលមិនធ្វើតាមចិត្តដូច្នោះ ១ បុគ្គលប្រកបដោយអតីត និងអនាគត ១ ។

# អដ្ឋកថា

## អតីតានាគតសមន្នាគតកថា

[ ៩២៣ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គល ដែលប្រកបដោយអតីត និងអនាគតដូចតទៅ

ក្នុងរឿងនោះ បណ្ឌិតគប្បីជ្រាបបញ្ញត្តិ ២ យ៉ាង គឺសមន្នាគតប្បញ្ញត្តិ គឺបញ្ញត្តិពាក្យថា ប្រកប ១ បដិលាភប្បញ្ញត្តិ គឺបញ្ញត្តិពាក្យថា ការបាន ចំពោះ ១ ។ ក្នុងបញ្ញត្តិ ២ យ៉ាងនោះ បុគ្គលដល់ព្រមដោយបច្ចុប្បន្នធម៌ លោក ហៅថា **សមន្នាគត** ឯសមាបត្តិទាំងឡាយរបស់បុគ្គលដែលបាន សមាបត្តិ ៨ មិនប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា ចំណែកមួយជាអតីត ចំណែកមួយជាអនាគត ចំណែកមួយជាបច្ចុប្បន្នក៏ពិត តែទោះជាយ៉ាងនោះ លោក ក៏ហៅថា **លាភី** គឺបុគ្គលមានប្រក្រតីបាន ព្រោះភាពជាបុគ្គលចាក់ ធ្លុះហើយ ជាអ្នកមិនវិនាសទៅ ។ ក្នុងបញ្ហានេះ ជនទាំងឡាយណា មិន កាន់យកការចែកយ៉ាងនេះ ហើយមានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំង ឡាយថា ព្រោះឈានទាំងឡាយ សូម្បីជាអតីត និងអនាគត មានដល់បុគ្គល ដែលបានឈាន ព្រោះហេតុនោះ ឈានលាភីបុគ្គលទាំងនោះ រមែងជាបុគ្គល

ប្រកបដោយអតីតខ្លះ ដោយអនាគតខ្លះ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។ម្យ៉ាងទៀត បទថា **អដ្ឋ-វិមោក្ខជ្ឈាយី** ជាដើម សម្រេចដល់ភាពជាអ្នកមានប្រក្រតីបាន ( សមាបត្តិ ៨ ) មិនមែនសម្រេចដល់ភាពជាបុគ្គលប្រកបដោយអតីត និងអនាគត ដូច្នេះឡើយ ៕

**អដ្ឋកថាអតីតានាគតសមន្នាគតកថា ចប់**

**វគ្គទី ៩ ចប់**

# អភិធម្មបិដក

## និទ្ទេសកថា

[ ៩៣០ ] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ខន្ធ ៥ ជាកិរិយាកើតឡើងឬ ។ អើ ។ ការប្រជុំនៃខន្ធទាំង ១០ មានខន្ធទាំង ១០ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំនៃខន្ធទាំង ១០ មាន ខន្ធទាំង ១០ មកកាន់ភាពចំពោះមុខឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣១ ] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ខន្ធទាំង ៤ ជាកិរិយាកើតឡើងឬ ។ អើ ។ ការប្រជុំនៃខន្ធទាំង ៩ មានខន្ធទាំង ៩ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំនៃខន្ធទាំង ៩ មានខន្ធទាំង ៩ មកកាន់ភាពចំពោះមុខឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣២ ] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ញាណជាកិរិយាកើតឡើងឬ ។ អើ ។ ការប្រជុំនៃខន្ធទាំង ៦ មាន ខន្ធទាំង ៦ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំនៃខន្ធទាំង ៦ មាន ខន្ធទាំង ៦ មកកាន់ភាពចំពោះមុខឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ២ ។បេ។ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣៣ ] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត រលត់ហើយ មគ្គកើតឡើងឬ ។ អើ ។ បុគ្គលស្លាប់ ទើបចម្រើនមគ្គ បុគ្គលធ្វើមរណកាល ទើបចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

និរោធកថា ចប់

# អដ្ឋកថា

## និរោធកថា

[ ៩៣០ ] ឥឡូវនេះ នឹងពណ៌នាអំពីការរលត់ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ ទាំងឡាយថា ខន្ធ ៥ គឺនាមក្ខន្ធ ៤ ដែលជាកុសល ឬជាអកុសល ដែលដល់នូវការរាប់ថា ជាកិរិយា និងរូប ដែលមានចិត្តជាសមុដ្ឋាន រមែងកើតឡើងព្រមជាមួយភង្គក្ខណៈរបស់ភវង្គចិត្ត ដែលដល់នូវការរាប់ថា ខន្ធដែលស្វែងរកការកើត ព្រោះថា កាលខន្ធទាំងនោះ មិនទាន់កើតឡើង កាលភវង្គចិត្តរលត់ហើយ ការកាត់ផ្តាច់នៃសន្តតិគប្បីមាន ដូច្នេះ ពាក្យសួររបស់សកវាទីថា **ឧបបត្តេសិយេ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បណ្តាបទទាំងនោះ បទថា **ឧបបត្តេសិយេ** ជាសត្តមីវិភត្តិ ឯកវចនៈ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ពហុវចនៈ ក្នុងបទទាំង ៤ ។ ក្នុងពាក្យនេះ លោកអធិប្បាយ ៤ បទថា **ឧបបត្តេសិយេសុ បញ្ចសុ ខន្ធេសុ អនិរុទ្ធេសុ** ប្រែថា កាលខន្ធ ៥ ដែលស្វែងរកនូវការកើតមិនទាន់រលត់ ។ បទថា **ធសន្ធំ** សកវាទីពោលដោយអំណាចនៃខន្ធ ៥ ដែលស្វែងរកការកើត និងខន្ធ ៥ ដែលជាកិរិយា ។ ក្នុងបញ្ហាទាំងនោះ បញ្ហាដំបូងនោះ បរវាទីឆ្លើយបដិសេធដោយគិតថា ខន្ធទាំងនោះ ឈ្មោះថា មាន ៥ ប៉ុណ្ណោះ ដោយអំណាចនៃលក្ខណៈរបស់ខន្ធ និងដោយអំណាចនៃកិរិយា ។ ក្នុងបញ្ហាទី ២ បរវាទីសំដៅយកការផ្សេងគ្នានៃខន្ធ ៥ ដោយអំណាចនៃខន្ធ

ដែលកើតមុន និងកើតក្រោយ និងដោយអំណាចនៃខន្ធ ដែលស្វែងរកការកើត និងខន្ធដែលជាកិរិយា ទើបឆ្លើយទទួល តែត្រូវសកវាទីសួរដល់ការប្រជុំនៃផស្សៈ ២ យ៉ាង និងនៃចិត្ត ២ យ៉ាង ក៏ឆ្លើយបដិសេធ ព្រោះការមិនមានគោលអាងក្នុងព្រះសូត្រ ។

[ ៩៣១ ] បទថា **កិរិយា ចត្តារោ** សេចក្តីថា សកវាទីកាន់យកនាមក្ខន្ធ ៤ ដែលជាកុសល ឬជាអកុសល ដោយវៀរចាករូប ។

[ ៩៣២ ] បទថា **កិរិយា ញាណំ** បានដល់ ញាណដែលមិនមានអារម្មណ៍ ដែលបរវាទីទទួលហើយ សម្រាប់ព្រះអរហន្ត ក្នុងខណៈដែលលោកដល់ព្រមដោយចក្ខុវិញ្ញាណ ។

[ ៩៣៣ ] ពាក្យសួរថា **និរុទ្ធេ មគ្គោ ឧប្បជ្ជតិ** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ព្រោះកាលខន្ធ ៥ ដែលស្វែងរកការកើតមិនទាន់រលត់ហើយ មគ្គក៏មិនកើតឡើង ។ ពាក្យសួរដោយលេសន័យថា **មតោ មគ្គំ ភាវេតិ** ជាពាក្យរបស់បរវាទី ។ សកវាទីឆ្លើយបដិសេធថា **ន ហេវំ** ក៏ព្រោះថា ចាប់តាំងអំពីបដិសន្ធិ រហូតដល់ចុតិចិត្តសត្វ ឈ្មោះថា មានជីវិតនោះឯង ដូច្នេះ ។ល។

**អដ្ឋកថានិរោធកថា ចប់**

# អភិធម្មបិដក

## រូបមគ្គោតិកថា

[ ៩៣៤ ] រូប របស់បុគ្គលព្រមព្រៀងដោយមគ្គ ជាមគ្គឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងចិត្តទុកចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូបមិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប របស់បុគ្គលព្រមព្រៀងដោយមគ្គ ជាមគ្គទេ ។

[ ៩៣៥ ] សម្មាវាចា ជាមគ្គឬ ។ អើ ។ ( សម្មាវាចា ) ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសម្មាវាចា មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាវាចានោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ ( សម្មាវាចា ) មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាវាចានោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សម្មាវាចា ជាមគ្គទេ ។

[ ៩៣៦ ] សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាមគ្គឬ ។ អើ ។ ( សម្មាអាជីវៈ ) ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះ

សម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែង សម្មាអាជីវៈ មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះ សម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ សម្មាអាជីវៈមិនមាន អារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាអាជីវៈនោះ មិន មានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សម្មាអាជីវៈ ជាមគ្គទេ ។

[ ៩៣៧ ] សម្មាទិដ្ឋិជាមគ្គ សម្មាទិដ្ឋិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាទិដ្ឋិនោះ មានឬ ។ អើ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាទិដ្ឋិនោះ មានឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង ប្រកបដោយ អារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាអាជីវៈនោះ មាន ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាសង្កប្ប ។បេ។ សម្មា-វាយាមៈ ។បេ។ សម្មាសតិ ។បេ។

[ ៩៣៨ ] សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង ប្រកបដោយ អារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាសមាធិនោះ មានឬ ។ អើ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុកចំពោះសម្មាវាចានោះ មានឬ ។ អ្នក

មិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មានឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣៩ ] សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេឬ ។ អើ ។ សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៤០ ] សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង មិនមានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ ។បេ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង មិន

មានអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៤១ ] បុគ្គលមិនគួរនិយាយថា រូប របស់បុគ្គលដែលព្រមព្រៀងដោយមគ្គ ជាមគ្គទេឬ ។ អើ ។ ក្រែងសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជាមគ្គឬ ។ អើ ។ ប្រសិនបើ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជាមគ្គ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប របស់បុគ្គលដែលព្រមព្រៀងដោយមគ្គ ជាមគ្គ ។

រូបមគ្គោតិកថា ចប់

# អដ្ឋកថា

## រូបមគ្គោតិកថា

[ ៩៣៤ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបជាមគ្គដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហិសាសកៈ និកាយសមិតិយៈ និងនិកាយមហាសង្ឃិកៈទាំងឡាយថា សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជារូប ដូច្នេះ ពាក្យសួររបស់សកវាទីថា **មគ្គសមង្គិស្ស** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **សារម្មណោ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើសម្មាវាចាជាដើម តាមលទ្ធិរបស់អ្នក ជារូប មិនជាវិរតិសោត មគ្គមានសម្មាទិដ្ឋិជាដើម ជាសភាវៈដែលមានអារម្មណ៍ជាដើម យ៉ាងណា រូបនោះ ក៏គប្បីជាយ៉ាងនោះ ដូច្នេះ ។ ក្នុងបញ្ហានោះ គប្បីជ្រាបពាក្យបដិសេធ និងពាក្យឆ្លើយទទួល ដោយសមគួរដោយអំណាចនៃលទ្ធិរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៗ ។

**អដ្ឋកថារូបមគ្គោតិកថា ចប់**

# អភិធម្មបិដក

## បញ្ចវិញ្ញាណសមង្គីមគ្គភាវនាកថា

[ ៩៤២ ] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណ មានឬ ។ អើ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណមានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គ-ភាវនា របស់បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណ មានទេ ។

[ ៩៤៣ ] ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងមុន មានអារម្មណ៍កើតឡើងមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា មានវត្ថុផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលនូវគោចរវិស័យរបស់គ្នានិងគ្នា មិនកើតឡើងអំពីការមិនប្រមូលមក មិនកើតឡើងអំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើងអំពីការមិនប្រឡូកប្រឡំគ្នា មិនកើតឡើងមិនមុន មិនក្រោយ មិនកើតឡើងក្នុងលំដាប់ស្មើនៃគ្នានិងគ្នា ។បេ។ ក្រែងបញ្ចវិញ្ញាណ មិនមានការពិចារណាទេឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនមានការពិចារណាទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណ មានទេ ។

[ ៩៤៤ ] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណប្រារព្ធសភាវៈសុញ្ញ ទើបកើតឡើងឬ ។ អ្នក

មិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងទេ ។

[ ៩៤៥ ] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុវិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុវិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ប្រារព្ធវេទនា ប្រារព្ធសញ្ញា ប្រារព្ធចេតនា ប្រារព្ធចិត្ត ប្រារព្ធចក្ខុ ។បេ។ ប្រារព្ធកាយ ប្រារព្ធសំឡេង ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ មាន ឯមនោ-វិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធ អតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ មាន ឯមនោ-វិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៩៤៦ ] បុគ្គលមិនគួរនិយាយថា មគ្គភាវនា របស់បុគ្គលដែលព្រម ព្រៀងដោយបញ្ចវិញ្ញាណ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ មិន កាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ។បេ។ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធរសដោយអណ្តាត ។បេ។ ពាល់ត្រូវ ផោដ្ឋព្វៈដោយកាយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ពាក្យ ដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គភាវនា របស់ បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណ មាន ។

**បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា ចប់**

# អដ្ឋកថា

## បញ្ចវិញ្ញាណសមង្គិស្សមគ្គកថា

[ ៩៤២-៩៤៣ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលព្រមព្រៀងដោយបញ្ចវិញ្ញាណ ចម្រើនមគ្គដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ការចម្រើនមគ្គ មានដល់បុគ្គលព្រមព្រៀងដោយបញ្ចវិញ្ញាណ ព្រោះអាស្រ័យព្រះសូត្រថា ភិក្ខុឃើញរូបដោយចក្ខុហើយ រមែងមិនកាន់យកដោយនិមិត្តជាដើម ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ កាលនោះ សកវាទីក៏ពោលថា **ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើការចម្រើនមគ្គ មានដល់បុគ្គលដែលព្រមព្រៀងដោយវិញ្ញាណ ៥ នោះសោត មគ្គ ក៏គប្បីមានគតិដូចវិញ្ញាណ ៥ ឬវិញ្ញាណ ៥ គប្បីមានគតិដូចមគ្គ តែបញ្ចវិញ្ញាណទាំងនោះ មិនមានគតិដូចមគ្គ ព្រោះមិនមានព្រះនិព្វានជាអារម្មណ៍ និងព្រោះមិនមែនលោកុត្តរ ទោះបីមគ្គ ក៏មិនមានគតិដូចគ្នានឹងបញ្ចវិញ្ញាណ ព្រោះមគ្គ សង្គ្រោះជាមួយបញ្ចវិញ្ញាណទាំងនោះមិនបានដោយលក្ខណៈ ដូច្នេះ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបអធិប្បាយថា បើមគ្គភាវនា គប្បីមានដល់បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណសោត មគ្គដែលសម្បយុត្តដោយមនោវិញ្ញាណណា មនោវិញ្ញាណនោះ ក៏គប្បីមានដល់បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណបាន ។ កាលបើយ៉ាងនេះ លោក

ពោលលក្ខណៈនេះថា បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយជាដើម អ្នកមិនគប្បីពោលពាក្យនោះយ៉ាងនេះ ហើយពោលថា វិញ្ញាណ ៦ តែអ្នកមិនពោលយ៉ាងនោះ ពោលត្រឹមតែពាក្យថា បញ្ចវិញ្ញាណ ដូច្នេះ ព្រោះហេតុនោះ បុគ្គលណាមួយ មិនគប្បីពោលថា មគ្គភាវនា មានដល់បុគ្គលដែលព្រមព្រៀងដោយបញ្ចវិញ្ញាណ ដូច្នេះ ព្រោះក្នុងសេចក្ដីនេះ មានអធិប្បាយយ៉ាងនេះឯង ព្រោះហេតុនោះ ទើបសកវាទីឲ្យបរវាទីទទួលលក្ខណៈនោះហើយ ក៏ពោលថា **តេ ច វត រេ វត្តព្វេ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា** ដូច្នេះ ។

ន័យម្យ៉ាងទៀត វិញ្ញាណ ៥ មានធម៌ដែលកើតឡើងហើយជាវត្ថុ ឯមគ្គ មិនមានវត្ថុ ។ វិញ្ញាណទាំង ៥ នោះ មានធម៌ដែលកើតឡើងហើយជាអារម្មណ៍ មគ្គ ជានវត្តព្វារម្មណ៍ ។ វិញ្ញាណ ៥ មានធម៌ដែលកើតឡើងមុនជាវត្ថុ មគ្គ មិនមានវត្ថុ ។ វិញ្ញាណទាំង ៥ នោះ មានធម៌ដែលកើតឡើងមុនជាអារម្មណ៍ប៉ុណ្ណោះ មគ្គ មិនមានធម៌ដែលកើតឡើងមុនជាអារម្មណ៍ ។ វិញ្ញាណទាំង ៥ នោះ មានធម៌ខាងក្នុងខ្លួនជាវត្ថុ មគ្គ មិនមានវត្ថុ ។ វិញ្ញាណទាំង ៥ នោះ មានធម៌ខាងក្រៅខ្លួនជាអារម្មណ៍ ដោយអំណាចនៃរូបជាដើម មគ្គ មាននិព្វានជាអារម្មណ៍ ។ វិញ្ញាណ ៥ មានធម៌ដែលមិនទាន់ទម្លាយជាវត្ថុ ព្រោះធ្វើវត្ថុដែលមិនទាន់បែកធ្លាយ ឲ្យជាទីអាស្រ័យ រួចប្រព្រឹត្តទៅ មគ្គ មិនមានវត្ថុ ។ វិញ្ញាណទាំង ៥ នោះ មានធម៌ដែលមិនទាន់បែកធ្លាយជាអារម្មណ៍ ព្រោះប្រារព្ធរូបជាដើម ដែលមិនទាន់បែកធ្លាយ

នោះឯងប្រព្រឹត្តទៅ មគ្គ មានព្រះនិព្វានជាអារម្មណ៍ ។ វិញ្ញាណទាំង ៥ នោះ មានវត្ថុផ្សេងគ្នា មគ្គ មិនមានវត្ថុ ឬមានវត្ថុមួយ ។ វិញ្ញាណទាំង ៥ នោះ មានអារម្មណ៍ផ្សេងគ្នា មគ្គ មានអារម្មណ៍មួយ ។ វិញ្ញាណទាំង ៥ នោះ មិនសោយអារម្មណ៍នៃគ្នានិងគ្នា ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍រៀងៗ ខ្លួន មាន រូបារម្មណ៍ជាដើម មគ្គ រមែងមិនធ្វើរូបារម្មណ៍ជាដើម ត្រឹមតែមួយឲ្យជា អារម្មណ៍ ។ វិញ្ញាណទាំង ៥ នោះ កើតឡើង ដោយមិនមានការដាក់ចិត្ត មិនមានការធ្វើទុកក្នុងចិត្តមិនបាន ព្រោះធ្វើកិរិយាមនោធាតុឲ្យជាបុរេចារិក ហើយកើតឡើង មគ្គ មិនមានអាវជ្ជនៈឡើយ វិញ្ញាណទាំង ៥ នោះ ដេរដាសដោយការទទួលអារម្មណ៍ទាំងឡាយកើតឡើង មគ្គ មិនមានការ លាយឡំគ្នាជាមួយវត្ថុដទៃ ។ វិញ្ញាណទាំង ៥ នោះ រមែងកើតឡើងដោយ ភាពមុនក្រោយនៃគ្នានិងគ្នា ការកើតមុន កើតក្រោយ របស់មគ្គ រួមជាមួយ នឹងវិញ្ញាណទាំង ៥ នោះ មិនមាន ព្រោះមគ្គ កើតឡើង ក្នុងកាលដែល វិញ្ញាណទាំង ៥ នោះមិនកើត ក្នុងសម័យដែលវិបស្សនាញាណចាស់ក្លា ក្នុង អរូបដែលជាទីដែលវិញ្ញាណ ៥ មិនកើត ។ វិញ្ញាណទាំង ៥ នោះ មិន កើតតគ្នានិងគ្នា ព្រោះមានសម្បដិច្ឆន្នចិត្តជាដើម ខណ្ឌក្នុងរវាងចន្លោះ ការ ខណ្ឌក្នុងរវាងដោយសម្បដិច្ឆន្នចិត្តជាដើមរបស់មគ្គ មិនមានឡើយ ។ កិច្ច របស់វិញ្ញាណទាំង ៥ នោះ វៀរចាកការដឹងចំពោះអារម្មណ៍របស់ខ្លួនហើយ សូម្បីត្រឹមតែការបង់ចិត្ត ក៏មិនមាន កិច្ចរបស់មគ្គ មានការដកនូវកិលេស ចោល ព្រោះក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅ ព្រោះហេតុនោះ ទើប

សកវាទីឲ្យបរវាទីទទួល នូវភាពដែលមគ្គមិនមានគតិ ដូចវិញ្ញាណទាំង ៥ នោះ ដោយអាការទាំងនេះហើយ ទើបពោលថា **ឆោ ច វត រេ វត្តព្វេ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា** ដូច្នេះ ។

[ ៩៤៤ ] បទថា **សុញ្ញតំ អារព្ភ** សេចក្តីថា សកវាទីសួរថា លោកុត្តរមគ្គ ប្រារព្ធសុញ្ញតនិព្វានកើតឡើង លោកិយមគ្គ ប្រារព្ធបុណ្យដែលជាសុទ្ធសង្ខារកើតឡើង យ៉ាងណា តាមលទ្ធិរបស់អ្នក ចក្ខុវិញ្ញាណក៏ប្រារព្ធកើតឡើង យ៉ាងនោះឬ បរវាទីឆ្លើយបដិសេធ ព្រោះព្រះបាលីថា ចក្ខុវិញ្ញាណកើត ព្រោះអាស្រ័យចក្ខុ និងរូប ។ ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួលដោយពាក្យថា វត្ថុណាមិនមាននិមិត្តក្នុងទីនោះ វត្ថុនោះឯង ឈ្មោះថាភាពទទេ ព្រោះបាលីថា មិនកាន់យកដោយនិមិត្ត ។ ក្នុង ២ បញ្ហាទៀតថា **ចក្ខុញ្ច បដិច្ច** ជាដើម ក៏ន័យនេះឯង ។

[ ៩៤៥ ] ក្នុងបទថា **ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ** នោះ មានអធិប្បាយដូចតទៅ ការចម្រើនមគ្គ មានដល់បុគ្គលព្រមព្រៀងដោយមនោ-វិញ្ញាណហើយ មនោវិញ្ញាណ រមែងកើតឡើង ព្រោះប្រារព្ធធម៌ដែលជាអតីត

និងអនាគត យ៉ាងណា សូម្បីចក្ខុវិញ្ញាណ តាមលទ្ធិរបស់អ្នក ក៏យ៉ាងនោះ ឬ ក្នុងបទទាំងឡាយថា **ជវស្សំ អាវត្ត** ក៏ន័យនេះឯង ។

[ ៩៤៦ ] ក្នុងបទថា **ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី** នេះ អធិប្បាយថា លោកពោលដល់ការមិនកាន់យកនិមិត្តក្នុងខណៈនៃជវនៈ មិនមែនក្នុងខណៈនៃចក្ខុវិញ្ញាណ ។ ព្រោះហេតុនោះ ពាក្យថា ចក្ខុវិញ្ញាណនេះ សំដៅយកត្រឹមតែជាលោកិយ ទើបអះអាងមិនបាន ។៚

**អដ្ឋកថាបញ្ចវិញ្ញាណសមង្គិស្សមគ្គកថា ចប់**

# អភិធម្មបិដក

## បញ្ចវិញ្ញាណាកុសលាបីតិកថា

[ ៩៤៧ ] បញ្ចវិញ្ញាណជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានទេ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតមុន មានអារម្មណ៍កើតមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រឡូកគ្នា មានអារម្មណ៍មិនប្រឡូកគ្នា មានវត្ថុផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលនូវគោចរវិស័យនៃគ្នានិងគ្នា មិនកើតឡើងអំពីការមិនពិចារណា មិនកើតឡើងអំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើងអំពីការមិនប្រឡូកប្រឡូកគ្នា មិនកើតឡើងមិនមុន មិនក្រោយ មិនកើតឡើងក្នុងលំដាប់ស្មើនៃគ្នានិងគ្នា ក្រែងបញ្ចវិញ្ញាណ មិនមានកំណត់ទុកក្នុងចិត្តទេ ឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនមានកំណត់ទុកក្នុងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានទេ ។

[ ៩៤៨ ] ចក្ខុវិញ្ញាណ ជាកុសលឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុ-វិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ

អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើង ឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យ ចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងទេ ។

[ ៩៤៩ ] ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធចិត្ត ។បេ។ ប្រារព្ធចក្ខុ ។បេ។ ប្រារព្ធកាយ ។បេ។ ប្រារព្ធសំឡេង ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ជាកុសលក៏មាន ជា អកុសលក៏មាន ឯមនោវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯមនោវិញ្ញាណ ប្រារព្ធ អតីត និងអនាគត ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏

មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯមនោវិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធចិត្ត ប្រារព្ធចក្ខុ ។បេ។ ប្រារព្ធកាយ ប្រារព្ធសំឡេង ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៥០ ] បុគ្គល មិនគួរនិយាយថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ជាអ្នកកាន់យកនូវនិមិត្ត ។បេ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ។បេ។ ឮសំឡេងដោយត្រចៀក ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ជាអ្នកកាន់យកនូវនិមិត្ត ។បេ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ។

## បញ្ចវិញ្ញាណាកុសលាបីតិកថា ចប់

# អដ្ឋកថា

## បញ្ចវិញ្ញាណាកុសលាបីតិកថា

[ ៩៤៧ ] ឥឡូវនេះ នឹងពណ៌នាអំពីបញ្ចវិញ្ញាណ ជាកុសលក៏មាន និងជាអកុសលក៏មានដូចតទៅ

ក្នុងរឿងនេះ បណ្ឌិតគប្បីជ្រាបដោយអត្ថ តាមន័យដែលខ្ញុំបានពោលហើយខាងដើមនោះឯង ។ល។

**អដ្ឋកថាបញ្ចវិញ្ញាណាកុសលាបីតិកថា ចប់**

# អភិធម្មបិដក

## បញ្ចវិញ្ញាណកាសាភោគាតិកថា

[ ៩៥១ ] បញ្ចវិញ្ញាណ ប្រកបដោយការសង្ឃឹមឬ ។ អើ ។ ក្រែង បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ប្រកបដោយការសង្ឃឹមទេ ។បេ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតមុន មានអារម្មណ៍កើតមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា មានវត្ថុផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលនូវគោចរវិស័យនៃគ្នានិងគ្នា មិនកើតឡើង អំពីការមិនពិចារណា មិនកើតឡើង អំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើង អំពីការមិនប្រឡូកប្រឡំគ្នា មិនមែនកើតឡើង មិនមុន មិនក្រោយ ក្រែងបញ្ចវិញ្ញាណ មិនកើតឡើង ក្នុងលំដាប់ស្មើនៃគ្នានិងគ្នាទេឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនកើតឡើង ក្នុងលំដាប់ស្មើនៃគ្នានិងគ្នាទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ប្រកបដោយការសង្ឃឹមទេ ។

[ ៩៥២ ] ចក្ខុវិញ្ញាណ ប្រកបដោយការសង្ឃឹមឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងសភាវៈសូន្យ ទើបកើតឡើងទេ ។

[ ៩៥៣ ] ចក្ខុវិញ្ញាណ ប្រកបដោយការសង្រួមឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្រួមឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ប្រកបដោយការសង្រួម មនោ-វិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្រួម ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ប្រកបដោយការសង្រួម មនោវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ប្រកបដោយការសង្រួម ចក្ខុវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ប្រកបដោយការសង្រួម មនោវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើត

ឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្ស័យ ចក្ខុវិញ្ញាណ ប្រារព្ធអតីត និងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនោវិញ្ញាណ ប្រកបដោយការសង្ស័យ មនោវិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្ស័យ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។បេ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៥៤ ] បុគ្គល មិនគួរនិយាយថា បញ្ចវិញ្ញាណ ប្រកបដោយការសង្ស័យទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ជាអ្នកកាន់យកនូវនិមិត្ត ។បេ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ជាអ្នកកាន់យកនូវនិមិត្ត ។បេ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បញ្ចវិញ្ញាណ ប្រកបដោយការសង្ស័យ ។បេ។

## បញ្ចវិញ្ញាណាសាភោគាតិកថា ចប់

# អដ្ឋកថា

## បញ្ចវិញ្ញាណកថាសាភោគាតិកថា

[ ៩៥១ ] ឥឡូវនេះ នឹងពណ៌នាអំពីបញ្ចវិញ្ញាណ មានការចងចិត្ត ដូចតទៅ

ក្នុងរឿងនោះ ឈ្មោះថា ការគិតពិចារណា រមែងមានដោយអំណាច នៃកុសល និងអកុសល ។ សេចក្ដីនេះ ព្រះសាស្ដាទ្រង់ត្រាស់ថា ភិក្ខុឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកដោយនិមិត្ត ... មិនកាន់យកដោយនិមិត្ត ដូច្នេះជាដើម ។ ជនទាំងឡាយណា កាន់យកព្យញ្ជនៈនោះ ដោយមិនពិចារណា ទើបមានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា វិញ្ញាណ ៥ មានការចងចិត្ត ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងរឿងមុននោះឯង ។៙

**អដ្ឋកថាបញ្ចវិញ្ញាណកថាសាភោគាតិកថា ចប់**

# អភិធម្មបិដក

## ទុសីលសមញ្ញាគតោតិកថា

[ ៩៥៥ ] បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសីល ២ ឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយផស្សៈ ២ វេទនា ២ សញ្ញា ២ ចេតនា ២ ចិត្ត ២ សទ្ធា ២ វីរិយៈ ២ សតិ ២ សមាធិ ២ បញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៥៦ ] បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសីល ជាលោកិយ ឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយផស្សៈ ជាលោកិយ វេទនា ជាលោកិយ សញ្ញា ជាលោកិយ ចេតនា ជាលោកិយ ចិត្ត ជាលោកិយ សទ្ធា ជាលោកិយ វីរិយៈ ជាលោកិយ សតិ ជាលោកិយ សមាធិ ជាលោកិយ បញ្ញា ជាលោកិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៥៧ ] បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសីល ជាលោកិយ និងលោកុត្តរឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយផស្សៈ ជាលោកិយ និងលោកុត្តរ ។បេ។ ប្រកបដោយបញ្ញា ជាលោកិយ និងលោកុត្តរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសីល ជាលោកិយឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ជាបុថុជ្ជនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៥៨ ] បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាវាចា ជាលោកិយឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាទិដ្ឋិ

ជាលោកិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ព្រមព្រៀង ដោយមគ្គ ប្រកបដោយសម្មាវាចា ជាលោកិយឬ ។ អើ ។ បុគ្គល ព្រម ព្រៀងដោយមគ្គ ប្រកបដោយសម្មាសង្កប្ប ជាលោកិយ ។បេ។ សម្មា- វាយាមៈ ជាលោកិយ ។បេ។ សម្មាសតិ ជាលោកិយ ។បេ។ សម្មាសមាធិ ជាលោកិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ព្រមព្រៀង ដោយមគ្គ ប្រកបដោយសម្មាកម្មន្តៈ ជាលោកិយ ។បេ។ សម្មាអាជីវៈ ជា លោកិយឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាទិដ្ឋិ ជាលោកិយ ។បេ។ សម្មាសមាធិ ជាលោកិយឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

[ ៩៥៩ ] បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាវាចា ជា លោកិយ និងលោកុត្តរឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកប ដោយសម្មាទិដ្ឋិ ជាលោកិយ និងលោកុត្តរឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។បេ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាវាចា ជាលោកិយ និងលោកុត្តរឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មា- សង្កប្ប ជាលោកិយ និងលោកុត្តរ ។បេ។ សម្មាវាយាមៈ ជាលោកិយ និង លោកុត្តរ ។បេ។ ដោយសម្មាសតិ ជាលោកិយ និងលោកុត្តរ ។បេ។ ដោយ សម្មាសមាធិ ជាលោកិយ និងលោកុត្តរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ព្រមព្រៀងដោយមគ្គ ( ប្រកប ) ដោយសម្មាកម្មន្តៈ ជា លោកិយ និងលោកុត្តរ ។បេ។

[ ៩៦០ ] បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាអាជីវៈ ជាលោកិយ និងលោកុត្តរឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាទិដ្ឋិ ជាលោកិយ និងលោកុត្តរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មាអាជីវៈ ជាលោកិយ និងលោកុត្តរឬ ។ អើ ។ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសម្មា-សង្កប្ប ជាលោកិយ និងលោកុត្តរឬ ។បេ។ ប្រកបដោយសម្មាសមាធិ ជាលោកិយ និងលោកុត្តរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦១ ] បុគ្គល មិនគួរនិយាយថា បុគ្គលព្រមព្រៀងដោយមគ្គ ប្រកបដោយសីល ២ ឬ ។ អើ ។ កាលសីល ជាលោកិយរលត់ទៅ មគ្គកើតឡើងឬ ។ អើ ។ បុគ្គល ទ្រុស្តសីល មានសីលធ្លុះធ្លាយ មានសីលដាច់ចម្រើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បុគ្គល ព្រមព្រៀងដោយមគ្គ ប្រកបដោយសីល ២ ។

**ទ្វិសីលសមន្នាគតោតិកថា ចប់**

# អដ្ឋកថា

## ទ្វិសីលសមន្នាគតោតិកថា

[ ៩៥៥ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គល ប្រកបដោយសីល ២ យ៉ាងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយនោះឯងថា ព្រោះបុគ្គលអ្នកមានសីល រមែងឲ្យលោកុត្តរមគ្គកើតដោយលោកិយសីលបាន តាមព្រះបាលី ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីល ដូច្នេះជាដើម ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា ជាអ្នកប្រកបដោយសីល ២ យ៉ាង គឺដោយលោកិយសីលដែលកើតមុន និងលោកុត្តរសីលក្នុងខណៈនៃមគ្គ ដូច្នេះ ពាក្យសួររបស់សកវាទីថា **មគ្គសមង្គី** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះទើបសកវាទីពោលថា **ទ្វីហិ ផស្សេហិ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើបុគ្គលនោះប្រកបដោយសីល ២ យ៉ាង គឺលោកិយសីល និងលោកុត្តរសីលក្នុងខណៈជាមួយគ្នាបានសោត បុគ្គលនោះ គប្បីជាអ្នកប្រកបដោយធម៌នីមួយៗ ២ មានផស្សៈ ២ ជាដើមបាន ដូច្នេះ ។ បរវាទី កាលមិនឃើញន័យដែលមានយ៉ាងនោះ ទើបឆ្លើយបដិសេធ ។

[ ៩៥៧ ] ក្នុងបញ្ហាថា **លោកិយេន ច លោកុត្តរេន ច** បរវាទីឆ្លើយសំដៅយកលោកិយសីល ដែលសមាទានហើយក្នុងកាលមុន និង

លោកុត្តរសីល ដែលមានសម្មាវាចាជាដើម ដែលកើតឡើងក្នុងខណៈនៃមគ្គ ទើបឆ្លើយទទួល ។

[ ៩៦១ ] ពាក្យសួរថា **លោកិយេ សីលេ និរុទ្ធេ** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី សំដៅយកការរលត់គឺការរលត់ក្នុងខណៈ ( ភង្គក្ខណៈ ) ។ បរវាទីនោះ កាលកំណត់ពាក្យថាសីលរលត់នោះ ដូចគ្នានឹងមានការកន្លងសីលទៀត ទើបសួរថា **ទុស្សីលោ** ជាដើម ។ ម្យ៉ាងទៀត ការតាំងលទ្ធិរបស់បរវាទីនោះ រមែងសម្តែងនូវភាពដែលបុគ្គលជាអ្នកមានសីលមិនដាច់មកអំពីមុនប៉ុណ្ណោះ មិនបានសម្តែងនូវភាពដែលបុគ្គលជាអ្នកប្រកបដោយសីល ២ យ៉ាង ព្រោះហេតុនោះ ទើបលទ្ធិនោះ ហាក់ដូចជាមិនបានតាំងទុក ដូច្នេះ ។l៙

## អដ្ឋកថាទុតិយសីលសមញ្ញាគតោតិកថា ចប់

# អភិធម្មបិដក

## សីលអចេតសិកន្តិកថា

[ ៩៦២ ] សីល មិនមែនជាចេតសិក ( មិនប្រកបដោយចិត្ត ) ទេឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។បេ។ កាយាយតនៈ ។បេ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( មិនមែនជាចេតសិក ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល មិនមែនជាចេតសិកទេឬ ។ អើ ។ ផស្សៈ មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល មិនមែនជាចេតសិកទេឬ ។ អើ ។ វេទនា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សទ្ធា ។បេ។ វិរិយៈ ។បេ។ សតិ ។បេ។ សមាធិ ។បេ។ បញ្ញា មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦៣ ] ផស្សៈ ជាចេតសិកឬ ។ អើ ។ សីល ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សទ្ធា ។បេ។ វិរិយៈ ។បេ។ សតិ ។បេ។ សមាធិ ។បេ។ បញ្ញា ជាចេតសិកឬ ។ អើ ។ សីល ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦៤ ] សីល មិនមែនជាចេតសិកទេឬ ។ អើ ។ សីល មានផលមិនជាទីប្រាថ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែង ( សីល ) មានផលជាទីប្រាថ្នាឬ ។ អើ ។ ប្រសិនបើ ( សីល ) មានផលជាទីប្រាថ្នា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សីល មិនមែនជាចេតសិកទេ ។

[ ៩៦៥ ] សទ្ធា មានផលជាទីប្រាថ្នា សទ្ធា ជាចេតសិកឬ ។ អើ ។

សីល មានផលជាទីប្រាថ្នា សីល ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វីរិយៈ សតិ សមាធិ ។បេ។ សញ្ញា មានផលជាទីប្រាថ្នា បញ្ញា ជាចេតសិកឬ ។ អើ ។ សីល មានផលជាទីប្រាថ្នា សីល ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦៦ ] សីល មានផលជាទីប្រាថ្នា សីល មិនមែនជាចេតសិកទេឬ ។ អើ ។ សទ្ធា មានផលជាទីប្រាថ្នា សទ្ធា មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល មានផលជាទីប្រាថ្នា សីល មិនមែនជាចេតសិកទេឬ ។ អើ ។ វីរិយៈ ។បេ។ សតិ សមាធិ ។បេ។ បញ្ញា មានផលជាទីប្រាថ្នា បញ្ញា មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦៧ ] សីល មិនមែនជាចេតសិកទេឬ ។ អើ ។ ( សីល ) មិនមានផល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែង ( សីល ) ប្រកបដោយផល ប្រកបដោយវិបាកឬ ។ អើ ។ ប្រសិនបើ ( សីល ) ប្រកបដោយផល ប្រកបដោយវិបាកមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សីល មិនមែនជាចេតសិកទេ ។បេ។

[ ៩៦៨ ] ចក្ខាយតនៈ មិនមែនជាចេតសិក មិនមានវិបាកទេឬ ។ អើ ។ សីល មិនមែនជាចេតសិក មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាយតនៈ ។បេ។ កាយាយតនៈ ។បេ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ មិនមែនជាចេតសិក មិនមានវិបាកទេឬ ។ អើ ។ សីល មិន

មែនជាចេតសិក មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦៩ ] សីល មិនមែនជាចេតសិក តែប្រកបដោយវិបាកឬ ។ អើ ។ ចក្ខាយតនៈ មិនមែនជាចេតសិក តែប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល មិនមែនជាចេតសិក តែប្រកបដោយវិបាកឬ ។ អើ ។ សោតាយតនៈ ។បេ។ កាយាយតនៈ ។បេ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ មិនមែនជាចេតសិក តែប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧០ ] សម្មាវាចា មិនមែនជាចេតសិកទេឬ ។ អើ ។ សម្មាទិដ្ឋិ មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាវាចា មិនមែនជាចេតសិកទេឬ ។ អើ ។ សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ មិនមែនជាចេតសិកទេឬ ។ អើ ។ សម្មាទិដ្ឋិ មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាអាជីវៈ មិនមែនជាចេតសិកទេឬ ។ អើ ។ សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ មិនមែនជាចេតសិកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧១ ] សម្មាទិដ្ឋិ ជាចេតសិកឬ ។ អើ ។ សម្មាវាចា ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាទិដ្ឋិ ជាចេតសិកឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ សម្មាសតិ ។បេ។ សម្មាសមាធិ ជាចេតសិកឬ ។ អើ ។ សម្មាវាចា ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាសមាធិ ជាចេតសិកឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាចេតសិកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧២ ] បុគ្គល មិនគួរនិយាយថា សីល មិនមែនជាចេតសិកទេឬ ។ អើ ។ កាលសីលកើតឡើងហើយ រលត់ទៅ បុគ្គល ឈ្មោះថា ទ្រុស្តសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ សីល មិនមែនជាចេតសិកទេ ។

សីលអចេតសិកន្តិកថា ចប់

# អដ្ឋកថា

## សីលអចេតសិកត្ថិកថា

[ ៩៦២ ] ឥឡូវនេះ នឹងពណ៌នាអំពីសីល មិនមែនជាចេតសិកដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ព្រោះកាលសីលកើតឡើង រលត់ទៅហើយឈ្មោះថា មានការសន្សំសីលដែលមានការសមាទានជាហេតុ ដែលជាហេតុឲ្យបុគ្គល ឈ្មោះថា ជាអ្នកមានសីល ព្រោះហេតុនោះឯង ទើបសីលមិនមែនចេតសិក ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងរឿងទាន មិនមែនចេតសិកនោះឯង ។ សូម្បីបរវាទីឲ្យលទ្ធិតាំងហើយ ក៏មិនអាចតាំងទុកបាន ព្រោះកាន់យកព្រះសូត្រ ដោយមិនបានពិចារណា ដូច្នេះ ៗ។

**អដ្ឋកថាសីលអចេតសិកត្ថិកថា ចប់**

# អភិធម្មបិដក

## សីលឆចិត្តានុបរិវត្តិតិកជា

[ ៩៧៣ ] សីល មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( មិនប្រព្រឹត្តទៅតាមចិត្ត ) ទេឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ សីល មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អើ ។ ផស្សៈ មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អើ ។ វេទនា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញា មិនប្រព្រឹត្តទៅ តាមចិត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧៤ ] ផស្សៈ ប្រព្រឹត្តទៅតាមចិត្តឬ ។ អើ ។ សីល ប្រព្រឹត្តទៅ តាមចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ចេតនា សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញា ប្រព្រឹត្តទៅតាមចិត្តឬ ។ អើ ។ សីល ប្រព្រឹត្តទៅតាមចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧៥ ] សម្មាវាចា មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អើ ។ សម្មាទិដ្ឋិ មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាវាចា មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អើ ។ សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ មិន ប្រព្រឹត្តទៅតាមចិត្តទេឬ ។ អើ ។ សម្មាទិដ្ឋិ មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាអាជីវៈ មិនប្រព្រឹត្តទៅតាមចិត្តទេ ឬ ។ អើ ។ សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ មិនប្រព្រឹត្តទៅតាមចិត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧៦ ] សម្មាទិដ្ឋិ ប្រព្រឹត្តទៅតាមចិត្តឬ ។ អើ ។ សម្មាវាចា ប្រព្រឹត្តទៅតាមចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាទិដ្ឋិ ប្រព្រឹត្តទៅតាមចិត្តឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ប្រព្រឹត្តទៅតាមចិត្ត ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧៧ ] សម្មាសង្កប្ប ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ ប្រព្រឹត្តទៅតាមចិត្តឬ ។ អើ ។ សម្មាវាចា ប្រព្រឹត្តទៅចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាសមាធិ ប្រព្រឹត្តទៅចិត្តឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ប្រព្រឹត្តទៅតាមចិត្តឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៩៧៨ ] បុគ្គល មិនគួរនិយាយថា សីល មិនប្រព្រឹត្តទៅតាមចិត្តទេ ឬ ។ អើ ។ កាលសីលកើតឡើងហើយ រលត់ទៅ បុគ្គល ឈ្មោះថា ទុស្សីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ សីល មិនប្រព្រឹត្តទៅតាមចិត្តទេ ។

**សីលនចិត្តានុបរិវត្តិតិកថា ចប់**

# អដ្ឋកថា

## សីលនចិត្តានុបរិវត្តីតិកថា

[ ៩៧៣ ] ឥឡូវនេះ នឹងពណ៌នាអំពីសីល មិនអនុលោមតាមចិត្ត

ក្នុងរឿងនោះ បទថា **ន ចិត្តានុបរិវត្តិ** ជាការផ្សេងគ្នា រវាងកាសា

ប៉ុណ្ណោះ ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននោះឯង ។៚

**អដ្ឋកថាសីលនចិត្តានុបរិវត្តីតិកថា ចប់**

# អភិធម្មបិដក

## សមាទានហេតុកកថា

[ ៩៧៩ ] សីល មានការសមាទានជាហេតុ ទើបចម្រើនឬ ។ អើ ។ ផស្សៈ មានការសមាទានជាហេតុ ទើបចម្រើន វេទនា ទើបចម្រើន សញ្ញា ទើបចម្រើន ចេតនា ទើបចម្រើន ចិត្ត ទើបចម្រើន សទ្ធា ទើបចម្រើន វិរិយៈ ទើបចម្រើន សតិ ទើបចម្រើន សមាធិ ទើបចម្រើន បញ្ញា ( មានការសមាទានជាហេតុ ) ទើបចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៨០ ] សីល មានការសមាទានជាហេតុ ទើបចម្រើនឬ ។ អើ ។ ( សីល ) ចម្រើនដូចជាវល្លិ ចម្រើនដូចជាពួរជ្រៃ ចម្រើនដូចជាឈើ ចម្រើនដូចជាស្មៅ ចម្រើនដូចជាគុម្ពស្មៅយាប្លងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៨១ ] សីល មានការសមាទានជាហេតុ ទើបចម្រើនឬ ។ អើ ។ កាលបុគ្គលសមាទានសីលហើយ ត្រិះរិះនូវកាមវិតក្ក ត្រិះរិះនូវព្យាបាទវិតក្ក ត្រិះរិះវិហេសាវិតក្ក សីល ទើបចម្រើនឬ ។ អើ ។ ការប្រជុំនៃផស្សៈពីរ ។បេ។ នៃចិត្ត ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំនៃផស្សៈ ២ ។បេ។ នៃចិត្ត ២ មានឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់កាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប

និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតដែលឆ្ងាយ ក្រៃលែងឆ្ងាយ ( អំពីគ្នា ) នេះ មាន ៤ ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងផែនដីនេះ ជាធម្មជាតឆ្ងាយ ក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស ឆ្ងាយ អំពីពួកអសប្បុរស ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុ នោះ អ្នកមិនគួរពោលថា ពួកធម៌ជាកុសល និងអកុសល ប្រកបដោយ ទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខទេ ។

[ ៩៨២ ] បុគ្គល មិនគួរនិយាយថា សីល មានការសមាទានជាហេតុ ទើបចម្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ( ពួកជន ណា ) ដាំសួនច្បារ ដាំឈើ ។បេ។ ជនទាំងនោះ ជាអ្នកតាំងនៅក្នុងធម៌ បរិបូរណ៍ដោយសីល ទៅកាន់ស្ថានសួគ៌ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សីល មានការសមាទានជាហេតុ ទើបចម្រើន ។

## សមាទានហេតុកកថា ចប់

# អដ្ឋកថា

## សមាទានហេតុកកថា

[ ៩៧៩ ] ឥឡូវនេះ នឹងពណ៌នាអំពីសីល មានការសមាទានជាហេតុ ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយនោះឯងថា សីល ដែលមានការសមាទានជាហេតុ រមែងចម្រើនបាន ព្រោះព្រះបាលីដែលកាន់យកអត្ថ ដោយមិនពិចារណាក្នុងរឿងកសាងអារាមថា បុណ្យ រមែងចម្រើនសព្វកាល ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី សំដៅយកការសន្សំសីល ដែលមិនប្រកបដោយចិត្ត ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននោះឯង ដូច្នេះ ។

**អដ្ឋកថាសមាទានហេតុកកថា ចប់**

# អភិធម្មបិដក

## វិញ្ញត្តិសីលន្តិកថា

[ ៩៨៣ ] វិញ្ញត្តិ[១] ជាសីលឬ ។ អើ ។ ការវៀរចាកបាណាតិបាត ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកអទិន្នាទាន ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកកាមេសុ-មិច្ឆាចារ ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកមុសាវាទ ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការក្រាបសំពះ ជាសីល ការក្រោកទទួល ជាសីល ការធ្វើអញ្ជលី ជាសីល ការធ្វើសេចក្តីគោរពក្រែង ជាសីល ការនាំមកនូវទីអង្គុយ ជាសីល ការនាំមកនូវទីដេក ជាសីល ការនាំមកនូវទឹកលាងជើង ជាសីល ការនាំមកនូវកំណល់ជូតជើង ជាសីល ការបរិកម្មនូវខ្លួន ( ដុសក្អែល ) ក្នុងការងូតទឹក ជាសីលឬ ។ អើ ។ ការវៀរចាកបាណាតិបាត ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការ

---

១- សំដៅយកវិញ្ញត្តិដែលជាកាយកម្ម និងវចីវិញ្ញត្តិដែលជាវចីកម្ម ។

វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ជាសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៨៤ ] បុគ្គល មិនគួរនិយាយថា វិញ្ញត្តិ ជាសីលទេឬ ។ អើ ។ ( វិញ្ញត្តិ ) ជាភាពរបស់បុគ្គលទ្រុស្តសីលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ វិញ្ញត្តិជាសីល ។

វិញ្ញត្តិសីលន្តិកថា ចប់

# អដ្ឋកថា

## វិញ្ញត្តិសីលន្តិកថា

[ ៩៨៤ ] ឥឡូវនេះ នឹងពណ៌នាអំពីវិញ្ញត្តិ ជាសីលដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈ និងនិកាយសមិតិយៈទាំងឡាយថា វិញ្ញត្តិ គឺការកម្រើកកាយនិងវាចា ជាសីល ព្រោះកាន់យកថា កាយវិញ្ញត្តិ ជាកាយកម្ម វចីវិញ្ញត្តិ ជាវចីកម្ម ដូច្នេះ ពាក្យសួររបស់សកវាទីថា **វិញ្ញត្តិ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ព្រោះចេតនាជាគ្រឿងវៀរ ឈ្មោះថា សីល រូបធម៌មិនមែនជាសីល ព្រោះហេតុនោះ សកវាទីដើម្បីចោទសួរបរវាទីនោះ ដោយអត្ថនោះ ទើបពោលពាក្យថា **ចាណាតិចាតា វេរមណី** ជាដើម ។ បទថា **អភិវាទនំ សីលំ** ជាដើម លោកពោលដើម្បីលើកមកសម្តែងនូវវិញ្ញត្តិយ៉ាងនោះ ដែលបញ្ញត្តិថា សីល ។ ព្រោះវិញ្ញត្តិនោះ មិនមែនចេតនាជាគ្រឿងវៀរ ព្រោះហេតុនោះ ទើបសកវាទីពោលពាក្យថា **ចាណាតិចាតា** ជាដើមទៀត ។ លទ្ធិរបស់បរវាទីនោះ ឈ្មោះថា តាំងនៅមិនបាន ព្រោះតាំងនៅចំពោះហើយ ដោយលេសន័យដូច្នេះ ។ល។

**អដ្ឋកថាវិញ្ញត្តិសីលន្តិកថា ចប់**

# អភិធម្មបិដក

## អវិញ្ញត្តិទុស្សីល្យន្តិកថា

[ ៩៨៥ ] អវិញ្ញត្តិ[១] ជាភាពទ្រុស្តឬ ។ អើ ។ ការសម្លាប់សត្វ ( ជាភាពទ្រុស្តសីល ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការកាន់យកទ្រព្យដែលគេមិនឲ្យ ( ជាភាពទ្រុស្តសីល ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រព្រឹត្តខុសក្នុងពួកកាម ( ជាភាពទ្រុស្តសីល ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការនិយាយកុហក ( ជាភាពទ្រុស្តសីល ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ( ជាភាពទ្រុស្តសីល ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុណ្យ និងមិនមែនបុណ្យ ( បាប ) ទាំង ២ នៃបុគ្គលសមាទានបាបកម្មហើយឲ្យទាន រមែងចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុណ្យ និងមិនមែនបុណ្យ ទាំង ២ រមែងចម្រើនឬ ។ អើ ។ ការប្រជុំនៃផស្សៈ ២ ។បេ។ នៃចិត្ត ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំនៃផស្សៈ ២ ។បេ។ នៃចិត្ត ២ មានឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មក

---

១- បានដល់ ការធ្វើបាប ប្រាសចាកចិត្តប៉ុនដោយបន្តាប់ ។

កាន់ភាពចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ ធម្មជាតដែលឆ្ងាយក្រៃលែងឆ្ងាយ នេះមាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងផែនដីនេះ ជាធម្មជាតឆ្ងាយក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះ ហេតុនោះ ធម៌របស់ពួកសប្បុរស ឆ្ងាយអំពីពួកអសប្បុរស ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ពួកធម៌ ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខទេ ។ កាលបុគ្គល សមាទានបាបកម្មហើយ ឲ្យចីវរ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលាន-ប្បច្ចយភេសជ្ជបរិក្ខារ ក្រាបសំពះ ចំពោះបុគ្គលដែលគួរក្រាបសំពះ ក្រោក ទទួល ចំពោះបុគ្គលដែលគួរក្រោកទទួល ធ្វើអញ្ជលីកម្ម ចំពោះបុគ្គលដែល គួរធ្វើអញ្ជលីកម្ម គោរពក្រែង ចំពោះបុគ្គលដែលគួរដល់សាមីចិកម្ម ឲ្យអាសនៈ ដល់បុគ្គលដែលគួរដល់អាសនៈ បង្ហាញផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ បុណ្យ និងមិនមែនបុណ្យ ទាំង ២ រមែងចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។បេ។ បុណ្យ និងមិនមែនបុណ្យទាំង ២ រមែងចម្រើនឬ ។ អើ ។ ការ ប្រជុំនៃផស្សៈ ២ ។បេ។ នៃចិត្ត ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។បេ។ ការប្រជុំនៃផស្សៈ ២ ។បេ។ នៃចិត្តពីរ មានឬ ។ អើ ។ ពួកធម៌ ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយនេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងផែនដីនេះ ជាធម្មជាតឆ្ងាយក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស ឆ្ងាយអំពីពួកអសប្បុរស ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និងស មកកាន់ភាពចំពោះមុខទេ ។

[ ៩៨៦ ] បុគ្គល មិនគួរនិយាយថា អវិញ្ញត្តិជាភាពទ្រុស្តសីលឬ ។ អើ ។ ក្រែងបុគ្គលសមាទានបាបកម្ម មានឬ ។ អើ ។ ប្រសិនបើ បុគ្គលសមាទានបាបកម្ម មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អវិញ្ញត្តិ ជាភាពទ្រុស្តសីល ។

អវិញ្ញត្តិទុស្សីល្យន្តិកថា ចប់

ទសមវគ្គ ចប់

## ឧទ្ទាននៃទសមវគ្គនោះ គឺ

និយាយអំពីរូប របស់បុគ្គលព្រមព្រៀងដោយមគ្គជាមគ្គ ១ មគ្គភាវនា របស់បុគ្គលព្រមព្រៀងដោយបញ្ចវិញ្ញាណមាន ១ បញ្ចវិញ្ញាណជាកុសលក៏មាន ជាអកុសលក៏មាន ១ បញ្ច-វិញ្ញាណប្រកបដោយការសង្សឹម ១ បុគ្គលព្រមព្រៀងដោយមគ្គ ប្រកបដោយសីលពីរ ១ សីលមិនមែនជាចេតសិក ១ សីលមិនប្រព្រឹត្តទៅតាមចិត្ត ១ សីលមានការសមាទានជាហេតុ ទើបចម្រើន ១ វិញ្ញត្តិជាសីល ១ អវិញ្ញត្តិជាភាពទ្រុស្តសីល ១ ។

### ទុតិយបណ្ណាសក ចប់

( ក្នុងទុតិយបណ្ណាសកនេះ ) និយាយអំពីនិយាម ( ជាដើម ) សង្គហៈ ( ជាដើម ) គតិ ( ជាដើម ) អានិសង្សជាបញ្ច-វោការគត ( ជាដើម ) និងនិរោធ ជាបញ្ចវោការគត របស់បុគ្គលព្រមព្រៀងដោយមគ្គ ( ជាដើម ) ។

# អដ្ឋកថា

## អវិញ្ញត្តិទុស្សីល្យន្តិកថា

[ ៩៨៣ ] ឥឡូវនេះ នឹងពណ៌នាអំពីអវិញ្ញត្តិ គឺការមិនកម្រើកកាយវាចា ជាភាពទ្រុស្តសីលដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា អវិញ្ញត្តិ ជាការទ្រុស្តសីល ព្រោះសំដៅយកការសន្សំវត្ថុដែលមិនមែនបុណ្យ ដែលមិនប្រកបដោយចិត្ត និងសំដៅយកភាពបរិបូរណ៍នៃអង្គរបស់ការប្រើ ក្នុងបាណាតិបាតជាដើម ។ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **បាណាតិបាតោ** ជាដើម ដើម្បីចោទបរវាទីនោះថា បើអវិញ្ញត្តិនោះ គប្បីជាការទ្រុស្តសីលណាមួយ ក្នុងបាណាតិបាតជាដើមសោត ដូច្នេះ ។ បទថា **បាបកម្មំ សមាទិយិត្វា** អធិប្បាយថា ធ្វើនូវការសមាទានបាបយ៉ាងនេះថា អញនឹងសម្លាប់បុគ្គលឈ្មោះនោះ អញនឹងលួចកណ្ឌៈនោះជាដើម ។ ត្រូវសកវាទីសួរថា **ឧភោ វឌ្ឍន្តិ** បរវាទីសំដៅយកការមិនកើតឡើងនៃបាបក្នុងខណៈឲ្យទាន ទើបឆ្លើយ

បដិសេធ ។ ត្រូវសួរលើកទី ២ សំដៅយកការសន្សំបាប ដែលមិនប្រកប ជាមួយចិត្ត ទើបឆ្លើយទទួល ។ ពាក្យដ៏សេស ក្នុងទីនេះ គប្បីជ្រាបដោយ ន័យដែលពោលក្នុងរឿងបុណ្យ សម្រេចអំពីការបរិភោគនោះឯង ។ សូម្បី ការតាំងលទ្ធិរបស់បរវាទីនោះ រមែងសម្រេចក្នុងចំណែកខាងដើម គឺក្នុងការ សមាទានបាប តែមិនសម្រេចភាពជាអ្នកទ្រុស្តសីល ព្រោះអវិញ្ញត្តិ ដូច្នេះឯង ៗ៚

**អដ្ឋកថាអវិញ្ញត្តិទុស្សីល្យន្តិកថា ចប់**

**វគ្គទី ១០ ចប់**

**ទុតិយបណ្ណាសក ចប់**

# អភិធម្មបិដក-៨៦

# កថាវត្ថុ តតិយភាគ

## តិស្សោបិ អនុសយកថា

[ ១ ] *សកៈ អនុស័យ ជាអព្យាក្រឹតឬ ។ បរៈ ។ អើ ។ វិបាក និង អព្យាក្រឹត កិរិយា និងអព្យាក្រឹត រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាអព្យាក្រឹត ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។*

[ ២ ] *កាមរាគានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ កាមរាគបរិយុដ្ឋាន ។បេ។ កាមច្ឆន្ទនីវរណៈ ជាអកុសលឬ ។ អើ ។ កាមរាគានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។*

[ ៣ ] *បដិឃានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ បដិឃៈ បដិឃបរិយុដ្ឋាន បដិឃសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ បដិឃៈ បដិឃបរិយុដ្ឋាន បដិឃសញ្ញោជនៈ ជាអកុសល ដែរឬ ។ អើ ។ បដិឃានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។*

[ ៤ ] *មានានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ មានះ មានបរិយុដ្ឋាន*

មានសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មានៈ មានបរិយុដ្ឋាន មានសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ មានានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥ ] ទិដ្ឋានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ ទិដ្ឋិ ទិដ្ឋោឃៈ ទិដ្ឋិយោគៈ ទិដ្ឋិបរិយុដ្ឋាន ទិដ្ឋិសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទិដ្ឋិ ទិដ្ឋោឃៈ ទិដ្ឋិយោគៈ ទិដ្ឋិបរិយុដ្ឋាន ទិដ្ឋិសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ ទិដ្ឋានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦ ] វិចិកិច្ឆានុស័យ ជាអព្យាក្រឹតដែរឬ ។ អើ ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋាន វិចិកិច្ឆាសញ្ញោជនៈ វិចិកិច្ឆានីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋាន វិចិកិច្ឆាសញ្ញោជនៈ វិចិកិច្ឆានីវរណៈ ជាអកុសលឬ ។ អើ ។ វិចិកិច្ឆានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧ ] ភវរាគានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ ភវរាគៈ ភវរាគបរិយុដ្ឋាន ភវរាគសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភវរាគៈ ភវរាគបរិយុដ្ឋាន ភវរាគសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ ភវរាគានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨ ] អវិជ្ជានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ

អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋាន អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋាន អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ ជាអកុសលឬ ។ អើ ។ អវិជ្ជានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩ ] បុគ្គល មិនគួរពោលថា អនុស័យ ជាអព្យាក្រឹតទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយអនុស័យឬ ។ អើ ។ កុសលធម៌ និងអកុសលធម៌ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អនុស័យ ជាអព្យាក្រឹត ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យា-ក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ កុសលធម៌ និងអកុសលធម៌ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ រាគៈជាអព្យាក្រឹត ។

[ ១០ ] អនុស័យ មិនមានហេតុទេឬ ។ អើ ។ រូប និព្វាន ចក្ខា-យតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( មិនមានហេតុ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគានុស័យ មិនមានហេតុឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ ។បេ។ កាមច្ឆន្ទនីវរណៈ មិនមានហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ កាមរាគ-បរិយុដ្ឋាន ។បេ។ កាមច្ឆន្ទនីវរណៈ ប្រកបដោយហេតុឬ ។ អើ ។ កាមរាគា-

នុស័យ ប្រកបដោយហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិឃានុស័យ ។បេ។ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ មិនមានហេតុឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋាន អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ មិនមានហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា អវិជ្ជោឃៈ ។បេ។ អវិជ្ជានីវរណៈ ប្រកបដោយហេតុឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១ ] បុគ្គល មិនគួរពោលថា អនុស័យមិនមានហេតុទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ អនុស័យប្រកបដោយហេតុដោយហេតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អនុស័យ មិនមានហេតុ ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ រាគៈ ប្រកបដោយហេតុ ដោយហេតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ រាគៈ មិនមានហេតុទេ ។

[ ១២ ]អនុស័យ ប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ប្រាសចាកចិត្ត ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគានុស័យ ប្រាសចាកចិត្តដែរឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទ-

នីវរណៈ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ កាមរាគបរិយុដ្ឋាន ។បេ។ កាមច្ឆន្ទនីវរណៈ ប្រកបដោយចិត្តឬ ។ អើ ។ កាមរាគានុស័យ ប្រកបដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣ ] កាមរាគានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ កាមរាគានុស័យ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤ ] កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អើ ។ កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥ ] កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្ត កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ខ្លះប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦ ] បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ ។បេ។ អវិជ្ជានីវរណៈ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ ។បេ។ អវិជ្ជានីវរណៈ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា-នុស័យ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អើ ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ចុះអវិជ្ជាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ខ្លះប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។

[ ១៧ ] បុគ្គល មិនគួរពោលថា អនុស័យ ប្រាសចាកចិត្តទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹតកំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ អនុស័យ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ អនុស័យប្រាសចាកចិត្ត ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹតកំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា ប្រកបដោយរាគៈដែរឬ ។ អើ ។ រាគៈ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ រាគៈប្រាសចាកចិត្ត ។

## តិស្សោបិ អនុសយកថា ចប់

# អដ្ឋកថា

## តិស្សោបិ អនុសយកថា

[ ១ ] ឥឡូវនេះ នឹងពណ៌នាអំពីអនុស័យ ជាធម៌ទាំង ៣ គឺជាអព្យាកត ជាអហេតុកៈ និងជាចិត្តវិប្បយុត្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈ និងនិកាយសម្មិតិយៈទាំងឡាយថា ព្រោះបុថុជ្ជន កាលចិត្តដែលជាកុសល និងអព្យាកត ដែលកំពុងប្រព្រឹត្តទៅ គប្បីពោលថា ជាអ្នកមានអនុស័យ ម្យ៉ាងទៀត ហេតុឯណា គប្បីមានក្នុងខណៈនោះ អនុស័យទាំងឡាយ មិនជាសហេតុកៈដោយហេតុនោះផង មិនសម្បយុត្តជាមួយចិត្តដូងនោះផង ព្រោះហេតុនោះ ទើបអនុស័យទាំងនោះ ជាអព្យាកត ជាអហេតុកៈ ជាចិត្តវិប្បយុត្ត ដូច្នេះ ពាក្យសួររបស់សកវាទីក្នុងរឿងទាំង ៣ សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសអាចដឹងបាន តាមគន្លងនៃព្រះបាលីនោះឯង ព្រោះមានន័យដែលបានពោលហើយខាងដើម ព្រោះហេតុនោះ ទើបខ្ញុំមិនធ្វើឲ្យពិស្តារ ដូច្នេះ ។ល។

**អដ្ឋកថាតិស្សោបិអនុសយកថា ចប់**

# អភិធម្មបិដក

## ញាណកថា

[ ១៨ ] កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលមិនគួរនិយាយថា មានញាណទេឬ ។ អើ ។ កាលបើរាគៈ ប្រាសចេញហើយ បុគ្គលមិនគួរនិយាយថា មានរាគៈ ទៅប្រាសហើយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលមិនគួរនិយាយថា មានញាណទេឬ ។ អើ ។ កាលបើទោសៈ ប្រាសចេញហើយ ។បេ។ កាលបើមោហៈ ប្រាសចេញហើយ ។បេ។ កាលបើកិលេស ប្រាសចេញហើយ បុគ្គលមិនគួរនិយាយថា មិនមានកិលេសទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩ ] កាលបើរាគៈ ប្រាសចេញហើយ បុគ្គលគួរនិយាយថា មានរាគៈ ទៅប្រាសហើយឬ ។ អើ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលបើទោសៈ

ប្រាសចេញហើយ ។បេ។ កាលបើមោហៈ ប្រាសចេញហើយ ។បេ។ កាលបើកិលេស ប្រាសចេញហើយ បុគ្គលគួរនិយាយថា មិនមានកិលេសទេឬ ។ អើ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អើ ។ បុគ្គលមានញាណ ដោយញាណជាអតីត មានញាណ ដោយញាណដែលរលត់ហើយ ប្រាសចេញហើយ ស្ងប់រម្ងាប់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ញាណកថា ចប់

# អដ្ឋកថា

## ញាណកថា

[ ១៨-១៩ ] ឥឡូវនេះ នឹងពោលអំពីញាណដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា កាលការមិនដឹង គឺអញ្ញាណទៅប្រាសហើយដោយមគ្គញ្ញាណ កាលចិត្តដែលជាញាណវិប្បយុត្តកំពុងប្រព្រឹត្តទៅ ដោយអំណាចចក្ខុវិញ្ញាណជាដើមទៀត ក៏មិនគួរពោលថា មានញាណ ព្រោះហេតុដែលមគ្គចិត្តនោះ មិនប្រព្រឹត្តទៅ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះសកវាទីក៏ពោលពាក្យថា **រាគោ វិគតោ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើអញ្ញាណទៅប្រាសហើយ បញ្ញត្តិថា ជាបុគ្គលមានញាណ ដូច្នេះ មិនគប្បីមានសោត កាលរាគៈជាដើម ទៅប្រាសហើយ សូម្បីបញ្ញត្តិថា ជាអ្នកប្រាសចាករាគៈជាដើម ក៏មិនគប្បីមានសោត ដោយហេតុនោះ អ្នករមែងជាបុគ្គលមិនឈ្លាសក្នុងបញ្ញត្តិ ពោលដោយបុគ្គល ។ បរវាទី កាលមិនឃើញការត្រឹមត្រូវ ក្នុងភាពជាអ្នកមានរាគៈជាដើម ក្នុងកាលរាគៈជាដើម ទៅប្រាសហើយ ទើបឆ្លើយបដិសេធ ។

ក្នុងទីបំផុត ព្រោះបុគ្គលគួរត្រូវពោលថា ជាអ្នកមានញាណ ព្រោះការបានញាណ ព្រោះហេតុនោះ ទើបសកវាទីឆ្លើយបដិសេធថា **ន ហេវំ** ដូច្នេះ ។ ៚

# អភិធម្មបិដក

## ញាណចិត្តវិប្បយុត្តន្តិកថា

[ ២០ ] ញាណប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ប្រាសចាកចិត្ត ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណប្រាសចាកចិត្តដែរឬ ។ អើ ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ប្រកបដោយចិត្តឬ ។ អើ ។ ញាណប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១ ] ញាណប្រាសចាកចិត្តឬ ។ អើ ។ ញាណរាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អើ ។ បញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អើ ។ ញាណដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តហើយ ចុះបញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។

អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២ ] បុគ្គល មិនគួរនិយាយថា ញាណប្រាសចាកចិត្តទេឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយចក្ខុវិញ្ញាណ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អើ ។ ញាណ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ញាណប្រាសចាកចិត្ត ។ ព្រះអរហន្ត ប្រកបដោយចក្ខុវិញ្ញាណ បុគ្គលគួរនិយាយថា មានបញ្ញាដែរឬ ។ អើ ។ បញ្ញា ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ បញ្ញា ប្រាសចាកចិត្ត ។

ញាណចិត្តវិប្បយុត្តត្តិកថា ចប់

# អដ្ឋកថា

## ញាណចិត្តវិប្បយុត្តក្ថិកថា

[ ២០-២២ ] ឥឡូវនេះ ជាការពោលអំពីញាណ ដែលមិនប្រកប ដោយចិត្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយ បុព្វសេលិយៈទាំងឡាយថា ព្រោះព្រះអរហន្តដែលដល់ព្រមដោយចក្ខុវិញ្ញាណ ជាដើម លោកហៅថា ជាអ្នកមានញាណ ព្រោះសំដៅយកមគ្គញ្ញាណ ដែល លោកបានហើយ តែញាណរបស់ព្រះអរហន្តនោះ មិនសម្បយុត្តដោយ ចក្ខុវិញ្ញាណចិត្តនោះ ព្រោះហេតុនោះ ទើបញាណមិនប្រកបជាមួយចិត្ត ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជា ពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **រូបំ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើញាណតាមលទ្ធិរបស់អ្នក ជាចិត្តវិប្បយុត្ត សោត ញាណនោះ ក៏គប្បីជាធម៌ឯណានីមួយ ក្នុងរូបជាដើម ដែលជាចិត្ត-វិប្បយុត្ត ដូច្នេះ ។ បរវាទីឆ្លើយបដិសេធ ។ ពាក្យដ៏សេស មានន័យដូច ពោលហើយខាងដើមនោះឯង ។ ក្នុងទីបំផុត ត្រូវសកវាទីសួរថា **បញ្ញវា** បរវាទីប្រាថ្នានូវពាក្យបញ្ញត្តិនោះ ដោយអំណាចនៃការបានចំពោះហើយ នូវ បញ្ញា ព្រោះហេតុនោះ ទើបឆ្លើយទទួល ។l៚

**អដ្ឋកថាញាណចិត្តវិប្បយុត្តក្ថិកថា ចប់**

# អភិធម្មបិដក

## ឥន្ទ្រិយយមក ឧទ្ទុក្ខន្តិកកថា

[ ២៣ ] បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាហេតុនាំឲ្យកើតទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទីរម្ងត់ទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទីរម្ងត់ទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាមគ្គ ញាណប្រព្រឹត្តទៅថា នេះជាមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤ ] បុគ្គល កាលនិយាយវាចាថា នេះជាហេតុនាំឲ្យកើតទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា នេះជាទីរម្ងត់ទុក្ខ ។បេ។ នេះជាមគ្គ តែញាណមិនប្រព្រឹត្តទៅថា នេះជាមគ្គឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥ ] បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅ

ថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា រូបមិនទៀង ញាណ ប្រព្រឹត្តទៅថា រូបមិនទៀងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា វេទនា ។បេ។ សញ្ញា សង្ខារ ។បេ។ វិញ្ញាណ មិនទៀង ញាណ ប្រព្រឹត្តទៅថា វិញ្ញាណ មិនទៀងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦ ] បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា រូប មិនមែនជារបស់ខ្លួន ញាណ ប្រព្រឹត្តទៅថា រូប មិនមែនជារបស់ខ្លួនដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ វិញ្ញាណ មិនមែនជារបស់ខ្លួន ញាណ ប្រព្រឹត្តទៅថា វិញ្ញាណ មិនមែនជារបស់ខ្លួនដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧ ] បុគ្គល កាលនិយាយវាចាថា រូប មិនទៀង តែញាណមិនប្រព្រឹត្តទៅថា រូបមិនទៀងទេឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ វិញ្ញាណ មិនទៀង តែញាណមិនប្រព្រឹត្តទៅថា វិញ្ញាណ មិន

ទៀតទេឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា រូប មិនមែនជារបស់ខ្លួន តែញាណមិនប្រព្រឹត្តទៅថា រូប មិនមែនជារបស់ខ្លួនទេឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល កាលនិយាយវាចាថា វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ វិញ្ញាណ មិនមែនជារបស់ខ្លួន តែញាណមិនប្រព្រឹត្តទៅថា វិញ្ញាណ មិនមែនជារបស់ខ្លួនទេឬ ។ អើ ។ បុគ្គល កាលនិយាយវាចាថា នេះជាទុក្ខ តែញាណមិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨ ] បុគ្គល កាលនិយាយវាចាថា ឥទំ ទុក្ខំ ( នេះជាទុក្ខ ) ញាណប្រព្រឹត្តទៅថា ឥទំ ទុក្ខំ ( នេះជាទុក្ខ ) ដែរឬ ។ អើ ។ ញាណ ប្រព្រឹត្តទៅថា ឥ ផង ថា ទំ ផង ថា ទុ ផង ថា ខំ ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**ឥទំទុក្ខន្តិកថា ចប់**

# អដ្ឋកថា

## ឥធំទុក្ខកថា

[ ២៣ ] ឥឡូវនេះ នឹងពណ៌នាអំពីការបន្ទឹវាចាថា នេះទុក្ខដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ក្នុងខណៈនៃលោកុត្តរមគ្គកើត ព្រះយោគាវចរបន្ទឹវាចាថា នេះទុក្ខ កាលព្រះយោគាវចរនោះ ពោលវាចាថា នេះទុក្ខ យ៉ាងនេះ ញាណថា នេះទុក្ខ រមែងប្រព្រឹត្តទៅ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលរបស់បរវាទី សំដៅយកការពោលវាចាបែបនោះ និងការប្រព្រឹត្តទៅនៃញាណ ក្នុងខណៈនៃមគ្គ ។ ព្រោះបរវាទីនោះ កាន់យកជាបុថុជ្ជនប៉ុណ្ណោះ ពោលវាចា ដែលប្រកបដោយសច្ចៈដ៏សេស តែញាណបែបនោះ មិនប្រព្រឹត្តទៅដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបលោកបដិសេធក្នុងបញ្ហា មានសមុទយៈជាដើម ។

[ ២៤ ] បទថា **រូបំ អនិច្ចំ** ជាដើម សកវាទីពោលដោយអំណាចនៃការសម្តែងបរិយាយនៃទុក្ខ ។ កាលបរវាទី មិនឃើញវោហារបែបនោះ ក្នុង

លទ្ធិរបស់ខ្លួន ទើបឆ្លើយបដិសេធ ។

[ ២៨ ] បទថា **ឥ** ក្តី បទថា **ទំ** ជាដើមក្តី សកវាទីពោលហើយ ដើម្បីសម្តែងថា បើញាណក្នុងទុក្ខរបស់ព្រះយោគាវចរនោះ ប្រព្រឹត្តទៅសោត ក៏រមែងប្រព្រឹត្តទៅដោយញាណ ៤ ដោយលំដាប់ក្នុងអក្ខរៈថា **ឥ** អក្ខរៈថា **ទំ** អក្ខរៈថា **ទុ** អក្ខរៈថា **ខំ** ឬ ។ តែបរវាទី មិនប្រាថ្នាបែបនោះ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ៕៚

**អដ្ឋកថាឥទំទុក្ខន្តិកថា ចប់**

# អភិធម្មបិដក

## ឥទ្ធិពលកថា

[ ២៩ ] បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្ប ( មហាកប្ប ) ឬ ។ អើ ។ អាយុដែលសម្រេចដោយឫទ្ធិនោះ គតិដែលសម្រេចដោយឫទ្ធិនោះ ការបាននូវអត្តភាពដែលសម្រេចដោយឫទ្ធិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ បុគ្គល គប្បីស្ថិតនៅអស់កប្បជាអតីត គប្បីស្ថិតនៅអស់កប្បជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គលគប្បីស្ថិតនៅអស់ ២ កប្ប គប្បីស្ថិតនៅអស់ ៣ កប្ប គប្បីស្ថិតនៅអស់ ៤ កប្បដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ បុគ្គល កាលបើជីវិតមាននៅ គប្បីស្ថិតនៅអស់ជីវិតដ៏សេសសល់ កាលបើជីវិតមិនមានទេ គប្បីស្ថិតនៅអស់ជីវិតដ៏សេសសល់ ។ បុគ្គល កាលបើជីវិតមាន គប្បីស្ថិតនៅអស់ជីវិតដ៏សេសសល់ ។ ប្រសិនបើ បុគ្គល កាលបើជីវិតមាន គប្បីស្ថិតនៅអស់ជីវិតដ៏សេសសល់ ។ ប្រសិនបើ បុគ្គល កាលបើជីវិតមាននៅ គប្បីស្ថិតនៅអស់ជីវិតដ៏សេសសល់ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បទេ ។បេ។ បុគ្គល កាលបើជីវិតមិនមានទេ គប្បីស្ថិតនៅអស់ជីវិតដ៏សេសសល់ ។ មានតែបុគ្គលស្លាប់ហើយ

គប្បីស្ថិតនៅ បុគ្គល មានមរណកាលធ្វើហើយ គប្បីស្ថិតនៅដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០ ] បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បដែរឬ ។ អើ ។ ផស្សៈ កើតឡើងហើយ បុគ្គល គប្បីបានដើម្បីផ្គងឡើងដោយឫទ្ធិថា កុំរលត់ទៅវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនាកើតឡើងហើយ ។បេ។ សញ្ញាកើតឡើងហើយ ។បេ។ ចេតនាកើតឡើងហើយ ។បេ។ ចិត្តកើតឡើងហើយ សទ្ធាកើតឡើងហើយ វិរិយៈកើតឡើងហើយ សតិកើតឡើងហើយ សមាធិកើតឡើងហើយ ។បេ។ បញ្ញាកើតឡើងហើយ បុគ្គល គប្បីបានដើម្បីផ្គងឡើងដោយឫទ្ធិថា កុំរលត់ទៅវិញឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១ ] បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ រូប បុគ្គលគប្បីបានដើម្បីផ្គងឡើងដោយឫទ្ធិថា ចូរទៀងចុះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ វិញ្ញាណ បុគ្គលគប្បីបានដើម្បីផ្គងឡើងដោយឫទ្ធិថា ចូរទៀងចុះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២ ] បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បដែរឬ ។ អើ ។ ពួកសត្វ មានកិរិយាកើតជាធម្មតា បុគ្គល គប្បីបានដើម្បីផ្គងឡើងដោយឫទ្ធិថា កុំកើតឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វ មានសេចក្ដីគ្រាំគ្រាជាធម្មតាថា កុំគ្រាំគ្រាទៅឡើយ ។បេ។ ពួកសត្វ

មានសេចក្តីឈឺថ្កាត់ជាធម្មតាថា កុំឈឺថ្កាត់ឡើយ ។បេ។ ពួកសត្វ មានសេចក្តីស្លាប់ជាធម្មាតា បុគ្គល គប្បីបានដើម្បីផ្គងឡើងដោយឫទ្ធិថា កុំស្លាប់ឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣ ] បុគ្គលមិនគួរនិយាយថា បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បុគ្គលណាមួយ បានចម្រើន បានធ្វើឲ្យច្រើន បានឲ្យប្រព្រឹត្តទៅ បានធ្វើឲ្យជាទីតាំង បានផ្គងឡើង បានសន្សំ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ កាលប្រាថ្នា គប្បីស្ថិតនៅអស់ ១ កប្ប ឬអស់កប្បដ៏សេសសល់បាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បបាន ។

[ ៣៤ ] បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមានបុគ្គលនីមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬក៏បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានាដល់ធម៌ទាំង ៤ បានឡើយ ។ ធម៌ទាំង ៤ តើដូចម្តេច ។ មិនមានបុគ្គលណានីមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬក៏បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានាថា សភាវៈមានសេចក្តីគ្រាំគ្រាជាធម្មតា កុំគ្រាំគ្រាឡើយ សភាវៈមានសេចក្តីឈឺថ្កាត់ជាធម្មតា កុំឈឺថ្កាត់ឡើយ ។បេ។ សភាវៈមានសេចក្តីស្លាប់ជាធម្មតា កុំស្លាប់ឡើយ ។បេ។ កម្មដ៏លាមកទាំងឡាយឯណា ដែលបុគ្គលធ្វើហើយ

ក្នុងកាលមុន ជាកម្មប្រកបដោយសេចក្ដីសៅហ្មង អាចធ្វើឲ្យទៅកើតក្នុងភព ថ្មីទៀត មានទុក្ខជាកម្រៃ មានវិបាកជាទុក្ខ មានជាតិ ជរា និងមរណៈតទៅ មិនមានបុគ្គលណានីមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ឬក៏បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានាថា វិបាករបស់បាបកម្ម ទាំងនោះ កុំកើតបានឡើយ ម្នាលភិក្ខុទាំងឡាយ មិនមានបុគ្គលណានីមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ឬក៏បុគ្គលឯណា មួយ ក្នុងលោក ជាអ្នកធានាដល់ធម៌ទាំង ៤ នេះឡើយ ពាក្យដូច្នេះ មាន ក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលប្រកប ដោយកម្លាំងឫទ្ធិ គប្បីស្ថិតនៅអស់កប្បឡើយ ។

ឥទ្ធិពលកថា ចប់

# អដ្ឋកថា

## ឥទ្ធិពលកថា

[ ២៩ ] ឥឡូវនេះ នឹងពណ៌នាអំពីកម្លាំងនៃឫទ្ធិដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា បុគ្គលដែលប្រកបដោយកម្លាំងនៃឫទ្ធិ គប្បីតាំងនៅបានអស់កប្ប ព្រោះកាន់យកអត្ថនៃអានិសង្សរបស់ឥទ្ធិបាទភាវនា ដោយមិនពិចារណា ពាក្យសួររបស់សកវាទីថា **ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យ** សំដៅដល់ជនទាំងនោះ ។

ក្នុងបញ្ហានោះ ឈ្មោះថា កប្ប មាន ៣ យ៉ាង គឺមហាកប្ប ១ កប្បឯកទេស ១ អាយុកប្ប ១ ។ ពិតហើយ មហាកប្បប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ហៅថា **កប្ប** ដែលមកក្នុងព្រះបាលី ( អង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះ មាន ៤ ដូច្នេះ និងក្នុងព្រះបាលីថា អាយុនៃពួកព្រហ្មកាយិកទេវតា ប្រមាណ ១ កប្បនេះ លោកហៅថា កប្បឯកទេស ។ ក្នុងព្រះបាលី ( វិនយបិដក ចុល្លវគ្គ ) ថា ឆេះនៅក្នុងនរកអស់មួយកប្ប រីករាយក្នុងស្ថានសួគ៌អស់មួយកប្ប នេះលោកហៅថា អាយុកប្ប អធិប្បាយថា ការកំណត់អាយុ ការតាំងនៅនៃអាយុ ឈ្មោះថា ការកំណត់ព្រំដែននៃអាយុដោយអំណាចផលនៃកម្ម ឬដោយការរាប់ឆ្នាំ ។ ក្នុងបញ្ហាទាំងនោះ សកវាទីសួរសំដៅយកមហាកប្ប បរវាទីក៏ឆ្លើយទទួល ។ លំដាប់នោះ ទើបសកវាទី

ពោលថា **ឥទ្ធិមយិកោ សោ អាយុ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើបុគ្គលប្រកបដោយកម្លាំងនៃឫទ្ធិ តាមលទ្ធិរបស់អ្នកនោះ គប្បីរស់នៅអស់មហាកប្ប ១ ឬអស់មហាកប្បឯកទេស លើសអាយុកប្បដែលកំណត់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) យ៉ាងនេះថា មនុស្សណារស់នៅយ៉ាងយូរ មនុស្សនោះរស់នៅត្រឹម ១០០ ឆ្នាំ ឬតិចជាងក៏មាន ច្រើនជាងក៏មាន ដូច្នេះ អាយុរបស់បុគ្គលនោះ គប្បីសម្រេចដោយឫទ្ធិឬ ដូច្នេះ ។ បរវាទីឆ្លើយបដិសេធ ព្រោះព្រះមានព្រះភាគបានត្រាស់ថា ឈ្មោះថា ជីវិតិន្ទ្រិយដែលសម្រេចដោយឫទ្ធិ មិនមាន មានតែការកើតឡើងដោយកម្មប៉ុណ្ណោះ ។ មានពាក្យសួរថា ក្នុងសេចក្ដីនេះ មានអ្វីប្លែកអំពីអ្នកមានឫទ្ធិ ព្រោះបុគ្គលមិនមានឫទ្ធិ ក៏គប្បីរស់នៅអស់អាយុកប្ប មិនមែនឬ ឆ្លើយថា គប្បីជ្រាបការប្លែកគ្នាដូច្នេះថា បុគ្គលមានឫទ្ធិនោះ អាចហាមធម៌ដែលធ្វើអន្តរាយទាំងឡាយដោយកម្លាំងឫទ្ធិ ហើយអាចហាមអកាលមរណៈ គឺការស្លាប់ក្នុងកាលដែលមិនសមគួរ ក្នុងចន្លោះនៃការប្រព្រឹត្តទៅនៃជីវិត ដរាបដល់អស់អាយុ តែកម្លាំងបែបនេះ មិនមានដល់បុគ្គលដែលមិនមានឫទ្ធិ សេចក្ដីនេះ ជាការផ្សេងគ្នារបស់បុគ្គលដែលមានឫទ្ធិ និងបុគ្គលមិនមានឫទ្ធិទាំងនោះ ។

បទថា **អតីតំ អនាគតំ** សេចក្ដីថា សកវាទីចោទសួរ ព្រោះការឆ្លើយទទួលដោយមិនប្លែកគ្នារបស់បរវាទីថា គប្បីតាំងនៅអស់កប្ប ។ បទថា **ទ្វេ កប្បេ** ជាដើម សកវាទីពោលដើម្បីចោទសួរថា បើបុគ្គលមានឫទ្ធិ អាចឈានកន្លងការកំណត់ជីវិតបានសោត ក៏មិនអាចឈានកន្លងនូវការកំណត់ជីវិត

ត្រឹមតែមួយកប្បប៉ុណ្ណោះ បុគ្គលនោះ គប្បីឈានកន្លងហើយ តាំងនៅអស់កប្បមិនមែនតិចឡើយ ។

[ ៣០ ] បទថា **ឧប្បន្នោ ជសេប្បោ** ជាដើម សកវាទីពោលដើម្បីសម្តែងថា វត្ថុទាំងពួង មិនគប្បីបានដោយឫទ្ធិ សូម្បីវត្ថុដ៏ក្រៃលែងជាងឫទ្ធិនៅមាន ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាឥទ្ធិពលកថា ចប់**

# អភិធម្មបិដក

## សមាធិកថា

[ ៣៥ ] តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃចិត្ត ជាអតីត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃចិត្ត ជាអនាគត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ ក្រែងអតីតរលត់ហើយ អនាគតមិនទាន់កើតទេឬ ។ អើ ។ ប្រសិនបើ អតីតរលត់ហើយ អនាគតមិនទាន់កើតទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា តំណនៃចិត្ត ជាសមាធិទេ ។

[ ៣៦ ] សមាធិ ប្រកបដោយខណៈនៃចិត្តមួយឬ ។ អើ ។ បុគ្គល ប្រកបដោយចក្ខុវិញ្ញាណ ចូលកាន់សមាបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ប្រកបដោយសោតវិញ្ញាណ ។បេ។ ប្រកបដោយឃាន-វិញ្ញាណ ។បេ។ ប្រកបដោយជិវ្ហាវិញ្ញាណ ។បេ។ ប្រកបដោយកាយវិញ្ញាណ ។បេ។ ប្រកបដោយអកុសលចិត្ត ។បេ។ ប្រកបដោយរាគសហគតចិត្ត ។បេ។ ប្រកបដោយទោសសហគតចិត្ត ។បេ។ ប្រកបដោយមោហសហគតចិត្ត ។បេ។ ប្រកបដោយអនោត្តប្បសហគតចិត្ត ចូលកាន់សមាបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧ ] តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃអកុសលចិត្ត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តំណនៃចិត្ត ដែលប្រកប

ដោយរាគៈ ។បេ។ ប្រកបដោយទោសៈ ។បេ។ ប្រកបដោយមោហៈ ។បេ។ ប្រកបដោយអនោត្តប្បៈ ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨ ] បុគ្គល មិនគួរនិយាយថា តំណនៃចិត្ត ជាសមាធិទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអាវុសោ និគ្រន្ថទាំងឡាយ តថាគតមិនញាប់ញ័រដោយកាយ មិនពោលវាចា អាចដើម្បីនៅជាអ្នកទទួលសេចក្ដីសុខតែម្យ៉ាង អស់យប់ និងថ្ងៃទាំងឡាយ ៧ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ តំណនៃចិត្ត ជាសមាធិ ។

**សមាធិកថា ចប់**

# អដ្ឋកថា

## សមាធិកថា

[ ៣៥ ] ឥឡូវនេះ នឹងពណ៌នាអំពីសមាធិដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយសព្វត្ថិកវាទ និងនិកាយឧត្តរាបថកៈទាំងឡាយថា ចិត្តសន្តតិជាសមាធិ ព្រោះអាស្រ័យពុទ្ធវចនៈថា ព្រះតថាគត អាចដើម្បីនៅជាអ្នកទទួលសេចក្តីសុខតែម្យ៉ាង អស់យប់ និងថ្ងៃទាំងឡាយ ៧ ដូច្នេះជាដើម ដោយមិនកាន់យកថា ឯកគ្គតាចេតសិក កើតឡើងហើយក្នុងខណៈនៃចិត្តមួយ ឈ្មោះថា សមាធិ ព្រោះអត្ថថា ការតាំងចិត្តដូច្នេះ ពាក្យសួររបស់សកវាទីថា **ចិត្តសន្តតិ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គ្រានោះទើបសកវាទីពោលថា **អតីតា** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើការបន្តនៃចិត្ត ជាសមាធិសោត ឈ្មោះថា ការបន្តនៃចិត្ត ដែលជាអតីតខ្លះ ដែលជាអនាគតខ្លះមាន មិនមែនចិត្តបច្ចុប្បន្នមួយដួងប៉ុណ្ណោះ ដែលឈ្មោះថា ចិត្តសន្តតិ ចិត្តសន្តតិទាំងអស់នោះ រមែងជាសមាធិ តាមលទ្ធិរបស់អ្នកឬ បរវាទីនោះ កាលមិនប្រាថ្នាបែបនោះ ទើបឆ្លើយបដិសេធ ។

បទថា **ននុ អតីតំ និរុទ្ធំ** ជាដើម សកវាទីពោលដើម្បីសម្តែងថា ក្នុងតំណនៃចិត្ត ចិត្តដែលកើតឡើងចំពោះមុខនោះឯង ធ្វើនូវកិច្ច ចិត្តដែលជាអតីត និងអនាគត ឈ្មោះថា មិនមាន ព្រោះជាចិត្តដែលរលត់ទៅហើយ និងព្រោះជាចិត្តដែលមិនទាន់កើតឡើង ចិត្តនោះ ឈ្មោះថា ជាសមាធិបាន

ដូចម្តេច ។

[ ៣៦ ] ពាក្យសួរថា **ឯកចិត្តក្ខណិកោ** ជាពាក្យរបស់បរវាទី ។ បន្ទាប់អំពីនោះ ឯកគ្គតាណា ក្នុងលទ្ធិរបស់សកវាទី ដែលសម្បយុត្តដោយបច្ចុប្បន្នកុសលចិត្ត ដែលព្រះមានព្រះភាគត្រាស់ហៅថា សមាធិ ក្នុងបាលីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចម្រើនសមាធិ ដូច្នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី សំដៅយកឯកគ្គតានោះ ។ បទថា **ចក្ខុ-វិញ្ញាណសមង្គី** ជាដើម បរវាទីពោលដោយលេសន័យ ព្រោះកាន់យកត្រឹមតែពាក្យថា ប្រព្រឹត្តទៅក្នុងខណៈនៃចិត្តមួយដួង ។ ដោយហេតុនោះឯង ទើបសកវាទីឆ្លើយបដិសេធ ។

[ ៣៨ ] ព្រះសូត្រថា **ឆន្ទុ វត្តំ ភគវតា** នេះ រមែងសម្រេចនូវភាពដែលសមាធិចិត្តប្រព្រឹត្តទៅ ដោយអំណាចមុន និងក្រោយ ជាសភាវៈមិនលាយឡំគ្នា តែមិនសម្រេចភាពជាសមាធិដោយការបន្ត ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនសម្រេចប្រយោជន៍ ដូច្នេះ ៕

## អដ្ឋកថាសមាធិកថា ចប់

# អភិធម្មបិដក

## ធម្មដ្ឋិតតាកថា

[ ៣៩ ] ធម្មដ្ឋិតតា ( ការតាំងនៅនៃធម៌ គឺបដិច្ចសមុប្បាទ ) សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈមិនមាន អនុបាទាបរិនិព្វានមិនមានដល់ធម្មដ្ឋិតតានោះៗ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០ ] ការតាំងនៅនៃរូប សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈមិនមាន អនុបាទាបរិនិព្វាន មិនមានដល់ការតាំងនៅនៃរូបនោះៗ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការតាំងនៅនៃវេទនា ។បេ។ ការតាំងនៅនៃសញ្ញា ។បេ។ ការតាំងនៅនៃសង្ខារ ។បេ។ ការតាំងនៅនៃវិញ្ញាណ សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈមិនមាន អនុបាទាបរិនិព្វាន មិនមានដល់ការតាំងនៅនៃវិញ្ញាណនោះៗ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ធម្មដ្ឋិតតាកថា ចប់

# អដ្ឋកថា

## ធម្មដ្ឋិតតាកថា

[ ៣៩ ] ឥឡូវនេះ នឹងពណ៌នាអំពីការតាំងនៅនៃធម៌ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ឈ្មោះថា ការតាំងនៅនៃធម៌ ពោល គឺបដិច្ចសមុប្បាទ ១ មាន ធម៌នោះ ជារបស់សម្រេចហើយ ដូច្នេះ ព្រោះអាស្រ័យបាលីថា ធាតុនោះ តាំងនៅហើយនោះឯង ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីនោះថា **តាយ ឋិតតា** ដើម្បីចោទសួរបរវាទីនោះថា បើឈ្មោះថា ការតាំងនៅនៃធម៌ដទៃ ដែលសម្រេចហើយដល់ធម៌ទាំងឡាយមានអវិជ្ជាជាដើម ដែលសម្រេចហើយមានសោត ការតាំងនៅដទៃ ដែលសម្រេចហើយ ព្រោះការតាំងនៅនៃធម៌នោះ តាមលទ្ធិរបស់អ្នក មានឬ ដូច្នេះ បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានលទ្ធិយ៉ាងនោះ ។

[ ៤០ ] បរវាទីត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល សំដៅយកភាពជាអនន្តរប្បច្ច័យ និងភាពជាអញ្ញមញ្ញប្បច្ច័យ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចខ្ញុំពោលហើយ ខាងដើមនោះឯង ៕

**អដ្ឋកថាធម្មដ្ឋិតតាកថា ចប់**

# អភិធម្មបិដក

## អនិច្ចតាកថា

[ ៤១ ] សេចក្ដីមិនទៀង សម្រេចហើយឬ ។ អើ ។ សេចក្ដីមិនទៀង នៃសេចក្ដីមិនទៀងនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្ដីមិនទៀង នៃសេចក្ដីមិនទៀងនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈមិនមាន អនុបាទាបរិនិព្វាន មិនមានដល់សេចក្ដីមិនទៀងនោះៗ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២ ] ជរា សម្រេចហើយឬ ។ អើ ។ ជរា នៃជរានោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា នៃជរានោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈមិនមាន អនុបាទាបរិនិព្វាន មិនមានដល់ជរានោះៗ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣ ] មរណៈ សម្រេចហើយឬ ។ អើ ។ មរណៈ នៃមរណៈនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មរណៈ នៃមរណៈនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈមិនមាន អនុបាទាបរិនិព្វាន មិនមានដល់មរណៈនោះៗ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤ ] រូប សម្រេចហើយ ចុះសេចក្ដីមិនទៀងនៃរូប មានដែរឬ ។ អើ ។ សេចក្ដីមិនទៀង សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃសេចក្ដីមិន

ទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប សម្រេចហើយ ចុះជរានៃរូប មានដែរឬ ។ អើ ។ ជរា សម្រេចហើយ ចុះជរា នៃជរា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្តីអន្តរធាននៃរូប មានដែរឬ ។ អើ ។ មរណៈ សម្រេចហើយ ចុះការបែកធ្លាយ និងការអន្តរធាននៃមរណៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ ពួកសង្ខារ ។បេ។ វិញ្ញាណ សម្រេចហើយ ចុះសេចក្តីមិនទៀងនៃវិញ្ញាណ មានដែរឬ ។ អើ ។ សេចក្តីមិនទៀង សម្រេចហើយ ចុះសេចក្តីមិនទៀង នៃសេចក្តីមិនទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណ សម្រេចហើយ ចុះជរានៃវិញ្ញាណ មានដែរឬ ។ អើ ។ ជរា សម្រេចហើយ ចុះជរា នៃជរា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្តីអន្តរធាននៃវិញ្ញាណ មានដែរឬ ។ អើ ។ មរណៈ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្តីអន្តរធាននៃមរណៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អនិច្ចតាកថា ចប់

ឯកាទសមវគ្គ ចប់

## ឧទ្ទាននៃឯការទសមវគ្គនោះ គឺ

អនុស័យជាអព្យាក្រឹតជាអហេតុកៈ ប្រាសចាកចិត្ត ១ កាលបើសេចក្ដីមិនដឹងប្រាសចេញហើយ បុគ្គលមានញាណ ១ ញាណប្រាសចាកចិត្ត ១ ញាណប្រព្រឹត្តទៅក្នុងសព្វណា ១ បុគ្គលប្រកបដោយកម្លាំងនៃឫទ្ធិ គប្បីស្ថិតនៅអស់កប្ប ១ តំណនៃចិត្តជាសមាធិ ១ ធម្មដ្ឋិតតា ១ និងអនិច្ចតា ១ ។

# អដ្ឋកថា

## អនិច្ចតាកថា

[ ៤១ ] ឥឡូវនេះ នឹងពណ៌នាអំពីការមិនទៀងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា សូម្បីការមិនទៀងនៃរូបជាដើម ដែលមិនទៀង ជាការៈសម្រេចហើយ ដូចរូបជាដើម ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គ្រានោះ ទើបសកវាទីពោលថា **តាយ អនិច្ចតាយ** ដើម្បីចោទសួរបរវាទីនោះថា បើការមិនទៀងជារបស់សម្រេចហើយ ដូចរូបជាដើម តាមលទ្ធិរបស់អ្នកមានសោត ការមិនទៀង ដែលសម្រេចហើយដទៃ ក៏គប្បីមានដល់ការមិនទៀងនោះ ដូច្នេះ ។ បរវាទីនោះ បដិសេធហើយ ដោយការមិនមានការមិនទៀង ២ យ៉ាងរួមគ្នា តែឆ្លើយទទួលទៀត ព្រោះការមិនទៀងនោះ រមែងមិនជាការទៀង ហេតុដែលអន្តរធានទៅជាមួយការមិនទៀងនោះឯង ។ លំដាប់នោះ សកវាទីមិនឲ្យឱកាស ដែលមានលេសន័យដល់បរវាទីនោះ ទើបលើកឡើងនូវទោស គឺការមិនចូលទៅកាត់វដ្តៈ ដោយអំណាចនៃធម៌បន្តៗ គ្នាទៅថា ការមិនទៀងដែលបន្តអំពីការមិនទៀងនោះ នៃការមិនទៀងទី ២ ដែលបរវាទីនោះទទួលហើយ ទើបពោលពាក្យថា **តាយ តាយេវ** ជាដើម ។

[ ៤២ ] បទថា **ជរា បរិនិប្ផន្នា** ជាដើម សកវាទីពោលដោយអំណាចនៃការប្រកបរឿយៗ នូវការបែកភាពមិនទៀង ព្រោះឈ្មោះថា ការ

មិនទៀងដទៃចាកជរា និងមរណៈនៃធម៌ដែលកើតឡើងហើយ មិនមាន ។ ក្នុងបញ្ហានោះ បណ្ឌិតគប្បីជ្រាបពាក្យឆ្លើយទទួល និងពាក្យបដិសេធរបស់បរវាទី ដោយន័យដែលពោលហើយពីមុននោះឯង ។

[ ៤៤ ] បទថា **រូបំ បរិនិប្ផន្នំ** ជាដើម សកវាទីពោលដើម្បីប្រៀបធៀបជាមួយធម៌ទាំងឡាយ ដែលមានការមិនទៀងនោះ ។ ក្នុងសេចក្តីនោះ បរវាទីកាលសម្គាល់ថា ការមិនទៀង ជរា និងមរណៈ មានដល់ធម៌ទាំងឡាយ មានរូបជាដើម ដែលសម្រេចហើយ មាន យ៉ាងណា ការមិនទៀងជាដើមនោះ មិនមានដល់ធម៌ទាំងឡាយ មានការមិនទៀងជាដើម ដែលសម្រេចហើយ ក៏យ៉ាងនោះ ទើបឆ្លើយបដិសេធដោយចំណែកមួយប៉ុណ្ណោះដូច្នេះ ។ល។

**អដ្ឋកថាអនិច្ចតាកថា ចប់**

**វគ្គទី ១១ ចប់**

# អភិធម្មបិដក

## សំវរកម្មន្តិកថា

[ ៤៥ ] ការសង្រួម ជាកម្មឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសង្រួមសោតិន្ទ្រិយ ។បេ។ ការសង្រួមឃានិន្ទ្រិយ ។បេ។ ការសង្រួមជិវ្ហិន្ទ្រិយ ។បេ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អើ ។ ការសង្រួមសោតិន្ទ្រិយ ។បេ។ ការសង្រួមឃានិន្ទ្រិយ ។បេ។ ការសង្រួមជិវ្ហិន្ទ្រិយ ជាជិវ្ហាកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការសង្រួមសោតិន្ទ្រិយ ។បេ។ ការសង្រួមឃានិន្ទ្រិយ ។បេ។ ការសង្រួមជិវ្ហិន្ទ្រិយ ។បេ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦ ] ការមិនសង្រួម ជាកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការមិនសង្រួមសោតិន្ទ្រិយ ។បេ។ ការមិនសង្រួមឃានិន្ទ្រិយ ។បេ។ ការមិនសង្រួម

ជិវ្ហិន្ទ្រិយ ។បេ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អើ ។ ការមិនសង្រួមសោតិន្ទ្រិយ ។បេ។ ការមិនសង្រួមឃានិន្ទ្រិយ ។បេ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ជាជិវ្ហាកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការមិនសង្រួមសោតិន្ទ្រិយ ។បេ។ ការមិនសង្រួមឃានិន្ទ្រិយ ។បេ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ។បេ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៧ ] បុគ្គល មិនគួរនិយាយថា ការសង្រួមក្តី ការមិនសង្រួមក្តី ជាកម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញនូវរូបដោយចក្ខុហើយ កាន់យកនូវនិមិត្ត ។បេ។ មិនកាន់យកនូវនិមិត្ត ឮនូវសំឡេងដោយត្រចៀក ។បេ។ ដឹងច្បាស់នូវធម៌ដោយចិត្ត កាន់យកនូវនិមិត្ត ។បេ។ មិនកាន់យកនូវនិមិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការសង្រួមក្តី ការមិនសង្រួមក្តី ក៏ជាកម្មដែរ ។

# អដ្ឋកថា

## សំវរកម្មន្តិកថា

[ ៤៥ ] ឥឡូវនេះ នឹងពោលអំពីការសង្រួមជាកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ការសង្រួមក្តី ការមិនសង្រួមក្តី ជាកម្ម ព្រោះអាស្រ័យព្រះសូត្រថា ឃើញនូវរូបដោយចក្ខុហើយ កាន់យកនូវនិមិត្ត ។បេ។ មិនកាន់យកនូវនិមិត្ត ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ពោលថា **ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មំ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា ចេតនាឯណា ដែលសកវាទីពោលក្នុងលទ្ធិរបស់ខ្លួនថា ចេតនាកម្ម ចេតនានោះ ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ វចីទ្វារ និងមនោទ្វារ បានឈ្មោះថាជាកាយកម្មជាដើម យ៉ាងណា បើការសង្រួមតាមលទ្ធិរបស់អ្នកជាកម្មសោត ការសង្រួមនោះ កាលប្រព្រឹត្តទៅក្នុងចក្ខុន្ទ្រិយជាដើម ក៏គប្បីបានឈ្មោះថាចក្ខុកម្មជាដើម យ៉ាងនោះ ។ ចំណែកបរវាទី កាលមិនឃើញបទព្រះសូត្រ បែបនោះ ក៏ឆ្លើយបដិសេធក្នុងទ្វារទាំង ៤ និងបដិសេធ ដោយសំដៅយក

បសាទកាយ ក្នុងកាយទ្វារទី ៥ តែឆ្លើយទទួល សំដៅយកវិញ្ញត្តិកាយ ។ ពិតហើយ បរវាទីនោះ រមែងកាន់យកបសាទកាយខ្លះ វិញ្ញត្តិកាយខ្លះ ថាជាកាយិន្ទ្រិយនោះឯង ។ ក្នុងមនោទ្វារ សំដៅយកវិបាកទ្វារ រមែងឆ្លើយបដិសេធ ។ សំដៅយកកម្មទ្វារ រមែងឆ្លើយទទួល ។ ក្នុងការមិនសង្រួមក៏ន័យនេះ ។ ព្រះសូត្រថា ភិក្ខុឃើញរូបដោយចក្ខុជាដើម សម្តែងចំពោះនូវការសង្រួម និងការមិនសង្រួមក្នុងទ្វារទាំងឡាយប៉ុណ្ណោះ មិនមែនសម្តែងភាពដែលការសង្រួម និងការមិនសង្រួមជាកម្ម ព្រោះហេតុនោះ ព្រះសូត្រដែលលើកមកនោះ ទើបមិនមែនជាគោលអាងក្នុងទីនេះ ដូច្នេះ ។ល។

## អដ្ឋកថាសំវរកម្មន្តិកថា ចប់

# អភិធម្មបិដក

## កម្មកថា

[ ៤៨ ] កម្មទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ប្រកបដោយវិបាក និងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនាជាកិរិយា និងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនាជាកាមាវចរ ជាវិបាក និងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ជារូបាវចរ អរូបាវចរ អបរិយាបន្ន ជាវិបាក និងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកឬ ។ អើ ។ ចេតនា ជាកាមាវចរ ជាកិរិយា និងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ជារូបាវចរ អរូបាវចរ ជាកិរិយា និងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩ ] ចេតនា ជាវិបាក និងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាវិបាក និងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

[ ៥០ ] ចេតនា ជាកិរិយា និងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាកិរិយា និងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

[ ៥១ ] ចេតនា ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន ជាវិបាក និងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាអបរិយាបន្ន ជាវិបាក និងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

[ ៥២ ] ចេតនា ជាកាមាវចរ រូបាវចរ អរូបាវចរ ជាកិរិយា និងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនាជាអរូបាវចរ ជាកិរិយា និងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

[ ៥៣ ] បុគ្គល មិនគួរនិយាយថា កម្មទាំងអស់ ប្រកបដោយវិបាកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថា កម្មទាំងឡាយ ដែលប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ អស់ទៅ ព្រោះមិនបានទទួលឡើយ កម្មនោះឯង គប្បីកើតឡើងក្នុងបច្ចុប្បន្ន ឬក្នុងបរិយាយដទៃ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ កម្មទាំងអស់ ប្រកបដោយវិបាក ។

កម្មកថា ចប់

# អដ្ឋកថា

## កម្មកថា

[ ៤៨ ] ឥឡូវនេះ នឹងពោលអំពីកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា កម្មទាំងពួង មានវិបាក ព្រោះអាស្រ័យបទព្រះសូត្រ ( ក្នុងអង្គុត្តរនិកាយ ឆក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនា ថាជាកម្ម ដូច្នេះជាដើម ពាក្យសួររបស់សកវាទីថា **សព្វំ កម្មំ** ជាដើម ដើម្បីសម្ដែងការបែកនេះដល់ជនទាំងនោះថា ចេតនាដែលព្រះសាស្ដាទ្រង់ត្រាស់ហៅថា កម្មដោយមិនប្លែកគ្នា ក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយតថាគត ហៅចេតនា ថាជាកម្ម ដូច្នេះ ចេតនានោះ ជាកុសលក្ដី ជាអកុសលក្ដី មានវិបាក ចំណែកចេតនាដែលជាអព្យាកត មិនមានវិបាកឡើយ ដូច្នេះពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាទាំងឡាយទៀតថា **សព្វា ចេតនា** គប្បីជ្រាបថា បរវាទីឆ្លើយបដិសេធ សំដៅយកចេតនាដែលជាអព្យាកត និងឆ្លើយទទួល សំដៅយកចេតនា ដែលជាកុសល និងជាអកុសល ។ បទថា **វិបាកាព្យាកតា** ជាដើម សកវាទីពោល ដើម្បីសម្ដែង

ចេតនា ដែលមានវិបាក និងមិនមានវិបាក ដោយសង្ខេប ។ ពាក្យដ៏សេស ក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ៥៣ ] ព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថា ជាដើម ព្រះមានព្រះភាគ ត្រាស់សំដៅដល់ការសោយវិបាកក្នុងភពទាំងឡាយ មានភពបច្ចុប្បន្នជាដើម ក្នុងកាលបច្ច័យនៅមាន ព្រោះហេតុនោះ ទើប ព្រះសូត្រនោះ មិនមែនជាគោលអាងក្នុងរឿងនេះ ៕

**អដ្ឋកថាកម្មកថា ចប់**

# អភិធម្មបិដក

## សទ្ធាវិចារកោតិកថា

[ ៥៤ ] សំឡេង ជាវិបាកឬ ។ អើ ។ សំឡេងគួរដល់ការទទួលសុខ គួរដល់ការទទួលទុក្ខ គួរដល់ការទទួលអទុក្ខមសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ប្រកបដោយអារម្មណ៍ ការរំពឹង ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងចិត្តទុក មានដល់សំឡេងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសំឡេង មិនគួរដល់ការទទួលសុខ មិនគួរដល់ការទទួលទុក្ខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់សំឡេងនោះទេឬ ។ អើ ។ ប្រសិនបើ សំឡេងមិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ទេ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់សំឡេងនោះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សំឡេង ជាវិបាកទេ ។

[ ៥៥ ] ផស្សៈ ជាវិបាក ចុះផស្សៈ គួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់ផស្សៈនោះដែរឬ ។ អើ ។ សំឡេង ជាវិបាក ចុះសំឡេងគួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់សំឡេងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៦ ] សំឡេង ជាវិបាក ចុះសំឡេងមិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់សំឡេងនោះទេឬ ។ អើ ។ ផស្សៈ ជាវិបាក ចុះផស្សៈមិនគួរដល់ការទទួលសុខ មិនគួរដល់ការទទួលទុក្ខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់ផស្សៈនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧ ] បុគ្គល មិនគួរនិយាយថា សំឡេង ជាវិបាកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា សំឡេងនោះ ជាសំឡេងដ៏ប្រសើរ ដូចជាសំឡេងនៃសត្វករវិក ព្រោះភាវៈនៃកម្មនោះ ជាអំពើដែលបុគ្គលធ្វើហើយ សន្សំហើយ ឲ្យដុះដាលឡើងហើយ ឲ្យបរិបូណ៌ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សំឡេង ជាវិបាក ។

## សទ្ទវិបាកោតិកថា ចប់

# អដ្ឋកថា

## សទ្ទវិបាកោតិកថា

[ ៥៤ ] ឥឡូវនេះ នឹងពណ៌នាអំពីសំឡេងជាវិបាកដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា សំឡេងជាវិបាក ព្រោះមិនពិចារណាអត្ថ ហើយកាន់យកពាក្យដែលព្រះមានព្រះភាគត្រាស់ថា តថាគតនោះ ជាបុគ្គលមានសំឡេង ដូចសំឡេងព្រហ្ម ... ព្រោះធ្វើកម្មនោះ ដែលបានធ្វើហើយ បានសន្សំហើយ បានចម្រើនហើយ ជាកម្មបរិបូណ៌ ដូច្នេះ ។ ពាក្យសួររបស់សកវាទី ពោលដើម្បីសម្ដែងដល់ជនទាំងនោះថា អរូបធម៌ទាំងឡាយ គឺនាមក្ខន្ធ ៤ មានកម្មជាសមុដ្ឋាន រមែងបានឈ្មោះថា វិបាក តែវោហារនេះមិនមានក្នុងរូបធម៌ទាំងឡាយ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **សុខវេទនីយោ** ជាដើម សកវាទីពោលដើម្បីសម្ដែងថា ឈ្មោះថា វិបាកហើយ រមែងយ៉ាងនេះ ។

[ ៥៧ ] ព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ថា តថាគតនោះ ជាបុគ្គលមានសំឡេងដូចសំឡេងនៃព្រហ្ម ព្រោះកម្មនោះ បានធ្វើហើយជាដើម ដែលបរវាទីនាំមកពោលនោះ ក៏ដើម្បីសម្ដែងឲ្យជ្រាបដល់ការបាន ( មហា-បុរិស ) លក្ខណៈ ។ ពិតហើយ ព្រះមហាបុរសជាអ្នកមានបរិវារដែលល្អក៏ព្រោះធ្វើកម្មក្នុងកាលមុន តែបរិវារនោះ ក៏មិនមែនវិបាក ព្រោះហេតុនោះទើបព្រះសូត្រនេះ មិនមែនជាគោលអាងថា សំឡេង ជាវិបាក ដូច្នេះ ។៚

# អភិធម្មបិដក

## សឡាយតនកថា

[ ៥៨ ] ចក្ខាយតនៈ ជាវិបាកដែរឬ ។ អើ ។ ចក្ខាយតនៈ គួរដល់ការទទួលសុខ គួរដល់ការទទួលទុក្ខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់ចក្ខាយតនៈនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងចក្ខាយតនៈមិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់ចក្ខាយតនៈនោះទេឬ ។ អើ ។ ប្រសិនបើ ចក្ខាយតនៈ មិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់ចក្ខាយតនៈនោះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខាយតនៈជាវិបាកទេ ។បេ។ ផស្សៈជាវិបាក ចុះផស្សៈគួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់ផស្សៈនោះដែរឬ ។ អើ ។ ចក្ខាយតនៈជាវិបាក ចុះចក្ខាយតនៈ គួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់ចក្ខាយតនៈនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខាយតនៈជាវិបាក ចុះចក្ខាយតនៈ មិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់ចក្ខាយតនៈនោះទេឬ ។ អើ ។ ផស្សៈជាវិបាក ចុះផស្សៈមិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់ផស្សៈនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

សោតាយតនៈ ។បេ។ ឃានាយតនៈ ។បេ។ ជិវ្ហាយតនៈ ។បេ។

[ ៥៩ ] កាយាយតនៈ ជាវិបាកឬ ។ អើ ។ កាយាយតនៈគួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកមានដល់កាយាយតនៈនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងកាយាយតនៈ មិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់កាយាយតនៈនោះទេឬ ។ អើ ។ ប្រសិនបើកាយាយតនៈមិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់កាយាយតនៈនោះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយាយតនៈ ជាវិបាកទេ ។បេ។ ផស្សៈ ជាវិបាក ចុះផស្សៈគួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់ផស្សៈនោះដែរឬ ។ អើ ។ កាយាយតនៈ ជាវិបាក ចុះកាយាយតនៈ គួរដល់ការទទួលសុខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មានដល់កាយាយតនៈនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយាយតនៈ ជាវិបាក ចុះកាយាយតនៈ មិនគួរដល់ការ

ទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់កាយាយតនៈនោះទេឬ ។ អើ ។ ផស្សៈ ជាវិបាក ចុះផស្សៈមិនគួរដល់ការទទួលសុខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក មិនមានដល់ផស្សៈនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០ ] បុគ្គល មិនគួរពោលថា សឡាយតនៈ ជាវិបាកទេឬ ។ អើ ។ ក្រែងសឡាយតនៈ កើតឡើង ព្រោះកម្មដែលបុគ្គលធ្វើហើយឬ ។ អើ ។ ប្រសិនបើ សឡាយតនៈ កើតឡើង ព្រោះកម្មដែលបុគ្គលធ្វើហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សឡាយតនៈ ជាវិបាក ។

សឡាយតនកថា ចប់

# អដ្ឋកថា

## សឡាយតនកថា

[ ៥៨ ] ឥឡូវនេះ នឹងពណ៌នាអំពីសឡាយតនៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ព្រោះសឡាយតនៈកើតឡើង ព្រោះបុគ្គលធ្វើកម្ម ព្រោះហេតុនោះ ទើបសឡាយតនៈជាវិបាក ដូច្នេះ ពាក្យសួររបស់សកវាទីថា **ចក្ខាយតនំ វិបាកោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។

[ ៦០ ] មនាយតនៈ គប្បីជាវិបាកបានក្នុងបទនេះថា **សឡាយតនំ វិបាកោ** ចំណែកអាយតនៈដែលសល់ក្រៅអំពីនោះ មានកម្មជាសមុដ្ឋានតែម្យ៉ាង ទើបមិនជាវិបាក ព្រោះហេតុនោះ ទើបសេចក្តីនេះ មិនមែនជាគោលអះអាងថា សឡាយតនៈ ជាវិបាកទាំងអស់នោះទេ ដូច្នេះ ។

**អដ្ឋកថាសឡាយតនកថា ចប់**

# អភិធម្មបិដក

## សត្តក្ខត្តុំបរមកថា

[ ៦១ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនឬ ។ អើ ។ សត្តក្ខត្តុំបរមបុគ្គល បានផ្តាច់បង់ចាកជីវិតមាតា ផ្តាច់បង់ចាកជីវិតបិតា ផ្តាច់បង់ចាកជីវិតព្រះអរហន្ត មានចិត្តប្រទូស្ត ញុំាងព្រះលោហិតរបស់ព្រះតថាគតឲ្យពុរពោរឡើង និងបំបែកសង្ឃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនឬ ។ អើ ។ សត្តក្ខត្តុំបរមបុគ្គល មិនគួរដើម្បីរម្ងាប់នូវធម៌ ( គឺអនន្តរិយកម្ម ) ជាចន្លោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្តក្ខត្តុំបរមបុគ្គល មិនគួរដើម្បីរម្ងាប់នូវធម៌ ( គឺអនន្តរិយកម្ម ) ជាចន្លោះទេឬ ។ អើ ។ សត្តក្ខត្តុំបរមបុគ្គល ផ្តាច់បង់ចាកជីវិតមាតា ផ្តាច់បង់ចាកជីវិតបិតា ផ្តាច់បង់ចាកជីវិតព្រះអរហន្ត មានចិត្តប្រទូស្ត ញុំាងព្រះលោហិតរបស់ព្រះតថាគតឲ្យពុរពោរឡើង និងបំបែកសង្ឃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនឬ ។ អើ ។ សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើន ដោយនិយមៈ ( ការកំណត់ ) ណា និយមៈនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត

៧ ជងទៀតយ៉ាងច្រើន ដោយពោជ្ឈង្គទាំងឡាយណា សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល និងពោជ្ឈង្គទាំងនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើន ដោយនិយមៈណា និយមៈនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើនដោយនិយមៈណា និយមៈនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើនទេ ។

[ ៦៥ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើន ដោយពោជ្ឈង្គទាំងឡាយណា សតិប្បដ្ឋាន ។បេ។ និងពោជ្ឈង្គទាំងនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើន ដោយពោជ្ឈង្គទាំងឡាយណា ពោជ្ឈង្គទាំងនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សត្តក្ខត្តុំបរម-បុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើនទេ ។

[ ៦៦ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើនឬ ។ អើ ។ ( សត្តក្ខត្តុំបរមបុគ្គលទៀង ) ដោយសកទាគាមិនិយមៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយអនាគាមិនិយមៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយអរហត្តនិយមៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះដោយនិយមៈដូចម្តេច ។ ដោយសោតាបត្តិនិយមៈ ។

[ ៦៧ ] សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនឬ ។ អើ ។ បុគ្គលណាមួយ ឈានចុះកាន់សោតាបត្តិនិយាមៈ បុគ្គលទាំងអស់នោះ ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៨ ] បុគ្គល មិនគួរនិយាយថា សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនទេឬ ។ អើ ។ ក្រែងបុគ្គលនោះ ជាសត្តក្ខត្តុំបរមៈ ( កើត ៧ ដងទៀតយ៉ាងច្រើន ) ឬ ។ អើ ។ ប្រសិនបើបុគ្គលនោះ ជាសត្តក្ខត្តុំបរមៈមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សត្តក្ខត្តុំបរមបុគ្គល ទៀងដោយការកើត ៧ ដងទៀតយ៉ាងច្រើនមែន ។

សត្តក្ខត្តុំបរមកថា ចប់

# អភិធម្មបិដក

## កោលំកោលឯកពីជិកថា

[ ៦៩ ] បុគ្គល មិនគួរនិយាយថា កោលំកោលបុគ្គល ទៀនដោយការកើត ៦ ជាតិទៀតឬ ។ អើ ។ ក្រែងបុគ្គលនោះ ជាកោលំកោលៈ ( កើត ៦ ជាតិទៀត ) ឬ ។ អើ ។ ប្រសិនបើ បុគ្គលនោះ ជាកោលំកោលៈមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កោលំកោលបុគ្គល ទៀនដោយការកើត ៦ ជាតិទៀតពិត ។

[ ៧០ ] បុគ្គល មិនគួរនិយាយថា ឯកវីជិបុគ្គល ទៀនដោយពូជ ( បដិសន្ធិ ) ១ ទេឬ ។ អើ ។ ក្រែងបុគ្គលនោះជាឯកវីជី ( មានពូជតែ ១ ) ឬ ។ អើ ។ ប្រសិនបើ បុគ្គលនោះ ជាឯកវីជីមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ឯកវីជិបុគ្គលទៀនដោយពូជ ១ ទៀតពិត ។

កោលំកោលឯកពីជិកថា ចប់

# អដ្ឋកថា

## សត្តក្ខត្តុំបរមកថា

[ ៦១ ] ឥឡូវនេះ នឹងពណ៌នាអំពីសត្តក្ខត្តុំបរមបុគ្គលដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា ព្រោះព្រះមានព្រះភាគត្រាស់ថា សត្តក្ខត្តុបរមបុគ្គលមាន ព្រោះហេតុនោះ ទើបសត្តក្ខត្តុបរមបុគ្គល ឈ្មោះថា ជាបុគ្គលទៀងដោយភាពជាអ្នកមានការកើត ៧ ដងទៀតយ៉ាងច្រើន ដូច្នេះ ពាក្យសួររបស់សកវាទី ដើម្បីសម្ដែងការបែកនេះដល់ជនទាំងនោះថា បុគ្គលនោះ គប្បីជាអ្នកមានការកំណត់ពិតប្រាកដ ដោយភាពជាអ្នកមានការកើត ៧ ជាតិទៀតយ៉ាងក្រៃលែង ដោយហេតុណា វៀរអរិយមគ្គហើយ ការកំណត់ពិតប្រាកដនៃហេតុដទៃមាន ដូច្នេះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

ក្នុងបទទាំងឡាយ បទថា **មាតា ជីវិតា** ជាដើម គប្បីជ្រាបពាក្យអធិប្បាយយ៉ាងនេះថា និយាម មាន ២ យ៉ាង គឺ **សម្មត្តនិយាម ១ មិច្ឆត្តនិយាម ១** ។ អរិយមគ្គ ឈ្មោះថា **សម្មត្តនិយាម** អរិយមគ្គនោះកំណត់នូវភាពជាវិបាកធម៌ និងការកើតឡើងនៃអរិយផល ។ ចំណែកមិច្ឆត្តនិយាម កំណត់នូវអនន្តរិយកម្ម អនន្តរិយកម្មនោះ កំណត់ការកើតឡើងក្នុងនរក ដែលមិនមានកពដទៃខណ្ឌក្នុងចន្លោះ ។ ក្នុងបញ្ហានោះ សត្តក្ខត្តុបរមបុគ្គល ជាបុគ្គលដែលសោតាបត្តិមគ្គកំណត់ហើយ ដោយភាពជាសភាវធម៌ដែលមិនធ្លាក់ទៅកាន់អបាយ និងដោយការកើតឡើងនៃអរិយផល ចំណែក

និយាមនៃមគ្គដ៏សេស មិនមានដល់សត្តក្ខត្តុបរមបុគ្គលនោះ ព្រោះមិនមែនជាធម៌ដែលលោកសម្រេចហើយ សូម្បីសត្តក្ខត្តុបរមបុគ្គលនោះ ក៏មិនអាចធ្វើអនន្តរិយកម្មបាន តែបើអ្នក ( បរវាទី ) គាប់ចិត្ត និយាមនៃសត្តក្ខត្តុបរម-បុគ្គលនោះ ព្រោះហេតុនោះ ទើបខ្ញុំសួរអ្នកថា សត្តក្ខត្តុបរមបុគ្គលនោះ ជាបុគ្គលដែលមិច្ឆត្តនិយាមនេះ កំណត់ហើយ តាមលទ្ធិរបស់អ្នកឬ ។

[ ៦២ ] ក្នុងបញ្ហាទាំងឡាយថា **អភព្វោ អន្តរា** បរវាទីឆ្លើយបដិសេធសំដៅយកការមិនមានធម៌ដទៃ ខណ្ឌក្នុងរវាងចន្លោះ ។ ពាក្យឆ្លើយទទួលសំដៅយកការកើត ៧ ជាតិទៀត ជាយ៉ាងក្រៃលែង ។

[ ៦៣ ] ក្នុងបញ្ហាទាំងឡាយថា **អត្ថិ សោ និយាមោ** បរវាទី កាលមិនឃើញនិយាមរបស់សត្តក្ខត្តុបរមបុគ្គល ទើបឆ្លើយបដិសេធ ។ បទថា **អត្ថិ តេ សតិប្បដ្ឋានា** ជាដើម សកវាទីពោលដើម្បីសម្តែងនូវមគ្គធម៌ទាំងឡាយ ដែលលោកហៅថា និយាម ។ ម្យ៉ាងទៀត ធម៌ មានសតិប្បដ្ឋានជាដើមនោះ មិនមាន ព្រោះការមិនកើតឡើងនៃបឋមមគ្គទៀតដល់សត្តក្ខត្តុ-បរមបុគ្គលនោះ ព្រោះហេតុនោះ ទើបបរវាទីឆ្លើយបដិសេធ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ៦៨ ] ក្នុងពាក្យដែលបរវាទីនាំមកនេះថា **ឆន្ទុ សោ សត្តក្ខត្តុបរមោ** អធិប្បាយថា ព្រះមានព្រះភាគទ្រង់ព្យាករដោយកម្លាំងនៃញាណរបស់ទ្រង់ថា បុគ្គលនេះ ត្រាច់ទៅអស់កពមានប្រមាណប៉ុណ្ណេះហើយ នឹងបរិនិព្វាន បុគ្គលនេះប៉ុណ្ណេះ ដូច្នេះ ពាក្យណាមួយ ដែលទ្រង់ត្រាស់ថា សត្តក្ខត្តុបរមបុគ្គល កោលំកោលបុគ្គល និងឯកពីជិបុគ្គល ដូច្នេះ ឈ្មោះថា ជានិយាមនៃកព មិនមានឡើយ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអះអាង ដូច្នេះ ។ល។

**អដ្ឋកថាសត្តក្ខត្តុំបរមកថា ចប់**

# កោលំកោលឯកពីជី

កិច្ចពណ៌នាពោលអំពីកោលំកោលបុគ្គល និងបុគ្គលដែលជាឯកពីជី បណ្ឌិតគប្បីជ្រាបអត្ថ ដោយឧបាយនេះឯង ។ល។

**អដ្ឋកថាកោលំកោលឯកពីជី ចប់**

# អភិធម្មបិដក

## ជីវិតាវោរោបនកថា

[ ៧១ ] បុគ្គលបរិបូរណ៍ដោយទិដ្ឋិ ( សម្មាទិដ្ឋិ ) គប្បីក្លែងផ្តាច់បង់ជីវិតសត្វដែរឬ ។ អើ ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីក្លែងផ្តាច់បង់ជីវិតមាតា ។បេ។ ផ្តាច់បង់ជីវិតបិតា ។បេ។ ផ្តាច់បង់ជីវិតព្រះអរហន្ត ។បេ។ មានចិត្តប្រទូស្ត ញុំាងព្រះលោហិតរបស់ព្រះតថាគតឲ្យពុរពោរឡើង ។បេ។ និងបំបែកសង្ឃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២ ] បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីក្លែងផ្តាច់បង់ជីវិតសត្វដែរឬ ។ អើ ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ មិនគោរពក្នុងព្រះសាស្តាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ មិនគោរពក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ក្នុងសិក្ខាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣ ] ក្រែងបុគ្គលបរិបូរណ៍ដោយទិដ្ឋិ ប្រកបដោយសេចក្តីគោរពក្នុងព្រះសាស្តាដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ ប្រកបដោយសេចក្តីគោរពក្នុងព្រះសាស្តាដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីក្លែងផ្តាច់បង់ជីវិតសត្វទេ ។ ក្រែងបុគ្គលបរិបូរណ៍ដោយទិដ្ឋិ ប្រកបដោយសេចក្តីគោរពក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ក្នុងសិក្ខាដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ ប្រកបដោយសេចក្តីគោរពក្នុងសិក្ខាដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោល

ថា បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីក្លែងផ្តាច់បង់ជីវិតសត្វទេ ។

[ ៧៤ ] បុគ្គលបរិបូរណ៍ដោយទិដ្ឋិ មិនមានសេចក្តីគោរពក្នុងព្រះសាស្តាទេឬ ។ អើ ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីជុះដាក់ នោមដាក់ ស្តោះដាក់ ក្នុងព្រះស្តូបនៃព្រះពុទ្ធ គប្បីពេបជ្រាយក្នុងព្រះស្តូបនៃព្រះពុទ្ធដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៥ ] បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីក្លែងផ្តាច់បង់ជីវិតសត្វឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តិដល់សាវកទាំងឡាយហើយ ពួកសាវករបស់តថាគត សូម្បីមានហេតុដល់ជីវិតក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខានោះឡើយ ក៏យ៉ាងនោះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីក្លែងផ្តាច់បង់ជីវិតសត្វទេ ។

**ជីវិតាវោរោបនកថា ចប់**

# អដ្ឋកថា

## ជីវិតាវោរោបនកថា

[ ៧១ ] ឥឡូវនេះ នឹងពណ៌នារឿងការក្លែងផ្តាច់ជីវិតដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយ បុព្វសេលិយៈទាំងឡាយថា ព្រោះបាណាតិបាត មានដោយចិត្តដែលសម្បយុត្តជាមួយទោសៈ ព្រះអរិយបុគ្គលដែលបរិបូរណ៍ដោយទិដ្ឋិ គឺសោតាបន្ន លះទោសៈមិនទាន់បាន ព្រោះហេតុនោះ ព្រះអរិយបុគ្គលដែលបរិបូរណ៍ ដោយទិដ្ឋិនោះ គប្បីក្លែងផ្តាច់ជីវិតសត្វបាន ដូច្នេះ ពាក្យសួររបស់សកវាទី ថា **ទិដ្ឋិសម្បន្នោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាទាំងឡាយ មានបទថា **សញ្ចិច្ច មាតរំ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ ដែលព្រះមានព្រះភាគ ត្រាស់ថា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ដូច្នេះ ។

[ ៧២-៧៥ ] បទថា **សត្ថរិ អគារវោ** ជាដើម សកវាទីពោលដើម្បីសម្តែងការមិនឈានកន្លងសិក្ខាបទ របស់បុគ្គលដែលមានការគោរពក្នុងព្រះសាស្តាជាដើម ។ បរវាទីឆ្លើយបដិសេធ ដោយគិតថា ឈ្មោះថា ការមិនគោរពរបស់ព្រះអរិយៈ ដែលបរិបូរណ៍ដោយទិដ្ឋិនោះ ដោយអំណាចនៃ

អកុសល មិនមាន និងឆ្លើយទទួលនូវភាពដែលព្រះសោតាបន្ន ដែលមានសេចក្តីគោរព ត្រូវសួរទៀតថា **អគារវោ** ក៏បរវាទីឆ្លើយទទួល សំដៅយកការមិនធ្វើអភិវាទ និងមិនធ្វើប្រទក្សិណព្រះចេតិយ ព្រោះមិនបានមនសិការ ទាក់ទងនឹងការមិនមានសតិ របស់ព្រះសោតាបន្ន ដែលមានចិត្តរាយមាយ ព្រោះរវល់ខ្វល់ខ្វាយក្នុងកិច្ចដទៃៗ ។ ត្រូវសួរទៀតដោយន័យថា **ឱហាយេយ្យ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនក្លែងធ្វើដោយកិរិយាបែបនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាជីវិតាវោរោបនកថា ចប់

# អភិធម្មបិដក

## ទុគ្គតិកថា

[ ៧៦ ] បុគ្គល បរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិដែរឬ ។ អើ ។ បុគ្គល បរិបូរណ៍ដោយទិដ្ឋិ គប្បីត្រេកអរក្នុងរូប ប្រកបដោយសេចក្ដីវិនាសដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីត្រេកអរក្នុងរូប ប្រកបដោយសេចក្ដីវិនាសដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិទេ ។

[ ៧៧ ] បុគ្គល បរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិដែរឬ ។ អើ ។ បុគ្គល បរិបូរណ៍ដោយទិដ្ឋិ គប្បីត្រេកអរក្នុងសំឡេង ប្រកបដោយសេចក្ដីវិនាស ។បេ។ ក្នុងក្លិន ។បេ។ ក្នុងរស ។បេ។ ក្នុងផោដ្ឋព្វៈ ។បេ។ គប្បីសេពនូវមេថុនធម្ម ដោយស្រីអមនុស្ស តិរច្ឆានញី ដោយនាគកញ្ញា គប្បីទទួលពពែ និងចៀម ទទួលមាន់ និងជ្រូក ទទួលដំរី គោ សេះឈ្មោល និងសេះញី ។បេ។ ទទួលទទា ចាប ក្ងោក ចចាតដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីទទួលទទា ចាប ក្ងោក ចចាតដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលបរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិទេ ។

[ ៧៨ ] បុគ្គល បរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិ ចុះបុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីត្រេកអរក្នុងរូប ប្រកបដោយសេចក្ដីវិនាសដែរឬ ។ អើ ។ ព្រះអរហន្ត លះបង់ទុគ្គតិ ចុះព្រះអរហន្ត គប្បីត្រេកអរក្នុងរូប ប្រកបដោយសេចក្ដីវិនាសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលបរិបូរណ៍

ដោយទិដ្ឋិ លះបង់ទុគ្គតិ ចុះបុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីត្រេកអរក្នុងសំឡេង ប្រកបដោយសេចក្តីវិនាស ។បេ។ ក្នុងក្លិន ។បេ។ ក្នុងរស ។បេ។ ក្នុងផោដ្ឋព្វៈ ។បេ។ គប្បីទទួលទទា ចាប ក្ងោក ចចាត ដែរឬ ។ អើ ។ ព្រះអរហន្ត លះបង់ទុគ្គតិ ចុះព្រះអរហន្ត គប្បីទទួលទទា ចាប ក្ងោក ចចាតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៩ ] ព្រះអរហន្ត លះបង់ទុគ្គតិ តែព្រះអរហន្ត មិនគប្បីត្រេកអរក្នុងរូប ប្រកបដោយសេចក្តីវិនាសទេឬ ។ អើ ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិ តែបុគ្គលបរិបូរណ៍ដោយទិដ្ឋិ មិនគប្បីត្រេកអរក្នុងរូប ប្រកបដោយសេចក្តីវិនាសទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះបង់ទុគ្គតិ តែព្រះអរហន្ត មិនគប្បីត្រេកអរក្នុងសំឡេង ប្រកបដោយសេចក្តីវិនាស ។បេ។ ក្នុងក្លិន ។បេ។ ក្នុងរស ។បេ។ ក្នុងផោដ្ឋព្វៈ ។បេ។ គប្បីសេពមេថុនធម្ម ដោយស្រីអមនុស្ស តិរច្ឆានញី នាគកញ្ញា គប្បីទទួលពពែ និងចៀម ទទួលមាន់ និងជ្រូក ទទួលដំរី គោ សេះឈ្មោល និងសេះញី ។បេ។ ទទួលទទា ចាប ក្ងោក និងចចាតដែរឬ ។ អើ ។ បុគ្គល

បរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិ តែបុគ្គលបរិបូរណ៍ដោយទិដ្ឋិ មិនគប្បី ទទួលទទា ចាប ក្ងោក ចចាតទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០ ] បុគ្គល មិនគួរនិយាយថា បុគ្គលបរិបូរណ៍ដោយទិដ្ឋិ លះបង់ ទុគ្គតិទេឬ ។ អើ ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ គប្បីកើតក្នុងនរក ។បេ។ កើត ក្នុងកំណើតតិរច្ឆាន ។បេ។ កើតក្នុងបិត្តិវិស័យដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ ព្រោះហេតុនោះ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិ ។

ទុគ្គតិកថា ចប់

# អដ្ឋកថា

## ទុគ្គតិកថា

[ ៧៦ ] ឥឡូវនេះ នឹងពណ៌នាអំពីទុគ្គតិដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា កាន់យកទាំង ២ គឺទុគ្គតិ ១ តណ្ហាដែលមានរូបជាដើម របស់ទុគ្គតិសត្វជាអារម្មណ៍ ១ ថាជាទុគ្គតិ ហើយមិនបែកប្រភេទយ៉ាងនោះទៀត ទើបពោលថា បុគ្គលដល់ព្រមដោយទិដ្ឋិ លះទុគ្គតិបាន ដោយមិនផ្សេងគ្នាឡើយ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បទថា **អាចាយិកោ រូបេ រជ្ជេយ្យ** ជាដើម សកវាទីពោលដើម្បីចោទសួរ ដោយអំណាចនៃលទ្ធិរបស់បរវាទីថា បុគ្គលដល់ព្រមដោយទិដ្ឋិ លះទុគ្គតិមិនបាន ។ ពាក្យដ៏សេស ក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ៨០ ] បទថា **និរយំ ឧបបជ្ជេយ្យ** ជាដើម រមែងសម្តែងការលះទុគ្គតិប៉ុណ្ណោះ ឬរមែងសម្តែងការលះតណ្ហា ដែលជាហេតុនាំទៅកាន់ទុគ្គតិ មិនមែនសម្តែងដល់ការលះតណ្ហា ដែលមានរូបជាដើមរបស់ទុគ្គតិសត្វទាំងឡាយជាអារម្មណ៍ ព្រោះហេតុនោះ ទើបសេចក្តីនេះ មិនជាគោលអះអាងដូច្នេះ ៕

**អដ្ឋកថាទុគ្គតិកថា ចប់**

# អភិធម្មបិដក

## សត្តមភវិកកថា

[ ៨១ ] បុគ្គល មិនគួរនិយាយថា បុគ្គលដែលកើតក្នុងភពជាគម្រប់ ៧ លះបង់ទុគ្គតិទេឬ ។ អើ ។ បុគ្គលដែលកើតក្នុងភពជាគម្រប់ ៧ គប្បីកើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បុគ្គលដែលកើតក្នុងភពជាគម្រប់ ៧ លះបង់ទុគ្គតិ ។

សត្តមភវិកកថា ចប់

ទុតិយវគ្គ ចប់

## ឧទ្ទាននៃទ្វាទសមវគ្គនោះ គឺ

និយាយអំពីសេចក្តីសង្រួមជាកម្ម ១ សេចក្តីមិនសង្រួមជាកម្ម ដូចគ្នា ១ កម្មទាំងអស់ប្រកបដោយវិបាក ១ សំឡេងជាវិបាក ១ សឡាយតនៈជាវិបាក ១ សត្តក្ខត្តុំបរមបុគ្គលទៀងដោយការកើត ៧ ជងទៀតយ៉ាងច្រើន ១ កោលំកោលៈបុគ្គលទៀងដោយការកើត ៦ ជងទៀត ១ ឯកវីជិបុគ្គលទៀងដោយពូជមួយទៀត ១ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ ក្លែងផ្តាច់បង់ជីវិតសត្វ ១ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ លះបង់ទុគ្គតិ ១ បុគ្គលដែលកើតក្នុងភពជាគម្រប់ ៧ លះបង់ទុគ្គតិដូចគ្នាដែរ ១ ។

# អដ្ឋកថា

## សត្តមភាវិកកថា

[ ៨១ ] ក្នុងកិច្ចពណ៌នាអំពីព្រះសោតាបន្ន ដែលមានភពទី ៧ ក៏ន័យនេះឯង គឺដូចគ្នានឹងរឿងបុគ្គលដែលដល់ព្រមដោយទិដ្ឋិ ដូច្នេះឯង ។៚

**អដ្ឋកថាសត្តមភាវិកកថា ចប់**

**វគ្គទី ១២ ចប់**

# អភិធម្មបិដក

## កប្បដ្ឋកថា

[ ៨២ ] បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ កប្បតាំងនៅផង ព្រះពុទ្ធកើតឡើង ក្នុងលោកផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ កប្បតាំងនៅផង សង្ឃបែកគ្នាផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ កប្បតាំងនៅផង បុគ្គលតាំងនៅក្នុងកប្ប ធ្វើកម្មដែលគួរដល់ការតាំងនៅក្នុងកប្បផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ កប្បតាំងនៅផង បុគ្គលតាំងនៅក្នុងកប្ប ធ្វើនូវមរណកាលផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ បុគ្គល គប្បីស្ថិតនៅអស់កប្បជាអតីត ស្ថិតនៅអស់កប្ប ជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្ប ២ គប្បីស្ថិតនៅអស់កប្ប ៣ គប្បីស្ថិតនៅអស់កប្ប ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បឬ ។ អើ ។ បុគ្គលតាំងនៅក្នុងកប្ប កាលបើកប្ប គឺភ្លើងកំពុងឆេះ តើទៅក្នុងទីណា ។ ទៅកាន់លោកធាតុដទៃ ។ បុគ្គលស្លាប់ហើយ ទៅកាន់អាកាសធាតុបានឬ ។ បុគ្គលស្លាប់ហើយ រមែងទៅបាន ។ កម្មដែល

គួរដល់ការតាំងនៅក្នុងកប្ប ឲ្យផលក្នុងកពតទៅខាងមុខ ជាលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលតាំងនៅក្នុងកប្ប ទៅកាន់អាកាសបានដែរឬ ។ អើ ។ បុគ្គលតាំងនៅក្នុងកប្បមានឫទ្ធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល តាំងនៅក្នុងកប្ប មានឫទ្ធិឬ ។ អើ ។ បុគ្គលតាំងនៅក្នុងកប្បចម្រើនឆន្ទិទ្ធិបាទ ចម្រើនវីរិយិទ្ធិបាទ ចម្រើនចិត្តិទ្ធិបាទ ចម្រើនវីមំ-សិទ្ធិបាទឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៣ ] បុគ្គលមិនគួរនិយាយថា បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្បទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

បុគ្គលអ្នកបំបែកសង្ឃ ទៅកាន់អបាយ ទៅកាន់នរក តាំងនៅអស់កប្ប ត្រេកអរក្នុងពួក មិនតាំងនៅក្នុងធម៌ រមែងឃ្លាតចាកធម៌ ជាគ្រឿងក្សេមចាកយោគៈ លុះបំបែកសង្ឃ ដែលព្រមព្រៀងគ្នាហើយ រមែងឆេះនៅក្នុងនរកអស់កប្ប ( ទាំងអស់ ) ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្ប ។

## កប្បដ្ឋកថា ចប់

# អដ្ឋកថា

## កប្បដ្ឋកថា

[ ៨២ ] ឥឡូវនេះ នឹងពណ៌នាអំពីរឿងកប្បដ្ឋៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈទាំងឡាយថា បុគ្គលធ្វើសង្ឃភេទ រមែងតាំងនៅក្នុងនរកអស់ ១ កប្ប ដូច្នេះ ព្រោះកាន់យកព្រះសូត្រថា លុះបំបែកសង្ឃ ដែលព្រមព្រៀងគ្នាហើយ រមែងឆេះនៅក្នុងនរកអស់កប្ប ( ទាំងអស់ ) ដូច្នេះ ពាក្យសួររបស់សកវាទីថា **កប្បដ្ឋោ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **ពុទ្ធោ ច លោកេ** សកវាទីពោលហើយ ដើម្បីសម្តែងការមិនមានសង្ឃភេទ ដោយវៀរចាកការកើតឡើងរបស់ព្រះពុទ្ធ ។ បទថា **កប្បោ ច សណ្ឋាតិ សង្ឃោ ច ភិជ្ជតិ** ជាដើម សកវាទីពោលដើម្បីសម្តែងថា បើបុគ្គលតាំងនៅអស់កប្បនោះ រមែងតាំងនៅអស់កប្បទាំងមូលសោត បុគ្គលនោះ ក៏ត្រូវធ្វើកម្មនោះ តាំងអំពីកប្បដែលកំពុងតាំងឡើងហើយកកើត តាំងនៅក្នុងនរកនោះ ។ បទថា **អតីតំ** ជាដើម មានអធិប្បាយដូចពាក្យដែលពោលហើយខាងដើមនោះឯង ។ ក្នុងបញ្ហាថា **កប្បដ្ឋោ ឥទ្ធិមា** បរវាទីឆ្លើយបដិសេធ សំដៅយកឫទ្ធិដែលសម្រេចដោយការចម្រើនភាវនា តែឆ្លើយទទួល សំដៅយកឫទ្ធិដែលសម្រេចព្រមជាមួយនឹងការកើតរបស់បុគ្គលដែលបុគ្គលតាំងនៅអស់កប្ប ក្នុងលទ្ធិរបស់បរវាទី សំដៅយកឫទ្ធិដែលសម្រេចដោយកាចម្រើនភាវនា តែឆ្លើយទទួល សំដៅយកឫទ្ធិដែល

សម្រេច ដែលសម្រេចព្រមនឹងការកើតរបស់បុគ្គលដែលជាកប្បដ្ឋៈ ដែលបរវាទីកាន់យកក្នុងលទ្ធិរបស់ខ្លួន ។ បទថា **ឆន្ទិទ្ធិចាគោ** ជាដើម សកវាទីពោលដើម្បីចោទសួរថា ពាក្យថា បុគ្គលមានឫទ្ធិដោយឫទ្ធិ ដែលសម្រេចព្រមនឹងការកើត នេះត្រឹមតែជាលទ្ធិ ប្រយោជន៍អ្វីដោយលទ្ធិនោះ បើឫទ្ធិរបស់បុគ្គលដែលមានឫទ្ធិ ដែលសម្រេចព្រមនឹងការកើតមានសោត បុគ្គលនេះ ក៏គប្បីចម្រើនឥទ្ធិបាទទាំងនេះ សម្រេចហើយ ។

[ ៨៣ ] ព្រះសូត្រថា **អាបាយិកោ នេរយិកោ** ព្រះមានព្រះភាគត្រាស់សំដៅយកអាយុកប្ប ដែលជាវេលាត្រឹមតែចំណែកមួយ អំពីទីដែលបែងចែកកប្បមួយ ចេញជា ៨០ ចំណែក ដែលបុគ្គលតាំងនៅក្នុងកប្ប ដែលធ្វើសង្ឃភេទ គប្បីតាំងនៅ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនជាគោលអាង ដូច្នេះ ។l៚

## អដ្ឋកថាកប្បដ្ឋកថា ចប់

# អភិធម្មបិដក

## កុសលចិត្តប្បដិលាភកថា

[ ៨៤ ] បុគ្គលតាំងនៅអស់កប្ប មិនគប្បីបានចំពោះនូវកុសលចិត្តទេ ឬ ។ អើ ។ បុគ្គលតាំងនៅអស់កប្ប គប្បីឲ្យនូវទានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលតាំងនៅអស់កប្ប គប្បីឲ្យនូវទានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលតាំងនៅអស់កប្ប មិនគប្បីបានចំពោះនូវកុសលចិត្តទេ ។

[ ៨៥ ] បុគ្គលតាំងនៅអស់កប្ប មិនគប្បីបានចំពោះនូវកុសលចិត្តទេ ឬ ។ អើ ។ បុគ្គលតាំងនៅអស់កប្ប គប្បីឲ្យចីវរឬ ។បេ។ ឲ្យបិណ្ឌបាត ។បេ។ ឲ្យសេនាសនៈ ។បេ។ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យវត្ថុគួរទំពាស៊ី ឲ្យវត្ថុគួរបរិភោគ ឲ្យទឹកគួរផឹក ថ្វាយបង្គំចេតិយ លើកឡើងនូវផ្កាកម្រង លើកឡើងនូវគ្រឿងក្រអូប លើកឡើងនូវគ្រឿងលាបក្នុងចេតិយ ។បេ។ ធ្វើនូវចេតិយ ឲ្យជាអភិទក្សិណដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលតាំងនៅអស់កប្ប គប្បីធ្វើនូវចេតិយ ឲ្យជាអភិទក្សិណ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលតាំងនៅអស់កប្ប មិនគប្បីបានចំពោះនូវកុសលចិត្តទេ ។បេ។

[ ៨៦ ] បុគ្គលតាំងនៅអស់កប្ប គប្បីបានចំពោះនូវកុសលចិត្តដែរឬ ។ អើ ។ បុគ្គលគប្បីបានចំពោះនូវកុសលចិត្ត ដែលចេញចាកកប្បនោះដែរឬ ។ អើ ។ បុគ្គលគប្បីបានចំពោះនូវកុសលចិត្ត ជារូបាវចរ ។បេ។ អរូបាវចរ ។បេ។ លោកុត្តរដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

កុសលចិត្តប្បដិលាភកថា ចប់

# អដ្ឋកថា

## កុសលចិត្តប្បដិលាភកថា

[ ៨៤ ] ឥឡូវនេះ នឹងពណ៌នាអំពីការត្រឡប់បាននូវកុសលចិត្តរបស់បុគ្គលដែលតាំងនៅអស់កប្បដូចតទៅ

ក្នុងរឿងនោះ បុគ្គលតាំងនៅអស់កប្ប ក្នុងលទ្ធិរបស់សកវាទី រមែងត្រឡប់បានកាមាវចរកុសលចិត្តប៉ុណ្ណោះ បុគ្គលគប្បីរារាំងការកើតឡើងក្នុងនរកនោះ ដោយមហគ្គតកុសល ឬលោកុត្តរកុសលណា បុគ្គលរមែងមិនត្រឡប់បានកុសលនោះ ។ ជនទាំងឡាយណា មិនធ្វើការចែកនេះហើយ មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា បុគ្គលដែលតាំងនៅអស់កប្បនោះ រមែងមិនត្រឡប់បានកុសលចិត្ត ដោយមិនផ្សេងគ្នាឡើយ ពាក្យសួររបស់សកវាទី ដើម្បីទម្លាយលទ្ធិនោះ ដោយការសម្ដែងការចែកដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាកុសលចិត្តប្បដិលាភកថា ចប់**

# អភិធម្មបិដក

## អន្តរាបយុត្តកថា

[ ៨៧ ] បុគ្គលប្រកបក្នុងកម្ម ដែលឲ្យផលជាលំដាប់ ( គឺអនន្តរិយកម្ម ) ហើយគប្បីឈានចុះកាន់សម្មត្តនិយាមដែរឬ ។ អើ ។ បុគ្គលគប្បីឈានចុះកាន់សភាវៈទាំងពីរ គឺមិច្ឆត្តនិយាម ១ សម្មត្តនិយាម ១ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ប្រកបក្នុងកម្មដែលឲ្យផលជាលំដាប់ គប្បីឈានចុះកាន់សម្មត្តនិយាមដែរឬ ។ អើ ។ ក្រែងកម្មនោះ បុគ្គលនោះប្រកបហើយ សេចក្តីក្តៅក្រហាយ បុគ្គលនោះចូលទៅជិត តម្កល់ទុកហើយ សេចក្តីស្តាយក្រោយ បុគ្គលនោះ ឲ្យកើតហើយឬ ។ អើ ។ ប្រសិនបើ កម្មនោះ បុគ្គលនោះប្រកបហើយ សេចក្តីក្តៅក្រហាយ បុគ្គលនោះ តម្កល់ទុកហើយ សេចក្តីស្តាយក្រោយ បុគ្គលនោះឲ្យកើតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រកបក្នុងកម្មដែលឲ្យផលជាលំដាប់ គប្បីឈានចុះកាន់សម្មត្តនិយាមទេ ។

[ ៨៨ ] បុគ្គលប្រកបក្នុងកម្ម ដែលឲ្យផលជាលំដាប់ មិនគួរឈានចុះកាន់សម្មត្តនិយាមទេឬ ។ អើ ។ បុគ្គលនោះផ្តាច់បង់ជីវិតមាតា ផ្តាច់បង់ជីវិតបិតា ផ្តាច់បង់ជីវិតព្រះអរហន្ត មានចិត្តប្រទូស្ត ញ៉ាំងលោហិតព្រះតថាគតឲ្យពុរពោរឡើង និងបំបែកសង្ឃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រកបក្នុងកម្ម ដែលឲ្យផលជាលំដាប់ ហើយប្រមូលមកនូវកម្មនោះ បន្ទោបង់នូវសេចក្តីក្តៅក្រហាយ កម្ចាត់បង់នូវសេចក្តីស្តាយ

ក្រោយ មិនគួរឈានចុះកាន់សម្មត្តនិយាមទេឬ ។ អើ ។ ( បុគ្គលនោះ ) ផ្តាច់បង់ជីវិតមាតា ផ្តាច់បង់ជីវិតបិតា ។បេ។ និងបំបែកសង្ឃឬ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រកបក្នុងកម្មដែលឲ្យផលជាលំដាប់ ហើយប្រមូលមកនូវកម្មនោះ បន្ទោបង់នូវសេចក្តីក្តៅក្រហាយ កម្ចាត់បង់នូវសេចក្តីស្តាយក្រោយ មិនគួរឈានចុះកាន់សម្មត្តនិយាមទេឬ ។ អើ ។ ក្រែងកម្មនោះ បុគ្គលនោះ ប្រមូលទុកហើយ សេចក្តីក្តៅក្រហាយ បុគ្គលនោះ បន្ទោបង់ហើយ សេចក្តីស្តាយក្រោយ បុគ្គលនោះ កម្ចាត់បង់ហើយឬ ។ អើ ។ ប្រសិនបើ កម្មនោះ បុគ្គលនោះ ប្រមូលទុកហើយ សេចក្តីក្តៅក្រហាយ បុគ្គលនោះ បន្ទោបង់ហើយ សេចក្តីស្តាយក្រោយ បុគ្គលនោះ កម្ចាត់បង់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រកបក្នុងកម្មដែលឲ្យផលជាលំដាប់ ប្រមូលមកនូវកម្មនោះ បន្ទោបង់នូវសេចក្តីក្តៅក្រហាយ កម្ចាត់បង់នូវសេចក្តីស្តាយក្រោយ មិនគួរឈានចុះកាន់សម្មត្តនិយាមទេ ។

[ ៨៩ ] បុគ្គលប្រកបក្នុងកម្ម ដែលឲ្យផលជាលំដាប់ គប្បីឈានចុះកាន់សម្មត្តនិយាមដែរឬ ។ អើ ។ ក្រែងបុគ្គលប្រកបនូវកម្មនោះ មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលប្រកបនូវកម្មនោះ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រកបក្នុងកម្ម ដែលឲ្យផលជាលំដាប់ គប្បីឈានចុះកាន់សម្មត្តនិយាមទេ ។

**អនន្តរាបយុត្តកថា ចប់**

# អដ្ឋកថា

## អនន្តរាបយុត្តកថា

[ ៨៧ ] ឥឡូវនេះ នឹងពណ៌នាអំពីរឿងបុគ្គលដែលប្រើឲ្យធ្វើអនន្តរិយកម្មដូចតទៅ

ក្នុងទីនេះ បុគ្គលណា ប្រើឲ្យធ្វើអនន្តរិយកម្ម មានការសម្លាប់មាតាជាដើមដែលឲ្យផល ដោយមិនមានកពដទៃរាំងក្នុងរវាងអំពីស្លាប់ទៅ បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រើឲ្យធ្វើអនន្តរិយកម្ម ក្នុងរឿងនេះ សកវាទីធ្វើការសន្និដ្ឋាន គឺដាក់នូវទិដ្ឋិក្នុងលទ្ធិរបស់ខ្លួនថា បុគ្គលណា ជាអ្នកប្រើឲ្យគេធ្វើកម្មនោះ ដោយពាក្យប្រើដែលទៀងទាត់ បុគ្គលនោះ រមែងជាបុគ្គលទៀងក្នុងផ្លូវដែលខុស បុគ្គលនោះ រមែងជាបុគ្គលមិនគួរឈានចុះកាន់សម្មត្តនិយាម ព្រោះភាពដែលចេតនាញុំាងនូវបំណងឲ្យសម្រេច កើតឡើងហើយ តែបុគ្គលណាជាអ្នកប្រើឲ្យគេធ្វើកម្មនោះ ដោយពាក្យប្រើដែលមិនទៀងទាត់ បុគ្គលនោះ មិនឈ្មោះថា ជាអ្នកទៀងក្នុងផ្លូវដែលខុស បុគ្គលនោះ រមែងជាបុគ្គលគួរឈានចុះកាន់សម្មត្តនិយាម ព្រោះភាពដែលចេតនាញុំាងបំណងឲ្យសម្រេចមិនទាន់កើតឡើង ដូច្នេះ ។

ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា បុគ្គលឈ្មោះថា ជាអ្នកមិនគួរឈានចុះកាន់សម្មត្តនិយាមទាំងនោះសូម្បីដោយពាក្យប្រើដែលមិនទៀងទាត់ ដូច្នេះ ដើម្បីទម្លាយលទ្ធិនៃជនទាំងនោះ ទើបសកវាទីឲ្យបរវាទីសួរខ្លួនមុនថា **អនន្តរាបយុត្តោ** ជាដើម ។ ដោយ

ហេតុនោះ ទើបពាក្យសួរជំបូងក្នុងបញ្ហានេះ ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល សំដៅយកការមិនមានចេតនា ដែលញ៉ាំងបំណងឲ្យសម្រេច ជាពាក្យរបស់សកវាទី ។ បន្ទាប់អំពីនោះ បរវាទីសម្គាល់ថា បុគ្គលនោះ ជាបុគ្គលទៀងក្នុងផ្លូវដែលខុស ព្រោះការប្រើឲ្យធ្វើកម្ម មានការសម្លាប់មាតាជាដើមនោះឯង ព្រោះហេតុនោះ ទើបសួរបញ្ហាថា **មិច្ឆត្តនិយាមញ្ច** ជាដើម ។ សកវាទីឆ្លើយបដិសេធថា **ន ហេវំ** សំដៅយកត្រឹមតែការមិនឈានចុះកាន់និយាមទាំងពីរយ៉ាងរបស់បុគ្គលម្នាក់ ។

បទថា **ឆន្ទុ តំ កម្មំ** បានដល់ អនន្តរិយកម្ម មានការសម្លាប់មាតាជាដើម ។ ក្នុងបញ្ហានោះ សកវាទីឆ្លើយទទួលថា **អាមន្តា** សំដៅយកពាក្យប្រើដែលមិនទៀងទាត់ ព្រោះថា វិប្បដិសារី និងការក្តៅក្រហាយ រមែងកើតឡើងដល់បុគ្គលដែលប្រកបពាក្យប្រើ សូម្បីដែលមិនទៀងទាត់ ហើយតាំងនៅថា អញធ្វើកម្មដែលមិនសមគួរហើយនោះឯង ដូច្នេះ ។ បទថា **ហាញ្ចិ** ជាដើម បរវាទីពោលហើយ ក៏ដើម្បីនឹងឲ្យលទ្ធិតាំងទុកដោយការកាន់យកនូវហេតុ ត្រឹមតែការកើតឡើងនៃការរំខានចិត្ត ។

[ ៨៨ ] ឥឡូវនេះ ជាពាក្យសួររបស់សកវាទីថា **អនន្តរាបយុត្តោ បុគ្គលោ អភព្វោ** ព្រោះកាន់យកបុគ្គលនោះឯង បុគ្គលដែលប្រើឲ្យធ្វើអនន្តរិយកម្ម សូម្បីដោយពាក្យប្រើដែលមិនទៀងទាត់ ដែលបរវាទីឆ្លើយបដិសេធថា មានការឈានចុះកាន់សម្មត្តនិយាមបាន បរវាទីឆ្លើយទទួលដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ លំដាប់នោះ សកវាទី ដើម្បីចោទសួរ

បរវាទីនោះ ក៏សួរថា បុគ្គលធ្វើកម្ម មានសម្លាប់មាតាជាដើម ឈ្មោះថា មិនគួរឈានចុះកាន់សម្មត្តនិយាម ឯកម្មទាំងនោះ ដែលបុគ្គលនោះធ្វើហើយ តាមលទ្ធិរបស់អ្នកឬ ទើបពោលពាក្យថា **មាតា ជីវិតា វោរោបិតា** ជាដើម ។ បរវាទីកាលមិនឃើញការធ្វើបែបនោះ ព្រោះវត្ថុទាំងនោះ មិនត្រូវបៀតបៀន ទើបឆ្លើយបដិសេធថា **ន ហេវំ** ។

បទថា **តំ កម្មំ បដិសំហរិត្វា** សកវាទីពោលសំដៅយកកម្ម ដែលជាពាក្យប្រើមិនទៀងទាត់ ។ បុគ្គលហាមពាក្យប្រើថា ចូរអ្នកកុំធ្វើវត្ថុដែលខ្ញុំប្រើហើយ ដូច្នេះ កម្មនោះឈ្មោះថា ជាកម្មដែលបុគ្គលនោះលះបង់ហើយ ។ ក្នុងសេចក្តីនេះ ព្រោះភាពដែលពាក្យប្រើនោះ ខ្លួនដកហើយនោះឯង ទើបឈ្មោះថា ខ្លួនបន្ទោបង់នូវវិប្បដិសារី និងការក្តៅក្រហាយចិត្តបាន ។ កាលបើយ៉ាងនេះ ក្នុងបញ្ហានេះ បរវាទីដែលសម្គាល់នូវភាពដែលពាក្យប្រើដំបូងប៉ុណ្ណោះ ជាពាក្យប្រើទៀងទាត់ ទើបឆ្លើយទទួលថា **អាមន្តា** ។ ពេលនោះ ទើបសកវាទីឲ្យបរវាទីទទួលនូវភាពដែលកម្មនោះ ជាកម្មដែលដកហើយ ហើយញ៉ាំងលទ្ធិរបស់ខ្លួនឲ្យតាំងនៅ ទើបពោលពាក្យថា **ហញ្ចិ** ជាដើម ។

[ ៨៩ ] ក្នុងបញ្ហាចុងក្រោយថា **អនន្តរាបយុត្តោ** ម្តងទៀត ជាពាក្យសួររបស់បរវាទី ដែលដូចគ្នានឹងបញ្ហាដំបូង ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ។ ពាក្យសាកសួរថា **ឆន្ទុ តំ កម្មំ** ជាពាក្យរបស់បរវាទី ។ សកវាទីឆ្លើយទទួល សំដៅយកកាលដែលប្រើឲ្យធ្វើក្នុងកាលមុនដកពាក្យ ។ ការតាំងលទ្ធិថា **ហញ្ញិ** ជាដើម ជាពាក្យរបស់បរវាទី ដោយអំណាចពាក្យប្រើដែលមិនទៀងទាត់ ព្រោះកាន់យកហេតុ ត្រឹមតែភាពជាអ្នកប្រើឲ្យធ្វើក្នុងគ្រាដំបូង ។ លទ្ធិនេះ រមែងតាំងនៅមិនបាន ព្រោះតាំងទុក ដោយមិនពិចារណា ដូច្នេះ ។ល។

## អដ្ឋកថាអនន្តរាបយុត្តកថា ចប់

# អភិធម្មបិដក

## និយតនិយាមកថា

[ ៩០ ] និយតបុគ្គល រមែងឈានចុះកាន់និយាមឬ ។ អើ ។ មិច្ឆត្តនិយតបុគ្គល ( បុគ្គលដែលកំណត់ខុស ) ឈានចុះកាន់សម្មត្តនិយាម សម្មត្តនិយតបុគ្គល ( បុគ្គលដែលកំណត់ត្រូវ ) ឈានចុះកាន់មិច្ឆត្តនិយាមដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និយតបុគ្គល ឈានចុះកាន់និយាមឬ ។ អើ ។ បុគ្គលចម្រើនមគ្គមុន ទើបឈានចុះកាន់និយាមជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនសោតាបត្តិមគ្គមុន ទើបឈានចុះកាន់សោតាបត្តិនិយាមជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនសកទាគាមិមគ្គ ។បេ។ អនាគាមិមគ្គ ។បេ។ អរហត្តមគ្គមុន ទើបឈានចុះកាន់អរហត្តនិយាម ជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនសតិប្បដ្ឋាន ។បេ។ សម្មប្បធាន ។បេ។ ឥទ្ធិបាទ ។បេ។ ឥន្ទ្រិយ ។បេ។ ពល ។បេ។ ពោជ្ឈង្គមុន ទើបឈានចុះកាន់និយាមជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩១ ] បុគ្គលមិនគួរនិយាយថា និយតបុគ្គល ឈានចុះកាន់និយាមទេឬ ។ អើ ។ ព្រះពោធិសត្វ មិនគួរដើម្បីត្រាស់ដឹងនូវធម៌ដោយជាតិនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ និយតបុគ្គល ឈានចុះកាន់និយាមដែរ ។

**និយតនិយាមកថា ចប់**

# អដ្ឋកថា

## និយតនិយាមកថា

[ ៩០ ] ឥឡូវនេះ នឹងពណ៌នានិយាមរបស់បុគ្គលដែលទៀងហើយដូចតទៅ

ក្នុងរឿងនោះ និយាម មាន ២ យ៉ាង គឺអនន្តរិយកម្ម ឈ្មោះថា **មិច្ឆត្ត-និយាម ១** អរិយមគ្គ ឈ្មោះថា **សម្មត្តនិយាម ១** វៀរនិយាមពីរនេះហើយធម៌ដទៃ ឈ្មោះថា និយាម រមែងមិនមាន ។ ពិតហើយ តេភូមិកធម៌ដ៏សេសទាំងពួង ឈ្មោះថា **អនិយតធម៌** សូម្បីតែបុគ្គលដែលប្រកបដោយតេភូមិកធម៌ទាំងនោះ ក៏ឈ្មោះថា ជាអនិយតទាំងអស់ ។ ព្រះពុទ្ធទាំងឡាយមិនព្យាករបុគ្គលដែលមិនទៀងថា សត្វនេះ នឹងសម្រេចពោធិញ្ញាណក្នុងអនាគតកាល ដោយកម្លាំងញាណរបស់ព្រះអង្គ តែព្រះពោធិសត្វ លោកហៅថា បុគ្គលទៀង ព្រោះភាពជាអ្នកមានបុណ្យច្រើន ។ ជនទាំងឡាយណាមានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយអបរសេលិយៈទាំងឡាយថា បុគ្គលទៀង រមែងឈានចុះកាន់ផ្លូវទៀង ព្រោះបំណងថា ព្រះពោធិសត្វដែលកើតក្នុងភពចុងក្រោយ ជាបុគ្គលគួរត្រាស់ដឹងក្នុងជាតិនោះព្រោះកាន់យកត្រឹមតែវោហារនេះ ដោយប្រការដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **មិច្ឆត្តនិយតោ** ជាដើម សកវាទីពោលដើម្បីសម្ដែងភាពមិនជានិយាមដទៃរបស់បុគ្គលដែលទៀងហើយ ដោយនិយាមណាមួយ ។ បទ

ថា **បុព្វេ មគ្គំ ភាវេត្វា** ជាដើម សកវាទីពោលដើម្បីសម្ដែងប្រភេទនៃនិយាម ។ បទថា **សតិប្បដ្ឋានំ** ជាដើម សកវាទីពោល ដើម្បីសម្ដែងប្រភេទនៃធម៌ក្នុងនិយាមណាមួយ ។

[ ៩១ ] បទថា **ភព្វោ ពោធិសត្តោ** រមែងសម្ដែងភាពដែលព្រះពោធិសត្វ ជាអ្នកគួរត្រាស់ដឹងតែម្យ៉ាង មិនមែនសម្ដែងការឈានចុះកាន់និយាមរបស់និយតបុគ្គល ព្រោះហេតុនោះ ទើបពាក្យនេះ មិនមែនជាគោលអះអាង ។ ពិតហើយ ព្រះពោធិសត្វនោះ ជាបុគ្គលមិនទៀងទាត់ ដោយនិយតធម៌ណាមួយ ក្នុងកាលមុន ឈានចុះកាន់សម្មត្តនិយាមហើយ ដោយការឃើញសច្ចៈ ត្រង់មណ្ឌលពោធិព្រឹក្ស ដោយប្រការដូច្នេះឯង ៕

## អដ្ឋកថានិយតនិយាមកថា ចប់

# អភិធម្មបិដក

## និវុតកថា

[ ៩២ ] និវុតបុគ្គល ( បុគ្គលដែលត្រូវនីវរណៈរួបរឹតហើយ ) លះបង់នីវរណៈឬ ។ អើ ។ បុគ្គលរីករាយ លះបង់រាគៈ បុគ្គលប្រទូស្ត លះបង់ទោសៈ បុគ្គលវង្វេង លះបង់មោហៈ បុគ្គលសៅហ្មង លះបង់កិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់រាគៈដោយរាគៈ លះបង់ទោសៈដោយទោសៈ លះបង់មោហៈដោយមោហៈ លះបង់កិលេសដោយកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រាគៈប្រកបដោយចិត្តហើយ មគ្គប្រកបដោយចិត្តដែរឬ ។ អើ ។ កាប្រជុំនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រាគៈ ជាអកុសល មគ្គ ជាកុសលឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ទីចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ទីចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយនេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងប្រឹថពីនេះ ជាធម្មជាតឆ្ងាយក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះហេតុនោះ ធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោល ថា ពួកកុសល និងអកុសល ។បេ។ មកកាន់ទីចំពោះមុខទេ ។

[ ៩៣ ] នីវុតបុគ្គល លះបង់នីវរណៈដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលនោះ កាលបើចិត្តតម្កល់នៅមាំបរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់គួរដល់ការងារ តាំងនៅនឹង ជាធម្មជាតមិនញាប់ញ័រ យ៉ាងនេះហើយ រមែងបង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា នីវុតបុគ្គល លះបង់នីវរណៈទេ ។

[ ៩៤ ] បុគ្គលមិនគួរនិយាយថា នីវុតបុគ្គល លះបង់នីវរណៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលនោះ កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចចាកកាមាសវៈផង ។បេ។ ចិត្តរមែងរួចចាក អវិជ្ជាសវៈផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ នីវុតបុគ្គល តែងលះបង់នីវរណៈដែរ ។

**នីវុតកថា ចប់**

# អដ្ឋកថា

## និវុតកថា

[ ៩២ ] ឥឡូវនេះ នឹងពណ៌នារឿងរបស់បុគ្គលដែលមានចិត្ត ត្រូវនីវរណៈគ្របសង្កត់ហើយដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា បុគ្គលដែលត្រូវនីវរណៈទាំងឡាយគ្របសង្កត់ហើយ បិទបាំងហើយ រឹតរុំហើយ រមែងលះនីវរណៈ ព្រោះភាពដែលបុគ្គល ដែលបរិសុទ្ធហើយ មិនមានកិច្ចដើម្បីភាពបរិសុទ្ធ ដូច្នេះ ។ ពាក្យសួររបស់សកវាទីថា **និវុតោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បទថា **រត្តោ រាគំ** ជាដើម សកវាទីពោលដើម្បីសម្តែងកំហុស ក្នុងការលះនីវរណៈរបស់បុគ្គលដែលមានចិត្ត ត្រូវនីវរណៈគ្របសង្កត់ហើយ ។

[ ៩៣ ] បទថា **បរិសុទ្ធេ បរិយោទាតេ** ជាដើម សកវាទីពោលដើម្បីសម្តែងសមុច្ឆេទវិសុទ្ធិ នៃបុគ្គលបរិសុទ្ធហើយ ដោយវិក្ខម្ភនវិសុទ្ធិ ។

[ ៩៤ ] បទថា **តស្ស ឯវំ ជានតោ** ជាដើម រមែងសម្តែងការអស់ទៅនៃអាសវៈរបស់បុគ្គលដែលដឹង ឃើញយ៉ាងនេះ មិនមែនសម្តែងដល់ការលះនីវរណៈរបស់បុគ្គលដែលមានចិត្ត ត្រូវនីវរណៈកំពុងគ្របសង្កត់ ព្រោះហេតុនោះ ទើបសេចក្តីនេះមិនមែនជាគោលអះអាង ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថានិវុតកថា ចប់**

# អភិធម្មបិដក

## សម្មោហវិនោទនី

[ ៩៥ ] បុគ្គល ដែលមានសញ្ញោជនៈ ក្នុងទីចំពោះមុខ លះបង់សញ្ញោជនៈដែរឬ ។ អើ ។ បុគ្គលរីករាយ លះបង់រាគៈ បុគ្គលប្រទូស្ត លះបង់ទោសៈ បុគ្គលវង្វេង លះបង់មោហៈ បុគ្គលសៅហ្មង លះបង់កិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់រាគៈដោយរាគៈ លះបង់ទោសៈដោយទោសៈ លះបង់មោហៈដោយមោហៈ លះបង់កិលេសដោយកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រាគៈប្រកបដោយចិត្តហើយ មគ្គក្រុបដោយចិត្តដែរឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រាគៈជាអកុសលហើយ ចុះមគ្គជាកុសលឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ការៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ការៈចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយនេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងប្រឹថពីនេះ ជាធម្មជាតឆ្ងាយក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះហេតុនោះ ធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរស

ទាំងឡាយ ពាក្យដូច្នេះមាន ក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ពួកធម៌ជាកុសល និងអកុសល ។បេ។ មកកាន់ការៈចំពោះមុខទេ ។

[ ៩៦ ] បុគ្គល ដែលមានសញ្ញាជនៈ ក្នុងទីចំពោះមុខ លះបង់សញ្ញាជនៈដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលនោះ កាលបើចិត្តតម្កល់នៅមាំ ។បេ។ យ៉ាងនេះ រមែងបង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលមានសញ្ញាជនៈ ក្នុងទីចំពោះមុខ លះបង់សញ្ញាជនៈទេ ។

[ ៩៧ ] បុគ្គលមិនគួរនិយាយថា បុគ្គលមានសញ្ញាជនៈ ក្នុងទីចំពោះមុខ លះបង់សញ្ញាជនៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលនោះ កាលបើដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចចាកកាមាសវៈផង ។បេ។ ចិត្តរមែងរួចចាកអវិជ្ជាសវៈផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមានសញ្ញាជនៈ ក្នុងទីចំពោះមុខ លះបង់សញ្ញាជនៈដែរ ។

## សម្មុខីភូតកថា ចប់

# អដ្ឋកថា

## សម្មុជ្ជិភាគកថា

[ ៩៥ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមានចិត្ត ដល់ព្រមដោយសំយោជនៈដូចតទៅ

ក្នុងរឿងនោះ បទថា **សម្មុជ្ជិភាគោ** បានដល់ បុគ្គលដែលចូលដល់ភាពជាអ្នកមានចិត្តដល់ព្រមចំពោះសំយោជនៈទាំងឡាយ គឺចូលដល់ការនៅរួមដោយសំយោជនៈទាំងនោះ ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងរឿងដែលត្រូវនីវរណៈគ្របសង្កត់ហើយនោះឯង ដោយប្រការដូច្នេះ ៕

**អដ្ឋកថាសម្មុជ្ជិភាគកថា ចប់**

# អភិធម្មបិដក

## សមាបន្នអស្សាទេតិកថា

[ ៩៨ ] បុគ្គលចូលឈាន រមែងរីករាយ ការត្រេកអរក្នុងឈាន មានឈានជាអារម្មណ៍ឬ ។ អើ ។ ឈាននោះ ជាអារម្មណ៍របស់ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនោះទេ ។បេ។ ឈាននោះ ជាអារម្មណ៍របស់ឈាននោះឬ ។ អើ ។ បុគ្គលពាល់ត្រូវផស្សៈនោះ ដោយផស្សៈនោះ ទទួលវេទនានោះ ដោយវេទនានោះ សម្គាល់នូវសញ្ញានោះ ដោយសញ្ញានោះ នឹកនូវចេតនានោះ ដោយចេតនានោះ គិតនូវចិត្តនោះ ដោយចិត្តនោះ ត្រិះរិះនូវវិតក្កនោះ ដោយវិតក្កនោះ ពិចារណានូវវិចារនោះ ដោយវិចារនោះ ពេញចិត្តនូវបីតិនោះ ដោយបីតិនោះ រឭកនូវសតិនោះ ដោយសតិនោះ ដឹងច្បាស់នូវបញ្ញានោះ ដោយបញ្ញានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការត្រេកអរក្នុងឈានប្រកបដោយចិត្តហើយ ចុះឈានប្រកបដោយចិត្តដែរឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការត្រេកអរក្នុងឈានជាអកុសល ចុះឈានជាកុសលឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ភាវៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ភាវៈចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាល

ភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយនេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃនិងប្រឹថពីនេះ ជាធម្មជាតឆ្ងាយក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះហេតុនោះធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ ពាក្យដូច្នេះមានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ពួកធម៌ជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ភាវៈចំពោះមុខទេ ។

[ ៩៩ ] បុគ្គលមិនគួរនិយាយថា បុគ្គលចូលឈាន រមែងរីករាយការត្រេកអរក្នុងឈាន មានឈានជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ភិក្ខុនោះរីករាយចំពោះឈាននោះប្រាថ្នានូវឈាននោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ បានចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ចតុត្ថជ្ឈាន ភិក្ខុនោះ រីករាយចំពោះឈាននោះ ប្រាថ្នានូវឈាននោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ព្រោះហេតុនោះ បុគ្គលចូលឈាន រមែងរីករាយ ការត្រេកអរក្នុងឈានមានឈានជាអារម្មណ៍ពិត ។

**សមាបន្នអស្សាទេតិកថា ចប់**

# អដ្ឋកថា

## សមាបន្នអស្សាទេតិកថា

[ ៩៨ ] ឥឡូវនេះ នឹងពណ៌នារឿងបុគ្គលចូលសមាបត្តិ រមែងត្រេកអរដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា បុគ្គលចូលឈាន រមែងត្រេកអរ ហើយការត្រេកអរក្នុងឈាននោះ របស់បុគ្គលនោះ មានឈានជាអារម្មណ៍ ព្រោះអាស្រ័យព្រះបាលីថា ភិក្ខុក្នុងសាសនានេះ ... ក៏ចូលបឋមជ្ឈាន ភិក្ខុនោះ រីករាយក្នុងឈាននោះ ដូច្នេះ ពាក្យសួររបស់សកវាទីថា **សមាបន្នោ** ជាដើម ដោយសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាទាំងឡាយថា **តំ ឈានំ តស្ស ឈានស្ស អារម្មណំ** បរវាទីកាលមិនឃើញនូវភាពដែលឈាននោះ ជាអារម្មណ៍របស់ឈាននោះ ទើបឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ រមែងឆ្លើយទទួល ដោយពាក្យក្នុងព្រះសូត្រថា ក៏ចូលបឋមជ្ឈាន ភិក្ខុនោះ រីករាយក្នុងឈាននោះ ដូច្នេះ ។

[ ៩៩ ] ព្រះសូត្រថា **សោ តទស្សាទេតិ** រមែងញ៉ាំងសេចក្តីត្រេកអរក្នុងឈានឲ្យសម្រេចដល់បុគ្គលដែលបានឈាន ដែលចេញចាកឈានហើយ មិនមែនញ៉ាំងសេចក្តីត្រេកអរ សេចក្តីរីករាយក្នុងឈាន ដែលមានឈានជាអារម្មណ៍ ឲ្យសម្រេចក្នុងខាងក្នុងសមាបត្តិនោះៗ ឯង ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអះអាង ដូច្នេះ ។៚

# អភិធម្មបិដក

## អសាតរាគកថា

[ ១០០ ] ការត្រេកអរ ក្នុងរបស់ដែលមិនជាទីត្រេកអរ មានដែរឬ ។ អើ ។ ពួកសត្វត្រេកអរក្នុងសេចក្ដីទុក្ខ ពួកសត្វខ្លះ ប្រាថ្នា ស្រឡាញ់ ស្វែង ស្វះស្វែង ស្វែងរកនូវសេចក្ដីទុក្ខ ស្ថិតនៅ ចុះចិត្តស៊ប់ ចំពោះសេចក្ដីទុក្ខ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងពួកសត្វត្រេកអរក្នុងសេចក្ដីសុខ សត្វពួកខ្លះ ប្រាថ្នា ស្រឡាញ់ ស្វែង ស្វះស្វែង ស្វែងរកនូវសេចក្ដីសុខ ស្ថិតនៅ ចុះចិត្តស៊ប់ ចំពោះសេចក្ដីសុខ មានដែរឬ ។ អើ ។ ប្រសិនបើ ពួកសត្វត្រេកអរក្នុងសេចក្ដីសុខ សត្វពួកខ្លះ ប្រាថ្នា ស្រឡាញ់ ស្វែង ស្វះស្វែង ស្វែងរកនូវសេចក្ដីសុខ ស្ថិតនៅ ចុះចិត្តស៊ប់ ចំពោះសេចក្ដីសុខ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការត្រេកអរក្នុងរបស់ដែលមិនជាទីត្រេកអរ មានទេ ។

[ ១០១ ] ការត្រេកអរ ក្នុងរបស់ដែលមិនជាទីត្រេកអរ មានដែរឬ ។ អើ ។ រាគានុស័យ ដេកសម្ងំក្នុងទុក្ខវេទនា បដិឃានុស័យ ដេកសម្ងំក្នុងសុខវេទនាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរាគានុស័យ ដេកសម្ងំក្នុងសុខវេទនា បដិឃានុស័យ ដេកសម្ងំក្នុងទុក្ខវេទនាឬ ។ អើ ។ ប្រសិនបើ រាគានុស័យ ដេកសម្ងំក្នុងសុខវេទនា បដិឃានុស័យ ដេកសម្ងំក្នុងទុក្ខវេទនា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការត្រេកអរក្នុងរបស់ដែលមិនជាទីត្រេកអរ មានទេ ។

[ ១០២ ] បុគ្គលមិនគួរនិយាយថា ការត្រេកអរ ក្នុងរបស់ដែលមិនជាទីត្រេកអរ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលនោះ បានដល់នូវសេចក្តីត្រេកអរ និងសេចក្តីទឹងយ៉ាងនេះហើយ រមែងទទួលនូវវេទនាណាមួយ ជាសុខក្តី ជាទុក្ខក្តី ជាអទុក្ខមសុខក្តី បុគ្គលនោះ រមែងត្រេកអរ រាប់រក ស្ថិតនៅ ចុះចិត្តស៊ប់ ចំពោះវេទនានោះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការត្រេកអរក្នុងរបស់ដែលមិនជាទីត្រេកអរមាន ។

អសាតរាគកថា ចប់

# អដ្ឋកថា

## អសាតរាគកថា

[ ១០០ ] ឥឡូវនេះ នឹងពណ៌នារឿងការត្រេកអរក្នុងវត្ថុដែលមិនគាប់ចិត្តដូចតទៅ

ក្នុងរឿងនោះ ព្រះសូត្រ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា កុមារនោះ ... រមែងទទួលនូវវេទនាណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ។ កុមារនោះ តែងត្រេកអរ និយាយសរសើរ ប្រកាន់វេទនានោះ ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃការត្រេកអរ ក្នុងវត្ថុដែលបុគ្គលជួបមកហើយ ។

ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា ការត្រេកអររីករាយក្នុងទុក្ខវេទនា ដោយអំណាចនៃការគាប់ចិត្តក្នុងរាគៈក៏មានបាន ព្រោះហេតុនោះ ការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្តក៏ត្រូវមាន ដូច្នេះ ព្រោះអាស្រ័យពាក្យក្នុងព្រះសូត្រថា **អភិនន្ទតិ** ។ ពាក្យសួររបស់សកវាទីថា **អត្ថិ អសាតរាគោ** សំដៅដល់ជនទាំងនោះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **អសាតរាគោ** សេចក្តីថា ការពេញចិត្តថា ឱហ្ន៎ វត្ថុនោះឯង គប្បីមានដល់អញ ក្នុងការសោយទុក្ខដែលមិនគាប់ចិត្ត ។ ពាក្យឆ្លើយទទួលដោយអំណាចលទ្ធិរបស់ខ្លួនថា **អាមន្តា** ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ១០២ ] ម្យ៉ាងទៀត ក្នុងព្រះសូត្រថា **សោ តំ វេទនំ អភិនន្ទតិ**

អធិប្បាយថា ឈ្មោះថា ការកើតឡើងនៃរាគៈ ព្រោះវិលត្រឡប់មកប្រារព្ធនូវទុក្ខវេទនានោះឯង រមែងមិនមាន តែបុគ្គល កាលពិចារណាឃើញនូវធម៌ដែលមានការសោយអារម្មណ៍ជាលក្ខណៈដោយការកាន់យក ឬនូវទុក្ខវេទនានោះឯង ដោយភាពជាអត្តា រមែងត្រេកអរក្នុងវេទនានោះ ដោយការត្រេកអរចំពោះវត្ថុដែលខ្លួនជួបហើយ ពោល គឺទិដ្ឋិ និងមានះ មិនមែនត្រេកអរក្នុងការផ្លាស់ប្តូរនៃទុក្ខវេទនា សូម្បីជាបុគ្គលដែលត្រូវទុក្ខវេទនាគ្របសង្កត់ហើយ ប្រាថ្នានូវកាមសុខ ដែលជាចំណែកផ្ទុយនឹងទុក្ខវេទនានោះ ក៏ឈ្មោះថា រមែងត្រេកអរចំពោះទុក្ខវេទនា ។ ការត្រេកអរក្នុងទុក្ខវេទនា រមែងមានដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអះអាងដល់ការត្រេកអរ ក្នុងវត្ថុដែលមិនគាប់ចិត្ត ដោយប្រការដូច្នេះ ។

## អដ្ឋកថាអស្សាតរាគកថា ចប់

# អភិធម្មបិដក

## ធម្មតណ្ហាអព្យាកតាតិកថា

[ ១០៣ ] ធម្មតណ្ហា ជាអព្យាក្រឹតឬ ។ អើ ។ វិបាក និងអព្យាក្រឹតកិរិយា និងអព្យាក្រឹត រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាអព្យាក្រឹត ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៤ ] ធម្មតណ្ហា ជាអព្យាក្រឹតឬ ។ អើ ។ រូបតណ្ហា ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មតណ្ហា ជាអព្យាក្រឹតឬ ។ អើ ។ សទ្ទតណ្ហា ។បេ។ គន្ធតណ្ហា រសតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៥ ] រូបតណ្ហា ជាអកុសលឬ ។ អើ ។ ធម្មតណ្ហា ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ជាអកុសលឬ ។ អើ ។ ធម្មតណ្ហា ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៦ ] ធម្មតណ្ហា ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា តណ្ហាជាអកុសលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា តណ្ហា ជាអកុសល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មតណ្ហា ជាអព្យាក្រឹតទេ ។

[ ១០៧ ] ធម្មតណ្ហា ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា លោភៈជាអកុសល ធម្មតណ្ហាជាលោភៈឬ ។ អើ ។ ប្រសិនបើ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា លោកៈជាអកុសល ធម្មតណ្ហាជាលោកៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មតណ្ហា ជាអព្យាក្រឹតទេ ។

[ ១០៨ ] ធម្មតណ្ហា ហៅថា លោកៈ ជាអព្យាក្រឹតឬ ។ អើ ។ រូបតណ្ហា ហៅថា លោកៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មតណ្ហា ហៅថា លោកៈ ជាអព្យាក្រឹតដែរឬ ។ អើ ។ សទ្ទតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ហៅថា លោកៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៩ ] រូបតណ្ហា ហៅថា លោកៈ ជាអកុសលឬ ។ អើ ។ ធម្មតណ្ហា ហៅថា លោកៈ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ហៅថា លោកៈ ជាអកុសលឬ ។ អើ ។ ធម្មតណ្ហា ហៅថា លោកៈ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១០ ] ធម្មតណ្ហា ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា តណ្ហាណា ជាធម្មជាតតាក់តែងភពថ្មី ប្រកបដោយតម្រេក

ខ្លាំង ត្រេកត្រអាលក្នុងអារម្មណ៍នោះៗ តណ្ហានោះ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម្មតណ្ហា ជាអព្យាក្រឹតទេ ។

[ ១១១ ] បុគ្គលមិនគួរនិយាយថា ធម្មតណ្ហា ជាអព្យាក្រឹតទេឬ ។ អើ ។ ក្រែងធម្មតណ្ហានោះហើយឬ ។ អើ ។ ប្រសិនបើ ធម្មតណ្ហានោះហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា តណ្ហា ជាអព្យាក្រឹតដែរ ។

ធម្មតណ្ហាអព្យាកតាតិកថា ចប់

# អដ្ឋកថា

## ធម្មតណ្ហាអព្យាកតាតិកថា

[ ១០៣ ] ឥឡូវនេះ នឹងពណ៌នាអំពីធម្មតណ្ហាជាអព្យាក្រឹតដូចតទៅ ក្នុងបញ្ហាទាំងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា បណ្តាតណ្ហាទាំង ៦ គឺរូបតណ្ហា ។បេ។ ធម្មតណ្ហា ព្រោះតណ្ហាចុងក្រោយនៃតណ្ហាទាំងអស់នេះ ព្រះមានព្រះភាគត្រាស់ថា **ធម្មតណ្ហា** ព្រោះហេតុនោះ តណ្ហានោះ គប្បីជាអព្យាក្រឹត ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ អត្ថនៃបញ្ហាដ៏សេសទាំងឡាយ គប្បីជ្រាបតាមព្រះបាលី ។

[ ១១០ ] តណ្ហាទាំង ៦ ព្រះមានព្រះភាគទ្រង់សម្តែងសង្ខេបជា ៣ ប្រភេទ មានកាមតណ្ហាជាដើម ។ តណ្ហាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ មានរូបជាដើម ដោយអំណាចនៃការត្រេកអរក្នុងកាម ឈ្មោះថា កាមតណ្ហា ។ តណ្ហាដែលកើតព្រមជាមួយសស្សតទិដ្ឋិ ក្នុងការឃើញថា អត្តា និងលោក មាន ដូច្នេះ ឈ្មោះថា ភវតណ្ហា ។ តណ្ហាដែលកើតព្រមជាមួយ

នឹងឧច្ឆេទទិដ្ឋិ ក្នុងការឃើញថា អត្តា និងលោក មិនមាន ដូច្នេះ ឈ្មោះថា វិភវតណ្ហា ។

[ ១១១ ] បទថា **ធម្ម សា ធម្មតណ្ហា** រមែងសម្ដែងដល់ការប្រព្រឹត្តទៅរបស់តណ្ហា ដោយប្រារព្ធធម្មារម្មណ៍ មិនមែនសម្ដែងដល់ភាពដែលធម្មតណ្ហានោះ ជាអព្យាក្រឹត ព្រោះហេតុនោះ ទើបពាក្យនេះ មិនមែនជាគោលអះអាង ដូច្នេះ ។៚

**អដ្ឋកថាធម្មតណ្ហាអព្យាកតាតិកថា ចប់**

# អភិធម្មបិដក

## ធម្មតណ្ហានិទ្ទុក្ខសមុទយោតិកថា

[ ១១២ ] ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អើ ។ រូបតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេ ។ អើ ។ សទ្ទតណ្ហា ។បេ។ គន្ធតណ្ហា រសតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៣ ] រូបតណ្ហា ជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ ធម្មតណ្ហា ជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទតណ្ហា ។បេ។ គន្ធតណ្ហា ។បេ។ រសតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ ធម្មតណ្ហា ជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា តណ្ហា ជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា តណ្ហា ជាហេតុនាំឲ្យកើតទុក្ខដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេ ។

[ ១១៤ ] ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា លោភៈ ជាហេតុនាំឲ្យកើតទុក្ខ ធម្មតណ្ហា ក៏ជាលោភៈដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា លោភៈ

ជាហេតុនាំឲ្យកើតទុក្ខ ធម្មតណ្ហា ក៏ជាលោកៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេ ។

[ ១១៥ ] ធម្មតណ្ហា ជាលោកៈ មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អើ ។ រូបតណ្ហា ជាលោកៈ មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មតណ្ហា ជាលោកៈ មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អើ ។ សទ្ទតណ្ហា ។បេ។ គន្ធតណ្ហា ។បេ។ រសតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ជាលោកៈ មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៦ ] រូបតណ្ហា ជាលោកៈ ជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ ធម្មតណ្ហា ជាលោកៈ ជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ទតណ្ហា ។បេ។ ផោដ្ឋព្វតណ្ហា ជាលោកៈ ជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ ធម្មតណ្ហា ជាលោកៈ ជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៧ ] ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យកើតទុក្ខទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា តណ្ហាណា ជាធម្មជាតតាក់តែងភពថ្មី ប្រកបដោយតម្រេកខ្លាំង ត្រេកត្រអាលក្នុងអារម្មណ៍នោះៗ គឺកាមតណ្ហា ភវ-តណ្ហា វិភវតណ្ហា ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម្មតណ្ហា ជាហេតុនាំឲ្យកើតទុក្ខទេ ។

[ ១១៨ ] បុគ្គល មិនគួរនិយាយថា ធម្មតណ្ហា មិនមែនជាហេតុនាំឲ្យ

កើតទុក្ខទេឬ ។ អើ ។ ក្រែងធម្មតណ្ហានោះហើយឬ ។ អើ ។ ប្រសិនបើធម្មតណ្ហានោះហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មតណ្ហាមិនមែនជាហេតុនាំឲ្យកើតទុក្ខទេ ។

ធម្មតណ្ហានទុក្ខសមុទយោតិកថា ចប់

តេរសមវគ្គ ចប់

## ឧទ្ទាននៃតេរសមវគ្គនោះ គឺ

និយាយអំពីបុគ្គលតាំងនៅក្នុងកប្ប គប្បីស្ថិតនៅអស់កប្ប ១ បុគ្គលតាំងនៅក្នុងកប្ប មិនគប្បីបានចំពោះនូវកុសលចិត្ត ១ បុគ្គលប្រកបក្នុងកម្ម ដែលនាំឲ្យផលជាលំដាប់ គប្បីឈានចុះកាន់សម្មត្តនិយាម ១ និយតបុគ្គលឈានចុះកាន់និយាម ១ នីវុតបុគ្គលលះបង់នីវរណៈ ១ បុគ្គលមានសញ្ញោជនៈក្នុងទីចំពោះមុខ លះបង់សញ្ញោជនៈ ១ ការត្រេកអរក្នុងឈាន ១ ការត្រេកអរក្នុងរបស់ដែលមិនជាទីត្រេកអរ ១ ធម្មតណ្ហាជាអព្យាក្រឹត ១ ធម្មតណ្ហាមិនមែនជាហេតុនាំឲ្យកើតទុក្ខ ១ ។

# អដ្ឋកថា

## ធម្មតណ្ហានទុក្ខសមុទយោតិកថា

[ ១១២ ] ឥឡូវនេះ នឹងពណ៌នាអំពីធម្មតណ្ហា មិនមែនជាហេតុឲ្យកើតទុក្ខដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វ-សេលិយៈទាំងឡាយថា ព្រោះតណ្ហានោះ ព្រះមានព្រះភាគត្រាស់ហៅថាធម្មតណ្ហា ព្រោះហេតុនោះ ទើបមិនមែនជាទុក្ខសមុទយៈ ដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យក្នុងរឿងមុននោះឯង ៕

**អដ្ឋកថាធម្មតណ្ហានទុក្ខសមុទយោតិកថា ចប់**

**វគ្គទី ១៣ ចប់**

# អភិធម្មបិដក

## កុសលាកុសលប្បដិសន្ធហានកថា

[ ១១៩ ] កុសលមូល ទន្ទ្រានអកុសលមូលដែរឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងអកុសលឲ្យកើតឡើង ការំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងកុសលឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កុសលមូលទន្ទ្រានអកុសលមូលហើយ តែបុគ្គលមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងអកុសលឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងកុសលឲ្យកើតឡើងទេឬ ។ អើ ។ កុសលរបស់បុគ្គល កាលមិនរំពឹង រមែងកើតឡើង ។បេ។ របស់បុគ្គល កាលមិនតាំងចិត្តទុក រមែងកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កុសលរបស់បុគ្គល កាលរំពឹង រមែងកើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក រមែងកើតឡើងឬ ។ អើ ។ ប្រសិនបើកុសលរបស់បុគ្គល កាលរំពឹង រមែងកើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក រមែងកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កុសលមូល ទន្ទ្រានអកុសលមូលទេ ។

[ ១២០ ] កុសលមូល ទន្ទ្រានអកុសលមូលដែរឬ ។ អើ ។ អកុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត ដោយមិនមែនជាឧបាយនៃប្រាជ្ញា រមែងកើតឡើងឬ ។ អើ ។ កុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត ដោយមិនមែនជាឧបាយនៃប្រាជ្ញា រមែងកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ក្រែងកុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញាកើត ឡើងឬ ។ អើ ។ ប្រសិនបើ កុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត ដោយ ឧបាយនៃប្រាជ្ញាកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កុសលមូល ទន្ទ្រានអកុសលមូលទេ ។

[ ១២១ ] កុសលមូល ទន្ទ្រានអកុសលមូលដែរឬ ។ អើ ។ នេក្ខម្ម-សញ្ញា កើតជាលំដាប់នៃកាមសញ្ញា អព្យាបាទសញ្ញា កើតជាលំដាប់នៃ ព្យាបាទសញ្ញា អវិហឹសាសញ្ញា កើតជាលំដាប់នៃវិហិំសាសញ្ញា មេត្តា កើត ជាលំដាប់នៃព្យាបាទ ករុណា កើតជាលំដាប់នៃវិហឹសា មុទិតា កើតជាលំដាប់ នៃអរតិ ( ការមិនត្រេកអរ ) ឧបេក្ខា កើតជាលំដាប់នៃបដិឃៈឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២២ ] អកុសលមូល ទន្ទ្រានកុសលមូលដែរឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងកុសលឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងអកុសលឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ អកុសលមូល ទន្ទ្រានកុសលមូលហើយ តែបុគ្គល មិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងកុសល ឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងអកុសល ឲ្យកើតឡើងទេឬ ។ អើ ។ អកុសលរបស់បុគ្គល កាលមិនរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលមិនតាំងចិត្តទុក កើតឡើងទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ ក្រែងអកុសលរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។

របស់បុគ្គល កាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ អកុសល របស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អកុសលមូល ទន្ទ្រាន កុសលមូលទេ ។

[ ១២៣ ] អកុសលមូល ទន្ទ្រានកុសលមូលដែរឬ ។ អើ ។ កុសល របស់បុគ្គល កាលធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា កើតឡើងឬ ។ អើ ។ អកុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញាកើតឡើង ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអកុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត ដោយឧបាយមិនមែនជាប្រាជ្ញាកើតឡើងឬ ។ អើ ។ ប្រសិនបើ អកុសលរបស់បុគ្គល កាលធ្វើទុកក្នុងចិត្តដោយឧបាយមិនមែនជា ប្រាជ្ញា កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អកុសលមូល ទន្ទ្រានកុសលមូលទេ ។

[ ១២៤ ] អកុសលមូល ទន្ទ្រានកុសលមូលដែរឬ ។ អើ ។ កាមសញ្ញា កើតឡើង ជាលំដាប់នៃនេក្ខម្មសញ្ញា ព្យាបាទសញ្ញា កើតឡើង ជាលំដាប់ នៃអព្យាបាទសញ្ញា វិហឹសាសញ្ញា កើតឡើង ជាលំដាប់នៃអវិហឹសាសញ្ញា ព្យាបាទ កើតឡើង ជាលំដាប់នៃមេត្តា វិហឹសា កើតឡើង ជាលំដាប់នៃ

ករុណា អរតិ កើតឡើង ជាលំដាប់នៃមុទិតា បដិឃៈ កើតឡើង ជាលំដាប់នៃឧបេក្ខាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៥ ] បុគ្គល មិនគួរនិយាយថា កុសលមូល ទន្ទ្រានអកុសលមូល អកុសលមូល ទន្ទ្រានកុសលមូលទេឬ ។ អើ ។ ក្រែងបុគ្គលត្រេកអរក្នុងវត្ថុណា រមែងនឿយណាយក្នុងវត្ថុនោះវិញ នឿយណាយក្នុងវត្ថុណា រមែងត្រេកអរក្នុងវត្ថុនោះវិញឬ ។ អើ ។ ប្រសិនបើ បុគ្គលត្រេកអរក្នុងវត្ថុណា រមែងនឿយណាយក្នុងវត្ថុនោះវិញ នឿយណាយក្នុងវត្ថុណា រមែងត្រេកអរក្នុងវត្ថុនោះវិញមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កុសលមូលទន្ទ្រានអកុសលមូលបាន អកុសលមូលទន្ទ្រានកុសលមូលបាន ។

កុសលាកុសលប្បដិសន្ទហនកថា ចប់

# អដ្ឋកថា

## កុសលាកុសលប្បដិសន្ធហានកថា

[ ១១៩ ] ឥឡូវនេះ នឹងពណ៌នាអំពីការបន្តនៃកុសល និងអកុសល ដូចតទៅ

ក្នុងរឿងនោះ កុសល ឈ្មោះថា កើតឡើង ក្នុងលំដាប់នៃអកុសល ឬ អកុសល ឈ្មោះថា កើតឡើង ក្នុងលំដាប់នៃកុសល មិនមាន ព្រោះហេតុនោះ ទើបការបន្តនូវគ្នានិងគ្នារបស់កុសល និងអកុសលទាំងនោះ មិនត្រឹមត្រូវ ។ ជនទាំងឡាយណា កាន់យកលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ព្រោះបុគ្គលត្រេកត្រអាល និងប្រាសចាកតម្រេក ក្នុងវត្ថុតែមួយនោះឯង ហេតុនោះ ទើបធម៌នោះ ឈ្មោះថា បន្តនូវគ្នានិងគ្នា ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យទាំងពីរ គឺ **អាវដ្ដនា បណិធិ** ជាឈ្មោះរបស់អាវជ្ជនចិត្តនោះឯង ។ ពិតហើយ ឈ្មោះថា **អាវដ្ដន** ព្រោះអត្ថថា ញុំាំងភវង្គចិត្តនោះឲ្យវិល ( ដាច់ ) ទៅ ។ ឈ្មោះថា **បណិធិ** ព្រោះអត្ថថា តម្កល់ គឺការតាំងចិត្តក្នុងអារម្មណ៍ ដទៃចាកអារម្មណ៍របស់ភវង្គ ។ បទថា **កុសលំ អនាវដ្ដេន្តស្ស** សេចក្ដីថា សកវាទីសួរថា កុសលនោះ ដែលកើតបន្តក្នុងលំដាប់នៃអកុសល កុសលនោះ រមែងកើតដល់បុគ្គលមិននឹកដល់ឬ ឯបរវាទីកាលមិនឃើញការកើតឡើងរបស់កុសល ដោយវៀរចាកការនឹកភាវក ទើបឆ្លើយបដិសេធ ។

[ ១២០ ] បទថា **កុសលំ អយោនិសោ មនសិករោតោ** នេះ សកវាទីពោលដើម្បីចោទសួរថា បើកុសលគប្បីកើតក្នុងលំដាប់នៃអកុសល សោត កុសលនោះ ក៏គប្បីកើតដល់បុគ្គលដែលមនសិការដោយឧបាយមិនត្រូវទំនង ដោយការបង្អោនទឹកដល់អកុសលនោះឯង ។ បទដ៏សេស គប្បីជ្រាបតាមព្រះបាលីនោះឯង ។ បទថា **ននុ យស្មឹយេវ វត្ថុស្មឹ** ជាដើម សំដែងនូវការកើតឡើងនៃចិត្ត មានរាគៈ និងចិត្តដែលប្រាសចាករាគៈ ក្នុងអារម្មណ៍តែមួយ មិនមែនសំដែងនូវភាពដែលកុសល និងអកុសល មានក្នុងលំដាប់នូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបពាក្យនេះ មិនមែនជាគោលអាង ដោយប្រការដូច្នេះ ៕៚

## អដ្ឋកថាកុសលាកុសលប្បដិសន្ធហានកថា ចប់

# អភិធម្មបិដក

## សឡាយតនុប្បត្តិកថា

[ ១២៦ ] សឡាយតនៈ ( អាយតនៈ ៦ ) តាំងនៅក្នុងផ្ទៃមាតា មិនមុនមិនក្រោយឬ ។ អើ ។ សត្វមានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកទាប ចុះកាន់ផ្ទៃមាតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៧ ] ចក្ខ្វាយតនៈ តាំងនៅដោយបដិសន្ធិចិត្ត ដែលកំពុងស្វែងរកកំណើតឬ ។ អើ ។ ដៃទាំងឡាយតាំងនៅ ជើងទាំងឡាយតាំងនៅ ក្បាលតាំងនៅ ត្រចៀកតាំងនៅ ច្រមុះតាំងនៅ មាត់តាំងនៅ ធ្មេញទាំងឡាយតាំងនៅដោយបដិសន្ធិចិត្ត ដែលកំពុងស្វែងរកកំណើតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាយតនៈ ។បេ។ ឃានាយតនៈ ។បេ។ ជិវ្ហាយតនៈ តាំងនៅដោយបដិសន្ធិចិត្តដែលកំពុងស្វែងរកកំណើតដែរឬ ។ អើ ។ ដៃទាំងឡាយតាំងនៅ ជើងទាំងឡាយតាំងនៅ ក្បាលតាំងនៅ ត្រចៀកតាំងនៅ ច្រមុះតាំងនៅ មាត់តាំងនៅ ធ្មេញទាំងឡាយ តាំងនៅដោយបដិសន្ធិចិត្ត ដែលកំពុងស្វែងរកកំណើតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៨ ] ចក្ខ្វាយតនៈ កើតឡើងជាខាងក្រោយនៃសត្វនៅក្នុងផ្ទៃមាតាឬ ។ អើ ។ សត្វធ្វើកម្មដើម្បីបានចំពោះនូវចក្ខុ ក្នុងផ្ទៃមាតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាយតនៈ ។បេ។ ឃានាយតនៈ ។បេ។ ជិវ្ហាយតនៈ កើតឡើងជាខាងក្រោយនៃសត្វដែលនៅក្នុងផ្ទៃមាតាឬ ។ អើ ។ សត្វធ្វើកម្មដើម្បីបានចំពោះនូវអណ្តាតក្នុងផ្ទៃមាតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះ

ទេ ។បេ។ សក់ រោម ក្រចក ធ្មេញ ឆ្អឹង កើតឡើងជាខាងក្រោយនៃសត្វដែលនៅក្នុងផ្ទៃមាតាឬ ។ អើ ។ សត្វធ្វើកម្មដើម្បីបានចំពោះនូវឆ្អឹងក្នុងផ្ទៃមាតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៩ ] បុគ្គល មិនគួរនិយាយថា សក់ រោម ក្រចក ធ្មេញ ឆ្អឹង កកើតឡើងជាខាងក្រោយនៃសត្វដែលនៅក្នុងផ្ទៃមាតាឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

( សត្វដែលចូលទៅចាប់បដិសន្ធិក្នុងផ្ទៃមាតា ) ដំបូង កើតជាកលលរូប ក្លាយអំពីកលលរូប កើតជាអម្ពុទៈ ក្លាយអំពីអម្ពុទៈ កើតជាបេសិ ( ដុំសាច់ ) ក្លាយអំពីបេសិ កើតជាឃនៈ ( ដុំរឹង ) ក្លាយអំពីឃនៈ ក៏បែកកើតជាបញ្ចសាខាទាំងសក់ រោម ក្រចក ក៏កើតមានព្រម មាតារបស់សត្វនោះបរិភោគភោជន គឺបាយ និងទឹកណា សត្វដែលនៅក្នុងផ្ទៃមាតានោះ តែងញុំាំងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងផ្ទៃនៃមាតានោះ ដោយភោជន មានបាយ និងទឹកជាដើមនោះឯង ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សក់ រោម ក្រចក ធ្មេញ ឆ្អឹង កើតឡើងជាខាងក្រោយនៃសត្វដែលតាំងនៅក្នុងផ្ទៃមាតា ។

**សឡាយតនុប្បត្តិកថា ចប់**

# អដ្ឋកថា

## សឡាយតនុប្បត្តិកថា

[ ១២៦ ] ឥឡូវនេះ នឹងពណ៌នាការកើតឡើងនៃសឡាយតនៈដូចតទៅ ក្នុងរឿងនោះ លទ្ធិរបស់បរវាទីថា អាយតនៈ ៦ ខាងក្នុងរបស់ឱបបត្តិក-កំណើតទាំងឡាយ កើតឡើងព្រមជាមួយបដិសន្ធិចិត្ត ដូចដែលស្វែងរកការកើតនោះឯង ។ សម្រាប់គព្ភសេយ្យកៈ ក្នុងអាយតនៈ ៦ ខាងក្នុង ទាំងមនាយតនៈ និងកាយាយតនៈប៉ុណ្ណោះ កើតឡើងក្នុងបដិសន្ធិក្ខណៈ ចំណែកអាយតនៈ ៤ ដ៏សេស កើតឡើងក្នុងរាត្រី ៧ និង ៧ ( រាល់ៗ សប្តាហ៍ ) ។ អាយតនៈទាំងនោះ កើតឡើង ព្រោះកម្មដែលឲ្យបដិសន្ធិនោះឯង ឬកម្មដទៃដែលជាកម្មដែលខ្លួនធ្វើហើយ ដូច្នេះ ។

ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយអបរសេលិយៈទាំងឡាយថា អាយតនៈ ៦ ខាងក្នុង ដែលជាពូជកើតក្នុងខណៈនៃបដិសន្ធិ ក្នុងផ្ទៃរបស់មាតានោះឯង ព្រោះការកើតអំពីកម្មតែមួយ ដូចពន្លកនៃដើមឈើដែលមានមែកជាដើម ដែលមានមែក ប្រគាបដែលបរិបូណ៌ហើយជាដើម ដូច្នេះ ពាក្យសួររបស់សកវាទីថា **សឡាយតនំ**

ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **សព្វេគ្គុប្បច្ចត្តិ** ជាដើម សកវាទីពោលដើម្បីចោទសួរថា កាលសឡាយតនៈមាន សត្វដែលកើតក្នុងផ្ទៃ គប្បីបែបនេះហើយ ទើបឈានចុះកាន់ផ្ទៃមាតាឬ ។

[ ១២៨ ] ពាក្យសួរថា **មាតុកុច្ឆិគតស្ស** ជាពាក្យរបស់បរវាទី ។

[ ១២៩ ] ពាក្យសួរតទៅខាងមុខថា **មាតុកុច្ឆិគតស្ស បច្ឆាកេសា** ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថាសឡាយតនុប្បត្តិកថា ចប់**

# អភិធម្មបិដក

## អនន្តរប្បច្ចយកថា

[ ១៣០ ] សោតវិញ្ញាណ កើតជាលំដាប់នៃចក្ខុវិញ្ញាណឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងចក្ខុវិញ្ញាណឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងសោតវិញ្ញាណឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតវិញ្ញាណ កើតឡើងជាលំដាប់នៃចក្ខុវិញ្ញាណឬ ។ អ្នកមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងចក្ខុវិញ្ញាណឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងសោតវិញ្ញាណ ឲ្យកើតឡើងដែរឬ ។ អើ ។ សោតវិញ្ញាណរបស់បុគ្គល កាលមិនរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលមិនបានតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសោតវិញ្ញាណរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ សោតវិញ្ញាណរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សោតវិញ្ញាណ កើតជាលំដាប់នៃចក្ខុវិញ្ញាណទេ ។

[ ១៣១ ] សោតវិញ្ញាណ កើតជាលំដាប់នៃចក្ខុវិញ្ញាណឬ ។ អើ ។ ចក្ខុវិញ្ញាណរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវរូបនិមិត្ត ( និមិត្តរបស់រូប ) កើតឡើងឬ ។ អើ ។ សោតវិញ្ញាណរបស់បុគ្គល កាលធ្វើទុកក្នុងចិត្តនូវរូប-

និមិត្ត កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣២ ] ចក្ខុវិញ្ញាណ មានរូបជាអារម្មណ៍តែម្យ៉ាង មិនមានវត្ថុដទៃជាអារម្មណ៍ទេឬ ។ អើ ។ សោតវិញ្ញាណ មានរូបជាអារម្មណ៍តែម្យ៉ាង មិនមានវត្ថុដទៃជាអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុ និងរូបឬ ។ អើ ។ សោតវិញ្ញាណ កើតឡើងព្រោះអាស្រ័យចក្ខុ និងរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុ និងរូបឬ ។ អើ ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុ និងរូប ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យចក្ខុ និងរូប ពាក្យដូច្នេះមានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យចក្ខុ និងរូប ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សោតវិញ្ញាណ កើតឡើង ព្រោះអាស្រ័យចក្ខុ និងរូបទេ ។ សោតវិញ្ញាណ កើតឡើងជាលំដាប់នៃចក្ខុវិញ្ញាណឬ ។ អើ ។ ចក្ខុវិញ្ញាណនោះឯង គឺសោតវិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៣ ] ឃានវិញ្ញាណ កើតឡើងជាលំដាប់នៃសោតវិញ្ញាណ ។បេ។ ជិវ្ហាវិញ្ញាណ កើតឡើងជាលំដាប់នៃឃានវិញ្ញាណឬ ។បេ។

[ ១៣៤ ] កាយវិញ្ញាណ កើតឡើងជាលំដាប់នៃជិវ្ហាវិញ្ញាណឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងជិវ្ហាវិញ្ញាណ ឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងកាយវិញ្ញាណ ឲ្យកើត

ឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយវិញ្ញាណ កើតឡើងជាលំដាប់នៃជិវ្ហាវិញ្ញាណ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងជិវ្ហាវិញ្ញាណឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងកាយវិញ្ញាណឲ្យកើតឡើងដែរឬ ។ អើ ។ កាយវិញ្ញាណរបស់បុគ្គល កាលមិនរំពឹងកើតឡើង ។បេ។ របស់បុគ្គល កាលមិនបានតាំងចិត្តទុក កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងកាយវិញ្ញាណរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើងដែរឬ ។ អើ ។ ប្រសិនបើ កាយវិញ្ញាណរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុកកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយវិញ្ញាណ កើតឡើងជាលំដាប់នៃជិវ្ហាវិញ្ញាណទេ ។

[ ១៣៥ ] កាយវិញ្ញាណ កើតឡើងជាលំដាប់នៃជិវ្ហាវិញ្ញាណឬ ។អើ ។ ជិវ្ហាវិញ្ញាណរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវរសនិមិត្ត កើតឡើងឬ ។ អើ ។ កាយវិញ្ញាណរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវរសនិមិត្តកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជិវ្ហាវិញ្ញាណ មានរសជាអារម្មណ៍តែម្យ៉ាង មិនមានវត្ថុដទៃជាអារម្មណ៍ទេឬ ។ អើ ។ កាយវិញ្ញាណ មានរសជាអារម្មណ៍តែម្យ៉ាង មិនមានវត្ថុដទៃជាអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជិវ្ហាវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្តាត និងរសឬ ។ អើ ។ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និង

រសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្តាត និងរសឬ ។ អើ ។ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ជិវ្ហាវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្តាត និងរសទេ ។ កាយវិញ្ញាណ កើតឡើងជាលំដាប់នៃជិវ្ហាវិញ្ញាណឬ ។ អើ ។ ជិវ្ហា-វិញ្ញាណនោះឯង គឺកាយវិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៦ ] បុគ្គលមិនគួរនិយាយថា វិញ្ញាណ ៥ កើតឡើង ជាលំដាប់តគ្នានិងគ្នាទេឬ ។ អើ ។ ក្រែងបុគ្គលណានីមួយ រាំ ច្រៀង ប្រគំ មើលរូបខ្លះ ស្តាប់សំឡេងខ្លះ ហិតក្លិនខ្លះ ស្រូបរសខ្លះ ពាល់ត្រូវផោដ្ឋព្វៈខ្លះ មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលណានីមួយ រាំ ច្រៀង ប្រគំ មើលរូបខ្លះ ស្តាប់សំឡេងខ្លះ ហិតក្លិនខ្លះ ស្រូបរសខ្លះ ពាល់ត្រូវផោដ្ឋព្វៈខ្លះ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិញ្ញាណ ៥ កើតឡើង ជាលំដាប់តគ្នានិងគ្នាដែរ ។

**អនន្តរបច្ចយកថា ចប់**

# អដ្ឋកថា

## អនន្តរប្បច្ចយកថា

[ ១៣០ ] ឥឡូវនេះ នឹងពណ៌នាអំពីអនន្តរប្បច្ច័យដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា វិញ្ញាណទាំងនេះ កើតជាប់តគ្នានិងគ្នា មិនមានអ្វីរារាំង ព្រោះឃើញការប្រែប្រួលដោយរហ័ស ក្នុងការឃើញរូប និងការស្តាប់សំឡេងជាដើម ក្នុងការរាំ និងការច្រៀងជាដើម ពាក្យសួររបស់សកវាទីថា **ចក្ខុវិញ្ញាណស្ស** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ១៣២ ] សកវាទីពោលពាក្យថា **សោតវិញ្ញាណំ រូបារម្មណំ យេវ** ដើម្បីចោទសួរថា បើសោតវិញ្ញាណ គប្បីកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណសោត សោតវិញ្ញាណនោះ ក៏គប្បីមានរូបជាអារម្មណ៍ ដូចវិបាកមនោធាតុ ( សម្បដិច្ឆន្នចិត្ត ) ។ ក្នុងបញ្ហាទាំងឡាយថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ** បរវាទីឆ្លើយបដិសេធ ព្រោះមិនមានក្នុងព្រះសូត្រ តែកាលកំណត់ដល់ការកើតឡើង ក្នុងលំដាប់ជាប់តគ្នា ទើបឆ្លើយទទួលដោយអំណាចនៃលទ្ធិ ។ បទថា **តញ្ញេវ ចក្ខុវិញ្ញាណំ តំ សោតវិញ្ញាណំ**

សេចក្ដីថា សកវាទីសួរថា ការកើតជាប់តគ្នារបស់បឋមជវ័ន និងទុតិយជវ័ន នោះឯង រមែងប្រព្រឹត្តទៅ ព្រោះជាមនោវិញ្ញាណ យ៉ាងណា ចក្ខុវិញ្ញាណ និងសោតវិញ្ញាណទាំងពីរនោះ ក៏យ៉ាងនោះ តាមលទ្ធិរបស់អ្នកបែបនោះឬ ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងពួងដោយន័យនេះ ។

[ ១៣៦ ] បទថា **ឆជ្ជតិ គាយតិ** ជាដើម រមែងសម្ដែងដល់ការកើតផ្សំគ្នានៃវិញ្ញាណ ព្រោះការផ្លាស់ប្ដូរទៅដោយរហ័ស ព្រោះការប្រជុំនៃអារម្មណ៍ តែមិនមែនសម្ដែងដល់ភាពដែលចក្ខុវិញ្ញាណនោះ ជាអនន្តរប្បច្ច័យ ព្រោះហេតុនោះ ទើបសេចក្ដីនេះ មិនមែនជាគោលអាង ជាអនន្តរប្បច្ច័យដល់សោតវិញ្ញាណ ដូច្នេះ ។៚

**អដ្ឋកថាអនន្តរប្បច្ចយកថា ចប់**

# អភិធម្មបិដក

## អរិយរូបកថា

[ ១៣៧ ] អរិយរូប អាស្រ័យមហាភូតរូបដែរឬ ។ អើ ។ អរិយរូប ជាកុសលឬ ។ អើ ។ មហាភូត ជាកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មហាភូតជាអព្យាក្រឹតឬ ។ អើ ។ អរិយរូបជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរិយរូប អាស្រ័យមហាភូតរូបដែរឬ ។ អើ ។ អរិយរូប មិនមានអាសវៈ មិនមានប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈមិនគប្បីជោតក្រង ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង មិនជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈមិនគប្បីស្ទាបអង្អែល មិនជាប្រយោជន៍ដល់ឧបាទាន មិនគួរដល់សេចក្ដីសៅហ្មងទេឬ ។ អើ ។ មហាភូតរូប មិនមានអាសវៈ ។បេ។ មិនគួរដល់សេចក្ដីសៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មហាភូតរូប ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ គួរដល់សេចក្ដីសៅហ្មងដែរឬ ។ អើ ។ អរិយរូប ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ គួរដល់សេចក្ដីសៅហ្មងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៨ ] បុគ្គលមិនគួរនិយាយថា អរិយរូប អាស្រ័យមហាភូតទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបណានីមួយ គឺជាមហាភូតរូបទាំង ៤ និងរូបដែលអាស្រ័យនូវមហាភូតរូបទាំង ៤ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អរិយរូប អាស្រ័យមហាភូតរូបដែរ ។

# អដ្ឋកថា

## អរិយរូបកថា

[ ១៣៧ ] ឥឡូវនេះ នឹងពណ៌នាអំពីអរិយរូប គឺរូបរបស់ព្រះអរិយៈ ឬរូបដ៏ប្រសើរដូចតទៅ

ក្នុងរឿងនោះ ជនពួកណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា សម្មាវាចា សម្មាកម្មន្តៈ ជារូបហើយ រូបនោះឯងជាឧបាទាយរូប ព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា រូបទាំងអស់ ( នោះ ) គឺមហាភូតរូប ៤ និងរូបដែលអាស្រ័យនូវមហាភូតរូប ៤ ក្តី ដូច្នេះ ។ ពាក្យសួររបស់សកវាទីថា **អរិយរូបំ មហាភូតានំ ឧបាទាយ** ដូច្នេះ សំដៅដល់ជនទាំងនោះ ។ បណ្ឌិតគប្បីជ្រាបវិគ្គហៈ ពាក្យថា អរិយរូប ក្នុងបញ្ហានោះ ដូច្នេះថា រូបនៃព្រះអរិយៈទាំងឡាយ ឈ្មោះថា អរិយរូប ឬថា រូបដ៏ប្រសើរ ឈ្មោះថា អរិយរូប ។ បរវាទីឆ្លើយទទួលថា **អាមន្តា** ព្រោះតាំងនៅក្នុងលទ្ធិ ។ ត្រូវសួរថា **កុសលំ** ក៏ឆ្លើយទទួលដោយអំណាចនៃលទ្ធិនោះឯង ។ ក្នុងពាក្យសួរថា អរិយរូប ជាអនាសវៈជាដើម ក៏មានន័យនេះដូចគ្នា ។

[ ១៣៨ ] ព្រះសូត្រថា **យំ កិញ្ចិ រូបំ** ជាដើម រមែងសម្តែងដល់ភាពដែលរូបទាំងឡាយដ៏សេស វៀរលែងមហាភូតរូបចេញ ជាឧបាទាយរូប មិនមែនសម្តែងដល់ភាពដែលសម្មាវាចា សម្មាកម្មន្តៈទាំងនោះ ជាឧបាទាយរូបឡើយ ។ ពិតហើយ ភាពដែលសម្មាវាចា សម្មាកម្មន្តៈទាំងនោះជារូប មិនសម្រេច ហើយភាពជាឧបាទាយរូបរបស់សម្មាវាចាជាដើមនោះ មានមកអំពីណា ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនជាគោលអាង ដូច្នេះ ។៚

**អដ្ឋកថាអរិយរូបកថា ចប់**

# អភិធម្មបិដក

## អញ្ញអនុសយោតិកថា

[ ១៣៩ ] កាមរាគានុស័យដទៃ កាមរាគបរិយុដ្ឋានដទៃឬ ។ អើ ។ កាមរាគៈដទៃ កាមរាគបរិយុដ្ឋានដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈនោះឯង គឺកាមរាគបរិយុដ្ឋាននោះឬ ។ អើ ។ កាម-រាគានុស័យនោះឯង គឺកាមរាគបរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤០ ] បដិឃានុស័យដទៃ បដិឃបរិយុដ្ឋានដទៃឬ ។ អើ ។ បដិឃៈដទៃ បដិឃបរិយុដ្ឋានដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិឃៈនោះឯង គឺបដិឃបរិយុដ្ឋាននោះឬ ។ អើ ។ បដិឃានុស័យនោះឯង គឺបដិឃបរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤១ ] មានានុស័យដទៃ មានបរិយុដ្ឋានដទៃឬ ។ អើ ។ មានៈដទៃ មានបរិយុដ្ឋានដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មានៈនោះឯង គឺមានបរិយុដ្ឋាននោះឬ ។ អើ ។ មានានុស័យនោះឯង គឺមាន-បរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤២ ] ទិដ្ឋានុស័យដទៃ ទិដ្ឋិបរិយុដ្ឋានដទៃឬ ។ អើ ។ ទិដ្ឋិដទៃ ទិដ្ឋិបរិយុដ្ឋានដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទិដ្ឋិនោះឯង គឺទិដ្ឋិបរិយុដ្ឋាននោះឬ ។ អើ ។ ទិដ្ឋានុស័យនោះឯង គឺទិដ្ឋិបរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៣ ] វិចិកិច្ឆានុស័យជាទេ វិចិកិច្ឆាបរិយុដ្ឋានជាទេឬ ។ អើ ។ វិចិកិច្ឆាជាទេ វិចិកិច្ឆាបរិយុដ្ឋានជាទេដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិចិកិច្ឆានោះឯង គឺវិចិកិច្ឆាបរិយុដ្ឋាននោះឬ ។ អើ ។ វិចិកិច្ឆានុស័យនោះឯង គឺវិចិកិច្ឆាបរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៤ ] ភវរាគានុស័យជាទេ ភវរាគបរិយុដ្ឋានជាទេឬ ។ អើ ។ ភវរាគៈជាទេ ភវរាគបរិយុដ្ឋានជាទេដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភវរាគៈនោះឯង គឺភវរាគបរិយុដ្ឋាននោះឬ ។ អើ ។ ភវរាគានុស័យនោះឯង គឺភវរាគបរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៥ ] អវិជ្ជានុស័យជាទេ អវិជ្ជាបរិយុដ្ឋានជាទេឬ ។ អើ ។ អវិជ្ជាជាទេ អវិជ្ជាបរិយុដ្ឋានជាទេដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជានោះឯង គឺអវិជ្ជាបរិយុដ្ឋាននោះឬ ។ អើ ។ អវិជ្ជានុស័យនោះឯង គឺអវិជ្ជាបរិយុដ្ឋាននោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៦ ] បុគ្គលមិនគួរនិយាយថា អនុស័យដទៃ បរិយុដ្ឋានដទៃទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹតប្រព្រឹត្តទៅ គួរពោលថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ គួរពោលថា បុគ្គលត្រូវកិលេសរួបរឹត ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អនុស័យដទៃ បរិយុដ្ឋានដទៃ ។ បុថុជ្ជន កាលបើចិត្តជាកុសល និងអព្យាក្រឹតប្រព្រឹត្តទៅ គួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ គួរពោលថា បុគ្គលត្រូវកិលេសរួបរឹតឬ ។ អ្នកមិនគួរពោលថាយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ រាគៈដទៃ បរិយុដ្ឋានដទៃ ។

អញ្ញអនុសយោតិកថា ចប់

# អដ្ឋកថា

## អញ្ញអនុសយោតិកថា

[ ១៣៩ ] ឥឡូវនេះ នឹងពណ៌នាអំពីអនុស័យជាអញ្ញៈដូចតទៅ

ក្នុងរឿងនោះ ជនពួកណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រោះបុថុជ្ជន កាលចិត្តជាកុសល ឬអព្យាកត កំពុងប្រព្រឹត្តទៅ គប្បីពោលបានថា បុគ្គលនោះ មានអនុស័យ តែមិនគប្បីពោលថា បុគ្គលនោះ ត្រូវកិលេសរួបរឹត ព្រោះហេតុនោះ អនុស័យម្យ៉ាង បរិយុដ្ឋានក៏ម្យ៉ាង ដូច្នេះ ពាក្យសួររបស់សកវាទីថា **អញ្ញោ កាមរាគានុសយោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងរឿងអនុសយកថាខាងដើមនោះឯង ។

[ ១៤៦ ] ម្យ៉ាងទៀត បទថា **សានុសយោ** ជាដើម រមែងសម្តែងនូវភាពដែលពាក្យបុគ្គលគប្បីពោលថា បុថុជ្ជន ឈ្មោះថា ជាអ្នកមានអនុស័យ ព្រោះភាពដែលបុគ្គលនោះ មិនទាន់បានលះអនុស័យក្នុងសម័យនោះ តែសម្តែងនូវភាពដែលពាក្យបុគ្គលមិនគប្បីពោលថា ជាបុគ្គលដែលបរិយុដ្ឋាន-កិលេសរួបរឹត ព្រោះកិលេសនោះ មិនទាន់បានកើតឡើង មិនមែនសម្តែងដល់ភាពដែលអនុសយកិលេសម្យ៉ាង និងបរិយុដ្ឋានកិលេសម្យ៉ាង ព្រោះហេតុនោះ ទើបពាក្យដែលលើកមកអាងនោះ មិនមែនជាគោលអាង ដូច្នេះ ។ល។

**អដ្ឋកថាអញ្ញអនុសយោតិកថា ចប់**

# អភិធម្មបិដក

## បរិយុដ្ឋានចិត្តវិប្បយុត្តត្តិកកថា

[ ១៤៧ ] បរិយុដ្ឋាន ( ការរួបរឹតនៃកិលេស ) ប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ប្រាសចាកចិត្ត ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បរិយុដ្ឋានប្រាសចាកចិត្តឬ ។ អើ ។ ចិត្តប្រកបដោយរាគៈ ចិត្តប្រកបដោយទោសៈ ចិត្តប្រកបដោយមោហៈ ។បេ។ ចិត្តជាអកុសល ចិត្តសៅហ្មង មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងចិត្តប្រកបដោយរាគៈ ចិត្តប្រកបដោយទោសៈ ចិត្តប្រកបដោយមោហៈ ។បេ។ ចិត្តជាអកុសល ចិត្តសៅហ្មង មានដែរឬ ។ អើ ។ ប្រសិនបើ ចិត្តប្រកបដោយរាគៈ ចិត្តប្រកបដោយទោសៈ ចិត្តប្រកបដោយមោហៈ ។បេ។ ចិត្តជាអកុសល ចិត្តសៅហ្មង មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បរិយុដ្ឋានប្រាសចាកចិត្តទេ ។

បរិយុដ្ឋានចិត្តវិប្បយុត្តត្តិកកថា ចប់

# អដ្ឋកថា

## បរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា

[ ១៤៧ ] ឥឡូវនេះ នឹងពណ៌នាអំពីបរិយុដ្ឋានក្កិលេស មិនប្រកប ជាមួយចិត្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈ ទាំងឡាយថា ព្រោះកិលេសទាំងឡាយ មានរាគៈជាដើម កើតឡើង សូម្បី ដល់បុគ្គលមនសិការដោយភាពជារបស់មិនទៀងជាដើម ដូចពាក្យដែលព្រះ មានព្រះភាគទ្រង់ត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា បពិត្រ ព្រះភារទ្វាជៈដ៏ចម្រើន ជួនកាល យើងខ្ញុំគិតថា នឹងធ្វើទុកក្នុងចិត្តថា អារម្មណ៍ មិនល្អ ក៏ប្រែក្លាយទៅជាអារម្មណ៍ល្អវិញក៏បាន ដូច្នេះ ព្រោះហេតុនោះ ទើប បរិយុដ្ឋានក្កិលេស មិនប្រកបជាមួយចិត្ត ដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យ ដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលមក ហើយខាងដើមនោះឯង ។ល។

**អដ្ឋកថាបរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា ចប់**

# អភិធម្មបិដក

## បរិយាយបន្នកថា

[ ១៤៨ ] រូបរាគៈ ដេកតាមរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ ការស្វែងរកសមាបត្តិ ការស្វែងរកកំណើត ការនៅជាសុខ ក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខ ក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងការមិនស្វែងរកសមាបត្តិ ការមិនស្វែងរកកំណើត ការមិននៅជាសុខ ក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ចិត្តដែលមិនស្វែងរកកំណើត ចិត្តដែលមិននៅជាសុខ ក្នុងបច្ចុប្បន្នទេឬ ។ អើ ។ ប្រសិនបើ ការមិនស្វែងរកសមាបត្តិ ការមិនស្វែងរកកំណើត ការមិននៅជាសុខ ក្នុងបច្ចុប្បន ។បេ។ មានអារម្មណ៍ជាមួយគ្នា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបរាគៈ ដេកតាមរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុទេ ។បេ។

[ ១៤៩ ] រូបរាគៈ ដេកតាមរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ សទ្ទរាគៈដេកតាមសទ្ទធាតុ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបរាគៈដេកតាមរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុឬ ។

អើ ។ គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ (ដែលប៉ះពាល់ត្រូវ) ដេកតាមផោដ្ឋព្វធាតុ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥០ ] សទ្ទរាគៈ ដេកតាមសទ្ទធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងសទ្ទធាតុទេឬ ។ អើ ។ រូបរាគៈ ដេកតាមរូបធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ ដេកតាមផោដ្ឋព្វធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុទេឬ ។ អើ ។ រូបរាគៈ ដេកតាមរូបធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥១ ] អរូបរាគៈ ដេកតាមអរូបធាតុ រាប់បញ្ចូលក្នុងអរូបធាតុដែរឬ ។ អើ ។ ការស្វែងរកសមាបត្តិ ការស្វែងរកកំណើត ការនៅជាសុខ ក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខ ក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងការមិនស្វែងរកសមាបត្តិ ការមិនស្វែងរកកំណើត ការមិននៅជាសុខក្នុងបច្ចុប្បន្ន មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ទេឬ ។ អើ ។ ប្រសិនបើ ការមិនស្វែងរកសមាបត្តិ ការមិនស្វែងរកកំណើត ។បេ។

មានអារម្មណ៍ជាមួយគ្នា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អរូបរាគៈ ដេកតាមអរូបធាតុ រាប់បញ្ចូលក្នុងអរូបធាតុទេ ។

[ ១៥២ ] អរូបរាគៈ ដេកតាមអរូបធាតុ រាប់បញ្ចូលក្នុងអរូបធាតុដែរឬ ។ អើ ។ សទ្ទរាគៈ ដេកតាមសទ្ទធាតុ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរូបរាគៈ ដេកតាមអរូបធាតុ រាប់បញ្ចូលក្នុងអរូបធាតុដែរឬ ។ អើ ។ គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ ដេកតាមផោដ្ឋព្វធាតុ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៣ ] សទ្ទរាគៈ ដេកតាមសទ្ទធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងសទ្ទធាតុទេឬ ។ អើ ។ អរូបរាគៈ ដេកតាមអរូបធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ ដេកតាមផោដ្ឋព្វធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុទេឬ ។ អើ ។ អរូបរាគៈ ដេកតាមអរូបធាតុ តែបុគ្គលមិនគួរពោលថា រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៤ ] បុគ្គលមិនគួរនិយាយថា រូបរាគៈ ដេកតាមរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ ដេកតាមអរូបធាតុ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អើ ។ ក្រែងកាមរាគៈ ដេកតាមកាមធាតុ រាប់បញ្ចូលក្នុងកាមធាតុដែរឬ ។ អើ ។ ប្រសិនណាបើកាមរាគៈ ដេកតាមកាមធាតុ រាប់បញ្ចូលក្នុងកាមធាតុ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបរាគៈ ដេកតាមរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ ដេកតាមអរូបធាតុ រាប់បញ្ចូលក្នុងអរូបធាតុដែរ ។

បរិយាបន្នកថា ចប់

# អដ្ឋកថា

## បរិយាយន្តកថា

[ ១៤៨ ] ឥឡូវនេះ នឹងពណ៌នាអំពីធម៌ដែលទាក់ទងគ្នាដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយសមិតិយៈទាំងឡាយថា ព្រោះកាមរាគៈ ព្រះមានព្រះភាគត្រាស់ថា ដេកត្រាំក្នុងកាមធាតុ រាប់បញ្ចូលក្នុងកាមធាតុ ព្រោះហេតុនោះ សូម្បីរូបរាគៈ និងអរូបរាគៈ ក៏ឈ្មោះថា ដេកត្រាំក្នុងរូបធាតុ និងអរូបធាតុ រាប់បញ្ចូលក្នុងរូបធាតុ និងអរូបធាតុនោះឯង ដូច្នេះ ពាក្យសួររបស់សកវាទីថា **រូបរាគោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបទទាំងនោះ បទថា **អនុសេតិ** អធិប្បាយថា សកវាទីសួរថា កាមរាគៈ រមែងដេកត្រាំដោយអំណាចនៃការកើតព្រមជាមួយកាមធាតុ ពោល គឺកាម-វិតក្កយ៉ាងណា សូម្បីរូបរាគៈ ក៏ដេកត្រាំដោយអំណាចនៃការកើតព្រមជាមួយរូបធាតុយ៉ាងនោះ តាមលទ្ធិរបស់អ្នកឬ ។ បទថា **បរិយាបន្នោ** អធិប្បាយថា សកវាទីសួរថា ដូចការរាប់បញ្ចូលនោះ ឈ្មោះថា រាប់បញ្ចូលក្នុងកាមធាតុ ព្រោះរាប់បញ្ចូលគ្នាដោយអំណាចកិលេសកាមរបស់កាមធាតុ ៣ យ៉ាង យ៉ាងណា សូម្បីរូបរាគៈ ក៏ជាសភាវៈដែលរាប់បញ្ចូលក្នុងរូបធាតុ ក៏យ៉ាងនោះ តាមលទ្ធិរបស់អ្នកឬ ។ ចំណែកបរវាទី កាលមិនកំណត់បំណងរបស់សកវាទីនោះ ទើបឆ្លើយទទួលថា **អាមន្តា** ដោយអំណាចនៃលទ្ធិត្រឹមតែម្យ៉ាងប៉ុណ្ណោះ ។ លំដាប់នោះ សកវាទីក៏ពោលថា **សមាបត្តេសិយោ**

ជាដើម ដើម្បីឲ្យបរវាទីនោះកំណត់សេចក្ដីនោះ និងដើម្បីសួរប្រៀបធៀបជាមួយចិត្ត ដែលស្វែងរកសមាបត្តិ ពោល គឺកុសលវិបាកចិត្ត និងកិរិយាចិត្ត ជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបអត្ថតាមព្រះបាលីនោះឯង ។

[ ១៥៤ ] បទថា **ឆន្ទុ កាមរាគោ** ជាដើម រមែងសម្ដែងដល់ភាពដែលកាមរាគៈនោះឯង ជាធម្មជាតដែលដេកត្រាំក្នុងកាមធាតុផង ជាសភាវៈដែលរាប់បញ្ចូលក្នុងកាមធាតុផង មិនមែនសម្ដែងដល់ភាពដែលធាតុក្រៅអំពីនេះដេកត្រាំ និងរាប់បញ្ចូលក្នុងធាតុក្រៅអំពីនេះឡើយ ដោយប្រការដូច្នេះ ។l៚

**អដ្ឋកថាបរិយាយបន្នកថា ចប់**

# អភិធម្មបិដក

## អព្យាកតកថា

[ ១៥៥ ] ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ វិបាក និងអព្យាក្រឹត កិរិយា និងអព្យាក្រឹត រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាអព្យាក្រឹត ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទិដ្ឋិជាអព្យាក្រឹតឬ ។ អើ ។ ផស្សៈ ប្រកបដោយទិដ្ឋិ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ វេទនាប្រកបដោយទិដ្ឋិ ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ចិត្ត ( ប្រកបដោយទិដ្ឋិ ) ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៦ ] ផស្សៈ ប្រកបដោយទិដ្ឋិ ជាអកុសលឬ ។ អើ ។ ទិដ្ឋិ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនាប្រកបដោយទិដ្ឋិ ។បេ។ សញ្ញា ចេតនា ចិត្ត ( ប្រកបដោយទិដ្ឋិ ) ជាអកុសលដែរឬ ។ អើ ។ ទិដ្ឋិ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៧ ] ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ ទិដ្ឋិ មិនមានផល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងទិដ្ឋិប្រកបដោយផល ប្រកបដោយវិបាកដែរឬ ។ អើ ។ ប្រសិនបើ ទិដ្ឋិប្រកបដោយផល ប្រកបដោយវិបាកដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទិដ្ឋិជាអព្យាក្រឹតទេ ។

[ ១៥៨ ] ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ទោសទាំងឡាយ មានមិច្ឆាទិដ្ឋិដ៏ក្រៃលែងឬ ។ អើ ។ ប្រសិនបើ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទោសទាំងឡាយ មានមិច្ឆាទិដ្ឋិដ៏ក្រៃលែង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទិដ្ឋិ ជាអព្យាក្រឹតទេ ។

[ ១៥៩ ] ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវច្ឆៈ មិច្ឆាទិដ្ឋិជាអកុសល សម្មាទិដ្ឋិជាកុសល ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទិដ្ឋិ ជាអព្យាក្រឹតទេ ។

[ ១៦០ ] ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបុណ្ណៈ បណ្ដាគតិទាំងពីរ តថាគតពោលនូវគតិណាមួយ គឺនរក ឬកំណើតតិរច្ឆានរបស់បុគ្គលជាមិច្ឆាទិដ្ឋិពិត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទិដ្ឋិ ជាអព្យាក្រឹតទេ ។

[ ១៦១ ] បុគ្គលមិនគួរនិយាយថា ទិដ្ឋិ ជាអព្យាក្រឹតទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវច្ឆៈ ទិដ្ឋិថា លោកទៀងដូច្នេះនុ៎ះ ជាអព្យាក្រឹត ម្នាលវច្ឆៈ ទិដ្ឋិថា លោកមិនទៀងដូច្នេះនុ៎ះ ជាអព្យាក្រឹត ម្នាលវច្ឆៈ ទិដ្ឋិថា លោកមានទីបំផុតដូច្នេះ ។បេ។ ម្នាលវច្ឆៈ ថា លោកមិនមានទីបំផុត ដូច្នេះ ... ម្នាលវច្ឆៈ ថា ជីវិតនោះ គឺសរីរៈនោះ ដូច្នេះ ... ម្នាល វច្ឆៈ ថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះ ... ម្នាលវច្ឆៈ ថា សត្វស្លាប់ទៅកើតទៀតក៏មាន ដូច្នេះ ... ម្នាលវច្ឆៈ ថា សត្វស្លាប់ទៅ មិនកើតទៀត ក៏មានដូច្នេះ ... ម្នាលវច្ឆៈ ថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន ដូច្នេះ ... ម្នាលវច្ឆៈ ទិដ្ឋិថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន

ក៏មានដូច្នេះនុ៎ះ ជាអព្យាក្រឹត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទិដ្ឋិ ជាអព្យាក្រឹតពិត ។

[ ១៦២ ] ទិដ្ឋិ ជាអព្យាក្រឹតឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយកម្មណាក្តី ដែលបុរសបុគ្គលជាមិច្ឆាទិដ្ឋិ សម្រេចកាន់យកហើយតាមទិដ្ឋិ ។បេ។ វចីកម្មណាក្តី ។បេ។ មនោកម្មណាក្តី ( ដែលបុរសបុគ្គលជាមិច្ឆាទិដ្ឋិ ) សម្រេចកាន់យកហើយតាមទិដ្ឋិ ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី សេចក្តីតាំងចិត្តទុកណាក្តី សង្ខារទាំងឡាយណាក្តី ធម៌ទាំងអស់នោះ ប្រព្រឹត្តទៅព្រមដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មិនជាប្រយោជន៍ ទាំងដើម្បីសេចក្តីទុក្ខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទិដ្ឋិ ជាអព្យាក្រឹតទេ ។

## អព្យាកតកថា ចប់

# អដ្ឋកថា

## អព្យាកតកថា

[ ១៥៥ ] ឥឡូវនេះ នឹងពណ៌នាអំពីអព្យាកតដូចតទៅ

ក្នុងរឿងនោះ អព្យាកត មាន ៤ គឺវិបាក កិរិយា រូប និងនិព្វាន ហៅថា អព្យាកត ព្រោះភាពជាធម៌មិនឲ្យផល ( វិបាក ) ។ ទិដ្ឋិ ដែលព្រះមានព្រះភាគទ្រង់មិនព្យាករ ព្រោះមិនត្រាស់ដោយភាវៈទៀងជាដើមថា ម្នាលវច្ឆៈ ពាក្យនេះ តថាគតមិនបានព្យាករថា លោកទៀង ដូច្នេះទេ ដូច្នេះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយឧត្តរាបថកៈទាំងឡាយថា ទិដ្ឋិ ជាអព្យាកត ហាក់ដូចជាអព្យាកតដំបូង គឺវិបាកអព្យាកត ព្រោះមិនកាន់យកវិភាគនេះ ដូច្នេះ ។ ពាក្យសួររបស់សកវាទីថា **ទិដ្ឋិគតំ អព្យាកតំ** ក៏ដើម្បីសម្តែងវិភាគនោះ ដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ។l

**អដ្ឋកថាអព្យាកតកថា ចប់**

# អភិធម្មបិដក

## អបរិយាបន្នកថា

[ ១៦៣ ] ទិដ្ឋិ ជាអបរិយាបន្នឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហន្តមគ្គ អរហន្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ( ជាអបរិយាបន្ន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៤ ] បុគ្គលមិនគួរនិយាយថា ទិដ្ឋិ ជាអបរិយបន្នទេឬ ។ អើ ។ គួរពោលថា បុថុជ្ជន ជាអ្នកប្រាសចាកតម្រេក ក្នុងកាមទាំងឡាយដែរឬ ។ អើ ។ គួរពោលថា បុគ្គលប្រាសចាកទិដ្ឋិដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ទិដ្ឋិ ជាអបរិយាបន្ន ។

អបរិយាបន្នកថា ចប់

ចុទ្ទសមវគ្គ ចប់

## ឧទ្ទាននៃចុទ្ទសមវគ្គនោះ គឺ

និយាយអំពីកុសលមូលទ្រទ្រង់អកុសលមូល អកុ-
សលមូលទ្រទ្រង់កុសលមូល ១ សឡាយតនៈ ១
ឆវិញ្ញាណកាយ ១ អរិយរូបអាស្រ័យមហាភូតរូប
១ អនុស័យនោះឯង គឺបរិយុដ្ឋាននោះ ១ បរិ-
យុដ្ឋានប្រាសចាកចិត្ត ១ រូបរាគៈជាដើមដេកតាម
កាមធាតុ ១ ទិដ្ឋិជាអព្យាក្រឹត ១ ទិដ្ឋិជាអបរិ-
យាបន្ន ១ ។

# អដ្ឋកថា

## អបរិយាបន្នកថា

[ ១៦៣ ] ឥឡូវនេះ នឹងពណ៌នាអំពីអបរិយាបន្ន គឺលោកុត្តរដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា ព្រោះបុថុជ្ជនដែលបានឈាន គប្បីពោលបានថា ជាអ្នកមានរាគៈទៅប្រាសហើយក្នុងកាមទាំងឡាយ តែមិនគប្បីពោលថា ជាអ្នកមានទិដ្ឋិទៅប្រាសហើយ ព្រោះហេតុនោះ ទើបទិដ្ឋិជាអបរិយាបន្ន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ដូច្នេះ ។

**អដ្ឋកថាអបរិយាបន្នកថា ចប់**

**វគ្គទី ១៤ ចប់**

# អភិធម្មបិដក

## បច្ចយកថា

[ ១៦៥ ] ភាវៈនៃធម៌ជាបច្ច័យ កំណត់ហើយឬ ។ អើ ។ ក្រែង វីមំសាជាហេតុ គឺអធិបតីនោះឯងឬ ។ អើ ។ ប្រសិនបើ វីមំសាជាហេតុ គឺ អធិបតីនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យ ដោយហេតុប្បច្ច័យ បច្ច័យដោយអធិបតិប្បច្ច័យ ។

[ ១៦៦ ] ក្រែងឆន្ទាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយឬ ។ អើ ។ ប្រសិនបើ ឆន្ទាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ ម្នាល អ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយសហជាតប្បច្ច័យ ។

[ ១៦៧ ] ក្រែងវីរិយាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយឬ ។ អើ ។ ប្រសិនបើ វីរិយាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ ម្នាល អ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយសហជាតប្បច្ច័យ ។ ក្រែងវីរិយាធិបតិ ជាអធិបតីនៃសហជាតធម៌ ទាំងឡាយ គឺឥន្ទ្រិយនោះឬ ។ អើ ។ ប្រសិនបើ វីរិយាធិបតិ ជាអធិបតី នៃសហជាតធម៌ទាំងឡាយ គឺឥន្ទ្រិយនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុ នោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយ ឥន្ទ្រិយប្បច្ច័យ ។

[ ១៦៨ ] ក្រែងវីរិយាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺ

អង្គនៃមគ្គនោះឬ ។ អើ ។ ប្រសិនបើ វីរិយាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺអង្គនៃមគ្គនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយមគ្គប្បច្ច័យ ។

[ ១៦៩ ] ក្រែងចិត្តាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយឬ ។ អើ ។ ប្រសិនបើ ចិត្តាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយសហជាតប្បច្ច័យ ។

[ ១៧០ ] ក្រែងចិត្តាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺអាហារនោះឬ ។ អើ ។ ប្រសិនបើ ចិត្តាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺអាហារនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយអាហារប្បច្ច័យ ។

[ ១៧១ ] ក្រែងចិត្តាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺឥន្ទ្រិយនោះឬ ។ អើ ។ ប្រសិនបើ ចិត្តាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺឥន្ទ្រិយនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ១៧២ ] ក្រែងវីមំសាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយឬ ។ អើ ។ ប្រសិនបើ វីមំសាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយសហជាតប្បច្ច័យ ។

[ ១៧៣ ] ក្រែងវីមំសាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺឥន្ទ្រិយនោះឬ ។ អើ ។ ប្រសិនបើ វីមំសាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺឥន្ទ្រិយនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ១៧៤ ] ក្រែងវីមំសាធិបតិ ជាអធិបតីនៃសហជាតធម៌ទាំងឡាយ គឺអង្គនៃមគ្គនោះឬ ។ អើ ។ ប្រសិនបើ វីមំសាធិបតិ ជាអធិបតីនៃសហ-ជាតធម៌ទាំងឡាយ គឺអង្គនៃមគ្គនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយមគ្គប្បច្ច័យ ។

[ ១៧៥ ] ក្រែងការពិចារណាកើតឡើង ព្រោះធ្វើអរិយធម៌ឲ្យធ្ងន់ គឺអារម្មណ៍នោះឬ ។ អើ ។ ប្រសិនបើ ការពិចារណាកើតឡើង ព្រោះធ្វើអរិយធម៌ឲ្យធ្ងន់ គឺអារម្មណ៍នោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអធិបតិប្បច្ច័យ បច្ច័យដោយអារម្មណប្បច្ច័យ ។

[ ១៧៦ ] ក្រែងពួកធម៌ជាកុសលមុនៗ ជាបច្ច័យដោយអនន្តរប្បច្ច័យនៃពួកធម៌ជាកុសលក្រោយៗ គឺអាសេវនានោះឬ ។ អើ ។ ប្រសិនបើ ពួកធម៌ជាកុសលមុនៗ ជាបច្ច័យ ដោយអនន្តរប្បច្ច័យនៃពួកធម៌ជាកុសលក្រោយៗ គឺអាសេវនានោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអនន្តរប្បច្ច័យ បច្ច័យដោយអាសេវនប្បច្ច័យ ។

[ ១៧៧ ] ក្រែងពួកធម៌ជាអកុសលមុនៗ ជាបច្ច័យដោយអនន្តរប្បច្ច័យនៃពួកធម៌ជាអកុសលក្រោយៗ គឺអាសេវនានោះឬ ។ អើ ។ ប្រសិនបើ ពួក

ធម៌ជាអកុសលមុនៗ ជាបច្ច័យ ដោយអនន្តរប្បច្ច័យនៃពួកធម៌ជាអកុសលក្រោយៗ គឺអាសេវនានោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអនន្តរប្បច្ច័យ បច្ច័យដោយអាសេវនប្បច្ច័យ ។

[ ១៧៨ ] ក្រែងពួកធម៌ ជាកិរិយាព្យាក្រឹតមុនៗ ជាបច្ច័យដោយអនន្តរប្បច្ច័យនៃពួកធម៌ជាកិរិយាព្យាក្រឹតក្រោយៗ គឺអាសេវនានោះឬ ។ អើ ។ ប្រសិនបើ ពួកធម៌ជាកិរិយាព្យាក្រឹតមុនៗ ជាបច្ច័យ ដោយអនន្តរប្បច្ច័យនៃពួកធម៌ជាកិរិយាព្យាក្រឹតក្រោយៗ គឺអាសេវនានោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បច្ច័យដោយអនន្តរប្បច្ច័យ បច្ច័យដោយអាសេវនប្បច្ច័យ ។

[ ១៧៩ ] បុគ្គលមិនគួរនិយាយថា ភាវៈនៃធម៌ជាបច្ច័យកំណត់ហើយទេឬ ។ អើ ។ បច្ច័យដោយហេតុប្បច្ច័យក៏មាន បច្ច័យដោយអារម្មណប្បច្ច័យក៏មាន បច្ច័យដោយអនន្តរប្បច្ច័យក៏មាន បច្ច័យដោយសមនន្តរប្បច្ច័យក៏មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ភាវៈនៃធម៌ជាបច្ច័យកំណត់ហើយទេ ។

**បច្ចយតាកថា ចប់**

# អដ្ឋកថា

## បច្ចយតាកថា

[ ១៦៥ ] ឥឡូវនេះ នឹងពណ៌នាអំពីភាពជាបច្ច័យដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ធម៌ដែលជាបច្ច័យ ដោយហេតុប្បច្ច័យ រមែងជាបច្ច័យដោយហេតុប្បច្ច័យ ដល់ធម៌ទាំងឡាយណា ព្រោះមិនជាបច្ច័យដោយអារម្មណប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ដល់ធម៌ទាំងនោះឯង ឬធម៌ដែលជាបច្ច័យ ដោយអារម្មណប្បច្ច័យ ដល់ធម៌ទាំងឡាយណាហើយ ព្រោះមិនជាបច្ច័យដោយអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យដល់ធម៌ទាំងនោះនោះឯង ព្រោះហេតុនោះ ភាពជាបច្ច័យ លោកកំណត់ហើយដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថាបច្ចយតាកថា ចប់**

# អភិធម្មបិដក

## អញ្ញមញ្ញប្បច្ចយកថា

[ ១៨០ ] សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ហើយបុគ្គលមិនគួរពោលថា អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យផងទេឬ ។ អើ ។ ក្រែងអវិជ្ជាកើតដោយសារសង្ខារឬ ។ អើ ។ ប្រសិនបើ អវិជ្ជាកើតដោយសារសង្ខារ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យផង អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យផងដែរ ។

[ ១៨១ ] ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ តែបុគ្គលមិនគួរពោលថា តណ្ហាកើតមាន ព្រោះឧបាទានជាបច្ច័យផងទេឬ ។ អើ ។ ក្រែងតណ្ហាកើតដោយសារឧបាទានឬ ។ អើ ។ ប្រសិនបើ តណ្ហាកើតដោយសារឧបាទាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យផង តណ្ហាកើតមាន ព្រោះឧបាទានជាបច្ច័យផងដែរ ។

[ ១៨២ ] ម្នាលភិក្ខុទាំងឡាយ ជាតិកើតមាន ព្រោះជរា និងមរណៈជាបច្ច័យ ភពកើតមាន ព្រោះជាតិជាបច្ច័យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ ព្រោះហេតុនោះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យហើយ បុគ្គលមិនគួរពោលថា អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យទេ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ តែបុគ្គលមិនគួរពោលថា

តណ្ហាកើតមាន ព្រោះឧបាទានជាបច្ច័យទេ ។

[ ១៨៣ ] ម្នាលភិក្ខុទាំងឡាយ នាម និងរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណកើតមាន ព្រោះនាម និងរូបជាបច្ច័យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យផង អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យផង ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យផង តណ្ហាកើតមាន ព្រោះឧបាទានជាបច្ច័យផងដែរ ។

អញ្ញមញ្ញប្បច្ចយកថា ចប់

# អដ្ឋកថា

## អញ្ញមញ្ញប្បច្ចយកថា

[ ១៨០ ] ឥឡូវនេះ នឹងពណ៌នាអំពីអញ្ញមញ្ញប្បច្ច័យដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា សង្ខារទាំងឡាយកើត ព្រោះអវិជ្ជាជាបច្ច័យនេះប៉ុណ្ណោះជាបែបផែនក្នុងលទ្ធិ ពាក្យថា អវិជ្ជាកើតព្រោះសង្ខារជាបច្ច័យ ដូច្នេះរមែងមិនមាន ព្រោះហេតុនោះ ទើបអវិជ្ជាប៉ុណ្ណោះ ជាបច្ច័យដល់សង្ខារទាំងឡាយ តែសង្ខារទាំងឡាយ មិនជាបច្ច័យដល់អវិជ្ជាឡើយ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ដើម្បីសម្តែងសេចក្តីថា សូម្បីភាពជាបច្ច័យដល់គ្នានិងគ្នារបស់បច្ច័យទាំងឡាយ មានអវិជ្ជា និងសង្ខារជាដើមមាន ដូច្នេះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបទនេះថា **អវិជ្ជា សង្ខារេន** លោកកាន់យកអបុញ្ញាភិសង្ខារតែម្យ៉ាង ព្រោះហេតុនោះ ក្នុងពាក្យនេះថា ព្រោះសង្ខារជាបច្ច័យ ក៏កើតអវិជ្ជាបាន បណ្ឌិតគប្បីជ្រាបភាពជាបច្ច័យ ដោយអំណាចសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងសម្បយុត្តប្បច្ច័យ ។

[ ១៨១ ] ក្នុងបទនេះថា **ឧបាទានប្បច្ចយាបិ តណ្ហា** បណ្ឌិតគប្បីជ្រាបថា វៀរកាមុបាទានចេញហើយ ឧបាទាន ៣ ដ៏សេស រមែងជាបច្ច័យដល់តណ្ហាបាន ដូចសង្ខារទាំងឡាយ ជាបច្ច័យដល់អវិជ្ជា ។ ពាក្យដ៏សេសគប្បីជ្រាបតាមព្រះបាលីនោះឯង ។

[ ១៨២ ] ពាក្យសួរថា **ជរាមរណប្បច្ចយា** ជាដើម ជាពាក្យរបស់បរវាទី ។ ពាក្យសួរថា **នាមរូបំ វិញ្ញាណប្បច្ចយា** ជាដើម ជាពាក្យរបស់សកវាទី ដូច្នេះឯង ។ល។

**អដ្ឋកថាអញ្ញមញ្ញប្បច្ចយកថា ចប់**

# អភិធម្មបិដក

## អដ្ឋកថា

[ ១៨៤ ] កាលសម្រេចហើយឬ ។ អើ ។ រូប ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អតីតកាលសម្រេចហើយឬ ។ អើ ។ រូប ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលជាអនាគតសម្រេចហើយឬ ។ អើ ។ រូប ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណសម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលជាបច្ចុប្បន្នសម្រេចហើយឬ ។ អើ ។ រូប ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណដែលកន្លងទៅហើយ ជាកាលកន្លងទៅហើយឬ ។ អើ ។ ចុះកាលជាអតីត មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណដែលមិនទាន់មានមក ជាកាលអនាគតឬ ។ អើ ។ ចុះកាលជាអនាគត មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះ

ទេ ។បេ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណដែលកើតចំពោះមុខ ជាកាលបច្ចុប្បន្នឬ ។ អើ ។ ចុះកាលជាបច្ចុប្បន្ន មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ៥ ដែលកន្លងហើយ ជាកាលកន្លងទៅហើយ ខន្ធ ៥ ដែលមិនទាន់មកដល់ ជាកាលអនាគត ខន្ធ ៥ ដែលកើតចំពោះមុខ ជាកាលបច្ចុប្បន្នឬ ។ អើ ។ ចុះកាល មាន ១៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ១២ ដែលកន្លងហើយ ជាកាលកន្លងទៅហើយ អាយតនៈ ១២ ដែលមិនទាន់មកដល់ ជាកាលអនាគត អាយតនៈ ១២ ដែលកើតចំពោះមុខ ជាកាលបច្ចុប្បន្នឬ ។ អើ ។ ចុះកាល មាន ៣៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ ១៨ ដែលកន្លងហើយ ជាកាលកន្លងទៅហើយ ធាតុ ១៨ ដែលមិនទាន់មកដល់ ជាកាលអនាគត ធាតុ ១៨ ដែលកើតចំពោះមុខ ជាកាលបច្ចុប្បន្នឬ ។ អើ ។ ចុះកាល មាន ៥៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ឥន្ទ្រិយ ២២ ដែលកន្លងហើយ ជាកាលកន្លងទៅហើយ ឥន្ទ្រិយ ២២ ដែលមិនទាន់មកដល់ ជាកាលអនាគត ឥន្ទ្រិយ ២២ ដែលកើតចំពោះមុខ ជាកាលបច្ចុប្បន្នឬ ។ អើ ។ ចុះកាល មាន ៦៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៥ ] បុគ្គលមិនគួរនិយាយថា កាលសម្រេចហើយទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កថាវត្ថុនេះ មាន ៣ យ៉ាង ។ កថាវត្ថុ ៣ យ៉ាងនេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវកាលដែលកន្លងទៅហើយ ហើយគប្បីសង្ស័យថា ហេតុយ៉ាងនេះ

មានហើយក្នុងកាលកន្លងទៅហើយផង ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវកាលដែលមិនទាន់មកដល់ ហើយគប្បីសង្ស័យថា ហេតុយ៉ាងនេះ នឹងមានក្នុងកាលជាអនាគតផង ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវកាល ដែលកើតចំពោះមុខឥឡូវនេះ ហើយគប្បីសង្ស័យថា ហេតុយ៉ាងនេះ កំពុងមានក្នុងបច្ចុប្បន្ន ឥឡូវនេះផង ម្នាលភិក្ខុទាំងឡាយ កថាវត្ថុ មាន ៣ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ កាលសម្រេចហើយ ។

អដ្ឋកថា ចប់

# អដ្ឋកថា

## អទ្ធាកថា

[ ១៨៤ ] ឥឡូវនេះ នឹងពណ៌នាអំពីរយៈកាលដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិថា ឈ្មោះថា អទ្ធា ពោល គឺវេលា ដែលជាសភាវៈសម្រេចហើយមាន ព្រោះអាស្រ័យព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ កថាវត្ថុ មាន ៣ យ៉ាងនេះឯង ដូច្នេះ ពាក្យសួររបស់សកវាទីថា **អទ្ធា បរិនិប្ផន្នោ** ដើម្បីសម្តែងនូវការចែកដល់ជនទាំងនោះថា ឈ្មោះថា អទ្ធាណាមួយ ដែលជាសភាវៈសម្រេចហើយមិនមាន វៀរត្រឹមតែកាលប្បញ្ញត្តិ តែខន្ធទាំងឡាយ មានរូបជាដើម ជារបស់សម្រេចហើយ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **រូបំ** ជាដើម ដើម្បីសួរបរវាទីនោះថា បើកាលនោះ ជារបស់សម្រេចហើយសោត កាលនោះ ក៏គប្បីដូចគ្នានឹងខន្ធណាមួយ ក្នុងរូបក្ខន្ធជាដើម ។ បរវាទីឆ្លើយបដិសេធ ។ ពាក្យដ៏សេសគប្បីជ្រាបតាមព្រះបាលីនោះឯង ។៘

**អដ្ឋកថាអទ្ធាកថា ចប់**

# អភិធម្មបិដក

## ខណាលយមុហុត្តកថា

[ ១៨៦ ] កាលមួយខណៈ សម្រេចហើយ កាលមួយស្របក់សម្រេចហើយ កាលមួយរំពេច សម្រេចហើយឬ ។ អើ ។ រូប ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ( សម្រេចហើយ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៧ ] បុគ្គលមិនគួរនិយាយថា កាលមួយរំពេច សម្រេចហើយទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កថាវត្ថុនេះ មាន ៣ យ៉ាង ។ កថាវត្ថុ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវកាលកន្លងហើយ ហើយគប្បីសន្សំយថា ហេតុយ៉ាងនេះ មានហើយក្នុងកាលកន្លងទៅហើយផង ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវកាលដែលមិនទាន់មកដល់ ហើយគប្បីសន្សំយថា ហេតុយ៉ាងនេះនឹងមានក្នុងកាលជាអនាគតផង ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវកាលដែលកំពុងកើតមានចំពោះមុខ ឥឡូវនេះ ហើយគប្បីសន្សំយថា ហេតុយ៉ាងនេះ កំពុងមានក្នុងបច្ចុប្បន្ន ឥឡូវនេះផង ម្នាលភិក្ខុទាំងឡាយ កថាវត្ថុ មាន ៣ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ កាលមួយរំពេច សម្រេចហើយ ។

ខណាលយមុហុត្តកថា ចប់

# អដ្ឋកថា

## ខណលយមុហុត្តកថា

[ ១៨៦ ] ឥឡូវនេះ នឹងពណ៌នាអំពីខណលយមុហុត្តៈ[១] គឺស្របក់ ឬគ្រាដូចតទៅ

ក្នុងរឿងខណៈ លយៈ និងមុហុត្តៈ ក៏ន័យនេះឯង គឺន័យដូចគ្នានឹងអទ្ធា ព្រោះខណៈទាំងអស់នេះជាដើម ជាពាក្យបរិយាយរបស់អទ្ធានោះឯង ។ ល។

**អដ្ឋកថាខណលយមុហុត្តកថា ចប់**

១- ការផ្ទាត់ម្រាមដៃបន្តគ្នាមិនដាច់ ១០ ដង ជា ១ ខណៈ ១០ ខណៈ ជា ១ លយៈ ១០ លយៈ ជា ១ ខណលយៈ ១០ ខណលយៈ ជា ១ មុហុត្តៈ ១០ មុហុត្តៈ ជា ១ ខណមុហុត្តៈ ។

# អភិធម្មបិដក

## អាសវកថា

[ ១៨៨ ] អាសវៈ ៤ យ៉ាង ជាអនាសវៈ ( ធម៌មិនមានអាសវៈ ) ឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គ ( ជាអនាសវៈ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរពោលថា អាសវៈ ៤ យ៉ាង ជាអនាសវៈទេឬ ។ អើ ។ អាសវៈទាំងនោះជាធម៌ប្រកបដោយអាសវៈ ដោយអាសវៈទាំងឡាយណា ( អាសវៈទាំងឡាយនោះ ) ដទៃទៀត ជាអនាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អាសវៈ ៤ ជាអនាសវៈដែរ ។

អាសវកថា ចប់

# អដ្ឋកថា

## អាសវកថា

[ ១៨៨ ] ឥឡូវនេះ នឹងពណ៌នាអំពីអាសវៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទថា ព្រោះអាសវៈ ៤ គប្បីជាអារម្មណ៍របស់អាសវៈបាន ដោយអាសវៈណា ឈ្មោះថា អាសវៈដទៃក្រៅលែងជាអាសវៈ ៤ មិនមាន ព្រោះហេតុនោះ ទើបអាសវៈ ៤ មិនជាអារម្មណ៍របស់អាសវៈ ដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **មគ្គោ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើអាសវៈទាំងនោះ មិនជាអារម្មណ៍របស់អាសវៈសោត កាលបើយ៉ាងនេះ អាសវៈទាំងនោះ ក៏គប្បីសម្រេចលក្ខណៈមានមគ្គជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាអាសវកថា ចប់**

# អភិធម្មបិដក

## ជរាមរណកថា

[ ១៨៩ ] ជរា និងមរណៈរបស់ពួកលោកុត្តរធម៌ ជាលោកុត្តរដែរឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គ ( ជាលោកុត្តរ ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា និងមរណៈរបស់សោតាបត្តិមគ្គ ជាសោតាបត្តិមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា និងមរណៈរបស់សោតាបត្តិមគ្គ ជាសោតាបត្តិមគ្គដែរឬ ។ អើ ។ ជរា និងមរណៈរបស់សោតាបត្តិផល ជាសោតាបត្តិផលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា និងមរណៈរបស់សកទាគាមិមគ្គ ។បេ។ របស់សកទាគាមិផល ។បេ។ របស់អនាគាមិមគ្គ ។បេ។ របស់អនាគាមិផល ។បេ។ របស់អរហត្តមគ្គ ជាអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា និងមរណៈរបស់អរហត្តមគ្គ ជាអរហត្តមគ្គឬ ។ អើ ។ ជរា និងមរណៈរបស់អរហត្តផល ជាអរហត្តផលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា និងមរណៈរបស់សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ។បេ។ របស់ពោជ្ឈង្គទាំងឡាយ ជាពោជ្ឈង្គដែរឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩០ ] បុគ្គលមិនគួរនិយាយថា ជរា និងមរណៈរបស់ពួកលោកុត្តរធម៌ ជាលោកុត្តរដែរឬ ។ អើ ។ ( ជរា និងមរណៈ ) ជាលោកិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ( ជរា និងមរណៈ ) ជាលោកុត្តរដែរ ។

ជរាមរណកថា ចប់

# អដ្ឋកថា

## ជរាមរណកថា

[ ១៨៩ ] ឥឡូវនេះ នឹងពណ៌នាអំពីជរា និងមរណៈដូចតទៅ

ក្នុងរឿងនោះ ធម្មតាជរា និងមរណៈ មិនគួរពោលថា ជាលោកិយឬលោកុត្តរ ព្រោះមិនមែនជាសភាវៈដែលសម្រេចហើយ ។ ពិតហើយ ក្នុងទុកមាតិកាថា **លោកិយា ធម្មា លោកុត្តរា ធម្មា** ដូច្នេះ ជរា និងមរណៈមិនចាត់ចូលក្នុងលោកិយបទ និងលោកុត្តរបទ ។ ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ជរា និងមរណៈរបស់លោកុត្តរធម៌ជាលោកុត្តរ ព្រោះមិនកាន់យកលក្ខណៈ នេះពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ៕

**អដ្ឋកថាជរាមរណកថា ចប់**

# អភិធម្មបិដក

## សញ្ញាវេទយិតកថា

[ ១៩១ ] សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកុត្តរដែរឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គ ( ជាលោកុត្តរ ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរពោលថា សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកុត្តរទេឬ ។ អើ ។ ចុះជាលោកិយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ជាលោកុត្តរដែរ ។

សញ្ញាវេទយិតកថា ចប់

# អដ្ឋកថា

## សញ្ញាវេទយិតកថា

[ ១៩១ ] ឥឡូវនេះ នឹងពណ៌នាអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ដូចតទៅ

ក្នុងរឿងនោះ មិនមានធម៌ណាមួយ ដែលឈ្មោះថា សញ្ញាវេទយិត-និរោធសមាបត្តិ មានតែការរម្ងត់ខន្ធទាំង ៤ ដោយប្រការដូច្នេះ ទើបសញ្ញា-វេទយិតនិរោធសមាបត្តិនោះ មិនមែនជាលោកិយ និងមិនមែនជាលោកុត្តរ ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទនោះឯងថា ព្រោះសញ្ញាវេទយិតនិរោធសមាបត្តិ មិនជាលោកិយ ព្រោះហេតុនោះ ទើបជាលោកុត្តរ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននោះឯង ។

**អដ្ឋកថាសញ្ញាវេទយិតកថា ចប់**

# អភិធម្មបិដក

## ទុតិយសញ្ញាវេទយិតកថា

[ ១៩២ ] សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកិយឬ ។ អើ ។ រូប (ជាលោកិយ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ (ជាលោកិយ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះជាកាមាវចរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះជារូបាវចរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះជាអរូបាវចរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៣ ] បុគ្គលមិនគួរនិយាយថា សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកិយទេឬ ។ អើ ។ ចុះជាលោកុត្តរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ជាលោកិយពិត ។

ទុតិយសញ្ញាវេទយិតកថា ចប់

# អដ្ឋកថា

## ទុតិយសញ្ញាវេទយិតកថា

[ ១៩២ ] ឥឡូវនេះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទទាំងឡាយថា ព្រោះសញ្ញាវេទយិតនិរោធសមាបត្តិ មិនជាលោកុត្តរ ព្រោះហេតុនោះ ទើបជាលោកិយ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននោះឯង ៕

**អដ្ឋកថាទុតិយសញ្ញាវេទយិតកថា ចប់**

# អភិធម្មបិដក

## តតិយសញ្ញាវេទយិតកថា

[ ១៩៤ ] បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលដែរឬ ។ អើ ។ ផស្សៈ មានមរណៈជាទីបំផុត វេទនា មានមរណៈជាទីបំផុត សញ្ញា មានមរណៈជាទីបំផុត ចេតនា មានមរណៈជាទីបំផុត ចិត្ត មានមរណៈជាទីបំផុត របស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផស្សៈ មានមរណៈជាទីបំផុត វេទនា មានមរណៈជាទីបំផុត សញ្ញា មានមរណៈជាទីបំផុត ចេតនា មានមរណៈជាទីបំផុត ចិត្ត មានមរណៈជាទីបំផុត របស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ មិនមានទេឬ ។ អើ ។ ប្រសិនបើ ផស្សៈ មានមរណៈជាទីបំផុត វេទនា មានមរណៈជាទីបំផុត សញ្ញា មានមរណៈជាទីបំផុត ចេតនា មានមរណៈជាទីបំផុត ចិត្ត មានមរណៈជាទីបំផុត របស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើនូវមរណកាលទេ ។

[ ១៩៥ ] បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលដែរឬ ។ អើ ។ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត របស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត របស់បុគ្គលដែលចូលកាន់សញ្ញាវេទ-

យិតនិរោធ មិនមានទេឬ ។ អើ ។ ជាកាលកិរិយារបស់បុគ្គល ដែលមិនមានផស្សៈ កាលកិរិយារបស់បុគ្គល ដែលមិនមានវេទនា ។បេ។ កាល-កិរិយារបស់បុគ្គល ដែលមិនមានចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងជាកាលកិរិយារបស់បុគ្គលដែលមានផស្សៈ ។បេ។ កាលកិរិយារបស់បុគ្គលដែលមានចិត្តឬ ។ អើ ។ ប្រសិនបើ ជាកាលកិរិយារបស់បុគ្គលដែលមានផស្សៈ ។បេ។ កាលកិរិយារបស់បុគ្គលដែលមានចិត្តមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលទេ ។

[ ១៩៦ ] បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលដែរឬ ។ អើ ។ ថ្នាំពិសគប្បីចូលទៅ កាំបិតគប្បីមុត ភ្លើងគប្បីឆេះចំពោះកាយរបស់បុគ្គល ដែលចូលកាន់សញ្ញាវេទយិតនិរោធដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ថ្នាំពិសមិនគប្បីចូលទៅ កាំបិតមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយរបស់បុគ្គល ដែលចូលកាន់សញ្ញាវេទយិតនិរោធទេឬ ។ អើ ។ ប្រសិនបើ ថ្នាំពិសមិនគប្បីចូលទៅ កាំបិតមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយរបស់បុគ្គល ដែលចូលកាន់សញ្ញាវេទយិតនិរោធទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលទេ ។

[ ១៩៧ ] បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលដែរឬ ។ អើ ។ ថ្នាំពិសគប្បីចូលទៅ កាំបិតគប្បីមុត ភ្លើងគប្បីឆេះ ចំពោះ

កាយរបស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធដែរឬ ។ អើ ។ បុគ្គល មិនចូលកាន់និរោធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាលទេឬ ។ អើ ។ បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ កំណត់ដោយនិយាមណា មិនគប្បីធ្វើមរណកាល និយាមនោះ មានដែរឬ ។ មិនមានទេ ។ ប្រសិនបើ បុគ្គលចូលកាន់សញ្ញា-វេទយិតនិរោធ កំណត់ដោយនិយាមណា មិនគប្បីធ្វើមរណកាល និយាមនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ មិនគប្បីធ្វើមរណកាលទេ ។

[ ១៩៨ ] បុគ្គលប្រកបដោយចក្ខុវិញ្ញាណ មិនគប្បីធ្វើមរណកាលទេឬ ។ អើ ។ បុគ្គលប្រកបដោយចក្ខុវិញ្ញាណ កំណត់ដោយនិយាមណា មិនគប្បីធ្វើមរណកាល និយាមនោះ មានដែរឬ ។ មិនមានទេ ។ ប្រសិនបើ បុគ្គលប្រកបដោយចក្ខុវិញ្ញាណ កំណត់ដោយនិយាមណា មិនគប្បីធ្វើមរណ-កាល និយាមនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រកបដោយចក្ខុវិញ្ញាណ មិនគប្បីធ្វើមរណកាលទេ ។

**តតិយសញ្ញាវេទយិតកថា ចប់**

# អដ្ឋកថា

## តតិយសញ្ញាវេទយិតកថា

[ ១៩៤ ] ឥឡូវនេះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈទាំងឡាយថា បុគ្គលដែលចូលសញ្ញាវេទយិតនិរោធសមាបត្តិ គប្បីធ្វើកាលកិរិយាបាន ដោយកាន់យកគោលថា ការកំណត់ពិតប្រាកដនៃកាលដែលសត្វទាំងឡាយ មានការស្លាប់ជាធម្មតា រមែងមិនមានថា បុគ្គលនោះស្លាប់ បុគ្គលនោះ មិនស្លាប់ ដូច្នេះ ពាក្យសួររបស់សកវាទីដើម្បីសម្តែងដល់វេលាស្លាប់ និងមិនមែនវេលាស្លាប់ នៃការស្លាប់ជាធម្មតារបស់បុគ្គលដែលចូលសមាបត្តិដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **អត្ថិ** ជាដើម ដើម្បីចោទសួរបរវាទីនោះ ដោយអាការថា ធម៌ទាំងឡាយ មានផស្សៈជាដើមដែលកើតក្នុងសម័យមានការស្លាប់ជាទីបំផុត ឈ្មោះថា គប្បីមានដល់បុគ្គលដែលធ្វើកាលកិរិយាបានឬ ។

[ ១៩៥ ] បរវាទីត្រូវសួរថា **អជស្សកស្ស កាលកិរិយា** ជាដើម ក៏ឆ្លើយបដិសេធ ដោយសំដៅយកសត្វដ៏សេស គឺក្រៅអំពីបុគ្គលចូលសមាបត្តិនោះ ។

[ ១៩៦ ] បរវាទីត្រូវសួរថា **វិសំ កមេយ្យ** ជាដើម ក៏ឆ្លើយបដិសេធដោយសំដៅយកអានុភាពនៃសមាបត្តិ ។

[ ១៩៧ ] តែឆ្លើយទទួលក្នុងគ្រាទី ២ ដោយសំដៅយកសរីរៈប្រក្រតី ។

កាលបើយ៉ាងនេះ ឈ្មោះថា អានុភាពនៃសមាបត្តិក៏មិនមាន ដោយហេតុនោះឯង ទើបសកវាទីញ៉ាំញីបរវាទីនោះថា បុគ្គលមិនចូលកាន់និរោធទេឬ ។ ពាក្យសួរថា **ន កាលំ ករេយ្យ** ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហារបស់បរវាទីថា **អត្ថិ សោ និយាមោ** ព្រោះ ឈ្មោះថា និយាមបែបនេះ មិនមាន ព្រោះហេតុនោះ ទើបសកវាទីឆ្លើយបដិសេធ ។

[ ១៩៨ ] បទថា **ចក្ខុវិញ្ញាណសមង្គី** ជាដើម ដែលសកវាទីពោលក៏ដើម្បីសម្ដែងថា កាលនិយាមបែបនេះ មិនមាន សត្វក៏ត្រូវស្លាប់តាមកាលប៉ុណ្ណោះ មិនស្លាប់ពុំជួកាល ដូច្នេះ ។ ក្នុងបញ្ហានោះ មានពាក្យអធិប្បាយថា បើការធ្វើកាលកិរិយាគប្បីមាន ព្រោះការមិនមាននិយាមសោត ការធ្វើកាលកិរិយានោះ ក៏គប្បីមានដល់បុគ្គលដែលដល់ព្រមដោយចក្ខុវិញ្ញាណ ព្រោះហេតុនោះ គប្បីមានការភ្លាំងភ្លាត់អំពីព្រះសូត្រថា សត្វ មិនស្លាប់ មិនកើតដោយវិញ្ញាណ ៥ ដូច្នេះ ។ម្យ៉ាងទៀត ការធ្វើកាលកិរិយា មិនមានដល់បុគ្គលដែលដល់ព្រមដោយចក្ខុវិញ្ញាណយ៉ាងណា ការធ្វើកាលកិរិយា ក៏មិនមានដល់បុគ្គលអ្នកចូលនិរោធសមាបត្តិក៏យ៉ាងនោះ ដោយប្រការដូច្នេះ ។

## អដ្ឋកថាតតិយសញ្ញាវេទយិតកថា ចប់

# អភិធម្មបិដក

## អសញ្ញសត្តបិកាកថា

[ ១៩៩ ] សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វដែរឬ ។ អើ ។ អលោភៈ ជាកុសលមូល អទោសៈ ជាកុសលមូល អមោហៈ ជាកុសលមូល សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា របស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អលោភៈ ជាកុសលមូល អទោសៈ ជាកុសលមូល ។បេ។ បញ្ញារបស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ មិនមានទេឬ ។ អើ ។ ប្រសិនបើ អលោភៈ ជាកុសលមូល អទោសៈ ជាកុសលមូល អមោហៈ ជាកុសលមូល សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា របស់បុគ្គលដែលចូលកាន់សញ្ញាវេទយិតនិរោធ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វទេ ។

[ ២០០ ] សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វដែរឬ ។ អើ ។ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្តរបស់បុគ្គល ដែលចូលកាន់សញ្ញាវេទយិតនិរោធ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត របស់បុគ្គលដែលចូលកាន់សញ្ញា-វេទយិតនិរោធ មិនមានទេឬ ។ អើ ។ ជាមគ្គភាវនារបស់បុគ្គលមិនមានផស្សៈ ។បេ។ មគ្គភាវនា របស់បុគ្គលមិនមានចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងជាមគ្គភាវនា របស់បុគ្គលមានផស្សៈ ។បេ។ មគ្គ-

ភាវនារបស់បុគ្គលមានចិត្តដែរឬ ។ អើ ។ ប្រសិនបើ ជាមគ្គភាវនា របស់បុគ្គលមានផស្សៈ ។បេ។ មគ្គភាវនា របស់បុគ្គលមានចិត្តមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វទេ ។

[ ២០១ ] សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វដែរឬ ។ អើ ។ បុគ្គលណាមួយ ចូលកាន់សញ្ញាវេទយិតនិរោធ បុគ្គលទាំងអស់នោះទាក់ទងដោយអសញ្ញសត្វដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០២ ] បុគ្គលមិនគួរនិយាយថា សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វទេឬ ។ អើ ។ ក្រែងសត្វមិនមានសញ្ញា ក្នុងលោកនេះក៏មាន មិនមានសញ្ញាក្នុងលោកនាយនោះ ក៏មានដែរឬ ។ អើ ។ ប្រសិនបើសត្វមិនមានសញ្ញា ក្នុងលោកនេះក៏មាន មិនមានសញ្ញាក្នុងលោកនាយនោះក៏មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញាវេទយិតនិរោធសមាបត្តិ ទាក់ទងដោយអសញ្ញសត្វដែរ ។

## អសញ្ញសត្តូបិកាកថា ចប់

# អដ្ឋកថា

## អសញ្ញសត្តបិកាកថា

[ ១៩៩ ] ឥឡូវនេះ នឹងពណ៌នាអំពីសមាបត្តិ ដែលឲ្យចូលដល់កព អសញ្ញសត្តដូចតទៅ

ក្នុងរឿងនោះ ការនាំដែលប្រព្រឹត្តទៅដោយអំណាចនៃសញ្ញាវិរាគៈ ជាអសញ្ញសមាបត្តិក្តី និរោធសមាបត្តិក្តី ឈ្មោះថា សញ្ញាវេទយិតនិរោធ-សមាបត្តិ ទើបសញ្ញាវេទយិតនិរោធសមាបត្តិមាន ២ គឺលោកិយ ១ លោកុត្តរ ១ ដោយប្រការដូច្នេះ ។ បណ្តាសញ្ញាវេទយិតនិរោធសមាបត្តិទាំងនោះ សមាបត្តិដែលជាលោកិយ ជាហេតុឲ្យចូលដល់អសញ្ញសត្ត ជារបស់បុថុជ្ជន ដែលជាលោកុត្តរ ជារបស់ព្រះអរិយៈទាំងឡាយ តែសមាបត្តិដែលជាលោកុត្តរនោះ មិនជាហេតុឲ្យចូលដល់អសញ្ញសត្ត ។ ជនទាំងឡាយណា មានលទ្ធិដូចលទ្ធិរបស់និកាយហេតុវាទទាំងឡាយថា សញ្ញាវេទយិតនិរោធសមាបត្តិ ជាហេតុឲ្យចូលដល់កពនៃអសញ្ញសត្ត ដោយមិនបែកគ្នា ព្រោះមិនធ្វើការបែក នេះពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះ ដោយអំណាចនៃកុសលមូល គឺអលោភៈជាដើមថា មានដល់បុគ្គលដែលចូលអសញ្ញសមាបត្តិ តែមិនមានដល់បុគ្គល ដែលចូលនិរោធសមាបត្តិ ទើបពោលពាក្យថា **អត្ថិ** ជាដើម ។

[ ២០២ ] ក្នុងបញ្ហាថា **ឥធាបិ អសញ្ញី** ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតភាពជាអ្នកមិនមានសញ្ញាហើយ ព្រោះបុគ្គលចូលសមាបត្តិដោយអំណាចនៃសញ្ញាវិរាគៈ ក្នុងធម្មវិន័យបាន ។ បទថា **តត្រាបិ** ក៏ត្រាស់ដោយអសញ្ញសត្វនោះឯង ព្រោះហេតុនោះ បរវាទីកាន់យកប្បញ្ហានេះហើយទើបឲ្យលទ្ធិតាំងទុក តែក៏តាំងទុកដោយភាពក្លាំងក្លាត់ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតភាពជាអ្នកមិនមានសញ្ញាហើយ ដោយសំដៅយកនិរោធសមាបត្តិ ក្នុងធម្មវិន័យនេះ ។ ក្នុងភពនៃអសញ្ញសត្វនោះ ក៏ទ្រង់អនុញ្ញាតនិរោធសមាបត្តិរបស់ព្រះអនាគាមី ដែលចុតិចាកលោកនេះនោះឯង ព្រោះហេតុនោះ លទ្ធិដែលបរវាទីតាំងទុកដោយប្បញ្ហានេះ រមែងមិនតាំងនៅបានឡើយ ដូច្នេះ ។៚

**អដ្ឋកថាអសញ្ញសត្តូបិកាកថា ចប់**

# អភិធម្មបិដក

## កម្មបច្ចយកថា

[ ២០៣ ] កម្មជទៃ ការសន្សំនូវកម្មជទៃឬ ។ អើ ។ ផស្សៈជទៃ ការសន្សំនូវផស្សៈជទៃ វេទនាជទៃ ការសន្សំនូវវេទនាជទៃ សញ្ញាជទៃ ការសន្សំនូវសញ្ញាជទៃ ចេតនាជទៃ ការសន្សំនូវចេតនាជទៃ ចិត្តជទៃ ការសន្សំនូវចិត្តជទៃ សទ្ធាជទៃ ការសន្សំនូវសទ្ធាជទៃ វីរិយៈជទៃ ការសន្សំនូវវីរិយៈជទៃ សតិជទៃ ការសន្សំនូវសតិជទៃ សមាធិជទៃ ការសន្សំនូវសមាធិជទៃ បញ្ញាជទៃ ការសន្សំនូវបញ្ញាជទៃ រាគៈជទៃ ការសន្សំនូវរាគៈជទៃ ។បេ។ អនោត្តប្បៈជទៃ ការសន្សំនូវអនោត្តប្បៈជទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៤ ] កម្មជទៃ ការសន្សំនូវកម្មជទៃឬ ។ អើ ។ ការសន្សំនូវកម្មកើតជាមួយនឹងកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មកើតជាមួយនឹងកម្មឬ ។ អើ ។ ការសន្សំនូវកម្មជាកុសល កើតជាមួយនឹងកម្មជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មជាកុសល កើតជាមួយនឹងកម្មជាកុសលឬ ។ អើ ។ ការសន្សំនូវកម្មប្រកបដោយសុខវេទនា កើតជាមួយនឹងកម្មដែលប្រកបដោយសុខវេទនាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយទុក្ខវេទនា ។បេ។ ការសន្សំនូវកម្មប្រកបដោយអទុក្ខមសុខវេទនា កើតជាមួយនឹងកម្ម ដែលប្រកបដោយអទុក្ខមសុខវេទនាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មកើតជាមួយនឹងកម្មឬ ។ អើ ។ ការសន្សំនូវកម្មជាអកុសល កើតជាមួយ

នឹងកម្ម ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មជាអកុសល កើតជាមួយនឹងកម្មជាអកុសលដែរឬ ។ អើ ។ ការសន្សំនូវកម្មប្រកបដោយសុខវេទនា កើតជាមួយនឹងកម្មដែលប្រកបដោយសុខវេទនាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយទុក្ខវេទនា ។បេ។ ការសន្សំនូវកម្មប្រកបដោយអទុក្ខមសុខវេទនា កើតជាមួយនឹងកម្មដែលប្រកបដោយអទុក្ខមសុខវេទនាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៥ ] កម្មកើតជាមួយនឹងចិត្ត ជាកម្មប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការសន្សំនូវកម្ម កើតជាមួយនឹងចិត្ត ជាការសន្សំនូវកម្មប្រកបដោយអារម្មណ៍ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មកើតជាមួយនឹងចិត្ត ការសន្សំនូវកម្មមិនមានអារម្មណ៍ទេឬ ។ អើ ។ កម្មកើតជាមួយនឹងចិត្ត ជាកម្មមិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៦ ] កម្មកើតជាមួយនឹងចិត្ត កាលបើចិត្តបែកធ្លាយទៅ កម្មក៏បែកធ្លាយដែរឬ ។ អើ ។ ការសន្សំនូវកម្ម កើតជាមួយនឹងចិត្ត កាលបើចិត្តបែកធ្លាយទៅ ការសន្សំនូវកម្មក៏បែកធ្លាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៧ ] ការសន្សំនូវកម្មកើតជាមួយនឹងចិត្ត កាលបើចិត្តបែកធ្លាយទៅ ការសន្សំនូវកម្មមិនបែកធ្លាយទេឬ ។ អើ ។ កម្មកើតជាមួយនឹងចិត្ត កាលបើចិត្តបែកធ្លាយទៅ កម្មមិនបែកធ្លាយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មចំពោះកម្មឬ ។ អើ ។ កម្មនោះឯង គឺជាការ

សន្សំនូវកម្មនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្ម ចំពោះកម្ម វិបាករបស់បុគ្គលកាលសន្សំនូវកម្មកើតឡើងឬ ។ អើ ។ កម្ម នោះឯង ការសន្សំនូវកម្មនោះឯង គឺជាវិបាករបស់កម្មនោះឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មចំពោះកម្ម វិបាករបស់បុគ្គលកាល សន្សំនូវកម្មកើតឡើង ចុះវិបាកប្រកបដោយអារម្មណ៍ដែរឬ ។ អើ ។ ការ សន្សំនូវកម្មប្រកបដោយអារម្មណ៍ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំនូវកម្មមិនមានអារម្មណ៍ទេឬ ។ អើ ។ វិបាកមិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មជាទៃ ការសន្សំនូវកម្មជាទៃឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបុណ្ណៈ បុគ្គលពួកខ្លះ ក្នុងលោក នេះ តាក់តែងនូវកាយសង្ខារ ដែលប្រកបដោយព្យាបាទខ្លះ មិនមានព្យាបាទ ខ្លះ នូវវចីសង្ខារដែលប្រកបដោយព្យាបាទខ្លះ មិនមានព្យាបាទខ្លះ តាក់តែង នូវមនោសង្ខារ ។បេ។ លុះបុគ្គលនោះ តាក់តែងនូវកាយសង្ខារ ដែលប្រកប ដោយព្យាបាទខ្លះ មិនមានព្យាបាទខ្លះ នូវវចីសង្ខារ ដែលប្រកបដោយព្យាបាទ ខ្លះ មិនមានព្យាបាទខ្លះ តាក់តែងនូវមនោសង្ខារ ។បេ។ ហើយ តែងចូល ទៅកើតក្នុងលោក ដែលប្រកបដោយព្យាបាទខ្លះ មិនមានព្យាបាទខ្លះ ផស្សៈ ទាំងឡាយប្រកបដោយព្យាបាទខ្លះ មិនមានព្យាបាទខ្លះ រមែងពាល់ត្រូវបុគ្គល នោះ ដែលចូលទៅកើតក្នុងលោក ដែលប្រកបដោយព្យាបាទខ្លះ មិនមាន ព្យាបាទខ្លះ បុគ្គលនោះ ត្រូវផស្សៈទាំងឡាយ ដែលប្រកបដោយព្យាបាទខ្លះ មិនមានព្យាបាទខ្លះ ពាល់ត្រូវហើយ រមែងរងនូវវេទនាដែលប្រកបដោយ

ព្យាបាទខ្លះ មិនមានព្យាបាទខ្លះ មានសេចក្តីសុខ និងទុក្ខ ប្រឡូកប្រឡំគ្នា ដូចមនុស្ស និងទេវតាពួកខ្លះ វិនិបាតពួកខ្លះ ម្នាលបុណ្ណៈ កំណើតនៃសត្វតូច និងធំ ដូច្នេះឯង សត្វធ្វើនូវកម្មណា រមែងចូលទៅកើតដោយកម្មនោះ ផស្សៈទាំងឡាយ រមែងពាល់ត្រូវបុគ្គលដែលកើតហើយនុ៎ះ ម្នាលបុណ្ណៈ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាមត៌កយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា កម្មដទៃ ការសន្សំនូវកម្មដទៃទេ ។

កម្មូបចយកថា ចប់

បន្នរសមវគ្គ ចប់

## ឧទ្ទាននៃបច្ចុប្បន្នរសមវគ្គនោះ គឺ

និយាយអំពីការៈនៃធម៌ ជាបច្ច័យកំណត់ហើយ ១ បដិច្ចសមុប្បាទ ១ អទ្ធា ( កាល ) ១ ខណៈ លយៈ មុហុត្តៈ ១ អាសវៈបួនជាអនាសវៈ ១ ជរា និងមរណៈរបស់លោកុត្តរធម៌ ជាលោកុត្តរ ១ សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកុត្តរ ១ សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកិយ ១ បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ គប្បីធ្វើមរណកាល ១ មគ្គនោះឯង ទាក់ទងដោយអសញ្ញសត្វ ១ កម្មជទៃ ការសន្សំនូវកម្មជទៃ ១ ។

### បណ្ណាសកទី ៣ ចប់

( ក្នុងបណ្ណាសកនេះនិយាយអំពី ) អនុស័យ សំវរៈ កប្បៈ មូលៈ និងបច្ច័យដែលកំណត់ហើយ ។

# អដ្ឋកថា

## កម្មបច្ចយកថា

[ ២០៣ ] ឥឡូវនេះ នឹងពណ៌នាអំពីការសន្សំកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយសមិតិយៈទាំងឡាយថា ឈ្មោះថា ការសន្សំកម្មដទៃក្រៅអំពីកម្ម ទាំងជាចិត្តវិប្បយុត្ត ជាអព្យាកត ជាអនារម្មណៈ ។ ពាក្យសួររបស់សកវាទីថា **អញ្ញំ កម្មំ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទី ដើម្បីចោទសួរបរវាទីនោះថា បើការសន្សំកម្មដទៃក្រៅអំពីកម្មសោត ការសន្សំផស្សៈជាដើម ក៏គប្បីដទៃអំពីផស្សៈជាដើម ដូច្នេះ ទើបពោលពាក្យថា **អញ្ញោ ផស្សោ** ជាដើម ។ បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានក្នុងលទ្ធិ ។

[ ២០៤ ] ក្នុងបញ្ហាទាំងឡាយថា **កម្មេន សហជាតោ** បរវាទីឆ្លើយបដិសេធ សំដៅយកការមិនប្រកបជាមួយចិត្ត តែឆ្លើយទទួល សំដៅយកការប្រកបជាមួយចិត្ត ។ ក្នុងបញ្ហាថា **កុសលោ** បរវាទីឆ្លើយបដិសេធសំដៅយកការមិនប្រកប តែឆ្លើយទទួល សំដៅយកការប្រកប ។ ក្នុងបញ្ហាទាំងឡាយថា **អកុសលោ** ខាងមុខ ក៏ន័យនេះឯង ។

[ ២០៥ ] បរវាទីត្រូវសួរថា **សារម្មណោ** រមែងកាន់យកការមិនមានអារម្មណ៍ដោយចំណែកមួយប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ។

[ ២០៦ ] បទថា **ចិត្តំ ភិជ្ជមានំ** សេចក្តីថា ចិត្តកំពុងរលត់ក្នុងកាល

ណា កម្មក៏កំពុងរលត់ក្នុងកាលនោះ ។ម្យ៉ាងទៀត ពាក្យថា ចិត្តនេះ លោកប្រកបបឋមាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ អធិប្បាយថា កាលចិត្តកំពុងរលត់ ។ ម្យ៉ាងទៀត ព្រះបាលីក៏យ៉ាងនេះ ។ ក្នុងសេចក្តីនេះ ការសន្សំនៃកម្ម ដែលសម្បយុត្តជាមួយចិត្ត រមែងរលត់ ដែលវិប្បយុត្ត រមែងមិនរលត់ ព្រោះហេតុនោះ ទើបបរវាទីឆ្លើយទទួលផង ឆ្លើយបដិសេធផង ។

[ ២០៧ ] បទថា **កម្មម្ហិ កម្មូបចយោ** សេចក្តីថា កាលកម្មមាន ការសន្សំកម្មក៏មាន ម្យ៉ាងទៀត ការសន្សំកម្មតាំងនៅចំពោះក្នុងកម្ម វិបាករមែងកើតព្រោះការសន្សំកម្មនោះឯង ។ លទ្ធិរបស់បរវាទីថា កាលកម្មនោះរលត់ហើយ ការសន្សំកម្ម រមែងតាំងនៅរហូតដល់ការកើតឡើងនៃវិបាក ដូចពូជរមែងតាំងនៅរហូតដល់ការកើតឡើងនៃពន្លករបស់ពូជ ព្រោះហេតុនោះ ទើបបរវាទីឆ្លើយទទួល ។ បទថា **តញ្ញេវ កម្មំ សោ កម្មូបចយោ សោ កម្មវិបាកោ** សេចក្តីថា ព្រោះលទ្ធិរបស់បរវាទីនោះថា កាលកម្មមាន ការសន្សំនៃកម្មក៏មាន ឯការសន្សំនៃកម្មនោះ តាំងនៅជរាបដល់ការកើតឡើងនៃវិបាក ព្រោះហេតុនោះ ទើបសកវាទីសួរដល់ធម៌ទាំង ៣ នោះរួមគ្នា ។ សកវាទីថា

**វិចាកោ សារម្មណោ** ដើម្បីសួរថា សូម្បីវិបាកធម្មធម្ម: គឺធម៌ដែលជាហេតុឲ្យវិបាកកើតឡើង ជាធម៌ដែលរាប់បញ្ចូលដោយអារម្មណ៍នោះឯង ដូចវិបាក ឬ ។ ចំណែកបរវាទីឆ្លើយទទួលមួយបទ បដិសេធមួយបទ ដោយអំណាចនៃលទ្ធិ ។ ក្នុងបដិលោមបញ្ហាក៏ន័យនេះដូចគ្នា ។ ពាក្យដ៏សេស ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបតាមព្រះបាលីនោះឯង ។ល។

**អដ្ឋកថាកម្មបច្ចយកថា ចប់**

**វគ្គទី ១៨ ចប់**

**តតិយបណ្ណាសក ចប់**

# អភិធម្មបិដក

## និគ្គហកថា

[ ២០៨ ] បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃបានដែរឬ ។ អើ ។ បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃថា អ្នកកុំត្រេកអរ កុំខឹង កុំវង្វេង កុំសៅហ្មងឡើយបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃបានដែរឬ ។ អើ ។ បុគ្គលដទៃ សង្កត់សង្កិនថា ផស្សៈ របស់បុគ្គលដទៃ ដែលកើតឡើងហើយ កុំរលត់ទៅវិញឡើយបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ សង្កត់សង្កិនថា វេទនា របស់បុគ្គលដទៃ ដែលកើតឡើងហើយ ។បេ។ សញ្ញា ដែលកើតឡើងហើយ ។បេ។ ចេតនា ដែលកើតឡើងហើយ ចិត្ត ដែលកើតឡើងហើយ សទ្ធា ដែលកើតឡើង វិរិយៈ ដែលកើតឡើងហើយ សតិ ដែលកើតឡើងហើយ សមាធិ ដែលកើតឡើងហើយ ។បេ។ បញ្ញា ដែលកើតឡើងហើយ កុំរលត់ទៅវិញឡើយ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៩ ] បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ លះបង់រាគៈ លះបង់ទោសៈ ។បេ។ លះបង់អនោត្តប្បៈ ដើម្បីប្រយោជន៍ដល់បុគ្គលដទៃបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១០ ] បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ ចម្រើនមគ្គ ចម្រើនសតិប្បដ្ឋាន ។បេ។ ចម្រើនពោជ្ឈង្គ

ដើម្បីប្រយោជន៍ដល់បុគ្គលដទៃបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១១ ] បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ កំណត់ដឹងនូវទុក្ខ លះនូវសមុទយៈ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ចម្រើននូវមគ្គ ដើម្បីប្រយោជន៍ដល់បុគ្គលដទៃ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១២ ] បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើអំពើដល់បុគ្គលដទៃ សុខ ទុក្ខ គឺបុគ្គលដទៃធ្វើ បុគ្គលដទៃធ្វើ បុគ្គលដទៃទទួលរង ( សុខ ទុក្ខ ) បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៣ ] បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អ្នកធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង អ្នកមិនធ្វើបុណ្យដោយខ្លួនឯង តែងបរិសុទ្ធស្អាតដោយខ្លួនឯង សេចក្ដីបរិសុទ្ធ និងមិនបរិសុទ្ធចំពោះខ្លួន អ្នកដទៃ នឹងជម្រះអ្នកដទៃឲ្យស្អាតពុំបានឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុ

នោះ អ្នកមិនគួរពោលថា បុគ្គលដទៃសង្កត់សង្កិនចិត្តរបស់បុគ្គលដទៃបានទេ ។

[ ២១៤ ] បុគ្គលមិនគួរនិយាយថា បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃបានទេឬ ។ អើ ។ ក្រែងពួកជនអ្នកដល់នូវកម្លាំងមាន ពួកជនអ្នកស្ទាត់ជំនាញ មានដែរឬ ។ អើ ។ ប្រសិនបើ ពួកជនអ្នកដល់នូវកម្លាំងមាន ពួកជនអ្នកស្ទាត់ជំនាញក៏មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលដទៃ សង្កត់សង្កិនចិត្តរបស់បុគ្គលដទៃបាន ។

និគ្គហកថា ចប់

# បគ្គហាកថា

[ ២១៥ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃថា អ្នកកុំត្រេកអរ កុំខឹង កុំវង្វេង កុំសៅហ្មងឡើយ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៦ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ ញុំាងអលោភៈជាកុសលមូលឲ្យកើត ញុំាងអទោសៈជាកុសលមូលឲ្យកើត ញុំាងអមោហៈជាកុសលមូលឲ្យកើត ញុំាងសទ្ធាឲ្យកើត ញុំាងវីរិយៈឲ្យកើត ញុំាងសតិឲ្យកើត ញុំាងសមាធិឲ្យកើត ញុំាងបញ្ញាឲ្យកើតដល់បុគ្គលដទៃ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៧ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ ផ្គងចិត្តថា ផស្សៈ របស់បុគ្គលដទៃដែលកើតឡើងហើយ កុំរលត់ទៅវិញឡើយ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ ផ្គងចិត្តថា វេទនា ដែលកើតឡើងហើយ ។បេ។ បញ្ញា របស់បុគ្គលដទៃ ដែលកើតឡើងហើយ កុំរលត់ទៅវិញឡើយ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៨ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ លះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ។បេ។ លះបង់អនោត្តប្បៈ ដើម្បីប្រយោជន៍ដល់បុគ្គលដទៃ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៩ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។

អើ ។ បុគ្គលដទៃ ចម្រើនមគ្គ ចម្រើនសតិប្បដ្ឋាន ។បេ។ ចម្រើនពោជ្ឈង្គ ដើម្បីប្រយោជន៍ដល់បុគ្គលដទៃបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២០ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ កំណត់ដឹងនូវទុក្ខ ។បេ។ ចម្រើននូវមគ្គ ដើម្បីប្រយោជន៍ដល់បុគ្គលដទៃ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២១ ] បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើអំពើដល់បុគ្គលដទៃ សុខ ទុក្ខ ដែលបុគ្គលដទៃធ្វើ បុគ្គលដទៃធ្វើបុគ្គលដទៃទទួលរង ( នូវសុខ ទុក្ខ ) បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃបានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អ្នកធ្វើបាបដោយខ្លួនឯង ។បេ។ អ្នកដទៃនឹងជម្រះអ្នកដទៃឲ្យស្អាតពុំបានឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃបានទេ ។

[ ២២២ ] បុគ្គលមិនគួរពោលថា បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃបានទេឬ ។ អើ ។ ក្រែងពួកជនអ្នកដល់នូវកម្លាំងមាន ពួកជនអ្នកស្ទាត់ជំនាញ មានដែរឬ ។ អើ ។ ប្រសិនបើ ពួកជនអ្នកដល់នូវកម្លាំងក៏មាន ពួកជនអ្នកស្ទាត់ជំនាញក៏មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលដទៃ ទំនុកបម្រុងចិត្តរបស់បុគ្គលដទៃបាន ។

**បគ្គហកថា ចប់**

# អដ្ឋកថា

## និគ្គហកថា ( *ជាដើម* )

*[ ២០៨ ] ឥឡូវនេះ នឹងពណ៌នាអំពីការសង្កត់សង្កិនចិត្តដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា បុគ្គលណា មានកម្លាំង មានការជំនាញ ក្នុងឈាន ក្នុងលោក បើបុគ្គលនោះ មិនអាចសង្កត់ចិត្តរបស់អ្នកដទៃបានសោត ការមានកម្លាំង ឬការជំនាញក្នុងឈាន នឹងមានប្រយោជន៍អ្វីដល់ជនទាំងនោះ ។ ព្រោះភាពជាអ្នកមានកម្លាំង និងភាពជំនាញក្នុងឈាន ទើបបុគ្គលទាំងនោះសង្កត់ចិត្តរបស់បុគ្គលដទៃបានពិតប្រាកដ ដូច្នេះ ពាក្យសួររបស់សកវាទីថា* **បរោបរស្ស** *ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បណ្ដាបទទាំងនោះ បទថា* **និគ្គណ្ហាតិ** *បានដល់ ហាមចិត្តមិនឲ្យធ្លាក់ទៅកាន់សង្កិលេស ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ។*

*[ ២១៥ ] ក្នុងកថាពោលអំពីបគ្គហៈ គឺការទំនុកបម្រុងចិត្ត ក៏មានន័យនេះដូចគ្នា ។៚*

**អដ្ឋកថានិគ្គហកថា ( ជាដើម ) ចប់**

# អភិធម្មបិដក

## សុខានុប្បទានកថា

[ ២២៣ ] បុគ្គលដទៃ ប្រគល់សេចក្តីសុខឲ្យដល់បុគ្គលដទៃ បានដែរ ឬ ។ អើ ។ បុគ្គលដទៃ ប្រគល់សេចក្តីទុក្ខឲ្យដល់អ្នកដទៃ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ ប្រគល់សេចក្តីសុខឲ្យដល់បុគ្គលដទៃ មិនបានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ ប្រគល់សេចក្តីសុខឲ្យដល់បុគ្គលដទៃ បានដែរឬ ។ អើ ។ បុគ្គលដទៃប្រគល់សេចក្តីសុខរបស់ខ្លួន ប្រគល់សេចក្តីសុខរបស់ពួកជនដទៃ ប្រគល់សេចក្តីសុខរបស់បុគ្គលនោះដល់បុគ្គលដទៃ បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃ ប្រគល់សេចក្តីសុខរបស់ខ្លួនមិនបាន ប្រគល់សេចក្តីសុខរបស់ពួកជនដទៃមិនបាន ប្រគល់សេចក្តីសុខរបស់បុគ្គលនោះឲ្យដល់បុគ្គលដទៃ មិនបានទេឬ ។ អើ ។ ប្រសិនបើ បុគ្គលដទៃ ប្រគល់សេចក្តីសុខរបស់ខ្លួនមិនបាន ប្រគល់សេចក្តីសុខរបស់ពួកជនដទៃមិនបាន ប្រគល់សេចក្តីសុខរបស់បុគ្គលនោះ ឲ្យដល់បុគ្គលដទៃមិនបានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលដទៃ ប្រគល់សេចក្តីសុខឲ្យដល់បុគ្គលដទៃបានទេ ។

[ ២២៤ ] បុគ្គលដទៃ ប្រគល់សេចក្តីសុខឲ្យដល់បុគ្គលដទៃ បានដែរ ឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើនូវអំពើដល់បុគ្គលដទៃ សុខ ទុក្ខ ដែលបុគ្គលដទៃធ្វើ បុគ្គលដទៃធ្វើ បុគ្គលដទៃទទួលរង ( នូវសុខ ទុក្ខ ) បានដែរ

ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៥ ] បុគ្គលមិនគួរនិយាយថា បុគ្គលដទៃ ប្រគល់សេចក្ដីសុខឲ្យដល់បុគ្គលដទៃ បានទេឬ ។ អើ ។ ក្រែងព្រះឧទាយិត្ថេរមានអាយុ បានពោលដូច្នេះហើយថា ឱហ្ន៎ ព្រះមានព្រះភាគ ទ្រង់កម្ចាត់បង់នូវទុក្ខធម៌ទាំងឡាយជាច្រើនដល់ពួកយើង ឱហ្ន៎ ព្រះមានព្រះភាគ ទ្រង់បង្អោនចូលមក នូវសុខធម៌ទាំងឡាយជាច្រើនដល់ពួកយើង ឱហ្ន៎ ព្រះមានព្រះភាគ ទ្រង់កម្ចាត់បង់នូវអកុសលធម៌ទាំងឡាយជាច្រើន ដល់ពួកយើង ឱហ្ន៎ ព្រះមានព្រះភាគទ្រង់បង្អោនចូលមកនូវកុសលធម៌ទាំងឡាយជាច្រើន ដល់ពួកយើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលដទៃ ប្រគល់សេចក្ដីសុខ ឲ្យដល់បុគ្គលដទៃបាន ។

សុខានុប្បទានកថា ចប់

# អដ្ឋកថា

## សុខានុប្បទានកថា

[ ២២៣ ] ឥឡូវនេះ នឹងពណ៌នាអំពីការប្រគល់សេចក្តីសុខដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទថា បុគ្គលដទៃ ប្រគល់សេចក្តីសុខឲ្យដល់បុគ្គលដទៃបាន ព្រោះអាស្រ័យព្រះសូត្រ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ដែលព្រះឧទាយិត្ថេរពោលថា ឱហ្ន៎ ព្រះមានព្រះភាគ ទ្រង់បង្អោនចូលមកនូវសុខធម៌ទាំងឡាយជាច្រើនដល់ពួកយើងជាដើម ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បរវាទី ត្រូវសកវាទីសួរថា **ឧក្ខំ អនុប្បទេតិ** កាលមិនឃើញបទព្រះសូត្របែបនោះទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាថា **អត្តនោ សុខំ** សេចក្តីថា បរវាទីឆ្លើយបដិសេធ ដោយគិតថា បុគ្គលណាម្នាក់ មិនអាចប្រគល់សេចក្តីសុខរបស់ខ្លួន ឬរបស់អ្នកដទៃ ឲ្យដល់បុគ្គលណាម្នាក់បានឡើយ សេចក្តីសុខណា ក៏ជារបស់បុគ្គលនោះឯង ឈ្មោះថា ការប្រគល់សេចក្តីសុខអ្វីក្នុងសេចក្តីសុខនេះ ។ ចំណែកក្នុងបញ្ហាថា **ឆេវត្តនោ** ជាដើម បរវាទីឆ្លើយទទួលតាម

លទ្ធិថា ឈ្មោះថា ការប្រគល់សេចក្ដីសុខបែបនេះ មិនអាចមាន ។ បទថា **ឆោ ច វត រេ** សកវាទីពោលហើយ ព្រោះមិនមានសេចក្ដីសុខបែបនោះ ។ ព្រះបាលីថា **សុខធម្មានំ ឱបហាត្តា** ជាដើម រមែងសម្ដែងនូវកាលដែលព្រះមានព្រះភាគ ទ្រង់ជាបច្ច័យ ដើម្បីឲ្យកើតសេចក្ដីសុខដល់ជនដទៃ មិនមែនសម្ដែងសេចក្ដីសុខឲ្យ ដូចការឲ្យវត្ថុផ្សេងៗ មានអាហារជាដើមឡើយ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាង ដោយប្រការដូច្នេះ ។

**អដ្ឋកថាសុខានុប្បទានកថា ចប់**

# អភិធម្មបិដក

## អធិគ្គយ្ហមនសិការកថា

[ ២២៦ ] បុគ្គលត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្តឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវចិត្តនោះ ដោយចិត្តនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដឹងច្បាស់នូវចិត្តនោះ ដោយចិត្តនោះឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវចិត្តនោះ ដោយចិត្តនោះថា ចិត្ត ដូច្នេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដឹងច្បាស់នូវចិត្តនោះ ដោយចិត្តនោះថា ចិត្ត ដូច្នេះឬ ។ អើ ។ ចិត្តនោះ ជាអារម្មណ៍របស់ចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចិត្តនោះ ជាអារម្មណ៍របស់ចិត្តនោះឬ ។ អើ ។ បុគ្គលពាល់ត្រូវនូវផស្សៈនោះ ដោយផស្សៈនោះ ដោយវេទនានោះ ។បេ។ ដោយសញ្ញានោះ ។បេ។ ដោយចេតនានោះ ។បេ។ ដោយចិត្តនោះ ។បេ។ ដោយវិតក្កនោះ ។បេ។ ដោយវិចារនោះ ។បេ។ ដោយបីតិនោះ ។បេ។ ដោយសតិនោះ ។បេ។ ដឹងច្បាស់នូវបញ្ញានោះ ដោយបញ្ញានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្តនូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត ធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវអតីតថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត ធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំង ៣ ។បេ។ នៃចិត្តទាំងបីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីតដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត តែងធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត តែងធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត តែងធ្វើ

ទុកក្នុងចិត្ត នូវអតីត ថាជាអតីត ធ្វើទុកក្នុងចិត្តនូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគត តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត ធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្នដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងបី ។បេ។ នៃចិត្តទាំងបីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីតដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្នថា ជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអតីតថា ជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគតថា ជាអនាគតដែរឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំងបី ។បេ។ នៃចិត្តទាំងបីឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៧ ] បុគ្គលមិនគួរនិយាយថា បុគ្គលត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង មិនទៀង ដូច្នេះ ក្នុងកាលណា រមែងនឿយណាយចំពោះទុក្ខ ក្នុងកាលនោះឯង នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង ជាទុក្ខ ដូច្នេះ ក្នុងកាលណា រមែងនឿយណាយចំពោះទុក្ខ ក្នុងកាលនោះឯង នេះជាផ្លូវប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធ បុគ្គលឃើញច្បាស់ដោយបញ្ញាថា ធម៌ទាំងឡាយទាំងពួង ជាអនត្តា ដូច្នេះ ក្នុងកាលណា រមែងនឿយណាយចំពោះទុក្ខ ក្នុងកាលនោះឯង នេះជាផ្លូវប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះបុគ្គលត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្តមែន ។

**អធិគ្គយ្ហមនសិការកថា ចប់**

# អដ្ឋកថា

## អធិគ្គយ្ហមនសិការកថា

[ ២២៦ ] ឥឡូវនេះ នឹងពណ៌នារឿងបុគ្គលត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្តដូចតទៅ

ក្នុងរឿងនោះ មនសិការ មាន ២ យ៉ាង គឺ **ឈយតោមនសិការ ១ អារម្មណតោមនសិការ ១** ។ ក្នុងមនសិការ ២ យ៉ាងនោះ បើបុគ្គលឃើញសង្ខារឯណានីមួយ ដោយភាពជារបស់មិនទៀងហើយ បុគ្គលនោះ ជាអ្នកឈ្មោះថា មនសិការក្នុងសង្ខារទាំងឡាយដ៏សេស ដោយន័យថា សង្ខារទាំងពួងមិនទៀងហ្ន៎ ដូច្នេះ ។ តែកាលមនសិការសង្ខារទាំងឡាយដែលជាអតីត បុគ្គលមិនអាចមនសិការសង្ខារទាំងឡាយដែលជាអនាគតបាន ។ កាលបុគ្គលមនសិការសង្ខារឯណានីមួយ ក្នុងសង្ខារដែលជាអតីតជាដើម បុគ្គលនោះរមែងជាបុគ្គល ឈ្មោះថា មនសិការដោយអារម្មណ៍ ។ បណ្ដាមនសិការទាំងនោះ បុគ្គលកាលមនសិការក្នុងបច្ចុប្បន្ន រមែងមនសិការសង្ខារទាំងឡាយដោយចិត្តណា បុគ្គលនោះ មិនអាចមនសិការចិត្តនោះ ក្នុងបច្ចុប្បន្នខណៈបានឡើយ ។

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយបរសេលិយៈទាំងឡាយថា បុគ្គលឈ្មោះថា កាលមនសិការ រមែងមនសិការសង្ខារទាំងពួង ដោយការកាន់យកការត្រាស់ដឹងដូច្នេះ ព្រោះអាស្រ័យបាលីថា សង្ខារទាំងឡាយ មិនទៀងហ្ន៎ ដូច្នេះជាដើម

ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះ ដោយភាពជាអ្នកមានចិត្តនោះ ព្រោះភាពដែលបុគ្គល រមែងមនសិការសង្ខារទាំងពួងនោះ ដោយមនសិការរួមគ្នាដោយចិត្តណា សូម្បីចិត្តនោះ ក៏គប្បីត្រូវមនសិការ ទើបពោលពាក្យថា **តេន ចិត្តេន** ជាដើម ។ បរវាទីឆ្លើយបដិសេធ ដោយសំដៅយកថា បុគ្គលណាម្នាក់ មិនអាចដឹងចំពោះនូវការធ្វើឲ្យជាអារម្មណ៍ តែឆ្លើយទទួល ដោយសំដៅយកថា ចិត្តនោះ រមែងជាវត្ថុដែលត្រូវដឹងបាននោះឯង ព្រោះចិត្តត្រូវដឹងបានថា ចិត្ត មានលក្ខណៈយ៉ាងនេះ ។

ម្យ៉ាងទៀត បរវាទីរមែងឆ្លើយបដិសេធ ដោយគិតថា ចិត្តនោះឯង មិនជាអារម្មណ៍របស់ចិត្តនោះ តែរមែងឆ្លើយទទួល ដោយអំណាចនៃលទ្ធិដែលកើតឡើង ព្រោះអាស្រ័យព្រះបាលីថា កាលណាឃើញដោយបញ្ញាថា សង្ខារទាំងពួងមិនទៀងជាដើម ។ បញ្ហាដ៏សេស ២ ទៀត ក៏ន័យនេះឯង ។ ឯក្នុងពាក្យទាំងឡាយថា **តេន ជស្សេន** បរវាទីកាលមិនឃើញព្រះសូត្របែប

នោះ ទើបឆ្លើយបដិសេធ ។ ដោយហេតុនោះឯង ក្នុងបញ្ហាទាំងឡាយ មានអតីតកាលជាដើម បណ្ឌិតគប្បីជ្រាបការបដិសេធ និងការឆ្លើយទទួល ដោយន័យដែលពោលមកហើយខាងដើមនោះឯង ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនោះឯង ។

[ ២២៧ ] ព្រះបាលីថា **សព្វេ សង្ខារា** ជាដើម ព្រះមានព្រះភាគត្រាស់សំដៅដល់ការឃើញដោយន័យ មិនមែនការឃើញដោយអារម្មណ៍ក្នុងខណៈជាមួយគ្នា ព្រោះហេតុនោះ ទើបព្រះសូត្រនោះ មិនមែនជាគោលអាង ដូច្នេះ ។ល។

**អដ្ឋកថាអធិគ្គយ្ហមនសិការកថា ចប់**

# អភិធម្មបិដក

## រូបហេតុកថា

[ ២២៨ ] រូប ជាហេតុឬ ។ អើ ។ អលោភៈ ជាហេតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អទោសៈ ជាហេតុឬ ។បេ។ អមោហៈ ជាហេតុ លោភៈ ជាហេតុ ទោសៈ ជាហេតុ មោហៈ ជាហេតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប ជាហេតុឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាហេតុទេ ។

[ ២២៩ ] អលោភៈ ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអលោភៈនោះ មានដែរឬ ។ អើ ។ រូប ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អទោសៈ ជាហេតុ អមោហៈ ជាហេតុ លោភៈ ជាហេតុ ទោសៈ ជាហេតុ មោហៈ ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះមោហៈនោះ មានដែរឬ ។ អើ ។ រូប ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣០ ] រូប ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អលោភៈ ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អទោសៈ ជាហេតុ អមោហៈ ជាហេតុ លោភៈ ជាហេតុ ទោសៈ ជាហេតុ មោហៈ ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះមោហៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣១ ] បុគ្គលមិនគួរនិយាយថា រូប ជាហេតុទេឬ ។ អើ ។ ក្រែងមហាភូតជាហេតុ ជាទីអាស្រ័យរបស់ពួកឧបាទាយរូបឬ ។ អើ ។ ប្រសិនបើមហាភូត ជាហេតុ ជាទីអាស្រ័យរបស់ពួកឧបាទាយរូប ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជាហេតុមែន ។

រូបហេតូតិកថា ចប់

# អដ្ឋកថា

## រូបហេតុតិកថា

[ ២២៨ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបជាហេតុដូចតទៅ

ក្នុងរឿងនោះ បទថា **ហេតុ** បានដល់ ហេតុ ដែលជាឈ្មោះរបស់ហេតុ មានកុសលមូលជាដើមខ្លះ ដែលជាឈ្មោះរបស់បច្ច័យណាមួយខ្លះ ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា រូប ជាហេតុ ដោយមិនប្លែកគ្នាឡើយ ព្រោះអាស្រ័យត្រឹមតែព្រះបាលីថា មហាភូតរូប ៤ ជាហេតុ ដូច្នេះ ព្រោះមិនញែកអត្ថយ៉ាងនេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **អលោភោ ហេតុ** សេចក្តីថា សកវាទីរមែងសួរថា រូប ជាហេតុ ពោល គឺអលោភៈ តាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធ ។ ក្នុងបញ្ហាដ៏សេស ក៏ន័យនេះឯង ។

[ ២៣១ ] ក្នុងបទថា **មហាភូតា ឧបាទាយរូបានំ ឧបាទាយហេតុ** នេះ ពោលដល់ភាពជាហេតុ ព្រោះអត្ថថា ជាបច្ច័យ មិនបានពោលភាពជាហេតុ ព្រោះអត្ថថា ជាមូលឡើយ ព្រោះហេតុនោះ ទើបពាក្យនេះ មិនមែនជាគោលអាង ដូច្នេះ ។

**អដ្ឋកថារូបហេតុតិកថា ចប់**

# អភិធម្មបិដក

## រូបសហេតុកន្តិកថា

[ ២៣២ ] រូប ប្រកបដោយហេតុឬ ។ អើ ។ រូប ( ប្រកប ) ដោយហេតុ គឺអលោភៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយហេតុ គឺអទោសៈ ។បេ។ ដោយហេតុ គឺអមោហៈ ។បេ។ ដោយហេតុ គឺលោភៈ ។បេ។ ដោយហេតុ គឺទោសៈ ។បេ។ ដោយហេតុ គឺមោហៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៣ ] រូប ប្រកបដោយហេតុឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ប្រកបដោយហេតុទេ ។

[ ២៣៤ ] អលោភៈ ប្រកបដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអលោភៈនោះ មានដែរឬ ។ អើ ។ រូប ប្រកបដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អទោសៈ ប្រកបដោយហេតុ ។បេ។ អមោហៈ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា លោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ

អនោត្តប្បៈ ប្រកបដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអនោត្តប្បៈនោះ មានដែរឬ ។ អើ ។ រូប ប្រកបដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៥ ] រូប ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អលោភៈ ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អទោសៈ ប្រកបដោយហេតុ ។បេ។ អនោត្តប្បៈ ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអនោត្តប្បៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៦ ] បុគ្គលមិនគួរនិយាយថា រូប ប្រកបដោយហេតុទេឬ ។ អើ ។ ក្រែងរូបប្រកបដោយបច្ច័យឬ ។ អើ ។ ប្រសិនបើ រូបប្រកបដោយបច្ច័យមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបប្រកបដោយហេតុមែន ។

## រូបសហេតុកន្តិកថា ចប់

# អដ្ឋកថា

## រូបសហេតុកន្តិកកថា

[ ២៣២ ] ក្នុងកិច្ចពណ៌នាកថា អំពីរូបប្រកបដោយហេតុ បណ្ឌិតគប្បី ជ្រាបអត្ថដោយន័យដូចពោលហើយ ក្នុងអដ្ឋកថា រូបំ ហេតូតិកថា នោះឯង ដូច្នេះ ។

**អដ្ឋកថារូបសហេតុកន្តិកកថា ចប់**

# អភិធម្មបិដក

## រូបកុសលាកុសលផ្តិកថា

[ ២៣៧ ] រូប ជាកុសលឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាកុសលទេ ។

[ ២៣៨ ] អលោភៈ ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអលោភៈនោះ មានដែរឬ ។ អើ ។ រូប ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អទោសៈ ជាកុសល ។បេ។ អមោហៈ ជាកុសល ។បេ។ សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញា ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះបញ្ញានោះ មានដែរឬ ។ អើ ។ រូប ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៩ ] រូប ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អលោភៈ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអលោភៈនោះ មិនមានទេ

ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អទោសះ ជាកុសល ។បេ។ បញ្ញា ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះបញ្ញានោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤០ ] រូប ជាអកុសលឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាអកុសលទេ ។បេ។

[ ២៤១ ] លោភះ ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះលោភះនោះ មានដែរឬ ។ អើ ។ រូប ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទោសះ មោហះ មានះ ។បេ។ អនោត្តប្បៈ ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអនោត្តប្បៈនោះ មានដែរឬ ។ អើ ។ រូប ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤២ ] រូប ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការ

តាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ លោភៈ ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ទោសៈ មោហៈ មានះ ។បេ។ អនោត្តប្បៈ ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះអនោត្តប្បៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៣ ] បុគ្គលមិនគួរនិយាយថា រូប ជាកុសលក៏មាន ជាអកុសលក៏មានទេឬ ។ អើ ។ ក្រែងកាយកម្ម និងវចីកម្ម ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ប្រសិនបើ កាយកម្ម និងវចីកម្ម ជាកុសលក៏មាន ជាអកុសលក៏មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជាកុសលក៏មាន ជាអកុសលក៏មាន ។

## រូបកុសលាកុសលន្តិកថា ចប់

# អដ្ឋកថា

## រូបកុសលាកុសលត្ថិកថា

[ ២៣៧ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបជាកុសល និងអកុសលតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិដូចលទ្ធិនៃនិកាយមហិសាសកៈ និងនិកាយសមិតិយៈទាំងឡាយថា កាយវិញ្ញត្តិរូប និងវចីវិញ្ញត្តិរូប ពោល គឺកាយកម្ម និងវចីកម្ម ជាកុសលខ្លះ ជាអកុសលខ្លះ ព្រោះអាស្រ័យព្រះបាលីថា កាយកម្ម វចីកម្ម ជាកុសលក៏មាន ជាអកុសលក៏មាន ដូច្នេះ ពាក្យសួររបស់សកវាទីថា **រូបំ កុសលំ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើតាមលទ្ធិរបស់អ្នក រូប ជាកុសលសោត រូបនោះ ក៏គប្បីជាសការម្មណៈផ្សេងៗ បែបនេះ ទើបពោលពាក្យថា **សារម្មណំ** ជាដើម ក្នុងបញ្ហាពោលដោយអកុសលខាងមុខ ក៏មានន័យនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថារូបកុសលាកុសលត្ថិកថា ចប់**

# អភិធម្មបិដក

## រូបវិបាកកោតិកថា

[ ២៨៤ ] រូប ជាវិបាកឬ ។ អើ ។ រូប គួរដល់ការវេទនាសុខ គួរដល់ការវេទនាទុក្ខ គួរដល់ការវេទនាអទុក្ខមសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ។បេ។ ប្រកបដោយចិត្ត ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាវិបាកទេ ។

[ ២៨៥ ] ផស្សៈ ជាវិបាក ផស្សៈ គួរដល់ការវេទនាសុខ គួរដល់ការវេទនាទុក្ខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះផស្សៈនោះ មានដែរឬ ។ អើ ។ រូប ជាវិបាក រូប គួរដល់ការវេទនាសុខ គួរដល់ការវេទនាទុក្ខ ។បេ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៦ ] រូប ជាវិបាក រូប មិនគួរដល់ការវេទនាសុខ មិនគួរដល់ការវេទនាទុក្ខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះរូបនោះ

មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាក ផស្សៈ មិនគួរដល់ការវេទសុខ មិនគួរដល់ការវេទទុក្ខ ។បេ។ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៧ ] បុគ្គលមិនគួរនិយាយថា រូប ជាវិបាកទេឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ ប្រកបដោយចិត្ត និងចេតសិក ដែលកើតឡើង ព្រោះធ្វើនូវកម្មជាវិបាកឬ ។ អើ ។ ប្រសិនបើ ធម៌ទាំងឡាយ ប្រកបដោយចិត្ត និងចេតសិក ដែលកើតឡើង ព្រោះធ្វើនូវកម្មជាវិបាកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបដែលកើតឡើង ព្រោះធ្វើនូវកម្មជាវិបាក ។

### រូបវិបាកោតិកថា ចប់

# អដ្ឋកថា

## រូបវិចារកោតិកថា

[ ២៤៤ ] ឥឡូវនេះ នឹងពណ៌នារូបជាវិបាកដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយសមិតិយៈទាំងឡាយថា រូបណា ដែលកើតឡើងហើយ ព្រោះធ្វើនូវកម្ម ដូចចិត្ត និងចេតសិក ដែលកើតឡើងហើយ ព្រោះធ្វើកម្ម រូបនោះ ក៏ជាវិបាក ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើតាមលទ្ធិរបស់អ្នក រូប ជាវិបាកសោត រូបនោះ ក៏គប្បីជាសភាវៈផ្សេងៗ បែបនេះ ទើបពោលពាក្យថា **សុខវេទនីយំ** ជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ៗ។

**អដ្ឋកថារូបវិចារកោតិកថា ចប់**

# អភិធម្មបិដក

## រូបរូបាវចរារូបាវចរន្តិកកថា

[ ២៤៨ ] រូប ជារូបាវចរ មានដែរឬ ។ អើ ។ រូប ស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ចិត្តដែលមិនស្វែងរកកំណើត ចិត្តដែលមិននៅជាសុខក្នុងបច្ចុប្បន្នឬ ។ អើ ។ ប្រសិនបើរូបមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជារូបាវចរ មានទេ ។

[ ២៤៩ ] រូប ជាអរូបាវចរ មានដែរឬ ។ អើ ។ រូបដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែង

រកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ។បេ។ មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិឬ ។ អើ ។ ប្រសិនបើ រូបមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត ។បេ។ មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាអរូបាវចរ មានទេ ។

[ ២៥០ ] បុគ្គលមិនគួរនិយាយថា រូប ជារូបាវចរក៏មាន រូប ជាអរូបាវចរក៏មានឬ ។ អើ ។ ក្រែងរូបជាកាមាវចរ ព្រោះធ្វើកម្មជាកាមាវចរឬ ។ អើ ។ ប្រសិនបើ រូប ជាកាមាវចរ ព្រោះធ្វើកម្មជាកាមាវចរមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជារូបាវចរ ព្រោះធ្វើកម្ម ជារូបាវចរ រូប ជាអរូបាវចរ ព្រោះធ្វើកម្ម ជាអរូបាវចរដែរ ។

### រូបរូបាវចរារូបាវចរន្តិកថា ចប់

# អដ្ឋកថា

## រូបរូបាវចរារូបាវចរន្តិកថា

[ ២៤៨ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបជារូបាវចរ និងអរូបាវចរតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ ទាំងឡាយថា ព្រោះរូបដែលកើតឡើង ព្រោះធ្វើកម្មដែលជាចំណែកកាមាវចរ រមែងជាកាមាវចរ ព្រោះហេតុនោះ រូប ក៏គប្បីជារូបាវចរ និងអរូបាវចរ ព្រោះធ្វើកម្មដែលជាចំណែករូបាវចរ និងអរូបាវចរ ដូច្នេះ ពាក្យសួររបស់សកវាទី ថា **អត្ថិ រូបំ រូបាវចរារូបាវចរំ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យតាមដែលពោល ហើយខាងដើមនោះឯង ។ល។

**អដ្ឋកថារូបរូបាវចរារូបាវចរន្តិកថា ចប់**

# អភិធម្មបិដក

## រូបភាគរូបធាតុបរិយាយឆ្នោតិអាធិកថា

[ ២៥១ ] រូបភាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ រូបភាគៈដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបភាគៈ មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ទេឬ ។ អើ ។ ប្រសិនបើ រូបភាគៈ មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបភាគៈ រាប់បញ្ចូលក្នុងរូបធាតុទេ ។

[ ២៥២ ] រូបភាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ សទ្ទភាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបភាគៈ រាប់បញ្ចូលក្នុងរូបធាតុដែរឬ ។ អើ ។ គន្ធភាគៈ ។បេ។ រសភាគៈ ។បេ។ ផោដ្ឋព្វភាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៣ ] បុគ្គលមិនគួរនិយាយថា សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬទេ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរនិយាយថា គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬទេ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៤ ] អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុឬ ។ អើ ។ អរូបរាគៈដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអរូបរាគៈដែលមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ឬ ។ អើ ។ ប្រសិនបើ អរូបរាគៈ ដែលមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់

ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ចិត្តដែលមិនស្វែងរកកំណើត ចិត្តដែលមិនទៅជាសុខក្នុងបច្ចុប្បន្ន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេ ។

[ ២៥៥ ] អរូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុដែរឬ ។ អើ ។ គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៦ ] បុគ្គលមិនគួរនិយាយថា សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុទេឬ ។ អើ ។ បុគ្គលមិនគួរពោលថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរនិយាយថា គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៧ ] បុគ្គលមិនគួរនិយាយថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អើ ។ ក្រែងកាមរាគៈ រាប់បញ្ចូលកាមធាតុឬ ។ អើ ។ ប្រសិនបើ កាមរាគៈ រាប់បញ្ចូលក្នុងកាមធាតុមែន

ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុបាន ។

រូបរាគរូបធាតុបរិយាបន្នោតិអាទិកថា ចប់

សោឡសមវគ្គ ចប់

## ឧទ្ទាននៃសោឡសមវគ្គនោះ គឺ

និយាយអំពីការសង្កត់សង្កិនចិត្ត ១ ការទំនុកបម្រុងចិត្ត ១ ការប្រគល់ឲ្យនូវសេចក្ដីសុខ ១ ការត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្ត ១ រូបជាហេតុ ១ រូបប្រកបដោយហេតុ ១ រូបជាកុសលក៏មាន ជាអកុសលក៏មាន ១ រូបជាវិបាក ១ រូបជារូបាវចរក៏មាន រូបជាអរូបាវចរក៏មាន ១ កិលេសទាំងអស់ រាប់បញ្ចូលក្នុងកាមធាតុ ១ ។

# អដ្ឋកថា

## រូបរាគរូបធាតុបរិយាយឆ្នោតិអាធិកថា

[ ២៥១ ] ឥឡូវនេះ នឹងពណ៌នាអំពីរូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រោះកាមរាគៈ រាប់បញ្ចូលក្នុងកាមធាតុ ហេតុនោះ រូបរាគៈទាំងឡាយ ក៏គប្បីរាប់បញ្ចូលក្នុងរូបធាតុ និងអរូបធាតុ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ម្យ៉ាងទៀត ក្នុងបញ្ហានេះ ការផ្សេងគ្នានៃបទ មានត្រឹមប៉ុណ្ណេះថា រូបរាគៈរមែងដេកត្រាំក្នុងរូបធាតុ ឯអរូបរាគៈ រមែងដេកត្រាំក្នុងអរូបធាតុ ។ លទ្ធិនោះ ជារបស់និកាយអន្ធកៈទាំងឡាយផង របស់និកាយសមិតិយៈទាំងឡាយផង តែបញ្ហានេះ ជារបស់និកាយអន្ធកៈទាំងឡាយប៉ុណ្ណោះ ។៚

**អដ្ឋកថារូបរាគរូបធាតុបរិយាយឆ្នោតិអាធិកថា ចប់**

**វគ្គទី ១៦ ចប់**

# អភិធម្មបិដក

## អត្ថិអរហតោបុញ្ញូបចយោតិកថា

[ ២៥៨ ] ការសន្សំបុណ្យរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ការសន្សំបាបរបស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសន្សំបាបរបស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ការសន្សំបុណ្យរបស់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៩ ] ការសន្សំបុណ្យរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្តតាក់តែងបុញ្ញាភិសង្ខារ តាក់តែងអានេញ្ជាភិសង្ខារ ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីគតិ ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភព ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីបច្ច័យដ៏ក្រៃលែង ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភោគៈច្រើន ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីមានបរិវារច្រើន ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភាពដ៏ល្អលើសលែងក្នុងទេវលោក ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភាពដ៏ល្អលើសលែង ក្នុងមនុស្សលោកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦០ ] ការសន្សំបុណ្យរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្តសន្សំទុកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តមិនមានការសន្សំទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តលះបង់ ។បេ។ ព្រះអរហន្តប្រកាន់ខ្ជាប់ ។បេ។ ព្រះអរហន្តកកាយចេញ ។បេ។ ព្រះអរហន្ត ប្រមូលយក ។បេ។ ព្រះអរហន្តកម្ចាត់ចេញ ។បេ។ ព្រះអរហន្តក្រសោវយកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត

មិនសន្សំ មិនមែនជាមិនសន្សំ គឺលែងសន្សំហើយ ស្ថិតនៅឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្តមិនសន្សំ មិនមែនជាមិនសន្សំ គឺលែងសន្សំហើយ ស្ថិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យរបស់ព្រះអរហន្ត មានទេ ។

[ ២៦១ ] ក្រែងព្រះអរហន្តមិនលះបង់ មិនប្រកាន់ខ្ជាប់ លុះលះបង់ហើយ ស្ថិតនៅ មិនកកាយចេញ មិនប្រមូលយក លុះកកាយចេញហើយ ស្ថិតនៅ មិនកម្ចាត់ចេញ មិនក្រសាវយក លុះកម្ចាត់ចេញហើយ ស្ថិតនៅឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្តមិនកម្ចាត់ចេញ មិនក្រសាវយក លុះកម្ចាត់ចេញហើយ ស្ថិតនៅមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យរបស់ព្រះអរហន្ត មានទេ ។

[ ២៦២ ] ការសន្សំបុណ្យរបស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ព្រះអរហន្តគប្បីឲ្យទានដែរឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្តគប្បីឲ្យទានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យរបស់ព្រះអរហន្ត មិនមានទេ ។

[ ២៦៣ ] ព្រះអរហន្ត គប្បីឲ្យចីវរ ។បេ។ គប្បីឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យវត្ថុគួរទំពាស៊ី ឲ្យវត្ថុគួរបរិភោគ ឲ្យទឹកគួរផឹក ថ្វាយបង្គំចេតិយ លើកឡើងនូវផ្កាកម្រង លើកឡើងនូវគ្រឿងក្រអូប លើកឡើងនូវគ្រឿងលាបឮដ៏ចេតិយ ។បេ។ គប្បីធ្វើអភិទក្សិណាចេតិយដែរឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត គប្បីធ្វើអភិទក្សិណាចេតិយដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យរបស់ព្រះអរហន្ត មិនមានទេ ។

## អត្ថិអរហតោបុញ្ញូបចយោតិកថា ចប់

# អដ្ឋកថា

## អត្ថិអរហតោបុញ្ញូបចយោតិកថា

[ ២៥៨ ] ឥឡូវនេះ នឹងពណ៌នាការសន្សំបុណ្យរបស់ព្រះអរហន្តទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ការសន្សំបុណ្យរបស់ព្រះអរហន្តមាន ព្រោះអាស្រ័យកម្ម មានការឲ្យទាន និងការថ្វាយបង្គំព្រះចេតិយជាដើមរបស់ព្រះអរហន្ត ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា ឈ្មោះថា ព្រះអរហន្តជាអ្នកលះបុណ្យ និងបាបបានហើយ បើព្រះអរហន្តគប្បីធ្វើបុណ្យសោត ក៏គប្បីធ្វើបាបបាន ដូច្នេះ ទើបពោលពាក្យថា **អបុញ្ញូ-បចយោ** បរវាទីកាលមិនឃើញការធ្វើបាណាតិបាតជាដើម ក៏ឆ្លើយបដិសេធ ។

[ ២៥៩ ] ក្នុងបទថា **បុញ្ញាភិសង្ខារំ** ជាដើម បរវាទីឆ្លើយបដិសេធ ដោយគិតថា កម្មដែលជាហេតុនាំទៅកាន់ភពរបស់ព្រះអរហន្ត មិនមាន ។

[ ២៦២ ] ក្នុងបទថា **ទានំ ទទេយ្យ** ជាដើម សកវាទីឆ្លើយទទួល ព្រោះការប្រព្រឹត្តទៅនៃទានជាដើមរបស់ព្រះអរហន្ត មានដោយកិរិយាចិត្ត តែបរវាទីមិនកាន់យកចិត្ត ទើបឲ្យលទ្ធិរបស់ខ្លួន តាំងនៅដោយការសម្តែងត្រឹមតែការប្រព្រឹត្តទៅនៃការធ្វើ ។ ទោះជាយ៉ាងនោះ លទ្ធិនោះ ក៏តាំងនៅមិនបាន ព្រោះតាំងទុកដោយអយោនិសោមនសិការ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថាអត្ថិអរហតោបុញ្ញូបចយោតិកថា ចប់**

# អភិធម្មបិដក

## ឆដ្ឋិ អរហតោ អកាលមច្ចុតិកថា

[ ២៦៤ ] សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មានដែរឬ ។ អើ ។ សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បុគ្គលណា ផ្តាច់បង់ព្រះអរហន្តចាកជីវិត បុគ្គលនោះ កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិត កាលបើជីវិតមិនមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរឬ ។ ( បុគ្គលនោះ ) កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិត ។ ប្រសិនបើ ( បុគ្គលនោះ ) កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មិនមានទេ ។ ( បុគ្គលនោះ ) កាលបើជីវិតមិនមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៥ ] សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ថ្នាំពិសមិនគប្បីចូលទៅ គ្រឿងសស្រ្តាមិនគប្បីមុត ភ្លើងមិនគប្បីឆេះចំពោះកាយរបស់ព្រះអរហន្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ក្រែងថ្នាំពិសគប្បីចូលទៅ គ្រឿងសស្ត្រាគប្បីមុត ភ្លើងគប្បីឆេះចំពោះកាយរបស់ព្រះអរហន្តដែរឬ ។ អើ ។ ប្រសិនបើ ថ្នាំពិសគប្បីចូលទៅ គ្រឿងសស្ត្រាគប្បីមុត ភ្លើងគប្បីឆេះ ចំពោះកាយរបស់ព្រះអរហន្តដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្តមិនមានទេ ។

[ ២៦៦ ] ថ្នាំពិសមិនគប្បីចូលទៅ គ្រឿងសស្ត្រាមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយរបស់ព្រះអរហន្តទេឬ ។ អើ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៧ ] សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលថា កម្មទាំងឡាយប្រកបដោយចេតនា ដែលសត្វធ្វើហើយសន្សំហើយ អស់ទៅ ព្រោះតែមិនបានទទួលផលដូច្នេះឡើយ កម្មនោះឯងគប្បីឲ្យផលក្នុងបច្ចុប្បន្ន ឬក្នុងអត្តភាពជាលំដាប់ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្តីស្លាប់ក្នុងកាលមិនគួររបស់ព្រះអរហន្ត មិនមានទេ ។

**នត្ថិ អរហតោ អកាលមច្ចុតិកថា ចប់**

# អដ្ឋកថា

## ឆត្ថិ អរហតោ អកាលមច្ចុតិកថា

[ ២៦៤ ] ឥឡូវនេះ នឹងពណ៌នាអំពីសេចក្ដីស្លាប់ ក្នុងកាលមិនគួររបស់ព្រះអរហន្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា ឈ្មោះថា ព្រះអរហន្ត ត្រូវសោយកម្មវិបាកទាំងពួងហើយ ទើបបរិនិព្វាន ព្រោះហេតុនោះ ទើបព្រះអរហន្ត មិនមានអកាលមរណៈ ព្រោះកាន់យកដោយមិនពិចារណាអត្ថនៃព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលថា កម្មទាំងឡាយប្រកបដោយចេតនាដែលសត្វធ្វើហើយ សន្សំហើយ អស់ទៅ ព្រោះតែមិនបានទទួលផលដូច្នេះឡើយ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើព្រះអរហន្ត មិនមានអកាលមរណៈសោតឈ្មោះថា អ្នកសម្លាប់ព្រះអរហន្ត ក៏មិនគប្បីមាន ដូច្នេះ ទើបពោលថា **ឆត្ថិ អរហន្តឃាតកោ** បរវាទីឆ្លើយបដិសេធតាមសភាវៈនៃអនន្តរិយកម្ម និងបុគ្គលបែបនោះឯង ។

[ ២៦៥ ] ក្នុងបញ្ហាថា **វិសំ ឧ កមេយ្យ** បរវាទីឆ្លើយបដិសេធ តាមលទ្ធិថា កម្មដែលលោកធ្វើក្នុងកាលមុន មិនទាន់អស់ទៅដរាបណា ថ្នាំពិសក៏មិនធ្វើអន្តរាយដរាបនោះ ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាម

ព្រះបាលីនោះឯង ។

[ ២៦៧ ] ព្រះសូត្រថា **ឆាហំ ភិក្ខវេ** ជាដើម បរវាទីពោលហើយ សំដៅដល់អត្ថនេះថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា តថាគតមិនពោលថា កម្មដែលប្រព្រឹត្តទៅដោយសញ្ចេតនា ដែលបុគ្គលធ្វើហើយ មិនទាន់បានទទួល មិនបានជួប មិនបានសោយផលហើយនឹងអស់ទៅ គឺមិនពោលថា កម្មទាំង នោះ ជារបស់អស់ទៅដោយវិថិទាំងអស់ ឯកម្មនោះ ដែលនឹងឲ្យផលក្នុង ទិដ្ឋធម៌ គប្បីឲ្យផលក្នុងទិដ្ឋធម៌ មិនមែនឲ្យផលក្នុងភពដទៃ កម្មដែលឲ្យ ផលក្នុងភពខាងមុខ រមែងឲ្យផលក្នុងភពដែលចូលដល់ឧបបត្តិ បន្ទាប់ទៅ មិនឲ្យផលក្នុងភពដទៃ កម្មដែលឲ្យផលក្នុងភពដទៃៗ បានឱកាសឲ្យផលក្នុង កាលណា រមែងឲ្យផលក្នុងកាលបែបនោះ ឬក្នុងវារៈដទៃៗ តទៅ កាល ការប្រព្រឹត្តទៅនៃសំសារៈ ក្នុងទីទាំងពួង មានយ៉ាងនេះ កាលកម្មបានវារៈ ឲ្យផល បុគ្គលនៅក្នុងទីណា មិនផុតចាកបាបកម្ម ប្រទេសរបស់លោកនោះ រមែងមិនមាន កាលបើភាពយ៉ាងនេះមាន ការតាំងលទ្ធិថា ព្រះអរហន្ត មិន មានអកាលមរណៈ ដូច្នេះឯណា ដែលធ្វើហើយ ដោយអំណាចការកំណត់ ថា ព្រះអរហន្ត គប្បីសោយកម្មដែលមិនទាន់ដល់វារៈនៃការឲ្យផលយ៉ាង ពិតប្រាកដ ការតាំងលទ្ធិនោះ រមែងជាអាបត្តិទុក្កដ ។

**អដ្ឋកថា នត្ថិ អរហតោ អកាលមច្ចុតិកថា ចប់**

# អភិធម្មបិដក

## សព្វមិទំ កម្មតោតិកថា

[ ២៦៨ ] ធម្មជាតទាំងអស់នេះមាន ព្រោះកម្មឬ ។ អើ ។ ចុះកម្មមាន ព្រោះកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតទាំងអស់នេះមាន ព្រោះកម្មឬ ។ អើ ។ ធម្មជាតទាំងអស់នេះ ជាហេតុដែលធ្វើក្នុងកាលមុនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតទាំងអស់នេះមានព្រោះកម្មឬ ។ អើ ។ ធម្មជាតទាំងអស់នេះមាន ព្រោះវិបាករបស់កម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតទាំងអស់នេះមាន ព្រោះវិបាករបស់កម្មឬ ។ អើ ។ បុគ្គលសម្លាប់សត្វដោយវិបាករបស់កម្មឬ ។ អើ ។ បាណាតិបាត មានផលដែរឬ ។ អើ ។ វិបាករបស់កម្ម មានផលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាករបស់កម្មមិនមានផលទេឬ ។ អើ ។ បាណាតិបាត មិនមានផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ និយាយកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ កាត់នូវទី-តនៃផ្ទះ ប្លន់ពួកអ្នកស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ឈរចាំក្បែរផ្លូវ ( ដើម្បីដណ្តើមយកទ្រព្យ ) លួចប្រពន្ធបុគ្គលដទៃ សម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ដោយវិបាករបស់កម្ម បុគ្គលគប្បីឲ្យទាន គឺឲ្យចីវរ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដោយវិបាករបស់កម្មឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលដែរឬ ។ អើ ។ វិបាករបស់កម្ម មានផល

ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាករបស់កម្ម មិនមានផល ទេឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មិនមានផលទេឬ ។ អ្នកមិន គួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៩ ] បុគ្គលមិនគួរនិយាយថា ធម្មជាតទាំងអស់នេះ មានព្រោះ កម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

លោកប្រព្រឹត្តទៅដោយកម្ម ពពួកសត្វប្រព្រឹត្តទៅដោយកម្ម
សត្វទាំងឡាយ មានកម្មជាចំណង ( ហេតុ ) ដូចជាប្រែក
ទប់របស់រថ កាលប្រព្រឹត្តទៅ បុគ្គលរមែងបាននូវកិត្តិសព្ទ
ដោយកម្ម បាននូវសេចក្តីសរសើរដោយកម្ម បាននូវសេចក្តី
វិនាសផង បាននូវសេចក្តីបៀតបៀនផង បាននូវការជាប់
ចំណងផង ក៏ដោយកម្ម បុគ្គលបានដឹងនូវកម្មនោះថា មាន
អំពើផ្សេងៗ គ្នាហើយ ហេតុអ្វីក៏និយាយថា កម្មមិនមាន ក្នុង
លោក ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម្មជាតទាំង អស់នេះ មានព្រោះកម្ម ។

**សព្វមិទំ កម្មតោតិកថា ចប់**

# អដ្ឋកថា

## សព្វមិទំ កម្មតោតិកថា

[ ២៦៨ ] ឥឡូវនេះ នឹងពណ៌នាអំពីធម្មជាតទាំងអស់នេះ មានព្រោះកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងនិកាយសិទ្ធត្ថិកៈទាំងឡាយថា ធម្មជាតទាំងអស់នេះ ពោល គឺកម្មវដ្តៈ កិលេសវដ្តៈ និងវិបាកវដ្តៈ កើតព្រោះកម្មនោះឯង ព្រោះអាស្រ័យព្រះសូត្រថា លោកប្រព្រឹត្តទៅដោយកម្ម ដូច្នេះ ពាក្យសួររបស់សកវាទីថា **សព្វមិទំ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា កាលបើយ៉ាងនេះ សូម្បីកម្ម ក៏រមែងកើតអំពីកម្ម ទើបពោលថា **កម្មម្បិ កម្មតោ** ដូច្នេះ ។ បរវាទីឆ្លើយបដិសេធ ដោយគិតថា បើកម្មឈ្មោះថា កើតអំពីកម្មពិតមែន កម្មនោះ ក៏គប្បីក្លាយជាវិបាកទៅហើយ ។ បទថា **បុព្វេកតហេតុ** សកវាទីសួរដើម្បីចោទថា បើវត្ថុទាំងពួងនេះ កើតអំពីកម្ម វត្ថុនោះ ក៏គប្បីជាហេតុដែលធ្វើហើយក្នុងកាលមុន ។ បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសថាជាលទ្ធិបុព្វេកតហេតុវាទ ។

បទថា **កម្មវិបាកតោ** សកវាទីសួរដើម្បីចោទថា បើវត្ថុទាំងពួងនេះ កើតព្រោះកម្ម កម្មណាដែលជាហេតុ នៃការប្រព្រឹត្តទៅក្នុងអតីតភព កម្មនោះ ក៏កើតអំពីកម្មក្នុងភពមុនជាងនោះទៅទៀត ព្រោះហេតុនោះ កម្មវិបាក

រមែងសម្រេច ព្រោះហេតុនោះ វត្ថុទាំងពួងនេះ រមែងកើតឡើង ព្រោះកម្មវិបាក តាមលទ្ធិរបស់អ្នកឬ ដូច្នេះ ។ បរវាទីឆ្លើយបដិសេធ សំដៅយកការកើតអំពីកម្មនៃការប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដូចការកើតអំពីពូជនៃពន្លករបស់ពូជ ។ បរវាទីត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះភាពដែលកម្មនោះប្រព្រឹត្តទៅ ព្រោះកម្មក្នុងកាលមុន ដូចពូជរមែងកើតអំពីពូជដើម ( ពូជមុនដំបូង ) ។ បទថា **ចាណាំ ហានេយ្យ** សកវាទីពោលដើម្បីចោទសួរថា បើវត្ថុទាំងពួងកើតអំពីកម្មវិបាកសោត បុគ្គលក៏គប្បីធ្វើបាណាតិបាតជាដើម ដោយកម្មវិបាកនោះឯង ។ បរវាទីឆ្លើយទទួលតាមលទ្ធិថា សូម្បីចេតនាក្នុងភាពជាអ្នកទ្រុស្តសីលដែលកើតឡើងអំពីកម្មមុន ក៏ជាវិបាកដោយបរិយាយមួយនោះឯង ។ លំដាប់នោះ សកវាទីក៏ពោលថា **សផលោ** ដើម្បីចោទសួរបរវាទីនោះថា បើបាណាតិបាត រមែងកើតអំពីកម្មវិបាក តាមលទ្ធិរបស់អ្នកសោត សូម្បីវិបាកក៏ជាវត្ថុដែលមានផល ដូចបាណាតិបាត មានផល ។ បរវាទីកាលឃើញនូវភាពដែលបាណាតិបាតមានផល ព្រោះភាពជាផលឲ្យកើតក្នុងនរកជាដើម ទើបឆ្លើយទទួល តែកាលមិនឃើញឋានៈ ដែលសកវាទីពោលថា វត្ថុឈ្មោះនេះ ជាផលរបស់កម្មវិបាកឬ ទើបឆ្លើយបដិសេធ ។ ក្នុងអទិន្នាទានជាដើម ក៏មានន័យនេះឯង ។ បទថា **គិលានប្បច្ចយភេសជ្ជបរិក្ខារោ សផលោ** សេចក្តីថា សកវាទីរមែងសួរថា ផលនៃការឲ្យទានមានដោយអំណាចនៃទេយ្យធម៌ឬ ។

[ ២៦៩ ] *ព្រះសូត្រថា* **កម្មុនា វត្តតិ** *រមែងបដិសេធភាពជាអ្នកមិនពោលដល់កម្ម ដោយគិតថា កម្មមិនមាន ហើយសម្តែងនូវភាពជាអ្នកពោលដល់គោលរបស់កម្ម និងភាពជាអ្នកកាន់យកថា កម្មជារបស់ខ្លួន ថាកម្មមាន ដូច្នេះ មិនមែនសម្តែងនូវភាពដែលធម្មជាតទាំងអស់ កើតឡើងព្រោះកម្មឡើយ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាងដូច្នេះ ។*

**អដ្ឋកថា សត្តមិទំ កម្មតោតិកថា ចប់**

# អភិធម្មបិដក

## ឥន្ទ្រិយពន្ទុកថា

[ ២៧០ ] ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខឬ ។ អើ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាដែរឬ ។ អើ ។ ប្រសិនបើ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេ ។

[ ២៧១ ] ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ ។បេ។ មានការប្រែប្រួលទៅជាធម្មតា នោះឯងមិនមែនជាទុក្ខទេឬ ។ អើ ។ ធម្មជាតដែល

ជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។បេ។ មានការប្រែប្រួលទៅជាធម្មតា នោះឯងមិនមែនជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។បេ។ មានការប្រែប្រួលទៅជាធម្មតា នោះឯងជាទុក្ខឬ ។ អើ ។ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។បេ។ មានការប្រែប្រួលទៅជាធម្មតា នោះឯងជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧២ ] ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀងឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀងមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេ ។

[ ២៧៣ ] បុគ្គលមិនគួរនិយាយថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេឬ ។ អើ ។ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះមានព្រះភាគ ដោយការកំណត់ដឹងនូវទុក្ខ ដែលជាប់ទាក់ទងដោយឥន្ទ្រិយ យ៉ាងណា បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះមានព្រះភាគ ដោយការកំណត់ដឹងនូវទុក្ខ ដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ក៏យ៉ាងនោះដែរឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុក្ខជាប់ទាក់ទងដោយឥន្ទ្រិយ ដែលបុគ្គលកំណត់ដឹងហើយ មិនកើតឡើងទៀត យ៉ាងណា ទុក្ខមិនជាប់ទាក់ទងដោយឥន្ទ្រិយ ដែលបុគ្គលកំណត់ដឹងហើយ មិនកើតឡើងទៀត ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខមែន ។

ឥន្ទ្រិយពទ្ធកថា ចប់

# អដ្ឋកថា

## ឥន្ទ្រិយពទ្ធកថា

[ ២៧០ ] ឥឡូវនេះ នឹងពណ៌នាអំពីធម្មជាតដែលជាប់ទាក់ទង ដោយឥន្ទ្រិយទើបជាទុក្ខដូចតទៅ

ក្នុងរឿងនោះ ទុក្ខមាន ២ យ៉ាង គឺឥន្ទ្រិយពទ្ធទុក្ខ គឺទុក្ខដែលទាក់ទងដោយឥន្ទ្រិយ និងអនិន្ទ្រិយពទ្ធទុក្ខ គឺទុក្ខដែលមិនទាក់ទងដោយឥន្ទ្រិយ ។ **ឥន្ទ្រិយពទ្ធ** ឈ្មោះថា ជាទុក្ខ ព្រោះភាពជាវត្ថុនៃទុក្ខ **អនិន្ទ្រិយពទ្ធ** ឈ្មោះថា ជាទុក្ខ ព្រោះភាពដែលព្រះមានព្រះភាគទ្រង់សង្គ្រោះទុក្ខ ក្នុងពាក្យថា របស់ណាមិនទៀង របស់នោះ ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ត្រូវការកើត និងការរលត់បៀតបៀន ដូច្នេះ ។ ជនទាំងឡាយណា មិនកាន់យកការបែកនេះ មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទទាំងឡាយថា ការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់នៃព្រះមានព្រះភាគ ដើម្បីកំណត់ដឹងទុក្ខឯណា ទុក្ខនោះក៏ជាឥន្ទ្រិយពទ្ធទុក្ខប៉ុណ្ណោះ មិនមែនទុក្ខដទៃក្រៅអំពីនេះឡើយ ដូច្នេះ ពាក្យសួររបស់សកវាទីថា **ឥន្ទ្រិយពទ្ធញ្ញេវ** ដើម្បីសម្តែងនូវភាពដែលវត្ថុដែលមិនទាក់ទងដោយឥន្ទ្រិយ សូម្បីក្រៅអំពីនេះ ក៏ជាទុក្ខ សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **ឥន្ទ្រិយពទ្ធញ្ញេវ អនិច្ចំ** ដូច្នេះជាដើម ដើម្បីចោទសួរបរវាទីនោះថា ព្រោះព្រះមានព្រះភាគត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ ព្រោះហេតុនោះ វត្ថុដែលទាក់ទងដោយឥន្ទ្រិយប៉ុណ្ណោះ គប្បីជាសភាវៈមិនទៀងឬ

ដូច្នេះ ។ បទថា **ននុ អនិន្ទ្រិយពទ្ធំ អនិច្ចំ** អធិប្បាយថា វត្ថុដែលមិនទាក់ទង ដោយឥន្ទ្រិយ ដូចជាផែនដី ភ្នំ ដុំថ្មជាដើម ក៏មិនទៀង មិនមែនឬ ។

[ ២៧៣ ] ក្នុងបញ្ហាថា **ន វត្តព្វំ ឥន្ទ្រិយពទ្ធញ្ចេវ ទុក្ខំ** ពាក្យឆ្លើយ ទទួលថា **អាមន្តា** ជាពាក្យរបស់សកវាទី ។ ពិតហើយ វត្ថុដែលមិនទាក់ទង ដោយឥន្ទ្រិយ ក៏ជាអារម្មណ៍របស់ទុក្ខទោមនស្សទាំងឡាយបាន តែភ្លើងក្នុង រដូវប្រាំងក្តី ខ្យល់ក្នុងរដូវរងាក្តី ក៏ជាអារម្មណ៍របស់ទុក្ខ ការវិនាសនៃភោគៈ ជាដើម ក៏ជាអារម្មណ៍របស់ទោមនស្សពិតប្រាកដ ព្រោះហេតុនោះ សូម្បី វៀរចាកអត្ថថា មិនទៀង វត្ថុដែលមិនទាក់ទងដោយឥន្ទ្រិយ ក៏គប្បីពោល បានថាជាទុក្ខ តែមិនគួរពោលថា ជាទុក្ខអរិយសច្ច ព្រោះមិនមែនទុក្ខ ដែល កើតអំពីកម្ម និងកិលេសទាំងឡាយ និងមិនគួរពោលថា ជាទុក្ខអរិយសច្ច ព្រោះមិនគប្បីកំណត់ដឹងដោយមគ្គ ។ ម្យ៉ាងទៀត ព្រោះការបែកធ្លាយទៅនៃ ស្មៅ និងដើមឈើជាដើម ឬការបែកធ្លាយទៅនៃពូជ ដែលកើតតាមរដូវ កាលជាដើម រមែងមិនឈ្មោះថា ជាទុក្ខនិរោធអរិយសច្ច ព្រោះហេតុនោះ វត្ថុដែលទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខផង ជាអរិយសច្ចផង តែសកវាទី ឆ្លើយទទួលថា **អាមន្តា** ដើម្បីសម្តែងការផ្សេងគ្នានេះថា វត្ថុដែលមិនទាក់

ទងដោយឥន្ទ្រិយ ក៏ជាទុក្ខដូចគ្នា ។ បទថា **យថា ឥន្ទ្រិយពទ្ធស្ស** ជាដើម រមែងសម្តែងដល់ការនៅប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីការកំណត់ដឹងទុក្ខ ដែលទាក់ទងដោយឥន្ទ្រិយ គឺការមិនកើតឡើងទៀត របស់ទុក្ខដែលកំណត់ដឹងហើយ ។ ដោយហេតុនោះឯង ក្នុងបញ្ហានោះ ទើបសកវាទីបដិសេធ ។ សេចក្តីពិត បុគ្គលណាមួយ មិនអាចបដិសេធភាពដែលវត្ថុមិនទាក់ទងដោយឥន្ទ្រិយ ដែលសង្គ្រោះហើយ ដោយពាក្យថា របស់ណាមិនទៀង របស់នោះជាទុក្ខ ដូច្នេះ ជាទុក្ខ ព្រោះហេតុនោះ ទើបពាក្យនេះ មិនមែនជាគោលអាងថា វត្ថុដែលទាក់ទងដោយឥន្ទ្រិយប៉ុណ្ណោះ ជាទុក្ខ ដូច្នេះឯង ។

## អដ្ឋកថាឥន្ទ្រិយពទ្ធកថា ចប់

# អភិធម្មបិដក

## ឋបេត្វា អរិយមគ្គង្គិកថា

[ ២៧៤ ] សង្ខារទាំងឡាយដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខឬ ។ អើ ។ ចុះទុក្ខសមុទយៈ ក៏ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះទុក្ខសមុទយៈ ក៏ជាទុក្ខដែរឬ ។ អើ ។ អរិយសច្ចមានតែ ៣ យ៉ាងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរិយសច្ចៈ មានតែ ៣ យ៉ាងទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសច្ចមាន ៤ យ៉ាង គឺទុក្ខ ១ ទុក្ខសមុទយៈ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសច្ចមាន ៤ យ៉ាង គឺទុក្ខ ១ ទុក្ខសមុទយៈ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ មែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អរិយសច្ចមានតែ ៣ យ៉ាងនេះទេ ។

[ ២៧៥ ] ចុះទុក្ខសមុទយៈ ជាទុក្ខដែរឬ ។ អើ ។ ដោយអត្ថដូចម្តេច ។ ដោយអត្ថថា មិនទៀង ។ ចុះអរិយមគ្គមិនទៀងដែរឬ ។ អើ ។ អរិយមគ្គជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរិយមគ្គមិនទៀង ចុះអរិយមគ្គនោះ មិនមែនជាទុក្ខទេឬ ។ អើ ។ ទុក្ខសមុទយៈមិនទៀង ចុះទុក្ខ-សមុទយៈនោះ មិនមែនជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុក្ខសមុទយៈមិនទៀង ចុះទុក្ខសមុទយៈនោះ ជាទុក្ខឬ ។ អើ ។ អរិយមគ្គមិនទៀង ចុះអរិយមគ្គនោះ ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៦ ] បុគ្គលមិនគួរនិយាយថា សង្ខារទាំងឡាយដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខឬ ។ អើ ។ ក្រែងទុក្ខនិរោធគាមិនីបដិ-បទានោះមានឬ ។ អើ ។ ប្រសិនបើ ទុក្ខនិរោធគាមិនីបដិបទាមានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ខារទាំងឡាយដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខ ។

ឋបេត្វា អរិយមគ្គន្តិកថា ចប់

# អដ្ឋកថា

## ឋបេត្វា អរិយមគ្គង្គិកថា

[ ២៧៤ ] ឥឡូវនេះ នឹងពណ៌នាអំពីលើកលែងតែអរិយមគ្គដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទទាំងឡាយថា ព្រោះអរិយមគ្គ ព្រះមានព្រះភាគត្រាស់ហៅថា ទុក្ខនិរោធគាមិនីបដិបទា ព្រោះហេតុនោះ វៀរអរិយមគ្គ សង្ខារដ៏សេស ឈ្មោះថា ជាទុក្ខ ដូច្នេះ ។ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីពោលថា **ទុក្ខសមុទយោចិ** ដើម្បីចោទសួរបរវាទីនោះថា បើយ៉ាងនេះសោត សភាពនៃសមុទយៈ ក៏ត្រូវជាទុក្ខ ។ បរវាទីឆ្លើយបដិសេធ សំដៅយកសមុទយៈនោះមានលក្ខណៈជាហេតុ ។ បរវាទី កាលត្រូវសួរទៀត ក៏ឆ្លើយទទួល សំដៅយកសមុទយៈនោះ ជាលោកិយធម៌ មានការកើតរលត់ ។ ក្នុងបញ្ហាទាំងឡាយថា **តីណេវ** បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ តែឆ្លើយទទួលដោយអំណាចលទ្ធិ ។ ពាក្យដ៏សេសក្នុងរឿងនេះ មានអត្ថងាយហើយ ដូច្នេះ ។៚

**អដ្ឋកថា ឋបេត្វា អរិយមគ្គង្គិកថា ចប់**

# អភិធម្មបិក

## ៨ វគ្គពុំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា

[ ២៧៧ ] បុគ្គលមិនគួរនិយាយថា សង្ឃទទួលទក្ខិណាទានបានទេឬ ។ អើ ។ ក្រែងសង្ឃជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកឬ ។ អើ ។ ប្រសិនបើ សង្ឃជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃទទួលទក្ខិណាទានបាន ។

[ ២៧៨ ] បុគ្គលមិនគួរនិយាយថា សង្ឃទទួលទក្ខិណាទានបានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃទទួលទក្ខិណាទានបាន ។

[ ២៧៩ ] បុគ្គលមិនគួរនិយាយថា សង្ឃទទួលទក្ខិណាទានបានទេឬ ។ អើ ។ ក្រែងជនពួកខ្លះ ឲ្យទានដល់សង្ឃ មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ឲ្យទានដល់សង្ឃ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃទទួលទក្ខិណាទានបាន ។ ក្រែងជនពួកខ្លះ ឲ្យចីវរ ។បេ។ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យខាទនីយៈ ឲ្យភោជនីយៈ ។បេ។ ឲ្យទឹកគួរផឹកដល់សង្ឃមានដែរឬ ។ អើ ។ ប្រសិនបើ

ជនពួកខ្លះ ឲ្យទឹកគួរផឹកដល់សង្ឃ មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃគួរទទួលទក្ខិណាទានបាន ។

[ ២៨០ ] បុគ្គលមិនគួរនិយាយថា សង្ឃទទួលទក្ខិណាទានបានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សង្ឃបរិបូណ៌ដោយសមាធិ ទទួលទក្ខិណាទាន បីដូចភ្លើង
ទទួលគ្រឿងបូជា ឬដូចជាផែនដី ទទួលភ្លៀងធំ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ឃទទួលទក្ខិណាទានបាន ។

[ ២៨១ ] សង្ឃទទួលទក្ខិណាទានបានឬ ។ អើ ។ មគ្គទទួលទក្ខិណាទាន ផលទទួលទក្ខិណាទាន បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា ចប់

# អដ្ឋកថា

## ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា

[ ២៧៧ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនគួរនិយាយថា សង្ឃទទួលទក្ខិណាទានបានដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈ ពោល គឺមហាបុញ្ញវាទីក្នុងខណៈនេះថា កាលពោលដោយបរមត្ថហើយ ព្រះសង្ឃ គឺមគ្គ និងផលប៉ុណ្ណោះ ឈ្មោះថា ព្រះសង្ឃដទៃក្រៅអំពីមគ្គ និងផលមិនមាន មគ្គ និងផល ទទួលអ្វីមិនបាន ព្រោះហេតុនោះ ទើបមិនគួរពោលថា ព្រះសង្ឃទទួលទក្ខិណាទាន ដូច្នេះ ពាក្យសួររបស់សកវាទីថា **ន វត្តព្វំ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **ននុ សង្ឃោ អាហុនេយ្យោ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើតាមលទ្ធិរបស់អ្នកព្រះសង្ឃមិនគប្បីទទួលទក្ខិណាទានសោត ព្រះសាស្តា ក៏មិនគប្បីសរសើរសង្ឃដោយព្រះតម្រាស់ថា **អាហុនេយ្យោ** ជាដើម ។

[ ២៧៨ ] បទថា **សង្ឃស្ស ទានំ ទេន្តិ** សកវាទីពោលដើម្បីចោទសួរថា បុគ្គលពួកណា រមែងថ្វាយទានដល់ព្រះសង្ឃ កាលបុគ្គលទទួលទានមិនមាន បុគ្គលទាំងនោះ គប្បីថ្វាយទានដល់បុគ្គលណា ដូច្នេះ ។

[ ២៨០ ] ព្រះសូត្រថា **អាហុតឹ ជាតវេទោ វ** សកវាទីនាំមកអំពីលទ្ធិដទៃ ។ ក្នុងបទទាំងនោះ បទថា **មហាមេឃំ** លោកពោលសំដៅយកមេឃ គឺភ្លៀង ។ ពិតហើយ ផែនដី រមែងទទួលទឹកភ្លៀង មិនទទួលមេឃឡើយ ។

[ ២៨១ ] បទថា **មគ្គោ បដិគ្គណ្ហាតិ** បរវាទីពោលតាមលទ្ធិថា មគ្គនិងផលជាព្រះសង្ឃ ។ ការពិត មគ្គ និងផលនោះ មិនមែនព្រះសង្ឃ តែបុគ្គល ៨ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយ ព្រោះអាស្រ័យខន្ធទាំងឡាយដ៏បរិសុទ្ធ ព្រោះការប្រាកដកើតឡើងនៃមគ្គ និងផល ឈ្មោះថា ព្រះសង្ឃ ព្រោះហេតុនោះ ទើបសេចក្ដីនេះ មិនមែនជាគោលអាង ដូច្នេះ ។៚

**អដ្ឋកថានវត្ថុពុំសង្ឃោនក្ខិណាំបដិគ្គណ្ហាតីតិកថា ចប់**

# អភិធម្មបិដក

## ៥ វគ្គពុំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

[ ២៨២ ] បុគ្គលមិនគួរនិយាយថា សង្ឃញុំាំងទក្ខិណាទានឲ្យស្អាតទេ ឬ ។ អើ ។ ក្រែងសង្ឃជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យ-បុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកឬ ។ អើ ។ ប្រសិនបើ សង្ឃជាអាហុនេយ្យបុគ្គល ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃញុំាំងទក្ខិណាទានឲ្យស្អាត ។

[ ២៨៣ ] បុគ្គលមិនគួរនិយាយថា សង្ឃញុំាំងទក្ខិណាទានឲ្យស្អាតទេ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃញុំាំងទក្ខិណាទានឲ្យស្អាត ។

[ ២៨៤ ] បុគ្គលមិនគួរនិយាយថា សង្ឃញុំាំងទក្ខិណាទានឲ្យស្អាតទេឬ ។ អើ ។ ក្រែងជនពួកខ្លះ បានឲ្យទានដល់សង្ឃ ហើយញុំាំងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ បានឲ្យទានដល់សង្ឃ ហើយញុំាំងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃញុំាំងទក្ខិណាទានឲ្យស្អាត ។

[ ២៨៥ ] ក្រែងជនពួកខ្លះ បានឲ្យចីវរ ។បេ។ ឲ្យបិណ្ឌបាត ។បេ។ ឲ្យសេនាសនៈ ឲ្យគិលានប្បច្ច័យភេសជ្ជបរិក្ខារ ឲ្យខាទនីយៈ ឲ្យភោជនីយៈ ។បេ។ ឲ្យទឹកគួរផឹកដល់សង្ឃ ហើយញុំាងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ បានឲ្យទឹកគួរផឹកដល់សង្ឃហើយ ញុំាងសង្ឃឲ្យត្រេកអរ នឹងទក្ខិណាទាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃញុំាងទក្ខិណាទានឲ្យស្អាត ។

[ ២៨៦ ] សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាតឬ ។ អើ ។ មគ្គ ញុំាងទក្ខិណាទានឲ្យស្អាត ផល ញុំាងទក្ខិណាទានឲ្យស្អាតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា ចប់

# អដ្ឋកថា

## ៨ វត្ថុពុំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

[ ២៨២ ] ឥឡូវនេះ នឹងពណ៌នាអំពីសង្ឃញ៉ាំងទក្ខិណាទានឲ្យស្អាតដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈនោះឯងថា មគ្គ និងផលប៉ុណ្ណោះ ឈ្មោះថា ព្រះសង្ឃ មគ្គ និងផលនោះ រមែងមិនអាចធ្វើនូវទក្ខិណាឲ្យបរិសុទ្ធបាន ព្រោះហេតុនោះ មិនគប្បីពោលថា សង្ឃញ៉ាំងទក្ខិណាទានឲ្យស្អាត ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **អាហុនេយ្យា** ជាដើម សកវាទីពោលដើម្បីសម្តែងថា បើសង្ឃមិនអាចញ៉ាំងទក្ខិណាឲ្យស្អាតសោត ព្រះមានព្រះភាគ គង់មិនពោលសរសើរសង្ឃនោះយ៉ាងនេះ ។ បទថា **វិសោធេតិ** បានដល់ ធ្វើឲ្យមានផលច្រើន ។ ពិតហើយ ទានមានប្រមាណតិច ដែលគេឲ្យហើយក្នុងសង្ឃ រមែងជាទានមានផលច្រើន ទានមានប្រមាណច្រើន ដែលគេឲ្យហើយក្នុងសង្ឃ ក៏រឹងរឹតតែមានផលច្រើន ។

[ ២៨៣ ] បទថា **ទក្ខិណេយ្យា** បានដល់ បុគ្គលគួរដល់ទក្ខិណា គឺគួរដល់ទានដែលគេឲ្យដោយសេចក្ដីគោរព អធិប្បាយថា ជាអ្នកធ្វើទក្ខិណានោះឲ្យបរិសុទ្ធ ។

[ ២៨៥ ] បទថា **ទក្ខិណំ អារាធេន្តិ** បានដល់ ឲ្យបុណ្យ គឺទក្ខិណានោះដល់ព្រម អធិប្បាយថា រមែងឲ្យសម្រេចផលដ៏ធំដោយទក្ខិណា សូម្បីមានប្រមាណតិច ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យតាមដែលពោលហើយនោះឯង ។l៚

**អដ្ឋកថានវត្តពុំសង្ឃោទក្ខិណាវិសោធេតីតិកថា ចប់**

# អភិធម្មបិដក

## ៨ វគ្គទី ៦ សង្ឃោ កុញ្ញកាតិកថា

[ ២៨៧ ] បុគ្គលមិនគួរនិយាយថា សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធ ភ្លក្សទេឬ ។ អើ ។ ក្រែងជនពួកខ្លះ ធ្វើសង្ឃភត្ត ធ្វើឧទ្ទេសភត្ត ធ្វើបបរ និងទឹក មានដែរឬ ។ អើ ។ ប្រសិនបើជនពួកខ្លះ ធ្វើសង្ឃភត្ត ធ្វើឧទ្ទេស-ភត្ត ធ្វើបបរ និងទឹក មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្សដែរ ។

[ ២៨៨ ] បុគ្គលមិនគួរនិយាយថា សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធ ភ្លក្សទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា គណភោជន បរម្បរភោជន អតិរិត្តភោជន អនតិរិត្តភោជនមែនឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគទ្រង់ត្រាស់ថា គណភោជន បរម្បរភោជន អតិរិត្តភោជន អនតិរិត្តភោជនមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្សដែរ ។

[ ២៨៩ ] បុគ្គលមិនគួរនិយាយថា សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធ ភ្លក្សទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ទឹកបាន ៨ យ៉ាង គឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកអត់គ្រាប់ ទឹកផ្លែ

ស្រគំ ទឹកផ្លែច័ន ទឹកក្រអៅឈូក ទឹកផ្លែមាក់ប្រាងមែនឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទឹកបាន ៨ យ៉ាង គឺទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកអត់គ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែច័ន ទឹកក្រអៅឈូក ទឹកផ្លែមាក់ប្រាងមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សដែរ ។

[ ២៩០ ] សង្ឃបរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សដែរឬ ។ អើ ។ មគ្គបរិភោគ ផឹក ទំពាស៊ី លិទ្ធភក្ស ផលបរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា ចប់

# អដ្ឋកថា

## ឆវត្ថុវត្ថុំ សង្ឃោ ភុញ្ជតីតិកថា

[ ២៨៧ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនគួរនិយាយថា សង្ឃបរិភោគដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈនោះឯងថា មគ្គ និងផលប៉ុណ្ណោះ ឈ្មោះថា ព្រះសង្ឃ មគ្គ និងផលនោះនឹងបរិភោគអ្វីបាន ព្រោះហេតុនោះ ទើបមិនគួរពោលថា ព្រះសង្ឃឆាន់អាហារផឹក ទំពាស៊ី លិទ្ធ ភុក្ស ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើព្រះសង្ឃតាមលទ្ធិរបស់អ្នក មិនគប្បីឆាន់អាហារសោត ការធ្វើសង្ឃភត្តជាដើម ក៏គប្បីជាវត្ថុមិនមានប្រយោជន៍ ទើបពោលពាក្យថា **ននុ អត្ថិ កេចិ សង្ឃភត្តានិ ករោន្តិ** ជាដើម ។

[ ២៨៨ ] បទថា **គណភោជនំ** ជាដើម សកវាទីពោលហើយ ដើម្បីចោទសួរថា បើព្រះសង្ឃមិនគួរឆាន់អាហារសោត ការឆាន់អាហារជាពួកគណៈ គប្បីមានដល់អ្នកណា ។

[ ២៨៩ ] បទថា **អដ្ឋ បានានិ** នេះ សកវាទីពោលដើម្បីចោទសួរថា បើព្រះសង្ឃមិនបានផឹកទឹកបាន ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតទឹកបាន ៨ យ៉ាងនោះ ដើម្បីអ្នកណា ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយន័យ ដែលពោលហើយខាងដើមនោះឯង ៕ល៚

**អដ្ឋកថាឆវត្ថុវត្ថុំសង្ឃោភុញ្ជតីតិកថា ចប់**

# អភិធម្មបិដក

## នវត្តពុំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

[ ២៩១ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកដែរឬ ។ អើ ។ ប្រសិនបើ ព្រះសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

[ ២៩២ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិ-ណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

[ ២៩៣ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងគោតមី នាងចូរឲ្យទានចំពោះសង្ឃចុះ កាលបើនាងឲ្យទានចំពោះសង្ឃហើយ តថាគតឯងក្តី សង្ឃក្តី ក៏ឈ្មោះថានាងបានបូជាហើយ ពាក្យដូច្នេះ

មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

[ ២៩៤ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះឥន្ទជាធំជាងទេវតា បានក្រាបបង្គំទូលព្រះមានព្រះភាគថា

បុណ្យឲ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វ គឺមនុស្សអ្នកប្រាថ្នានូវបុណ្យ កាលបូជាធ្វើ គេឲ្យទានចំពោះបុគ្គលពួកណា ទើបមានផលច្រើន បុគ្គលអ្នកប្រតិបត្តិដើម្បីផល ៤ ពួក បុគ្គលអ្នកស្ថិតនៅក្នុងផល ៤ ពួក បុគ្គលទាំងនុ៎ះ ជាសង្ឃ មានចិត្តត្រង់ មានចិត្តតម្កល់មាំក្នុងបញ្ញា និងសីល បុណ្យឲ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វ គឺមនុស្សអ្នកប្រាថ្នានូវបុណ្យ កាលបូជាធ្វើ គេឲ្យទានចំពោះសង្ឃ ទើបមានផលច្រើន ព្រោះបុគ្គលនុ៎ះ ជាសង្ឃ មានគុណដ៏ធំទូលាយ ដល់នូវភាពដ៏ប្រសើរ សង្ឃនុ៎ះ មានគុណរាប់មិនបាន ដូចជាសាគរទ្រទ្រង់នូវទឹក សង្ឃទាំងនុ៎ះឯង ជាសាវ័ករបស់ព្រះពុទ្ធ មានព្យាយាមជាងនរៈ អ្នកប្រសើរបំផុត ជាអ្នកធ្វើនូវពន្លឺ រមែងសម្តែងនូវធម៌ ទានដែលគេឲ្យដោយល្អ ដែលគេបូជាតូចដោយល្អ ដែលគេបូជាធំដោយល្អ ចំពោះសង្ឃទាំងនោះ ( រមែងមានផលច្រើន ) ពួកជនណា ឲ្យទាន ឧទ្ទិសចំពោះសង្ឃ ទក្ខិណាទាន

នោះ ( របស់ពួកជននោះ ) ឈ្មោះថា តាំងនៅក្នុងសង្ឃ
ជាទានមានផលច្រើន ដែលព្រះពុទ្ធអ្នកជ្រាបច្បាស់នូវលោក
ទ្រង់សរសើរហើយ ពួកជនណា កាលរឭកឃើញនូវការបូជា
ដូច្នេះហើយ ជាអ្នកមានចិត្តរីករាយ គប្បីកម្ចាត់បង់នូវមន្ទិល
គឺសេចក្តីកំណាញ់ ព្រមទាំងឫសក្នុងលោក ។
ជនទាំងនោះ មិនមានគេនិន្ទា រមែងចូលទៅកាន់ស្ថានសួគ៌ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យចំពោះសង្ឃ ជាទានមានផលច្រើន ។

**ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា ចប់**

# អដ្ឋកថា

## ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

[ ២៩១ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈនោះឯងថា មគ្គ និងផលប៉ុណ្ណោះ ឈ្មោះថា ព្រះសង្ឃ ។ បុគ្គលណាមួយ មិនអាចឲ្យអ្វីមួយដល់មគ្គ និងផលនោះបានផង មគ្គ និងផលនោះក៏មិនអាចទទួលអ្វីមួយបានផង ។ម្យ៉ាងទៀត ឧបការៈណាមួយ ព្រោះការឲ្យដល់មគ្គ និងផលទាំងនោះ រមែងមិនសមបំណង ដូច្នោះ ទើបមិនគួរពោលថា ទានដែលឲ្យដល់សង្ឃ មានផលច្រើន ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **អាហុនេយ្យា** ជាដើម សកវាទីពោលដើម្បីសម្តែងថា បើទានដែលឲ្យដល់សង្ឃ មិនមានផលច្រើនសោត ព្រះមានព្រះភាគ ទ្រង់ក៏មិនសរសើរព្រះសង្ឃបែបនេះ ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនោះឯង ដូច្នេះ ៕

**អដ្ឋកថា នវត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា ចប់**

# អភិធម្មបិដក

## ឆ វគ្គពុំ ពុទ្ធស្ស ធិន្នំ មហាប្ផលន្តិកថា

[ ២៩៥ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ព្រះអង្គប្រសើរជាងពួកសត្វមានជើងពីរ វិសេសជាងពួកសត្វមានជើងពីរ ជាប្រធានរបស់ពួកសត្វមានជើងពីរ ខ្ពង់ខ្ពស់ជាងពួកសត្វមានជើងពីរ ថ្លៃថ្លាជាងពួកសត្វមានជើងពីរ មិនមានបុគ្គលស្មើ ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបស្មើ មិនមានចំណែកប្រៀប មិនមានបុគ្គលប្រៀបបានឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ព្រះអង្គប្រសើរជាងពួកសត្វមានជើងពីរ វិសេសជាងពួកសត្វមានជើងពីរ ជាប្រធានរបស់ពួកសត្វមានជើងពីរ ខ្ពង់ខ្ពស់ជាងពួកសត្វមានជើងពីរ ថ្លៃថ្លាជាងពួកសត្វមានជើងពីរ មិនមានបុគ្គលស្មើ ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបស្មើ មិនមានចំណែកប្រៀប មិនមានបុគ្គលប្រៀបបានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

[ ២៩៦ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ បុគ្គលណាមួយ សមស្មើនឹងព្រះពុទ្ធ ដោយសីល សមាធិ និងបញ្ញាមានដែរឬ ។ មិនមានទេ ។ ប្រសិនបើ បុគ្គលណាមួយ សមស្មើនឹងព្រះពុទ្ធដោយសីល សមាធិ និងបញ្ញា មិនមានទេ

ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

[ ២៩៧ ] បុគ្គលមិនគួរនិយាយថា ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

បុគ្គលប្រសើរជាងព្រះពុទ្ធក្តី ស្មើនឹងព្រះពុទ្ធក្តី មិនមានក្នុងលោកនេះ និងក្នុងលោកខាងមុខឡើយ ព្រោះថា ព្រះពុទ្ធទ្រង់ដល់នូវការៈ ប្រសើរជាងពួកអាហុនេយ្យបុគ្គល របស់ពួកជនអ្នកត្រូវការដោយបុណ្យ អ្នកស្វែងរកផលដ៏ធំទូលាយ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទានដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

**ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ចប់**

# អដ្ឋកថា

## ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា

[ ២៩៥ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈនោះឯងថា ព្រះមានព្រះភាគត្រាស់ដឹងហើយ រមែងមិនបរិភោគអ្វីមួយ តែសម្ដែងព្រះអង្គដូចបរិភោគ ដើម្បីអនុលោមតាមសត្វលោក ព្រោះហេតុនោះ ទើបមិនគួរពោលថា ទាន ដែលថ្វាយដល់ព្រះពុទ្ធនោះ មានផលច្រើន ព្រោះទាននោះ មិនមានឧបការគុណ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **ទិបទានំ អគ្គោ** ជាដើម សកវាទីពោលដើម្បីសម្ដែងថា ទានដែលឲ្យហើយក្នុងមនុស្សទ្រុស្តសីល គង់មានគុណដល់ ១០០០ នឹងពោលថ្វី ដល់ទានដែលថ្វាយក្នុងបុគ្គលដ៏ប្រសើរ ដែលមានសភាពបែបនេះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ដូច្នេះ ។l។

**អដ្ឋកថា នវត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ចប់**

# អភិធម្មបិដក

## ទក្ខិណាវិសុទ្ធិកថា

[ ២៩៨ ] ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេឬ ។ អើ ។ ក្រែងបដិគ្គាហកពួកខ្លះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកមានដែរឬ ។ អើ ។ ប្រសិនបើបដិគ្គាហកពួកខ្លះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេ ។

[ ២៩៩ ] ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរស ៤ គូ ឬបុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេ ។

[ ៣០០ ] ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេឬ ។ អើ ។ ក្រែងបុគ្គលពួកខ្លះ ឲ្យទានចំពោះសោតាបន្នបុគ្គល ហើយញ៉ាំងសោតាបន្នបុគ្គលឲ្យត្រេកអរចំពោះទក្ខិណាទាន មានដែរឬ ។ អើ ។

ប្រសិនបើ បុគ្គលពួកខ្លះ ឲ្យទានចំពោះសោតាបន្នបុគ្គល ហើយញុំាងសោតាបន្នបុគ្គល ឲ្យត្រេកអរចំពោះទក្ខិណាទានមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេ ។ ក្រែងបុគ្គលពួកខ្លះ ឲ្យទានចំពោះសកទាគាមិបុគ្គល ។បេ។ ចំពោះអនាគាមិបុគ្គល ។បេ។ ចំពោះព្រះអរហន្ត ហើយញុំាងព្រះអរហន្តឲ្យត្រេកអរ ចំពោះទក្ខិណាទានមានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលពួកខ្លះ ឲ្យទានចំពោះព្រះអរហន្ត ហើយញុំាងព្រះអរហន្តឲ្យត្រេកអរចំពោះទក្ខិណាទានមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេ ។

[ ៣០១ ] ទានបរិសុទ្ធតែអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយកទេឬ ។ អើ ។ បុគ្គលដទៃជាអ្នកធ្វើដល់បុគ្គលដទៃ សុខ ទុក្ខដែលបុគ្គលដទៃធ្វើ បុគ្គលដទៃធ្វើ បុគ្គលដទៃទទួលផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិនេះ មាន ៤ យ៉ាង ។ ទក្ខិណាវិសុទ្ធិ ៤ យ៉ាង តើដូចម្ដេច ។ ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកក៏មាន ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយកក៏មាន ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកក៏មាន ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផងក៏មាន ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក តើដូចម្ដេច ម្នាលអានន្ទ ទាយក

ក្នុងលោកនេះ មានសីល មានធម៌ល្អ ពួកបដិគ្គាហកទ្រុស្តសីល មានធម៌អាក្រក់ ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ ទ្រុស្តសីល មានធម៌អាក្រក់ ពួកបដិគ្គាហកមានសីល មានធម៌ល្អ ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ ទ្រុស្តសីល មានធម៌អាក្រក់ ពួកបដិគ្គាហកក៏ទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នា ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផង តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ មានសីល មានធម៌ល្អ ពួកបដិគ្គាហកក៏មានសីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផង យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិមាន ៤ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទានបរិសុទ្ធអំពីតែទាយក មិនបរិសុទ្ធអំពីបដិគ្គាហកទេ ។

ទក្ខិណាវិសុទ្ធិកថា ចប់

សត្តរសមវគ្គ ចប់

## ឧទ្ទាននៃសត្តរសមវគ្គនោះ គឺ

និយាយអំពីការសន្សំបុណ្យរបស់ព្រះអរហន្តមាន ១ អកាល-មច្ចុរបស់ព្រះអរហន្តមិនមាន ១ ធម្មជាតទាំងអស់នេះ មានព្រោះកាម ១ ធម្មជាតជាប់ដោយឥន្ទ្រិយជាទុក្ខ ១ សង្ខារដ៏សេសវៀរលែងតែអរិយមគ្គជាទុក្ខ ១ ព្រះសង្ឃតែងទទួលទក្ខិណាទាន ១ ព្រះសង្ឃតែងជម្រះទក្ខិណាទាន ១ ព្រះសង្ឃតែងឆាន់ ផឹក ទំពាស៊ី ភូក្ស ១ ទានដែលបុគ្គលឲ្យដល់សង្ឃ មានផលច្រើន ១ ទានបរិសុទ្ធក៏មាន ១ ។

# អដ្ឋកថា

## ទក្ខិណាវិសុទ្ធិកថា

[ ២៩៨ ] ឥឡូវនេះ នឹងពណ៌នាអំពីទានបរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា បើទក្ខិណាគប្បីបរិសុទ្ធ គឺគប្បីមានផលច្រើន ព្រោះបដិគ្គាហកសោត ទានដែលទាយកឲ្យហើយ វិបាកដែលបដិគ្គាហកឲ្យកើតហើយ ព្រោះហេតុនោះ បុគ្គលដទៃក៏គប្បីធ្វើដល់បុគ្គលដទៃបាន គឺបុគ្គលគប្បីដល់សុខ និងទុក្ខ ដែលបុគ្គលដទៃធ្វើឲ្យបុគ្គលធ្វើម្នាក់ បុគ្គលទទួលផលម្នាក់ទៀត ព្រោះហេតុនោះ ទាន រមែងបរិសុទ្ធព្រោះទាយកប៉ុណ្ណោះ រមែងមិនបរិសុទ្ធព្រោះបដិគ្គាហក ចិត្តវិសុទ្ធិរបស់ទាយកទាំងនោះ រមែងជាហេតុឲ្យនូវវិបាក ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **អាហុនេយ្យា** ជាដើម សកវាទីពោលដើម្បីសម្តែងថា បើទានមិនបរិសុទ្ធ ព្រោះបដិគ្គាហកសោត ភាពដែលព្រះអរិយបុគ្គលជាអ្នកគួរដល់ការបូជាជាដើម គប្បីធ្វើប្រយោជន៍អ្វីបាន ។

[ ៣០១ ] បទថា **អញ្ញោ អញ្ញស្ស ការកោ** អធិប្បាយថា បើទាន-ចេតនារបស់ទាយកជាវត្ថុដែលបដិគ្គាហកធ្វើសោត ក៏សមគួរហើយយ៉ាងនេះ តែទានចេតនារបស់ទាយកនោះ ជារបស់បរិសុទ្ធបាន ក៏ត្រូវអាស្រ័យវត្ថុពោល គឺបដិគ្គាហកហើយ ទើបបរិសុទ្ធ ព្រោះអត្ថថា មានផលច្រើន ព្រោះហេតុនោះ ទើបបញ្ហានោះ មិនមានការចោទសួរក្នុងពាក្យថា ទានបរិសុទ្ធតែអំពីបដិគ្គាហក ដោយប្រការដូច្នេះ ។

**អដ្ឋកថាទក្ខិណាវិសុទ្ធិកថា ចប់**

**វគ្គទី ១៧ ចប់**

# អភិធម្មបិដក

## មនុស្សលោកកថា

[ ៣០២ ] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងចេតិយ អារាម វិហារ ស្រុក និគម នគរ ដែន ជនបទ ដែលព្រះពុទ្ធគង់នៅហើយ មានដែរឬ ។ អើ ។ ប្រសិនបើចេតិយ អារាម វិហារ ស្រុក និគម នគរ ដែន ជនបទ ដែលព្រះពុទ្ធគង់នៅហើយមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកដែរ ។

[ ៣០៣ ] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ប្រសូតក្នុងលុម្ពិនីវ័ន ត្រាស់ដឹងទៀបគល់ពោធិព្រឹក្ស ព្រះមានព្រះភាគ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ជិតក្រុងពារាណសី ព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារជិតបាវាលចេតិយ ព្រះមានព្រះភាគ ទ្រង់បរិនិព្វានជិតក្រុងកុសិនារាឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ប្រសូតក្នុងលុម្ពិនីវ័ន ។បេ។ ព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ជិតក្រុងកុសិនារា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះពុទ្ធមានព្រះភាគទ្រង់គង់នៅក្នុងមនុស្សលោកដែរ ។

[ ៣០៤ ] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគតគង់នៅទៀបគល់សាលរាជព្រឹក្ស ក្នុង

ព្រៃសុភគៈ ជិតក្រុងឈ្មោះឧក្កដ្ឋា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត បានត្រាស់ដឹងជាដំបូង ទៀបអជបាលនិគ្រោធ ក្នុងឧរុវេលប្រទេស ម្នាល ភិក្ខុទាំងឡាយ សម័យមួយ តថាគតគង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវា-បស្ថាន ជិតក្រុងរាជគហៈ ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគតគង់នៅ ក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ម្នាលភិក្ខុ ទាំងឡាយ សម័យមួយ តថាគតគង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិត ក្រុងវេសាលី ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅក្នុងមនុស្សលោកដែរ ។

[ ៣០៥ ] ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ កើតក្នុងលោក ចម្រើនក្នុងលោក គ្របសង្កត់ លោក មិនជាប់ដោយលោកឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ កើត ក្នុងលោក ចម្រើនក្នុងលោក គ្របសង្កត់លោក មិនជាប់ដោយលោក ម្នាល អ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុង មនុស្សលោកទេ ។

មនុស្សលោកកថា ចប់

# អដ្ឋកថា

## មនុស្សលោកកថា

[ ៣០២ ] ឥឡូវនេះ នឹងពណ៌នាអំពីមនុស្សលោកដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈទាំងឡាយក្នុងឥឡូវនេះឯងថា ព្រះមានព្រះភាគ ទ្រង់បដិសន្ធិក្នុងស្ថានសួគ៌ជាន់តុសិត និងនៅក្នុងតុសិតទេវលោកនោះឯង មិនយាងមកកាន់មនុស្សលោក តែទ្រង់សម្ដែងត្រឹមតែរូបនិម្មិតក្នុងមនុស្សលោកនេះ ព្រោះមិនពិចារណាឲ្យល្អ ហើយកាន់យកព្រះសូត្រ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ដែលពោលថា ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលកើតក្នុងលោក ចម្រើនក្នុងលោក រមែងគ្របសង្កត់នូវលោក មិនជាប់ជំពាក់ដោយលោក ក៏យ៉ាងនោះឯង ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទី ដើម្បីនឹងឲ្យបរវាទីនោះទទួលដោយឱកាសដែលត្រូវសួរផង ដោយការអេះអាងដោយព្រះសូត្រផង ទើបពោលពាក្យថា **ឆន្នុ អត្ថិ** ជាដើម ។

[ ៣០៥ ] បទថា **លោកេ ជាតោ** បរវាទីពោលសំដៅយកស្ថានសួគ៌ជាន់តុសិត តែពាក្យនេះ ព្រះសាស្ដាទ្រង់ត្រាស់សំដៅយកមនុស្សលោកនេះ

ប៉ុណ្ណោះ ។ បទថា **លោកំ អភិភុយ្យ** បរវាទីពោលព្រោះការឃើញថា ទ្រង់គ្របសង្កត់ហើយនូវមនុស្សលោក តែក្នុងពាក្យនេះ ព្រះសាស្តាទ្រង់គ្របសង្កត់លោក គឺអារម្មណ៍គង់នៅ ។ បទថា **អនុបលិត្តោ លោកេន** បរវាទីពោលសំដៅយកការមិនប្រឡាក់ដោយមនុស្សលោក ។ សេចក្តីពិត ព្រះសាស្តា ទ្រង់មិនប្រឡាក់ដោយកិលេសទាំងឡាយ ក្នុងលោកធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាង ដូច្នេះ ៕

**អដ្ឋកថាមនុស្សលោកកថា ចប់**

# អភិធម្មបិដក

## ធម្មទេសនាកថា

[ ៣០៦ ] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ទេឬ ។ អើ ។ ចុះអ្នកណាសម្តែងធម៌ ។ ព្រះពុទ្ធនិម្មិតសម្តែង ។ ចុះព្រះពុទ្ធនិម្មិត ជាព្រះជិនស្រី ជាសាស្តា ជាសម្មាសម្ពុទ្ធ ជាសព្វញ្ញុពុទ្ធ ឃើញនូវធម៌ទាំងពួង ជាធម្មស្សាមី មានធម៌ជាទីរឭកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ទេឬ ។ អើ ។ ចុះអ្នកណាសម្តែង ។ ព្រះអានន្ទមានអាយុសម្តែង ។ ព្រះអានន្ទមានអាយុ ជាព្រះជិនស្រី ជាសាស្តា ជាសម្មាសម្ពុទ្ធ ជាសព្វញ្ញុពុទ្ធ ឃើញនូវធម៌ទាំងពួង ជាធម្មស្សាមី មានធម៌ជាទីរឭកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៧ ] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្តតថាគតគប្បីសម្តែងធម៌ដោយសង្ខេបខ្លះ ម្នាលសារីបុត្ត តថាគតគប្បីសម្តែងធម៌ដោយពិស្តារខ្លះ ម្នាលសារីបុត្ត តថាគតគប្បីសម្តែងធម៌ដោយសង្ខេបនិងពិស្តារខ្លះ ព្រោះបុគ្គលអ្នកត្រាស់ដឹង រកបានដោយកម្រ ពាក្យដូច្នេះមានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ ។

[ ៣០៨ ] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ សម្តែងនូវ

ធម៌ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងធម៌ ដើម្បីត្រាស់ដឹង មិនសំដែងធម៌ ដើម្បីមិនត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងធម៌ ប្រកបដោយហេតុ មិនសំដែងធម៌ មិនប្រកបដោយហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងធម៌ ប្រកបដោយបាដិហារ្យ មិនសំដែងធម៌ មិនប្រកបដោយបាដិហារ្យទេ ម្នាលភិក្ខុទាំងឡាយ តថាគត កាលសំដែងធម៌ណា ដើម្បីត្រាស់ដឹង មិនសំដែងធម៌ ដើម្បីមិនត្រាស់ដឹងទេ កាលសំដែងធម៌ ប្រកបដោយហេតុ មិនសំដែងធម៌ មិនប្រកបដោយហេតុទេ កាលសំដែងធម៌ ប្រកបដោយបាដិហារ្យ មិនសំដែងធម៌ មិនប្រកបដោយបាដិហារ្យទេ ឱវាទ អ្នកគួរធ្វើ អនុសាសនី អ្នកគួរធ្វើ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួររីករាយថា ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ព្រះធម៌ គឺព្រះពុទ្ធសំដែងល្អហើយ ព្រះសង្ឃ ប្រតិបត្តិហើយដោយប្រពៃ កាលដែលព្រះមានព្រះភាគ ទ្រង់សំដែងវេយ្យាករណ៍នេះ លោកធាតុដប់ពាន់ក៏កម្រើក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងនូវធម៌ ។

## ធម្មទេសនាកថា ចប់

# អដ្ឋកថា

## ធម្មទេសនាកថា

[ ៣០៦ ] ឥឡូវនេះ នឹងពណ៌នាអំពីព្រះមានព្រះភាគ ទ្រង់សម្ដែងនូវធម៌ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយវេតុល្លកៈនោះឯងថា ព្រះមានព្រះភាគ ទ្រង់តាំងនៅក្នុងស្ថានសួគ៌ជាន់តុសិត ហើយទ្រង់បញ្ជូនរូបនិម្មិតទៅ ដើម្បីប្រយោជន៍ដល់ការសម្ដែងធម៌ រូបនិម្មិតក្ដី ព្រះអានន្ទក្ដី ទទួលព្រះធម្មទេសនារបស់ព្រះពុទ្ធមកសម្ដែង មិនមែនព្រះពុទ្ធមានព្រះភាគទ្រង់សម្ដែងឡើយដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើរូបនិម្មិតនោះសម្ដែងធម៌ រូបនិម្មិតនោះ ក៏គប្បីជាព្រះសាស្ដា ដូច្នេះ ទើបពោលពាក្យថា **អភិនិម្មិតោ ជិនោ** ជាដើម ។ បរវាទីកាលមិនព្រមទទួលបែបនោះ ទើបឆ្លើយបដិសេធ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

### អដ្ឋកថាធម្មទេសនាកថា ចប់

# អភិធម្មបិដក

## ករុណាកថា

[ ៣០៩ ] ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ មេត្តា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ មុទិតា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។បេ។ ឧបេក្ខា ( មិនមានទេឬ ) ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១០ ] មេត្តា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អើ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មុទិតា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។បេ។ ឧបេក្ខា ( មានដែរឬ ) ។ អើ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១១ ] ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ ព្រះមានព្រះភាគ មិនប្រកបដោយសេចក្តីករុណាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះមានព្រះភាគ ប្រកបដោយសេចក្តីករុណា ជាប្រយោជន៍ដល់សត្វលោក ជាអ្នកអនុគ្រោះដល់សត្វលោក ប្រព្រឹត្តប្រយោជន៍ដល់សត្វលោកដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ប្រកបដោយសេចក្តីករុណា ជាប្រយោជន៍ដល់សត្វលោក ជាអ្នកអនុគ្រោះដល់សត្វលោក ប្រព្រឹត្តប្រយោជន៍ដល់សត្វលោក ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា

ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។

[ ៣១២ ] ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ចូលមហាករុណាសមាបត្តិដែរឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ចូលមហាករុណាសមាបត្តិដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។

[ ៣១៣ ] ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អើ ។ ព្រះមានព្រះភាគប្រកបដោយរាគៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ករុណារបស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។

## ករុណាកថា ចប់

# អដ្ឋកថា

## ករុណាកថា

[ ៣០៩ ] ឥឡូវនេះ នឹងពណ៌នាអំពីសេចក្តីករុណាដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា ធម្មតាសេចក្តីករុណា គឺរាគៈនោះឯង រាគៈនោះមិនមានដល់ព្រះមានព្រះភាគ ព្រោះហេតុនោះ សេចក្តីករុណារបស់ព្រះពុទ្ធមានព្រះភាគមិនមាន ព្រោះឃើញការប្រព្រឹត្តទៅនូវករុណាបដិរូប ( ធម៌ដែលស្រដៀងនឹងករុណា ) ក្នុងវិបត្តិនៃវត្ថុទាំងឡាយ ដែលគួរស្រឡាញ់ ដោយអំណាចនៃការត្រេកអររបស់បុគ្គលដែលមានរាគៈទាំងឡាយ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **នត្ថិ ពុទ្ធស្ស ភគវតោ មេត្តា** ជាដើម ដើម្បីចោទសួរបរវាទីនោះថា ឈ្មោះថា សេចក្តីករុណានោះមានជាតិស្មើជាមួយធម៌ទាំងឡាយ មានមេត្តាជាដើម ព្រោះភាពជាធម៌ មិនមែនកិលេស ព្រោះភាពមានសត្វជាអារម្មណ៍ ព្រោះភាពជាចេតោវិមុត្តិ និងព្រោះភាពជាធម៌មានអានិសង្ស ១១ ប្រការ ព្រោះហេតុនោះ បើសេចក្តី

ករុណារបស់ព្រះមានព្រះភាគមិនមានសោត ធម៌ទាំងឡាយ មានមេត្តាជាដើម ក៏មិនគប្បីមានដល់ព្រះសម្ពុទ្ធ ដូច្នេះ ។

[ ៣១១ ] ក្នុងបញ្ហាថា **អាការុណិកោ** បរវាទី កាលមិនឃើញវោហារបែបនោះ ទើបឆ្លើយបដិសេធ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ដូច្នេះ ។ល។

**អដ្ឋកថាករុណាកថា ចប់**

# អភិធម្មបិដក

## គន្ធជាតកថា

[ ៣១៤ ] ឧច្ចារៈ និងបស្សាវៈរបស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេកឬ ។ អើ ។ ព្រះមានព្រះភាគ សោយគ្រឿងក្រអូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះមានព្រះភាគសោយបាយ និងនំដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគសោយបាយនិងនំដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ឧច្ចារៈ និងបស្សាវៈរបស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេកទេ ។

[ ៣១៥ ] ឧច្ចារៈ និងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេកឬ ។ អើ ។ ជនពួកខ្លះ ងូត លាប ដុសខាត់នូវឧច្ចារៈ និងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ ទុកក្នុងហិប ដាក់ក្នុងទូតាំងផ្សាយលើរានផ្សារ ធ្វើនូវកិច្ចដែលខ្លួនត្រូវធ្វើដោយគ្រឿងក្រអូប ដោយគ្រឿងក្រអូបនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**គន្ធជាតកថា ចប់**

# អដ្ឋកថា

## គន្ធជាតកថា

[ ៣១៤ ] ឥឡូវនេះ នឹងពណ៌នាអំពីគន្ធជាតដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយឧត្តរាបថកៈថា ឧច្ចារបស្សាវៈរបស់ព្រះមានព្រះភាគ មានក្លិនក្រអូបក្រៃលែងជាងគន្ធជាតដទៃៗ គន្ធជាតដែលក្រអូបក្រៃលែងជាងឧច្ចារបស្សាវៈរបស់ព្រះពុទ្ធមិនមាន ដោយអំណាចនៃសេចក្តីស្រឡាញ់ក្នុងព្រះពុទ្ធមានព្រះភាគ ដោយមិនពិចារណា ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនោះឯង ដូច្នេះ ៕៚

**អដ្ឋកថាគន្ធជាតកថា ចប់**

# អភិធម្មបិដក

## ឯកមគ្គកថា

[ ៣១៦ ] បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ៤ ។បេ។ នៃបញ្ញាទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ឬ ។ អើ ។ ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយសកទាគាមិមគ្គ ។បេ។ ដោយអនាគាមិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយមគ្គដូចម្ដេច ។ ដោយអរហត្តមគ្គ ។ បុគ្គលលះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងការលះបង់សញ្ញោជនៈ ៣ ព្រះមានព្រះភាគត្រាស់ថា សោតាបត្តិផលឬ ។ អើ ។ ប្រសិនបើ ការលះបង់សញ្ញោជនៈ ៣ ព្រះមានព្រះភាគត្រាស់ថា សោតាបត្តិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ដោយអរហត្តមគ្គទេ ។បេ។ បុគ្គលលះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងភាវៈស្រាលស្តើងនៃកាមរាគៈ និងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា សកទាគាមិផលឬ ។ អើ ។ ប្រសិនបើ

ភាវៈស្រាលស្តើងនៃកាមរាគៈ និងព្យាបាទ ព្រះមានព្រះភាគ ត្រាស់ថា សកទាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គទេ ។ បុគ្គលលះបង់កាមរាគៈ ប្រកបដោយប្រមាណតិច ព្យាបាទ ប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់កាមរាគៈ ប្រកបដោយប្រមាណតិច ព្យាបាទ ប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងការលះបង់មិនសេសសល់ នូវកាមរាគៈ និងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា អនាគាមិផលឬ ។ អើ ។ ប្រសិនបើការលះបង់មិនសេសសល់ នូវកាមរាគៈ និងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា អនាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់កាមរាគៈ ប្រកបដោយប្រមាណតិច ព្យាបាទ ប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គទេ ។

[ ៣១៧ ] បុគ្គលមិនគួរនិយាយថា បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ទេឬ ។ អើ ។ ព្រះមានព្រះភាគ ចម្រើនសោតាបត្តមគ្គឬ ។ អើ ។ ព្រះមានព្រះភាគ ជាសោតាបន្នបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ចម្រើនសកទាគាមិមគ្គ ។បេ។ ចម្រើនអនាគាមិមគ្គឬ ។ អើ ។ ព្រះមានព្រះភាគ ជាអនាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៨ ] ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ៤

ដោយអរិយមគ្គ ១ ពួកសាវកធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ៤ ឬ ។ អើ ។ ពួកសាវក ឃើញធម៌ដែលព្រះមានព្រះភាគមិនឃើញហើយ ត្រាស់ដឹងធម៌ ដែលព្រះមានព្រះភាគមិនត្រាស់ដឹងហើយ ធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ មិនធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ឯកមគ្គកថា ចប់

# អដ្ឋកថា

## ឯកមគ្គកថា

[ ៣១៦ ] ឥឡូវនេះ នឹងពណ៌នាអំពីអរិយមគ្គមួយដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយឧត្តរាបថកៈទាំងនោះឯងថា ព្រះមានព្រះភាគ ជាព្រះសោតាបន្ន ហើយជាព្រះសកទាគាមី ហើយជាព្រះអនាគាមី ហើយធ្វើឲ្យជាក់ច្បាស់នូវអរហត្ត គឺធ្វើឲ្យជាក់ច្បាស់នូវផល ៤ ដោយអរិយមគ្គមួយប៉ុណ្ណោះ ព្រោះអំណាចសេចក្តីស្រឡាញ់ ក្នុងព្រះពុទ្ធមានព្រះភាគ ដោយមិនពិចារណា ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **ចតុន្នំ ផស្សានំ** ជាដើម ដើម្បីចោទសួរបរវាទីនោះ ដោយអំណាចការរួមគ្នាតែ ១ នូវចតុក្កធម៌ទាំងឡាយ មានផស្សៈ ៤ ជាដើម ដែលកើតឡើងជាមួយផលទាំង ៤ ។

បទថា **សោតាបត្តិមគ្គេន** ជាដើម សកវាទីពោលដើម្បីសួរថា ធ្វើឲ្យជាក់ច្បាស់ដោយមគ្គណា កាលបរវាទីឆ្លើយថា ដោយអរហត្តមគ្គ ទើបសកវាទីចោទសួរ ដោយអំណាចភាវៈនៃការលះកិលេសទាំងឡាយ មានសក្កាយទិដ្ឋិជាដើម ដោយអរហត្តមគ្គនោះ ។

[ ៣១៧ ] ក្នុងបញ្ហាថា **ភគវា សោតាបន្នោ** សកវាទីឆ្លើយបដិសេធថា ព្រះពុទ្ធត្រឹមតែជាសោតាបន្ន មិនមាន ។ ក្នុង ២ បញ្ហាខាងមុខ ក៏មានន័យនេះឯង ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ដូច្នេះ ៕

# អភិធម្មបិដក

## ឈានសង្គហកថា

[ ៣១៩ ] បុគ្គលចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយបានដែរ ឬ ។ អើ ។ បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានដែរ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយបានដែរឬ ។ អើ ។ បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២០ ] បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈានបានដែរ ឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងបឋមជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងទុតិយជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈានឬ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងបឋមជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងទុតិយជ្ឈានឲ្យកើតឡើងឬ ។ អើ ។ ទុតិ-យជ្ឈានរបស់បុគ្គល កាលមិនរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលមិនតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងទុតិ-យជ្ឈានរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ ទុតិយជ្ឈានរបស់បុគ្គល កាលរំពឹងកើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើង ម្នាលអ្នក

ដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិ-យជ្ឈានបានទេ ។ បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈានបានដែរឬ ។ អើ ។ បឋមជ្ឈានរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ ថាជាទោស កើតឡើងឬ ។ អើ ។ ទុតិយជ្ឈាន របស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បឋមជ្ឈានប្រកបដោយវិតក្ក ប្រកបដោយវិចារដែរឬ ។ អើ ។ ទុតិយជ្ឈានប្រកបដោយវិតក្ក ប្រកបដោយវិចារដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈានបានដែរឬ ។ អើ ។ បឋមជ្ឈាននោះឯង គឺទុតិយជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២១ ] បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានដែរឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងទុតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងទុតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងតតិយជ្ឈាន ឲ្យកើតឡើងដែរឬ ។ អើ ។ តតិយជ្ឈានរបស់បុគ្គល កាលមិនរំពឹងកើតឡើង ។បេ។ របស់បុគ្គល កាលមិនតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែង

តតិយជ្ឈានរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើតតិយជ្ឈានរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានទេ ។ បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានដែរឬ ។ អើ ។ ទុតិយជ្ឈានរបស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវវិតក្កនិងវិចារ ថាជាទោស កើតឡើងឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវវិតក្ក និងវិចារ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុតិយជ្ឈានប្រកបដោយបីតិដែរឬ ។ អើ ។ តតិយជ្ឈានប្រកបដោយបីតិដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានដែរឬ ។ អើ ។ ទុតិយជ្ឈាននោះឯង គឺតតិយជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២២ ] បុគ្គលចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានដែរឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងចតុត្ថជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានដែរឬ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងចតុត្ថជ្ឈានឲ្យកើតឡើង

ដែរឬ ។ អើ ។ ចតុត្ថជ្ឈាន របស់បុគ្គល កាលមិនរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលមិនតាំងចិត្តទុក កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ ក្រែងចតុត្ថជ្ឈានរបស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិបើ ចតុត្ថជ្ឈាន របស់បុគ្គល កាលរំពឹង កើតឡើង ។បេ។ របស់បុគ្គល កាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានទេ ។ បុគ្គលចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ ចតុត្ថជ្ឈានបានដែរឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវបីតិ ថាជាទោស កើតឡើងដែរឬ ។ អើ ។ ចតុត្ថជ្ឈានរបស់បុគ្គល កាល ធ្វើទុកក្នុងចិត្ត នូវបីតិ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ តតិយជ្ឈានប្រកបដោយសុខឬ ។ អើ ។ ចតុត្ថជ្ឈានប្រកប ដោយសុខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញអំពី តតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានដែរឬ ។ អើ ។ តតិយជ្ឈាននោះ ឯង គឺចតុត្ថជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៣ ] បុគ្គលមិនគួរនិយាយថា បុគ្គលចេញអំពីឈានមួយ រំកិល ទៅកាន់ឈានមួយបានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុ នោះ បុគ្គលចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយបាន ។

# អដ្ឋកថា

## ឈានសង្កន្តិកថា

[ ៣១៩ ] ឥឡូវនេះ នឹងពណ៌នាអំពីការរំកិលទៅកាន់ឈានដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហិសាសកៈ និងដូចលទ្ធិនិកាយអន្ធកៈពួកខ្លះថា យោគីបុគ្គលរំកិលចាកឈានមកកាន់ឈាន ដោយវៀរចាកការប្រព្រឹត្តទៅនៃឧបចារៈរបស់ឈាននោះៗ ព្រោះអាស្រ័យការសម្តែងឈានដោយលំដាប់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវទុតិយជ្ឈាន ។បេ។ ព្រោះរម្ងាប់នូវវិតក្កនិងវិចារ ។បេ។ ក៏បានដល់នូវតតិយជ្ឈាននោះ ។បេ។ ក៏បានដល់នូវចតុត្ថជ្ឈាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ពោលពាក្យថា **បឋមា ឈានា** ជាដើម ដើម្បីសួរបរវាទីថា បើតាមលទ្ធិរបស់អ្នក បុគ្គលមិនសម្រេចឧបចារៈនៃទុតិយជ្ឈាន រមែងរំកិលចាកបឋមជ្ឈាន ចូលកាន់ទុតិយជ្ឈានបាន ដោយមិនចាំបាច់ប្រព្រឹត្តទៅ តាមលំដាប់សោត បុគ្គលក៏គប្បីរំកិលចាកបឋមជ្ឈានចូលកាន់តតិយជ្ឈាន ចាកទុតិយជ្ឈាន ចូលកាន់ចតុត្ថជ្ឈានបាន ដូច្នេះ ។

[ ៣២០ ] បទថា **យោ បឋមស្ស** ជាដើម សកវាទីសួរថា បើបុគ្គលចូលទុតិយជ្ឈាន បន្ទាប់អំពីបឋមជ្ឈាន ឬចូលតតិយជ្ឈានជាដើម បន្ទាប់អំពីទុតិយជ្ឈានជាដើមបានសោត បុគ្គលក៏គប្បីចូលឈានបាន ដោយអាវជ្ជនចិត្ត

១ ( ការទឹកតែម្តង ចូលឈានបានគ្រប់ឈាន ) ។ បទថា **កាមេ អាទីនវតោ** អធិប្បាយថា កាលព្រះយោគីធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ដោយភាពជាទោស បឋមជ្ឈាន រមែងកើតឡើងខាងក្រោយ តែក្នុងខណៈនៃឈាន ព្រះយោគីបុគ្គល រមែងធ្វើនិមិត្តនោះៗ ឯង ក្នុងចិត្ត ។

បទថា **តញ្ចេវ បឋមំ** ជាដើម អធិប្បាយថា សកវាទីសួរថា បើឈានគប្បីកើតបាន ដោយមិនមានរវាងចន្លោះ ដូចជវនចិត្តដួងក្រោយ កើតបន្តអំពីជវនចិត្តដួងមុនសោត បឋមជ្ឈាននោះឯង ក៏គប្បីជាទុតិយជ្ឈាននោះបានតាមលក្ខណៈ ដោយវៀរចាកលំដាប់មុនក្រោយ ។ គប្បីជ្រាបអត្ថក្នុងទីទាំងពួង ដោយឧបាយនេះ ។

[ ៣២៣ ] ដោយពាក្យទាំងឡាយថា **វិវិច្ចេវ កាមេហិ** ជាដើម ព្រះសូត្រនេះ រមែងសម្តែងភាពដែលឈានទាំងឡាយ ជាឈានដែលព្រះមានព្រះភាគទ្រង់សម្តែងដោយលំដាប់ មិនមែនសម្តែងដល់ការកើតឡើងនៃឈានដែលជាប់តគ្នាទៅ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាង ដូច្នេះ ។

## អដ្ឋកថាឈានសង្កន្តិកថា ចប់

# អភិធម្មបិដក

## ឈានន្តរិកកថា

[ ៣២៤ ] ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃផស្សៈ មានដែរឬ ។បេ។ ធម៌ជាចន្លោះនៃបញ្ញាមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះនៃទុតិយជ្ឈាន និងតតិយជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះនៃតតិយជ្ឈាន និងចតុត្ថជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៥ ] ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃទុតិយជ្ឈាន និងតតិយជ្ឈានទេឬ ។ អើ ។ ប្រសិនបើ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃទុតិយជ្ឈាន និងតតិយជ្ឈានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ជាចន្លោះនៃឈាន មានទេ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃតតិយជ្ឈាន និងចតុត្ថជ្ឈានទេឬ ។ អើ ។ ប្រសិនបើ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃតតិយជ្ឈាន និងចតុត្ថជ្ឈានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ជាចន្លោះនៃឈាន មានទេ ។

[ ៣២៦ ] ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះនៃបឋមជ្ឈាន និងទុតិយជ្ឈានឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះនៃទុតិយជ្ឈាន និងតតិយជ្ឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះនៃបឋមជ្ឈាន និងទុតិយជ្ឈានឬ ។ អើ ។ ធម៌ជាចន្លោះ

នៃឈាន មានក្នុងចន្លោះនៃតតិយជ្ឈាន និងចតុត្ថជ្ឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៧ ] ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃទុតិយជ្ឈាន និងតតិយជ្ឈានទេឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃបឋមជ្ឈាន និងទុតិយជ្ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃតតិយជ្ឈាន និងចតុត្ថជ្ឈានទេឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះនៃបឋមជ្ឈាន និងទុតិយជ្ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៨ ] សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ ជាធម៌ ជាចន្លោះនៃឈានឬ ។ អើ ។ សមាធិប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាធម៌ ជាចន្លោះនៃធម៌ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ ជាធម៌ ជាចន្លោះនៃឈានឬ ។ អើ ។ សមាធិ មិនមានវិតក្ក មិនមានវិចារ ជាធម៌ ជាចន្លោះនៃឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៩ ] សមាធិ ប្រកបដោយវិតក្ក ប្រកបដោយវិចារ មិនមែនជាធម៌ ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ មិនមែនជាធម៌ ជាចន្លោះនៃឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សមាធិ មិនមានវិតក្ក មិនមានវិចារ មិនមែនជាធម៌ ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ មិនមែនជាធម៌ ជាចន្លោះនៃ

ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣០ ] សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ មានក្នុងចន្លោះនៃឈានទាំងពីរ ដែលកើតចំពោះហើយឬ ។ អើ ។ ក្រែងកាលសមាធិមិនមានវិតក្ក មានត្រឹមតែវិចារ កំពុងប្រព្រឹត្តទៅ បឋមជ្ឈានរលត់ ទុតិយជ្ឈានមិនទាន់កើតឡើងទេឬ ។ អើ ។ ប្រសិនបើ កាលសមាធិមិនមានវិតក្ក មានត្រឹមតែវិចារ កំពុងប្រព្រឹត្តទៅ បឋមជ្ឈានរលត់ ទុតិយជ្ឈាន មិនទាន់កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ មានក្នុងចន្លោះនៃឈានទាំងពីរ ដែលកើតចំពោះហើយ ថាជាធម៌ ជាចន្លោះនៃឈានទេ ។

[ ៣៣១ ] សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ មិនមែនជាធម៌ ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ ជាបឋមជ្ឈាន ។បេ។ ជាទុតិយជ្ឈាន ។បេ។ ជាតតិយជ្ឈាន ។បេ។ ជាចតុត្ថជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ សមាធិ មិនមានវិតក្ក មានត្រឹមតែវិចារ ជាធម៌ ជាចន្លោះនៃឈាន ។

[ ៣៣២ ] សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារ ជាធម៌ ជាចន្លោះនៃឈានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកសមាធិ ៣ យ៉ាង គឺសមាធិប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារ ១ សមាធិ មិនមានវិតក្កៈ មិនមានវិចារ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកសមាធិ ៣ យ៉ាង គឺសមាធិប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារ ១ សមាធិ មិនមានវិតក្កៈ មិនមានវិចារ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារ ជាធម៌ ជាចន្លោះនៃឈានទេ ។

ឈានន្តរិកកថា ចប់

# អដ្ឋកថា

## ឈានន្តរិកកថា

[ ៣២៤ ] ឥឡូវនេះ នឹងពណ៌នាអំពីធម៌ជាចន្លោះនៃឈានដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា ដែលមិនដឹងឱកាសនៃសមាធិ ដែលមិនមានវិតក្ក មានតែវិចារថា ក្នុងទិដ្ឋិបញ្ចកន័យ ព្រះមានព្រះភាគ ទ្រង់ចែកឈាន ៥ យ៉ាង សមាធិទាំងអស់ ទ្រង់លើកឡើងសម្តែង ៣ យ៉ាង ទើបមានលទ្ធិ ដូចលទ្ធិរបស់និកាយសមិតិយៈ និងដូចលទ្ធិរបស់និកាយអន្ធកៈពួកខ្លះថា ឈ្មោះថា ធម៌ជាចន្លោះនៃឈាននោះ មានក្នុងចន្លោះឈានទី ១ និងឈានទី ២ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ពោលពាក្យថា **អត្ថិ ផស្សន្តរិកា** ជាដើម ដើម្បីសួរបរវាទីនោះថា ឈានក្តី ផស្សៈជាដើមក្តី ជាចេតសិកធម៌ ព្រោះហេតុនោះ បើឈ្មោះថា ធម៌ជាចន្លោះនៃឈានគប្បីមានសោត សូម្បីធម៌ជាចន្លោះនៃផស្សៈជាដើម ក៏ត្រូវមាន តាមលទ្ធិរបស់អ្នកដូច្នេះ ។

បទថា **ទុតិយស្ស ច ឈានស្ស** សកវាទីសួរថា បើធម៌ជាចន្លោះឈានគប្បីមានសោត ឈានទាំងឡាយ មានទុតិយជ្ឈាន និងតតិយជ្ឈានជាដើមនោះឯង មាន ឯធម៌ជាចន្លោះឈានទាំងនោះ ក៏គប្បីមានដែរ ។ បរវាទីឆ្លើយបដិសេធផង ឆ្លើយទទួលផង ព្រោះការមិនមានត្រឹមតែម្យ៉ាងក្នុងលទ្ធិ ។

[ ៣២៦ ] ត្រូវសួរថា **បឋមស្ស ច** បរវាទីឆ្លើយទទួល ដោយអំណាច

នៃលទ្ធិ ។

[ ៣២៨ ] បទថា **សវិតក្កោ សវិចារោ** ជាដើម សកវាទីសួរថា កាលសមាធិដែលចែកជាសមាធិទាំង ៣ មាន សមាធិដែលមិនមានវិតក្ក មាន ត្រឹមតែវិចារនោះឯង ជាធម៌ជាចន្លោះនៃឈាន សមាធិក្រៅអំពីនេះ មិនមែន ព្រោះហេតុនោះ អ្វីជាហេតុប្លែកគ្នាក្នុងទីនេះ ។

[ ៣៣០ ] បទថា **ទ្វិន្នំ ឈានានំ បដុប្បន្នានំ** សកវាទី សួរសំដៅ ដល់បឋមជ្ឈាន និងទុតិយជ្ឈាន ។ បរវាទីឆ្លើយទទួលដោយលទ្ធិថា សមាធិ ដែលមិនមានវិតក្ក មានតែវិចារ ក្នុងចន្លោះនៃឈានទាំង ២ ដែលកើតឡើង ជាបច្ចុប្បន្នទាំងនោះ ឈ្មោះថា ធម៌ជាចន្លោះឈាន ។

បរវាទីត្រូវសួរថា **បឋមំ ឈានំ និរុទ្ធំ** ក៏ឆ្លើយទទួល ព្រោះគិតថា ការប្រព្រឹត្តទៅក្នុងខណៈមួយនៃឈានទាំង ៣ មិនត្រឹមត្រូវ ។

[ ៣៣១ ] បរវាទីសួរដោយអំណាចនៃចតុក្កន័យថា **អវិតក្កោ វិចារ-មត្តោ សមាធិ បឋមំ ឈានំ** សកវាទីឆ្លើយបដិសេធ ព្រោះការមិនមាននៃ ឈាននោះ ក្នុងន័យនោះ ។

[ ៣៣២ ] ក្នុងបទនេះថា **ឆន្ទុ តយោ សមាធី** មានអធិប្បាយថា បណ្ដាសមាធិទាំង ៣ នោះ សមាធិ ២ ជាឈានមួយ មិនជាធម៌ជាចន្លោះ នៃឈាន យ៉ាងណា សមាធិក្រៅអំពីនេះ ក៏គប្បីជាឈាននោះឯង មិនគប្បី ជាធម៌ជាចន្លោះនៃឈាន ក៏យ៉ាងនោះ ដោយប្រការដូច្នេះ ៕

**អដ្ឋកថាឈានន្តរិកកថា ចប់**

# អភិធម្មបិដក

## សមាបន្នោ សទ្ទំ សុណាតីតិកថា

[ ៣៣៣ ] បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរឬ ។ អើ ។ បុគ្គលចូលកាន់សមាបត្តិ ឃើញរូបដោយចក្ខុ ។បេ។ ដោយត្រចៀក ។បេ។ ដោយច្រមុះ ។បេ។ ដោយអណ្តាត ។បេ។ ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរឬ ។ អើ ។ បុគ្គលចូលកាន់សមាបត្តិ ព្រមព្រៀងដោយសោតវិញ្ញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសមាធិរបស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណឬ ។ អើ ។ ប្រសិនបើ សមាធិរបស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងទេ ។

[ ៣៣៤ ] សមាធិរបស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ចុះបុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសំឡេងដែរឬ ។ អើ ។ ប្រសិនបើ សមាធិរបស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ បុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសំឡេងដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងទេ ។ សមាធិរបស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ចុះបុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសំឡេងដែឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៥ ] បុគ្គលមិនគួរនិយាយថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេង ទេឬ ។ អើ ។ ក្រែងសំឡេង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈានឬ ។ អើ ។ ប្រសិនបើ សំឡេង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរ ។ សំឡេង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ។ ចុះបុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរឬ ។ អើ ។ វិតក្ក និងវិចារ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃទុតិយជ្ឈាន ចុះវិតក្ក និងវិចារ របស់ទុតិយជ្ឈាននោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សំឡេង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ។ ចុះបុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរឬ ។ អើ ។ បីតិជាសត្រូវនៃតតិយជ្ឈាន ខ្យល់ដកដង្ហើមចេញចូល ជាសត្រូវនៃចតុត្ថជ្ឈាន រូបសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់អាកាសានញ្ចាយតនៈ អាកាសានញ្ចាយតនសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់វិញ្ញាណញ្ចាយតនៈ វិញ្ញាណញ្ចាយតនសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់អាកិញ្ចញ្ញាយតនៈ អាកិញ្ចញ្ញាយតនសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនៈ សញ្ញា និងវេទនា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ ចុះសញ្ញា និងវេទនារបស់បុគ្គលនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**សមាបន្នោ សទ្ទំ សុណាតីតិកថា ចប់**

# អដ្ឋកថា
## សមាបន្នោ សទ្ទំ សុណាតីតិកថា

[ ៣៣៣ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលចូលសមាបត្តិ ឮសំឡេងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វ-សេលិយៈទាំងឡាយថា ព្រោះព្រះមានព្រះភាគត្រាស់សំឡេងថាជាបន្លា គឺជាសត្រូវចំពោះបឋមជ្ឈាន បើបុគ្គលចូលឈានមិនបានឮសំឡេងសោត សំឡេងនោះ គប្បីជាបន្លាបានដូចម្តេច ព្រោះហេតុនោះ បុគ្គលចូលឈាន បានឮសំឡេង ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **ចក្ខុនា រូបំ បស្សតិ** ជាដើម សកវាទីសួរថា ដរាបណាបុគ្គលនៅចូលឈាននៅឡើយ អារម្មណ៍តាមបញ្ចទ្វារមិនមាន កាលអារម្មណ៍តាមបញ្ចទ្វារនោះមិនមាន បើបុគ្គលនោះ បានឮសំឡេងសោត បុគ្គលនោះក៏គប្បីឃើញនូវរូបបាន ដូច្នេះ ។

[ ៣៣៥ ] បទថា **សទ្ទោ កណ្ដកោ** ព្រះមានព្រះភាគត្រាស់ហើយ ព្រោះសំឡេងនោះ ធ្វើនូវការរាយមាយ ។ ពិតហើយ កាលបើសំឡេងដែលគ្រោតគ្រាត ប៉ះខ្ទប់សោតៈហើយ ការចេញចាកឈាន មានដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាងថា បុគ្គលចូលសមាបត្តិ ឮសំឡេងបាន ដូច្នេះ ។

បទថា **ទុតិយស្ស ឈានស្ស** ជាដើម សកវាទីពោលដើម្បីឲ្យដឹងថា សត្រូវដទៃៗ មិនមានខាងក្នុងនៃសមាបត្តិ យ៉ាងណា សូម្បីការឮនូវសំឡេងជាដើម មិនមានក្នុងសមាបត្តិ ក៏យ៉ាងនោះ ។ ពាក្យទាំងពួង មានអត្ថងាយយល់ហើយ ។៙

**អដ្ឋកថាសមាបន្នោសទ្ទំសុណាតីតិកថា ចប់**

# អភិធម្មបិដក

## ចក្ខុនា រូបំ បស្សតីតិកថា

[ ៣៣៦ ] បុគ្គលឃើញរូប ដោយចក្ខុឬ ។ អើ ។ បុគ្គលឃើញរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលឃើញរូប ដោយរូបឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដឹងច្បាស់នូវរូប ដោយរូបឬ ។ អើ ។ រូប គឺមនោវិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលឃើញរូប ដោយចក្ខុឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃចក្ខុ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងការរំពឹង ។បេ។ ការតាំងចិត្តទុកនៃចក្ខុ មិនមានទេឬ ។ អើ ។ ប្រសិនបើ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃចក្ខុ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលឃើញរូប ដោយចក្ខុទេ ។

[ ៣៣៧ ] បុគ្គលឮសំឡេង ដោយត្រចៀកឬ ។បេ។ ធុំក្លិន ដោយប្រមុះឬ ។បេ។ លិទ្ធភ្លក្សរស ដោយអណ្តាតឬ ។បេ។

[ ៣៣៨ ] បុគ្គលពាល់ត្រូវផោដ្ឋព្វៈ ដោយកាយឬ ។ អើ ។ បុគ្គលពាល់ត្រូវរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលពាល់ត្រូវរូប ដោយរូបឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដឹងច្បាស់នូវរូប ដោយរូបឬ ។ អើ ។ រូប គឺមនោវិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលពាល់ត្រូវ

ផោដ្ឋព្វៈ ដោយកាយឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃកាយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងការរំពឹង ។បេ។ ការតាំងចិត្តទុកនៃកាយ មិនមានទេឬ ។ អើ ។ ប្រសិនបើ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃកាយ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលពាល់ត្រូវផោដ្ឋព្វៈ ដោយកាយទេ ។បេ។

[ ៣៣៩ ] បុគ្គលមិនគួរនិយាយថា បុគ្គលឃើញរូប ដោយចក្ខុ ។បេ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលឃើញរូបដោយចក្ខុ ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។

ចក្ខុនា រូបំ បស្សតីតិកថា ចប់

អដ្ឋារសមវគ្គ ចប់

## ឧទ្ទាននៃអដ្ឋារសមវគ្គនោះ គឺ

និយាយអំពីព្រះពុទ្ធមានព្រះភាគ គង់នៅក្នុងមនុស្សលោក ១ ព្រះពុទ្ធមានព្រះភាគទ្រង់សម្តែងធម៌ ១ករុណារបស់ព្រះពុទ្ធមានព្រះភាគមិនមាន ១ ឧច្ចារៈ និងបស្សាវៈរបស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេក ១ បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផលទាំង ៤ ដោយអរិយមគ្គតែមួយ ១ បុគ្គលចេញអំពីឈានរំកិលទៅកាន់ឈាន ១ ធម៌ជាចន្លោះនៃឈានមាន ១ បុគ្គលចូលកាន់សមាបត្តិឮសំឡេង ១ បុគ្គលឃើញរូបដោយចក្ខុ បុគ្គលពាល់ត្រូវផោដ្ឋព្វៈដោយកាយ ១ ។

# អដ្ឋកថា

## ចក្ខុនា រូបំ បស្សតីតិកថា

[ ៣៣៦ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលឃើញរូបដោយចក្ខុដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ចក្ខុបសាទប៉ុណ្ណោះ ឃើញរូប ព្រោះអាស្រ័យព្រះពុទ្ធវចនៈថា ឃើញរូបដោយចក្ខុ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះទើបសកវាទីពោលពាក្យថា **រូបេន រូបំ បស្សតិ** ជាដើម ដើម្បីសួរបរវាទីនោះថា បើបុគ្គលឃើញរូបដោយចក្ខុសោត បុគ្គលក៏គប្បីឃើញរូបដោយរូបដូច្នេះ ។ បរវាទីឆ្លើយបដិសេធ សំដៅយករូបាយតនៈ ត្រូវសួរដដែលទៀតក៏ឆ្លើយទទួល សំដៅយកចក្ខុនោះឯង ។

ក្នុងបទថា **បដិជានាតិ** នេះ មានអធិប្បាយថា ពួកយើងសួរថា ឃើញដោយសំដៅដល់ការដឹងចំពោះ មិនមែនសួរដល់ត្រឹមតែការចូលទៅអាស្រ័យចក្ខុឃើញ ព្រោះហេតុនោះ ចូរអ្នកពោលមកថា បុគ្គលមានចក្ខុ ឃើញរូបដោយរូប តាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធផង ឆ្លើយទទួលផងដោយន័យមុននោះឯង ។ គ្រានោះ ទើបសកវាទីពោលថា **រូបំ មនោវិញ្ញាណំ** ដើម្បីសួរបរវាទីនោះថា កាលបើយ៉ាងនេះ រូបក៏ប្រាកដថាជាមនោវិញ្ញាណ ព្រោះថា មនោវិញ្ញាណនោះ ឈ្មោះថា ដឹង ដូច្នេះ ។ បរវាទី កាលមិនបានលេសន័យ គឺគោលអាងបន្តិចបន្តួច ទើបឆ្លើយបដិសេធ ។ បទថា **អត្ថិ**

**ចក្ខុស្ស អាវដ្ដនា** ជាដើម សេចក្តីថា សកវាទីសួរថា បើចក្ខុឃើញ ព្រោះអត្ថថា ដឹងសោត ការទឹកគិត គឺអាវជ្ជនៈរបស់ចក្ខុនោះ ក៏គប្បីជាអាវជ្ជនៈរបស់ចក្ខុវិញ្ញាណ ដូច្នេះ ។ បរវាទីឆ្លើយបដិសេធថា **ន ហេវំ** ព្រោះចក្ខាយតនៈ មិនទាក់ទងដោយការទឹក និងកើតឡើងបន្ទាប់អំពីការទឹកគិត ។ ក្នុងបទថា **សោតេន សទ្ទំ** ជាដើម ក៏មានន័យនេះឯង ។

[ ៣៣៩ ] ព្រះសូត្រថា **ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ បស្សតិ** ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយន័យរបស់សសម្ភារកថា ដូចបុគ្គលបាញ់ដោយព្រួញ គេក៏ហៅថា បាញ់ដោយធ្នូ យ៉ាងណា បុគ្គលសូម្បីឃើញដោយចក្ខុវិញ្ញាណ គេក៏ហៅថា ឃើញដោយចក្ខុ ក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាងថា ឃើញរូបដោយភ្នែក ។ ក្នុងពាក្យដ៏សេសទាំងឡាយ ក៏មានន័យនេះឯង ដូច្នេះ ៕

**អដ្ឋកថា ចក្ខុនា រូបំ បស្សតីតិកថា ចប់**

**វគ្គទី ១៨ ចប់**

# អភិធម្មបិដក

## កិលេសជហានកថា

[ ៣៤០ ] បុគ្គលលះបង់ពួកកិលេសជាអតីត ( កន្លងហើយ ) ឬ ។ អើ ។ បុគ្គលញ៉ាំងរបស់ដែលរលត់ហើយ ឲ្យរលត់ទៅ ញ៉ាំងរបស់ដែលទៅប្រាសហើយ ឲ្យទៅប្រាស ញ៉ាំងរបស់ដែលអស់ហើយ ឲ្យអស់ទៅ ញ៉ាំងរបស់ដែលវិនាសទៅហើយ ឲ្យវិនាសទៅ ញ៉ាំងរបស់ដែលបាត់ទៅហើយ ឲ្យបាត់ទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់ពួកកិលេសជាអតីតឬ ។ អើ ។ ក្រែងរបស់ជាអតីត រលត់ទៅហើយឬ ។ អើ ។ ប្រសិនបើ របស់ជាអតីត រលត់ទៅហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់ពួកកិលេសជាអតីតទេ ។ បុគ្គលលះបង់ពួកកិលេសជាអតីតឬ ។ អើ ។ ក្រែងរបស់ជាអតីត មិនមានទេឬ ។ អើ ។ ប្រសិនបើ របស់ជាអតីត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់ពួកកិលេស ជាអតីតទេ ។

[ ៣៤១ ] បុគ្គលលះបង់ពួកកិលេស ជាអនាគតឬ ។ អើ ។ បុគ្គលញ៉ាំងរបស់មិនទាន់កើត មិនឲ្យកើត ញ៉ាំងរបស់មិនទាន់ដុះដាល មិនឲ្យដុះដាល ញ៉ាំងរបស់មិនទាន់លូតលាស់ មិនឲ្យលូតលាស់ ញ៉ាំងរបស់មិនទាន់កើតប្រាកដ មិនឲ្យកើតប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់ពួកកិលេស ជាអនាគតឬ ។ អើ ។ ក្រែងរបស់ជាអនាគត មិនទាន់កើតទេឬ ។ អើ ។ ប្រសិនបើ របស់ជាអនាគត មិនទាន់កើតទេ ម្នាលអ្នក

ដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់ពួកកិលេស ជាអនាគតទេ ។ បុគ្គលលះបង់ពួកកិលេស ជាអនាគតឬ ។ អើ ។ ក្រែងរបស់ជាអនាគត មិនមានទេឬ ។ អើ ។ ប្រសិនបើ របស់ជាអនាគត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះបង់ពួកកិលេស ជាអនាគតទេ ។

[ ៣៨២ ] បុគ្គលលះបង់ពួកកិលេស ជាបច្ចុប្បន្នឬ ។ អើ ។ បុគ្គលត្រេកអរ លះបង់រាគៈ បុគ្គលប្រទូស្ត លះបង់ទោសៈ បុគ្គលវង្វេង លះបង់មោហៈ បុគ្គលសៅហ្មង លះបង់ពួកកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះបង់រាគៈ ដោយរាគៈ លះបង់ទោសៈ ដោយទោសៈ លះបង់មោហៈដោយមោហៈ លះបង់ពួកកិលេសដោយពួកកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រាគៈប្រកបដោយចិត្ត មគ្គប្រកបដោយចិត្តដែរឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រាគៈ ជាអកុសល មគ្គ ជាកុសលឬ ។ អើ ។ ពួកធម៌ជាកុសល និងអកុសល ប្រកបដោយទោស និងមិនមានទោស ថោកទាប និងឧត្តម មានចំណែកខ្មៅ និង-ស មកកាន់ការៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសល និងអកុសល ។បេ។ មានចំណែក ( ខ្មៅ និងស ) មកកាន់ការៈចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយមាន ៤ ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងផែនដីនេះ ឈ្មោះថា ឆ្ងាយក្រៃលែងឆ្ងាយទី ១ ។បេ។ ព្រោះហេតុ

នោះ ធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ជាកុសល និងអកុសល ។បេ។ មកកាន់ការៈចំពោះមុខទេ ។

[ ៣៤៣ ] បុគ្គលមិនគួរនិយាយថា បុគ្គលលះបង់ពួកកិលេស ជាអតីត លះបង់ពួកកិលេស ជាអនាគត លះបង់ពួកកិលេស ជាបច្ចុប្បន្នទេឬ ។ អើ ។ បុគ្គលលះបង់ពួកកិលេស មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បុគ្គលលះបង់ពួកកិលេស ជាអតីត លះបង់ពួកកិលេស ជាអនាគត លះបង់ពួកកិលេស ជាបច្ចុប្បន្ន ។

**កិលេសជហនកថា ចប់**

# អដ្ឋកថា

## កិលេសជហានកថា

[ ៣៤០ ] ឥឡូវនេះ នឹងពណ៌នាអំពីការលះកិលេសដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយពួកខ្លះថា ព្រោះឈ្មោះថា ការលះកិលេស មាន ដ្បិតថា កិលេសទាំងឡាយដែលជាអតីតក្តី ជាអនាគតក្តី និងបច្ចុប្បន្នក្តី ជាសភាវៈដែលបុគ្គលអ្នកមានកិលេសលះបានហើយ លះទៅហើយទាំងអស់ ព្រោះហេតុនោះ បុគ្គលលះកិលេសដែលជាអតីតផង ដែលជាអនាគតផង ដែលជាបច្ចុប្បន្នផង ដូច្នេះ ពាក្យសួររបស់សកវាទីថា **អតីតេ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនោះឯង ។

[ ៣៤៣ ]ម្យ៉ាងទៀត ក្នុងបញ្ហារបស់បរវាទីថា **នត្ថិ កិលេសេ ជហាតិ** នេះ មានអធិប្បាយថា កាលបុគ្គលលះកិលេសទាំងឡាយ មិនមានសេចក្តីព្យាយាមលះកិលេសទាំងឡាយ មានកិលេសក្នុងអតីតជាដើម ដូចសេចក្តីព្យាយាមលះនូវសំរាមរបស់បុគ្គលដែលចោលនូវសំរាមនោះឡើយ តែកាល

អរិយមគ្គដែលមានព្រះនិព្វានជាអារម្មណ៍ប្រព្រឹត្តទៅហើយ កិលេសទាំងឡាយដែលមិនទាន់កើតនោះឯង ( សំដៅដល់កិលេសដែលជាអនុស័យ ) មិនកើតឡើង ព្រោះហេតុនោះ ទើបកិលេសទាំងឡាយ ឈ្មោះថា ត្រូវលះហើយ ព្រោះហេតុនោះ ទើបសកវាទីឆ្លើយបដិសេធថា **ន ហេវំ ។** បទថា **តេន ហិ អតីតេ កិលេសេ បជហាតិ** ជាដើម បរវាទីពោលដោយមានលេសន័យថា ព្រោះមិនគប្បីពោលថា ការលះកិលេស មិនមាន ព្រោះហេតុនោះ បុគ្គលលះកិលេសទាំងឡាយ មានកិលេសដែលជាអតីតជាដើម ដូច្នេះ ៕

**អដ្ឋកថាកិលេសជហានកថា ចប់**

# អភិធម្មបិដក

## សុញ្ញកថា

[ ៣៨៤ ] សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។ អើ ។ អនិមិត្ត ( និព្វាន ) រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។ អើ ។ អប្បណិហិត ( និព្វាន ) រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរនិយាយថា អនិមិត្ត រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរនិយាយថា អប្បណិហិត រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។ អើ ។ សង្ខារក្ខន្ធ មិនមែនជាមិនទៀង មិនមែនជាបច្ច័យប្រជុំតាក់តែង មិនមែនកើតឡើងអាស្រ័យហេតុ មិនមែនមានសភាពអស់ទៅ មិនមែនមានសភាពសូន្យទៅ មិនមែនមានសភាពប្រាសចាកតម្រេក មិនមែនមានសភាពរលត់ មិនមែនមានសភាពប្រែប្រួលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសង្ខារក្ខន្ធ មិនទៀង បច្ច័យប្រជុំតាក់តែង កើតឡើងអាស្រ័យហេតុ មានសភាពអស់ទៅ មានសភាពសូន្យទៅ មានសភាពប្រាសចាកតម្រេក មានសភាពរលត់ទៅ មានសភាពប្រែប្រួលឬ ។ អើ ។ ប្រសិនបើ សង្ខារក្ខន្ធមិនទៀង ។បេ។ មានសភាពប្រែប្រួល

ទៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេ ។

[ ៣៤៥ ] សេចក្តីសូន្យនៃរូបក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។ អើ ។ សេចក្តីសូន្យនៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងរូបក្ខន្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសូន្យនៃវេទនាខន្ធ ។បេ។ នៃសញ្ញាខន្ធ ។បេ។ នៃវិញ្ញាណក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។ អើ ។ សេចក្តីសូន្យនៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងវិញ្ញាណក្ខន្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៦ ] បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យនៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងរូបក្ខន្ធទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យនៃរូបក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យនៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងវេទនាខន្ធ ។បេ។ រាប់បញ្ចូលក្នុងសញ្ញាខន្ធ ។បេ។ រាប់បញ្ចូលក្នុងវិញ្ញាណក្ខន្ធទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យនៃវិញ្ញាណ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៧ ] បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយនេះ សូន្យចាកខ្លួនផង ចាកវត្ថុជារបស់ខ្លួនផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។

# អដ្ឋកថា

## សុញ្ញតាកថា

[ ៣៤៤ ] ឥឡូវនេះ នឹងពណ៌នាអំពីសេចក្តីសូន្យដូចតទៅ

ក្នុងរឿងនោះ បទថា **សុញ្ញតា** បានដល់ សុញ្ញតា ២ យ៉ាង គឺ អនត្តលក្ខណៈរបស់ខន្ធទាំងឡាយ ១ ព្រះនិព្វាន ១ ។ ក្នុងសុញ្ញតាទាំងនោះ អនត្តលក្ខណៈណាមួយ គប្បីជាធម៌ដែលរាប់បញ្ចូលដោយសង្ខារក្ខន្ធដោយបរិយាយមួយ ព្រះនិព្វានជាអបរិយាបន្នដោយបរិយាយមួយ ។ ជនទាំងឡាយណា មិនកាន់យកការចែកនេះ ទើបមានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា សុញ្ញតា ជាធម៌ទាក់ទងក្នុងសង្ខារ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **អនិមិត្តំ** បានដល់ ព្រះនិព្វានដែលវៀរចាកនិមិត្តទាំងពួង សូម្បីបទថា **អប្បណិហិតោ** ក៏ជាឈ្មោះរបស់ព្រះនិព្វាននោះឯង ។ សួរថា ព្រោះហេតុអ្វី ទើបលោកនាំព្រះនិព្វាននេះមកពោល ឆ្លើយថា ដើម្បីលើកទោសរបស់លទ្ធិដែលមិនពោលចែកធម៌ ដ្បិតថា លទ្ធិរបស់បុគ្គលណាថា សុញ្ញតាជាធម៌រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដោយចំណែកមួយ ដូច្នេះ ព្រោះមិនចែកលទ្ធិនៃជននោះ ក៏រមែងប្រាកដថា សូម្បីតែព្រះនិព្វាន ក៏ជាធម៌ដែលរាប់បញ្ចូលដោយសង្ខារក្ខន្ធ ដូច្នេះ ដើម្បីនឹងលើកឡើងនូវទោសរបស់លទ្ធិនេះ ទើបសកវាទីនាំពាក្យថា អនិមិត្ត និងអប្បណិហិត មកពោល ។ បរវាទី កាលមិនកាន់យកថា ព្រះនិព្វាននោះ ជាធម៌រាប់បញ្ចូលដោយសង្ខារក្ខន្ធនោះ ទើប

ឆ្លើយបដិសេធ ។ បទថា **សង្ខារក្ខន្ធោ ឧ អនិច្ចោ** ជាដើម សកវាទីសម្ដែងការខុស ដែលដល់នូវភាពជារបស់មិនទៀងនៃសុញ្ញតា គឺព្រះនិព្វាន ។

[ ៣៨៥ ] បទថា **សង្ខារក្ខន្ធស្ស សុញ្ញតា** សកវាទីសួរថា បើសុញ្ញតារបស់ខន្ធដទៃ រាប់បញ្ចូលដោយខន្ធដទៃសោត សូម្បីសុញ្ញតារបស់សង្ខារក្ខន្ធ ក៏គប្បីរាប់បញ្ចូលដោយខន្ធដ៏សេសបាន ដូច្នេះ ។

[ ៣៨៦ ] បទថា **សង្ខារក្ខន្ធស្ស សុញ្ញតា ឧ វត្តព្វា** ជាដើម សកវាទីពោលដោយបដិលោមថា បើសុញ្ញតារបស់សង្ខារក្ខន្ធ មិនរាប់បញ្ចូលដោយខន្ធដ៏សេសសោត សូម្បីសុញ្ញតានៃខន្ធដ៏សេស ក៏ឈ្មោះថា មិនរាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ដូច្នេះ ។ ព្រះសូត្រថា **សុញ្ញមិទំ ភិក្ខវេ សង្ខារា** បរវាទីនាំមកអំពីលទ្ធិដទៃ ។ ក្នុងបទទាំងនោះ បទថា **សង្ខារា** បានដល់ បញ្ចក្ខន្ធដែលមកដោយពាក្យថា សង្ខារទាំងឡាយ មិនទៀងហ្ន៎ ការឈមចុះក្នុងសាសនាថា បញ្ចក្ខន្ធទាំងនោះ ឈ្មោះថា ជាសភាវៈទទេ ព្រោះទទេចាកខ្លួននិងរបស់ដែលទាក់ទងដោយខ្លួនដូច្នេះ មាន និងមិនខុស ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាត តែព្រះសូត្រនេះ សម្ដែងនូវភាពដែលសុញ្ញតា ជាធម៌រាប់បញ្ចូលដោយសង្ខារក្ខន្ធ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាង ដូច្នេះ ។៚

## អដ្ឋកថាសុញ្ញតាកថា ចប់

# អភិធម្មបិដក

## សាមញ្ញផលកថា

[ ៣៨៨ ] សាមញ្ញផល ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រក ជាទីរឭក ជាទីប្រព្រឹត្តទៅខាងមុខ មិនច្យុត មិនស្លាប់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សាមញ្ញផល ជាអសង្ខតៈ ចុះនិព្វាន ជាសង្ខតៈឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៩ ] សាមញ្ញផល ជាអសង្ខតៈឬ ។ អើ ។ សាមញ្ញ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សាមញ្ញ ជាសង្ខតៈឬ ។ អើ ។ សាមញ្ញផល ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិផល ជាអសង្ខតៈឬ ។ អើ ។ សោតាបត្តិមគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិមគ្គ ជាសង្ខតៈឬ ។ អើ ។ សោតាបត្តិផល ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិផល ។បេ។ អនាគាមិមគ្គ ។បេ។ អរហត្តផល ជាអសង្ខតៈឬ ។

អើ ។ អរហត្តមគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរហត្តមគ្គ ជាសង្ខតៈឬ ។ អើ ។ អរហត្តផល ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិផល ជាអសង្ខតៈ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល ជាអសង្ខតៈ និព្វាន ជាអសង្ខតៈ ឬ ។ អើ ។ អសង្ខតៈ មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ៥ ឬ ។ អើ ។ ទីពឹងមាន ៥ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

សាមញ្ញផលកថា ចប់

# អដ្ឋកថា

## សាមញ្ញផលកថា

[ ៣៤៨ ] ឥឡូវនេះ នឹងពណ៌នាអំពីសាមញ្ញផលដូចតទៅ

ក្នុងរឿងនោះ ការសន្និដ្ឋាន គឺការដាក់ចិត្តក្នុងលទ្ធិរបស់សកវាទីថា វិបាកចិត្តរបស់អរិយមគ្គ ក្នុងមគ្គវីថិក្តី ក្នុងផលសមាបត្តិក្តី ឈ្មោះថា សាមញ្ញផល ដូច្នេះ ។ ជនទាំងឡាយណា មិនកាន់យកយ៉ាងនោះ ទើបមាន លទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា ការលះកិលេសផង ការកើតឡើងនៃផលផង ជាសាមញ្ញផល ព្រោះហេតុនោះ ទើបសាមញ្ញផល នោះ ជាអសង្ខតៈ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាប តាមព្រះបាលី ព្រោះមានន័យតាមដែលពោលហើយខាងដើមនោះឯង ។៙

**អដ្ឋកថាសាមញ្ញផលកថា ចប់**

# អភិធម្មបិដក

## បត្ថិកថា

[ ៣៥០ ] ការបានជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រក ជាទីរព្វក ជាទីប្រព្រឹត្តទៅខាងមុខ មិនច្យុត មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបានជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥១ ] ការបាននូវចីវរ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។បេ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបាននូវចីវរ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបាននូវបិណ្ឌបាត ។បេ។ នូវសេនាសនៈ ។បេ។ នូវគិលានបច្ចយភេសជ្ជបរិក្ខារ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។បេ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបាននូវគិលានបច្ចយភេសជ្ជបរិក្ខារ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបាននូវចីវរ ជាអសង្ខតៈ ការបាននូវបិណ្ឌបាត ។បេ។

នូវសេនាសនៈ ។បេ។ នូវគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ៥ ឬ ។ អើ ។ ទីពឹង មាន ៥ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥២ ] ការបាននូវបឋមជ្ឈាន ជាអសង្ខតៈ សេចក្តីទាំងអស់ អ្នកប្រាជ្ញគប្បីឲ្យពិស្តារផងចុះ ការបាននូវទុតិយជ្ឈាន នូវតតិយជ្ឈាន នូវចតុត្ថជ្ឈាន នូវអាកាសានញ្ចាយតនៈ នូវវិញ្ញាណញ្ចាយតនៈ នូវអាកិញ្ចញ្ញាយតនៈ នូវនេវសញ្ញានាសញ្ញាយតនៈ ។បេ។ នូវសោតាបត្តិមគ្គ នូវសោតាបត្តិផល នូវសកទាគាមិមគ្គ នូវសកទាគាមិផល នូវអនាគាមិមគ្គ នូវអនាគាមិផល នូវអរហត្តមគ្គ នូវអរហត្តផល ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។បេ។ មិនច្យុត មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបាននូវអរហត្តផល ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបាននូវសោតបត្តិមគ្គ ជាអសង្ខតៈ ការបាននូវសោតាបត្តិផល ជា

អសង្ខតៈ ។បេ។ ការបានទូវអរហត្ត ជាអសង្ខតៈ ការបានទូវអរហត្តផល ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ៩ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ៩ ឬ ។ អើ ។ ទីពឹង មាន ៩ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៣ ] បុគ្គលមិនគួរនិយាយថា ការបានជាអសង្ខតៈទេឬ ។ អើ ។ ការបាន គឺជារូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ការបានជាអសង្ខតៈ ។

បត្តិកថា ចប់

# អដ្ឋកថា

## បត្តិកថា

[ ៣៥០ ] ឥឡូវនេះ នឹងពណ៌នាអំពីការបានដូចតទៅ

ក្នុងរឿងនោះ បុគ្គលបាននូវវត្ថុណាមួយ ការបាននូវវត្ថុនោះៗ ឈ្មោះថា **បត្តិ** ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយនោះឯងថា ការបាននោះ ជាអសង្ខតៈ ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលី ព្រោះមានន័យដូចពោលមកហើយខាងដើមនោះឯង ។

[ ៣៥៣ ] បទថា **ន វត្តព្វំ** ជាដើម បរវាទីប្រកាសលទ្ធិ ដែលមានបញ្ញត្តិថា **បត្តិ** ជាអសង្ខតៈ ។ ក្នុងបញ្ហានោះ សកវាទីបដិសេធថា មិនគប្បីពោលយ៉ាងនោះ រមែងមិនទទួលនូវភាពដែលការបានជាសភាវធម៌ មានរូបជាដើមត្រឹមតែម្យ៉ាង ។ ពិតហើយ ធម៌ទាំងឡាយណាមួយ ឈ្មោះថា **បត្តិ** មិនមាន ព្រះមានព្រះភាគ ទ្រង់ក៏មិនបានបញ្ញត្តិនូវភាពដែលការបាននោះ ជាអសង្ខតៈ តែបរវាទីបានឲ្យលទ្ធិរបស់ខ្លួនតាំងនៅថា **បត្តិ** នោះ ជាអសង្ខតៈ ដោយត្រឹមតែការបដិសេធសភាវធម៌ ដូចពោលនោះឯង ។ លទ្ធិនោះ រមែងតាំងនៅមិនបាន ព្រោះភាពជាលទ្ធិដែលតាំងនៅហើយ ដោយមិនពិចារណា ដូច្នេះឯង ៕ ០៚

**អដ្ឋកថាបត្តិកថា ចប់**

# អភិធម្មបិដក

## កថាវត្ថុ

[ ៣៥៤ ] សេចក្តីទៀងទាត់ នៃធម៌ទាំងពួង ( មានរូបជាដើម ) ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។បេ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីទៀងទាត់ នៃធម៌ទាំងពួង ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៥ ] ភាពជារូបនៃរូប ក្រែងភាពជារូប ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។បេ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភាពជារូបនៃរូប ក្រែងភាពជារូប ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈមានពីរឬ ។ អើ ។ ទីពឹងមានពីរ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភាពជាវេទនានៃវេទនា ក្រែងភាពជាវេទនា ។បេ។ ភាពជាសញ្ញានៃសញ្ញា ក្រែងភាពជាសញ្ញា ។បេ។ ភាពជាសង្ខារនៃសង្ខារទាំងឡាយ ក្រែងភាពជាសង្ខារ ។បេ។ ភាពជាវិញ្ញាណនៃវិញ្ញាណ ក្រែងភាពជាវិញ្ញាណ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។បេ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភាពជារូបនៃរូប ក្រែងភាពជារូប ជាអសង្ខតៈ ។បេ។ ភាពជាវិញ្ញាណនៃវិញ្ញាណ ក្រែងភាពជាវិញ្ញាណ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈដែរឬ ។

អើ ។ អសង្ខតៈមាន ៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈមាន ៦ ឬ ។ អើ ។ ទីពឹង មាន ៦ ។បេ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៦ ] បុគ្គលមិនគួរនិយាយថា សេចក្តីទៀងទាត់ នៃធម៌ទាំងពួងជាអសង្ខតៈទេឬ ។ អើ ។ សេចក្តីទៀងទាត់ នៃធម៌ទាំងពួង គឺជារូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ សេចក្តីទៀងទាត់ នៃធម៌ទាំងពួង ជាអសង្ខតៈ ។

តថតាកថា ចប់

# អដ្ឋកថា

## តថតាកថា

[ ៣៥៤ ] ឥឡូវនេះ នឹងពណ៌នាអំពីសេចក្តីទៀងទាត់នៃធម៌ទាំងពួង ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះថា ឈ្មោះថា **តថតា** គឺភាពជាសភាវៈនៃរូបជាដើមនៃធម៌ទាំងពួង មានរូបជាដើម មានតែ **តថតា** នោះ ជាអសង្ខតៈ ព្រោះភាពជាធម៌មិនរាប់បញ្ចូលក្នុងរូបជាដើមដែលជាសង្ខតៈ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ ជាក់ច្បាស់ហើយនោះឯង ព្រោះមានន័យតាមដែលពោលមកហើយនោះឯង ។៙

**អដ្ឋកថាតថតាកថា ចប់**

# អភិធម្មបិដក

## កុសលកថា

[ ៣៥៧ ] និព្វានធាតុ ជាកុសលឬ ។ អើ ។ និព្វានធាតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃនិព្វានធាតុនោះមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងនិព្វានធាតុ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃនិព្វានធាតុនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើនិព្វានធាតុ មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃនិព្វានធាតុនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា និព្វានធាតុ ជាកុសលទេ ។

[ ៣៥៨ ] អលោភៈ ជាកុសលប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃអលោភៈនោះ មានដែរឬ ។ អើ ។ និព្វានធាតុ ជាកុសលប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃនិព្វានធាតុនោះមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អទោសៈ ជាកុសល ។បេ។ អមោហៈ ជាកុសល ។បេ។ សទ្ធា វីរិយៈ សតិ សមាធិ ។បេ។ បញ្ញា ជាកុសលប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុក នៃបញ្ញានោះមានដែរឬ ។ អើ ។ និព្វានធាតុ ជាកុសលប្រកបដោយអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃនិព្វានធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៩ ] និព្វានធាតុ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។

ការតាំងចិត្តទុកនៃនិព្វានធាតុនោះ មិនមានទេឬ ។ អើ ។ អលោភៈ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និព្វានធាតុ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃនិព្វានធាតុនោះ មិនមានទេឬ ។ អើ ។ អទោសៈ ជាកុសល ។បេ។ អមោហៈ ជាកុសល ។បេ។ សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញា ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។បេ។ ការតាំងចិត្តទុកនៃបញ្ញានោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦០ ] បុគ្គលមិនគួរនិយាយថា និព្វានធាតុ ជាកុសលទេឬ ។ អើ ។ ក្រែងនិព្វានធាតុ មិនមានទោសទេឬ ។ អើ ។ ប្រសិនបើ និព្វានធាតុ មិនមានទោសទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា និព្វានធាតុ ជាកុសលដែរ ។

## កុសលកថា ចប់

# អដ្ឋកថា

## កុសលកថា

[ ៣៥៧ ] ឥឡូវនេះ នឹងពណ៌នាអំពីកុសលដូចតទៅ

ក្នុងរឿងនោះ កុសល ជាធម៌មិនមានទោសផង ជាធម៌ មានផលដែលគួរប្រាថ្នាផង ។ វត្ថុដែលមិនប្រកបដោយកិលេស ឈ្មោះថា មិនមានទោស ។ ន័យនេះ រមែងប្រើបានជាមួយធម៌ទាំងពួង វៀរលែងអកុសល ។ បុណ្យដែលឲ្យសម្រេចនូវឥដ្ឋផល ក្នុងការប្រព្រឹត្តទៅនៃការកើតឡើងក្នុងភពតទៅ ឈ្មោះថា ផលដែលគួរប្រាថ្នា ន័យនេះ ប្រើបានជាមួយបទដើម ក្នុងកុសលត្តិកៈ[១] នោះឯង ។ ជនទាំងឡាយណា មិនកាន់យកការចែកនេះ មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រះនិព្វាន ជាកុសល ដោយហេតុត្រឹមតែភាពជាធម៌មិនមានទោសប៉ុណ្ណោះ ដូច្នេះ ពាក្យសួររបស់សកវាទី ដើម្បីសម្ដែងនូវភាពដែលព្រះនិព្វាន មិនជាកុសល ដោយអត្ថថា ជាឥដ្ឋវិបាកដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយអំណាចលទ្ធិរបស់ខ្លួន ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យ ដូចពោលមកហើយ ដូច្នេះ ។

**អដ្ឋកថាកុសលកថា ចប់**

---

១- បទដើមនៃកុសលត្តិកៈ បានដល់ បទថា កុសលា ធម្មា ។

# អភិធម្មបិដក

## អច្ចន្តនិយាមតាកថា

[ ៣៦១ ] សេចក្តីទៀងទាត់តែម្យ៉ាងរបស់បុថុជ្ជន មានដែរឬ ។ អើ ។ បុគ្គលសម្លាប់មាតា ជាបុគ្គលទៀងទាត់តែម្យ៉ាង បុគ្គលសម្លាប់បិតា ។បេ។ បុគ្គលសម្លាប់ព្រះអរហន្ត ។បេ។ បុគ្គលញុំាងព្រះលោហិតឲ្យពុរពោរឡើង ។បេ។ បុគ្គលបំបែកសង្ឃ ជាបុគ្គលទៀងទាត់តែម្យ៉ាងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីទៀងទាត់តែម្យ៉ាងរបស់បុថុជ្ជន មានដែរឬ ។ អើ ។ វិចិកិច្ឆានៃបុគ្គលទៀងទាត់តែម្យ៉ាង គប្បីកើតឡើងដែរឬ ។ អើ ។ ប្រសិនបើវិចិកិច្ឆានៃបុគ្គលទៀតទាត់តែម្យ៉ាង គប្បីកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីទៀងទាត់តែម្យ៉ាងរបស់បុថុជ្ជន មានទេ ។

[ ៣៦២ ] វិចិកិច្ឆារបស់បុគ្គលទៀងទាត់តែម្យ៉ាង មិនគប្បីកើតឡើងទេឬ ។ អើ ។ ( បុគ្គលទៀងទាត់តែម្យ៉ាង ) លះបង់ ( វិចិកិច្ឆា ) ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( បុគ្គលទៀងទាត់តែម្យ៉ាង ) លះបង់ ( វិចិកិច្ឆា ) ហើយឬ ។ អើ ។ ( លះបង់ ) ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( លះបង់ ) ដោយសកទាគាមិមគ្គ ។បេ។ ដោយអនាគាមិមគ្គ ។បេ។ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( លះបង់ ) ដោយមគ្គដូចម្តេច ។ ដោយមគ្គ ជាអកុសល ។ មគ្គជាអកុសល ជាទីស្រោចស្រង់ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង មិនដល់នូវការសន្សំកពូនឡើង មិនមានអាសវៈ ។បេ។ មិនគួរដល់សេចក្តី

សៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងមគ្គជាអកុសល មិនជាទីស្រោចស្រង់ ។បេ។ គួរដល់សេចក្ដីសៅហ្មងឬ ។ អើ ។ ប្រសិនបើ មគ្គជាអកុសល មិនជាទីស្រោចស្រង់ ។បេ។ គួរដល់សេចក្ដីសៅហ្មង ម្នាល អ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទៀងទាត់តែម្យ៉ាង លះបង់វិចិកិច្ឆា ដោយមគ្គ ជាអកុសលទេ ។

[ ៣៦៣ ] ឧច្ឆេទទិដ្ឋិរបស់បុគ្គលទៀង ដោយសស្សតទិដ្ឋិ គប្បីកើត ឡើងដែរឬ ។ អើ ។ ប្រសិនបើ ឧច្ឆេទទិដ្ឋិរបស់បុគ្គលទៀងដោយសស្សតទិដ្ឋិ គប្បីកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្ដីទៀងទាត់ តែម្យ៉ាងរបស់បុថុជ្ជន មានទេ ។

[ ៣៦៤ ] ឧច្ឆេទទិដ្ឋិរបស់បុគ្គល ទៀងដោយសស្សតទិដ្ឋិ មិនគប្បី កើតឡើងទេឬ ។ អើ ។ ( បុគ្គលនោះ ) លះបង់ ( ឧច្ឆេទទិដ្ឋិ ) ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( បុគ្គលនោះ ) លះបង់ ( ឧច្ឆេទទិដ្ឋិ ) ហើយឬ ។ អើ ។ ( លះបង់ ) ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ ( លះបង់ ) ដោយសកទាគាមិមគ្គ ។បេ។ ដោយ អនាគាមិមគ្គ ។បេ។ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( លះបង់ ) ដោយមគ្គដូចម្ដេច ។ ដោយមគ្គជាអកុសល ។ មគ្គ ជាអកុសល ។បេ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទៀង ដោយសស្សតទិដ្ឋិ លះបង់ឧច្ឆេទទិដ្ឋិ ដោយមគ្គជាអកុសលទេ ។

[ ៣៦៥ ] សស្សតទិដ្ឋិរបស់បុគ្គលទៀង ដោយឧច្ឆេទទិដ្ឋិ គប្បីកើតឡើង

ឬ ។ អើ ។ ប្រសិនបើ សស្សតទិដ្ឋិរបស់បុគ្គល ទៀងដោយឧច្ឆេទទិដ្ឋិ គប្បី កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីទៀងទាត់តែម្យ៉ាង របស់បុថុជ្ជន មានទេ ។

[ ៣៦៦ ] សស្សតទិដ្ឋិរបស់បុគ្គល ទៀងដោយឧច្ឆេទទិដ្ឋិ មិនគប្បី កើតឡើងទេឬ ។ អើ ។ ( បុគ្គលនោះ ) លះបង់ ( សស្សតទិដ្ឋិ ) ហើយ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( បុគ្គលនោះ ) លះបង់ ( សស្សត-ទិដ្ឋិ ) ហើយឬ ។ អើ ។ ( លះបង់ ) ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ ( លះបង់ ) ដោយសកទាគាមិមគ្គ ។បេ។ ដោយ អរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( លះបង់ ) ដោយមគ្គ ដូចម្តេច ។ ដោយមគ្គជាអកុសល ។ មគ្គជាអកុសល ។បេ។ ម្នាលអ្នកដ៏ ចម្រើន អ្នកមិនគួរពោលថា បុគ្គលទៀងដោយឧច្ឆេទទិដ្ឋិ លះបង់សស្សត-ទិដ្ឋិ ដោយមគ្គជាអកុសលទេ ។

[ ៣៦៧ ] បុគ្គលមិនគួរនិយាយថា សេចក្តីទៀងទាត់តែម្យ៉ាង របស់ បុថុជ្ជន មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយពួកធម៌ជាអកុសលខ្មៅតែ ម្យ៉ាង បុគ្គលនោះ មុជចុះហើយ ចេះតែមុជចុះទៅតែម្តង ពាក្យដូច្នេះ មាន ក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្តីទៀងទាត់តែម្យ៉ាង របស់ បុថុជ្ជន មាន ។

[ ៣៦៨ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គល

ខ្លះ ក្នុងលោកនេះ ប្រកបដោយពួកធម៌ជាអកុសលខ្មៅតែម៉្យាង បុគ្គលនោះ ឈ្មោះថា មុជចុះហើយ ចេះតែមុជចុះទៅតែម្តង ព្រោះហេតុនោះ សេចក្តីទៀងទាត់តែម៉្យាងរបស់បុថុជ្ជន មាន ព្រោះធ្វើនូវសេចក្តីចូលចិត្ត ដូច្នេះឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ងើបឡើងហើយ មុជចុះទៅវិញ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បុគ្គលងើបឡើងសព្វកាលហើយ មុជចុះទៅវិញឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៩ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រកបដោយពួកធម៌ជាអកុសលខ្មៅតែម៉្យាង បុគ្គលនោះ ឈ្មោះថា មុជចុះហើយ ចេះតែមុជចុះទៅតែម្តង ព្រោះហេតុនោះ សេចក្តីទៀងទាត់តែម៉្យាងរបស់បុថុជ្ជន មាន ព្រោះធ្វើនូវសេចក្តីចូលចិត្ត ដូច្នេះឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ងើបឡើងហើយ ឈរនៅ ងើបឡើងរកមើល សម្លឹងមើល ងើបឡើងហើយ ហែលទៅ ងើបឡើងហើយ ដល់ត្រើយខាងនាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បុគ្គលងើបឡើងសព្វកាលហើយ ឆ្លងទៅត្រើយខាងនាយបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**អច្ចន្តនិយាមតាកថា ចប់**

# អដ្ឋកថា

## អច្ចន្តនិយាមកថា

[ ៣៦១ ] ឥឡូវនេះ នឹងពណ៌នាអំពីការទៀងទាត់តែម្យ៉ាងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា អាស្រ័យព្រះសូត្រថា បុគ្គលនោះឈ្មោះថា មុជចុះហើយ ចេះតែមុជចុះទៅតែម្តង ដូច្នេះ ទើបមានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះថា បុថុជ្ជន មានការទៀងទាត់ ដោយចំណែកមួយ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **មាតុឃាតកោ** ជាដើម សកវាទីសួរថា កាលមិច្ឆត្តនិយាមនៃនិយតមិច្ឆាទិដ្ឋិបុគ្គលផង នៃបុគ្គលដែលធ្វើកម្មទាំងឡាយ មានសម្លាប់មាតាជាដើមផង មានបុគ្គលដែលសម្លាប់មាតាជាដើមនោះ ក៏គប្បីជាបុគ្គលទៀងដោយចំណែកមួយឬ ។ បរវាទីឆ្លើយបដិសេធថា **ន ហេវំ** ព្រោះលទ្ធិថា បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិនេះ ជាអ្នកទៀងទាត់ក្នុងសង្សារវដ្ត ជាអ្នកទៀងពិត ក្នុងភពតទៅ តែបុគ្គលទាំងនេះ ជាអ្នកទៀងពិត ក្នុងអត្តភាពមួយប៉ុណ្ណោះ ដូច្នេះ ។

បទថា **វិចិកិច្ឆា ឧប្បជ្ជេយ្យ** សេចក្តីថា សកវាទីពោលថា វិចិកិច្ឆាគប្បីកើតយ៉ាងនេះ គឺបុគ្គលនេះ ជាបុគ្គលទៀងក្តី មិនទៀងក្តីឬ ។ បរវាទីកាលមិនឃើញហេតុដែលធ្វើឲ្យវិចិកិច្ឆាមិនឲ្យកើតឡើង ទើបឆ្លើយទទួល ។

[ ៣៦២ ] តែបរវាទី ត្រូវសួរថា **នុប្បជ្ជេយ្យ** ក៏ឆ្លើយទទួល ដោយសំដៅយកការមិនកើតឡើងរបស់វិចិកិច្ឆា ក្នុងទិដ្ឋិដែលបុគ្គលសេពហើយ

និងឈានចុះកាន់និយាម ។ បន្ទាប់អំពីនោះ ត្រូវសួរថា **បហីនា** ក៏ឆ្លើយបដិសេធ ព្រោះភាពដែលវិចិកិច្ឆានោះ មិនទាន់បានលះដោយមគ្គ តែក៏ឆ្លើយទទួលថា លះបាន ព្រោះភាពដែលបុគ្គលប្រារព្ធទិដ្ឋិនោះហើយ វិចិកិច្ឆាក៏មិនផ្សាយឡើង ។ លំដាប់នោះ សកវាទីពោលពាក្យថា **សោតាបត្តិមគ្គេន** ជាដើម ដើម្បីសួរបរវាទីនោះដោយអំណាចនៃអរិយមគ្គនោះ ព្រោះឈ្មោះថា ការលះវិចិកិច្ឆានោះ បើវៀរចាកអរិយមគ្គហើយ លះមិនបាន ដូច្នេះ ។ បរវាទីឆ្លើយបដិសេធ ព្រោះភាពដែលវិចិកិច្ឆានោះ មិនទាន់បានលះដោយមគ្គមួយ ។ ត្រូវសួរទៀតថា **កតមេន** បរវាទីសំដៅយកមិច្ឆាមគ្គ ទើបពោលពាក្យថា **អកុសលេន** ដូច្នេះជាដើម ។

[ ៣៦៣ ] បទថា **ឧច្ឆេទទិដ្ឋិ ឧប្បជ្ជេយ្យ** សេចក្ដីថា សកវាទីសួរដល់ការកើតឡើងនៃនិយាមទី ២ ។ បរវាទីឆ្លើយទទួល ព្រោះនិយតមិច្ឆាទិដ្ឋិទាំង ៣ រមែងកើតឡើងដល់បុគ្គលម្នាក់បាន ព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ជនទាំងឡាយណា នៅក្នុងឧក្កលជនបទ ឈ្មោះវយភិញ្ញា ជានត្ថិកវាទ ជាអកិរិយវាទ ជាអហេតុកវាទ[១] ដូច្នេះ ។ លំដាប់នោះ សកវាទីក៏ពោលពាក្យថា **ហញ្ចិ** ជាដើម ដើម្បីសួរបរវាទីនោះថា ឈ្មោះថា បុគ្គលនោះ មិនជាអ្នកទៀងដោយចំណែកមួយ ។ ពិតហើយ និយាមទី ២ នៃបុគ្គលទៀងដោយចំណែកមួយ រមែងមិនមានតម្លៃ ។

១- បិដកខ្មែរជា ជនទាំងឡាយណា នៅក្នុងឧក្កលជនបទ ឈ្មោះវស្សៈ ១ ភញ្ញៈ ១ ជាអហេតុវាទ ជាអកិរិយវាទ នត្ថិកវាទ ... គួរតិះដៀល មិនសម្គាល់ថា គួរឃាត់ហាម ។

[ ៣៦៤ ] ក្នុងបញ្ហាថា **ឧប្បជ្ជេយ្យ** ជាដើម បរវាទីឆ្លើយទទួល ដោយសំដៅយកការមិនកើតឡើងនៃឧច្ឆេទទិដ្ឋិ ព្រោះកាន់យកការយល់ឃើញថា វត្ថុណាដែលសស្សតទិដ្ឋិ កាន់យកថា ទៀង វត្ថុនោះឯង រមែងដាច់សូន្យ ។ បរវាទី ត្រូវសួរថា **បហីនា** ក៏ឆ្លើយបដិសេធ ព្រោះឧច្ឆេទទិដ្ឋិនោះ មិនទាន់បានលះដោយមគ្គ តែឆ្លើយទទួល ព្រោះការមិនកើតឡើង ដោយន័យដែលពោលមកហើយ ។

[ ៣៦៥-៣៦៦ ] ក្នុងបទទាំងឡាយ មានបទថា **សស្សតទិដ្ឋិ ឧប្បជ្ជេយ្យ** ជាដើម ក៏ន័យនេះឯង ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ក្នុងវារៈពោលដោយវិចិកិច្ឆានោះឯង ។

[ ៣៦៧ ] ពាក្យសួរថា **ន វត្តព្វំ** ជាដើម ជាពាក្យរបស់បរវាទី ពាក្យឆ្លើយទទួលថា **អាមន្តា** ព្រោះភាពដែលព្រះសូត្របែបនោះ មាន ជាពាក្យរបស់សកវាទី ។ ក្នុងព្រះសូត្រនេះ មានអធិប្បាយថា បុគ្គលនោះ មិនមែនជាបុគ្គលលិចចុះក្នុងភពតៗ ទៅឡើយ ដ្បិតថា បុគ្គលនោះ ជាបុគ្គលមិនគួរដើម្បីលះទិដ្ឋិនោះ ក្នុងភពនេះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបព្រះសូត្រនេះមិនមែនជាគោលអាង ។

[ ៣៦៨ ] បទថា **សព្វកាលំ ឧម្មុជ្ជិត្វា និមុជ្ជតិ** ដូច្នេះជាដើម សកវាទីពោលដើម្បីសម្ដែងថា បរវាទីគប្បីស្វែងរកអត្ថ ដោយមិនធ្វើត្រឹមតែការប្រកាន់មាំត្រឹមតែពាក្យ ដោយប្រការដូច្នេះ ។៚

**អដ្ឋកថាអច្ចន្តនិយាមកថា ចប់**

# អភិធម្មបិដក

## ឥន្ទ្រិយកថា

[ ៣៧០ ] សទ្ធិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ សទ្ធា ជាលោកិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វីរិយិន្ទ្រិយ ។បេ។ សតិន្ទ្រិយ ។បេ។ សមាធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ បញ្ញា ជាលោកិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧១ ] សទ្ធា ជាលោកិយ មានដែរឬ ។ អើ ។ សទ្ធិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វីរិយៈ ។បេ។ សតិ ។បេ។ សមាធិ ។បេ។ បញ្ញា ជាលោកិយ មានដែរឬ ។ អើ ។ បញ្ញិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧២ ] មនៈ ជាលោកិយ មាន ចុះមនិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អើ ។ សទ្ធា ជាលោកិយ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនៈ ជាលោកិយ មាន ចុះមនិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អើ ។ បញ្ញា ជាលោកិយ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៣ ] សោមនស្ស ជាលោកិយ មាន ចុះសោមនស្សិន្ទ្រិយ ជាលោកិយ មាន ។បេ។ ជីវិត ជាលោកិយ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អើ ។ សទ្ធា ជាលោកិយ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ

មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជីវិត ជាលោកិយ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អើ ។ បញ្ញា ជាលោកិយ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៤ ] សទ្ធា ជាលោកិយ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ មនៈ ជាលោកិយ មាន ចុះមនិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា ជាលោកិយ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ មនៈ ជាលោកិយ មាន ចុះមនិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សទ្ធា ជាលោកិយ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ សោមនស្ស ជាលោកិយ មាន ចុះសោមនស្សិន្ទ្រិយ ជាលោកិយ មិនមាន ។បេ។ ជីវិត ជាលោកិយ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា ជាលោកិយ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ ជីវិត ជាលោកិយ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៥ ] សទ្ធា ជាលោកុត្តរ មាន ចុះសទ្ធិន្ទ្រិយ ជាលោកុត្តរ មានដែរឬ ។ អើ ។ សទ្ធា ជាលោកិយ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិរិយៈ ជាលោកុត្តរ មាន ។បេ។ បញ្ញា ជាលោកុត្តរ មាន ចុះបញ្ញិន្ទ្រិយ ជាលោកុត្តរ មានដែរឬ ។ អើ ។ បញ្ញា ជាលោកិយ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយ មានដែរឬ ។ អ្នកមិន

គួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៦ ] សទ្ធា ជាលោកិយ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ សទ្ធា ជាលោកុត្តរ មាន ចុះសទ្ធិន្ទ្រិយ ជាលោកុត្តរ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វីរិយៈ ជាលោកិយ មាន ។បេ។ បញ្ញា ជាលោកិយ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ បញ្ញា ជាលោកុត្តរ មាន ចុះបញ្ញិន្ទ្រិយ ជាលោកុត្តរ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៧ ] បញ្ញិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត កាលប្រមើលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ បានឃើញពួកសត្វ មានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយដ៏ក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ដែលឲ្យដឹងបានដោយងាយ ដែលឲ្យដឹងបានដោយកម្រ ពួកខ្លះឃើញទោស និងភ័យក្នុងបរលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បញ្ញិន្ទ្រិយ ជាលោកិយ មានដែរ ។

ឥន្ទ្រិយកថា ចប់

ឯកូនវីសតិមវគ្គ ចប់

## ឧទ្ទាននៃឯកូនវីសតិមវគ្គនោះ គឺ

និយាយអំពីបុគ្គលលះបង់ពួកកិលេសជាអតីត លះបង់ពួកកិលេសជាអនាគត លះបង់ពួកកិលេសជាបច្ចុប្បន្ន ១ សេចក្តីសូនទ្យរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ១ សាមញ្ញផល ជាអសង្ខត: ១ ការបានជាអសង្ខត: ១ សេចក្តីទៀងទាត់នៃធម៌ទាំងពួងជាអសង្ខត: ១ និព្វានធាតុជាកុសល ១ សេចក្តីទៀងទាត់តែម្យ៉ាងរបស់បុថុជ្ជន មាន ១ បញ្ចិន្ទ្រិយជាលោកិយ មិនមាន ១ ។

# អដ្ឋកថា

## ឥន្ទ្រិយកថា

[ ៣៧០ ] ឥឡូវនេះ នឹងពណ៌នាអំពីឥន្ទ្រិយដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទ និងនិកាយមហិសាសកៈទាំងឡាយថា សទ្ធាដែលជាលោកិយឈ្មោះថា ជាសទ្ធាប៉ុណ្ណោះ មិនឈ្មោះថា ជាសទ្ធិន្ទ្រិយ វីរិយៈដែលជាលោកិយ សតិដែលជាលោកិយ សមាធិដែលជាលោកិយ ។បេ។ បញ្ញាដែលជាលោកិយ ឈ្មោះថា ជាបញ្ញាប៉ុណ្ណោះ មិនឈ្មោះថា ជាបញ្ញិន្ទ្រិយដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ព្រោះធម៌ទាំងឡាយ មានសទ្ធាជាដើម សូម្បីជាលោកិយក៏ជាឥន្ទ្រិយ ដោយអត្ថថា ជាធំ មិនមែនមានធម៌ដទៃក្រៅអំពីសទ្ធាជាដើមឈ្មោះថា **សទ្ធិន្ទ្រិយ** ជាដើមឡើយ ព្រោះហេតុនោះ ទើបសកវាទីពោលពាក្យថា **ឥត្ថិ លោកិយា សទ្ធា** ជាដើម ដើម្បីសម្តែងភាពដែលសទ្ធាជាដើមជាលោកិយ ក៏ឈ្មោះថា **សទ្ធិន្ទ្រិយ** ជាដើម ។

[ ៣៧៣ ] *បទថា* **អត្ថិ លោកិយោ មនោ** *សកវាទីអធិប្បាយអត្ថនោះឲ្យជាក់ច្បាស់ដោយឧបមាថា ធម៌ទាំងឡាយនោះ មានមនោដែលជាលោកិយជាដើម ក៏ឈ្មោះថា ជាមនិន្ទ្រិយជាដើម យ៉ាងណា ធម៌ទាំងឡាយ មានសទ្ធាដែលជាលោកិយជាដើម ក៏ឈ្មោះថា ជាសទ្ធិន្ទ្រិយជាដើមបាន ក៏យ៉ាងនោះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ដូច្នេះ ។*

**អដ្ឋកថាឥន្ទ្រិយកថា ចប់**
**វគ្គទី ១៩ ចប់**

# អភិធម្មបិដក

## អសញ្ញិច្ចកថា

[ ៣៧៨ ] បុគ្គលមិនក្លែងផ្តាច់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្ម ឬ ។ អើ ។ បុគ្គលមិនក្លែងសម្លាប់សត្វមានជីវិត ឈ្មោះថា ជាអ្នកញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្មឬ ។ អើ ។ បុគ្គលមិនក្លែងកាន់យកវត្ថុដែលគេមិនបានឲ្យ ។បេ។ ពោលពាក្យកុហក ឈ្មោះថា ជាអ្នកពោលពាក្យកុហកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៩ ] បុគ្គលមិនក្លែងសម្លាប់សត្វមានជីវិត មិនបានឈ្មោះថា ជាអ្នកញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទេឬ ។ អើ ។ បុគ្គលមិនក្លែងផ្តាច់បង់ជីវិតមាតា មិនបានឈ្មោះថា ដល់អនន្តរិយកម្មទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនក្លែងកាន់យកវត្ថុដែលគេមិនបានឲ្យ ។បេ។ ពោលពាក្យកុហក មិនបានឈ្មោះថា ជាអ្នកពោលពាក្យកុហកទេឬ ។ អើ ។ បុគ្គលមិនក្លែងផ្តាច់បង់ជីវិតមាតា មិនបានឈ្មោះថា ដល់អនន្តរិយកម្មទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨០ ] បុគ្គលមិនក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្ម ឬ ។ អើ ។ បុគ្គលមិនក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ បុគ្គលក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។

អើ ។ ប្រសិនបើ បុគ្គលក្មេងផ្តាច់បង់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនក្មេងផ្តាច់បង់ជីវិតមាតា ឈ្មោះថា ដល់អនន្តរិយកម្មទេ ។

[ ៣៨១ ] បុគ្គលមិនគួរនិយាយថា បុគ្គលសម្លាប់មាតា ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងមាតា បុគ្គលនោះផ្តាច់បង់ជីវិតហើយឬ ។ អើ ។ ប្រសិនបើ មាតា បុគ្គលនោះផ្តាច់បង់ជីវិតហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលសម្លាប់មាតាដល់អនន្តរិយកម្ម ។ បុគ្គលមិនគួរនិយាយថា បុគ្គលសម្លាប់បិតា ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងបិតា បុគ្គលនោះផ្តាច់បង់ជីវិតហើយឬ ។ អើ ។ ប្រសិនបើ បិតា បុគ្គលនោះផ្តាច់បង់ជីវិតហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលសម្លាប់បិតា ដល់អនន្តរិយកម្ម ។ បុគ្គលមិនគួរនិយាយថា បុគ្គលសម្លាប់ព្រះអរហន្ត ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងព្រះអរហន្ត បុគ្គលនោះផ្តាច់បង់ជីវិតហើយឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត បុគ្គលនោះផ្តាច់បង់ជីវិតហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលសម្លាប់ព្រះអរហន្ត ដល់អនន្តរិយកម្ម ។ បុគ្គលមិនគួរនិយាយថា បុគ្គលញុំាងព្រះលោហិតពុះពោរឡើង ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងព្រះលោហិតរបស់ព្រះតថាគត បុគ្គលនោះឲ្យពុះពោរឡើងហើយឬ ។ អើ ។ ប្រសិនបើ ព្រះលោហិតរបស់តថាគត បុគ្គលនោះឲ្យពុះពោរឡើងហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលញុំាងព្រះលោហិតឲ្យ

ពុះពោរឡើង ដល់អនន្តរិយកម្ម ។ បុគ្គលបំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អើ ។ បុគ្គលទាំងអស់ បំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទាំងអស់ បំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អើ ។ បុគ្គលមានសេចក្តីសម្គាល់ក្នុងធម៌ បំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមានសេចក្តីសម្គាល់ក្នុងធម៌ បំបែកសង្ឃ ទើបដល់អនន្តរិយកម្មឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាលិ បុគ្គលជាអ្នកបំបែកសង្ឃ ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់កប្ប តែមិនបានក៏មាន ម្នាលឧបាលិ បុគ្គលជាអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនតាំងនៅអស់កប្ប មិនមែនជាតែមិនបានក៏មាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលមានសេចក្តីសម្គាល់ក្នុងធម៌ បំបែកសង្ឃ ដល់អនន្តរិយកម្មទេ ។

[ ៣៨២ ] បុគ្គលមិនគួរនិយាយថា បុគ្គលមានសេចក្តីសម្គាល់ក្នុងធម៌ បំបែកសង្ឃ ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

បុគ្គលអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនតាំងនៅក្នុងធម៌ ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់កប្ប ឃ្លាតចាកធម៌ ក្សេមចាកយោគៈ ( បុគ្គលនោះ ) លុះបំបែកសង្ឃ ដែលព្រមព្រៀងគ្នា រមែងទៅឆេះក្នុងនរកអស់កប្ប ។ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលបំបែកសង្ឃ ដល់អនន្តរិយកម្ម ។

## អសញ្ចិច្ចកថា ចប់

# អដ្ឋកថា

## អសញ្ចិច្ចកថា

[ ៣៧៨ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលមិនក្លែងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា ឈ្មោះថា អនន្តរិយវត្ថុ ជារបស់ធ្ងន់ ជាការៈ ព្រោះហេតុនោះ កាលបុគ្គលណា ប្រព្រឹត្តខុស សូម្បីមិនតាំងចិត្តក្នុងវត្ថុទាំងឡាយនោះ ក៏ជាអនន្តរិយកម្ម ដូច្នេះ ពាក្យសួររបស់សកវាទីថា **អសញ្ចិច្ច** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ដោយអំណាចនៃលទ្ធិ ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **អសញ្ចិច្ច ចាណំ ហន្ត្វា** ជាដើម ដើម្បីសួរបរវាទីនោះថា ព្រោះហេតុដែលឈ្មោះថា អនន្តរិយកម្ម ជាកម្មបថ បើបុគ្គលមិនតាំងចិត្ត ក៏គប្បីជាការបែកធ្លាយកម្មបថបានសោត កម្មទាំងឡាយដ៏សេស មានបាណាតិបាតជាដើម ទោះបីមិនតាំងចិត្ត ក៏គប្បីមានបាន ។ បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានក្នុងលទ្ធិបែបនោះ ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលី ។

[ ៣៨១ ] ពាក្យសួរថា **ន វត្តព្វំ មាតុឃាតកោ** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល សំដៅយកការសម្លាប់ ដោយមិនមានចេតនាក្នុងកាលដែលធ្វើនូវការព្យាបាល រក្សារោគជាដើម ជាពាក្យរបស់សកវាទី ។ ក្នុងបញ្ហាថា **ននុ មាតា ជីវិតា វោរោបិតា** ពាក្យឆ្លើយទទួល សំដៅយកការផ្តាច់ជីវិត ដោយមិនមានចេតនា ជាពាក្យរបស់សកវាទីនោះឯង ។ បរវាទីមិនកាន់យកពាក្យអធិប្បាយយ៉ាងនេះ ទើបតាំងលទ្ធិថា **ហញ្ចិ** តែក៏តាំងលទ្ធិ

នោះមិនបានឡើយ ព្រោះតាំងទុកដោយមិនមែនឧបាយ ។ សូម្បីបិតុឃាត ជាដើម ក៏មានន័យនេះឯង ។

ពាក្យសួររបស់សកវាទីថា **សង្ឃភេទោ អនន្តរិកោ** សំដៅយកបុគ្គល មានការសម្គាល់ថា ជាធម៌ ក្នុងការធ្វើសង្ឃភេទ ។ ពាក្យឆ្លើយទទួល ជា ពាក្យរបស់បរវាទី ព្រោះកាន់យកដោយមិនមែនឧបាយនូវព្រះបាលីថា បុគ្គល នោះ លុះបំបែកសង្ឃដែលព្រមព្រៀងគ្នា រមែងទៅឆេះក្នុងនរក អស់កប្ប ដូច្នេះ ។ ត្រូវសួរទៀតថា **សព្វេ** បរវាទីឆ្លើយបដិសេធ សំដៅយកបុគ្គល ដែលមានការសម្គាល់ថា ជាធម៌ ក្នុងចំណែករបស់ខ្លួន ។ រមែងឆ្លើយទទួល ដោយសំដៅយកបុគ្គលដែលមានការសម្គាល់ថា ជាធម៌ ក្នុងចំណែកដទៃ ។ ក្នុងបញ្ហា ២ ថា **ធម្មសញ្ញី** ក៏ន័យនេះឯង ។ ព្រះសូត្រថា **ឆន្ទំ វុត្តំ ភគវតា** ដូច្នេះ សកវាទីពោលដើម្បីសម្តែងដល់ភាពដែលបុគ្គលជាធម្មវាទី ជាអ្នក ធ្វើអនន្តរិយកម្មបាន ដោយទីបំផុតចំណែកមួយនោះឯង ។

[ ៣៨២ ] ព្រះមានព្រះភាគ ទ្រង់បំណាងយកអធម្មវាទីនោះឯង ក្នុង គាថាថា **អបាយិកោ នេរយិកោ** តែបរវាទីមិនកាន់យកព្រះបំណាងនេះ ទើប តាំងលទ្ធិ ។ លទ្ធិនោះ ឈ្មោះថា តាំងនៅមិនបាន ព្រោះមិនតាំងនៅដោយ ឧបាយប្រាជ្ញា ដូច្នេះឯង ។៚

**អដ្ឋកថាអសញ្ចិច្ចកថា ចប់**

# អភិធម្មបិដក

## ញាណកថា

[ ៣៨៣ ] ញាណរបស់បុថុជ្ជន មិនមានទេឬ ។ អើ ។ ការដឹង ការដឹងច្បាស់ ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ព្រម ការចូលទៅជិតកំណត់ ការចូលទៅជិតកំណត់ចំពោះរបស់បុថុជ្ជន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងការដឹង ការដឹងច្បាស់ ការពិចារណា ។បេ។ ការចូលទៅជិតកំណត់ចំពោះរបស់បុថុជ្ជន មានដែរឬ ។ អើ ។ ប្រសិនបើ ការដឹង ការដឹងច្បាស់ ការពិចារណា ។បេ។ ការចូលទៅជិតកំណត់ចំពោះរបស់បុថុជ្ជន មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណរបស់បុថុជ្ជន មិនមានទេ ។

[ ៣៨៤ ] ញាណរបស់បុថុជ្ជន មិនមានទេឬ ។ អើ ។ បុថុជ្ជន គប្បីចូលកាន់បឋមជ្ឈានបានដែរឬ ។ អើ ។ ប្រសិនបើ បុថុជ្ជន គប្បីចូលកាន់បឋមជ្ឈានបាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណរបស់បុថុជ្ជន មិនមានទេ ។

[ ៣៨៥ ] បុថុជ្ជន គប្បីចូលកាន់ទុតិយជ្ឈាន ។បេ។ កាន់តតិយជ្ឈាន ... កាន់ចតុត្ថជ្ឈាន ។បេ។ កាន់អាកាសានញ្ចាយតនៈ គប្បីចូលកាន់វិញ្ញាណញ្ចាយតនៈ ... កាន់អាកិញ្ចញ្ញាយតនៈ ... កាន់នេវសញ្ញានាសញ្ញាយតនៈ បុថុជ្ជន គប្បីឲ្យទាន ។បេ។ ឲ្យចីវរ ។បេ។ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ។បេ។ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារដែរឬ ។ អើ ។ ប្រសិនបើ បុថុជ្ជន គប្បីឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណរបស់បុថុជ្ជន មិនមានទេ ។

[ ៣៨៦ ] ញាណរបស់បុថុជ្ជន មានដែរឬ ។ អើ ។ បុថុជ្ជន កំណត់ដឹងទុក្ខ លះបង់សមុទយៈ ធ្វើឲ្យជាក់ច្បាស់និរោធ ចម្រើនមគ្គដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ញាណកថា ចប់

# អដ្ឋកថា

## ញាណកថា

[ ៣៨៣ ] ឥឡូវនេះ នឹងពណ៌នាអំពីញាណដូចតទៅ

ក្នុងរឿងនោះ ញាណ មាន ២ យ៉ាង គឺលោកិយញ្ញាណ ១ លោកុត្តរញ្ញាណ ១ ។ ញាណក្នុងសមាបត្តិក្តី កម្មស្សកតាញាណ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃការឲ្យទានជាដើមក្តី ជា **លោកិយញ្ញាណ** មគ្គញ្ញាណ ដែលកំណត់សច្ចៈក្តី ផលញ្ញាណក្តី ជា **លោកុត្តរញ្ញាណ** ។ ជនទាំងឡាយណា មិនធ្វើការចែកនេះ មានលទ្ធិ ដូចលទ្ធិរបស់និកាយហេតុវាទថា ញាណដែលកំណត់សច្ចៈប៉ុណ្ណោះ ជាញាណ ញាណក្រៅអំពីនេះ មិនមែនជាញាណឡើយ ព្រោះហេតុនោះ ទើបញាណរបស់បុថុជ្ជនមិនមាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **បញ្ញា** ជាដើម សកវាទីសម្តែងវេវចនៈរបស់ញាណ អធិប្បាយថា សកវាទីសម្តែងនូវញាណនោះ ដោយបញ្ញានោះថា បើញាណរបស់បុថុជ្ជននោះ មិនមាន បញ្ញាជាដើមក៏មិនមាន ឬបញ្ញាជាដើមមាន ញាណ

ក៏មាន ព្រោះហេតុអ្វី ព្រោះភាពដែលបញ្ញាជាដើម មិនមែនជាធម៌ដទៃក្រៅអំពីញាណឡើយ ។

[ ៣៨៤ ] បទថា **បឋមំ ឈានំ** ជាដើម សកវាទីសម្តែងញាណក្នុងសមាបត្តិ ។

[ ៣៨៥ ] បទថា **ទានំ ទទេយ្យ** ជាដើម សកវាទីសម្តែងដល់កម្មស្សកតាញាណ ។

[ ៣៨៦ ] បទថា **ទុក្ខំ បរិជានាតិ** សម្តែងមគ្គញាណ ដែលជាលោកុត្តរប៉ុណ្ណោះ មិនបានសម្តែងលោកុត្តរញ្ញាណឡើយ ដូច្នេះ ៕

**អដ្ឋកថាញាណកថា ចប់**

# អភិធម្មបិដក

## និរយបាលកថា

[ ៣៨៧ ] ពួកនិរយបាល ក្នុងស្ថាននរក មិនមានទេឬ ។ អើ ។ហេតុនៃកម្ម ក្នុងស្ថាននរក មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ហេតុនៃកម្ម ក្នុងស្ថាននរក មានដែរឬ ។ អើ ។ ពួកនិរយបាល ក្នុងស្ថាននរក មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៨ ] ហេតុនៃកម្ម ក្នុងស្ថានមនុស្ស មាន ចុះពួកអ្នកធ្វើកម្ម ( ធ្វើទោស ) មានដែរឬ ។ អើ ។ ហេតុនៃកម្ម ក្នុងស្ថាននរក មាន ចុះពួកនិរយបាល មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ហេតុនៃកម្ម ក្នុងស្ថាននរក មាន ចុះពួកនិរយបាល មិនមានទេឬ ។ អើ ។ ហេតុនៃកម្ម ក្នុងស្ថានមនុស្ស មាន ចុះពួកនិរយបាល មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៩ ] ពួកនិរយបាល ក្នុងស្ថាននរក មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ស្តេចវេស្សភូ មិនបៀតបៀន ស្តេចប្រេត ស្តេចសោមៈ
ស្តេចយមៈ ស្តេចវេស្សវ័ណ ក៏មិនបៀតបៀនដែរ មានតែ
កម្មរបស់ខ្លួន រមែងបៀតបៀនសត្វ ដែលច្យុតចាកលោកនេះ
ទៅកាន់បរលោក ក្នុងស្ថាននរកនោះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងស្ថាននរក មិនមានទេ ។

[ ៣៩០ ] ពួកនិរយបាល ក្នុងស្ថាននរក មិនមានទេឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលឲ្យធ្វើនូវហេតុ ឈ្មោះថា ចំណង ៥ យ៉ាង ចំពោះបុគ្គលនោះ គឺយកដែកគោលក្តៅ មក បោះត្រង់ដៃ ។ យកដែកគោលក្តៅ មកបោះត្រង់ដៃពីរពីរ ។ យកដែកគោល ក្តៅ មកបោះត្រង់ជើង ។ យកដែកគោលក្តៅ មកបោះត្រង់ជើងពីរពីរ ។ យកដែកគោលក្តៅ មកបោះត្រង់កណ្តាលដើមទ្រូង ។ បុគ្គលនោះ រងវេទនា ជាទុក្ខ ក្លៀវក្លា រឹងរូសក្នុងនរកនោះ បាបកម្មនោះ មិនទាន់អស់ទៅដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងស្ថាននរក មាន ។

[ ៣៩១ ] ពួកនិរយបាល ក្នុងស្ថាននរក មិនមានទេឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ផ្តួល បុគ្គលនោះហើយ ចាំងដោយដឹងទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួក និរយបាល ដាក់បុគ្គលនោះឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ហើយ ប្រាសដោយកាំបិតទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុគ្គលនោះក្នុងរថ បរទៅផង បរត្រឡប់មកវិញផង លើផែនដីដែលភ្លើង ឆេះរន្ទាល ប្រាលក្តៅ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ញ៉ាំងបុគ្គល នោះឲ្យឡើងផង ឲ្យចុះផង កាន់ភ្នំរងើកភ្លើងធំ ដែលភ្លើងឆេះរន្ទាល ប្រាល ក្តៅ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុគ្គលនោះ ឲ្យមាន ជើងឡើងលើ ក្បាលចុះក្រោម ហើយបោះទៅក្នុងខ្ទះ ដ៏ពេញដោយទឹក

ទង់ដែងក្តៅ ដែលភ្លើងឆេះរន្ទាលប្រាលឆ្អៅ បុគ្គលនោះ រមែងឆេះ នៅមាន ពពុះព្រួចៗ ក្នុងនរកនោះ ទៅខាងលើម្តង ទៅខាងក្រោមម្តង ទៅទទឹងម្តង បុគ្គលនោះ ដល់នូវសេចក្តីទុក្ខ ក្នុងនរកនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល បោះបុគ្គលនោះ ទៅក្នុងមហានរក ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង

មានជ្រុង ៤ មានទ្វារ ៤ ដែលធម្មតាចែកកាប់ដោយចំណែក
មានកំពែងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ភូមិរបស់
មហានរកនោះ ជាវិការនៃដែក ដែលរុងរឿង ប្រកបដោយ
សំដៅ ផ្សាយទៅអស់ទីមួយរយយោជន៍ដោយជុំវិញ ហើយ
ស្ថិតនៅសព្វកាល ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងស្ថាននរក មាន ។

**និរយបាលកថា ចប់**

# អដ្ឋកថា

## និរយបាលកថា

[ ៣៨៧ ] ឥឡូវនេះ នឹងពណ៌នាអំពីពួកនិរយបាលដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ក្នុងនរក កម្មរបស់សត្វនរកនោះឯង រមែងសម្លាប់សត្វនរកទាំងឡាយ ដោយរូបភាពជានាយនិរយបាល សត្វទាំងឡាយ ឈ្មោះថា នាយនិរយបាល មិនមាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **នត្ថិ និរយេសុ** ជាដើម ដើម្បីសួរបរវាទីនោះថា បើនាយនិរយបាលទាំងឡាយ មិនគប្បីមានក្នុងនរកសោត សូម្បីកម្មករណៈទាំងឡាយក៏មិនគប្បីមាន តែកាលបុគ្គលដែលធ្វើកម្មករណៈទាំងឡាយមាន ការធ្វើកម្មករណៈ ក៏គប្បីមាន មិនមែនឬ ដូច្នេះ ។

[ ៣៨៨ ] បទថា **អត្ថិ មនុស្សេសុ** សកវាទីពោលហើយ ដើម្បីឲ្យជ្រាបដោយជាក់ច្បាស់ ។ ក្នុងសេចក្តីនេះ មានអធិប្បាយថា ឧបមាថា កាលពួកមនុស្សដែល ( ត្រូវ ) ធ្វើកម្មករណៈមាន ការធ្វើកម្មករណៈក៏រមែងមានយ៉ាងណា សូម្បីក្នុងនរកនោះ ក៏យ៉ាងនោះឯង ។

[ ៣៨៩ ] ពាក្យសួរថា **អត្ថិ និរយេសុ** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ។ បរវាទីនាំព្រះសូត្រមក ដោយលទ្ធិរបស់ខ្លួនថា **ន វេស្សភូ នោបិ ច បេត្តិរាជា** ដូច្នេះ ។ សកវាទីរមែងទទួល

ព្រះសូត្រនោះ ព្រោះគិតថា នុ៎ះជាពាក្យដែលឈមចុះក្នុងព្រះសាសនា ។

ក្នុងបទទាំងនោះ បទថា **វេស្សភូ** បានដល់ ទេវតាមួយអង្គ ។ បទថា **បេត្តិរាជា** បានដល់ ប្រេតអ្នកមានឫទ្ធិច្រើនក្នុងបិត្តិវិស័យ ។ ស្តេចសោម ជាដើម ប្រាកដជាក់ច្បាស់ហើយនោះឯង ។ សេចក្តីនេះ លោកអធិប្បាយថា ស្តេចវេស្សភូជាដើម រមែងមិនសម្លាប់សត្វដែលលះលោកនេះហើយ ទៅកាន់លោកខាងមុខ តាមកម្មទាំងឡាយរបស់ខ្លួន ។ ម្យ៉ាងទៀត សត្វនោះ លះទីនោះទៅ ដោយកម្មទាំងឡាយណា កម្មទាំងឡាយដែលជារបស់ខ្លួនទាំងនោះឯង រមែងសម្លាប់សត្វក្នុងទីនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគសម្តែងដល់ភាពដែលសត្វទាំងឡាយ មានកម្មជារបស់ខ្លួន មិនមែនសម្តែងការមិនមាននិរយបាលទាំងឡាយនោះឡើយ ។

[ ៣៩១ ] ម្យ៉ាងទៀត បទនៃព្រះសូត្រទាំងឡាយ ដែលសកវាទីនាំមកពោលហើយថា **តមេនំ ភិក្ខវេ** ជាដើម មានអត្ថដូចលោកនាំមកហើយនោះឯង ។ល។

**អដ្ឋកថានិរយបាលកថា ចប់**

# អភិធម្មបិដក

## តិរច្ឆានកថា

[ ៣៩២ ] ពួកសត្វតិរច្ឆានក្នុងទេវលោក មានដែរឬ ។ អើ ។ ពួកទេវតាក្នុងស្ថានសត្វតិរច្ឆាន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ទេវលោក មានកំណើតជាតិរច្ឆានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ពួកកន្លាត កន្ទុំរុយ របោម រុយ ពស់ ខ្ទួយ ក្អែប ជន្លេន ក្នុងទេវលោកនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៣ ] ពួកសត្វតិរច្ឆាន ក្នុងទេវលោក មិនមានទេឬ ។ អើ ។ ក្រែងដំរីដ៏ប្រសើរ ឈ្មោះឯរាវណ យានជាទិព្វដែលទឹមដោយសេះមួយពាន់ ក្នុងទេវលោកនោះ មានឬ ។ អើ ។ ប្រសិនបើ ដំរីដ៏ប្រសើរឈ្មោះឯរាវណ យានជាទិព្វ ដែលទឹមដោយសេះមួយពាន់ ក្នុងទេវលោកនោះមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកសត្វតិរច្ឆាន ក្នុងទេវលោក មាន ។

[ ៣៩៤ ] ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ហ្មដំរី ហ្មសេះ ជនអ្នកឲ្យស្រូវដំណើប ជនអ្នកធ្វើកម្ម ជនអ្នកធ្វើកត្តក្នុងទេវលោកនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មិនមានទេ ។

**តិរច្ឆានកថា ចប់**

# អដ្ឋកថា

## តិរច្ឆានកថា

[ ៣៩២ ] ឥឡូវនេះ នឹងពណ៌នាអំពីពួកសត្វតិរច្ឆានដូចតទៅ

ក្នុងរឿងនោះ ទេវបុត្តទាំងឡាយ ឈ្មោះថា ឯរាវណជាដើម ក្នុងទេវតាទាំងឡាយនោះ រមែងកាឡាខ្លួនជាដំរី ជាសេះ សត្វតិរច្ឆានទាំងឡាយ មិនមានក្នុងទីនោះ ជនទាំងឡាយណា មានលទ្ធិដូច លទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា សត្វតិរច្ឆានទាំងឡាយ មានក្នុងពួកទេវតា ព្រោះឃើញទេវបុត្តទាំងឡាយ មានភេទជាសត្វតិរច្ឆាន ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ពោលពាក្យថា **អត្ថិ តិរច្ឆានគតេសុ** ជាដើម ដើម្បីសួរបរវាទីនោះថា បើសត្វតិរច្ឆានទាំងឡាយ គប្បីមានក្នុងទេវកំណើតបានសោត ទេវតាទាំងឡាយគប្បីមានក្នុងកំណើតរបស់សត្វតិរច្ឆានបាន ដូច្នេះ ។

បទថា **កីដា** ជាដើម សកវាទីសម្តែងដល់សត្វទាំងឡាយ ដែលបរវាទីប្រាថ្នាថា មិនមាន ។

[ ៣៩៣ ] ក្នុងបញ្ហាថា **ឯរាវណោ** សកវាទីទទួល ព្រោះភាពដែលដំរីឈ្មោះឯរាវណ និងយានទិព្វនោះមាន មិនមែនសត្វតិរច្ឆានមានឡើយ ។

*[ ៣៩៥ ] បទថា* **ហត្ថិពន្ធា** *ជាដើម សកវាទីពោលដើម្បីចោទសួរថា បើដំរីជាដើមគប្បីមានក្នុងទីនោះសោត សូម្បីពួកអ្នកចងដំរីជាដើម ក៏គប្បីមានក្នុងទីនោះ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា* **យាវសិកា** *បានដល់ អ្នកឲ្យស្មៅដល់សត្វស៊ី ។ បទថា* **ការណិកា** *បានដល់ នាយហត្ថាចារ្យ ជាដើម ដែលឲ្យជនទាំងឡាយនោះ ធ្វើការបង្ខឹក ( សត្វតិរច្ឆាន ) ដោយវិធីផ្សេងៗ ។ បទថា* **ភត្តការកា** *បានដល់ អ្នកចម្អិនអាហារឲ្យសត្វទាំងឡាយមានដំរីជាដើម ។ បទថា* **ន ហេវំ** *សេចក្ដីថា បរវាទី កាលមិនប្រាថ្នាបែបនោះ ទើបឆ្លើយបដិសេធ ដូច្នេះឯង ។*

## អដ្ឋកថានិរយបាលកថា ចប់

# អភិធម្មបិដក

## មគ្គកថា

[ ៣៩៥ ] មគ្គប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងមគ្គប្រកបដោយអង្គ ៨ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ មគ្គប្រកបដោយអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ឬ ។ អើ ។ ប្រសិនបើមគ្គប្រកបដោយអង្គ ៨ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ មគ្គប្រកបដោយអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គប្រកបដោយអង្គ ៥ ទេ ។ មគ្គប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយ បទ គឺអរិយសច្ច ៤
ប្រសើរជាងសច្ចៈទាំងឡាយ ធម៌ មានរាគៈទៅប្រាសហើយ
ប្រសើរជាងធម៌ទាំងឡាយ ព្រះមានព្រះភាគ ព្រះអង្គមានចក្ខុ
ប្រសើរជាងសត្វជើងពីរទាំងឡាយ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថាប្រកបដោយអង្គ ៨ ។

[ ៣៩៦ ] សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាសង្កប្ប ។បេ។ សម្មា-

វាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិ នោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មា-កម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មា-សមាធិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៧ ] សម្មាទិដ្ឋិជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង ជាតួមគ្គឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ សម្មាទិដ្ឋិជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះ ជាតួមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាសង្កប្បៈ ។បេ។ សម្មា-វាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិជាអង្គនៃមគ្គ សម្មាសមាធិ នោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាវាចា ។បេ។ សម្មាកម្មន្តៈ ។បេ។ សម្មា-អាជីវៈជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង ជាតួមគ្គឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៣៩៨ ] អរិយមគ្គប្រកបដោយអង្គ ៨ ឬ ។ អើ ។ ក្រែងព្រះមាន ព្រះភាគទ្រង់ត្រាស់ថា ឯកាយកម្ម វចីកម្ម អាជីវៈរបស់បុគ្គលនោះ ជាធម៌ ដ៏បរិសុទ្ធស្អាតមានក្នុងកាលមុនពិត អរិយមគ្គប្រកបដោយអង្គ ៨ នេះរបស់ បុគ្គលនោះ ដល់នូវកិរិយាពេញដោយភាវនាយ៉ាងនេះ ពាក្យដូច្នេះ មានក្នុង ព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថា ប្រកបដោយអង្គ ៥ ។

[ ៣៩៩ ] មគ្គប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មិនមានក្នុងធម្មវិន័យណា សមណៈទី ១ មិនមានក្នុងធម្មវិន័យនោះ សមណៈទី ២ មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៣ មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក៏មិនមានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ លុះតែអរិយមគ្គប្រកបដោយអង្គ ៨ មានក្នុងធម្មវិន័យណា សមណៈទី ១ មានក្នុងធម្មវិន័យនោះ សមណៈទី ២ ។បេ។ សមណៈទី ៣ ។បេ។ សមណៈទី ៤ ក៏មានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈទី ១ ក៏មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ ( ពាក្យតិះដៀល ) អំពីពួកសមណៈដទៃក៏សូន្យទៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថា ប្រកបដោយអង្គ ៨ ។

មគ្គកថា ចប់

# អដ្ឋកថា

## មគ្គកថា

[ ៣៩៥ ] ឥឡូវនេះ នឹងពណ៌នាអំពីមគ្គដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហិសាសកៈទាំងឡាយថា ពោលដោយត្រង់ មគ្គមានអង្គ ៥ ប៉ុណ្ណោះ ព្រោះអាស្រ័យព្រះសូត្រថា ឯកាយកម្ម វចីកម្ម អាជីវៈរបស់បុគ្គលនោះ ជាធម៌ដ៏បរិសុទ្ធស្អាត មានក្នុងកាលមុនពិត ដូច្នេះ និងព្រោះអាស្រ័យសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជាធម៌មិនប្រកបជាមួយចិត្ត ពាក្យសួររបស់សកវាទីថា **បញ្ចង្គិកោ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ៣៩៦ ] បទថា **សម្មាវាចា មគ្គង្គំ សា ច ន មគ្គោ** ជាដើម សកវាទីពោលដោយអំណាចនៃលទ្ធិដទៃ ។ ពិតហើយ ក្នុងលទ្ធិដទៃ សម្មាវាចាជាដើម រាប់ហើយថា ជាអង្គនៃមគ្គ តែលោកពណ៌នាថា មិនមែនមគ្គ ព្រោះភាពជារូប ។

[ ៣៩៧ ] បទថា **សម្មាទិដ្ឋិ មគ្គង្គំ** ជាដើម សកវាទីពោលថា ភាពដែលអង្គនៃមគ្គ មិនជាមគ្គ មិនមាន ដូច្នេះ ។

[ ៣៩៨ ] ក្នុងព្រះសូត្រថា **បុព្វេវ ខោ បនស្ស** ព្រះមានព្រះភាគត្រាស់ថា ឯកាយកម្ម វចីកម្ម អាជីវៈរបស់បុគ្គលនោះ ជាធម៌ដ៏បរិសុទ្ធស្អាត ក៏ដើម្បីសម្តែងនូវភាពដែលបដិបទា ដែលកុលបុត្តគប្បីសម្រេច ជាការៈបរិសុទ្ធហើយថា ឈ្មោះថា មគ្គភាវនា រមែងមានដល់បុគ្គលអ្នកមានសីលបរិសុទ្ធហើយ មិនមែនមានដល់បុគ្គលក្រៅអំពីនេះឡើយ ដូច្នេះ មិនមែនត្រាស់ដើម្បីសម្តែងដល់ភាពដែលមគ្គប្រកបដោយអង្គ ៥ ដោយវៀរចាកសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈទាំងនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អរិយមគ្គមានអង្គ ៨ នេះ ដល់នូវភាពបរិបូណ៌ដោយភាវនាដល់បុគ្គលនោះ ដោយប្រការដូច្នេះ ចំណែកព្រះសូត្រដែលសកវាទីនាំមកហើយ មានអត្ថតាមដែលលោកនាំមកហើយនោះឯង ។

## អដ្ឋកថាមគ្គកថា ចប់

# អភិធម្មបិដក

## ញាណកថា

[ ៤០០ ] ញាណមានវត្ថុ ១២ ជាលោកុត្តរឬ ។ អើ ។ លោកុត្តរញ្ញាណ មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ លោកុត្តរញ្ញាណ មាន ១២ ឬ ។ អើ ។ សោតាបត្តិមគ្គ មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិមគ្គ មាន ១២ ឬ ។ អើ ។ សោតាបត្តិផល មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិមគ្គ ។បេ។ អនាគាមិមគ្គ ។បេ។ អរហត្តមគ្គ មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរហត្តមគ្គ មាន ១២ ឬ ។ អើ ។ អរហត្តផល មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០១ ] បុគ្គលមិនគួរនិយាយថា ញាណមានវត្ថុ ១២ ជាលោកុត្តរទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮ ក្នុងកាលមុនថា នេះទុក្ខ ឈ្មោះថា អរិយសច្ច ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទុក្ខ ឈ្មោះថា អរិយសច្ចនោះឯង បុគ្គលគួរកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទុក្ខឈ្មោះថា អរិយសច្ចនោះ តថាគតបានកំណត់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា តណ្ហានាំឲ្យកើតទុក្ខ នេះ ឈ្មោះថា អរិយសច្ច ម្នាល

ភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា តណ្ហានាំឲ្យកើតទុក្ខ ឈ្មោះថា អរិយ-សច្ចនោះឯង បុគ្គលគួរលះបោល ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា តណ្ហានាំឲ្យកើតទុក្ខ ឈ្មោះថា អរិយសច្ចនោះ តថាគតបានលះបោលហើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទីរលត់ទុក្ខនេះ ឈ្មោះថា អរិយ-សច្ច ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទីរលត់ទុក្ខ ឈ្មោះថា អរិយសច្ចនោះឯង បុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទីរលត់ទុក្ខ ឈ្មោះថា អរិយសច្ចនោះ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា សេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ ឈ្មោះថា អរិយសច្ច ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា សេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា អរិយសច្ចនោះឯង បុគ្គលគួរចម្រើន ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ។បេ។ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮ ក្នុងកាលមុនថា សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា អរិយសច្ចនោះ តថាគតបានចម្រើនហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ញាណមានវត្ថុ ១២ ជាលោកុត្តរ ។

ញាណកថា ចប់

វិសមតិមវគ្គ ចប់

## ឧទ្ទាននៃវីសតិមវគ្គនោះ គឺ

និយាយអំពីមាតុឃាតក៍ ដល់អនន្តិយកម្ម បិតុឃាតក៍ ដល់អនន្តរិយកម្ម អរហន្តឃាតក៍ ដល់អនន្តរិយកម្ម រុហិរុប្បាទក៍ ដល់អនន្តអរិយកម្ម សង្ឃភេទក៍ ដល់អនន្តរិយកម្ម ១ ញាណរបស់បុថុជ្ជន មិនមាន ១ ពួកនិរយបាលក្នុងស្ថាននរក មិនមាន ១ ពួកសត្វតិរច្ឆានក្នុងទេវលោកមាន ១ មគ្គប្រកបដោយអង្គប្រាំ ១ ញាណមានវត្ថុ ១២ ជាលោកុត្តរ ១ ។

**ចតុត្ថបណ្ណាសក ចប់**

( ក្នុងបណ្ណាសកនេះ ) និយាយអំពីការសន្តត់សន្តិនជាដើម ១ ការសន្សំបុណ្យជាដើម ១ ព្រះមានព្រះភាគ ស្ថិតនៅក្នុងមនុស្សលោកជាដើម ១ ការលះកិលេសជាអតីតជាដើម ១ មាតុឃាតក៍ ដល់អនន្តរិយកម្មជាដើម ១ ។

# អដ្ឋកថា

## ញាណកថា

[ ៤០០ ] ឥឡូវនេះ នឹងពណ៌នាអំពីញាណដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វ-សេលិយៈ និងនិកាយអបរសេលិយៈទាំងឡាយថា ញាណដែលជាលោកុត្តរមានវត្ថុ ១២ ដោយសំដៅយកញាណមានអាការ ១២ ក្នុងធម្មចក្កប្បវត្តនសូត្រ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ពោលពាក្យថា **ទ្វាទស** ដើម្បីសួរបរវាទីនោះថា បើលោកុត្តរញ្ញាណនោះ មានវត្ថុ ១២ សោតមគ្គញ្ញាណទាំងឡាយ ក៏គប្បីមាន ១២ ដូច្នេះ បរវាទីឆ្លើយបដិសេធ សំដៅយកមគ្គមាន ១ តែឆ្លើយទទួល សំដៅយកការផ្សេងគ្នានៃញាណ ដោយអំណាចនៃសច្ចញ្ញាណ កិច្ចញ្ញាណ និងកតញ្ញាណទាំងឡាយ ក្នុងសច្ចៈនីមួយៗ ។ ក្នុងបទថា **ទ្វាទស សោតាបត្តិមគ្គា** ក៏ន័យនេះឯង ។

[ ៤០១ ] ព្រះសូត្រថា **ឆន្នុ វុត្តំ ភគវតា** ដូច្នេះ រមែងសម្តែងដល់ការផ្សេងគ្នានៃញាណដែលជាចំណែកខាងដើម និងចំណែកខាងចុង តាមលទ្ធិ មិនមែនសម្តែងដល់ភាពដែលអរិយមគ្គជាញាណ ១២ យ៉ាង ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាង ដូច្នេះ ។ល។

**អដ្ឋកថាញាណកថា ចប់**

**វគ្គទី ២០ ចប់**

**ចតុបណ្ណាសក ចប់**

# អភិធម្មបិដក

## សាសនកថា

[ ៤០២ ] សាសនា គេធ្វើជាថ្មីបានដែរឬ ។ អើ ។ សតិប្បដ្ឋាន គេធ្វើជាថ្មីបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សាសនា គេធ្វើជាថ្មីបានដែរឬ ។ អើ ។ សម្មប្បធាន ។បេ។ ឥទ្ធិបាទ ។បេ។ ឥន្ទ្រិយ ។បេ។ ពល ។បេ។ ពោជ្ឈង្គ គេធ្វើជាថ្មីបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អកុសល គេធ្វើក្នុងកាលមុន កុសល គេធ្វើក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អំពើប្រកបដោយអាសវៈ ។បេ។ គួរដល់សញ្ញោជនៈ គួរដល់គន្ថៈ គួរដល់ឱឃៈ គួរដល់យោគៈ គួរដល់នីវរណៈ ដែលបរាមាស គប្បីស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន ។បេ។ ប្រកបដោយកិលេស គេធ្វើក្នុងកាលមុន អំពើមិនប្រកបដោយកិលេស គេធ្វើក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៣ ] បុគ្គលណាមួយ ធ្វើសាសនារបស់ព្រះតថាគតជាថ្មី មានដែរឬ ។ អើ ។ បុគ្គលណាមួយ ធ្វើសតិប្បដ្ឋានជាថ្មី មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលណាមួយ ធ្វើសម្មប្បធាន ។បេ។ ឥទ្ធិបាទ ។បេ។ ឥន្ទ្រិយ ។បេ។ ពល ។បេ។ ពោជ្ឈង្គជាថ្មី មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលណាមួយ ធ្វើអកុសលក្នុងកាលមុន ធ្វើកុសលក្នុងកាលជាខាងក្រោយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលណាមួយ ធ្វើអំពើប្រកបដោយអាសវៈ ។បេ។ ប្រកបដោយកិលេស

ក្នុងកាលមុន ធ្វើអំពើមិនប្រកបដោយកិលេស ក្នុងកាលជាខាងក្រោយ មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៤ ] បុគ្គលបានធ្វើសាសនារបស់តថាគត ជាថ្មីវិញដែរឬ ។ អើ ។ បុគ្គលបានធ្វើសតិប្បដ្ឋាន ជាថ្មីវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលបានធ្វើសម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ។បេ។ ពោជ្ឈង្គ ជាថ្មីវិញ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលបានធ្វើអកុសលក្នុងកាល មុន ធ្វើកុសលក្នុងកាលជាខាងក្រោយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។បេ។ បុគ្គលបានធ្វើអំពើប្រកបដោយអាសវៈ ។បេ។ ប្រកបដោយ កិលេសក្នុងកាលមុន ធ្វើអំពើមិនប្រកបដោយកិលេស ក្នុងកាលជាខាង ក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## សាសនកថា ចប់

# អដ្ឋកថា

## សាសនកថា

[ ៤០២ ] ឥឡូវនេះ នឹងពណ៌នាអំពីសាសនាដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តាបថកៈពួកខ្លះថា សាសនាគេធ្វើជាថ្មី និងថា មានបុគ្គលពួកខ្លះ រមែងបន្ទឹសាសនារបស់ព្រះតថាគតជាថ្មី និងថា បុគ្គលអាចធ្វើសាសនារបស់ព្រះតថាគតជាថ្មីបាន ដោយសំដៅយកការសន្តាយនាទាំង ៣ ជង ដូច្នេះ ពាក្យសួររបស់សកវាទីក្នុងកថាទាំង ៣ សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **សតិប្បដ្ឋានា** ជាដើម សកវាទីសួរក្នុងបញ្ហាទាំង ៣ ថា អរិយធម៌ទាំងឡាយ មានសតិប្បដ្ឋានជាដើម និងការសម្តែងនូវកុសលធម៌ជាដើម ឈ្មោះថា សាសនា ។ ក្នុងសាសនានោះ ធម៌ទាំងឡាយ មានសតិប្បដ្ឋានជាដើម ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដើម្បីផលទាំងឡាយណា វៀរផលទាំងឡាយនោះចេញ ទើបសាសនា ឈ្មោះថា ជាការធ្វើជាថ្មី ដោយការធ្វើធម៌ពួកដទៃឲ្យជាសតិប្បដ្ឋានជាដើម ឬធ្វើអកុសលធម៌ជាដើម ឲ្យជាកុសលធម៌ជាដើម ។ សាសនានោះ ដែលបុគ្គលណាមួយ ធ្វើហើយយ៉ាងនោះឬ បុគ្គលណាមួយ ដែលធ្វើយ៉ាងនោះបាន មានឬ អាចដើម្បីធ្វើយ៉ាងនោះបានឬ ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង គប្បីជ្រាបតាមព្រះបាលីនោះឯង ។ល។

**អដ្ឋកថាសាសនកថា ចប់**

# អភិធម្មបិដក

## អវិវិត្តកថា

[ ៤០៥ ] បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេឬ ។ អើ ។ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកផស្សៈ ប្រកបដោយធាតុ ៣ ។បេ។ ចាកវេទនា សញ្ញា ចេតនា ចិត្ត សទ្ធា វីរិយៈ សតិ សមាធិ ប្រកបដោយធាតុ ៣ ចាកបញ្ញា ប្រកបដោយធាតុ ៣ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេឬ ។ អើ ។ ក្នុងខណៈណា បុថុជ្ជន ឲ្យចីវរ ក្នុងខណៈនោះ ក៏បានដល់នូវបឋមជ្ឈាន ។បេ។ បានដល់ នូវអាកាសានញ្ចាយតនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្នុងខណៈណា បុថុជ្ជន ឲ្យបិណ្ឌបាត ។បេ។ ឲ្យទីសេនាសនៈ ។បេ។ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងខណៈនោះ ក៏បានដល់នូវចតុត្ថជ្ឈាន បានដល់នូវនេវសញ្ញានាសញ្ញាយតនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៦ ] បុគ្គលមិនគួរនិយាយថា បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ប្រកបដោយធាតុ ៣ ទេឬ ។ អើ ។ កម្ម គួរដល់នូវរូបធាតុ និងអរូបធាតុ បុថុជ្ជន កំណត់ដឹងហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេ ។

*អវិវិត្តកថា ចប់*

# អដ្ឋកថា

## អវិវិត្តកថា

[ ៤០៥ ] ឥឡូវនេះ នឹងពណ៌នាអំពីបុថុជ្ជនមិនស្ងប់ស្ងាត់ដូចតទៅ ក្នុងរឿងនោះ ការសន្និដ្ឋានក្នុងលទ្ធិរបស់សកវាទី មានដូច្នេះថា ធម៌ណាកើតឡើងចំពោះមុខ ដល់បុគ្គលណា បុគ្គលនោះ ឈ្មោះថា មិនស្ងាត់ចាកធម៌នោះ ដូច្នេះ ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះឯងថា ព្រោះបុថុជ្ជន មិនកំណត់ដឹងធម៌ ដែលប្រកបដោយធាតុ ៣ គឺកាមធាតុ រូបធាតុ អរូបធាតុ ព្រោះហេតុនោះ បុថុជ្ជននោះ មិនស្ងាត់ចាកធម៌ ដែលប្រកបដោយធាតុទាំងពួង ៣ ក្នុងខណៈមួយឡើយ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បទថា **ផស្សេហិ** ជាដើម សកវាទីសម្តែងទោសដែលប្រព្រឹត្តទៅក្នុងខណៈមួយនៃធម៌ទាំងពួង មានផស្សៈជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាអវិវិត្តកថា ចប់**

# អភិធម្មបិដក

## សញ្ញោជនកថា

[ ៤០៧ ] ការដល់ព្រះអរហត្ត ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មានដែរឬ ។ អើ ។ ការដល់ព្រះអរហត្ត ព្រោះមិនលះសក្កាយទិដ្ឋិ ។បេ។ ព្រោះមិនលះវិចិកិច្ឆា ។បេ។ ព្រោះមិនលះសីលព្វតបរាមាស ព្រោះមិនលះរាគៈ ព្រោះមិនលះទោសៈ ព្រោះមិនលះមោហៈ ។បេ។ ព្រោះមិនលះអនោត្តប្បៈតិចតួច មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៨ ] ការដល់ព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានដែរឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ ប្រកបដោយមានះ ប្រកបដោយមក្ខៈ ប្រកបដោយបឡាសៈ ប្រកបដោយឧបាយាសៈ ប្រកបដោយកិលេសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត មិនមានរាគៈ មិនមានទោសៈ មិនមានមោហៈ មិនមានមានះ មិនមានមក្ខៈ មិនមានបឡាសៈ មិនមានឧបាយាសៈ មិនមានកិលេសទេឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្តមិនមានរាគៈ ។បេ។

មិនមានកិលេសទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានទេ ។

[ ៤០៩ ] បុគ្គលមិនគួរនិយាយថា ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានទេឬ ។ អើ ។ ព្រោះអរហន្ត ដឹងនូវពុទ្ធវិស័យទាំងអស់ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មាន ។

## សញ្ញោជនកថា ចប់

# អដ្ឋកថា

## សញ្ញោជនកថា

[ ៤០៧ ] ឥឡូវនេះ នឹងពណ៌នាអំពីសញ្ញោជនៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ការមិនលះសញ្ញោជនៈពួកខ្លះហើយ សម្រេចជាព្រះអរហន្ត មាន ដោយមានការសម្គាល់ថា ព្រោះព្រះអរហន្ត មិនដឹងពុទ្ធ-វិស័យទាំងពួង ព្រោះហេតុនោះ អវិជ្ជា និងវិចិកិច្ឆា ដែលមិនទាន់លះបានក្នុងពុទ្ធវិស័យនោះ គប្បីមានដល់ព្រះអរហន្តនោះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **អត្ថិ កិញ្ចិ សក្កាយទិដ្ឋិ** ជាដើម សកវាទីសម្ដែងថា ព្រះអរហន្តត្រូវលះសញ្ញោជនៈបានទាំងអស់ ។

[ ៤០៨ ] ក្នុង ២ បញ្ហាថា **សព្វំ ពុទ្ធវិសយំ** សកវាទីធ្វើការបដិសេធ ព្រោះព្រះអរហន្ត មិនមានសព្វញ្ញុតញ្ញាណ មិនមែនបដិសេធ ព្រោះព្រះអរហន្ត មិនលះអវិជ្ជា និងវិចិកិច្ឆា តែបរវាទីសំដៅយកភាពដែលព្រះអរហន្តមិនដឹងពុទ្ធវិស័យ ថាជាការមិនលះអវិជ្ជា និងវិចិកិច្ឆាទាំងឡាយ ទើបបានឲ្យលទ្ធិតាំងទុកដោយពាក្យថា **តេន ហិ** ដូច្នេះ តែលទ្ធិនោះ មិនមែនជាការតាំងនៅ ព្រោះឲ្យតាំងនៅដោយមិនមែនឧបាយ ដូច្នេះឯង ។៚

**អដ្ឋកថាសញ្ញោជនកថា ចប់**

# អភិធម្មបិដក

## ឥន្ទិកថា

[ ៤១០ ] សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវក ទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធ ទាំងឡាយក្តី នៃសាវកទាំងឡាយក្តីថា ឈើទាំងឡាយ ចូរមានស្លឹកជានិច្ច ដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសម្រេច តាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តីថា ឈើទាំងឡាយ ចូរមានផ្កាជានិច្ច ។បេ។ ឈើទាំងឡាយ ចូរមានផ្លែជានិច្ច ចូរត្រជាក់ត្រជុំ ជានិច្ច ចូរមានសេចក្តីក្សេមជានិច្ច ចូរមានបាយងាយជានិច្ច ចូរមានភ្លៀង ស្រួលជានិច្ច ដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី មាន ដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃ សាវកទាំងឡាយក្តីថា ផស្សៈកើតឡើងហើយ កុំរលត់ទៅវិញឡើយ ដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តីថា វេទនា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ចិត្ត សទ្ធា វិរិយៈ សតិ សមាធិ ។បេ។ បញ្ញាកើតឡើង ហើយ កុំរលត់ទៅវិញឡើយ ដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

[ ៤១១ ] សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវក

ទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នាថា រូប ចូរទៀង ដូច្នេះ មានដែរឬ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តីថា វេទនា សញ្ញា សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ចូរទៀង ដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១២ ] សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តីថា ពួកសត្វ មានជាតិជាធម្មតា កុំកើតឡើយ ដូច្នេះ មានដែរឬ ។បេ។ ថា ពួកសត្វ មានជរាជាធម្មតា កុំចាស់គ្រាំគ្រាឡើយ ដូច្នេះ ។បេ។ ថា ពួកសត្វ មានព្យាធិជាធម្មតា កុំឈឺចាប់ឡើយ ដូច្នេះ ។បេ។ ថា ពួកសត្វ មានមរណៈជាធម្មតា កុំស្លាប់ឡើយ ដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៣ ] បុគ្គលមិនគួរនិយាយថា សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី មានទេឬ ។ អើ ។ ក្រែងព្រះបិលិន្ទវច្ឆៈមានអាយុ មុជជ្រែកប្រាសាទមាស របស់ស្តេចទ្រង់ព្រះនាម

មាគធសេនិយពិម្ពិសារ ចុះមាស មានទៅជាធម្មតាឬ ។ អើ ។ ប្រសិនបើ បិលិន្ទវច្ឆៈមានអាយុ មុនជ្រែប្រាសាទមាស របស់ស្ដេចទ្រង់ព្រះនាមមាគធ-សេនិយពិម្ពិសារ មាសមានទៅជាធម្មតា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សេចក្ដីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្ដី នៃសាវកទាំងឡាយក្ដី មាន ។

ឥទ្ធិកថា ចប់

# អដ្ឋកថា

## ឥទ្ធិកថា

[ ៤១០ ] ឥឡូវនេះ នឹងពណ៌នាអំពីឫទ្ធិដូចតទៅ

ក្នុងរឿងនោះ ការសន្និដ្ឋាននេះ ក្នុងលទ្ធិរបស់សកវាទីមានថា ឈ្មោះថា ឫទ្ធិនេះ រមែងសម្រេចបានក្នុងចំណែកខ្លះ រមែងសម្រេចមិនបានក្នុងចំណែកខ្លះ ។ ឫទ្ធិ រមែងមិនសម្រេចដោយចំណែកមួយពិតប្រាកដ ក្នុងការធ្វើនូវធម៌ទាំងឡាយ ដែលមិនទៀងជាដើម ឲ្យជារបស់ទៀងជាដើម តែឫទ្ធិនោះ ដែលបុគ្គលធ្វើដើម្បីប្រយោជន៍ដល់ជនពួកណា ក្នុងការផ្លាស់ប្តូរ ការបន្ត គឺអាយុដែលស្មើគ្នា ធ្វើឲ្យមិនស្មើគ្នា ឬក្នុងការប្រព្រឹត្តទៅបានយូរជាងដោយអំណាចនៃការបន្ត ដែលមានចំណែកស្មើគ្នា ឫទ្ធិនោះ រមែងសម្រេចបានខ្លះ ព្រោះអាស្រ័យហេតុទាំងឡាយ មានបុណ្យរបស់ជនទាំងនោះជាដើម ដូចក្នុងការធ្វើទឹកដែលគួរផឹកឲ្យជាសប្បិ និងទឹកដោះស្រស់ជាដើម ដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ និងដូចក្នុងការបន្ត តាំងនៅអស់កាលយូររបស់ប្រទីបជាដើម ក្នុងទីដែលកប់នូវមហាធាតុជាដើម ដូច្នេះ ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ឫទ្ធិ ជាហេតុឲ្យសម្រេចសេចក្តីប្រាថ្នា មាន ព្រោះអាស្រ័យព្រះសូត្រដែលពោលថា ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏អធិដ្ឋានប្រាសាទរបស់ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ឲ្យក្លាយជាមាសទៅ ដូច្នេះ ពាក្យសួររបស់សកវាទីថា សេចក្តីសម្រេចតាមប្រាថ្នា សំដៅដល់ជនទាំងនោះ ។ ក្នុងបទទាំង

នោះ បទថា **អធិប្បាយឥទ្ធិ** បានដល់ ឫទ្ធិក្នុងសេចក្តីប្រាថ្នា អធិប្បាយថា ឫទ្ធិ គឺសេចក្តីសម្រេចតាមដែលត្រូវការ ។ បទថា **អាមន្តា** ជាពាក្យឆ្លើយទទួលរបស់បរវាទី ដែលតាំងក្នុងហេតុត្រឹមតែលទ្ធិ ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **និច្ចបណ្ណា រុក្ខា ហោន្តុ** ជាដើម ដើម្បីសាកសួរបរវាទីក្នុងភាពដែលធម៌ទាំងឡាយ មានការមិនទៀងជាដើម ជារបស់ទៀងជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ៤១៣ ] ក្នុងការឲ្យលទ្ធិតាំងទុក ដោយព្រះសូត្រថា **សុវណ្ណោ ច បាសាទោ** មានអធិប្បាយថា ប្រាសាទនោះ បានជាប្រាសាទមាស ព្រោះចូលទៅអាស្រ័យបុណ្យរបស់ព្រះរាជា មិនមែនដោយបំណងរបស់ព្រះថេរៈតែម្យ៉ាងប៉ុណ្ណោះទេ ។ ព្រោះហេតុនោះ ទើបព្រះសូត្រនេះ មិនមែនជាគោលអាង ដូច្នេះ ៕ល៕

## អដ្ឋកថាឥទ្ធិកថា ចប់

# អភិធម្មបិដក

## ពុទ្ធកថា

[ ៤១៤ ] *ភាវៈនៃព្រះពុទ្ធទាំងឡាយ ថោកទាប និងថ្លៃថ្លាជាងព្រះពុទ្ធទាំងឡាយ មានដែរឬ ។ អើ ។ ( ភាវៈនៃព្រះពុទ្ធទាំងឡាយ ថោកទាប និងថ្លៃថ្លាជាងព្រះពុទ្ធទាំងឡាយ ) ដោយសតិប្បដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយសម្មប្បធាន ។បេ។ ដោយឥទ្ធិបាទ ដោយឥន្ទ្រិយ ដោយពល ដោយពោជ្ឈង្គ ដោយវសីភាព ។បេ។ ដោយសព្វញ្ញុតញ្ញាណទស្សនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។*

*ពុទ្ធកថា ចប់*

# អដ្ឋកថា

## ពុទ្ធកថា

[ ៤១៤ ] ឥឡូវនេះ នឹងពណ៌នាអំពីព្រះពុទ្ធទាំងឡាយដូចតទៅ

ក្នុងរឿងនោះ វៀរលែងការផ្សេងគ្នានៃសរីរៈ ( កម្ពស់ ) ការផ្សេងគ្នានៃអាយុ និងការផ្សេងគ្នានៃរស្មី ដែលមានក្នុងកាលនោះៗ ហើយ ឈ្មោះថាការខ្វះ និងការលើសរបស់ព្រះពុទ្ធទាំងឡាយ ជាមួយនឹងព្រះពុទ្ធទាំងឡាយ ដោយធម៌ទាំងឡាយរបស់ព្រះពុទ្ធដ៏សេស មិនមាន តែជនទាំងឡាយណាមានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ការថោកទាប និងថ្លៃថ្លារបស់ព្រះពុទ្ធទាំងឡាយ ជាមួយនឹងព្រះពុទ្ធទាំងឡាយ មាន ដោយមិនប្លែកគ្នាឡើយ ដូច្នេះ ពាក្យសួររបស់សកវាទីថា **អត្ថិ ពុទ្ធានំ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលថា **សតិបដ្ឋានតោ** ជាដើម ដើម្បីសាកសួរបរវាទី ដោយធម៌ទាំងឡាយរបស់ព្រះពុទ្ធ ។ បរវាទី កាលមិនឃើញភាពថោកទាប និងថ្លៃថ្លាជាងគ្នា ដោយអំណាចនៃធម៌ទាំងនោះ ក៏ឆ្លើយបដិសេធនោះឯង ៕

**អដ្ឋកថាពុទ្ធកថា ចប់**

# អភិធម្មបិដក

## សព្វទិសាកថា

[ ៤១៥ ] ព្រះពុទ្ធទាំងឡាយ ស្ថិតនៅសព្វទិសឬ ។ អើ ។ ព្រះពុទ្ធស្ថិតនៅក្នុងទិសខាងកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពុទ្ធស្ថិតនៅក្នុងទិសខាងកើតឬ ។ អើ ។ ព្រះមានព្រះភាគអង្គនោះ មានព្រះនាមដូចម្ដេច មានជាតិដូចម្ដេច មានគោត្រដូចម្ដេច មាតាបិតារបស់ព្រះមានព្រះភាគអង្គនោះ មាននាមដូចម្ដេច គូនៃសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ មាននាមដូចម្ដេច ឧបដ្ឋាករបស់ព្រះមានព្រះភាគអង្គនោះ មាននាមដូចម្ដេច ទ្រទ្រង់ចីវរយ៉ាងណា ទ្រទ្រង់បាត្រយ៉ាងណា ( គង់នៅ ) ក្នុងស្រុកឬនិគម ក្នុងនគរ ឬដែន ឬក៏ជនបទណា ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពុទ្ធស្ថិតនៅក្នុងទិសខាងត្បូង ។បេ។ ក្នុងទិសខាងលិច ។បេ។ ក្នុងទិសខាងជើង ។បេ។ ក្នុងទិសខាងក្រោមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពុទ្ធ ស្ថិតនៅក្នុងទិសខាងក្រោមឬ ។ អើ ។ ព្រះមានព្រះភាគអង្គនោះ មានព្រះនាមដូចម្ដេច ។បេ។ ( គង់នៅ ) ក្នុងជនបទណា ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពុទ្ធ ស្ថិតនៅក្នុងទិសខាងលើឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពុទ្ធ ស្ថិតនៅក្នុងទិសខាងលើឬ ។ អើ ។ ព្រះពុទ្ធស្ថិតនៅក្នុងចាតុម្មហារាជិកា ។បេ។ ស្ថិតនៅក្នុងតាវត្តិង្ស ស្ថិតនៅក្នុងយាមៈ ស្ថិតនៅក្នុងតុសិត ស្ថិតនៅក្នុងនិម្មានរតី ស្ថិតនៅក្នុងបរនិម្មិតវសវត្តី ។បេ។ ស្ថិតនៅក្នុងព្រហ្មលោកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

សព្វទិសាកថា ចប់

# អដ្ឋកថា

## សត្តទិសាកថា

[ ៤១៥ ] ឥឡូវនេះ នឹងពណ៌នាអំពីព្រះពុទ្ធទាំងឡាយ ស្ថិតនៅក្នុងទិសទាំងពួងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា ព្រះពុទ្ធទាំងឡាយ ស្ថិតនៅក្នុងទិសទាំងពួង ព្រោះញុំាងការដឹង ដែលកំណត់យកឯង របស់ខ្លួនឲ្យកើតឡើងថា លោកធាតុសន្និវាសដោយជុំវិញ គឺក្នុងទិសទាំង ៤ ក្នុងទិសខាងក្រោម និងក្នុងទិសខាងលើ ព្រះពុទ្ធទាំងឡាយ ស្ថិតនៅក្នុងលោកធាតុទាំងអស់ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បរវាទី ត្រូវសួរថា **បុរត្ថិមាយ** ក៏ឆ្លើយបដិសេធ ព្រោះសំដៅយកព្រះសក្យមុនី ។ ត្រូវសួរទៀត ក៏ឆ្លើយទទួល ព្រោះសំដៅយកព្រះពុទ្ធដែលតាំងនៅក្នុងលោកធាតុដទៃ ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ បទថា **កិន្នាមោ សោ ភគវា** ជាដើម សកវាទីពោលហើយ ដើម្បីចោទសួរថា បើអ្នកមិនជ្រាប ចូរអ្នកពោលដល់ព្រះពុទ្ធអង្គនោះ ដោយអំណាចនៃព្រះនាមជាដើម ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីទាំងពួង ដោយឧបាយនេះ ៕

**អដ្ឋកថាសត្តទិសាកថា ចប់**

# អភិធម្មបិដក

## ធម្មកថា

[ ៤១៦ ] ពួកធម៌ទាំងអស់ ជានិយតៈឬ ។ អើ ។ ( ពួកធម៌ទាំងអស់ ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( ពួកធម៌ទាំងអស់ ) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ គំនរ ជាអនិយតៈ មិនមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងគំនរ ជាអនិយតៈ មានដែរឬ ។ អើ ។ ប្រសិនបើ គំនរ ជាអនិយតៈ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌ទាំងអស់ ជានិយតៈទេ ។

[ ៤១៧ ] ពួកធម៌ទាំងអស់ ជានិយតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គំនរ ៣ យ៉ាង គឺគំនរ ជាមិច្ឆត្តនិយតៈ ១ គំនរ ជាសម្មត្តនិយតៈ ១ គំនរ ជាអនិយតៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គំនរ ៣ យ៉ាង គឺគំនរ ជាមិច្ឆត្តនិយតៈ ១ គំនរ ជាសម្មត្តនិយតៈ ១ គំនរ ជាអនិយតៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌ទាំងអស់ ជាអនិយតៈទេ ។

[ ៤១៨ ] រូប ជានិយតៈ ដោយអត្ថថា វិនាសឬ ។ អើ ។ ( រូប ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( រូប ) ជាសម្មត្ត-និយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ជានិយតៈ ដោយអត្ថថា ដឹងច្បាស់ឬ ។ អើ ។ ( វិញ្ញាណ ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

( វិញ្ញាណ ) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៩ ] បុគ្គលមិនគួរនិយាយថា រូប ជានិយតៈ ដោយអត្ថថា វិនាស ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ជានិយតៈ ដោយអត្ថថា ដឹងច្បាស់ទេឬ ។ អើ ។ រូបក៏មាន វេទនាក៏មាន សញ្ញាក៏មាន សង្ខារទាំងឡាយក៏មាន វិញ្ញាណក៏មាន វេទនា សញ្ញា សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ រូបក៏មាន វេទនាក៏មាន សញ្ញាក៏មាន សង្ខារទាំងឡាយក៏មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ព្រោះហេតុនោះ រូប ជានិយតៈ ដោយអត្ថថា វិនាស វេទនា ។បេ។ សញ្ញា សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ ជានិយតៈ ដោយអត្ថថា ដឹងច្បាស់ ។

**ធម្មកថា ចប់**

# អដ្ឋកថា

## ធម្មកថា

[ ៤១៦ ] ឥឡូវនេះ នឹងពណ៌នាអំពីធម៌ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះថា ព្រោះធម៌ទាំងឡាយ មានរូបជាដើម ជានិយតៈ ព្រោះសភាពនៃរូបជាដើម រមែងមិនលះនូវសភាវៈនោះ ព្រោះហេតុនោះ ទើបធម៌ទាំងពួង ជានិយតៈ ដូច្នេះ ពាក្យសួររបស់សកវាទីថា **សព្វេ ធម្មា** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **មិច្ឆត្តនិយតា** ជាដើម ដើម្បីចោទសួរបរវាទីថា បើធម៌ទាំងឡាយ មានរូបជាដើមនោះ គប្បីជានិយតៈ គឺគប្បីជាមិច្ឆត្តនិយតៈ ឬគប្បីជាសម្មត្តនិយតៈសោត ឈ្មោះថា និយាមដទៃក្រៅអំពីនេះ មិនមាន ដូច្នេះ ។ ក្នុងបញ្ហានោះ ពាក្យបដិសេធ និងពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ៤១៨ ] បទថា **រូបំ រូបដ្ឋេន** ជាដើម សកវាទីសួរ ដោយអំណាចនៃអត្ថដែលជាហេតុឲ្យពោលថា ជានិយតៈ ។ ក្នុងសេចក្ដីនេះ លោកអធិប្បាយថា បុគ្គលគប្បីពោលដោយបំណងថា រូប ឈ្មោះថា ជានិយតៈ ដោយអត្ថថា ជារូប ព្រោះហេតុនោះ ទើបរូបជារូបប៉ុណ្ណោះ មិនមែនជាសភាវធម៌ មានវេទនាជាដើម បុគ្គលណាម្នាក់ មិនគប្បីពោលដោយប្រការដទៃក្រៅអំពីនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានរូបដទៃ ក្រៅអំពីអត្ថថា ជារូប

ពិតហើយ សភាពនៃរូប មានរូបជាអត្ថផង សភាវៈនៃរូប ជារូបនោះឯងផង មិនមែនជាធម៌ដទៃក្រៅអំពីរូប តែវោហារនេះ រមែងមានដើម្បីឲ្យដឹងដល់ការផ្សេងគ្នារបស់រូប និងធម៌ទាំងឡាយ មានវេទនាជាដើម ដូច្នេះ ។ ព្រោះហេតុនោះ ទើបរូប ជាវត្ថុដែលសកវាទីពោលថា **រូបំ រូបដ្ឋេន និយតំ** ដូច្នេះ ពោលហើយថា ជានិយតៈ ដូច្នេះ ឈ្មោះថា ជានិយតៈ គប្បីជាមិច្ឆត្តនិយតៈ ឬជាសម្មត្តនិយតៈ និយាមដទៃ ក្រៅអំពីនិយតៈនេះ រមែងមិនមាន កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបបរវាទីឆ្លើយទទួល ព្រោះអំណាចក្នុងវាទនៃអត្ថ ។ ពិតហើយ ក្នុងបទថា **រូបំ រូបដ្ឋេន និយតំ** នេះ លោកអធិប្បាយថា រូបក៏ជារូបប៉ុណ្ណោះ មិនជាសភាវធម៌ មានវេទនាជាដើម ។ ព្រោះហេតុនោះ ទើបលោកឆ្លើយទទួល ។

ម្យ៉ាងទៀត ភាពដែលរូបនោះ ជានិយតៈ ដោយប្រការដទៃចាកប្រការដែលពោលមកនេះ មិនមាន ព្រោះហេតុនោះ ទើបសកវាទីពោលពាក្យថា **មិច្ឆត្តនិយតំ** ជាដើមដដែលទៀត ដើម្បីនឹងសួរដោយន័យនោះឯង ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ។

[ ៤១៩ ] លទ្ធិថា **តេន ហិ រូបំ** ដូច្នេះ រមែងតាំងទុកមិនបានឡើយ ព្រោះឲ្យតាំងទុកហើយ ដោយមិនមែនឧបាយ ដូច្នេះ ។ល។

**អដ្ឋកថាធម្មកថា ចប់**

# អភិធម្មបិដក

## កម្មកថា

[ ៤២០ ] ពួកកម្មទាំងអស់ ជានិយតៈឬ ។ អើ ។ ( ពួកកម្មទាំងអស់ ) ជាមិច្ឆត្តនិយតៈឬ ។ អើ ។ ( ពួកកម្មទាំងអស់ ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( ពួកកម្មទាំងអស់ ) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ គំនរ ជាអនិយតៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងគំនរ ជាអនិយតៈ មានដែរឬ ។ អើ ។ ប្រសិនបើ គំនរ ជាអនិយតៈ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកកម្មទាំងអស់ ជានិយតៈទេ ។

[ ៤២១ ] ពួកកម្មទាំងអស់ ជានិយតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា គំនរ មាន ៣ យ៉ាង គឺគំនរជាមិច្ឆត្តនិយតៈ ១ គំនរជាសម្មត្តនិយតៈ ១ គំនរជាអនិយតៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា គំនរ មាន ៣ យ៉ាង គឺគំនរជាមិច្ឆត្តនិយតៈ ១ គំនរជាសម្មត្តនិយតៈ ១ គំនរជាអនិយតៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកកម្មទាំងអស់ ជានិយតៈទេ ។

[ ៤២២ ] ទិដ្ឋធម្មវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងបច្ចុប្បន្នឬ ។ អើ ។ ( ទិដ្ឋធម្មវេទនិយកម្ម ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( ទិដ្ឋធម្មវេទនិយកម្ម ) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ឧបបជ្ជវេទនិយកម្ម ។បេ។ អបរា-

បរិយាវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងជាតិជាលំដាប់តទៅឬ ។ អើ ។ ( អបរាបរិយាវេទនិយកម្ម ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( អបរាបរិយាវេទនិយកម្ម ) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៣ ] បុគ្គលមិនគួរនិយាយថា ទិដ្ឋធម្មវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងបច្ចុប្បន្ន ឧបបជ្ជវេទនិយកម្ម ។បេ។ អបរាបរិយាវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងជាតិជាលំដាប់តទៅឬ ។ អើ ។ ទិដ្ឋធម្មវេទនិយកម្ម ជាឧបបជ្ជវេទនិយៈក៏មាន ជាអបរាបរិយាវេទនិយៈក៏មាន ។បេ។ ឧបបជ្ជវេទនិយកម្ម ជាទិដ្ឋធម្មវេទនិយៈក៏មាន ជាអបរាបរិយាវេទនិយៈក៏មាន ។បេ។ អបរាបរិយាវេទនិយកម្ម ជាទិដ្ឋធម្មវេទនិយៈក៏មាន ជាឧបបជ្ជវេទនិយៈក៏មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ទិដ្ឋធម្មវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងបច្ចុប្បន្ន ឧបបជ្ជវេទនិយកម្ម ។បេ។ អបរាបរិយាវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងជាតិជាលំដាប់តទៅ ។

កម្មកថា ចប់

ឯកវីសតិមវគ្គ ចប់

## ឧទ្ទាននៃវគ្គនោះ គឺ

និយាយអំពីសាសនា ដែលបុគ្គលធ្វើជាថ្មី បុគ្គលណាមួយ ធ្វើសាសនានៃតថាគតជាថ្មីមាន បុគ្គលបានដើម្បីធ្វើសាសនានៃតថាគតជាថ្មីវិញ ១ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ប្រកបដោយធាតុបី ១ ការដល់នូវព្រះអរហត្ត ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មាន ១ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី មាន ១ ការៈនៃព្រះពុទ្ធទាំងឡាយ ជាកទាប និងថ្លៃថ្លាជាងព្រះពុទ្ធទាំងឡាយ មាន ១ ព្រះពុទ្ធទាំងឡាយ ស្ថិតនៅសព្វទិស ១ ពួកធម៌ទាំងអស់ ជានិយតៈ ១ ពួកកម្មទាំងអស់ ជានិយតៈ ១ ។

# អដ្ឋកថា

## កម្មកថា

[ ៤២០ ] ឥឡូវនេះ នឹងពណ៌នាអំពីកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះឯងថា ព្រោះឋានៈនៃទិដ្ឋធម្ម-វេទនីយៈជាដើម ជានិយតៈ ដោយអត្ថថា ជាទិដ្ឋធម្មវេទនីយៈជាដើម ព្រោះហេតុនោះ ទើបកម្មទាំងពួង ជានិយតៈ ដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ៤២០ ] ក្នុងបទថា **ទិដ្ឋធម្មវេទនីយដ្ឋេន និយតំ** នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី សំដៅយកសេចក្ដីនេះថា ទិដ្ឋធម្មវេទនីយកម្ម ជាកម្មដែលគប្បីទទួលក្នុងភពបច្ចុប្បន្ននេះប៉ុណ្ណោះ បើទិដ្ឋធម្មវេទនីយកម្មនេះ អាចឲ្យផលក្នុងភពបច្ចុប្បន្នបាន ក៏រមែងឲ្យផល បើមិនអាចសោត ឈ្មោះថា ជាអហោសិកម្ម ដូច្នេះ ។ ម្យ៉ាងទៀត ទិដ្ឋធម្មវេទនីយកម្មនេះ រមែងជានិយតៈ ដោយអំណាចនៃមិច្ឆត្តនិយាម និងសម្មត្តនិយាម ។ គប្បីជ្រាបពាក្យដ៏សេស ដោយន័យដែលពោលហើយខាងដើមនោះឯង ។៚

**អដ្ឋកថាកម្មកថា ចប់**

**វគ្គទី ២១ ចប់**

# អភិធម្មបិដក

## បរិនិព្វានកថា

[ ៤២៤ ] បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មានដែរឬ ។ អើ ។ បរិនិព្វាន ព្រោះមិនលះបង់សក្កាយទិដ្ឋិ ។បេ។ ព្រោះមិនលះបង់អនោត្តប្បៈតិចតួច មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៥ ] បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មានដែរឬ ។ អើ ។ ព្រះអរហន្តប្រកបដោយរាគៈ ។បេ។ ប្រកបដោយកិលេសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត មិនមានរាគៈ ។បេ។ មិនមានកិលេសទេឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្តមិនមានរាគៈ ។បេ។ មិនមានកិលេសទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មានទេ ។

[ ៤២៦ ] បុគ្គលមិនគួរនិយាយថា បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មានទេឬ ។ អើ ។ ព្រះអរហន្ត ដឹងពុទ្ធវិស័យទាំងអស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មាន ។

បរិនិព្វានកថា ចប់

# អដ្ឋកថា

## បរិនិព្វានកថា

[ ៤២៤ ] ឥឡូវនេះ នឹងពណ៌នាអំពីបរិនិព្វាន ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រោះព្រះអរហន្ត មានសញ្ញោជនៈដែលមិនទាន់លះ ក្នុងវិស័យរបស់ព្រះសព្វញ្ញុពុទ្ធ រមែងបរិនិព្វានបាន ហេតុនោះ ទើបបរិនិព្វានដោយមិនលះបង់សញ្ញោជនៈណាមួយ មាន ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យដូចពោលហើយខាងដើមនោះឯង ៕

**អដ្ឋកថាបរិនិព្វានកថា ចប់**

# អភិធម្មបិដក

## កុសលចិត្តកថា

[ ៤២៧ ] ព្រះអរហន្ត មានកុសលចិត្តហើយ បរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត តាក់តែងបុញ្ញាភិសង្ខារ តាក់តែងអនេញ្ជាភិសង្ខារ ធ្វើកម្មប្រព្រឹត្តទៅដើម្បីគតិ ធ្វើកម្មប្រព្រឹត្តទៅដើម្បីភព ធ្វើកម្មប្រព្រឹត្តទៅដើម្បីភាពជាធំ ធ្វើកម្មប្រព្រឹត្តទៅដើម្បីភាពជាអធិបតី ធ្វើកម្មប្រព្រឹត្តទៅដើម្បីមានភោគៈច្រើន ធ្វើកម្មប្រព្រឹត្តទៅដើម្បីមានបរិវារច្រើន ធ្វើកម្មប្រព្រឹត្តទៅដើម្បីលម្អដ៏លើសក្នុងទេវលោក ធ្វើកម្មប្រព្រឹត្តទៅដើម្បីលម្អដ៏លើសក្នុងមនុស្សលោក ទើបបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៨ ] ព្រះអរហន្ត មានកុសលចិត្តហើយ បរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត កាលសន្សំ កាលមិនសន្សំ កាលលះបង់ កាលប្រកាន់ កាលកកាយចេញ កាលកៀរគរ កាលកម្ចាត់ចេញ ។បេ។ កាលប្រមូលមក ទើបបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ លុះមិនសន្សំហើយ ស្ថិតនៅឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ លុះមិនសន្សំហើយ ស្ថិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត មានកុសលចិត្តហើយ បរិនិព្វានទេ ។ ក្រែងព្រះអរហន្ត មិនលះបង់ មិនប្រកាន់ លុះលះបង់ហើយ ស្ថិតនៅ មិនកកាយចេញ មិនកៀរគរ លុះមិនកកាយចេញហើយ ស្ថិតនៅ ក្រែងព្រះអរហន្ត មិនកម្ចាត់ចេញ មិនប្រមូលមក លុះកម្ចាត់ចេញហើយ

ស្ថិតនៅឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មិនកម្ចាត់ចេញ មិនប្រមូលមក លុះកម្ចាត់ចេញហើយ ស្ថិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត មានកុសលចិត្តហើយ បរិនិព្វានទេ ។

[ ៤២៩ ] បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត មានកុសលចិត្តហើយ បរិនិព្វានទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មានសតិតម្កល់នៅស៊ប់ មានស្មារតី ដឹងខ្លួន ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មានសតិតម្កល់នៅស៊ប់ មានស្មារតី ដឹងខ្លួន ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត មានកុសលចិត្តហើយ បរិនិព្វាន ។

កុសលចិត្តកថា ចប់

# អដ្ឋកថា

## កុសលចិត្តកថា

[ ៤២៧ ] ឥឡូវនេះ នឹងពណ៌នាអំពីចិត្តជាកុសលដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រោះព្រះអរហន្តជាអ្នកមានសតិបរិបូណ៌ សូម្បីតែកាលបរិនិព្វាន ក៏មានសតិសម្បជញ្ញៈនោះឯង រមែងបរិនិព្វាន ព្រោះហេតុនោះ ទើបព្រះអរហន្ត មានចិត្តជាកុសលបរិនិព្វាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ព្រោះឈ្មោះថា កុសលចិត្ត រមែងមានដោយអំណាចការសាងសន្សំនូវបុញ្ញាភិសង្ខារ ព្រោះហេតុនោះ ទើបសកវាទីពោលពាក្យថា **អរហតោ បុញ្ញាភិសង្ខារំ** ជាដើម ដើម្បីសួរបរវាទីដោយអត្ថនោះ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ គប្បីជ្រាបតាមព្រះបាលីនោះឯង ។

[ ៤២៨ ] បទថា **សតោ សម្បជានោ** នេះ បរវាទីសម្តែងការស្លាប់របស់បុគ្គលដែលមិនវង្វេង ដោយអំណាចនៃសតិសម្បជញ្ញៈ ដែលជាកិរិយាក្នុងខណៈនៃជវន មិនមែនដើម្បីសម្តែងចិត្តដែលជាកុសល ព្រោះហេតុនោះ ទើបពាក្យនេះ មិនមែនជាគោលអាង ដូច្នេះ ។ល។

**អដ្ឋកថាកុសលចិត្តកថា ចប់**

# អភិធម្មបិដក

## អានេញ្ជកថា

[ ៤៣០ ] ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិ-និព្វានឬ ។ អើ ។ ក្រែងព្រះអរហន្ត ស្ថិតនៅក្នុងបកតិចិត្ត ( ចិត្តជាប្រក្រតី ) ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត ស្ថិតនៅក្នុងបកតិចិត្ត ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានទេ ។

[ ៤៣១ ] ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត ស្ថិតនៅក្នុងចិត្តដែលសម្រេចដោយកិរិយា ហើយបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត ស្ថិតនៅក្នុងវិបាកចិត្ត ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត ស្ថិតនៅក្នុងវិបាកចិត្ត ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានទេ ។

[ ៤៣២ ] ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត ស្ថិតនៅក្នុងចិត្តជាកិរិយា និងអព្យាក្រឹត ហើយបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត ស្ថិតនៅក្នុងចិត្តជាវិបាក និងអព្យាក្រឹត ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត ស្ថិតនៅក្នុងចិត្តជាវិបាក និងអព្យាក្រឹត ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ

ហើយបរិនិព្វានទេ ។

[ ៤៣៣ ] ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិ-និព្វានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈាន ហើយបរិនិព្វានក្នុងលំដាប់ ( អំពីចតុត្ថជ្ឈាននោះ ) ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈាន ហើយបរិនិព្វានក្នុងលំដាប់ ( អំពីចតុត្ថជ្ឈាននោះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានទេ ។

## អានេញ្ជកថា ចប់

# អដ្ឋកថា

## អានេញ្ជកថា

[ ៤៣០ ] ឥឡូវនេះ នឹងពណ៌នាអំពីសេចក្តីមិនញាប់ញ័រដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះថា ព្រះអរហន្ត តាំងនៅក្នុងភាពជាអ្នកមិនញាប់ញ័រហើយ ទើបបរិនិព្វាន ព្រោះកំណត់យកថា ព្រះមានព្រះភាគ តាំងនៅក្នុងចតុត្ថជ្ឈានហើយ ទើបបរិនិព្វាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **បកតិចិត្តេ** បានដល់ ភវង្គចិត្ត ។ ពិតហើយ សត្វដែលមានសញ្ញាទាំងពួង តាំងនៅក្នុងភវង្គចិត្តហើយ រមែងធ្វើកាលកិរិយា ដោយចុតិចិត្តដែលមានភវង្គជាទីបំផុត ។ ដោយប្រការយ៉ាងនេះ ទើបសកវាទីពោលនឹងបរវាទីនោះយ៉ាងនេះ ដើម្បីចោទសួរដោយអត្ថនេះ ។ ក្នុងបញ្ហានោះ សូម្បីបកតិចិត្តរបស់ព្រះអរហន្ត ក្នុងចតុវោការភព ជាធម្មជាតមិនញាប់ញ័រក៏ពិត តែបញ្ហានេះ លោកក៏លើកឡើងសម្តែងហើយ ដោយបញ្ចវោការភព ព្រោះហេតុនោះ ទើបសកវាទីពោលពាក្យថា **នោ ច វត រេ វត្តព្វេ** ជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាអានេញ្ជកថា ចប់**

# អភិធម្មបិដក

## ធម្មាភិសមយកថា

[ ៤៣៤ ] ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកនៅក្នុងគតិ មានដែរឬ ។ អើ ។ ការសម្ដែងធម៌ ការស្ដាប់ធម៌ ការសាកសួរធម៌ ការជេញជោលសួរ ការសមាទានសីល ភាវៈនៃការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ភាវៈនៃការដឹងប្រមាណ ក្នុងភោជន ការប្រកបរឿយៗ ក្នុងកិរិយាភ្ញាក់រឭកអស់រាត្រីខាងដើម និងរាត្រីខាងចុងនៃសត្វ ដែលដេកនៅក្នុងគតិ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការសម្ដែងធម៌ ។បេ។ ការប្រកបរឿយៗ ក្នុងកិរិយាភ្ញាក់រឭក អស់រាត្រីខាងដើម និងរាត្រីខាងចុងនៃសត្វ ដែលដេកនៅក្នុងគតិ មិនមានទេឬ ។ អើ ។ ប្រសិនបើ ការសម្ដែងធម៌ ការស្ដាប់ធម៌ ។បេ។ ការប្រកបរឿយៗ ក្នុងកិរិយាភ្ញាក់រឭក អស់រាត្រីខាងដើម និងរាត្រីខាងចុងនៃសត្វ ដែលដេកនៅក្នុងគតិ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកនៅក្នុងគតិ មានទេ ។

[ ៤៣៥ ] ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកនៅក្នុងគតិ មានដែរឬ ។ អើ ។ គ្រែងបច្ច័យទាំងឡាយ ២ គឺសំឡេងគឺកកង អំពីសម្នាក់នៃបុគ្គលដទៃ ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ព្រោះអាស្រ័យសម្មាទិដ្ឋិ មាន

ឬ ។ អើ ។ ប្រសិនបើ បច្ច័យទាំងឡាយ ២ គឺសំឡេងគឹកកង អំពីសម្នាក់នៃបុគ្គលដទៃ ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ព្រោះអាស្រ័យសម្មាទិដ្ឋិ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកនៅក្នុងគភ៌ មានទេ ។

[ ៤៣៦ ] ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកនៅក្នុងគភ៌ មានដែរឬ ។ អើ ។ ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកលក់ មានសេចក្តីប្រមាទ មានសតិភ្លេច មិនដឹងខ្លួន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ធម្មាភិសមយកថា ចប់

# អដ្ឋកថា

## ធម្មាភិសមយកថា

[ ៤៣៤ ] ឥឡូវនេះ នឹងពណ៌នាអំពីការត្រាស់ដឹងធម៌ដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះថា ការត្រាស់ដឹងធម៌ មានដល់សត្វដែលដេកក្នុងគភ៌ ព្រោះកាន់យកព្រះសោតាបន្នក្នុងភពអតីត ដែលនៅក្នុងផ្ទៃមាតា ហើយចេញចាកផ្ទៃ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **អត្ថិ គព្ភសេយ្យាយ ធម្មទេសនា** ជាដើម ដើម្បីចោទសួរបរវាទីនេះថា បើការត្រាស់ដឹងធម៌ មានក្នុងផ្ទៃនោះសោត ក៏គប្បីមានការសម្ដែងធម៌ជាដើមក្នុងទីនោះ ដែលជាហេតុនៃការត្រាស់ដឹងធម៌ ដូច្នេះ ។

[ ៤៣៦ ] បទថា **សុត្តស្ស** ជាដើម សកវាទីពោលសំដៅយកភវង្គវារ ។ ពិតហើយ ភវង្គរបស់សត្វដែលនៅក្នុងគភ៌ រមែងប្រព្រឹត្តទៅច្រើន ព្រោះហេតុនោះ សត្វដែលដេកលក់ហើយ ឈ្មោះថា ដេកលក់ហើយ ព្រោះមិនមានការប្រព្រឹត្តទៅនៃពេលវេលាដែលគប្បីធ្វើកិច្ច ឈ្មោះថា ប្រមាទហើយ ព្រោះមិនមានភាវនានុយោគ ឈ្មោះថា ជាអ្នកមិនមានសតិ មិនមានសម្បជញ្ញៈ ព្រោះមិនមានសតិ និងសម្បជញ្ញៈ ដែលជាគ្រឿងកំណត់កម្មដ្ឋាន កាលបើយ៉ាងនេះ ការត្រាស់ដឹងធម៌របស់សត្វបែបនេះ នឹងមានអំពីណា ។ល។

**អដ្ឋកថាធម្មាភិសមយកថា ចប់**

# អភិធម្មបិដក

## តិកេស្បាបិកថា

[ ៤៣៧ ] ការដល់នូវព្រះអរហត្តនៃសត្វ ដែលដេកនៅក្នុងគភ៌ មានដែរឬ ។ អើ ។ ការដល់នូវព្រះអរហត្តនៃសត្វ ដែលដេកលក់ មានសេចក្តីប្រមាទ មានសតិភ្លេច មិនដឹងខ្លួន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការត្រាស់ដឹងធម៌នៃសត្វ ដែលកំពុងយល់សប្តិ មានដែរឬ ។ អើ ។ ការត្រាស់ដឹងធម៌នៃសត្វ ដែលដេកលក់ មានសេចក្តីប្រមាទ មានសតិភ្លេច មិនដឹងខ្លួន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការដល់នូវព្រះអរហត្តនៃសត្វ ដែលកំពុងយល់សប្តិ មានដែរឬ ។ អើ ។ ការដល់នូវព្រះអរហន្តនៃសត្វ ដែលដេកលក់ មានសេចក្តីប្រមាទ មានសតិភ្លេច មិនដឹងខ្លួន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

តិកេស្បាបិកថា ចប់

# អដ្ឋកថា

## តិស្សោបិកថា

[ ៤៣៧ ] ឥឡូវនេះ នឹងពណ៌នាអំពីកថាទាំង ៣ ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះឯងថា ការសម្រេចអរហត្ត មានដល់សត្វដែលនៅក្នុងផ្ទៃ ព្រោះកាន់យកការសម្រេចអរហត្តរបស់ព្រះសោតាបន្ន ដែលកើតហើយមិនយូរ និងព្រោះកាន់យកគភ៌តាំងនៅ ៧ ឆ្នាំ របស់នាងសុប្បវាសាឧបាសិកា និងក្នុងរឿងនេះថា ការត្រាស់ដឹងធម៌ រមែងមានដល់សត្វដែលនៅក្នុងផ្ទៃ និងការសម្រេចអរហត្ត មានក្នុងផ្ទៃនោះ ព្រោះកាន់យកការទៅបាន ក្នុងអាកាសជាដើម ក្នុងការយល់សប្តិ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងរឿងមុននោះឯង ៕

**អដ្ឋកថាតិស្សោបិកថា ចប់**

# អភិធម្មបិដក

## អព្យាកតកថា

[ ៤៣៨ ] ចិត្តទាំងអស់របស់បុគ្គលដែលកំពុងយល់សប្តិ ជាអព្យាក្រឹត ឬ ។ អើ ។ បុគ្គលគប្បីសម្លាប់សត្វ ដោយការយល់សប្តិដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលសម្លាប់សត្វដោយការយល់សប្តិដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់របស់បុគ្គល ដែលកំពុងយល់សប្តិ ជាអព្យាក្រឹតទេ ។

[ ៤៣៩ ] បុគ្គលគប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ដោយការយល់-សប្តិ ។បេ។ គប្បីពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យទ្រគោះ ពោលពាក្យរោយរាយ គប្បីកាត់នូវទី-ត ប្លន់អ្នកស្រុក ប្លន់យកទ្រព្យផ្ទះមួយ ឈរចាំដណ្តើមយកទ្រព្យគេក្បែរផ្លូវ លួចប្រពន្ធបុគ្គលដទៃ ធ្វើអំពើសម្លាប់អ្នកស្រុក ធ្វើអំពើសម្លាប់អ្នកនិគម សេពមេថុនធម្ម ដោយការយល់សប្តិ អសុចិរបស់បុគ្គល ដែលកំពុងយល់សប្តិ គប្បីហូរចេញ និងបុគ្គលគប្បីឲ្យទាន គប្បីឲ្យចីវរ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជ-បរិក្ខារ ឲ្យគ្រឿងស៊ី ឲ្យគ្រឿងបរិភោគ ឲ្យទឹកផឹក ថ្វាយបង្គំចេតិយ បំពាក់ផ្កាកម្រង បំពាក់គ្រឿងក្រអូប លាបនូវគ្រឿងលាបលើចេតិយ ។បេ។ ធ្វើអភិទក្សិណាចេតិយ ដោយការយល់សប្តិ មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលគប្បីធ្វើអភិទក្សិណាចេតិយ ដោយការយល់សប្តិបាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់របស់បុគ្គល ដែលកំពុងយល់សប្តិ ជា

អព្យាក្រឹតទេ ។

[ ៤៤០ ] បុគ្គលមិនគួរនិយាយថា ចិត្តទាំងអស់របស់បុគ្គល ដែលកំពុងយល់សប្តិ ជាអព្យាក្រឹតទេឬ ។ អើ ។ ក្រែងចិត្តរបស់បុគ្គល ដែលកំពុងយល់សប្តិ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាអព្វោហារិយៈឬ ។ អើ ។ ប្រសិនបើ ចិត្តរបស់បុគ្គលដែលកំពុងយល់សប្តិ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាអព្វោហារិយៈ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ចិត្តទាំងអស់របស់បុគ្គល ដែលកំពុងយល់សប្តិ ជាអព្យាក្រឹត ។

អព្យាកតកថា ចប់

# អដ្ឋកថា

## អព្យាកតកថា

[ ៤៣៨ ] ឥឡូវនេះ នឹងពណ៌នាអំពីអព្យាក្រឹតដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈពួកខ្លះនោះឯងថា ចិត្តរបស់បុគ្គលដែលយល់សប្តិទាំងពួង ជាអព្យាកត ព្រោះព្រះបាលី ( វិនយបិដក តេរសកណ្ឌ ) ថា ម្នាលភិក្ខុទាំងឡាយ ចេតនានោះ មានមែន ប៉ុន្តែ ចេតនានោះ ជាអព្វោហារិកា ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនោះឯង ។

[ ៤៤០ ] បទថា **សុបិនគតស្ស ចិត្តំ អព្វោហារិកំ** សកវាទី ពោលសំដៅដល់អាបត្តិ ។ ពិតហើយ អកុសលចិត្តរបស់អ្នកយល់សប្តិ ប្រព្រឹត្តទៅដោយអំណាចនៃបាណាតិបាតជាដើមក៏ពិត តែការប្រទូស្តសត្វ មិនមាន ព្រោះហេតុនេះ ទើបព្រះមានព្រះភាគ មិនអាចបញ្ញត្តិអាបត្តិ ក្នុងសេចក្តីនេះបាន ដោយហេតុនេះ ទើបចិត្តនោះ ជាអព្វោហារិកៈ មិនមែនអព្យាកត ដូច្នេះ ។០៚

**អដ្ឋកថាអព្យាកតកថា ចប់**

# អភិធម្មបិដក

## អាសេវនប្បច្ចយគាថា

[ ៤៤១ ] ភាពនៃអាសេវនប្បច្ច័យទីមួយ មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាណាតិបាត បុគ្គលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅព្រម ដើម្បីនរក ប្រព្រឹត្តទៅព្រម ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅព្រម ដើម្បីប្រេតវិស័យ ផលនៃបាណាតិបាត ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជាមនុស្ស រមែងប្រព្រឹត្តទៅព្រម ដើម្បីអាយុខ្លី ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ភាពនៃអាសេវនប្បច្ច័យទីមួយ មាន ។

[ ៤៤២ ] ភាពនៃអាសេវនប្បច្ច័យទីមួយ មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អទិន្នាទាន បុគ្គលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅព្រម ដើម្បីនរក ប្រព្រឹត្តទៅព្រម ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅព្រម ដើម្បីប្រេតវិស័យ ផលនៃអទិន្នាទាន ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជាមនុស្ស រមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីវិនាសនៃភោគៈ ។បេ។ ផលនៃកាមេសុមិច្ឆាចារ ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជាមនុស្ស រមែងប្រព្រឹត្តទៅព្រម ដើម្បីសត្រូវ និងពៀរ ។បេ។ ផលនៃមុសាវាទ ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជាមនុស្ស

រមែងប្រព្រឹត្តទៅព្រម ដើម្បីការពោលបង្កាច់ដោយពាក្យមិនពិត ។បេ។ ផល នៃបិសុណាវាចា ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជា មនុស្ស រមែងប្រព្រឹត្តទៅព្រម ដើម្បីបែកចាកមិត្ត ។បេ។ ផលនៃផរុសវាចា ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជាមនុស្ស រមែង ប្រព្រឹត្តទៅព្រម ដើម្បីសំឡេងមិនជាទីគាប់ចិត្ត ។បេ។ ផលនៃសម្ផប្បលាបៈ ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើតជាមនុស្ស រមែង ប្រព្រឹត្តទៅព្រម ដើម្បីវាចាដែលគេមិនគប្បីកាន់យក ។បេ។ ម្នាលភិក្ខុទាំង ឡាយ ការផឹកនូវសុរា និងមេរ័យ បុគ្គលសេពហើយ ។បេ។ ផលនៃការផឹក នូវសុរា និងមេរ័យ ដែលស្រាលស្តើងជាងគេទាំងអស់ របស់សត្វដែលកើត ជាមនុស្ស រមែងប្រព្រឹត្តទៅព្រម ដើម្បីឆ្កួត ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ ព្រោះហេតុនោះ ភាពនៃអាសេវនប្បច្ច័យទីមួយ មាន ។

[ ៤៤៣ ] ភាពនៃអាសេវនប្បច្ច័យទីមួយ មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ បុគ្គល សេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅព្រម ដើម្បីនរក ប្រព្រឹត្តទៅព្រម ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅព្រម ដើម្បីប្រេតវិស័យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ភាពនៃអាសេវ-នប្បច្ច័យទីមួយ មាន ។

[ ៤៤៤ ] ភាពនៃអាសេវនប្បច្ច័យទីមួយ មិនមានទេឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិច្ឆាសង្កប្ប ។បេ។

មិច្ឆាសមាធិ បុគ្គលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ។បេ។ ប្រព្រឹត្តទៅព្រម ដើម្បីប្រេតវិស័យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ភាពនៃអាសេវនប្បច្ច័យនីមួយ មាន ។

[ ៤៤៥ ] ភាពនៃអាសេវនប្បច្ច័យនីមួយ មិនមានទេឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិ បុគ្គលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចុះស៊ប់ កាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ភាពនៃអាសេវនប្បច្ច័យនីមួយ មាន ។

[ ៤៤៦ ] ភាពនៃអាសេវនប្បច្ច័យនីមួយ មិនមានទេឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្ប បុគ្គលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិ បុគ្គលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌ចុះស៊ប់ កាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ភាពនៃអាសេវនប្បច្ច័យនីមួយ មាន ។

## អាសេវនប្បច្ចយតាកថា ចប់

# អដ្ឋកថា

## អាសេវនប្បច្ចយកថា

[ ៤៤១ ] ឥឡូវនេះ នឹងពណ៌នាអំពីភាពជាអាសេវនប្បច្ច័យដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយ ឧត្តរាបថកៈពួកខ្លះនោះឯងថា ព្រោះធម៌ទាំងពួងជាខណៈ បុគ្គលណាម្នាក់ តាំងនៅសូម្បីមួយដួរខណៈហើយ ឈ្មោះថា សេពនូវអាសេវនប្បច្ច័យ មិនមាន ព្រោះហេតុនោះ ភាពជាអាសេវនប្បច្ច័យ មិនមានដោយពិត ម្យ៉ាងទៀត ធម៌ណាមួយ ដែលកើតឡើងហើយដោយភាពជាអាសេវនប្បច្ច័យ រមែងមិនមាន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទី ដើម្បីឲ្យបរវាទីនោះព្រមទទួល ដោយអំណាចនៃព្រះសូត្រនោះឯង ទើបនាំព្រះសូត្រមកថា ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាណាតិបាត បុគ្គលសេពហើយ ... មានក្នុងព្រះសូត្រឬ ដូច្នេះជាដើម ។ ព្រះសូត្រទាំងពួងនោះ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាអាសេវនប្បច្ចយកថា ចប់**

# អភិធម្មបិដក

## ខណិកកថា

[ ៤៤៧ ] ពួកធម៌ទាំងអស់ ប្រកបដោយខណៈនៃចិត្តមួយឬ ។ អើ ។ មហាប្រឹថពី ស្ថិតនៅ មហាសមុទ្ទ ស្ថិតនៅ ស្តេចនៃភ្នំឈ្មោះសិនេរុ ស្ថិតនៅ ទឹក ស្ថិតនៅ ភ្លើង ស្ថិតនៅ ខ្យល់ ស្ថិតនៅ ពួកស្មៅ និងឈើតូចឈើធំ ស្ថិតនៅក្នុងចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៨ ] ពួកធម៌ទាំងអស់ ប្រកបដោយខណៈនៃចិត្តមួយឬ ។ អើ ។ ចក្ខាយតនៈ កើតជាមួយនឹងចក្ខុវិញ្ញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខាយតនៈ កើតជាមួយនឹងចក្ខុវិញ្ញាណឬ ។ អើ ។ ក្រែងព្រះសារីបុត្តមានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោ ចក្ខុកើតខាងក្នុង មិនបែកធ្លាយមែន តែរូបខាងក្រៅ ក៏មិនមកកាន់វង្វង់នៃចក្ខុ ការពិចារណាដ៏សមគួរដល់ចក្ខុ និងរូបនោះ ក៏មិនមាន ការកើតប្រាកដនៃវិញ្ញាណ ភាពដ៏សមគួរដល់ចក្ខុ និងរូបនោះ មិនទាន់មាននៅឡើយទេ ម្នាលអាវុសោ ចក្ខុខាងក្នុង មិនបែកធ្លាយផង រូបខាងក្រៅ មកកាន់វង្វង់នៃចក្ខុផងមែន តែការពិចារណាដ៏សមគួរដល់ចក្ខុ និងរូបនោះ ក៏មិនមាន ការកើតប្រាកដនៃវិញ្ញាណ ភាពដ៏សមគួរដល់ចក្ខុ និងរូបនោះ មិនទាន់មាននៅឡើយទេ ម្នាលអាវុសោ លុះតែចក្ខុខាងក្នុង ក៏មិនបែកធ្លាយ រូបខាងក្រៅ ក៏មកកាន់វង្វង់នៃចក្ខុ ទាំងការពិចារណាដ៏សមគួរដល់ចក្ខុ និងរូបនោះក៏មាន ការកើតប្រាកដនៃវិញ្ញាណ ភាពដ៏សមគគួរដល់ចក្ខុ និងរូបនោះ ទើបមានយ៉ាងនេះឯង ពាក្យដូច្នេះ មាន

ក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ចក្ខាយតនៈ កើតជាមួយនឹងចក្ខុវិញ្ញាណទេ ។

[ ៤៤៩ ] សោតាយតនៈ ។បេ។ ឃានាយតនៈ ។បេ។ ជិវ្ហាយតនៈ ។បេ។ កាយាយតនៈ កើតជាមួយនឹងកាយវិញ្ញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយាយតនៈ កើតជាមួយនឹងកាយវិញ្ញាណឬ ។ អើ ។ ក្រែងព្រះសារីបុត្តមានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោ កាយខាងក្នុង មិនបែកធ្លាយមែន តែផោដ្ឋព្វៈខាងក្រៅ ក៏មិនមកកាន់វង្វង់ ( ការពិចារណា ដ៏សមគួរដល់កាយ និងផោដ្ឋព្វៈនោះ ) ក៏មិនមាន ។បេ។ ម្នាលអាវុសោ កាយខាងក្នុងមិនបែកធ្លាយផង ផោដ្ឋព្វៈខាងក្រៅ មកកាន់វង្វង់នៃចក្ខុផងមែន ( តែការពិចារណា ដ៏សមគួរដល់កាយ និងផោដ្ឋព្វៈនោះ ) ក៏មិនមាន ។បេ។ ម្នាលអាវុសោ លុះតែកាយខាងក្នុង ក៏មិនបែកធ្លាយ ផោដ្ឋព្វៈខាងក្រៅ មកកាន់វង្វង់នៃចក្ខុ ការពិចារណា ដ៏សមគួរដល់កាយ និងផោដ្ឋព្វៈនោះក៏មាន ការកើតប្រាកដនៃវិញ្ញាណ ភាពដ៏សមគួរដល់កាយ និងផោដ្ឋព្វៈនោះ ទើបមានយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា កាយាយតនៈ កើតជាមួយនឹងកាយវិញ្ញាណទេ ។

[ ៤៥០ ] បុគ្គលមិនគួរនិយាយថា ពួកធម៌ទាំងអស់ ប្រកបដោយខណៈនៃចិត្តមួយទេឬ ។ អើ ។ ពួកធម៌ទាំងអស់ទៀង ទៀងទាត់ ស្ថិតស្ថេរ មាន

សភាពមិនប្រែប្រួលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ពួកធម៌ទាំងអស់ ប្រកបដោយខណៈនៃចិត្តមួយ ។

ខណិកកថា ចប់

ពាវីសតិមវគ្គ ចប់

## ឧទ្ទាននៃពាវីសតិមវគ្គនោះ គឺ

និយាយអំពីបរិនិព្វាន ព្រោះកិរិយាមិនលះបង់នូវសញ្ញោជនៈតិចតួចមាន ១ ព្រះអរហន្តមានកុសលចិត្តបរិនិព្វាន ១ ព្រះអរហន្ត ស្ថិតនៅក្នុងសេចក្តីមិនញាប់ញ័របរិនិព្វាន ១ ការត្រាស់ដឹងធម៌នៃសត្វដេកនៅក្នុងគភ៌មាន ១ ការដល់ព្រះអរហត្តនៃសត្វដេកនៅក្នុងគភ៌មាន ការត្រាស់ដឹងធម៌នៃសត្វកំពុងយល់-សប្តិមាន ការដល់ព្រះអរហត្តនៃសត្វកំពុងយល់សប្តិមាន ១ ចិត្តទាំងអស់របស់បុគ្គលកំពុងយល់សប្តិជាអព្យាក្រឹត ១ ភាពនៃអាសេវនប្បច្ច័យមិនមាន ១ ពួកធម៌ទាំងអស់ ប្រកបដោយខណៈនៃចិត្តមួយ ១ ។

# អដ្ឋកថា

## ខណិកកថា

[ ៤៤៧ ] ឥឡូវនេះ នឹងពណ៌នាអំពីពួកធម៌ទាំងអស់ ប្រកបដោយខណៈនៃចិត្តមួយដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយអបរសេលិយៈទាំងឡាយថា ព្រោះសង្ខតធម៌ទាំងឡាយមិនទៀង ព្រោះហេតុនោះ ទើបសង្ខតធម៌ទាំងនោះ ប្រព្រឹត្តទៅមួយជួរខណៈចិត្តមួយប៉ុណ្ណោះ ។ កាលភាពមិនទៀងមាន ធម៌ណាមួយបែកធ្លាយទៅរហ័ស ធម៌ណាមួយបែកធ្លាយទៅយឺតយូរ ហេតុនោះ អ្វីជានិយាមក្នុងទីនេះ ពាក្យសួររបស់សកវាទីថា **ឯកចិត្តក្ខណិកា** ដូច្នេះ សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបទទាំងឡាយមានបទថា **ចិត្តេ មហាបថវី** ជាដើម បរវាទី កាលមិនឃើញការតាំងនៅបែបនៃមហាប្រឹថពីជាដើមនោះ ទើបឆ្លើយបដិសេធ ។

[ ៤៤៨ ] បទថា **ចក្ខាយតនំ** ជាដើម សកវាទីសួរថា បើធម៌ទាំងពួងគប្បីមានមួយជួរនៃខណចិត្តសោត អាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម កើតឡើងហើយ គប្បីរលត់ទៅព្រមជាមួយវិញ្ញាណទាំងឡាយ មាន

ចក្ខុវិញ្ញាណជាដើម បរវាទីឆ្លើយបដិសេធ សំដៅយកការកើតឡើងនៃវិញ្ញាណរបស់សត្វដែលកើតក្នុងផ្ទៃមាតា ។ ឆ្លើយទទួល សំដៅយកការប្រព្រឹត្តទៅ គឺបវត្តិកាល ដោយអំណាចនៃលទ្ធិនោះឯង ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ៤៥០ ] បទថា **តេន ហិ ឯកចិត្តក្ខណិកា** មានអធិប្បាយថា បរវាទីពោលអាងហេតុផល តាមគាប់ចិត្តរបស់ខ្លួនថា ធម៌ទាំងឡាយ ឈ្មោះថា ជារបស់ទៀង មិនមាន ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ប្រព្រឹត្តទៅក្នុងខណៈនៃចិត្តមួយ ដូច្នេះ ពាក្យនោះ មិនដូចពាក្យដែលបរវាទីនោះពោលហើយនោះទេ ៕

**អដ្ឋកថាឯកចិត្តក្ខណិកកថា ចប់**

**វគ្គទី ២២ ចប់**

# អភិធម្មបិដក

## ឯកាធិប្បាយកថា

[ ៤៥១ ] បុគ្គលគប្បីសេពមេថុនធម្ម ដោយសេចក្តីប្រាថ្នាតែមួយឬ ។ អើ ។ បុគ្គលមិនមែនជាសមណៈ មិនមែនជាភិក្ខុ មានឫសដាច់ហើយ ត្រូវបារាជិកដោយសេចក្តីប្រាថ្នាតែមួយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥២ ] បុគ្គលគប្បីសេពមេថុនធម្ម ដោយសេចក្តីប្រាថ្នាតែមួយឬ ។ អើ ។ បុគ្គលគប្បីសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យទ្រគោះ និយាយរោយរាយ កាត់ទី-តនៃផ្ទះ ប្លន់ពួកអ្នកស្រុក ប្លន់យកទ្រព្យផ្ទះមួយ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ លួចប្រពន្ធអ្នកដទៃ ធ្វើជាអ្នកសម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ដោយសេចក្តីប្រាថ្នាតែមួយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ឯកាធិប្បាយកថា ចប់

# អដ្ឋកថា

## ឯកាធិប្បាយកថា

[ ៤៥១ ] ឥឡូវនេះ នឹងពណ៌នាអំពីសេចក្ដីប្រាថ្នាតែមួយដូចតទៅ ក្នុងរឿងនោះ ឈ្មោះថា សេចក្ដីប្រាថ្នាតែមួយ ដោយសេចក្ដីករុណា ដែលជាសេចក្ដីប្រាថ្នាតែមួយ ឬឈ្មោះថា បុគ្គលមានសេចក្ដីប្រាថ្នាតែមួយ ព្រោះអត្ថថា មានសេចក្ដីប្រាថ្នាតែមួយ ដោយអំណាចធ្វើនូវការបូជាព្រះពុទ្ធ ជាមួយស្រីជាដើម ហើយតាំងសេចក្ដីប្រាថ្នាថា យើងទាំងពីរ នឹងជាមនុស្ស តែមួយ ក្នុងសង្សារវដ្ដ ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់ និកាយអន្ធកៈ និងនិកាយវេតុល្លកៈទាំងឡាយថា ជនពីរនាក់ មានសេចក្ដី ប្រាថ្នាតែមួយបែបនេះ ជនទាំងពីរនោះ គប្បីសេពមេថុនធម្មបាន ពាក្យសួរ របស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់ បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនោះឯង ។

# អភិធម្មបិដក

## អរហន្តវណ្ណកថា

[ ៤៥៣ ] ពួកអមនុស្សសេពមេថុនធម្ម ដោយក្លែងភេទជាព្រះអរហន្តដែរឬ ។ អើ ។ ពួកអមនុស្សសម្លាប់សត្វ ដោយក្លែងភេទជាព្រះអរហន្តដែរឬ ។បេ។ កាន់យកទ្រព្យដែលគេមិនបានឲ្យ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យទ្រគោះ និយាយពាក្យរោយរាយ កាត់ទី-តនៃផ្ទះ ប្លន់ពួកអ្នកស្រុក ប្លន់យកទ្រព្យផ្ទះមួយ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ លួចយកប្រពន្ធបុគ្គលដទៃ ធ្វើអំពើសម្លាប់អ្នកស្រុក ។បេ។ ធ្វើអំពើសម្លាប់អ្នកនិគម ដោយក្លែងភេទជាព្រះអរហន្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អរហន្តវណ្ណកថា ចប់

# អដ្ឋកថា

## អរហន្តវណ្ណកថា

[ ៤៥៣ ] ឥឡូវនេះ នឹងពណ៌នាអំពីភេទរបស់ព្រះអរហន្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា អមនុស្សទាំងឡាយសេពមេថុនធម្ម ដោយភេទរបស់ព្រះអរហន្តបាន ព្រោះឃើញកិច្ចបាបដែលសម្បូរដោយឥរិយាបថ សម្បូរដោយកិរិយា ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាអរហន្តវណ្ណកថា ចប់**

# អភិធម្មបិដក

## ឥស្សរិយកាមការិកាកថា

[ ៤៥៤ ] ព្រះពោធិសត្វទៅកាន់អសុរកាយ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វទៅកាន់នរក ទៅកាន់សញ្ជីវនរក ទៅកាន់កាលសុត្តនរក ទៅកាន់តាបននរក ទៅកាន់បតាបននរក ទៅកាន់សង្ឃាដកនរក ទៅកាន់រោរុវនរក ។បេ។ ទៅកាន់អវីចិនរក ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៥ ] ព្រះពោធិសត្វ ទៅកាន់អសុរកាយ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វទៅកាន់អសុរកាយ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ ប្រសិនបើ ព្រះពោធិសត្វទៅកាន់អសុរកាយ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មិនមានក្នុងព្រះសូត្រទេ ម្នាលដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វទៅកាន់អសុរកាយ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសទេ ។

[ ៤៥៦ ] ព្រះពោធិសត្វ យាងចុះកាន់គព្ភសេយ្យា ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វ គប្បីចូលទៅកើតក្នុងនរក គប្បីចូលទៅកើតក្នុងកំណើតតិរច្ឆាន ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៧ ] ព្រះពោធិសត្វ យាងចុះកាន់គព្ភសេយ្យា ព្រោះហេតុធ្វើ

សេចក្ដីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វ មានឫទ្ធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពោធិសត្វ មានឫទ្ធិឬ ។ អើ ។ ព្រះពោធិសត្វ មានឆន្ទិទ្ធិបាទចម្រើនហើយ ។បេ។ មានវីរិយិទ្ធិបាទ ។បេ។ មានចិត្តិទ្ធិបាទ ។បេ។ មានវីមំសិទ្ធិបាទ ចម្រើនហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពោធិសត្វយាងចុះកាន់គព្ភសេយ្យា ព្រោះហេតុធ្វើសេចក្ដីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វយាងចុះកាន់គព្ភសេយ្យា ព្រោះហេតុធ្វើសេចក្ដីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មិនមានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ ប្រសិនបើ ព្រះពោធិសត្វ យាងចុះកាន់គព្ភសេយ្យា ព្រោះហេតុធ្វើសេចក្ដីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មិនមានក្នុងព្រះសូត្រទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វ យាងចុះកាន់គព្ភសេយ្យា ព្រោះហេតុធ្វើសេចក្ដីប្រាថ្នា ឥស្សរិយយសទេ ។

[ ៤៥៨ ] ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយា ព្រោះហេតុធ្វើសេចក្ដីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វយល់ថា លោកទៀង ដូច្នេះ យល់ថា លោកមិនទៀង ដូច្នេះ យល់ថា លោកមានទីបំផុត ដូច្នេះ ។បេ។ ថា លោកមិនមានទីបំផុត ដូច្នេះ ថាជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះ ថាជីវិតដទៃ សរីរៈដទៃ ដូច្នេះ ថាសត្វស្លាប់ហើយ កើតទៀត ដូច្នេះ ថាសត្វស្លាប់ហើយ មិនកើតទៀត ដូច្នេះ ថាសត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះ ។បេ។ ថាស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះ ព្រោះហេតុធ្វើសេចក្ដីប្រាថ្នា ឥស្សរិយយសដែរឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥៩ ] ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយា ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយា ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ ប្រសិនបើ ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយា ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មិនមានក្នុងព្រះសូត្រទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយា ព្រោះហេតុធ្វើសេចក្តីប្រាថ្នា ឥស្សរិយយសទេ ។

[ ៦៦០ ] ព្រះពោធិសត្វ បានធ្វើអំពើមិនញ៉ាំងសត្វឲ្យក្តៅ ឧទ្ទិសចំពោះគ្រូដទៃ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វយល់ថា លោកទៀង ដូច្នេះ ។បេ។ យល់ថា សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះពោធិសត្វ ឧទ្ទិសចំពោះគ្រូដទៃ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយសឬ ។ អើ ។ ព្រះពោធិសត្វ ឧទ្ទិសចំពោះគ្រូដទៃ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ ប្រសិនបើ ព្រះពោធិសត្វ ឧទ្ទិសចំពោះគ្រូដទៃ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាឥស្សរិយយស ពាក្យដូច្នេះ មិនមានក្នុងព្រះសូត្រទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វ ឧទ្ទិសចំពោះគ្រូដទៃ ព្រោះហេតុធ្វើសេចក្តីប្រាថ្នា ឥស្សរិយយសទេ ។

# អដ្ឋកថា

## ឥស្សរិយការកការិកាកថា

[ ៤៥៤ ] ឥឡូវនេះ នឹងពណ៌នាអំពី ព្រោះហេតុធ្វើសេចក្តីប្រាថ្នា ឥស្សរិយយសដូចតទៅ

ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ថា ព្រះពោធិសត្វ រមែងទៅកាន់វិនិបាត ព្រះពោធិសត្វ ឈមចុះកាន់ភាពជាអ្នកដេកក្នុងផ្ទៃ ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយា ព្រះពោធិសត្វ បានធ្វើនូវសេចក្តីព្យាយាមដទៃទៀត ព្រះពោធិសត្វឧទ្ទិសសាស្ដាដទៃ ព្រោះធ្វើនូវការប្រាថ្នាក្នុងភាពជាធំ ព្រោះសំដៅយកឆទ្ទន្តជាតកជាដើម ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងកថាដំបូង មានអត្ថងាយយល់ហើយ ។

[ ៤៥៧ ] ក្នុងកថាទី ២ បទថា **ឥទ្ធិយា** សកវាទីសួរថា បើព្រះពោធិសត្វគប្បីដល់ហេតុ ដែលធ្វើសេចក្តីប្រាថ្នាក្នុងភាពជាធំសោត ក៏គប្បីដល់ដោយឫទ្ធិ មិនមែនដោយអំណាចកម្ម ដូច្នេះ ។ ក្នុងបញ្ហាដំបូង បរវាទី

សំដៅយកឫទ្ធិដែលសម្រេចដោយភាវនា ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាទី ២ សំដៅយកបុញ្ញឫទ្ធិ ទើបឆ្លើយទទួល ។

[ ៤៥៨ ] ក្នុងកថាទី ៣ សកវាទីពោលពាក្យថា **សស្សតោ លោកោ** ជាដើម ដើម្បីសួរថា ឈ្មោះថា ព្រោះធ្វើសេចក្តីប្រាថ្នាក្នុងភាពជាធំ ការធ្វើទុក្ករកិរិយា ដែលព្រះពោធិសត្វធ្វើដោយមិច្ឆាទិដ្ឋិ បើព្រះអង្គគប្បីធ្វើទុក្ករ-កិរិយានោះសោត ក៏គប្បីកាន់យកនូវទិដ្ឋិទាំងឡាយ មានសស្សតទិដ្ឋិជាដើម ។ ក្នុងកថាទី ៤ ក៏ន័យនេះឯង ដូច្នេះ ៕

**អដ្ឋកថាឥស្សរិយកាមការិកាកថា ចប់**

# អភិធម្មបិដក

## រាគប្បដិរូបកាទិកថា

[ ៤៦១ ] មិនមែនរាគៈ ប្រៀបដោយរាគៈ មានដែរឬ ។ អើ ។ មិនមែនផស្សៈ ប្រៀបដោយផស្សៈ មាន មិនមែនវេទនា ប្រៀបដោយវេទនា មាន មិនមែនសញ្ញា ប្រៀបដោយសញ្ញា មាន មិនមែនចេតនា ប្រៀបដោយចេតនា មាន មិនមែនចិត្ត ប្រៀបដោយចិត្ត មាន មិនមែនសទ្ធា ប្រៀបដោយសទ្ធា មាន មិនមែនវិរិយៈ ប្រៀបដោយវិរិយៈ មាន មិនមែនសតិ ប្រៀបដោយសតិ មាន មិនមែនសមាធិ ប្រៀបដោយសមាធិ មាន មិនមែនបញ្ញា ប្រៀបដោយបញ្ញា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មិនមែនទោសៈ ប្រៀបដោយទោសៈ មាន មិនមែនមោហៈ ប្រៀបដោយមោហៈ មាន មិនមែនកិលេស ប្រៀបដោយកិលេស មានដែរឬ ។ អើ ។ មិនមែនផស្សៈ ប្រៀបដោយផស្សៈ មាន ។បេ។ មិនមែនបញ្ញា ប្រៀបដោយបញ្ញា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

*រាគប្បដិរូបកាទិកថា ចប់*

# អដ្ឋកថា
## រាគប្បដិរូបកាទិកថា

[ ៤៦១ ] ឥឡូវនេះ នឹងពណ៌នាអំពីធម៌ ដែលមិនមែនរាគៈ ប្រៀបដោយរាគៈជាដើមដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ធម៌ដែលមិនមែនរាគៈ ជារាគៈប្រៀបធៀប មាន ព្រោះសំដៅយកមេត្តាករុណា និងមុទិតាធម៌ជាដើម ជាធម៌ដែលមិនមែនទោសៈជាទោសៈ ប្រហែលនឹងទោសៈ មាន ព្រោះសំដៅយកឥស្សា មច្ឆរិយៈ និងកុក្កុច្ចៈ ជាធម៌ដែលមិនមែនមោហៈ ប្រហែលគ្នានឹងមោហៈ មាន ព្រោះសំដៅយកហសិតុប្បាទ ។ ជាធម៌ដែលមិនមែនកិលេស ប្រហែលគ្នានឹងកិលេស មាន ព្រោះសំដៅយកការតិះដៀល ដែលបុគ្គលប្រដៅក្រទាំងឡាយ ការអនុគ្រោះភិក្ខុ ដែលមានសីលជាទីស្រឡាញ់ទាំងឡាយ ពាក្យតិះដៀលបាបការសរសើរសេចក្ដីល្អ វាទៈដែលគ្រោតគ្រាតរបស់ព្រះបិលិន្ទវច្ឆៈ និងព្រះតម្រាស់ថា បុគ្គលបរិភោគទឹកមាត់ មោឃបុរសរបស់ព្រះមានព្រះភាគ ពាក្យសួររបស់សកវាទី ក្នុងកថាទាំងពួង សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយ

ទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីក៏ពោលពាក្យថា **អត្ថិ ន ផស្សោ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា ព្រោះ ឈ្មោះថា ធម៌ទាំងឡាយ មានផស្សៈជាដើម របស់ធម៌ប្រៀបដោយផស្សៈជាដើម រមែងមិនមាន ព្រោះហេតុនោះ សូម្បីរាគធម៌ជាដើម របស់ធម៌ប្រៀបដោយរាគៈជាដើម ក៏រមែងមិនមាន ដូច្នេះ បរវាទីឆ្លើយបដិសេធ ព្រោះការមិនមាននៃសភាវធម៌ទាំងនោះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាភាគបញ្ចិវូបកាធិកថា ចប់

# អភិធម្មបិដក

## អបរិនិប្ផន្នកថា

[ ៤៦២ ] រូប មិនសម្រេចទេឬ ។ អើ ។ រូប មិនមែនជាអនិច្ចធម៌ មិនមែនជាសង្ខតធម៌ មិនមែនជាបដិច្ចសមុប្បន្នធម៌ មិនមែនជាខយធម៌ មិនមែនជាវយធម៌ មិនមែនជាវិរាគធម៌ មិនមែនជានិរោធធម៌ មិនមែនជាវិបរិណាមធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបជាអនិច្ចធម៌ ជាសង្ខតធម៌ ជាបដិច្ចសមុប្បន្នធម៌ ជាខយធម៌ ជាវយធម៌ ជាវិរាគធម៌ ជានិរោធធម៌ ជាវិបរិណាមធម៌ឬ ។ អើ ។ ប្រសិនបើ រូប ជាអនិច្ចធម៌ ជាសង្ខតធម៌ ។បេ។ ជាវិបរិណាមធម៌ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប មិនសម្រេចទេ ។

[ ៤៦៣ ] ទុក្ខ សម្រេចហើយឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ រូប មិនទៀងឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ រូប មិនទៀង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទុក្ខ សម្រេចហើយទេ ។

[ ៤៦៤ ] វេទនា ។បេ។ សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ ។បេ។ ចក្ខាយតនៈ ។បេ។ ធម្មាយតនៈ ។បេ។ ចក្ខុធាតុ ។បេ។ ធម្មធាតុ ។បេ។ ចក្ខុន្ទ្រិយ ។បេ។

[ ៤៦៥ ] អញ្ញាតាវិន្ទ្រិយ មិនសម្រេចទេឬ ។ អើ ។ អញ្ញាតាវិន្ទ្រិយ

មិនមែនជាអនិច្ចធម៌ ។បេ។ មិនមែនជាវិបរិណាមធម៌ទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ ក្រែងអញ្ញាតាវិន្ទ្រិយ ជាអនិច្ចធម៌ ជាសង្ខតធម៌ ។បេ។ ជាវិបរិណាមធម៌ឬ ។ អើ ។ ប្រសិនបើ អញ្ញាតាវិន្ទ្រិយ ជាអនិច្ចធម៌ ជាសង្ខតធម៌ ជាបដិច្ចសមុប្បន្នធម៌ ជាខយធម៌ ជាវយធម៌ ជាវិរាគធម៌ ជានិរោធធម៌ ជាវិបរិណាមធម៌ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អញ្ញាតាវិន្ទ្រិយ មិនសម្រេចទេ ។

[ ៤៦៦ ] ទុក្ខ សម្រេចហើយឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ អញ្ញាតាវិន្ទ្រិយ មិនទៀងទេឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ អញ្ញាតាវិន្ទ្រិយ មិនទៀង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទុក្ខ សម្រេចហើយទេ ។

អបរិនិប្ផន្នកថា ចប់

តេវីសតិមវគ្គ ចប់

## ឧទ្ទាននៃតេវីសតិមវគ្គនោះ គឺ

និយាយអំពីបុគ្គលគប្បីសេពមេថុនធម្ម ដោយសេចក្តីប្រាថ្នាតែមួយ ១ ពួកអមនុស្សសេពមេថុនធម្ម ដោយក្លែងភេទជាព្រះអរហន្ត ១ ព្រះពោធិសត្វទៅកាន់អសុរកាយ យាងចុះកាន់គព្ភសេយ្យា បានធ្វើទុក្ករកិរិយា បានធ្វើអំពើមិនញុំាងបុគ្គលឲ្យក្តៅ ឧទ្ទិសចំពោះគ្រូដទៃ ព្រោះហេតុធ្វើសេចក្តីប្រាថ្នាដើម្បីឥស្សរិយយស ១ មិនមែនរាគៈ ប្រៀបដោយរាគៈ មាន មិនមែនទោសៈ ប្រៀបដោយទោសៈ មាន មិនមែនមោហៈ ប្រៀបដោយមោហៈ មាន មិនមែនកិលេសប្រៀបដោយកិលេស មាន ១ រូប មិនសម្រេច អញ្ញាតាវិន្ទ្រិយ មិនសម្រេច ១ ។ សាសនាបុគ្គលធ្វើជាថ្មី ការរលត់ទុក្ខ សេចក្តីអធិប្បាយតែមួយ រូប មិនសម្រេច អញ្ញាតាវិន្ទ្រិយ មិនសម្រេចហើយ ។ មហានិយាម អនុស័យទាំងឡាយ ការសង្កត់សង្កិន ការញុំាញីនូវបរប្បវាទ មានខុទ្ទកជាគម្រប់ ៥ ការភ្ជីដែលតាំងនៅមាំក្នុងមូលនៃសូត្រ ក្នុងគម្ពីរកថាវត្ថុ ជាលទ្ធិនៃព្រះសាស្តា ។

**កថាវត្ថុប្បករណៈ មានភាណវារ ៣៥ ចប់**

# អដ្ឋកថា

## អបរិនិប្ផន្នកថា

[ ៤៦២ ] ឥឡូវនេះ នឹងពណ៌នាធម៌មិនសម្រេចដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយពួកខ្លះ និងនិកាយហេតុវាទថា ទុក្ខប៉ុណ្ណោះ ជាបរិនិប្ផន្ន គឺជាធម៌ដែលសម្រេចហើយ ឬកើតឡើងហើយ ចំណែកធម៌ដ៏សេស គឺខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ ជាអបរិនិប្ផន្ន គឺធម៌មិនសម្រេចហើយ មិនកើតឡើងហើយ ព្រោះអាស្រ័យពុទ្ធវចនៈ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

សេចក្តីទុក្ខ រមែងកើតឡើង សេចក្តីទុក្ខ រមែងស្ថិតនៅផង

វិនាសទៅផង វៀរចាកសេចក្តីទុក្ខ ឥតមានធម៌ដទៃកើតឡើង

វៀរចាកសេចក្តីទុក្ខ ឥតមានធម៌ដទៃរលត់ទេ ដូច្នេះ ។

ពាក្យសួររបស់សកវាទីថា **រូបំ អបរិនិប្ផន្នំ** សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **រូបំ ន អនិច្ចំ** ជាដើម ដើម្បីសួរបរវាទីថា បើរូបជាអបរិនិប្ផន្ន សោត រូបនោះ ក៏គប្បីមិនមែនជារបស់មិនទៀងជាដើម ។ បរវាទី កាលមិនឃើញរូបបែបនោះ ទើបឆ្លើយបដិសេធ ។

[ ៤៦៣ ] សកវាទីបដិសេធលទ្ធិមួយរបស់បរវាទីនោះ ដោយពាក្យថា **ននុ រូបំ អនិច្ចំ** ជាដើមហើយ កាលសួរបញ្ហាទី ២ ទើបពោលពាក្យថា **ទុក្ខញ្ញេវ បរិនិប្ផន្នំ** ដូច្នេះ ។ លំដាប់នោះ សកវាទី ដើម្បីបដិសេធលទ្ធិ

*របស់បរវាទីនោះទៀត ទើបសកវាទីពោលពាក្យថា* **ន យទនិច្ចំ** *ជាដើម ។*

*ក្នុងសេចក្តីនោះ មានអធិប្បាយថា សច្ចៈទី ១ ប៉ុណ្ណោះ ជាទុក្ខតែម្យ៉ាង ក៏មិនមែន ធម៌ណាមួយដែលមិនទៀង ធម៌នោះ ក៏ជាទុក្ខទាំងអស់ ទាំងរូបក៏ជារបស់មិនទៀង ព្រោះហេតុនោះ ទើបរូបនោះ ជាបរិនិប្ផន្ន ព្រោះហេតុនោះ អ្នកពោលពាក្យណាថា រូបជាអបរិនិប្ផន្ន ទើបអ្នកមិនគួរពោលពាក្យនោះថា ទុក្ខប៉ុណ្ណោះ ជាបរិនិប្ផន្ន ដូច្នេះ ។ ក្នុងការប្រកបក្នុងធម៌ទាំងឡាយ មានវេទនាជាមូលជាដើម ក៏ន័យនេះឯង ។ ម្យ៉ាងទៀត ក្នុងធម្មាយតនៈ និងធម្មធាតុទាំងឡាយ វៀរព្រះនិព្វានហើយ បណ្ឌិតគប្បីជ្រាបថា ធម៌ដ៏សេសទាំងអស់ ជាអនិច្ចំ ។ ឥន្ទ្រិយទាំងឡាយ ក៏ជាអនិច្ចំនោះឯង ។l៚*

**អដ្ឋកថាអបរិនិប្ផន្នកថា ចប់**

**វគ្គទី ២៣ ចប់**

**ខុទ្ទកអឌ្ឍបណ្ណាសក ចប់**

# និគមកថា

ដោយពាក្យ មានប្រមាណប៉ុណ្ណេះ ព្រះពុទ្ធឃោសាចារ្យ បានរួបរួមកថាទាំងពួង អំពីបណ្ណាសកទាំង ៤ និងវគ្គទាំង ៣ ប៉ុណ្ណោះ ហើយចែកជាប្រភេទចេញទៅ បានចំនួនក្រោម ៣០០ ។

ព្រះជិនស្រីសម្ពុទ្ធ ទ្រង់ជាអ្នកឈ្លាសក្នុងកថាមគ្គទាំងឡាយ ទ្រង់សម្ដែងហើយ នូវកថាវត្ថុប្បករណ៍ណា កិច្ចពណ៌នាអត្ថ នៃកថាវត្ថុប្បករណ៍នោះ សម្រេចហើយ ។

ខ្ញុំរចនាគម្ពីរនេះ មានប្រមាណ ១៣ ភាណវារ ដើម្បីការតាំងមាំនៃព្រះសទ្ធម្ម ដើម្បីជាបែបផែន ដូច្នេះឯង ។

កុសលណា ដែលខ្ញុំសម្រេចហើយ ដល់ព្រមហើយ មានដោយអំណាចនៃកុសលនោះ ចូរសត្វលោក គឺទេវតា និងមនុស្សទាំងឡាយ ទទួលរសនៃព្រះសទ្ធម្មរបស់ព្រះធម្មរាជានោះហោង ។៚

**អដ្ឋកថា កថាវត្ថុប្បករណ៍ ចប់ បរិបូណ៌ហោង**

# ក្បាលទី ៧២

# អភិធម្មបិដក បាលីប្រែ ~ ៨៥

## កថាវត្ថុ ទុតិយភាគ

### សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### សត្តមវគ្គ


| មាតិកា | លេខទំព័រ |
|---|---|
| អភិធម្មបិដក សង្គហិតកថា ...... ...... ...... ...... ...... | ២ |
| អដ្ឋកថាសង្គហិតកថា ...... ...... ...... ...... ...... | ៥ |
| អភិធម្មបិដក សម្បយុត្តកថា ...... ...... ...... ...... ...... | ៧ |
| អដ្ឋកថាសម្បយុត្តកថា ...... ...... ...... ...... ...... | ៩ |
| អភិធម្មបិដក ចេតសិកកថា ...... ...... ...... ...... ...... | ១១ |
| អដ្ឋកថាចេតសិកកថា ...... ...... ...... ...... ...... | ១៣ |
| អភិធម្មបិដក ទានកថា ...... ...... ...... ...... ...... | ១៤ |
| អដ្ឋកថាទានកថា ...... ...... ...... ...... ...... | ១៩ |
| អភិធម្មបិដក បរិភោគមយបុញ្ញកថា ...... ...... ...... ...... ...... | ២២ |
| អដ្ឋកថាបរិភោគមយបុញ្ញកថា ...... ...... ...... ...... ...... | ២៨ |
| អភិធម្មបិដក ឥតោទិន្នកថា ...... ...... ...... ...... ...... | ៣២ |
| អដ្ឋកថាឥតោទិន្នកថា ...... ...... ...... ...... ...... | ៣៦ |
| អភិធម្មបិដក បឋវីកម្មវិបាកោតិកថា ...... ...... ...... ...... ...... | ៣៨ |
| អដ្ឋកថាបឋវីកម្មវិបាកោតិកថា ...... ...... ...... ...... ...... | ៤៣ |
| អភិធម្មបិដក ជរាមរណំ វិបាកោតិកថា ...... ...... ...... ...... ...... | ៤៦ |
| អដ្ឋកថាជរាមរណំវិបាកោតិកថា ...... ...... ...... ...... ...... | ៤៩ |

អភិធម្មបិដក អរិយធម្មវិបាកកថា ...... ...... ...... ...... ...... ៥២
អដ្ឋកថាអរិយធម្មវិបាកកថា ...... ...... ...... ...... ...... ៥៥
អភិធម្មបិដក វិបាកវិបាកធម្មធម្មោតិកថា ...... ...... ...... ...... ...... ៥៧
អដ្ឋកថាវិបាកវិបាកធម្មធម្មោតិកថា ...... ...... ...... ...... ...... ៦០


## អដ្ឋមវគ្គ


អភិធម្មបិដក ឆគតិកថា ...... ...... ...... ...... ...... ៦៣
អដ្ឋកថាឆគតិកថា ...... ...... ...... ...... ...... ៦៥
អភិធម្មបិដក អន្តរាភវកថា ...... ...... ...... ...... ...... ៦៧
អដ្ឋកថាអន្តរាភវកថា ...... ...... ...... ...... ...... ៧៣
អភិធម្មបិដក កាមគុណកថា ...... ...... ...... ...... ...... ៧៧
អដ្ឋកថាកាមគុណកថា ...... ...... ...... ...... ...... ៨១
អភិធម្មបិដក កាមកថា ...... ...... ...... ...... ...... ៨៤
អដ្ឋកថាកាមកថា ...... ...... ...... ...... ...... ៨៦
អភិធម្មបិដក រូបធាតុកថា ...... ...... ...... ...... ...... ៨៧
អដ្ឋកថារូបធាតុកថា ...... ...... ...... ...... ...... ៨៩
អភិធម្មបិដក អរូបធាតុកថា ...... ...... ...... ...... ...... ៩០
អដ្ឋកថាអរូបធាតុកថា ...... ...... ...... ...... ...... ៩២
អភិធម្មបិដក រូបធាតុអាយតនកថា ...... ...... ...... ...... ...... ៩៣
អដ្ឋកថារូបធាតុយា អាយតនកថា ...... ...... ...... ...... ...... ៩៩
អភិធម្មបិដក អរូបរូបកថា ...... ...... ...... ...... ...... ១០១
អដ្ឋកថាអរូបេរូបកថា ...... ...... ...... ...... ...... ១០៤
អភិធម្មបិដក រូបំ កម្មន្តិកថា ...... ...... ...... ...... ...... ១០៥
អដ្ឋកថារូបំកម្មន្តិកថា ...... ...... ...... ...... ...... ១២២

អភិធម្មបិដក ជីវិតិន្ទ្រិយកថា ...... ...... ...... ...... ...... ១២៨
អដ្ឋកថាជីវិតិន្ទ្រិយកថា ...... ...... ...... ...... ...... ១២៩
អភិធម្មបិដក កម្មហេតុកថា ...... ...... ...... ...... ...... ១៣៣
អដ្ឋកថាកម្មហេតុកថា ...... ...... ...... ...... ...... ១៣៥

## នវមវគ្គ

អភិធម្មបិដក អានិសំសកថា ...... ...... ...... ...... ...... ១៣៦
អដ្ឋកថាអានិសំសទស្សាវីកថា ...... ...... ...... ...... ...... ១៣៨
អភិធម្មបិដក អមតារម្មណកថា ...... ...... ...... ...... ...... ១៤១
អដ្ឋកថាអមតារម្មណកថា ...... ...... ...... ...... ...... ១៤៦
អភិធម្មបិដក រូបសារម្មណន្តិកថា ...... ...... ...... ...... ...... ១៤៧
អដ្ឋកថារូបសារម្មណន្តិកថា ...... ...... ...... ...... ...... ១៤៩
អភិធម្មបិដក អនុសយអនារម្មណាតិកថា ...... ...... ...... ...... ...... ១៥០
អដ្ឋកថាអនុសយអនារម្មណាតិកថា ...... ...... ...... ...... ...... ១៥៤
អភិធម្មបិដក ញាណអនារម្មណន្តិកថា ...... ...... ...... ...... ...... ១៥៦
អដ្ឋកថាញាណអនារម្មណន្តិកថា ...... ...... ...... ...... ...... ១៥៨
អភិធម្មបិដក អតីតារម្មណកថា ...... ...... ...... ...... ...... ១៥៩
អភិធម្មបិដក អនាគតារម្មណកថា ...... ...... ...... ...... ...... ១៦០
អដ្ឋកថាអតីតានាគតារម្មណកថា ...... ...... ...... ...... ...... ១៦២
អភិធម្មបិដក វិតក្កានុបតិតកថា ...... ...... ...... ...... ...... ១៦៣
អដ្ឋកថាវិតក្កានុបតិតកថា ...... ...... ...... ...... ...... ១៦៥
អភិធម្មបិដក វិតក្កវិប្ផារសទ្ទកថា ...... ...... ...... ...... ...... ១៦៦
អដ្ឋកថាវិតក្កវិប្ផារសទ្ទកថា ...... ...... ...... ...... ...... ១៦៨
អភិធម្មបិដក នយថាចិត្តស្ស វាចាតិកថា ...... ...... ...... ...... ...... ១៧០

អដ្ឋកថានយថាចិត្តស្សវាចាតិកថា ...... ...... ...... ...... ...... ១៧៣
អភិធម្មបិដក នយថាចិត្តស្ស កាយកម្មន្តិកថា ...... ...... ...... ...... ...... ១៧៥
អដ្ឋកថានយថាចិត្តស្ស កាយកម្មន្តិកថា ...... ...... ...... ...... ...... ១៧៨
អភិធម្មបិដក អតីតានាគតប្បច្ចុប្បន្នកថា ...... ...... ...... ...... ...... ១៧៩
អដ្ឋកថាអតីតានាគតសមន្នាគតកថា ...... ...... ...... ...... ...... ១៨៣

## ឧសមវគ្គ

អភិធម្មបិដក និរោធកថា ...... ...... ...... ...... ...... ១៨៥
អដ្ឋកថានិរោធកថា ...... ...... ...... ...... ...... ១៨៧
អភិធម្មបិដក រូបមគ្គោតិកថា ...... ...... ...... ...... ...... ១៨៩
អដ្ឋកថារូបមគ្គោតិកថា ...... ...... ...... ...... ...... ១៩៣
អភិធម្មបិដក បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា...... ...... ...... ...... ...... ១៩៤
អដ្ឋកថាបញ្ចវិញ្ញាណសមង្គិស្ស មគ្គភាវនាកថា...... ...... ...... ...... ...... ១៩៧
អភិធម្មបិដក បញ្ចវិញ្ញាណា កុសលាបីតិកថា...... ...... ...... ...... ...... ២០២
អដ្ឋកថាបញ្ចវិញ្ញាណាកុសលាបីតិកថា ...... ...... ...... ...... ...... ២០៥
អភិធម្មបិដក បញ្ចវិញ្ញាណាសាភោគាតិកថា ...... ...... ...... ...... ...... ២០៦
អដ្ឋកថាបញ្ចវិញ្ញាណាសាភោគាតិកថា ...... ...... ...... ...... ...... ២០៩
អភិធម្មបិដក ទ្វិសីលសមន្នាគតោតិកថា ...... ...... ...... ...... ...... ២១០
អដ្ឋកថាទ្វិសីលសមន្នាគតោតិកថា ...... ...... ...... ...... ...... ២១៣
អភិធម្មបិដក សីលអចេតសិកន្តិកថា ...... ...... ...... ...... ...... ២១៥
អដ្ឋកថាសីលអចេតសិកន្តិកថា ...... ...... ...... ...... ...... ២១៩
អភិធម្មបិដក សីលនចិត្តានុបរិវត្តីតិកថា ...... ...... ...... ...... ...... ២២០
អដ្ឋកថាសីលនចិត្តានុបរិវត្តីតិកថា ...... ...... ...... ...... ...... ២២២
អភិធម្មបិដក សមាទានហេតុកកថា ...... ...... ...... ...... ...... ២២៣
អដ្ឋកថាសមាទានហេតុកកថា ...... ...... ...... ...... ...... ២២៥

អភិធម្មបិដក វិញ្ញត្តិសីលទ្ទិកថា ...... ...... ...... ...... ...... ២២៦
អដ្ឋកថាវិញ្ញត្តិសីលទ្ទិកថា ...... ...... ...... ...... ...... ២២៨
អភិធម្មបិដក អវិញ្ញត្តិទុស្សីល្យទ្ទិកថា ...... ...... ...... ...... ...... ២២៩
អដ្ឋកថាអវិញ្ញត្តិទុស្សីល្យទ្ទិកថា ...... ...... ...... ...... ...... ២៣៣

## បាលីប្រែ ~ ៨៦

## តតិយបណ្ណាសក

### ឯកាទសមវគ្គ

អភិធម្មបិដក តិស្សោបិ អនុសយកថា ...... ...... ...... ...... ...... ២៣៥
អដ្ឋកថាតិស្សោបិអនុសយកថា ...... ...... ...... ...... ...... ២៤២
អភិធម្មបិដក ញាណកថា ...... ...... ...... ...... ...... ២៤៣
អដ្ឋកថាញាណកថា ...... ...... ...... ...... ...... ២៤៥
អភិធម្មបិដក ញាណចិត្តវិប្បយុត្តទ្ទិកថា ...... ...... ...... ...... ...... ២៤៦
អដ្ឋកថាញាណចិត្តវិប្បយុត្តទ្ទិកថា ...... ...... ...... ...... ...... ២៤៨
អភិធម្មបិដក ឥទំ ទុក្ខន្តិកថា ...... ...... ...... ...... ...... ២៤៩
អដ្ឋកថា ឥទំ ទុក្ខន្តិកថា ...... ...... ...... ...... ...... ២៥២
អភិធម្មបិដក ឥទ្ធិពលកថា ...... ...... ...... ...... ...... ២៥៤
អដ្ឋកថាឥទ្ធិពលកថា ...... ...... ...... ...... ...... ២៥៨
អភិធម្មបិដក សមាធិកថា ...... ...... ...... ...... ...... ២៦១
អដ្ឋកថាសមាធិកថា ...... ...... ...... ...... ...... ២៦៣
អភិធម្មបិដក ធម្មដ្ឋិតតាកថា ...... ...... ...... ...... ...... ២៦៥
អដ្ឋកថាធម្មដ្ឋិតតាកថា ...... ...... ...... ...... ...... ២៦៦
អភិធម្មបិដក អនិច្ចតាកថា ...... ...... ...... ...... ...... ២៦៧
អដ្ឋកថាអនិច្ចតាកថា ...... ...... ...... ...... ...... ២៧០

## ធ្មានសមវគ្គ

អភិធម្មបិដក សំវរកម្មន្តិកថា ...... ...... ...... ...... ...... ២៧២
អដ្ឋកថាសំវរកម្មន្តិកថា ...... ...... ...... ...... ...... ២៧៤
អភិធម្មបិដក កម្មកថា ...... ...... ...... ...... ...... ២៧៦
អដ្ឋកថាកម្មកថា ...... ...... ...... ...... ...... ២៧៨
អភិធម្មបិដក សទ្ទវិបាកោតិកថា ...... ...... ...... ...... ...... ២៨០
អដ្ឋកថាសទ្ទវិបាកោតិកថា ...... ...... ...... ...... ...... ២៨២
អភិធម្មបិដក សឡាយតនកថា ...... ...... ...... ...... ...... ២៨៣
អដ្ឋកថាសឡាយតនកថា ...... ...... ...... ...... ...... ២៨៦
អភិធម្មបិដក សត្តក្ខត្តុំបរមកថា ...... ...... ...... ...... ...... ២៨៧
អភិធម្មបិដក កោលំកោលឯកពីជិកថា ...... ...... ...... ...... ...... ២៩០
អដ្ឋកថាសត្តក្ខត្តុបរមកថា ...... ...... ...... ...... ...... ២៩១
អដ្ឋកថាកោលំកោលឯកពីជិកថា ...... ...... ...... ...... ...... ២៩៣
អភិធម្មបិដក ជីវិតាវោរោបនកថា ...... ...... ...... ...... ...... ២៩៤
អដ្ឋកថាជីវិតាវោរោបនកថា ...... ...... ...... ...... ...... ២៩៦
អភិធម្មបិដក ទុគ្គតិកថា ...... ...... ...... ...... ...... ២៩៨
អដ្ឋកថាទុគ្គតិកថា ...... ...... ...... ...... ...... ៣០១
អភិធម្មបិដក សត្តមកវិកកថា ...... ...... ...... ...... ...... ៣០២
អដ្ឋកថាសត្តមកវិកកថា ...... ...... ...... ...... ...... ៣០៤

## តេរសមវគ្គ

អភិធម្មបិដក កប្បដ្ឋកថា ...... ...... ...... ...... ...... ៣០៥
អដ្ឋកថាកប្បដ្ឋកថា ...... ...... ...... ...... ...... ៣០៧

អភិធម្មបិដក កុសលចិត្តប្បដិលាភកថា ...... ...... ...... ...... ...... ៣០៩

អដ្ឋកថាកុសលចិត្តប្បដិលាភកថា ...... ...... ...... ...... ...... ៣១០

អភិធម្មបិដក អនន្តរាបយុត្តកថា ...... ...... ...... ...... ...... ៣១១

អដ្ឋកថាអនន្តរាបយុត្តកថា ...... ...... ...... ...... ...... ៣១៣

អភិធម្មបិដក និយតនិយាមកថា ...... ...... ...... ...... ...... ៣១៧

អដ្ឋកថានិយតនិយាមកថា ...... ...... ...... ...... ...... ៣១៨

អភិធម្មបិដក នីវុតកថា ...... ...... ...... ...... ...... ៣២០

អដ្ឋកថានីវុតកថា ...... ...... ...... ...... ...... ៣២២

អភិធម្មបិដក សម្មុខីភូតកថា ...... ...... ...... ...... ...... ៣២៣

អដ្ឋកថាសម្មុខីភូតកថា ...... ...... ...... ...... ...... ៣២៥

អភិធម្មបិដក សមាបន្នអស្សាទេតិកថា ...... ...... ...... ...... ...... ៣២៦

អដ្ឋកថាសមាបន្នអស្សាទេតិកថា ...... ...... ...... ...... ...... ៣២៨

អភិធម្មបិដក អសាតរាគកថា ...... ...... ...... ...... ...... ៣២៩

អដ្ឋកថាអសាតរាគកថា ...... ...... ...... ...... ...... ៣៣១

អភិធម្មបិដក ធម្មតណ្ហាអព្យាកតាតិកថា ...... ...... ...... ...... ...... ៣៣៣

អដ្ឋកថាធម្មតណ្ហាអព្យាកតាតិកថា ...... ...... ...... ...... ...... ៣៣៦

អភិធម្មបិដក ធម្មតណ្ហានទុក្ខសមុទយោតិកថា...... ...... ...... ...... ...... ៣៣៨

អដ្ឋកថាធម្មតណ្ហានទុក្ខសមុទយោតិកថា ...... ...... ...... ...... ...... ៣៤១

## ចតុត្ថវគ្គ

អភិធម្មបិដក កុសលាកុសលប្បដិសន្ទហនកថា .. ...... ...... ...... ...... ៣៤២

អដ្ឋកថាកុសលាកុសលប្បដិសន្ទហនកថា ...... ...... ...... ...... ...... ៣៤៦

អភិធម្មបិដក សឡាយតនុប្បត្តិកថា ...... ...... ...... ...... ...... ៣៤៨
អដ្ឋកថាសឡាយតនុប្បត្តិកថា ...... ...... ...... ...... ...... ៣៥០
អភិធម្មបិដក អនន្តរប្បច្ចយកថា ...... ...... ...... ...... ...... ៣៥២
អដ្ឋកថាអនន្តរប្បច្ចយកថា ...... ...... ...... ...... ...... ៣៥៦
អភិធម្មបិដក អរិយរូបកថា ...... ...... ...... ...... ...... ៣៥៨
អដ្ឋកថាអរិយរូបកថា ...... ...... ...... ...... ...... ៣៥៩
អភិធម្មបិដក អញ្ញអនុសយោតិកថា ...... ...... ...... ...... ...... ៣៦១
អដ្ឋកថាអញ្ញអនុសយោតិកថា ...... ...... ...... ...... ...... ៣៦៤
អភិធម្មបិដក បរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា ...... ...... ...... ...... ...... ៣៦៥
អដ្ឋកថាបរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា ...... ...... ...... ...... ...... ៣៦៦
អភិធម្មបិដក បរិយាបន្នកថា ...... ...... ...... ...... ...... ៣៦៧
អដ្ឋកថាបរិយាបន្នកថា ...... ...... ...... ...... ...... ៣៧១
អភិធម្មបិដក អព្យាកតកថា ...... ...... ...... ...... ...... ៣៧៣
អដ្ឋកថាអព្យាកតកថា ...... ...... ...... ...... ...... ៣៧៦
អភិធម្មបិដក អបរិយាបន្នកថា ...... ...... ...... ...... ...... ៣៧៧
អដ្ឋកថាអបរិយាបន្នកថា ...... ...... ...... ...... ...... ៣៧៩

## បន្នរសមវគ្គ

អភិធម្មបិដក បច្ចយតាកថា ...... ...... ...... ...... ...... ៣៨០
អដ្ឋកថាបច្ចយតាកថា ...... ...... ...... ...... ...... ៣៨៤
អភិធម្មបិដក អញ្ញមញ្ញប្បច្ចយកថា ...... ...... ...... ...... ...... ៣៨៥
អដ្ឋកថាអញ្ញមញ្ញប្បច្ចយកថា ...... ...... ...... ...... ...... ៣៨៧
អភិធម្មបិដក អទ្ធាកថា ...... ...... ...... ...... ...... ៣៨៩
អដ្ឋកថាអទ្ធាកថា ...... ...... ...... ...... ...... ៣៩២
អភិធម្មបិដក ខណលយមុហុត្តកថា ...... ...... ...... ...... ...... ៣៩៣

អដ្ឋកថាខណលយមុហុត្តកថា ...... ...... ...... ...... ...... ៣៩៤
អភិធម្មបិដក អាសវកថា ...... ...... ...... ...... ...... ៣៩៥
អដ្ឋកថាអាសវកថា ...... ...... ...... ...... ...... ៣៩៦
អភិធម្មបិដក ជរាមរណកថា ...... ...... ...... ...... ...... ៣៩៧
អដ្ឋកថាជរាមរណកថា ...... ...... ...... ...... ...... ៣៩៩
អភិធម្មបិដក សញ្ញាវេទយិតកថា ...... ...... ...... ...... ...... ៤០០
អដ្ឋកថាសញ្ញាវេទយិតកថា ...... ...... ...... ...... ...... ៤០១
អភិធម្មបិដក ទុតិយសញ្ញាវេទយិតកថា ...... ...... ...... ...... ...... ៤០២
អដ្ឋកថាទុតិយសញ្ញាវេទយិតកថា ...... ...... ...... ...... ...... ៤០៣
អភិធម្មបិដក តតិយសញ្ញាវេទយិតកថា ...... ...... ...... ...... ...... ៤០៤
អដ្ឋកថាតតិយសញ្ញាវេទយិតកថា ...... ...... ...... ...... ...... ៤០៧
អភិធម្មបិដក អសញ្ញសត្តូបិកាកថា ...... ...... ...... ...... ...... ៤០៩
អដ្ឋកថាអសញ្ញសត្តូបិកាកថា ...... ...... ...... ...... ...... ៤១១
អភិធម្មបិដក កម្មូបចយកថា ...... ...... ...... ...... ...... ៤១៣
អដ្ឋកថាកម្មូបចយកថា ...... ...... ...... ...... ...... ៤១៨

## ចតុត្ថបណ្ណាសក

### សោឡសមវគ្គ

អភិធម្មបិដក និគ្គហកថា ...... ...... ...... ...... ...... ៤២១
អភិធម្មបិដក បគ្គហកថា ...... ...... ...... ...... ...... ៤២៤
អដ្ឋកថានិគ្គហកថា ( ជាដើម ) ...... ...... ...... ...... ...... ៤២៦
អភិធម្មបិដក សុខានុប្បទានកថា ...... ...... ...... ...... ...... ៤២៧
អដ្ឋកថាសុខានុប្បទានកថា ...... ...... ...... ...... ...... ៤២៩
អភិធម្មបិដក អធិគ្គយ្ហមនសិការកថា ...... ...... ...... ...... ...... ៤៣១
អដ្ឋកថាអធិគ្គយ្ហមនសិការកថា ...... ...... ...... ...... ...... ៤៣៥

អភិធម្មបិដក រូបហេតុត្តិកថា ...... ...... ...... ...... ...... ៤៣៨
អដ្ឋកថារូបហេតុត្តិកថា ...... ...... ...... ...... ...... ៤៤០
អភិធម្មបិដក រូបសហេតុកត្តិកថា ...... ...... ...... ...... ...... ៤៤១
អដ្ឋកថារូបសហេតុកត្តិកថា ...... ...... ...... ...... ...... ៤៤៣
អភិធម្មបិដក រូបកុសលាកុសលត្តិកថា ...... ...... ...... ...... ...... ៤៤៤
អដ្ឋកថារូបកុសលាកុសលត្តិកថា ...... ...... ...... ...... ...... ៤៤៧
អភិធម្មបិដក រូបវិបាកោតិកថា ...... ...... ...... ...... ...... ៤៤៨
អដ្ឋកថារូបវិបាកោតិកថា ...... ...... ...... ...... ...... ៤៥០
អភិធម្មបិដក រូបរូបាវចរារូបាវចរត្តិកថា ...... ...... ...... ...... ...... ៤៥១
អដ្ឋកថារូបរូបាវចរារូបាវចរត្តិកថា ...... ...... ...... ...... ...... ៤៥៣
អភិធម្មបិដក រូបរាគរូបធាតុបរិយាបន្នោតិអាទិកថា ... ...... ...... ...... ៤៥៤
អដ្ឋកថារូបរាគរូបធាតុបរិយាបន្នោតិអាទិកថា ...... ...... ...... ...... ...... ៤៥៨

## សត្តរសមវគ្គ

អភិធម្មបិដក អត្ថិអរហតោបុញ្ញូបចយោតិកថា...... ...... ...... ...... ...... ៤៥៩
អដ្ឋកថាអត្ថិអរហតោបុញ្ញូបចយោតិកថា ...... ...... ...... ...... ...... ៤៦២
អភិធម្មបិដក នត្ថិ អរហតោ អកាលមច្ចូតិកថា ... ...... ...... ...... ៤៦៣
អដ្ឋកថានត្ថិ អរហតោ អកាលមច្ចូតិកថា ...... ...... ...... ...... ...... ៤៦៥
អភិធម្មបិដក សព្វមិទំ កម្មតោតិកថា ...... ...... ...... ...... ...... ៤៦៧
អដ្ឋកថាសព្វមិទំ កម្មតោតិកថា ...... ...... ...... ...... ...... ៤៦៩
អភិធម្មបិដក ឥន្ទ្រិយពទ្ធកថា ...... ...... ...... ...... ...... ៤៧២
អដ្ឋកថាឥន្ទ្រិយពទ្ធកថា ...... ...... ...... ...... ...... ៤៧៥
អភិធម្មបិដក ឋបេត្វា អរិយមគ្គន្តិកថា ...... ...... ...... ...... ...... ៤៧៨
អដ្ឋកថាឋបេត្វាអរិយមគ្គន្តិកថា ...... ...... ...... ...... ...... ៤៨០
អភិធម្មបិដក ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា ........ ...... ៤៨១

អដ្ឋកថានវត្តព្វំសង្ឃោទក្ខិណំបដិគ្គណ្ហាតីតិកថា ... ...... ...... ...... ៤៨៣
អភិធម្មបិដក ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា ...... ...... ៤៨៥
អដ្ឋកថានវត្តព្វំសង្ឃោទក្ខិណំវិសោធេតីតិកថា ...... ...... ...... ...... ៤៨៧
អភិធម្មបិដក ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា ...... ...... ...... ...... ...... ៤៨៩
អដ្ឋកថានវត្តព្វំសង្ឃោភុញ្ជតីតិកថា ...... ...... ...... ...... ...... ៤៩១
អភិធម្មបិដក ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា ....... ...... ...... ៤៩២
អដ្ឋកថានវត្តព្វំសង្ឃស្សទិន្នំមហប្ផលន្តិកថា ...... ...... ...... ...... ...... ៤៩៥
អភិធម្មបិដក ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ... ...... ...... ...... ៤៩៦
អដ្ឋកថានវត្តព្វំពុទ្ធស្សទិន្នំមហប្ផលន្តិកថា ...... ...... ...... ...... ...... ៤៩៨
អភិធម្មបិដក ទក្ខិណាវិសុទ្ធិកថា ...... ...... ...... ...... ...... ៤៩៩
អដ្ឋកថាទក្ខិណាវិសុទ្ធិកថា ...... ...... ...... ...... ...... ៥០៣

## អដ្ឋារសមវគ្គ

អភិធម្មបិដក មនុស្សលោកកថា ...... ...... ...... ...... ...... ៥០៥
អដ្ឋកថាមនុស្សលោកកថា ...... ...... ...... ...... ...... ៥០៧
អភិធម្មបិដក ធម្មទេសនាកថា ...... ...... ...... ...... ...... ៥០៩
អដ្ឋកថាធម្មទេសនាកថា ...... ...... ...... ...... ...... ៥១១
អភិធម្មបិដក ករុណាកថា ...... ...... ...... ...... ...... ៥១២
អដ្ឋកថាករុណាកថា ...... ...... ...... ...... ...... ៥១៤
អភិធម្មបិដក គន្ធជាតកថា ...... ...... ...... ...... ...... ៥១៦
អដ្ឋកថាគន្ធជាតកថា ...... ...... ...... ...... ...... ៥១៧
អភិធម្មបិដក ឯកមគ្គកថា ...... ...... ...... ...... ...... ៥១៨
អដ្ឋកថាឯកមគ្គកថា ...... ...... ...... ...... ...... ៥២១
អភិធម្មបិដក ឈានសង្កន្តិកថា ...... ...... ...... ...... ...... ៥២២
អដ្ឋកថាឈានសង្កន្តិកថា ...... ...... ...... ...... ...... ៥២៦

អភិធម្មបិដក ឈានន្តរិកកថា ...... ...... ...... ...... ...... ៥២៨
អដ្ឋកថាឈានន្តរិកកថា ...... ...... ...... ...... ...... ៥៣២
អភិធម្មបិដក សមាបន្នោ សទ្ទំ សុណាតីតិកថា.... ...... ...... ...... ...... ៥៣៤
អដ្ឋកថាសមាបន្នោ សទ្ទំ សុណាតីតិកថា ...... ...... ...... ...... ...... ៥៣៦
អភិធម្មបិដក ចក្ខុនា រូបំ បស្សតីតិកថា ...... ...... ...... ...... ...... ៥៣៨
អដ្ឋកថាចក្ខុនា រូបំ បស្សតីតិកថា ...... ...... ...... ...... ...... ៥៤១

## ឯកូនវីសតិមវគ្គ

អភិធម្មបិដក កិលេសជហនកថា ...... ...... ...... ...... ...... ៥៤៣
អដ្ឋកថាកិលេសជហនកថា ...... ...... ...... ...... ...... ៥៤៦
អភិធម្មបិដក សុញ្ញតាកថា ...... ...... ...... ...... ...... ៥៤៨
អដ្ឋកថាសុញ្ញតាកថា ...... ...... ...... ...... ...... ៥៥០
អភិធម្មបិដក សាមញ្ញផលកថា ...... ...... ...... ...... ...... ៥៥២
អដ្ឋកថាសាមញ្ញផលកថា ...... ...... ...... ...... ...... ៥៥៤
អភិធម្មបិដក បត្តិកថា ...... ...... ...... ...... ...... ៥៥៥
អដ្ឋកថាបត្តិកថា ...... ...... ...... ...... ...... ៥៥៨
អភិធម្មបិដក តថតាកថា ...... ...... ...... ...... ...... ៥៥៩
អដ្ឋកថាតថតាកថា ...... ...... ...... ...... ...... ៥៦១
អភិធម្មបិដក កុសលកថា ...... ...... ...... ...... ...... ៥៦២
អដ្ឋកថាកុសលកថា ...... ...... ...... ...... ...... ៥៦៤
អភិធម្មបិដក អច្ចន្តនិយាមតាកថា ...... ...... ...... ...... ...... ៥៦៥
អដ្ឋកថាអច្ចន្តនិយាមកថា ...... ...... ...... ...... ...... ៥៦៩
អភិធម្មបិដក ឥន្ទ្រិយកថា ...... ...... ...... ...... ...... ៥៧២
អដ្ឋកថាឥន្ទ្រិយកថា ...... ...... ...... ...... ...... ៥៧៦

## វីសតិមវគ្គ

អភិធម្មបិដក អសញ្ញិច្ចកថា ...... ...... ...... ...... ...... ៥៧៨
អដ្ឋកថាអសញ្ញិច្ចកថា ...... ...... ...... ...... ...... ៥៨២
អភិធម្មបិដក ញាណកថា ...... ...... ...... ...... ...... ៥៨៤
អដ្ឋកថាញាណកថា ...... ...... ...... ...... ...... ៥៨៦
អភិធម្មបិដក និរយបាលកថា ...... ...... ...... ...... ...... ៥៨៨
អដ្ឋកថានិរយបាលកថា ...... ...... ...... ...... ...... ៥៩១
អភិធម្មបិដក តិរច្ឆានកថា ...... ...... ...... ...... ...... ៥៩៣
អដ្ឋកថាតិរច្ឆានកថា ...... ...... ...... ...... ...... ៥៩៤
អភិធម្មបិដក មគ្គកថា ...... ...... ...... ...... ...... ៥៩៦
អដ្ឋកថាមគ្គកថា ...... ...... ...... ...... ...... ៥៩៩
អភិធម្មបិដក ញាណកថា ...... ...... ...... ...... ...... ៦០១
អដ្ឋកថាញាណកថា ...... ...... ...... ...... ...... ៦០៤

## ឯកវីសតិមវគ្គ

អភិធម្មបិដក សាសនកថា ...... ...... ...... ...... ...... ៦០៥
អដ្ឋកថាសាសនកថា ...... ...... ...... ...... ...... ៦០៧
អភិធម្មបិដក អវិវិត្តកថា ...... ...... ...... ...... ...... ៦០៨
អដ្ឋកថាអវិវិត្តកថា ...... ...... ...... ...... ...... ៦០៩
អភិធម្មបិដក សញ្ញោជនកថា ...... ...... ...... ...... ...... ៦១០
អដ្ឋកថាសញ្ញោជនកថា ...... ...... ...... ...... ...... ៦១២
អភិធម្មបិដក ឥទ្ធិកថា ...... ...... ...... ...... ...... ៦១៣
អដ្ឋកថាឥទ្ធិកថា ...... ...... ...... ...... ...... ៦១៦

អភិធម្មបិដក ពុទ្ធកថា ...... ...... ...... ...... ...... ៦១៨

អដ្ឋកថាពុទ្ធកថា ...... ...... ...... ...... ...... ៦១៩

អភិធម្មបិដក សព្វទិសាកថា ...... ...... ...... ...... ...... ៦២០

អដ្ឋកថាសព្វទិសាកថា ...... ...... ...... ...... ...... ៦២១

អភិធម្មបិដក ធម្មកថា ...... ...... ...... ...... ...... ៦២២

អដ្ឋកថាធម្មកថា ...... ...... ...... ...... ...... ៦២៤

អភិធម្មបិដក កម្មកថា ...... ...... ...... ...... ...... ៦២៦

អដ្ឋកថាកម្មកថា ...... ...... ...... ...... ...... ៦២៩


## ពាវីសតិមវគ្គ


អភិធម្មបិដក បរិនិព្វានកថា ...... ...... ...... ...... ...... ៦៣០

អដ្ឋកថាបរិនិព្វានកថា ...... ...... ...... ...... ...... ៦៣១

អភិធម្មបិដក កុសលចិត្តកថា ...... ...... ...... ...... ...... ៦៣២

អដ្ឋកថាកុសលចិត្តកថា ...... ...... ...... ...... ...... ៦៣៤

អភិធម្មបិដក អានេញ្ជកថា ...... ...... ...... ...... ...... ៦៣៥

អដ្ឋកថាអានេញ្ជកថា ...... ...... ...... ...... ...... ៦៣៧

អភិធម្មបិដក ធម្មាភិសមយកថា ...... ...... ...... ...... ...... ៦៣៨

អដ្ឋកថាធម្មាភិសមយកថា ...... ...... ...... ...... ...... ៦៤០

អភិធម្មបិដក តិស្សោបិកថា ...... ...... ...... ...... ...... ៦៤១

អដ្ឋកថាតិស្សោបិកថា ...... ...... ...... ...... ...... ៦៤២

អភិធម្មបិដក អព្យាកតកថា ...... ...... ...... ...... ...... ៦៤៣

អដ្ឋកថាអព្យាកតកថា ...... ...... ...... ...... ...... ៦៤៥

អភិធម្មបិដក អាសេវនបច្ចយតាកថា ...... ...... ...... ...... ...... ៦៤៦

អដ្ឋកថាអាសេវនប្បច្ចយតាកថា ...... ...... ...... ...... ...... ៦៤៩
អភិធម្មបិដក ខណិកកថា ...... ...... ...... ...... ...... ៦៥០
អដ្ឋកថាខណិកកថា ...... ...... ...... ...... ...... ៦៥៣

## តេវីសតិមវគ្គ

អភិធម្មបិដក ឯកាធិប្បាយកថា ...... ...... ...... ...... ...... ៦៥៥
អដ្ឋកថាឯកាធិប្បាយកថា ...... ...... ...... ...... ...... ៦៥៦
អភិធម្មបិដក អរហន្តវណ្ណកថា ...... ...... ...... ...... ...... ៦៥៧
អដ្ឋកថាអរហន្តវណ្ណកថា ...... ...... ...... ...... ...... ៦៥៨
អភិធម្មបិដក ឥស្សរិយកាមការិកាកថា ...... ...... ...... ...... ...... ៦៥៩
អដ្ឋកថាឥស្សរិយកាមការិកាកថា ...... ...... ...... ...... ...... ៦៦២
អភិធម្មបិដក រាគប្បដិរូបកាទិកថា ...... ...... ...... ...... ...... ៦៦៤
អដ្ឋកថារាគប្បដិរូបកាទិកថា ...... ...... ...... ...... ...... ៦៦៥
អភិធម្មបិដក អបរិនិប្ផន្នកថា ...... ...... ...... ...... ...... ៦៦៧
អដ្ឋកថាអបរិនិប្ផន្នកថា ...... ...... ...... ...... ...... ៦៧០